1

សំណើ 1

ច្បាប់នេះស្នើឡើងដោយសេចក្តីព្រាងច្បាប់ព្រឹទ្ធសភាលេខ 417 នៃសម័យប្រជុំសាមញ្ញ ឆ្នាំ 2025–2026 (ជំពូកទី 16 លក្ខន្តិកៈឆ្នាំ 2026) ត្រូវបានដាក់ជូនប្រជាពលរដ្ឋអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា XVI នៃរដ្ឋធម្មនុញ្ញនៃរដ្ឋ California។

ច្បាប់ដែលបានស្នើឡើងនេះ បន្ថែមមាត្រាថ្មីទៅក្នុងក្រមសុខាភិបាល និងសុវត្ថិភាព និង ក្រមយោធា និងអតីតយុទ្ធជន។ ដូច្នេះ បទប្បញ្ញត្តិថ្មីដែលត្រូវបានស្នើឱ្យបន្ថែមត្រូវបានបោះពុម្ពនៅក្នុងទម្រង់ជាប្រភេទ*អក្សរទ្រេត* ដើម្បីបញ្ជាក់ថាច្បាប់ទាំងនោះគឺថ្មី។

ច្បាប់ដែលបានស្នើឡើង

មាត្រាទី 2. ផ្នែកទី 16.1 (ចាប់ផ្តើមជាមួយមាត្រាទី 54050) ត្រូវបានបន្ថែមទៅភាគទី 31 នៃក្រមសុខាភិបាល និង សុវត្ថិភាព មានខ្លឹមសារដូចខាងក្រោម៖

ផ្នែកទី 16.1. ច្បាប់ស្តីពីមូលបត្របំណុលសម្រាប់អតីតយុទ្ធជន និងលំនៅឋានដែលមានតម្លៃសមរម្យ ឆ្នាំ 2026

ជំពូកទី 1. បទប្បញ្ញត្តិទូទៅ

54050. មាត្រានេះ រួមជាមួយមាត្រា 5ab (ចាប់ផ្តើមពីមាត្រា 998.750) នៃជំពូកទី 6 ផ្នែកទី 4 នៃក្រមយោធា និងអតីតយុទ្ធជន នឹងអាចហៅ និងមានឈ្មោះថា ច្បាប់ស្តីពីមូលបត្របំណុលសម្រាប់អតីតយុទ្ធជន និងលំនៅឋានដែលមានតម្លៃសមរម្យ នៃឆ្នាំ 2026។

54051. ផ្នែកនេះនឹងចាប់ផ្តើមមានប្រសិទ្ធភាព លុះត្រាតែត្រូវបានទទួលយកដោយអ្នកបោះឆ្នោតនៅក្នុងការបោះឆ្នោតទូទៅទូទាំងរដ្ឋ នៅថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2026។

54052. សម្រាប់គោលបំណងនៃផ្នែកនេះ ពាក្យថា "មូលនិធិ" សំដៅលើមូលនិធិទំនុកចិត្តនៃច្បាប់ស្តីពីមូលបត្របំណុលសម្រាប់លំនៅឋានដែលមានតម្លៃសមរម្យនៃឆ្នាំ 2026 ដែលត្រូវបានបង្កើតអនុលោមតាមមាត្រា 54054។

ជំពូកទី 2. ច្បាប់ស្តីពីមូលបត្របំណុលសម្រាប់លំនៅឋានដែលមានតម្លៃសមរម្យមូលនិធីទំនុកចិត្តនៃឆ្នាំ 2026 និង កម្មវិធី

54054. (a) មូលនិធិទំនុកចិត្តនៃច្បាប់ស្តីពីមូលបត្របំណុលសម្រាប់លំនៅឋានដែលមានតម្លៃសមរម្យនៃឆ្នាំ 2026 ត្រូវបានបង្កើតឡើងនៅទីនេះ នៅក្នុងរតនាគាររដ្ឋ។ វាគឺជាបំណងរបស់ស្ថាប័ននីតិបញ្ញត្តិដែលថា ប្រាក់ចំណូលដែលទទួលបានពីការចេញ និងការលក់មូលបត្របំណុលអនុលោមតាមផ្នែកនេះ ដោយមិនរាប់បញ្ចូលមូលបត្របំណុលសម្រាប់ការសងបំណុលចាស់ឡើងវិញ ដែលចេញអនុលោមតាមមាត្រា 54076 ដែលត្រូវដាក់តម្កល់ចូលទៅក្នុងមូលនិធិ ហើយត្រូវបានប្រើប្រាស់ដើម្បីផ្តល់ហិរញ្ញប្បទានដល់កម្មវិធីជួលលំនៅឋាន និង កម្មវិធីភាពជាម្ចាស់ផ្ទះដែលមានតម្លៃសមរម្យ ដូចបានរៀបរាប់នៅក្នុងជំពូកនេះ។

(b) ប្រាក់ចំណូលដែលទទួលបានពីការចេញ និង ការលក់មូលបត្របំណុលអនុលោមតាមផ្នែកនេះ សម្រាប់គោលបំណងដែលបានបញ្ជាក់នៅក្នុងជំពូកនេះ ត្រូវបែងចែកតាមរបៀបដូចខាងក្រោម៖

(1) ទឹកប្រាក់ចំនួន ប្រាំពាន់មួយរយលានដុល្លារ ($5,100,000,000) នឹងត្រូវដាក់តម្កល់ទៅក្នុងមូលនិធិប្រាក់កម្ចីសម្រាប់ការជួសជុលកែលម្អលំនៅឋាន ដែលបានបង្កើតឡើងអនុលោមតាមមាត្រាទី 50661 ដើម្បីប្រើប្រាស់សម្រាប់កម្មវិធីលំនៅឋានសម្រាប់គ្រួសារច្រើន ដែលត្រូវបានអនុញ្ញាតដោយជំពូកទី 6.7 (ចាប់ផ្តើមពីមាត្រាទី 50675) នៃផ្នែកទី 2។ យ៉ាងហោចណាស់ 10 ភាគរយនៃឯកតាលំនៅឋានដែលទទួលបានជំនួយនៅក្នុងគម្រោងអភិវឌ្ឍន៍នីមួយៗដែលកំពុងទទួលបានមូលនិធិនេះ ត្រូវតែមានតម្លៃសមរម្យសម្រាប់គ្រួសារដែលមានចំណូលទាបបំផុត។

(2) ទឹកប្រាក់ចំនួន មួយពាន់មួយរយហាសិបលានដុល្លារ ($1,150,000,000) ត្រូវដាក់តម្កល់ចូលទៅក្នុងមូលនិធិប្រាក់កម្ចីសម្រាប់ការជួសជុលកែលម្អលំនៅឋាន ដែលបានបង្កើតឡើងអនុលោមតាមមាត្រា 50661 ដើម្បីប្រើប្រាស់សម្រាប់គាំទ្រលំនៅឋានដូចដែលមានការពណ៌នាក្នុងមាត្រាទី 50675.14 អនុលោមតាម កម្មវិធីលំនៅឋានសម្រាប់គ្រួសារច្រើន ដែលត្រូវបានអនុញ្ញាតដោយជំពូកទី 6.7 (ចាប់ផ្តើមពីមាត្រាទី 50675) នៃផ្នែកទី 2។ អង្គភាពដែលទទួលបន្ទុកគ្រប់គ្រងត្រូវផ្តល់មូលនិធិបម្រុងសម្រាប់ឧបត្ថម្ភថ្លៃប្រតិបត្តិការដែលបានកំណត់ទុកជាមុន សម្រាប់ឯកតាលំនៅឋានដែលមានការគាំទ្រ នៅក្នុងគម្រោងដែលទទួលបានមូលនិធិទាំងនេះ។

(A) (i) រហូតដល់ 15 ភាគរយនៃមូលនិធិនេះ អាចត្រូវបានផ្តល់ជាជំនួយឥតសំណងដល់អង្គភាពដែលមានសិទ្ធិទទួល ដូចដែលបានកំណត់ក្នុងមាត្រាទី 50675.1.3 ដើម្បីទិញទ្រព្យសកម្មមូលធន សម្រាប់ការទិញ ការបំប្លែង ឬ ការជួសជុលកែលម្អលំនៅឋានអំឡុងពេលបណ្តោះអាសន្ន ឱ្យទៅជា លំនៅឋានអចិន្ត្រៃយ៍ រួមទាំងគាំទ្រគម្រោងដែលមានទីតាំងផ្សេងៗពីគ្នា សម្រាប់អ្នកដែលគ្មានផ្ទះសម្បែង អ្នកដែលគ្មានផ្ទះសម្បែងរស់នៅជាប្រចាំ ឬអ្នកដែលប្រឈមនឹងហានិភ័យក្លាយជាមនុស្សគ្មានផ្ទះសម្បែង ដូចដែលបានកំណត់ក្នុងផ្នែក 578.3 នៃចំណងជើងទី 24 នៃក្រមបទបញ្ញត្តិសហព័ន្ធ លក្ខខណ្ឌដើម្បីទិញ និង ការកម្រិតសិទ្ធិសម្រាប់ធានាថាឯកតាលំនៅឋាននៅតែមានតម្លៃសមរម្យ ចំណាយលើការផ្លាស់ទីលំនៅរបស់បុគ្គលដែលត្រូវផ្លាស់ទីចេញដោយសារការជួសជុលកែលម្អឯកតាដែលមានស្រាប់ និង ផ្តល់មូលនិធិបម្រុងសម្រាប់ឧបត្ថម្ភថ្លៃប្រតិបត្តិការរបស់ឯកតាដែលបានទិញ បំប្លែង ឬកែប្រែដោយប្រើមូលនិធិដែលផ្តល់តាមមាត្រានេះ។

(ii) កម្មវិធី ឬគម្រោងណាមួយដែលប្រើប្រាស់មូលនិធិដែលទទួលបានសម្រាប់គោលបំណងណាមួយដែលបានពណ៌នានៅក្នុងកថាខណ្ឌរងនេះ ត្រូវគោរពតាមបទបញ្ញត្តិនៃមាត្រាទី 50675.1.5 នៃក្រមសុខាភិបាល និងសុវត្ថិភាព និងផ្នែករង (i) នៃមាត្រាទី 50675.1.3។

(iii) ប្រសិនបើមានវិវាទវាងលក្ខខណ្ឌតម្រូវផ្សេងទៀតនៃកម្មវិធីលំនៅឋានសម្រាប់គ្រួសារច្រើន (ជំពូកទី 6.7 (ចាប់ផ្តើមពីមាត្រាទី 50675) នៃផ្នែកទី 2) និង កថាខណ្ឌនេះ ត្រូវយកកថាខណ្ឌនេះជាគោល ក្នុងការដោះស្រាយវិវាទនោះ ដូចដែលអាចត្រូវបានកំណត់នៅក្នុងគោលការណ៍ណែនាំដែលមានការអនុញ្ញាតអនុលោមតាមមាត្រាទី 54077។

(B) (i) ទឹកប្រាក់ចំនួន មួយរយហាសិបលានដុល្លារ ($150,000,000) នៃចំនួនទឹកប្រាក់នេះ ត្រូវប្រើប្រាស់ទៅលើលំនៅឋានសម្រាប់យុវជន។

(ii) សម្រាប់គោលបំណងនៃផ្នែករងនេះ "លំនៅឋានសម្រាប់យុវជន" មានន័យថា លំនៅឋានសម្រាប់យុវជនដែលកំពុងស្ថិតក្នុង ឬធ្លាប់ស្ថិតក្នុងប្រព័ន្ធថែទាំកុមារដោយគ្រួសារចិញ្ចឹម អនីតិជន ឬយុវជនដែលគ្មានផ្ទះសម្បែង ឬយុវជនដែលប្រឈមនឹងការគ្មានផ្ទះសម្បែងរួមទាំងប៉ុន្តែមិនកំណត់ លំនៅឋានដែលជួយពួកគេអភិវឌ្ឍជំនាញ និងធនធានដែលពួកគេត្រូវការដើម្បីផ្លាស់ប្តូរទៅកាន់ជីវិតពេញវ័យដែលអាចរស់នៅដោយឯករាជ្យ និងពឹងផ្អែកលើខ្លួនឯងបានដោយជោគជ័យ។

(iii) មូលនិធិដែលផ្តល់ជូនក្រោមកថាខណ្ឌរងនេះ ត្រូវប្រើប្រាស់សម្រាប់តែចំណាយមូលធនក្នុងការអភិវឌ្ឍ ការទិញ ការស្តារឡើងវិញ ឬការថែរក្សាលំនៅឋានសម្រាប់យុវជនប៉ុណ្ណោះ ហើយមិនត្រូវប្រើប្រាស់សម្រាប់ផ្តល់មូលនិធិដល់ប្រតិបត្តិការ ឬការផ្តល់សេវាឡើយ។

(iv) មូលនិធិណាមួយដែលមិនត្រូវបានចងកាតព្វកិច្ចសម្រាប់គោលបំណងក្នុងកថាខណ្ឌរងនេះ ក្នុងរយៈពេលបីឆ្នាំចាប់ពីពេលដែលមូលនិធិនោះមានសម្រាប់ប្រើប្រាស់ ត្រូវប្រគល់ត្រឡប់ទៅប្រើប្រាស់ជាទូទៅក្នុងកម្មវិធីលំនៅឋានសម្រាប់គ្រួសារច្រើន ដែលត្រូវបានអនុញ្ញាតដោយជំពូកទី 6.7 (ចាប់ផ្តើមពីមាត្រាទី 50675) នៃផ្នែកទី 2។

(3) ទឹកប្រាក់ចំនួន ប្រាំពីររយហាសិបលានដុល្លារ ($750,000,000) ដែលត្រូវបែងចែកថវិកាដោយស្ថាប័ននីតិបញ្ញត្តិទៅឱ្យកម្មវិធីដែលទូទៅហៅថា សំណុំកម្មវិធីវិនិយោគឡើងវិញ ដែលត្រូវបានបង្កើតឡើងអនុលោមតាមជំពូកទី 5.5 (ចាប់ផ្តើមពីមាត្រាទី 50606) នៃផ្នែកទី 2។ មូលនិធិណាមួយដែលមិនត្រូវបានចងកាតព្វកិច្ចសម្រាប់គោលបំណងនៃ កថាខណ្ឌនេះ ត្រឹមថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2036 ត្រូវប្រគល់ត្រឡប់សម្រាប់ការប្រើប្រាស់ទូទៅក្នុងកម្មវិធីលំនៅឋានសម្រាប់គ្រួសារច្រើន ដែលត្រូវបានអនុញ្ញាតដោយជំពូកទី 6.7 (ចាប់ផ្តើមពីមាត្រាទី 50675) នៃផ្នែកទី 2។

(4) ទឹកប្រាក់ចំនួន ពីររយលានដុល្លារ ($200,000,000) ដែលត្រូវបែងចែកដោយស្ថាប័ននីតិប្បញ្ញត្តិ ទៅឱ្យកម្មវិធីមួយសម្រាប់ផ្តល់មូលនិធិដល់ការទិញយក និងការកែលម្អយូនីតលំនៅឋានដែលមិនមានការរឹតត្បិត ហើយដាក់លក្ខខណ្ឌកំណត់ឱ្យយូនីតលំនៅឋានទាំងនោះរក្សាតម្លៃសមរម្យក្នុងរយៈពេលវែង ដោយការពារកុំឱ្យអ្នករស់នៅបច្ចុប្បន្នត្រូវបានបណ្តេញចេញពីលំនៅឋាន។ មូលនិធិណាមួយដែលមិនត្រូវបានបែងចែកដោយអង្គភាពគ្រប់គ្រងក្នុងរយៈពេលបីឆ្នាំដំបូង នឹងត្រូវដាក់ឱ្យមានសម្រាប់ប្រើប្រាស់ដោយអង្គភាពគ្រប់គ្រងទៅលើកម្មវិធីលំនៅឋានសម្រាប់គ្រួសារច្រើន (ជំពូកទី 6.7 (ចាប់ផ្តើមពីមាត្រាទី 50675) នៃផ្នែកទី 2)។

(5) ទឹកប្រាក់ចំនួន ប្រាំមួយរយលានដុល្លារ ($600,000,000) នឹងត្រូវដាក់តម្កល់ទៅក្នុង មូលនិធិលំនៅឋានសាងសង់ខ្លួនឯង ដែលបានបង្កើតឡើងអនុលោមតាមមាត្រាទី 50697.1។ ទឹកប្រាក់នៅក្នុងមូលនិធិនេះត្រូវមានប្រើប្រាស់បានសម្រាប់កម្មវិធី CalHome ដែលត្រូវបានអនុញ្ញាតដោយជំពូកទី 6 (ចាប់ផ្តើមពីមាត្រាទី 50650) នៃផ្នែកទី 2 ដើម្បីផ្តល់ប្រាក់កម្ចីដោយផ្ទាល់ដែលអាចលើកលែងការសង ដើម្បីជួយដល់គម្រោងអភិវឌ្ឍន៍ដែលពាក់ព័ន្ធនឹងឯកតាកម្មសិទ្ធិអគារលំនៅឋានដែលមានច្រើន រួមទាំងការបែងចែកដីសម្រាប់លំនៅឋានគ្រួសារនីមួយៗ សម្រាប់កម្មវិធីជំនួយប្រាក់កម្ចីទិញផ្ទះប្រភេទសាងសង់ខ្លួនឯង និងសម្រាប់ផ្ទះសាងសង់ជាស្រេច។ មូលនិធិទាំងនេះក៏អាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងណាមួយដែលកម្មវិធីនេះអនុញ្ញាតផងដែរ។ មូលនិធិណាមួយដែលមិនត្រូវបានចងកាតព្វកិច្ចសម្រាប់គោលបំណងនៃ កថាខណ្ឌនេះ ត្រឹមថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2036 ត្រូវប្រគល់ត្រឡប់សម្រាប់ការប្រើប្រាស់ទូទៅក្នុងកម្មវិធីលំនៅឋានសម្រាប់គ្រួសារច្រើន ដែលត្រូវបានអនុញ្ញាតដោយជំពូកទី 6.7 (ចាប់ផ្តើមពីមាត្រាទី 50675) នៃផ្នែកទី 2។

(6) ទឹកប្រាក់ចំនួន ប្រាំរយលានដុល្លារ ($500,000,000) នឹងត្រូវដាក់តម្កល់ទៅក្នុង មូលនិធិជំនួយសម្រាប់ការទិញផ្ទះ ដែលបានបង្កើតឡើងអនុលោមតាមមាត្រាទី 51342។ ដោយមិនគិតពីមាត្រាទី 13340 នៃក្រមរដ្ឋាភិបាល និង មាត្រាទី 50697.1 មូលនិធិទាំងនេះត្រូវបានអនុម័តឱ្យបែងចែកជាបន្តបន្ទាប់ដល់ ទីភ្នាក់ងារហិរញ្ញវត្ថុលំនៅឋានរដ្ឋ California ដោយមិនគិតពីឆ្នាំសារពើពន្ធ សម្រាប់គោលបំណងនៃកម្មវិធីជំនួយសម្រាប់ការទិញផ្ទះ ដែលបានបង្កើតឡើងអនុលោមតាមជំពូកទី 6.8 (ចាប់ផ្តើមពីមាត្រាទី 51341) នៃផ្នែកទី 3។

(7) ទឹកប្រាក់ចំនួន បួនរយហាសិបលានដុល្លារ ($450,000,000) ត្រូវដាក់តម្កល់ទៅក្នុង មូលនិធិជំនួយលំនៅឋាន Joe Serna, Jr. សម្រាប់កម្មករផ្នែកកសិកម្ម មូលនិធិជំនួយលំនៅដ្ឋានឥតសំណងសម្រាប់កម្មករផ្នែកកសិកម្មដែលបានបង្កើតឡើងអនុលោមតាមមាត្រាទី 50517.5 ដើម្បីផ្តល់ជំនួយឥតសំណង ឬប្រាក់កម្ចី ឬទាំងពីរ សម្រាប់ការសាងសង់ ឬកែលម្អលំនៅឋានសម្រាប់កម្មករផ្នែកកសិកម្ម និងគ្រួសាររបស់ពួកគេ ឬសម្រាប់ការទិញផ្ទះសាងសង់ជាស្រេច ជាផ្នែកមួយនៃកម្មវិធីដើម្បីដោះស្រាយ និងការសម្រួលផលប៉ះពាល់នៃការផ្លាស់ទីលំនៅរបស់គ្រួសារកម្មករផ្នែកកសិកម្មជាច្រើន ដែលកំពុងកើតមាន ឬអាចនឹងកើតមាននាពេលអនាគតពីជំរកម្មករដែលមានស្រាប់ ឧទ្យានសម្រាប់លំនៅឋានចល័ត ឬលំនៅឋានផ្សេងទៀត។ មូលនិធិទាំងនេះក៏អាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងណាមួយដែលកម្មវិធីនេះអនុញ្ញាតផងដែរ។ មូលនិធិទាំងនេះក៏អាចនឹងត្រូវបានប្រើប្រាស់សម្រាប់ផ្តល់ជំនួយបច្ចេកទេសអនុលោមតាមមាត្រាទី 54007 ផងដែរ។ មូលនិធិណាមួយដែលមិនត្រូវបានចងកាតព្វកិច្ចសម្រាប់គោលបំណងនៃ កថាខណ្ឌនេះ ត្រឹមថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2036 ត្រូវប្រគល់ត្រឡប់សម្រាប់ការប្រើប្រាស់ទូទៅក្នុងកម្មវិធីលំនៅឋានសម្រាប់គ្រួសារច្រើន ដែលត្រូវបានអនុញ្ញាតដោយជំពូកទី 6.7 (ចាប់ផ្តើមពីមាត្រាទី 50675) នៃផ្នែកទី 2។

(8) ទឹកប្រាក់ចំនួន ពីររយលានដុល្លារ ($200,000,000) ត្រូវបែងចែកដោយស្ថាប័ននីតិបញ្ញត្តិ ទៅឱ្យកម្មវិធីជំនួយឥតសំណងលំនៅឋានសម្រាប់កុលសម្ព័ន្ធ ដែលបានបង្កើតឡើងអនុលោមតាមជំពូកទី 6.4 (ចាប់ផ្តើមពីមាត្រាទី 50651) ដើម្បីផ្តល់ហិរញ្ញប្បទានដល់លំនៅឋាន និងសកម្មភាពពាក់ព័ន្ធនឹងលំនៅឋាន ដែលនឹងជួយឱ្យកុលសម្ព័ន្ធនានាកសាង និង ស្តារសហគមន៍របស់ពួកគេឡើងវិញផងដែរ។ មូលនិធិណាមួយដែលមិនត្រូវបានចងកាតព្វកិច្ចសម្រាប់គោលបំណងនៃ កថាខណ្ឌនេះ ត្រឹមថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2036 ត្រូវប្រគល់ត្រឡប់សម្រាប់ការប្រើប្រាស់ទូទៅក្នុងកម្មវិធីលំនៅឋានសម្រាប់គ្រួសារច្រើន ដែលត្រូវបានអនុញ្ញាតដោយជំពូកទី 6.7 (ចាប់ផ្តើមពីមាត្រាទី 50675) នៃផ្នែកទី 2។

(9) ទឹកប្រាក់ចំនួន ប្រាំរយលានដុល្លារ ($500,000,000) សម្រាប់ កម្មវិធីជំនួយឥតសំណងហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍបំពេញចន្លោះ ឆ្នាំ 2019 ដែលបានបង្កើតឡើងអនុលោមតាមមាត្រាទី 53559 នៃក្រមសុខាភិបាល និងសុវត្ថិភាព សម្រាប់ផ្តល់ជំនួយឥតសំណងលើកទឹកចិត្តសម្រាប់ការអភិវឌ្ឍបំពេញចន្លោះផ្នែកសំណង់ថ្មី និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រលំនៅឋានតម្លៃសមរម្យដែលមានដង់ស៊ីតេខ្ពស់ និងលំនៅឋានដែលមានចំណូលចម្រុះ នៅទីតាំងដែលបានកំណត់ជាការអភិវឌ្ឍបំពេញចន្លោះ។ មូលនិធិណាមួយដែលមិនត្រូវបានចងកាតព្វកិច្ចសម្រាប់គោលបំណងនៃ កថាខណ្ឌនេះ ត្រឹមថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2036 ត្រូវប្រគល់ត្រឡប់សម្រាប់ការប្រើប្រាស់ទូទៅក្នុងកម្មវិធីលំនៅឋានសម្រាប់គ្រួសារច្រើន ដែលត្រូវបានអនុញ្ញាតដោយជំពូកទី 6.7 (ចាប់ផ្តើមពីមាត្រាទី 50675) នៃផ្នែកទី 2។

(10) ទឹកប្រាក់ចំនួន បីរយហាសិបលានដុល្លារ ($350,000,000) ត្រូវបែងចែកដោយស្ថាប័ននីតិបញ្ញត្តិ សម្រាប់គម្រោងលំនៅឋានតម្លៃសមរម្យថ្មីសម្រាប់និស្សិត។ មូលនិធិនេះគួរត្រូវបែងចែកស្មើៗគ្នារវាង សាកលវិទ្យាល័យនៃ California និង សាកលវិទ្យាល័យរដ្ឋ California។ គម្រោងមូលនិធិលំនៅឋានសម្រាប់និស្សិតគួរត្រូវបានបំពេញតាមលក្ខខណ្ឌដែលបានកំណត់ក្នុងផ្នែករង (f) នៃមាត្រាទី 17201 នៃក្រមអប់រំ។ សម្រាប់គម្រោងទាំងនេះ សាកលវិទ្យាល័យនៃ California និង សាកលវិទ្យាល័យរដ្ឋ California ត្រូវបានបំពេញតាមគណនេយ្យភាព និងការរាយការណ៍ដែលបានកំណត់ក្នុងផ្នែករង (i) និង (o) នៃមាត្រាទី 17201 របស់ក្រមអប់រំ។

(11) ទឹកប្រាក់ចំនួន ពីររយលានដុល្លារ ($200,000,000) ត្រូវដាក់តម្កល់ទៅក្នុងមូលនិធិនវានុវត្តន៍លំនៅឋានតម្លៃសមរម្យ ដែលបានបង្កើតឡើងអនុលោមតាមកថាខណ្ឌរង (F) នៃកថាខណ្ឌ (1) នៃផ្នែករង (a) នៃមាត្រាទី 53545។ ថវិកានៅក្នុងមូលនិធិនេះត្រូវមានសម្រាប់ប្រើប្រាស់បន្ទាប់ពីមានការបែងចែកថវិកាដោយស្ថាប័ននីតិបញ្ញត្តិ អនុលោមតាមកម្មវិធីជំនួយឥតសំណងផ្លូវផ្តងនឹងលំនៅឋានទំនុកចិត្តមូលដ្ឋានដែលបានបង្កើតឡើងអនុលោមតាមមាត្រាទី 50842.2 ដើម្បីផ្តល់ជំនួយឥតសំណងតាមរយៈការប្រកួតប្រជែង រឺ ប្រាក់កម្ចីដល់មូលនិធិទំនុកចិត្តលំនៅឋានមូលដ្ឋាន ដែលអភិវឌ្ឍ កាន់កាប់ ឱ្យខ្ចី ឬវិនិយោគក្នុងលំនៅឋានតម្លៃសមរម្យ ហើយត្រូវប្រើប្រាស់សម្រាប់បង្កើតកម្មវិធីសាកល្បង ដើម្បីបង្ហាញពីវិធីសាស្ត្រច្នៃប្រឌិតដែលអាចកាត់បន្ថយការចំណាយក្នុងការបង្កើត ឬរក្សាទុកលំនៅឋានតម្លៃសមរម្យ។ មូលនិធិទំនុកចិត្តលំនៅឋានមូលដ្ឋាន ត្រូវទទួលបានជាបន្តបន្ទាប់ពីការរួមចំណែករបស់វិស័យឯកជន ឬពីប្រភពរដ្ឋាភិបាលដែលមិនមានការរឹតត្បិតផ្សេងៗលើការប្រើប្រាស់សម្រាប់កម្មវិធីលំនៅឋាន។ មូលនិធិទាំងនេះក៏អាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងណាមួយដែលកម្មវិធីនេះអនុញ្ញាតផងដែរ។ មូលនិធិណាមួយដែលមិនត្រូវបានចងកាតព្វកិច្ចសម្រាប់គោលបំណងនៃ កថាខណ្ឌនេះ ក្នុងរយៈពេលបីឆ្នាំចាប់ពីពេលដែលមានសម្រាប់ប្រើប្រាស់ ត្រូវប្រគល់ត្រឡប់ទៅការប្រើប្រាស់ទូទៅក្នុង កម្មវិធីលំនៅឋានសម្រាប់គ្រួសារច្រើន ដែលត្រូវបានអនុញ្ញាតដោយជំពូកទី 6.7 (ចាប់ផ្តើមពីមាត្រាទី 50675) នៃផ្នែកទី 2 លើកលែងតែក្រសួងលំនៅឋាន និងការអភិវឌ្ឍសហគមន៍ កំណត់ថាមូលនិធិនោះគួរត្រូវបានប្រគល់ត្រឡប់ឱ្យបានឆាប់ ដោយសារតម្រូវការថយចុះ។

(12) ដោយមិនគិតពីកថាខណ្ឌទី (1) ដល់ទី (11) រួមបញ្ចូលទាំងទីភ្នាក់ងារអាជីវកម្ម សេវាអ្នកប្រើប្រាស់ និងលំនៅឋាន ឬអ្នកបន្តវេនរបស់ខ្លួន និងក្រសួងដែលគ្រប់គ្រងកម្មវិធីរបស់ខ្លួនអាចរៀបចំឱ្យស្របគ្នា ឬសម្រួលកម្មវិធីដែលទទួលបានមូលនិធិ បន្ទាប់ពីមានការបែងចែកថវិកាដោយស្ថាប័ននីតិបញ្ញត្តិ អនុលោមតាមផ្នែករងនេះ ដើម្បីបង្កើនប្រសិទ្ធភាព និងពន្លឿនការបញ្ចេញមូលនិធិ ដោយមានលក្ខខណ្ឌថា ការចំណាយនៅតែស្របតាមគោលបំណង និងការប្រើប្រាស់ដែលមានសិទ្ធិទទួលបាន ដែលត្រូវបានអនុម័តដោយអ្នកបោះឆ្នោត និងស្ថាប័ននីតិបញ្ញត្តិ។

54056. (a) ស្ថាប័ននីតិបញ្ញត្តិអាចធ្វើវិសោធនកម្មជាបន្តបន្ទាប់ទៅលើច្បាប់ណាមួយដែលពាក់ព័ន្ធនឹងកម្មវិធីមូលនិធិដែលទទួលបាន ឬធ្លាប់ទទួលបានអនុលោមតាមជំពូកនេះ ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃ

1

កម្មវិធីទាំងនោះ ឬដើម្បីលើកកម្ពស់ការសម្រេចបាននូវគោលដៅរបស់កម្មវិធីទាំងនោះ។

(b) ស្ថាប័ននីតិបញ្ញត្តិអាចធ្វើវិសោធនកម្មជំពូកនេះ ដើម្បីបែងចែកឡើងវិញនូវប្រាក់ដែលទទួលបានពីមូលបត្របំណុលដែលបានចេញ និងលក់អនុលោមតាមផ្នែកនេះ ក្នុងចំណោមកម្មវិធីមូលនិធិនានាដែលត្រូវទទួលបានអនុលោមតាមជំពូកនេះ តាមការចាំបាច់ ដើម្បីជំរុញនូវការអភិវឌ្ឍលំនៅឋានដែលមានតម្លៃសមរម្យប្រកបដោយប្រសិទ្ធភាពនៅក្នុងរដ្ឋនេះ។

(c) ក្រសួងលំនៅឋាន និងការអភិវឌ្ឍសហគមន៍ ឬ អង្គភាពគ្រប់គ្រងអាចបញ្ចេញមូលនិធិដែលបានផ្តល់សម្រាប់គម្រោងអភិវឌ្ឍន៍លំនៅឋានអនុលោមតាមជំពូកនេះក្នុងអំឡុងពេលសាងសង់។

ជំពូកទី 3. បទបញ្ញត្តិសារពើពន្ធ

54060. មូលបត្របំណុលដែលមានទឹកប្រាក់សរុបចំនួន ដប់ពាន់លានដុល្លារ ($10,000,000,000) ដោយមិនរាប់បញ្ចូលមូលបត្រណុលសម្រាប់សងបំណុលដែលបានចេញអនុលោមតាមមាត្រាទី 54076 ឬចំនួនដែលចាំបាច់តាមការកំណត់របស់គណៈកម្មាធិការ ត្រូវបានអនុញ្ញាតឱ្យចេញ និងលក់សម្រាប់អនុវត្តតាមគោលបំណងដែលបានកំណត់ក្នុងផ្នែកនេះ និងដើម្បីសងត្រឡប់ទៅកាន់មូលនិធិបង្វិលសម្រាប់ការចំណាយលើមូលបត្របំណុលកាតព្វកិច្ចទូទៅអនុលោមតាមមាត្រាទី 16724.5 របស់ក្រមរដ្ឋាភិបាល។ មូលបត្របំណុលណាមួយក៏ដោយ នៅពេលបានលក់ ចេញ និង ប្រគល់រួចត្រូវចាត់ទុកជាកាតព្វកិច្ចទូទៅត្រឹមត្រូវ និង មានអានុភាពចងក្រងផ្លូវច្បាប់របស់រដ្ឋ ហើយសេចក្តីទុកចិត្ត និង សមត្ថភាពឥណទានពេញលេញ ត្រូវបានធានាទុកដោយរបស់រដ្ឋ សម្រាប់ការទូទាត់ឱ្យបានទាន់ពេលវេលាប្រាក់ដើម និង ការប្រាក់លើមូលបត្របំណុលទាំងនោះ នៅពេលប្រាក់ដើម និងការប្រាក់ដល់កាលកំណត់ត្រូវទូទាត់។

54062. មូលបត្របំណុលដែលត្រូវបានអនុញ្ញាតដោយផ្នែងនេះ ត្រូវរៀបចំ អនុវត្ត ចេញ លក់ ទូទាត់ បញ្ចប់ និង ទូទាត់សងមកវិញ ដូចដែលបានកំណត់ក្នុង ច្បាប់ស្តីពីមូលបត្របំណុលកាតព្វកិច្ចទូទៅរបស់រដ្ឋ (ជំពូកទី 4 (ចាប់ផ្តើមពីមាត្រាទី 16720) នៃផ្នែកទី 3 នៃ ភាគទី 4 នៃចំណងជើងទី 2 របស់ក្រមរដ្ឋាភិបាល) លើកលែងតែ ផ្នែករង (a) និង (b) នៃមាត្រាទី 16727 នៃក្រមរដ្ឋាភិបាល ហើយបទបញ្ញត្តិទាំងអស់នៃច្បាប់នោះ ដែលត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ ត្រូវអនុវត្តចំពោះមូលបត្របំណុលទាំងនេះ និងផ្នែកនេះ លើកលែងតែមានចែងផ្សេងក្នុងមាត្រាទី 54078 ហើយបទបញ្ញត្តិទាំងនោះត្រូវបានបញ្ចូលជាផ្នែកមួយនៃផ្នែកនេះ ដូចបានចែងពេញលេញនៅក្នុងផ្នែកនេះ។

54064. (a) សម្រាប់តែគោលបំណងនៃការអនុញ្ញាតឱ្យចេញ និងលក់ មូលបត្របំណុលប៉ុណ្ណោះ ដែលអនុលោមដោយផ្នែកនេះតាម ច្បាប់ស្តីពីមូលបត្របំណុលកាតព្វកិច្ចទូទៅរបស់រដ្ឋ គណៈកម្មាធិការហិរញ្ញវត្ថុលំនៅឋាន ដែលបានបង្កើតឡើងតាមមាត្រាទី 53524 ត្រូវបន្តមានសុពលភាព។ សម្រាប់គោលបំណងនៃផ្នែកនេះ គណៈកម្មាធិការហិរញ្ញវត្ថុលំនៅឋានគឺជា "គណៈកម្មាធិការ" ដូចដែលពាក្យនេះត្រូវបានប្រើនៅក្នុងច្បាប់ស្តីពីមូលបត្របំណុលកាតព្វកិច្ចទូទៅរបស់រដ្ឋ។

(b) ការយោងទៅលើ "ក្រុមប្រឹក្សា" ដូចដែលបានប្រើនៅក្នុងភាគនេះ និងក្នុង ច្បាប់ស្តីពីមូលបត្របំណុលកាតព្វកិច្ចទូទៅរបស់រដ្ឋ មានន័យថា គណៈកម្មាធិការអភិវឌ្ឍន៍ និងហិរញ្ញវត្ថុលំនៅឋាន។ សិទ្ធិអំណាចនេះអាចត្រូវបានប្រគល់ឱ្យក្រសួងលំនៅឋាន នឹងការអភិវឌ្ឍសហគមន៍ ឬទីភ្នាក់ងារហិរញ្ញវត្ថុលំនៅឋានរដ្ឋ California សម្រាប់កម្មវិធីដែលស្ថាប័នទាំងនោះគ្រប់គ្រង។ ក្រសួងលំនៅឋាន និងការអភិវឌ្ឍសហគមន៍ត្រូវបានកំណត់ជា "ក្រុមប្រឹក្សា" សម្រាប់កម្មវិធីដែលក្រសួងគ្រប់គ្រង ហើយទីភ្នាក់ងារហិរញ្ញវត្ថុលំនៅឋានរដ្ឋ California គឺជា "ក្រុមប្រឹក្សា" សម្រាប់កម្មវិធីដែលទីភ្នាក់ងារនោះគ្រប់គ្រង។

54066. នៅពេលទទួលបានការស្នើសុំរបស់ក្រុមប្រឹក្សាបញ្ជាក់ថា ត្រូវការមូលនិធិសម្រាប់គោលបំណងដែលមានចែងក្នុងផ្នែកនេះ គណៈកម្មាធិការត្រូវកំណត់ថាតាមរយៈសេចក្តីសម្រេច តើចាំបាច់ ឬសមគួរដែរឬទេ ក្នុងការចេញ និងវលក់មូលបត្របំណុល ហើយប្រសិនបើចាំបាច់ ឬ សមគួរ ត្រូវកំណត់ចំនួនមូលបត្របំណុលដែលត្រូវចេញ និងលក់។ ការចេញ ប័ណ្ណបំណុលជាបន្តបន្ទាប់អាចត្រូវបានអនុញ្ញាត និង លក់ដើម្បីអនុវត្តសកម្មភាពទាំងនោះជាលំដាប់ ហើយវាមិនចាំបាច់ទាល់តែមូលបត្របំណុលទាំងអស់ ត្រូវបានអនុញ្ញាតឱ្យចេញ និង លក់នៅពេលណាមួយនោះទេ។ មូលបត្របំណុលអាចផ្តល់ការប្រាក់ដែលត្រូវជាប់ពន្ធលើប្រាក់ចំណូលរបស់សហព័ន្ធ។

54068. ជារៀងរាល់ឆ្នាំ ត្រូវប្រមូលទឹកប្រាក់មួយចំនួន តាមរបៀប និងនៅពេលដូចគ្នានឹងការប្រមូលចំណូលរដ្ឋផ្សេងទៀត ដោយបន្ថែមលើប្រាក់ចំណូលធម្មតារបស់រដ្ឋ នូវចំនួនទឹកប្រាក់ដែលចាំបាច់ សម្រាប់ទូទាត់ប្រាក់ដើម និងការប្រាក់នៃមូលបត្របំណុលក្នុងមួយឆ្នាំៗ។ វាជាកាតព្វកិច្ចរបស់មន្ត្រីទទួលបន្ទុកទាំងអស់ស្របតាមច្បាប់ជាមួយនឹងកាតព្វកិច្ចណាមួយទាក់ទងនឹងការប្រមូលប្រាក់ចំណូលរបស់រដ្ឋដើម្បីធ្វើ និងអនុវត្តរាល់សកម្មភាពដែលចាំបាច់ដើម្បីប្រមូលប្រាក់បន្ថែមនោះ។

54070. ដោយមិនគិតពីមាត្រាទី 13340 នៃក្រមរដ្ឋាភិបាល តាមរយៈបទបញ្ញត្តិនេះ ទឹកប្រាក់មួយចំនួនត្រូវបានអនុម័តឱ្យប្រើប្រាស់ជាបន្តបន្ទាប់ពីមូលនិធិទូទៅនៅក្នុងរតនាគាររដ្ឋ សម្រាប់គោលបំណងនៃផ្នែកនេះ ដោយចំនួនទឹកប្រាក់នោះស្មើនឹងចំនួនសរុបនៃទាំងពីរខាងក្រោម៖

(a) ចំនួនទឹកប្រាក់ប្រចាំឆ្នាំដែលចាំបាច់ សម្រាប់ទូទាត់ប្រាក់ដើម និងការប្រាក់នៃមូលបត្របំណុល ដែលបានចេញផ្សាយ និងលក់ស្របតាមភាគនេះ នៅពេលដែលប្រាក់ដើម និងការប្រាក់នោះដល់កាលកំណត់ត្រូវទូទាត់។

(b) ចំនួនទឹកប្រាក់ដែលចាំបាច់ដើម្បីអនុវត្តមាត្រាទី 54074 ដែលត្រូវបានអនុម័តឱ្យប្រើប្រាស់ដោយមិនគិតពីឆ្នាំសារពើពន្ធឡើយ។

54072. ក្រុមប្រឹក្សាអាចស្នើសុំក្រុមប្រឹក្សាភិបាលវិនិយោគប្រាក់រួម ដើម្បីបង្កើតប្រាក់កម្ចីពីគណនីវិនិយោគប្រាក់ប្រមូលផ្តុំរួមគ្នា ដោយអនុលោមតាមមាត្រាទី 16312 នៃក្រមរដ្ឋាភិបាលសម្រាប់គោលបំណងនៃភាគនេះ។ ចំនួនទឹកប្រាក់ដែលបានស្នើសុំ មិនត្រូវលើសពីចំនួនមូលបត្របំណុលដែលមិនទាន់បានលក់ ដែលគណៈកម្មាធិការមានតាមរយៈសេចក្តីសម្រេច បានអនុញ្ញាតឱ្យលក់នោះឡើយ ដោយមិនរាប់បញ្ចូលនូវមូលបត្របំណុលទូទាត់សង ដែលបានអនុញ្ញាតអនុលោមតាមមាត្រាទី 54076 និង ដោយដកចេញនូវចំនួនទឹកប្រាក់ណាមួយដែលបានឱ្យខ្ចីអនុលោមតាមមាត្រានេះ ហើយមិនទាន់បានទូទាត់សងវិញ ព្រមទាំងចំនួនទឹកប្រាក់ណាមួយដែលបានដកពីមូលនិធិទូទៅអនុលោមតាមមាត្រាទី 54074 ហើយមិនទាន់បានប្រគល់ជូនមូលនិធិទូទៅវិញ។ ក្រុមប្រឹក្សាត្រូវអនុវត្តឯកសារណាមួយដែលតម្រូវដោយក្រុមប្រឹក្សាវិនិយោគប្រាក់ប្រមូលផ្តុំរួមគ្នា ដើម្បីទទួលបាន និងសងប្រាក់កម្ចី។ រាល់ចំនួនទឹកប្រាក់ដែលបានខ្ចី នឹងត្រូវតម្កល់ទៅក្នុងមូលនិធិដើម្បីបែងចែកអនុលោមតាមផ្នែកនេះ។

54074. សម្រាប់គោលបំណងនៃការអនុវត្តភាគនេះ នាយកហិរញ្ញវត្ថុអាចអនុញ្ញាតឱ្យមានការដកប្រាក់ពីមូលនិធិទូទៅ នូវចំនួនទឹកប្រាក់ដែលមិនត្រូវលើសពីចំនួនមូលបត្របំណុល ដែលមិនទាន់បានលក់ ដែលគណៈកម្មាធិការមាន តាមរយៈសេចក្តីសម្រេច បានអនុញ្ញាតឱ្យលក់នោះឡើយ ដោយមិនរាប់បញ្ចូលនូវមូលបត្របំណុលទូទាត់សងណាមួយ ដែលបានអនុញ្ញាតអនុលោមតាមមាត្រាទី 54076 ដោយដកចេញនូវចំនួនទឹកប្រាក់ណាមួយដែលបានឱ្យខ្ចីអនុលោមតាមមាត្រាទី 54072 ហើយមិនទាន់បានទូទាត់សងវិញ ព្រមទាំងចំនួនទឹកប្រាក់ណាមួយដែលបានដកពីមូលនិធិទូទៅអនុលោមតាមមាត្រានេះ ហើយមិនទាន់បានប្រគល់ជូនមូលនិធិទូទៅវិញ។ ចំនួនទឹកប្រាក់ដែលបានដកត្រូវដាក់ក្នុងមូលនិធិដែលត្រូវបែងចែកស្របតាមភាគនេះ។ រាល់ថវិកាដែលត្រូវបានផ្តល់ជូនក្រោមមាត្រានេះ ត្រូវប្រគល់ជូនមូលនិធិទូទៅវិញ បូករួមទាំងការប្រាក់ដែលចំនួនទឹកប្រាក់ទាំងនោះនឹងទទួលបាននៅក្នុងគណនីវិនិយោគប្រាក់ប្រមូលផ្តុំរួមគ្នា ដោយដកចេញពីថវិកាដែលទទួលបានពីការលក់មូលបត្របំណុល ដែលតាមគោលការណ៍ត្រូវតម្កល់ទៅក្នុងមូលនិធិនោះ។

54076. មូលបត្របំណុលដែលបានចេញផ្សាយ និង លក់អនុលោមតាមផ្នែកនេះ អាចត្រូវបានទូទាត់សងស្របតាមអត្ថបទទី 6 (ដោយចាប់ផ្តើមពីមាត្រាទី 16780) នៃ ជំពូកទី 4 នៃផ្នែកទី 3 នៃភាគទី 4 នៃចំណងជើងទី 2 នៃក្រមរដ្ឋាភិបាល។ ការយល់ព្រមដោយអ្នកបោះឆ្នោតលើការលក់ និងការចេញផ្សាយមូលបត្របំណុល ដូចដែលបានពណ៌នានៅក្នុងផ្នែកនេះ គឺរួមបញ្ចូលទាំងការយល់ព្រមលើការលក់ និងការចេញផ្សាយមូលបត្របំណុល ដែលបានចេញផ្សាយដើម្បីទូទាត់សងមូលបត្របំណុល ដែលបានចេញផ្សាយអនុលោមតាមផ្នែកនេះ រួមទាំងមូលបត្របំណុល ទូទាត់សងដែលបានចេញផ្សាយពីមុនណាមួយផងដែរ។ មូលបត្របំណុលទូទាត់សងមួយដែលកំពុងទូទាត់សងឡើងវិញតាមការអនុញ្ញាតដោយមាត្រានេះ អាចត្រូវបានទុកជាមោឃៈតាមផ្លូវច្បាប់ក្នុងកម្រិតដែលអនុញ្ញាតដោយច្បាប់ស្របតាមរបៀប និងវិសាលភាពដែលមានចែងក្នុងសេចក្តីសម្រេច ដែលបានធ្វើវិសោធនកម្មជាបន្តបន្ទាប់តាមពេលវេលា ដែលអនុញ្ញាតឱ្យមាន មូលបត្របំណុលដែលត្រូវបានទូទាត់សងនោះ។

54076.5. ប្រាក់ចំណូលដែលទទួលបានពីមូលបត្របំណុល ក្នុងចំនួនទឹកប្រាក់ដែលមិនលើសពីចំនួនប្រាក់ដើមនៃមូលបត្របំណុល ដែលត្រូវបានអនុញ្ញាតឱ្យចេញផ្សាយដោយច្បាប់ស្តីពីមូលបត្របំណុលសម្រាប់អតីតយុទ្ធជន និងលំនៅឋានតម្លៃសមរម្យនៃ ឆ្នាំ 2026 (ដោយមិនរាប់បញ្ចូលនូវមូលបត្របំណុលទូទាត់សងណាមួយដែលបានចេញផ្សាយអនុលោមតាមមាត្រាទី 54076 នោះទេ) ត្រូវបានរំពឹងទុក និងអាចត្រូវបានប្រើប្រាស់ដើម្បីទូទាត់សងវិញ ដល់ប្រភពដែលអាចប្រើប្រាស់បានដោយស្របច្បាប់ណាមួយដែលត្រូវបានប្រើប្រាស់សម្រាប់ទូទាត់ការចំណាយលើគម្រោង ឬកម្មវិធីនានា (រួមទាំងមូលនិធិរបស់ក្រសួង ឬទីភ្នាក់ងាររដ្ឋជាក់លាក់ណាមួយ ដែលអាចត្រូវបានចំណាយលើការចំណាយនៃគម្រោង ឬកម្មវិធីទាំងនោះ) ដែលត្រូវបានអនុញ្ញាតអនុលោមតាមច្បាប់ស្តីពីមូលបត្របំណុលសម្រាប់អតីតយុទ្ធជន និងលំនៅឋានតម្លៃសមរម្យនៃ ឆ្នាំ 2026 និងបានទូទាត់បន្ទាប់ពីថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2026។ ទោះជាយ៉ាងណាក៏ដោយក្នុងលក្ខខណ្ឌដែលការចំណាយណាមួយដែលត្រូវទូទាត់សងវិញពីប្រាក់ចំណូលនៃមូលបត្របំណុល មិនត្រូវបានទូទាត់ចេញពីប្រាក់ចំណូលដែលបានមកពីបំណុលផ្សេងទៀតឡើយ លើកលែងតែបំណុលមុននោះ នឹងត្រូវបានសងបញ្ចប់ដោយប្រើប្រាក់ដែលទទួលបានពីមូលបត្របំណុល។

54077. ដើម្បីអនុវត្តការផ្តល់មូលនិធិដែលមានបញ្ជាក់លម្អិតនៅក្នុងមាត្រាទី 54054 អង្គភាពគ្រប់គ្រងអាចអនុម័តគោលការណ៍ណែនាំដែលកំណត់លក្ខខណ្ឌតម្រូវសម្រាប់ការគ្រប់គ្រងកម្មវិធីហិរញ្ញប្បទានរបស់ខ្លួន។ គោលការណ៍ណែនាំទាំងនេះមិនស្ថិតនៅក្រោមជំពូកទី 3.5 (ដោយចាប់ផ្តើមពីមាត្រាទី 11340) នៃផ្នែកទី 1 នៃភាគទី 3 នៃចំណងជើងទី 2 នៃក្រមរដ្ឋាភិបាលឡើយ។

54078. ដោយមិនគិតពីបទបញ្ញត្តិណាមួយនៅក្នុងច្បាប់ស្តីពីមូលបត្របំណុល កាតព្វកិច្ចទូទៅរបស់រដ្ឋឡើយ កាលបរិច្ឆេទដល់កំណត់នៃមូលបត្របំណុល ណាមួយដែលត្រូវបានអនុញ្ញាតដោយផ្នែកនេះ មិនត្រូវហួសពី 35 ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចេញផ្សាយមូលបត្របំណុលនោះឡើយ។

54080. ប្រាក់ចំណូលដែលបានមកពីការលក់មូលបត្របំណុលដែលត្រូវបានអនុញ្ញាតដោយផ្នែកនេះមិនមែនជា "ចំណូលពីពន្ធ" ដូចដែលពាក្យនោះត្រូវបានប្រើនៅក្នុងចំណងជើង XIII B នៃរដ្ឋធម្មនុញ្ញរដ្ឋ California ហើយការចាយវាយនៃប្រាក់ចំណូលទាំងនេះមិនស្ថិតក្រោមដែនកំណត់ដែលកំណត់ដោយអត្ថបទនោះទេ។

54082. ដោយមិនគិតពីបទបញ្ញត្តិណាមួយនៃច្បាប់ស្តីពីមូលបត្របំណុល កាតព្វកិច្ចទូទៅរបស់រដ្ឋពាក់ព័ន្ធនឹងប្រាក់ចំណូលដែលទទួលបានពីការលក់មូលបត្របំណុល ដែលត្រូវបានអនុញ្ញាតដោយផ្នែកនេះ ដែលជាកម្មវត្ថុនៃការវិនិយោគក្រោមអត្ថបទទី 4 (ដោយចាប់ផ្តើមពីមាត្រាទី 16470) នៃជំពូកទី 3 នៃផ្នែកទី 2 នៃភាគទី 4 នៃចំណងជើងទី 2 នៃក្រមរដ្ឋាភិបាលក៏ដោយ ក៏អគ្គហេរញ្ញិកអាចរក្សាទុកនូវគណនីដាច់ដោយឡែកមួយសម្រាប់ប្រាក់ចំណូលពីការវិនិយោគ។

54083. ដោយមិនគិតពីបទបញ្ញត្តិផ្សេងទៀតណាមួយនៃភាគនេះ ឬនៃច្បាប់ស្តីពី មូលបត្របំណុលកាតព្វកិច្ចទូទៅរបស់រដ្ឋក៏ដោយ ប្រសិនបើហិរញ្ញិកលក់ មូលបត្របំណុលអនុលោមតាមជំពូកនេះ ដែលរួមបញ្ចូលនូវមតិយោបល់របស់មេធាវីផ្នែកមូលបត្របំណុល ដែលបញ្ជាក់ថាការប្រាក់លើមូលបត្របំណុលទាំងនោះ ត្រូវបានដកចេញពីចំណូលសរុបសម្រាប់គោលបំណងពន្ធសហព័ន្ធ ក្រោមលក្ខខណ្ឌដែលបានកំណត់ ឬបើពុំនោះសោត មានសិទ្ធិទទួលបានអត្ថប្រយោជន៍ពន្ធសហព័ន្ធណាមួយ នោះហិរញ្ញិកអាចរក្សាទុកនូវគណនីដាច់ដោយឡែកនានា សម្រាប់ការវិនិយោគនូវប្រាក់ចំណូលពីមូលបត្របំណុល និង សម្រាប់ប្រាក់ចំណេញព្រមទាំងការវិនិយោគប្រាក់ចំណេញដែលទទួលបានពីប្រាក់ចំណូលទាំងនោះ។ ហិញ្ញិកអាចប្រើប្រាស់ ឬបែងចែកការប្រើប្រាស់ប្រាក់ចំណេញ ឬប្រាក់ចំណូលទាំងនោះ ដើម្បីបង់រំលស់ ការផាកពិន័យ ឬការទូទាត់ផ្សេងទៀតដែលត្រូវការនៅក្រោមច្បាប់សហព័ន្ធ ឬធ្វើសកម្មភាពផ្សេងទៀតទាក់ទងនឹងការវិនិយោគ និងការប្រើប្រាស់មូលបត្របំណុលទាំងនោះដែលត្រូវការ ឬសមគួរក្រោមច្បាប់សហព័ន្ធ ដើម្បីរក្សាស្ថានភាពលើកលែងពន្ធនៃមូលបត្របំណុលទាំងនោះ និងដើម្បីទទួលបានអត្ថប្រយោជន៍ផ្សេងទៀតនៅក្រោមច្បាប់សហព័ន្ធក្នុងនាមមូលនិធិនៃរដ្ឋនេះ។

54084. (a) ដោយស្ថិតក្រោមផ្នែករង (b) រាល់ថវិកាដែលទទួលបានពីបុព្វលាភ និងការប្រាក់បង្គរលើមូលបត្របំណុល ដែលបានលក់អនុលោមតាមផ្នែកនេះ ត្រូវផ្ទេរទៅកាន់មូលនិធិទូទៅដើម្បីចាត់ទុកជាឥណទានសម្រាប់ការចំណាយលើការប្រាក់នៃមូលបត្របំណុល។

(b) ចំនួនទឹកប្រាក់ដែលទទួលបានពីបុព្វលាភអាចត្រូវបានបម្រុងទុក និងប្រើប្រាស់ដើម្បីទូទាត់ការចំណាយលើការចេញផ្សាយមូលបត្របំណុល មុនពេលផ្ទេរទៅកាន់មូលនិធិទូទៅ។

ជំពូកទី 4. គណនេយ្យភាព

54088. អង្គភាពគ្រប់គ្រងត្រូវចេញផ្សាយនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ នូវព័ត៌មានលម្អិតពាក់ព័ន្ធនឹងការវិនិយោគដែលទទួលបានពីមូលបត្របំណុលនេះ អនុលោមតាមមាត្រាទី 50408 នៃក្រមសុខាភិបាល និងសុវត្ថិភាព។

ផ្នែកទី 3. អត្ថបទ 5ab (ចាប់ផ្តើមជាមួយមាត្រាទី 998.750) ត្រូវបានបន្ថែមទៅជំពូកទី 6 នៃភាគទី 4 នៃក្រមយោធា និងអតីតយុទ្ធជន មានខ្លឹមសារដូចខាងក្រោម៖

អត្ថបទ 5ab. ច្បាប់ស្តីពីមូលបត្របំណុលសម្រាប់អតីតយុទ្ធជន និងលំនៅឋានដែលមានតម្លៃសមរម្យនៃ ឆ្នាំ 2026។

998.750. រួមជាមួយផ្នែក 16.1 (ចាប់ផ្តើមពីមាត្រាទី 54050) នៃភាគទី 31 នៃក្រមសុខាភិបាល និងសុវត្ថិភាព អត្ថបទនេះត្រូវបានស្គាល់និង មានឈ្មោះថា ច្បាប់ស្តីពីមូលបត្របំណុលសម្រាប់អតីតយុទ្ធជន និងលំនៅឋានដែលមានតម្លៃសមរម្យនៃ ឆ្នាំ 2026។

998.751. (a) (1) ច្បាប់ស្តីពីមូលបត្របំណុលកាតព្វកិច្ចទូទៅរបស់រដ្ឋ (ជំពូកទី 4 (ដោយចាប់ផ្តើមពីមាត្រាទី 16720) នៃផ្នែកទី 3 នៃភាគទី 4 នៃចំណងជើងទី 2 របស់ក្រមរដ្ឋាភិបាល) ដូចដែលត្រូវបានធ្វើវិសោធនកម្មតាមពេលចាំបាច់ត្រូវបានទទួលយកក្នុងគោលបំណងសម្រាប់រៀបចំ អនុវត្ត ចេញផ្សាយ លក់ បញ្ចប់ លស់យកមកវិញ និងទូទាត់សងឡើងវិញ ព្រមទាំងការផ្តល់ជូនផ្សេងទៀតពាក់ព័ន្ធនឹងមូលបត្របំណុល ដែលត្រូវបានអនុញ្ញាតឱ្យចេញផ្សាយដោយអត្ថបទនេះ ហើយបទបញ្ញត្តិនៃច្បាប់នោះ ត្រូវបានរួមបញ្ចូលនៅក្នុងអត្ថបទនេះ ហាក់បីដូចជាត្រូវបានចែងយ៉ាងពេញលេញនៅក្នុងអត្ថបទនេះដែរ លើកលែងតែចំណុចទាំងពីរដូចខាងក្រោម៖

(A) ផ្នែករង (a) និង (b) នៃ មាត្រាទី 16727 និង ផ្នែករង (a) នៃមាត្រាទី 16755 នៃច្បាប់ស្តីពីមូលបត្របំណុលកាតព្វកិច្ចទូទៅរបស់រដ្ឋមិនត្រូវយកមកអនុវត្តឡើយ។

(B) កថាខណ្ឌទី 1 នៃផ្នែករង (c) នៃមាត្រាទី 16753 នៃច្បាប់ស្តីពីមូលបត្របំណុលកាតព្វកិច្ចទូទៅរបស់រដ្ឋ ត្រូវជំនួសទាំងស្រុងដោយខ្លឹមសារដូចខាងក្រោម៖ "ហិរញ្ញិកត្រូវតម្រូវឱ្យអ្នកដេញថ្លៃដែលទទួលបានជោគជ័យនៅក្នុងការលក់តាមរយៈការដេញថ្លៃប្រកួតប្រជែង ឬ អ្នកធានាទិញមូលបត្រនៅក្នុងការលក់តាមរយៈការចរចា ផ្តល់នូវប្រាក់តម្កល់បញ្ជាក់ពីសុច្ចរិតភាពយ៉ាងហោចណាស់ មួយភាគពីរនៃ 1 ភាគរយនៃចំនួនប្រាក់ដើមនៃមូលបត្របំណុល ដែលអ្នកដេញថ្លៃនោះគឺជាអ្នកដេញថ្លៃទទួលបានជោគជ័យ ឬដែលអ្នកធានាទិញមូលបត្របានដាក់ស្នើសំណើ។ ប្រាក់តម្កល់បញ្ជាក់ពីសុច្ចរិតភាពនេះ គួរមានចំនួនដែលត្រូវបានកំណត់យ៉ាងសមស្រប

1

ដោយហិរញ្ញិកយ៉ាងហោចណាស់មួយថ្ងៃមុនការលក់តាមរយៈការដេញថ្លៃប្រកួតប្រជែង ឬការលក់តាមរយៈការចរចានូវមូលបត្របំណុល តាមករណីដែលអាចអនុវត្តបាន។ ហិរញ្ញិកត្រូវបញ្ជាក់ពីទម្រង់នៃប្រាក់តម្កល់ ដែលអាចជាមូលប្បទានប័ត្របេឡាករ មូលបត្របំណុលធានា ការផ្ទេរប្រាក់តាមប្រព័ន្ធធនាគារ ឬការរួមបញ្ចូលគ្នានៃទម្រង់ទាំងនេះ។ ប្រាក់តម្កល់នេះមិនត្រូវទទួលបានការប្រាក់ឡើយ។"

(2) រាល់សេចក្តីយោងនៅក្នុងអត្ថបទនេះចំពោះពាក្យ "ក្នុងទីនេះ" គឺសំដៅទៅលើ អត្ថបទនេះផង និង ច្បាប់នោះផង ដូចដែលបានរួមបញ្ចូលក្នុងទីនេះ។

(b) សម្រាប់គោលបំណងនៃច្បាប់ស្តីពីមូលបត្របំណុលកាតព្វកិច្ចទូទៅរបស់រដ្ឋ ក្រសួងកិច្ចការអតីតយុទ្ធជន ត្រូវបានចាត់តាំងជា "ក្រុមប្រឹក្សា"។

998.752. ដូចដែលបានប្រើក្នុងទីនេះ ពាក្យខាងក្រោមមានន័យដូចខាងក្រោម៖

(a) "ក្រុមប្រឹក្សា" មានន័យថា ក្រសួងកិច្ចការអតីតយុទ្ធជន។

(b) "មូលបត្របំណុល" មានន័យថាមូលបត្របំណុលអតីតយុទ្ធជន ដែលជាមូលបត្របំណុលកាតព្វកិច្ចទូទៅរបស់រដ្ឋ ដែលបានចេញផ្សាយអនុលោមតាមអត្ថបទនេះ ទទួលយកបទបញ្ញត្តិនៃច្បាប់ស្តីពីមូលបត្របំណុលកាតព្វកិច្ចទូទៅរបស់រដ្ឋ ដូចដែលបានចែងក្នុងទីនេះ។

(c) "ច្បាប់ស្តីពីមូលបត្របំណុល" មានន័យថា អត្ថបទនេះអនុញ្ញាតឱ្យមានការចេញផ្សាយមូលបត្របំណុលកាតព្វកិច្ចទូទៅរបស់រដ្ឋ និង អនុម័តច្បាប់ស្តីពីមូលបត្របំណុលកាតព្វកិច្ចទូទៅរបស់រដ្ឋតាមរយៈសេចក្តីយោង។

(d) "គណៈកម្មាធិការ" មានន័យថាគណៈកម្មាធិការហិរញ្ញវត្ថុអតីតយុទ្ធជននៃឆ្នាំ 1943 ដែលត្រូវបានបង្កើតឡើងដោយមាត្រាទី 991។

(e) "មូលនិធិ" មានន័យថាមូលនិធិកសិដ្ឋាន និង ការសាងសង់លំនៅឋានសម្រាប់អតីតយុទ្ធជននៃឆ្នាំ 1943 ដែលត្រូវបានបង្កើតឡើងដោយមាត្រាទី 988។

(f) "មូលនិធិទូទាត់" មានន័យថាមូលនិធិទូទាត់មូលបត្របំណុលអតីតយុទ្ធជនដែលត្រូវបានបង្កើតឡើងដោយមាត្រាទី 988.6។

998.753. ក្នុងគោលបំណងបង្កើតមូលនិធិមួយដើម្បីផ្តល់ជំនួយផ្នែកកសិដ្ឋាន និង លំនៅឋានសម្រាប់អតីតយុទ្ធជន អនុលោមតាមច្បាប់ស្តីពីការទិញកសិដ្ឋាន និង លំនៅឋានសម្រាប់អតីតយុទ្ធជននៃឆ្នាំ 1974 (អត្ថបទទី 3.1 (ដោយចាប់ផ្តើមពីមាត្រាទី 987.50)) ព្រមទាំងច្បាប់ទាំងអស់ដែលធ្វើវិសោធនកម្ម និង បំពេញបន្ថែមលើច្បាប់នេះ គណៈកម្មាធិការអាចបង្កើតនូវបំណុល ឬកាតព្វកិច្ចនានារបស់រដ្ឋ California ក្នុងចំនួនទឹកប្រាក់សរុបមិនលើសពី មួយពាន់ពីររយហាសិបលានដុល្លារ ($1,250,000,000) ដោយមិនរាប់បញ្ចូលចំនួនទឹកប្រាក់នៃមូលបត្របំណុលទូទាត់សងណាមួយ ដែលបានចេញផ្សាយអនុលោមតាមមាត្រាទី 998.762 នោះឡើយ តាមរបៀបដែលបានចែងក្នុងទីនេះ។

998.754. (a) រាល់មូលបត្របំណុលដែលត្រូវបានអនុញ្ញាតដោយអត្ថបទនេះនៅពេលបានលក់ ចេញផ្សាយ និងប្រគល់ជូន គួរត្រូវ និងបង្កើតបានជាកាតព្វកិច្ចទូទៅស្របច្បាប់ និងមានតម្លៃចងកាតព្វកិច្ចតាមផ្លូវច្បាប់នៃរដ្ឋ California ហើយការធានា និងឥណទានពេញលេញរបស់រដ្ឋ California ត្រូវបានសន្យានៅទីនេះសម្រាប់ការទូទាត់ទាន់ពេលវេលានូវទាំងប្រាក់ដើម និងការប្រាក់នៃមូលបត្របំណុល ទាំងនោះ នៅពេលដែលប្រាក់ដើម និងការប្រាក់នោះដល់កាលកំណត់ត្រូវទូទាត់។

(b) គួរត្រូវប្រមូលជារៀងរាល់ឆ្នាំ តាមនីតិវិធី និង ពេលវេលាដូចគ្នាទៅនឹងការប្រមូលចំណូលរដ្ឋផ្សេងទៀត ដោយបន្ថែមលើប្រាក់ចំណូលធម្មតារបស់រដ្ឋ នូវចំនួនទឹកប្រាក់ដែលចាំបាច់ សម្រាប់ទូទាត់ប្រាក់ដើម និងការប្រាក់នៃមូលបត្របំណុលទាំងនេះ ដែលដល់កាលកំណត់ត្រូវទូទាត់ក្នុងមួយឆ្នាំៗ។ វាជាកាតព្វកិច្ចរបស់មន្ត្រីទទួលបន្ទុកទាំងអស់ស្របតាមច្បាប់ជាមួយនឹងកាតព្វកិច្ចណាមួយទាក់ទងនឹងការប្រមូលប្រាក់ចំណូលរបស់រដ្ឋដើម្បីធ្វើ និងអនុវត្តរាល់សកម្មភាពដែលចាំបាច់ដើម្បីប្រមូលប្រាក់បន្ថែមនោះ។

(c) នៅកាលបរិច្ឆេទដែលមូលនិធិត្រូវផ្ទេរអនុលោមតាមមាត្រាទី 16676 នៃក្រមរដ្ឋាភិបាល សម្រាប់ការទូទាត់សេវាបំណុលលើមូលបត្របំណុលក្នុងឆ្នាំសារពើពន្ធនីមួយៗ គួរត្រូវផ្ទេរទៅកាន់មូលនិធិសម្រាប់ការទូទាត់ ដើម្បីទូទាត់សេវាបំណុលទឹកប្រាក់ទាំងអស់ដែលមាននៅក្នុងមូលនិធិ ដែលចំនួននេះមិនត្រូវលើសពីចំនួនសេវាបំណុលដែលដល់កាលកំណត់ និងត្រូវទូទាត់នៅពេលនោះឡើយ។ ប្រសិនបើប្រាក់ដែលបានផ្ទេរនៅកាលបរិច្ឆេទផ្ទេរប្រាក់ មានចំនួនតិចជាងសេវាបំណុលដែលដល់កាលកំណត់ និងត្រូវទូទាត់នៅពេលនោះ សមតុល្យដែលនៅសល់មិនទាន់បានទូទាត់ ត្រូវផ្ទេរចេញពីមូលនិធិទៅកាន់មូលនិធិទូទៅភ្លាមៗនៅពេលដែលថវិកានោះអាចប្រើប្រាស់បាន ព្រមទាំងការប្រាក់លើចំនួនទឹកប្រាក់នោះ ចាប់ពីកាលបរិច្ឆេទផ្ទេរប្រាក់រហូតដល់ពេលបង់រួចរាល់ ដោយគិតតាមអត្រាការប្រាក់ដូចគ្នានឹងអត្រាការប្រាក់របស់មូលបត្របំណុល និងគិតការប្រាក់បូកបន្ថែមរៀងរាល់ប្រាំមួយខែ។ ដោយមិនគិតពីបទបញ្ញត្តិនៃច្បាប់ផ្សេងទៀតណាមួយដែលមានខ្លឹមសារផ្ទុយពីនេះក៏ដោយ ផ្នែករងនេះគួរត្រូវយកមកអនុវត្តចំពោះច្បាប់ស្តីពីមូលបត្របំណុល សម្រាប់ការទិញកសិដ្ឋាន និងលំនៅឋានសម្រាប់អតីតយុទ្ធជនទាំងអស់អនុលោមតាម ជំពូកនេះ។ ផ្នែករងនេះមិនផ្តល់សិទ្ធិធានាណាមួយលើមូលនិធិ មូលនិធិទូទាត់ ឬប្រាក់នៅក្នុងមូលនិធិទាំងនោះ ដល់អ្នកកាន់កាប់មូលបត្របំណុល ណាមួយដែលបានចេញផ្សាយក្រោមអត្ថបទនេះឡើយ។ សម្រាប់គោលបំណងនៃផ្នែករងនេះ "សេវាបំណុល" មានន័យថាប្រាក់ដើម (ទោះជាដល់កាលកំណត់ដោយការផុតកំណត់ ការលស់យកមកវិញ ឬការពន្លឿនការទូទាត់ក៏ដោយ) បុព្វលាភប្រសិនបើមាន ឬការប្រាក់ដែលត្រូវទូទាត់នៅកាលបរិច្ឆេទណាមួយពាក់ព័ន្ធនឹងស៊េរីនៃ មូលបត្របំណុលណាមួយ។ ផ្នែករងនេះមិនត្រូវយកមកអនុវត្តឡើយ ទោះជាយ៉ាងណាក៏ដោយក្នុងករណីនៃសេវាបំណុលណាមួយដែលត្រូវទូទាត់ពីប្រាក់ចំណូលនៃមូលបត្របំណុល ទូទាត់សងណាមួយ។

998.755. ដោយមិនគិតពីមាត្រាទី 13340 នៃក្រមរដ្ឋាភិបាលឡើយ ត្រូវមានការអនុម័តបម្រុងទុកថវិកាជាបន្តបន្ទាប់ពីមូលនិធិទូទៅនៅក្នុងរតនាគាររដ្ឋ សម្រាប់គោលបំណងនៃអត្ថបទនេះ ដោយមិនគិតពីឆ្នាំសារពើពន្ធឡើយ នូវចំនួនទឹកប្រាក់ដែលនឹងស្មើទៅនឹងចំណុចទាំងពីរដូចខាងក្រោម៖

(a) ចំនួនទឹកប្រាក់ប្រចាំឆ្នាំដែលចាំបាច់ សម្រាប់ទូទាត់ប្រាក់ដើមនៃ និងការប្រាក់នៃ មូលបត្របំណុល ដែលបានចេញផ្សាយ និងលក់ ដូចដែលបានចែងក្នុងទីនេះ នៅពេលដែលប្រាក់ដើម និងការប្រាក់នោះដល់កាលកំណត់ត្រូវទូទាត់។

(b) ចំនួនទឹកប្រាក់ដែលចាំបាច់ដើម្បីអនុវត្តមាត្រាទី 998.756។

998.756. សម្រាប់គោលបំណងនៃអត្ថបទនេះ នាយកហិរញ្ញវត្ថុ អាចអនុញ្ញាតឱ្យមានការដកប្រាក់ពីមូលនិធិទូទៅ នូវចំនួនទឹកប្រាក់ដែលមិនត្រូវលើសពីចំនួនមូលបត្របំណុល ដែលមិនទាន់បានលក់ ដែលគណៈកម្មាធិការបានអនុញ្ញាតឱ្យលក់អនុលោមតាមអត្ថបទនេះ ដោយមិនរាប់បញ្ចូលនូវមូលបត្របំណុលទូទាត់សងណាមួយដែលបានអនុញ្ញាតអនុលោមតាមមាត្រាទី 998.762 ដោយដកចេញនូវចំនួនទឹកប្រាក់ណាមួយដែលបានឱ្យខ្ចីអនុលោមតាមមាត្រាទី 998.757 ហើយមិនទាន់បានទូទាត់សងវិញ ព្រមទាំងចំនួនទឹកប្រាក់ណាមួយដែលបានដកអនុលោមតាមមាត្រានេះ ហើយមិនទាន់បានប្រគល់ជូនមូលនិធិទូទៅវិញ។ រាល់ចំនួនទឹកប្រាក់ដែលបានដកចេញ នឹងត្រូវតម្កល់ទៅក្នុងមូលនិធិ។ រាល់ថវិកាដែលត្រូវបានផ្តល់ជូនដល់ក្រុមប្រឹក្សាក្រោមមាត្រានេះ នឹងត្រូវប្រគល់ជូនមូលនិធិទូទៅវិញដោយក្រុមប្រឹក្សាបូករួមទាំងការប្រាក់ដែលចំនួនទឹកប្រាក់ទាំងនោះនឹងទទួលបាននៅក្នុងគណនីវិនិយោគប្រាក់ដែលប្រមូលផ្តុំរួមគ្នា ពីការលក់ប័ណ្ណបំណុល ដើម្បីអនុវត្តអត្ថបទនេះ។

998.757. ក្រុមប្រឹក្សាអាចស្នើសុំទៅក្រុមប្រឹក្សាវិនិយោគប្រាក់រួមដើម្បីផ្តល់កម្ចីពីគណនីវិនិយោគប្រាក់ដែលប្រមូលផ្តុំរួមគ្នាស្របតាមមាត្រាទី 16312 នៃក្រមរដ្ឋាភិបាល សម្រាប់គោលបំណងនៃការអនុវត្តអត្ថបទនេះ ដោយដកចេញនូវចំនួនទឹកប្រាក់ណាមួយដែលបានដកអនុលោមតាមមាត្រាទី 998.756 ហើយមិនទាន់បានប្រគល់ជូនមូលនិធិទូទៅវិញ។ ចំនួនទឹកប្រាក់ដែលបានស្នើសុំ មិនត្រូវលើសពីចំនួនមូលបត្របំណុល ដែលមិនទាន់បានលក់ ដែលគណៈកម្មាធិការ បានអនុញ្ញាតឱ្យលក់សម្រាប់គោលបំណងនៃការអនុវត្តអត្ថបទនេះ តាមរយៈសេចក្តីសម្រេច ដោយមិនរាប់បញ្ចូលនូវមូលបត្របំណុល ទូទាត់សងណាមួយដែលបានអនុញ្ញាតអនុលោមតាមមាត្រាទី 998.762 ដោយដកចេញនូវចំនួនទឹកប្រាក់ណាមួយដែលបានឱ្យខ្ចីអនុលោមតាមមាត្រានេះ ហើយមិនទាន់បានទូទាត់សងវិញ ព្រមទាំងចំនួនទឹកប្រាក់ណាមួយដែលបានដកអនុលោមតាមមាត្រាទី

998.756 ហើយមិនទាន់បានប្រគល់ជូនមូលនិធិទូទៅវិញ។ ក្រុមប្រឹក្សាត្រូវ អនុវត្តឯកសារនានាដែលតម្រូវដោយក្រុមប្រឹក្សាវិនិយោគប្រាក់ដែលប្រមូលផ្តុំ រួមគ្នា ដើម្បីទទួលបាន និងសងប្រាក់កម្ចី។ រាល់ចំនួនទឹកប្រាក់ដែលបានខ្ចី ត្រូវ តម្កល់ទៅក្នុងមូលនិធិ ដើម្បីបែងចែកដោយក្រុមប្រឹក្សាស្របតាមអត្ថបទនេះ។

998.758. តាមសំណើរបស់ក្រុមប្រឹក្សា ដោយមានការគាំទ្រពីសេចក្តី ថ្លែងការណ៍អំពីផែនការ និងគម្រោងរបស់ខ្លួនដែលត្រូវបានអនុម័តដោយ អភិបាលរដ្ឋ គណៈកម្មាធិការត្រូវកំណត់តាមរយៈសេចក្តីសម្រេចថា តើមាន ភាពចាំបាច់ ឬសមគួរឬទេ ក្នុងការចេញផ្សាយមូលបត្របំណុលណាមួយដែល ត្រូវបានអនុញ្ញាតអនុលោមតាមមាត្រានេះ ដើម្បីអនុវត្តផែនការ និងគម្រោង របស់ក្រុមប្រឹក្សា ហើយប្រសិនបើមានមែន ត្រូវកំណត់ចំនួន មូលបត្រ បំណុលដែលត្រូវចេញផ្សាយ និងលក់។ ការចេញផ្សាយមូលបត្របំណុល អាចត្រូវបានអនុញ្ញាត និងលក់ដើម្បីអនុវត្តផែនការ និងគម្រោងទាំងនេះ ជាដំណាក់កាលៗ ហើយវាមិនចាំបាច់តម្រូវឱ្យចេញផ្សាយ ឬលក់មូលបត្រ បំណុលទាំងអស់ក្នុងពេលតែមួយនោះឡើយ។

998.759. (a) រហូតទាល់តែមូលបត្របំណុលណាមួយដែលត្រូវ បានអនុញ្ញាតអនុលោមតាមអត្ថបទនេះ នៅសល់មិនទាន់បានទូទាត់សង រដ្ឋលេខាធិការកិច្ចការអតីតយុទ្ធជន នៅចុងបញ្ចប់នៃឆ្នាំសារពើពន្ធនីមួយៗ ត្រូវតម្រូវឱ្យមានការធ្វើស្ទង់មតិមួយស្តីពីស្ថានភាពហិរញ្ញវត្ថុនៃផ្នែកទិញ កសិដ្ឋាន និងលំនៅឋាន រួមគ្នាជាមួយនឹងការព្យាករណ៍អំពីប្រតិបត្តិការរបស់ ផ្នែកនេះ ដែលត្រូវធ្វើឡើងដោយគណនេយ្យករសាធារណៈឯករាជ្យដែលត្រូវ បានទទួលស្គាល់។ លទ្ធផលនៃការស្ទង់មតិ និងការព្យាករណ៍នីមួយៗ ត្រូវ រាយការណ៍ជាលាយលាយលក្ខណ៍អក្សរដោយគណនេយ្យករសាធារណៈ ជូនដល់រដ្ឋលេខាធិការកិច្ចការអតីតយុទ្ធជន ក្រុមប្រឹក្សាអតីតយុទ្ធជនរដ្ឋ California គណៈកម្មាធិការគោលនយោបាយនានាដែលពាក់ព័ន្ធនឹងកិច្ចការ អតីតយុទ្ធជននៅក្នុងព្រឹទ្ធសភា និងរដ្ឋសភា និងគណៈកម្មាធិការ។

(b) ផ្នែកទិញកសិដ្ឋាន និងលំនៅឋាន ត្រូវទូទាត់សងថ្លៃសេវាដល់ គណនេយ្យករសាធារណៈសម្រាប់សេវាកម្មទាំងនេះ ដោយប្រើប្រាស់ថវិកា ណាមួយដែលផ្នែកនេះអាចមាននៅលើប្រាក់តម្កល់ជាមួយហិរញ្ញិក។

998.760. (a) ហិរញ្ញិកត្រូវចេញផ្សាយ និងលក់មូលបត្របំណុល ដែល ត្រូវបានអនុញ្ញាតដោយមាត្រានេះ ក្នុងចំនួនទឹកប្រាក់ដែលបានកំណត់ដោយ គណៈកម្មាធិការថាមានភាពចាំបាច់ និងសមគួរ ដោយអនុលោមតាមមាត្រា ទី 998.758។ មូលបត្របំណុលត្រូវចេញផ្សាយ និង លក់តាមលក្ខខណ្ឌដូច បានបញ្ជាក់តាមដំណោះស្រាយដែលត្រូវទទួលយកដោយគណៈកម្មាធិការ អនុលោមតាមមាត្រាទី 16731 នៃក្រមរដ្ឋាភិបាល។

(b) ក្នុងករណីណាដែលគណៈកម្មាធិការយល់ឃើញថា មានភាពចាំបាច់ សម្រាប់ការលក់មូលបត្របំណុល ដោយមានប្រសិទ្ធភាព គណៈកម្មាធិការ អាចអនុញ្ញាត ឱ្យហិរញ្ញិកលក់មូលបត្របំណុលស៊េរីណាមួយក្នុងតម្លៃទាប ជាងតម្លៃចារឹករបស់វា ដោយមិនគិតពីមាត្រាទី 16754 នៃក្រមរដ្ឋាភិបាល ឡើយ។ ទោះជាយ៉ាងណាក៏ដោយការបញ្ចុះតម្លៃលើមូលបត្របំណុលមិនត្រូវ លើសពី 3 ភាគរយនៃតម្លៃចារឹករបស់វាឡើយ។

998.761. ចេញពីប្រាក់ដំបូងដែលទទួលបានពីការលក់មូលបត្របំណុល ដូចបានចែងក្នុងទីនេះ ត្រូវតម្កល់ប្រាក់ឡើងវិញចូលទៅក្នុងមូលនិធិបង្វិល សម្រាប់ការចំណាយលើមូលបត្របំណុលកាតព្វកិច្ចទូទៅ ដែលបានបង្កើត ឡើងដោយមាត្រាទី 16724.5 នៃក្រមរដ្ឋាភិបាលនូវចំនួនទឹកប្រាក់នៃការ ចំណាយទាំងអស់ដែលបានធ្វើឡើងសម្រាប់គោលបំណងដែលបានបញ្ជាក់ នៅក្នុងមាត្រានោះ ហើយថវិកាទាំងនោះអាចត្រូវបានប្រើប្រាស់សម្រាប់ គោលបំណងដូចគ្នានេះ និងត្រូវសងវិញតាមរបៀបដូចគ្នា នៅពេលណា ដែលមានការលក់មូលបត្របំណុលបន្ថែមទៀត។ ប្រាក់ទាំងអស់ដែលបាន ដាក់តម្កល់ក្នុងមូលនិធិ បានមកពីបុព្វលាភ និងការប្រាក់បង្គរលើមូលបត្រ បំណុលដែលបានលក់អនុលោមតាមអត្ថបទនេះ ត្រូវរក្សាទុកក្នុងមូលនិធិ ហើយនឹងមានសម្រាប់ផ្ទេរទៅមូលនិធិទូទៅជាឥណទានសម្រាប់ការចំណាយ លើការប្រាក់លើមូលបត្របំណុល លើកលែងតែចំនួនទឹកប្រាក់ដែលបាន មកពីបុព្វលាភ អាចត្រូវបានបម្រុងទុក និងប្រើដើម្បីទូទាត់ថ្លៃចេញផ្សាយ មូលបត្របំណុលមុនពេលផ្ទេរទៅមូលនិធិទូទៅ។

998.762. មូលបត្របំណុលណាមួយដែលបានចេញផ្សាយ និងលក់ អនុលោមតាមអត្ថបទនេះ អាចត្រូវបានទូទាត់សងស្របតាមអត្ថបទទី 6 (ដោយចាប់ផ្តើមពីមាត្រាទី 16780) នៃ ជំពូកទី 4 នៃផ្នែកទី 3 នៃភាគទី 4 នៃចំណងជើងទី 2 នៃក្រមរដ្ឋាភិបាល។ ការអនុម័តរបស់អ្នកបោះឆ្នោត សម្រាប់ការចេញផ្សាយ មូលបត្របំណុលអនុលោមតាមអត្ថបទនេះ រួមបញ្ចូលទាំងការអនុម័តសម្រាប់ការចេញផ្សាយ មូលបត្របំណុលដែលត្រូវ បានចេញផ្សាយដើម្បីទូទាត់សង មូលបត្របំណុលដែលត្រូវបានចេញផ្សាយ ដំបូងក្រោមអត្ថបទនេះ ឬមូលបត្របំណុលទូទាត់សងណាមួយដែលបាន ចេញផ្សាយពីមុនមក។ មូលបត្របំណុលណាមួយដែលត្រូវបានសងដោយ ប្រើប្រាក់ដែលទទួលបានពីប័ណ្ណបំណុលសម្រាប់សងបំណុលចាស់ ដូចដែល បានអនុញ្ញាតដោយមាត្រានេះ អាចត្រូវបានរំលស់កាតព្វកិច្ចតាមផ្លូវច្បាប់ ក្នុង កម្រិតដែលច្បាប់អនុញ្ញាត និងតាមរបៀប និងក្នុងកម្រិតដែលបានកំណត់ក្នុង សេចក្តីសម្រេច ដែលត្រូវបានធ្វើវិសោធនកម្មតាមពេលចាំបាច់ ហើយដែល អនុញ្ញាតឱ្យចេញប័ណ្ណបំណុលដែលត្រូវបានសងនោះ។

998.763. ដោយមិនគិតពីបទបញ្ញត្តិណាមួយនៃច្បាប់ស្តីពីមូលបត្រ បំណុលកាតព្វកិច្ចទូទៅរបស់រដ្ឋ ឬនៃអត្ថបទនេះក៏ដោយ ប្រសិនបើហិរញ្ញិក លក់មូលបត្របំណុលអនុលោមតាម អត្ថបទនេះ ដែលមេធាវីផ្នែកមូលបត្រ បំណុលបានចេញមតិយោបល់បញ្ជាក់ថា ការប្រាក់លើមូលបត្របំណុល ទាំងនោះ ត្រូវបានលើកលែងមិនដាក់បញ្ចូលក្នុងចំណូលសរុបសម្រាប់ គោលបំណងពន្ធលើប្រាក់ចំណូលសហព័ន្ធ ក្រោមលក្ខខណ្ឌណាមួយដែល បានកំណត់ ឬមានសិទ្ធិទទួលបានអត្ថប្រយោជន៍ពន្ធសហព័ន្ធណាមួយ ផ្សេងទៀត ហិរញ្ញិកអាចរក្សាទុកនូវគណនីដាច់ដោយឡែកនានា សម្រាប់ ការវិនិយោគប្រាក់ចំណូលពីមូលបត្របំណុល និងសម្រាប់ប្រាក់ចំណេញ ពីប្រាក់ចំណូលទាំងនោះ ព្រមទាំងអាចប្រើប្រាស់ ឬចាត់ចែងឱ្យប្រើប្រាស់ ប្រាក់ចំណូល ឬប្រាក់ចំណេញទាំងនោះ ដើម្បីទូទាត់ប្រាក់បង្វិលសង ប្រាក់ពិន័យ ឬការទូទាត់ផ្សេងទៀតដែលត្រូវបានតម្រូវដោយច្បាប់សហព័ន្ធ ឬចាត់វិធានការផ្សេងទៀតណាមួយពាក់ព័ន្ធនឹងការវិនិយោគ និងការប្រើ ប្រាស់ប្រាក់ចំណូលពីមូលបត្របំណុលដែលត្រូវបានតម្រូវ ឬអនុញ្ញាត អនុលោមតាមច្បាប់សហព័ន្ធ ដែលមានភាពចាំបាច់ ឬសមគួរដើម្បីរក្សា ស្ថានភាពលើកលែងពន្ធនៃមូលបត្របំណុលទាំងនោះ ឬដើម្បីទទួលបាន អត្ថប្រយោជន៍ផ្សេងទៀតអនុលោមតាមច្បាប់សហព័ន្ធ ក្នុងនាមមូលនិធិនៃរដ្ឋ នេះ។

998.764. ប្រាក់ចំណូលដែលទទួលបានពីការលក់មូលបត្របំណុល ដែលត្រូវបានអនុញ្ញាតដោយ មាត្រានេះ មិនមែនជា "ប្រាក់ចំណូលពីពន្ធ" ដូចដែលពាក្យនេះត្រូវបានប្រើប្រាស់នៅក្នុងអត្ថបទ XIII B នៃរដ្ឋធម្មនុញ្ញរដ្ឋ California ឡើយ ហើយការបញ្ចេញប្រាក់ទាំងនេះមិនស្ថិតនៅក្រោមការ ដាក់កម្រិតដែលត្រូវបានកំណត់ដោយអត្ថបទ XIII B នោះទេ។ ប្រាក់ចំណូល នៃមូលបត្របំណុលក្រោម "សេចក្តីប្រកាសអំពីបំណង" ក្នុងចំនួនមិនលើសពី ចំនួនប្រាក់ដើមនៃប័ណ្ណបំណុលដែលត្រូវបានអនុញ្ញាតឱ្យចេញដោយអត្ថបទ នេះ(ដោយមិនរាប់បញ្ចូលនូវមូលបត្របំណុលទូទាត់សងណាមួយដែលបាន ចេញផ្សាយស្របតាមមាត្រាទី 998.762) ត្រូវបានរំពឹងទុក និងអាចត្រូវ បានប្រើប្រាស់ដើម្បីសងត្រលប់ទៅកាន់ប្រភពស្របច្បាប់ណាមួយដែលអាច ប្រើប្រាស់បាន ដែលត្រូវបានប្រើដើម្បីទូទាត់ការចំណាយលើគម្រោង ឬកម្ម វិធីនានា (រួមទាំងមូលនិធិរបស់ក្រសួង ឬទីភ្នាក់ងាររដ្ឋជាក់លាក់ដែលអាច ត្រូវបានចំណាយលើការចំណាយនៃគម្រោង ឬកម្មវិធីទាំងនោះ) ដែលត្រូវ បានអនុញ្ញាតអនុលោមតាមអត្ថបទនេះ និងត្រូវបានទូទាត់បន្ទាប់ពីថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2026 ប៉ុន្តែក្នុងលក្ខខណ្ឌដែលថា រាល់ការចំណាយដែលត្រូវ សងត្រលប់ពីប្រាក់ចំណូលនៃមូលបត្របំណុលមិនត្រូវបានទូទាត់ចេញពី ប្រាក់ចំណូលនៃបំណុលផ្សេងទៀតណាមួយឡើយ លើកលែងតែបំណុល មុននោះនឹងត្រូវបានសងបញ្ចប់ដោយប្រើប្រាស់ប្រាក់ចំណូលនៃ មូលបត្រ បំណុលទាំងនេះ។

2

សំណើ 2

វិសោធនកម្មនេះត្រូវបានស្នើឡើងដោយវិសោធនកម្មរដ្ឋធម្មនុញ្ញ 20 នៃសម័យប្រជុំសាមញ្ញ 2025-2026 (សេចក្តីសម្រេច ជំពូកទី 130 លក្ខន្តិក: ឆ្នាំ 2026) បញ្ជាក់យ៉ាងច្បាស់នូវវិសោធនកម្មរដ្ឋធម្មនុញ្ញរដ្ឋ California ដោយធ្វើវិសោធនកម្មលើមាត្រានានានៃរដ្ឋធម្មនុញ្ញនេះ។ ដូច្នេះហើយ បទបញ្ញត្តិដែលមានស្រាប់ដែលស្នើឱ្យលុបត្រូវបានបោះពុម្ពក្នុងប្រភេទទម្រង់ ~~គូសឆូតចោល~~ ហើយបទប្បញ្ញត្តិថ្មីដែលស្នើឱ្យបន្ថែមត្រូវបានបោះពុម្ពជាប្រភេទ*អក្សរទ្រេត* ដើម្បីបញ្ជាក់ថាបទបញ្ញត្តិទាំងនោះថ្មី។

វិសោធនកម្មស្នើឡើងចំពោះអត្ថបទ XVI

ទីមួយ—(a) វិធានការនេះត្រូវបានស្គាល់ និង អាចហៅថា ច្បាប់ស្តីពីការសន្សំសម្រាប់អនាគតរបស់រដ្ឋ California។

(b) ស្ថាប័ននីតិបញ្ញត្តិយល់ឃើញ និងប្រកាសនូវរាល់ចំណុចទាំងអស់ដូចខាងក្រោម៖

(1) គ្រួសារនៅរដ្ឋ California យល់ថា ការរៀបចំផែនការហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ ទាមទារឱ្យមានការសន្សំប្រាក់ទុកក្នុងអំឡុងពេលមានអំណោយផល ដើម្បីត្រៀមខ្លួនសម្រាប់បញ្ហាប្រឈមដែលមិននឹកស្មានដល់ និងការធ្លាក់ចុះនៃសេដ្ឋកិច្ច។ រដ្ឋ California គួរតែអនុវត្តតាមគោលការណ៍ដែលសមហេតុផលដូចគ្នានេះ។

(2) ប្រជាពលរដ្ឋ California រំពឹងថារដ្ឋាភិបាលរបស់ខ្លួន នឹងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយការទទួលខុសត្រូវ ភាពប្រុងប្រយ័ត្ន និងដោយគិតគូរដល់មនុស្សជំនាន់ក្រោយ។ ការរក្សាទុកប្រាក់បម្រុងឱ្យបានគ្រប់គ្រាន់ ជួយធានាថាសេវាសាធារណៈចាំបាច់នានា នៅតែមានផ្តល់ជូនបាន នៅពេលដែលមានការចាំបាច់បំផុត។

(3) សេដ្ឋកិច្ចរបស់រដ្ឋ California គឺជាសេដ្ឋកិច្ចធំបំផុត និងមានសក្តានុពលបំផុតមួយនៅលើពិភពលោក ប៉ុន្តែវាក៏ងាយរងឥទ្ធិពលពីវដ្តសេដ្ឋកិច្ច ការប្រែប្រួលនៃចំណូល គ្រោះមហន្តរាយធម្មជាតិ ភាពអាសន្នផ្នែកសុខភាពសាធារណៈ និងព្រឹត្តិការណ៍ដែលមិនអាចដឹងមុនផ្សេងទៀត ដែលអាចដាក់បន្ទុកយ៉ាងធ្ងន់ធ្ងរដល់ថវិការដ្ឋ។

(4) នៅពេលដែលចំណូលរដ្ឋធ្លាក់ចុះក្នុងអំឡុងពេលសេដ្ឋកិច្ចធ្លាក់ចុះ ការដែលមិនបម្រុងទុកគ្រប់គ្រាន់អាចបង្ខំឱ្យមានជម្រើសដ៏លំបាកនានា ដែលរំខានដល់កម្មវិធី និងសេវាកម្មចាំបាច់នានា ដែលគ្រួសារ សិស្សានុសិស្ស ចាស់ជរា អតីតយុទ្ធជន កម្មករ និងអាជីវកម្មនានានៅក្នុងរដ្ឋ California កំពុងពឹងផ្អែក។

(5) ការកសាង និងថែរក្សាប្រាក់បម្រុងឱ្យបានរឹងមាំ ក្នុងអំឡុងពេលនៃកំណើនសេដ្ឋកិច្ច ជួយការពារប្រជាពលរដ្ឋ California ពីការកាត់បន្ថយភ្លាមៗនូវសេវាកម្មចាំបាច់នានា និងកាត់បន្ថយតម្រូវការសម្រាប់វិធានការកែតម្រូវធ្ងន់ធ្ងរ ក្នុងអំឡុងពេលមានបញ្ហាផ្នែកហិរញ្ញវត្ថុ។

(6) ការរៀបចំផែនការហិរញ្ញវត្ថុដ៏រឹងមាំ ទាមទារឱ្យមានការសំឡឹងមើលឱ្យឆ្ងាយជាងឆ្នាំសារពើពន្ធបន្ទាប់ និងការត្រៀមខ្លួនសម្រាប់បញ្ហាប្រឈមនាពេលអនាគត មុនពេលបញ្ហាទាំងនោះកើតឡើង។ ដូចគ្នាទៅនឹងគ្រួសារដែលសន្សំប្រាក់សម្រាប់ភាពអាសន្ន និងការចំណាយដែលមិននឹកស្មានដល់ រដ្ឋ California គួរតែសន្សំប្រាក់ក្នុងអំឡុងឆ្នាំដ៏ល្អ ដើម្បីការពារសាលារៀន សុវត្ថិភាពសាធារណៈ និងសេវាកម្មចាំបាច់នានា ក្នុងអំឡុងពេលដ៏លំបាក។

(7) គោលនយោបាយប្រាក់បម្រុងដ៏រឹងមាំ ជំរុញឱ្យមានស្ថិរភាពហិរញ្ញវត្ថុ លើកកម្ពស់ទំនុកចិត្តរបស់សាធារណជនទៅលើរដ្ឋាភិបាលរដ្ឋ គាំទ្រដល់កំណើនសេដ្ឋកិច្ចរយៈពេលវែង និងជួយរក្សាសមត្ថភាពរបស់រដ្ឋ California ក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះភាពអាសន្ន និងការធ្លាក់ចុះនៃសេដ្ឋកិច្ច។

(8) សំណើទី 98 ត្រូវបានអនុម័តដោយអ្នកបោះឆ្នោតក្នុងឆ្នាំ 1988 ដើម្បីផ្តល់កម្រិតមូលនិធិអប្បបរមាសម្រាប់សាលារៀននានា។ គ្មានចំណុចណាមួយនៅក្នុងច្បាប់នេះ មានគោលបំណងផ្លាស់ប្តូរការគណនា ឬការផ្តល់មូលនិធិនៃការធានាអប្បបរមាក្រោមមាត្រាទី 8 នៃអត្ថបទ XVI នោះទេ។

(c) ហេតុដូច្នេះហើយ វាគឺជាចេតនារបស់ស្ថាប័ននីតិបញ្ញត្តិ ក្នុងការពង្រឹងការប្តេជ្ញាចិត្តរបស់រដ្ឋចំពោះការរៀបចំថវិកាប្រកបដោយការទទួលខុសត្រូវ ការរៀបចំផែនការហិរញ្ញវត្ថុរយៈពេលវែង និងការសន្សំប្រាក់ប្រកបដោយភាពប្រុងប្រយ័ត្ន តាមរយៈការបង្កើនប្រាក់បម្រុងរបស់រដ្ឋ California និងការធានាថារដ្ឋមានការត្រៀមខ្លួនបានកាន់តែល្អប្រសើរសម្រាប់បញ្ហាប្រឈមសេដ្ឋកិច្ចនាពេលអនាគត។ ការពង្រឹងប្រាក់បម្រុង គឺជាការវិនិយោគទៅលើអនាគតរបស់រដ្ឋ California និង មនុស្សជំនាន់ក្រោយ។

ទីពីរ—មាត្រាទី 20 នៃអត្ថបទ XVI នេះត្រូវបានធ្វើវិសោធនកម្ម មានខ្លឹមសារដូចខាងក្រោម៖

មាត្រាទី 20. (a) (1) *(A)* គណនីស្ថិរភាពថវិកា ត្រូវបានបង្កើតឡើងនៅទីនេះ នៅក្នុងមូលនិធិទូទៅ។

(B) សមតុល្យដែលបានតម្កល់នៅក្នុងគណនីស្ថិរភាពថវិកា អនុលោមតាមកថាខណ្ឌ (2) នៃផ្នែករង (a) នេះ និងផ្នែករង (c) និង (d) មុនកាលបរិច្ឆេទចូលជាធរមាននៃវិធានការដែលបន្ថែមចូលកថាខណ្ឌរងនេះ ត្រូវរក្សាទុកនៅក្នុងគណនី ហើយត្រូវផ្ទេរ ដក ឬកែតម្រូវនៅពេលបន្ទាប់ អនុលោមតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញនេះ ដូចដែលបានធ្វើវិសោធនកម្មដោយវិធានការដែលបន្ថែមចូលកថាខណ្ឌនេះ។

(2) សម្រាប់ឆ្នាំសារពើពន្ធ ~~2015–16~~ *2027–28* និងរាល់ឆ្នាំសារពើពន្ធបន្ទាប់ពីនោះ ដោយផ្អែកលើច្បាប់ស្តីពីថវិកាសម្រាប់ឆ្នាំសារពើពន្ធ អគ្គនាយកគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋត្រូវផ្ទេរពីមូលនិធិទូទៅទៅកាន់គណនីស្ថិរភាពថវិកាយ៉ាងយូរបំផុតត្រឹមថ្ងៃទី 1 ខែតុលា នូវចំនួនទឹកប្រាក់ស្មើនឹង 1.5 ភាគរយ នៃចំនួនប៉ាន់ស្មាននៃចំណូលមូលនិធិទូទៅសម្រាប់ឆ្នាំសារពើពន្ធនោះ។

(b) (1) សម្រាប់ឆ្នាំសារពើពន្ធ ~~2015–16~~ *2027–28* និងរាល់ឆ្នាំសារពើពន្ធបន្ទាប់ពីនោះ ដោយផ្អែកលើច្បាប់ថវិកាសម្រាប់ឆ្នាំសារពើពន្ធ ក្រសួងហិរញ្ញវត្ថុត្រូវផ្តល់ជូនស្ថាប័ននីតិបញ្ញត្តិ នូវព័ត៌មានទាំងអស់ដូចខាងក្រោម៖

(A) ការប៉ាន់ស្មានអំពីចំនួនប្រាក់ចំណូលពីពន្ធរបស់មូលនិធិទូទៅ ដែលអាចត្រូវបានអនុម័តឱ្យប្រើប្រាស់អនុលោមតាមអត្ថបទ XIII B សម្រាប់ឆ្នាំសារពើពន្ធនោះ។

(B) (i) ការប៉ាន់ស្មាននៃផ្នែកណាមួយនៃប្រាក់ចំណូលពីពន្ធនៃមូលនិធិទូទៅ ដែលបានកំណត់នៅក្នុងកថាខណ្ឌរង (A) ដែលទទួលបានពីពន្ធលើប្រាក់ចំណូលបុគ្គល ដែលបានបង់លើចំណេញមូលធនសុទ្ធ។

(ii) ចំនួនទឹកប្រាក់សរុបនៃចំណុចខាងក្រោម។

~~(ii)~~ *(I)* ផ្នែកនៃការប៉ាន់ស្មានក្នុងប្រការ (i) ដែល ~~លើសពី 8 ភាគរយនៃ~~ *គឺលើសពី 8 ភាគរយ ប៉ុន្តែមិនលើសពី 10 ភាគរយនៃការប៉ាន់ស្មាន* ដែលធ្វើឡើងក្រោមកថាខណ្ឌរង (A)។

(II) មួយរយហាសិបភាគរយនៃផ្នែកនៃការប៉ាន់ស្មាននៅក្នុងប្រការ (i) ដែលលើសពី 10 ភាគរយ នៃការប៉ាន់ស្មានដែលបានធ្វើឡើងក្រោមកថាខណ្ឌរង (A)។

(C) ផ្នែកនៃកាតព្វកិច្ចផ្តល់មូលនិធិរបស់រដ្ឋក្រោមផ្នែកទី 8 ដែលជាលទ្ធផលបានមកពីការដាក់បញ្ចូលចំនួនទឹកប្រាក់ដែលបានគណនាក្រោមប្រការ (ii) នៃកថាខណ្ឌរង (B) ជាប្រាក់ចំណូលពីពន្ធនៃមូលនិធិទូទៅ ប្រសិនបើមាន។

(D) ចំនួនទឹកប្រាក់នៃការអនុម័តឱ្យប្រើប្រាស់ណាមួយ ដែលបានរៀបរាប់នៅក្នុងប្រការ (ii) នៃកថាខណ្ឌរង (B) នៃកថាខណ្ឌ (1) នៃ ឬផ្នែករង (C) នៃកថាខណ្ឌ (2) នៃ ផ្នែករង (c) ដែលត្រូវបានធ្វើឡើងពីប្រាក់ចំណូល ដែលបានរៀបរាប់នៅក្នុងប្រការ (ii) នៃកថាខណ្ឌរង (B) នៃកថាខណ្ឌនេះ។

(E) ចំនួនទឹកប្រាក់ដែលជាលទ្ធផលនៃការដកតម្លៃរួមបញ្ចូលគ្នា ដែលបានគណនាក្រោមកថាខណ្ឌរង (C) និង (D) ចេញពីតម្លៃដែលបានគណនាក្រោមប្រការ (ii) នៃកថាខណ្ឌរង (B)។ ប្រសិនបើតិចជាងសូន្យ ចំនួនទឹកប្រាក់នោះត្រូវចាត់ទុកថាសូន្យ សម្រាប់គោលបំណងនេះ។

(F) ចំនួនដែលតិចជាង ក្នុងចំណោមចំនួនទឹកប្រាក់ដែលបានគណនាក្រោមកថាខណ្ឌរង (E) ឬចំនួនទឹកប្រាក់នៃការផ្ទេរដែលធ្វើឱ្យសមតុល្យ

នៅក្នុងគណនីស្ថិរភាពថវិកាឈានដល់កម្រិតដែលបានបញ្ជាក់នៅក្នុងផ្នែករង (e)។

(2) នៅក្នុងឆ្នាំសារពើពន្ធ ~~2016–17~~ *2027–28* ពាក់ព័ន្ធនឹងឆ្នាំសារពើពន្ធ ~~2015–16~~ *2026–27* តែប៉ុណ្ណោះ និងនៅក្នុងឆ្នាំសារពើពន្ធ ~~2017–18~~ *2028–29* និងរាល់ឆ្នាំសារពើពន្ធបន្ទាប់ពីនោះ ដោយឡែកពីគ្នាពាក់ព័ន្ធនឹងឆ្នាំសារពើពន្ធនីមួយៗក្នុងចំណោមឆ្នាំសារពើពន្ធពីរឆ្នាំបន្ទាប់ ក្រសួងហិរញ្ញវត្ថុត្រូវគណនាចំនួនទាំងអស់ដូចខាងក្រោម ដោយប្រើប្រាស់វិធីសាស្ត្រដូចគ្នាដែលត្រូវបានប្រើសម្រាប់ឆ្នាំសារពើពន្ធពាក់ព័ន្ធនោះ និងត្រូវផ្តល់ការគណនាទាំងនោះជូនស្ថាប័ននីតិបញ្ញត្តិ៖

(A) ការប៉ាន់ស្មានដែលបានធ្វើបច្ចុប្បន្នភាពអំពីចំនួនប្រាក់ចំណូលពីពន្ធរបស់មូលនិធិទូទៅ ដែលអាចត្រូវបានអនុម័តឱ្យប្រើប្រាស់អនុលោមតាមអត្ថបទ XIII B។

(B) (i) ការប៉ាន់ស្មានដែលបានធ្វើបច្ចុប្បន្នភាពនៃផ្នែកណាមួយនៃប្រាក់ចំណូលពីពន្ធនៃមូលនិធិទូទៅ ដែលបានកំណត់នៅក្នុងកថាខណ្ឌរង (A) ដែលទទួលបានពីពន្ធលើប្រាក់ចំណូលបុគ្គល ដែលបានបង់លើចំណេញមូលធនសុទ្ធ។

(ii) ចំនួនទឹកប្រាក់សរុបនៃចំណុចខាងក្រោម។

~~(ii)~~ *(I)* ផ្នែកនៃការប៉ាន់ស្មានក្នុងប្រការ (i) ដែល ~~លើសពី 8 ភាគរយនៃ~~ *គឺលើសពី 8 ភាគរយ ប៉ុន្តែមិនលើសពី 10 ភាគរយនៃការប៉ាន់ស្មាន* ដែលបានធ្វើបច្ចុប្បន្នភាពដោយធ្វើឡើងក្រោមកថាខណ្ឌរង (A)។

(II) មួយរយហាសិបភាគរយនៃផ្នែកនៃការប៉ាន់ស្មាននៅក្នុងប្រការ (i) ដែលលើសពី 10 ភាគរយ នៃការប៉ាន់ស្មានដែលបានធ្វើឡើងក្រោមកថាខណ្ឌរង (A)។

(C) ការគណនាដែលបានធ្វើបច្ចុប្បន្នភាពនៃផ្នែកនៃកាតព្វកិច្ចផ្តល់មូលនិធិរបស់រដ្ឋក្រោមមាត្រាទី 8 ដែលជាលទ្ធផលបានមកពីការធ្វើបច្ចុប្បន្នភាពចំនួនទឹកប្រាក់ដែលបានគណនាក្រោមប្រការ (ii) នៃកថាខណ្ឌរង (B) ជាប្រាក់ចំណូលពីពន្ធនៃមូលនិធិទូទៅ ប្រសិនបើមាន។

(D) ចំនួនទឹកប្រាក់នៃការអនុម័តឱ្យប្រើប្រាស់ណាមួយ ដែលបានរៀបរាប់នៅក្នុងប្រការ (ii) នៃកថាខណ្ឌរង (B) នៃកថាខណ្ឌ (1) នៃ ឬផ្នែករង (C) នៃកថាខណ្ឌ (2) នៃ ផ្នែករង (c) ដែលត្រូវបានធ្វើឡើងពីប្រាក់ចំណូល ដែលបានរៀបរាប់នៅក្នុងប្រការ (ii) នៃកថាខណ្ឌរង (B) នៃកថាខណ្ឌ (1)។

(E) ចំនួនទឹកប្រាក់ដែលជាលទ្ធផលនៃការដកតម្លៃរួមបញ្ចូលគ្នា ដែលបានគណនាក្រោមកថាខណ្ឌរង (C) និង (D) ចេញពីតម្លៃដែលបានគណនាក្រោមប្រការ (ii) នៃកថាខណ្ឌរង (B)។ ប្រសិនបើតិចជាងសូន្យ ចំនួនទឹកប្រាក់នោះត្រូវចាត់ទុកថាសូន្យ សម្រាប់គោលបំណងនេះ។

(F) ចំនួនទឹកប្រាក់ដែលបានផ្ទេរពីមុនសម្រាប់ឆ្នាំសារពើពន្ធនោះដោយអគ្គនាយកគ្រប់គ្រងហិរញ្ញវត្ថុពីមូលនិធិទូទៅទៅកាន់គណនីស្ថិរភាពថវិកាអនុលោមតាមផ្នែករង (c) និង (d)។

(G) ចំនួនដែលតិចជាង (i) ចំនួនទឹកប្រាក់ ដែលមិនតិចជាងសូន្យ ដែលជាលទ្ធផលបានមកពីការដកចេញពីចំនួនទឹកប្រាក់ដែលបានគណនាក្រោមកថាខណ្ឌរង (E) នូវតម្លៃនៃការផ្អាក ឬការកាត់បន្ថយការផ្ទេរណាមួយអនុលោមតាមកថាខណ្ឌ (1) នៃ ផ្នែករង (a) នៃមាត្រាទី 22 ដែលត្រូវបានអនុម័តពីមុនដោយស្ថាប័ននីតិបញ្ញត្តិសម្រាប់ឆ្នាំសារពើពន្ធពាក់ព័ន្ធ និងចំនួនទឹកប្រាក់ដែលបានផ្ទេរពីមុនសម្រាប់ឆ្នាំសារពើពន្ធនោះដោយអគ្គនាយកគ្រប់គ្រងហិរញ្ញវត្ថុ ដូចដែលបានរៀបរាប់ក្នុងកថាខណ្ឌរង (F) ឬ (ii) ចំនួនទឹកប្រាក់នៃការផ្ទេរដែលធ្វើឱ្យសមតុល្យនៅក្នុងគណនីស្ថិរភាពថវិកា ឈានដល់កម្រិតដូចដែលបានបញ្ជាក់នៅក្នុង ផ្នែករង (e)។

(c) (1) (A) ត្រឹមថ្ងៃទី 1 ខែតុលា នៃឆ្នាំសារពើពន្ធ ~~2015–16~~ *2027–28* និងរាល់ឆ្នាំសារពើពន្ធបន្ទាប់ពីនោះ ដោយរាប់បញ្ចូលទាំងឆ្នាំសារពើពន្ធ ~~2029–30~~ *2039–40* ដោយផ្អែកលើការប៉ាន់ស្មានដែលបានចែងនៅក្នុងច្បាប់ថវិកាប្រចាំឆ្នាំ អនុលោមតាមកថាខណ្ឌ (2) និង (3) នៃផ្នែករង (h) និងចំនួនទឹកប្រាក់ដែលបានកំណត់នៅក្នុងកថាខណ្ឌ (2) នៃផ្នែករង (a) អគ្គនាយកគ្រប់គ្រងហិរញ្ញវត្ថុត្រូវផ្ទេរចំនួនទឹកប្រាក់ពីមូលនិធិទូទៅ និងគណនីស្ថិរភាពថវិកា អនុលោមតាមកាលវិភាគដែលផ្តល់ដោយនាយកហិរញ្ញវត្ថុ ដូចដែលបានចែងនៅក្នុងកថាខណ្ឌរង (B)។

(B) ដោយមិនគិតបីបទបញ្ញត្តិផ្សេងទៀតណាមួយនៃ មាត្រានេះក៏ដោយ នៅក្នុងឆ្នាំសារពើពន្ធដែលច្បាប់ថវិកាបានកំណត់ក្នុងកថាខណ្ឌរង (A) អនុវត្តចំពោះ៖

(i) ហាសិបភាគរយនៃចំនួនទាំងពីរដែលបានកំណត់ទាំងនៅក្នុងកថាខណ្ឌ (2) នៃផ្នែករង (a) និងចំនួនទឹកប្រាក់ដែលជាលទ្ធផលបានមកពីការដកតម្លៃដែលបានគណនាក្រោមកថាខណ្ឌរង (C) នៃកថាខណ្ឌ (1) នៃផ្នែករង (b) ចេញពីតម្លៃដែលបានគណនាក្រោមប្រការ (ii) នៃកថាខណ្ឌរង (B) នៃកថាខណ្ឌ (1) នៃផ្នែករង (b) ត្រូវផ្ទេរពីមូលនិធិទូទៅទៅកាន់គណនីស្ថិរភាពថវិកា។

(ii) 50 ភាគរយដែលនៅសល់ ត្រូវអនុម័តឱ្យប្រើប្រាស់ដោយស្ថាប័ននីតិបញ្ញត្តិ សម្រាប់កាតព្វកិច្ច និងគោលបំណងណាមួយ ឬច្រើន ដូចខាងក្រោម៖

(I) កាតព្វកិច្ចមូលនិធិទូទៅក្នុងឆ្នាំសារពើពន្ធមុនៗដែលមិនមានមូលនិធិអនុលោមតាមមាត្រាទី ~~8 ដែលមានស្រាប់នៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2014។~~ *8*។

(II) កម្ចីថវិកាសម្រាប់មូលនិធិទូទៅពីមូលនិធិនានានៅក្រៅមូលនិធិទូទៅ ~~ដែលមានសមតុល្យមិនទាន់ទូទាត់សងនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2014។~~ *ព្រមទាំងការទទួលស្គាល់មុនកាលកំណត់នូវការចំណាយលើកម្ចីដែលបានផ្តល់ឱ្យមូលនិធិទូទាត់បណ្តោះអាសន្នសម្រាប់គ្រូពេទ្យ និងការទទួលស្គាល់មុនកាលកំណត់នូវការចំណាយដែលបានរៀបរាប់ក្នុងកថាខណ្ឌ (1) នៃផ្នែករង (c) នៃមាត្រាទី 41206.04 នៃក្រមអប់រំ។*

(III) ការទាមទារទូទាត់សងសម្រាប់ថ្លៃចំណាយដែលត្រូវបានកំណត់ឱ្យទទួលខុសត្រូវ ដែលបានកើតឡើងមុនឆ្នាំសារពើពន្ធ 2004–05 ដែលមិនទាន់ត្រូវបានទូទាត់នៅឡើយ ហើយដែលអនុលោមតាមកថាខណ្ឌ (2) នៃផ្នែករង (b) នៃមាត្រាទី 6 នៃអត្ថបទ XIII B ត្រូវបានអនុញ្ញាតឱ្យទូទាត់ក្នុងរយៈពេលជាច្រើនឆ្នាំ ដូចដែលបានកំណត់ដោយច្បាប់។

(IV) បំណុលដែលគ្មានមូលនិធិគ្រប់គ្រាន់ សម្រាប់គម្រោងសោធននិវត្តន៍ថ្នាក់រដ្ឋ និងការផ្តល់មូលនិធិជាមុនសម្រាប់អត្ថប្រយោជន៍ផ្សេងទៀតក្រោយពេលបញ្ចប់ការងារ ដែលលើសពីចំនួនគោលបច្ចុប្បន្ន ដូចដែលបានកំណត់សម្រាប់ឆ្នាំសារពើពន្ធ បើមិនដូច្នេះទេ មូលនិធិនោះនឹងត្រូវផ្ទេរទៅគណនីស្ថិរភាពថវិកា។ សម្រាប់គោលបំណងនៃប្រការរងនេះ ចំនួនគោលបច្ចុប្បន្ន គឺជាចំនួនដែលតម្រូវឱ្យទូទាត់អនុលោមតាមច្បាប់ អនុស្សរណៈនៃការយោគយល់គ្នាដែលត្រូវបានយល់ព្រម អត្ថប្រយោជន៍កាលវិភាគដែលបង្កើតឡើងដោយនិយោជក ឬអង្គភាពដែលត្រូវបានអនុញ្ញាតឱ្យកំណត់ការបង់វិភាគទានទាំងនោះសម្រាប់និយោជិតដែលត្រូវបានដកចេញ ឬលើកលែងពីការចរចាជាសមូហភាព ឬការរួមបញ្ចូលណាមួយនៃចំណុចទាំងនេះ។ ដើម្បីមានសិទ្ធិទទួលបានក្រោមប្រការរងនេះ ការអនុម័តឱ្យប្រើប្រាស់ថវិកា ត្រូវបន្ថែម ហើយមិនត្រូវជំនួសថវិកាដែលនឹងត្រូវបានផ្តល់ជូនក្នុងករណីធម្មតា ដើម្បីទូទាត់កាតព្វកិច្ចដែលបានពណ៌នានៅក្នុងចំណុចរងនេះ សម្រាប់ឆ្នាំសារពើពន្ធបច្ចុប្បន្ន ឬឆ្នាំសារពើពន្ធបន្ទាប់ឡើយ។

2

(V) ប្រាក់កម្ចីរបស់សហព័ន្ធដែលបានផ្តល់ដល់មូលនិធិសម្រាប់អ្នកអត់ការងារធ្វើ។

(iii) ប្រសិនបើចំនួនថវិកាដែលត្រូវបានអនុម័តអោយប្រើប្រាស់អនុលោមតាមប្រការ (ii) លើសពីចំនួនសរុបនៃកាតព្វកិច្ច និងគោលបំណងដែលបានពណ៌នានៅក្នុងប្រការ (ii) នោះចំនួនដែលនៅសល់ត្រូវផ្ទេរទៅគណនីស្ថិរភាពថវិកា លើកលែងតែការផ្ទេរបែបនេះត្រូវស្ថិតក្រោមការកំណត់ក្នុងផ្នែករង (e)។

(2) (A) ត្រឹមថ្ងៃទី 1 ខែតុលា នៃឆ្នាំសារពើពន្ធ ~~2030-31~~ *2040-41* និងរាល់ឆ្នាំសារពើពន្ធបន្ទាប់ពីនោះ ដោយផ្អែកលើការប៉ាន់ស្មានដែលបានចែងនៅក្នុងច្បាប់ថវិកាប្រចាំឆ្នាំ អនុលោមតាមកថាខណ្ឌ (2) និង (3) នៃផ្នែករង (h) អគ្គនាយកគ្រប់គ្រងហិរញ្ញវត្ថុត្រូវផ្ទេរចំនួនទឹកប្រាក់ពីមូលនិធិទូទៅទៅកាន់គណនីស្ថិរភាពថវិកា អនុលោមតាមកាលវិភាគដែលផ្តល់ដោយនាយកហិរញ្ញវត្ថុ ដូចដែលបានចែងនៅក្នុងកថាខណ្ឌរង (B)។

(B) ក្នុងឆ្នាំសារពើពន្ធដែលច្បាប់ថវិកាបានកំណត់ក្នុងកថាខណ្ឌរង (A) អនុវត្តចំពោះ ចំនួនទឹកប្រាក់ដែលបានកំណត់ទាំងនៅក្នុងកថាខណ្ឌ (2) នៃផ្នែករង (a) និងចំនួនទឹកប្រាក់ដែលជាលទ្ធផលបានមកពីការដកតម្លៃដែលបានគណនាក្រោមកថាខណ្ឌរង (C) នៃកថាខណ្ឌ (1) នៃផ្នែករង (b) ចេញពីតម្លៃដែលបានគណនាក្រោមប្រការ (ii) នៃកថាខណ្ឌរង (B) នៃកថាខណ្ឌ (1) នៃផ្នែករង (b) ត្រូវផ្ទេរពីមូលនិធិទូទៅទៅកាន់គណនីស្ថិរភាពថវិកា។

(C) ទោះជាមានបទប្បញ្ញត្តិផ្សេងទៀតណាមួយនៃមាត្រានេះក៏ដោយ ស្ថាប័ននីតិប្បញ្ញត្តិអាចអនុម័តឱ្យប្រើប្រាស់ថវិកាបានរហូតដល់ 50 ភាគរយនៃចំនួនទឹកប្រាក់ដែលបានកំណត់ក្នុងកថាខណ្ឌ (2) នៃផ្នែករង (a) និងចំនួនទឹកប្រាក់ដែលទទួលបានពីការដកតម្លៃដែលបានគណនាតាមកថាខណ្ឌរង (C) នៃកថាខណ្ឌ (1) នៃផ្នែករង (b) ចេញពីតម្លៃដែលបានគណនាក្រោមប្រការ (ii) នៃកថាខណ្ឌរង (B) នៃកថាខណ្ឌ (1) នៃផ្នែករង (b) ដើម្បីបំពេញកាតព្វកិច្ច និងគោលបំណងមួយ ឬច្រើនដែលបានពណ៌នានៅក្នុងប្រការ (ii) នៃកថាខណ្ឌរង (B) នៃកថាខណ្ឌ (1)។

(3) ការផ្ទេរប្រាក់ដែលបានពណ៌នានៅក្នុងផ្នែករងនេះ ត្រូវរផ្អាក ឬកាត់បន្ថយ អនុលោមតាមកថាខណ្ឌ (1) នៃផ្នែករង (a) នៃមាត្រាទី 22។

(d) ត្រឹមថ្ងៃទី 1 ខែតុលា នៃឆ្នាំសារពើពន្ធ ~~2016-17~~ *2027-28* និងរាល់ឆ្នាំសារពើពន្ធបន្ទាប់ពីនោះ ដោយផ្អែកលើការប៉ាន់ស្មានដែលបានចែងនៅក្នុងច្បាប់ថវិកាប្រចាំឆ្នាំ អនុលោមតាមកថាខណ្ឌ (4) និង (5) នៃផ្នែករង (h) អគ្គនាយកគ្រប់គ្រងហិរញ្ញវត្ថុត្រូវផ្ទេរចំនួនទឹកប្រាក់រវាងមូលនិធិទូទៅ និងគណនីស្ថិរភាពថវិកា អនុលោមតាមកាលវិភាគដែលផ្តល់ដោយនាយកហិរញ្ញវត្ថុ ដូចខាងក្រោម៖

(1) ប្រសិនបើចំនួនទឹកប្រាក់នៅក្នុងកថាខណ្ឌរង (G) នៃកថាខណ្ឌ (2) នៃផ្នែករង (b) ធំជាងសូន្យ ត្រូវផ្ទេរចំនួនទឹកប្រាក់ពីមូលនិធិទូទៅទៅកាន់គណនីស្ថិរភាពថវិកា ដោយស្ថិតក្រោមការផ្អាក ឬការកាត់បន្ថយណាមួយនៃការផ្ទេរនេះ អនុលោមតាមកថាខណ្ឌ (1) នៃផ្នែករង (a) នៃមាត្រាទី 22។

(2) ប្រសិនបើចំនួនទឹកប្រាក់ដែលបានរៀបរាប់នៅក្នុង កថាខណ្ឌរង (F) នៃកថាខណ្ឌ (2) នៃផ្នែករង (b) ធំជាងចំនួនទឹកប្រាក់ដែលបានគណនាក្រោមកថាខណ្ឌរង (E) នៃកថាខណ្ឌ (2) នៃផ្នែករង (b) ត្រូវផ្ទេរចំនួនទឹកប្រាក់ដែលលើសនោះពីគណនីស្ថិរភាពថវិកា ត្រលប់ទៅកាន់មូលនិធិទូទៅវិញ។

(e) ដោយមិនគិតពីបទបញ្ញត្តិផ្សេងទៀតណាមួយនៃ មាត្រានេះក៏ដោយ ចំនួនទឹកប្រាក់នៃការផ្ទេរទៅកាន់គណនីស្ថិរភាពថវិកា អនុលោមតាមកថាខណ្ឌ (2) នៃផ្នែករង (a) និងផ្នែករង (c) និង (d) សម្រាប់ឆ្នាំសារពើពន្ធណាមួយ មិនត្រូវលើសពីចំនួនទឹកប្រាក់ដែលនឹងធ្វើឱ្យសមតុល្យនៅក្នុងគណនីនោះលើសពី ~~10~~ *20* ភាគរយ នៃចំនួនទឹកប្រាក់ចំណូលពីពន្ធនៃមូលនិធិទូទៅសម្រាប់ឆ្នាំសារពើពន្ធដែលបានប៉ាន់ស្មានស្របតាមផ្នែករង (b) ឡើយ។ សម្រាប់ឆ្នាំសារពើពន្ធណាមួយ ប្រាក់ចំណូលពីពន្ធនៃមូលនិធិទូទៅដែលមិនមានចែងក្នុងថាខណ្ឌនេះទេ នឹងត្រូវបានផ្ទេរទៅកាន់គណនីស្ថិរភាពថវិកា អាចត្រូវបានចំណាយសម្រាប់តែហេដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះ ដូចដែលបានកំណត់ដោយមាត្រា 13101 នៃក្រមរដ្ឋាភិបាល យោងតាមខ្លឹមសារនៃមាត្រានោះដែលមានសុពលភាពនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2014 រួមទាំងការថែទាំដែលបានពន្យារពេលលើហេដ្ឋារចនាសម្ព័ន្ធនោះ។

(f) មូលនិធិដែលបានរៀបរាប់នៅក្នុងផ្នែករង (b) ថាជាប្រាក់ចំណូលពីពន្ធនៃមូលនិធិទូទៅ គឺជាប្រាក់ចំណូលពីពន្ធនៃមូលនិធិទូទៅ សម្រាប់គោលបំណងនៃមាត្រាទី 8 សម្រាប់ឆ្នាំសារពើពន្ធដែលប្រាក់ចំណូលទាំងនោះត្រូវបានចាត់ចែងឱ្យ ប៉ុន្តែមិនត្រូវចាត់ទុកថាជាប្រាក់ចំណូលពីពន្ធនៃមូលនិធិទូទៅបន្ថែម ដោយផ្អែកលើមូលដ្ឋានដែលថាមូលនិធិទាំងនោះ ត្រូវបានផ្ទេរនៅពេលក្រោយពីគណនីស្ថិរភាពថវិកាទៅកាន់មូលនិធិទូទៅឡើយ។

(g) មន្ត្រីត្រួតពិនិត្យអាចប្រើប្រាស់មូលនិធិនៅក្នុងគណនីស្ថិរភាពថវិកា ដែលគាត់កំណត់ថាបច្ចុប្បន្នមិនមានភាពចាំបាច់ សម្រាប់គោលបំណងនៃមាត្រានេះ ដើម្បីជួយគ្រប់គ្រងតម្រូវការលំហូរសាច់ប្រាក់ប្រចាំថ្ងៃរបស់មូលនិធិទូទៅ។ រាល់ការប្រើប្រាស់ណាមួយអនុលោមតាមផ្នែករងនេះ មិនត្រូវធ្វើឱ្យប៉ះពាល់ដល់គោលបំណងនៃគណនីស្ថិរភាពថវិកាឡើយ។

(h) ច្បាប់ថវិកាប្រចាំឆ្នាំ ត្រូវរួមបញ្ចូលការប៉ាន់ស្មានដែលបានរៀបរាប់ទាំងអស់ដូចខាងក្រោម៖

(1) កថាខណ្ឌ (2) នៃផ្នែករង (a)។

(2) ប្រការ (ii) នៃកថាខណ្ឌរង (B) នៃកថាខណ្ឌ (1) នៃផ្នែករង (b)។

(3) កថាខណ្ឌរង (F) នៃកថាខណ្ឌ (1) នៃផ្នែករង (b)។

(4) ប្រការ (ii) នៃកថាខណ្ឌរង (B) នៃកថាខណ្ឌ (2) នៃផ្នែករង (b)។

(5) កថាខណ្ឌរង (G) នៃកថាខណ្ឌ (2) នៃផ្នែករង (b)។

(i) ដោយមិនគិតពីមាត្រាទី 5 នៃអត្ថបទ XIII B ឡើយ សម្រាប់ឆ្នាំសារពើពន្ធ 2027–28 និងរាល់ឆ្នាំសារពើពន្ធបន្ទាប់ពីនោះ ការផ្ទេរទៅកាន់គណនីស្ថិរភាពថវិកា មិនត្រូវចាត់ទុកថាជា "ការអនុម័តឱ្យប្រើប្រាស់ថវិកាដែលស្ថិតក្រោមកម្រិតកំណត់" សម្រាប់គោលបំណងនៃអត្ថបទ XIII B ឡើយ។ សម្រាប់ឆ្នាំសារពើពន្ធ 2027–28 និងរាល់ឆ្នាំសារពើពន្ធបន្ទាប់ពីនោះ មូលនិធិដែលបានដក ឬផ្ទេរពីគណនីស្ថិរភាពថវិកា ដែលមិនត្រូវបានរាប់បញ្ចូលពីមុនថាជា "ការអនុម័តឱ្យប្រើប្រាស់ថវិកាដែលស្ថិតក្រោមកម្រិតកំណត់" សម្រាប់គោលបំណងនៃអត្ថបទ XIII B ត្រូវចាត់ទុកថាជា "ការអនុម័តឱ្យប្រើប្រាស់ថវិកាដែលស្ថិតក្រោមកម្រិតកំណត់" សម្រាប់គោលបំណងនៃអត្ថបទ XIII B នៅក្នុងឆ្នាំសារពើពន្ធដែលមូលនិធិទាំងនោះត្រូវបានដកចេញពីគណនីស្ថិរភាពថវិកា ឬប្រគល់ត្រលប់ទៅកាន់មូលនិធិទូទៅវិញ។

(j) ជាការបំពេញបន្ថែមដល់គណនីស្ថិរភាពថវិកា គណនីរក្សាទុកបណ្តោះអាសន្នសម្រាប់អតិរេកដែលបានព្យាករណ៍ ដែលត្រូវបានបង្កើតឡើងនៅក្នុងមាត្រាទី 16418.7 នៃក្រមរដ្ឋាភិបាល ឬគណនីបន្តវេនណាមួយពីគណនីនោះ ត្រូវរៀបចំថវិកាប្រកបដោយការទទួលខុសត្រូវជាបច្ចេកទេសបន្ថែមមួយ ដើម្បីទប់ទល់នឹងភាពមិនប្រាកដប្រជានៃចំណូលពីពន្ធ។ ដោយមិនគិតពីមាត្រាទី 5 នៃអត្ថបទ XIII B ឡើយ សម្រាប់ឆ្នាំសារពើពន្ធ 2027–28 និងរាល់ឆ្នាំសារពើពន្ធបន្ទាប់ពីនោះ នៅពេលដែលការផ្ទេរមួយត្រូវបានធ្វើឡើងទៅកាន់គណនីកាន់ទុកបណ្តោះអាសន្នសម្រាប់អតិរេកដែលបានព្យាករណ៍ ស្របតាមច្បាប់ថវិកាប្រចាំឆ្នាំ ការផ្ទេរនោះមិនត្រូវចាត់ទុកថាជា "ការអនុម័តឱ្យប្រើប្រាស់ថវិកាដែលស្ថិតក្រោមកម្រិតកំណត់" សម្រាប់គោលបំណងនៃអត្ថបទ XIII B សម្រាប់ឆ្នាំសារពើពន្ធនោះឡើយ ក្នុងលក្ខខណ្ឌដែលថាចំនួនទឹកប្រាក់ដែលមិនស្ថិតក្រោមកម្រិតកំណត់នេះ មិនត្រូវលើសពី 10 ភាគរយ នៃចំនួនទឹកប្រាក់ចំណូលពីពន្ធនៃមូលនិធិទូទៅ សម្រាប់ឆ្នាំសារពើពន្ធដែលការផ្ទេរនោះត្រូវបានធ្វើឡើង។ សម្រាប់ឆ្នាំសារពើពន្ធ 2027–28 និងរាល់ឆ្នាំសារពើពន្ធបន្ទាប់ពីនោះ មូលនិធិដែលបានដក ឬផ្ទេរពីគណនីកាន់ទុកបណ្តោះអាសន្នសម្រាប់អតិរេកដែលបាន

ព្យាករណ៍ ដែលមិនត្រូវបានរាប់បញ្ចូលពីមុនថាជា "ការអនុម័តឱ្យប្រើប្រាស់ថវិកាដែលស្ថិតក្រោមកម្រិតកំណត់" សម្រាប់គោលបំណងនៃអត្ថបទ XIII B ត្រូវចាត់ទុកថាជា "ការអនុម័តឱ្យប្រើប្រាស់ថវិកាដែលស្ថិតក្រោមកម្រិតកំណត់" សម្រាប់គោលបំណងនៃអត្ថបទ XIII B នៅក្នុងឆ្នាំសារពើពន្ធដែលមូលនិធិទាំងនោះត្រូវបានដក ឬផ្ទេរទៅកាន់មូលនិធិទូទៅ ឬមូលនិធិរដ្ឋផ្សេងទៀតណាមួយ។

ទីបី—មាត្រាទី 22 នៃអត្ថបទ XVI នេះត្រូវបានធ្វើវិសោធនកម្ម មានខ្លឹមសារដូចខាងក្រោម៖

មាត្រាទី 22. (a) នៅពេលមានសេចក្តីប្រកាសរបស់អភិបាលរដ្ឋ ដែលប្រកាសអំពីភាពអាសន្នផ្នែកថវិកា និងបញ្ជាក់អំពីលក្ខខណ្ឌនានាដែលបង្កើតឱ្យមានភាពអាសន្ននេះ ស្ថាប័ននីតិបញ្ញត្តិអាចអនុម័តសេចក្តីព្រាងច្បាប់ដែលអនុវត្តនូវចំណុចណាមួយដូចខាងក្រោម៖

(1) ផ្អាក ឬកាត់បន្ថយតាមចំនួនទឹកប្រាក់ជាក់លាក់ណាមួយ សម្រាប់រយៈពេលមួយឆ្នាំសារពើពន្ធ នូវការផ្ទេរប្រាក់ពីមូលនិធិទូទៅទៅកាន់គណនីស្ថិរភាពថវិកា ដែលតម្រូវដោយមាត្រាទី 20។

(2) (A) បង្វិលត្រលប់មូលនិធិ ដែលត្រូវបានផ្ទេរទៅកាន់គណនីស្ថិរភាពថវិកា អនុលោមតាមមាត្រាទី 20 ត្រលប់ទៅកាន់មូលនិធិទូទៅវិញ សម្រាប់ការអនុម័តឱ្យប្រើប្រាស់ថវិកា ដើម្បីដោះស្រាយភាពអាសន្នផ្នែកថវិកា។

(B) ក្នុងឆ្នាំសារពើពន្ធណាមួយ ចំនួនដែលត្រូវបានប្រគល់ត្រឡប់ទៅមូលនិធិទូទៅ សម្រាប់ការអនុម័តឱ្យប្រើប្រាស់ថវិកាអនុលោមតាមកថាខណ្ឌរង (A) មិនអាចលើសពី 50 ភាគរយនៃសមតុល្យនៅក្នុង គណនីស្ថិរភាពថវិកាបានទេនៅក្នុងឆ្នាំសារពើពន្ធណាមួយ លើកលែងតែប្រាក់ពីគណនីស្ថិរភាពថវិកាត្រូវបានប្រគល់ត្រឡប់ទៅមូលនិធិទូទៅសម្រាប់ការអនុម័តឱ្យប្រើប្រាស់ថវិកា ក្នុងឆ្នាំសារពើពន្ធមុនភ្លាមៗ។

(3) ផ្អាក ឬកាត់បន្ថយតាមចំនួនទឹកប្រាក់ជាក់លាក់ណាមួយ សម្រាប់រយៈពេលមួយឆ្នាំសារពើពន្ធ នូវការផ្ទេរប្រាក់ពីមូលនិធិទូទៅទៅកាន់គណនីស្ថិរភាពថវិកាសម្រាប់ប្រព័ន្ធសាលារៀនរដ្ឋដែលតម្រូវដោយមាត្រាទី 21។

(4) អនុម័តឱ្យប្រើប្រាស់មូលនិធិដែលបានផ្ទេរទៅកាន់គណនីស្ថិរភាពប្រព័ន្ធសាលារៀនសាធារណៈ អនុលោមតាមមាត្រាទី 21 និងបែងចែកមូលនិធិទាំងនោះសម្រាប់ការគាំទ្រដល់មណ្ឌលសិក្សាធិការ និងមណ្ឌលសិក្សាមហាវិទ្យាល័យសហគមន៍។

(b) សម្រាប់គោលបំណងនៃមាត្រានេះ "ភាពអាសន្នផ្នែកថវិកា" មានន័យថា ចំណុចណាមួយដូចខាងក្រោម៖

(1) ភាពអាសន្នដែលត្រូវបានប្រកាសដោយអភិបាលរដ្ឋ ក្នុងអត្ថន័យនៃកថាខណ្ឌ (2) នៃផ្នែករង (c) នៃមាត្រាទី 3 នៃអត្ថបទ XIII B។

(2) (A) ការកំណត់ដោយអភិបាលរដ្ឋថា ធនធានដែលបានប៉ាន់ស្មានគឺមិនគ្រប់គ្រាន់ដើម្បីផ្តល់មូលនិធិសម្រាប់ការចំណាយនៃមូលនិធិទូទៅសម្រាប់ឆ្នាំសារពើពន្ធបច្ចុប្បន្ន ឬឆ្នាំសារពើពន្ធបន្ទាប់ បន្ទាប់ពីបានកាត់ទុកមូលនិធិសម្រាប់ប្រាក់បម្រុងសម្រាប់ការទូទាត់បន្ទុកចំណាយ ក្នុងកម្រិតមួយស្មើនឹងចំនួនខ្ពស់បំផុតនៃការចំណាយសរុបនៃមូលនិធិទូទៅ ដែលបានប៉ាន់ស្មាននៅពេលប្រកាសឱ្យប្រើប្រាស់ច្បាប់ថវិកាណាមួយ ក្នុងចំណោមច្បាប់ថវិកាថ្មីៗបំផុតទាំងបី ដោយបានកែតម្រូវសម្រាប់ចំណុចទាំងពីរដូចខាងក្រោម៖

(i) បម្រែបម្រួលជាភាគរយប្រចាំឆ្នាំនៃការចំណាយលើការរស់នៅសម្រាប់រដ្ឋដែលត្រូវបានវាស់វែងដោយសន្ទស្សន៍តម្លៃទំនិញប្រើប្រាស់រដ្ឋ California។

(ii) កំណើនជាភាគរយប្រចាំឆ្នាំនៃចំនួនប្រជាជនស៊ីវិលរបស់រដ្ឋ អនុលោមតាមផ្នែករង (b) នៃមាត្រាទី 7901 នៃក្រមរដ្ឋាភិបាល។

(B) ចំនួនទឹកប្រាក់អតិបរមាដែលអាចត្រូវបានដកយកមកប្រើប្រាស់សម្រាប់ភាពអាសន្នផ្នែកថវិកា ដែលត្រូវបានកំណត់ក្រោមកថាខណ្ឌនេះមិនត្រូវលើសពីចំនួនទឹកប្រាក់ដែលនឹងធ្វើឱ្យកម្រិតនៃការចំណាយសរុបនៃមូលនិធិទូទៅសម្រាប់ឆ្នាំសារពើពន្ធណាមួយ មានទំហំធំជាងចំនួនខ្ពស់បំផុតនៃការចំណាយសរុបនៃមូលនិធិទូទៅ ដែលបានប៉ាន់ស្មាននៅពេលអនុម័តឱ្យប្រើប្រាស់ច្បាប់ថវិកាណាមួយ ក្នុងចំណោមច្បាប់ថវិកាថ្មីៗបំផុតទាំងបី ដូចដែលបានគណនាអនុលោមតាមកថាខណ្ឌរង (A) ឬកម្រិតកំណត់ណាមួយដែលត្រូវបានដាក់កំហិតដោយ កថាខណ្ឌរង (B) នៃកថាខណ្ឌ (2) នៃផ្នែករង (a) ឡើយ។

(c) ប្រសិនបើលក្ខខណ្ឌដែលតម្រូវសម្រាប់អភិបាលរដ្ឋក្នុងការប្រកាសភាពអាសន្នផ្នែកថវិកា អនុលោមតាមផ្នែករង (b) ពិតជាមានមែន ការកែតម្រូវដែលបានស្នើឡើងចំពោះថវិការបស់អភិបាលរដ្ឋ ដែលត្រូវបានដាក់ជូនស្ថាប័ននីតិបញ្ញត្តិដោយនាយកហិរញ្ញវត្ថុ អនុលោមតាមផ្នែករង (e) នៃមាត្រាទី 13308 នៃក្រមរដ្ឋាភិបាល ឬការកែសម្រួលថវិកាផ្សេងទៀតណាមួយដែលតម្រូវឱ្យដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិដោយច្បាប់បន្តវេន ត្រូវចាត់ទុកថាជាសេចក្តីប្រកាសរបស់អភិបាលរដ្ឋអំពីភាពអាសន្នផ្នែកថវិកា ប្រសិនបើការកែសម្រួលនោះស្នើឡើងនូវចំណុចណាមួយដូចខាងក្រោម៖

(1) ការផ្អាក ឬការកាត់បន្ថយការផ្ទេរប្រាក់ពីមូលនិធិទូទៅទៅកាន់គណនីស្ថិរភាពថវិកា ឬគណនីស្ថិរភាពប្រព័ន្ធសាលារៀនសាធារណៈ។

(2) ការបង្វិលត្រលប់ប្រាក់ពីគណនីស្ថិរភាពថវិកាត្រលប់ទៅកាន់មូលនិធិទូទៅវិញស្របតាមមាត្រានេះ ឬការអនុម័តឱ្យប្រើថវិកាពីគណនីស្ថិរភាពប្រព័ន្ធសាលារៀនសាធារណៈ អនុលោមតាមមាត្រានេះ។

សំណើ 3

វិធានការផ្តួចផ្តើមនេះត្រូវបានដាក់ជូនប្រជាពលរដ្ឋដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី 8 នៃអត្ថបទ II នៃរដ្ឋធម្មនុញ្ញរដ្ឋ California ។

វិធានការផ្តួចផ្តើមនេះធ្វើវិសោធនកម្មផ្នែកមួយនៃរដ្ឋធម្មនុញ្ញរដ្ឋ California។ ដូច្នេះហើយ បទបញ្ញត្តិដែលមានស្រាប់ដែលស្នើឱ្យលុបត្រូវបានបោះពុម្ពក្នុងប្រភេទ ~~អក្សរដែលគូសឆូត~~ ហើយបទបញ្ញត្តិថ្មីដែលស្នើឱ្យបន្ថែមត្រូវបានបោះពុម្ពជាប្រភេទ*អក្សរទ្រេត* ដើម្បីបញ្ជាក់ថាច្បាប់ទាំងនោះថ្មី។

ច្បាប់ដែលបានដាក់ស្នើឡើង

ច្បាប់ស្តីពីការការពារការអប់រំ និងការថែទាំសុខភាពកុមាររដ្ឋ Californiaនៃឆ្នាំ 2026

មាត្រាទី 1. ចំណងជើង

វិធានការនេះត្រូវបានស្គាល់ និងអាចហៅថា "ច្បាប់ស្តីពីការការពារការអប់រំ និងការថែទាំសុខភាពកុមាររដ្ឋ California នៃឆ្នាំ 2026។"

ផ្នែកទី 2. ការរកឃើញ។

(a) ក្នុងឆ្នាំ 2012 អ្នកបោះឆ្នោតនៅរដ្ឋ California បានអនុម័តការដំឡើងពន្ធលើអ្នកដែលមានប្រាក់ចំណូលខ្ពស់—ដែលស្ថិតក្នុងកម្រិតកំពូល 2%—ដើម្បីផ្តល់មូលនិធិដល់សេវាសំខាន់ៗរបស់រដ្ឋ និងទប់ស្កាត់ការកាត់បន្ថយយ៉ាងធ្ងន់ធ្ងរដល់ការអប់រំសាធារណៈ ដែលបង្កឡើងដោយបញ្ហាប្រឈមផ្នែកសារពើពន្ធនៃវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរ។ អត្រាពន្ធទាំងនេះត្រូវបានពន្យារដោយអ្នកបោះឆ្នោតនៅក្នុងឆ្នាំ 2016 ជាមួយសម្លេង 63% បោះឆ្នោតគាំទ្រ។ ចាប់តាំងពីការអនុម័តជាលើកដំបូងមក វិធានការពន្ធនេះបានប្រមូលប្រាក់ជាង $104 ពាន់លាន សម្រាប់សាលារៀន និងសេវាចាំបាច់ផ្សេងៗទៀត។ វា

3

គឺជាផ្នែកជាមូលដ្ឋាននៃថវិការដ្ឋ និងមូលនិធិបម្រុងសម្រាប់ពេលមានអាសន្ន របស់រដ្ឋ

(b) ពន្ធលើប្រាក់ចំណូលសម្រាប់អ្នកមានចំណូលខ្ពស់នេះ បានអនុញ្ញាត ឱ្យរដ្ឋធ្វើការវិនិយោគយ៉ាងសំខាន់លើការអប់រំ និងសុខភាពកូនរបស់យើង និងបានជួយឱ្យប្រព័ន្ធសាលារៀនសាធារណៈរបស់រដ្ឋ California ក្លាយជា ប្រព័ន្ធដែលមានភាពប្រកួតប្រជែងជាងមុនក្នុងចំណោមរដ្ឋទាំង 50។ ក្នុងឆ្នាំ 2012 រដ្ឋ California ជាប់ក្នុងចំណោមរដ្ឋទាំង 10 គឺស្ថិតនៅបាតតារាងលើ ការចំណាយសម្រាប់សាលារៀន។ សព្វថ្ងៃនេះ ជាមួយនឹងចំណូលទាំងនេះ រដ្ឋ California បានធ្វើឱ្យមានវឌ្ឍនភាពពិតប្រាកដក្នុងការចំណាយសម្រាប់ សាលារៀន។ រដ្ឋរបស់យើងឥឡូវនេះផ្តល់ជូននូវអាហារនៅសាលារៀនដោយ ឥតគិតថ្លៃ មត្តេយ្យសិក្សាអន្តរកាល ដោយឥតគិតថ្លៃដល់កុមារអាយុបួនឆ្នាំ ទាំងអស់ ការថែទាំមុន និងក្រោយម៉ោងសិក្សាដោយឥតគិតថ្លៃសម្រាប់សិស្ស បឋមសិក្សាក្មេងៗ និងសេវាកម្មតាមសហគមន៍នៅក្នុងមណ្ឌលសិក្សាធិការ សាលារៀនជាច្រើន។

(c) លុះត្រាតែពន្ធនេះត្រូវបានពន្យារពេលដោយអ្នកបោះឆ្នោត វានឹង ផុតកំណត់នៅក្នុងឆ្នាំ 2030។ ដែលនាំឱ្យមានការកាត់បន្ថយភ្លាមៗនូវ ចំណូលរបស់រដ្ឋជាង $10 ពាន់លាន និងការកាត់បន្ថយយ៉ាងធ្ងន់ធ្ងរដល់ សាលារៀន ការថែទាំសុខភាពកុមារ និងសេវាចាំបាច់ផ្សេងៗទៀត។ វានឹង ធ្វើឱ្យបាត់បង់វិញនូវសមិទ្ធផលដែលសាលារៀនរបស់យើងសម្រេចបាន ចាប់តាំងពីការអនុម័តជាលើកដំបូងនូវ ពន្ធលើប្រាក់ចំណូលសម្រាប់អ្នកមាន ចំណូលខ្ពស់នៅក្នុងឆ្នាំ 2012។

(d) វិធានការនេះមិនដំឡើងពន្ធលើគូស្វាមីភរិយា ដែលមានប្រាក់ចំណូល តិចជាង $680,000 ឬបុគ្គលដែលមានប្រាក់ចំណូលតិចជាង $340,000 គិតជាតម្លៃប្រាក់ដុល្លារនាពេលបច្ចុប្បន្ននោះទេ។ វាមិនបានផ្លាស់ប្តូរអត្រាពន្ធ ដែលមានស្រាប់នោះទេ ដែលអត្រាទាំងនេះនៅតែរក្សាដដែលចាប់តាំងពី វិធានការពន្ធនេះត្រូវបានអនុម័តឱ្យប្រើប្រាស់ជាលើកដំបូងនៅក្នុងឆ្នាំ 2012។

(e) នេះមិនមែនជាពេលក្នុងការកាត់បន្ថយពន្ធឱ្យ អ្នកមានបំផុតនៅ California ទេ ព្រោះពួកគេមិនចាំបាច់ត្រូវការការកាត់បន្ថយពន្ធនេះឡើយ ហើយសាលារៀន និងសហគមន៍របស់យើងមិនអាចទ្រាំទ្រនឹងការបាត់បង់ ប្រាក់ចំណូលនេះបានទេ។ ការរក្សាពន្ធនេះលើអ្នកមានចំណូលខ្ពស់នឹងជួយ ធានាថា កុមារនៅ California ទទួលបាន ការអប់រំ និងការថែទាំសុខភាព ដែលពួកគេត្រូវការ ដើម្បីលូតលាស់ ទទួលបានជោគជ័យ និងអភិវឌ្ឍ សមត្ថភាពរបស់ពួកគេឱ្យបានពេញលេញ។ ប្រសិនបើអនុញ្ញាតឱ្យពន្ធនេះ ផុតកំណត់ នោះនឹងតម្រូវឱ្យមានការកាត់បន្ថយយ៉ាងច្រើនលើការអប់រំ និង សុខភាពសម្រាប់មនុស្សជំនាន់ក្រោយរបស់យើង។

(f) អនាគតរបស់រដ្ឋ California ពឹងផ្អែកលើភាពជោគជ័យរបស់កុមារ ជាង 9 លាននាក់របស់ខ្លួន។ កុមាររដ្ឋ California គ្រប់រូបស័ក្តិសមទទួល បានឱកាសប្រកបដោយសមធម៌ ដើម្បីក្លាយជាមនុស្សពេញវ័យដែលទទួល បានជោគជ័យ។ ប៉ុន្តែដើម្បីឱ្យកុមារទទួលបានជោគជ័យនៅពេលក្លាយជា មនុស្សពេញវ័យ ពួកគេត្រូវតែទទួលបានការអប់រំ និងការថែទាំសុខភាពដែល មានគុណភាពខ្ពស់។

(g) សម្រាប់កុមារ ការអប់រំ និងការថែទាំសុខភាពគឺជារឿងចាំបាច់ និង ពឹងផ្អែកលើគ្នាទៅវិញទៅមក។ ការទទួលបានការអប់រំដែលមានគុណ ភាព គឺជាមូលដ្ឋានគ្រឹះសម្រាប់ ភាពជោគជ័យរបស់កុមាររដ្ឋ California។ ទោះបីជាមានសាលារៀនគ្រប់គ្រាន់ក៏ដោយ ក៏កុមារមិនអាចទទួលបានការ អប់រំដែរ ប្រសិនបើជំងឺរារាំងពួកគេមិនឱ្យចូលរៀន។ ហើយកុមារដែលធំធាត់ នៅក្នុងសហគមន៍ដែលគ្មានការថែទាំសុខភាពគ្រប់គ្រាន់ ងាយនឹងឆ្លងជំងឺ ឬ មានស្ថានភាពជំងឺរ៉ាំរ៉ៃ ដែលរារាំងពួកគេមិនឱ្យចូលរៀនបានទៀងទាត់។

(h) ការស្រាវជ្រាវបង្ហាញថា ការទទួលបានការអប់រំ និងការថែទាំសុខភាព ដែលមានគុណភាពតាំងពីវ័យកុមារ ជួយបង្កើនឱកាសរបស់កុមារក្នុងការ ទទួលបានជោគជ័យនៅក្នុងសាលារៀន និងនៅក្នុងជីវិត។ ពន្ធលើអ្នកដែល មានប្រាក់ចំណូលខ្ពស់នេះ ជួយធានាថាកុមារនៅរដ្ឋ California ទទួល បានការអប់រំ និងការថែទាំសុខភាពដែលពួកគេត្រូវការ ដើម្បីលូតលាស់ និង សម្រេចបាននូវសក្តានុពលខ្ពស់បំផុតរបស់ពួកគេ។

(i) ចំណូលពីពន្ធលើប្រាក់ចំណូល ត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញនៃ រដ្ឋ California ថានឹងត្រូវទៅដោយផ្ទាល់ទៅកាន់មណ្ឌលសិក្សាធិការ សាលារៀនក្នុងតំបន់ និងមហាវិទ្យាល័យសហគមន៍។ ថវិការបស់រដ្ឋត្រូវ បានបញ្ចេញមកប្រើ ដើម្បី ជួយធ្វើឱ្យថវិកាមានតុល្យភាព និងផ្តល់សម្រាប់ មូលនិធិបម្រុងសម្រាប់ពេលមានអាសន្ន ដើម្បីទប់ស្កាត់ការកាត់បន្ថយ ដល់ការថែទាំសុខភាពសម្រាប់កុមារ និងក្រុមគ្រួសាររបស់ពួកគេ សេវាកម្ម សម្រាប់មនុស្សចាស់ គ្រួសារដែលធ្វើការងារចិញ្ចឹមជីវិត និងម្ចាស់អាជីវកម្ម ខ្នាតតូច ការទប់ស្កាត់ភ្លើងឆេះព្រៃ និងតម្រូវការចាំបាច់ផ្សេងៗទៀត ទោះបីជា នៅពេលដែលចំណូលធ្លាក់ចុះក៏ដោយ។ គ្រប់គ្នាទទួលបានអត្ថប្រយោជន៍។

(j) ដើម្បីធានាថាមូលនិធិទាំងនេះទាំងអស់ត្រូវបានប្រើប្រាស់ចំគោលដៅ តែមួយគត់ដែលអ្នកបោះឆ្នោតចង់បាន មូលនិធិទាំងនេះត្រូវបានដាក់បញ្ចូល ទៅក្នុងមូលនិធិពិសេសមួយដែលស្ថាប័ននីតិបញ្ញត្តិមិនអាចបង្វែរទៅរក គោលបំណងផ្សេងបានឡើយ។ គ្មានចំណូលណាមួយក្នុងចំណោមចំណូល ទាំងនេះ អាចត្រូវបានចំណាយលើការិយាធិបតេយ្យរបស់រដ្ឋ ឬការចំណាយ លើការគ្រប់គ្រងរដ្ឋបាលឡើយ។

(k) មូលនិធិទាំងនេះត្រូវឆ្លងកាត់ការសវនកម្មឯករាជ្យជារៀងរាល់ឆ្នាំ ដើម្បីធានាថាពួកវាត្រូវបានចំណាយសម្រាប់តែគោលបំណងដែលបាន កំណត់នៅក្នុងវិធានការនេះប៉ុណ្ណោះ។ មន្ត្រីជាប់ឆ្នោត នឹងត្រូវទទួលរង ការចោទប្រកាន់ និងទោសព្រហ្មទណ្ឌ ប្រសិនបើពួកគេប្រើប្រាស់មូលនិធិ ទាំងនោះមិនត្រឹមត្រូវ។

(l) វិធានការនេះបានជួយកសាង ហើយនឹងបន្តទ្រទ្រង់មូលនិធិបម្រុង សម្រាប់ពេលមានអាសន្នរបស់រដ្ឋ។ ក្នុងរយៈពេល 15 ឆ្នាំកន្លងមកនេះ ថវិកា របស់រដ្ឋ California បានប្រទះឡើងចុះយ៉ាងខ្លាំង។ ឆ្នាំដែលមានស្ថានភាព ហិរញ្ញវត្ថុល្អ ជារឿយៗត្រូវបានបន្តដោយឱនភាពថវិកាដ៏ធំ និងការកាត់បន្ថយ ថវិកាយ៉ាងធ្ងន់ធ្ងរ។ ការរក្សាមូលនិធិបម្រុងសម្រាប់ពេលមានអាសន្នរបស់ រដ្ឋ បានជួយការពារកុមារ មនុស្សចាស់ និងពលរដ្ឋរដ្ឋ California ដែល មានពិការភាពរបស់យើង ពីការកាត់បន្ថយមូលនិធិសាលារៀន និងការថែទាំ សុខភាព ក្នុងអំឡុងពេលមានការធ្លាក់ចុះនៃសេដ្ឋកិច្ច។

(m) ការកាត់បន្ថយថវិកាពីរដ្ឋាភិបាលសហព័ន្ធ នឹងប៉ះពាល់យ៉ាងខ្លាំងដល់ ប្រជាជនដែលមានចំណូលទាបនៅរដ្ឋ California ជាពិសេសកុមាររបស់ យើង។ ប៉ុន្តែច្បាប់ពន្ធសហព័ន្ធកំពុងផ្តល់ការបន្ធូរបន្ថយពន្ធយ៉ាងច្រើនសន្ធឹក សន្ធាប់ដល់អ្នកជាប់ពន្ធដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ ការរក្សាពន្ធដែល មានស្រាប់លើប្រជាជននៅរដ្ឋ California ដែលមានចំណូលខ្ពស់ គឺមាន សារៈសំខាន់ណាស់ ដើម្បីការពារសាលារៀនរបស់យើង និង សិស្សរបស់ យើង។

មាត្រាទី 3. គោលបំណង និង ចេតនា

(a) គោលបំណងសំខាន់របស់សំណើនេះ គឺដើម្បីជៀសវាងការកាត់បន្ថយ ថវិកាដែលអាចធ្វើឱ្យគុណភាពនៃការអប់រំ និងការបង្រៀននៅតាមសាលា សាធារណៈក្នុងមូលដ្ឋានរបស់រដ្ឋ California ធ្លាក់ចុះ នឹងមានគោលបំណង ផ្តល់ថវិកាគ្រប់គ្រាន់សម្រាប់សេវាថែទាំសុខភាពសំខាន់ៗសម្រាប់កុមារ និង សមាជិកគ្រួសាររបស់ពួកគេផងដែរ។

(b) សំណើនេះមានគោលបំណងការពារកុមាររបស់យើង ដោយបន្តអនុវត្ត អត្រាពន្ធលើប្រាក់ចំណូលដែលមានស្រាប់ចំពោះ អ្នកមានទ្រព្យសម្បត្តិ ស្តុកស្តម្ភនៅរដ្ឋ California។ ជំនួសឱ្យការបង្វិលប្រាក់ត្រលប់ចូលទៅ ក្នុងហោប៉ៅរបស់អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភវិញ វិធានការនេះបញ្ជូន ប្រាក់នោះទៅកាន់គណនីពិសេសមួយ ដែលត្រូវតែចំណាយសម្រាប់តែ ការធានាថាកុមាររដ្ឋ California គ្រប់រូប ទទួលបានការអប់រំក្នុងសាលារដ្ឋ ដែលមានគុណភាពប៉ុណ្ណោះ។ វាក៏ធ្វើឱ្យមានថវិការដ្ឋសម្រាប់ផ្តល់ការថែទាំ សុខភាពដល់កុមារ និងផ្តល់មូលនិធិសម្រាប់សេវាសំខាន់ៗផ្សេងទៀត។

(c) សំណើនេះធានានៅក្នុងរដ្ឋធម្មនុញ្ញថា ប្រាក់ចំណូលដែលប្រមូលបាន សម្រាប់សាលារៀន នឹងត្រូវផ្ញើដោយផ្ទាល់ទៅមណ្ឌលសិក្សាធិការសាលារៀន តាមមូលដ្ឋាន និង មហាវិទ្យាល័យសហគមន៍ ដើម្បីចំណាយលើការបង្រៀន ក្នុងថ្នាក់រៀន មិនមែនសម្រាប់ចំណាយផ្នែករដ្ឋបាលទេ។ ថវិកាសម្រាប់ សាលារៀននេះ មិនអាចត្រូវបានផ្អាក ឬដកហូតឡើយ ទោះបីជាមានអ្វី កើតឡើងចំពោះថវិការដ្ឋក៏ដោយ។

(d) ប្រាក់ចំណូលទាំងអស់ដែលប្រមូលបានពីវិធានការនេះ ត្រូវឆ្លងកាត់ការធ្វើសវនកម្មជារៀងរាល់ឆ្នាំដោយអាជ្ញាធរសវនកម្មក្នុងមូលដ្ឋាន និងដោយអគ្គនាយកគ្រប់គ្រងហិរញ្ញវត្ថុឯករាជ្យ ដើម្បីធានាថា ប្រាក់ទាំងនេះត្រូវបានប្រើប្រាស់តែសម្រាប់គោលបំណងដែលបានកំណត់នៅក្នុងវិធានការនេះប៉ុណ្ណោះ។

មាត្រាទី 4. មាត្រាទី 36 នៃអត្ថបទ XIII នៃរដ្ឋធម្មនុញ្ញរដ្ឋ California ត្រូវបានធ្វើវិសោធនកម្មដែលមានខ្លឹមសារដូចខាងក្រោម៖

មាត្រាទី 36. (a) សម្រាប់គោលបំណងនៃមាត្រានេះ៖

(1) “សេវាសុវត្ថិភាពសាធារណៈ” មានដូចខាងក្រោម៖

(A) ការផ្តល់ការងារ និងការបណ្តុះបណ្តាលមន្ត្រីសុវត្ថិភាពសាធារណៈ រួមទាំងមន្ត្រីអនុវត្តច្បាប់ មេធាវីដែលត្រូវបានចាត់តាំងសម្រាប់នីតិវិធីព្រហ្មទណ្ឌ និងបុគ្គលិកសន្តិសុខតុលាការ។

(B) ការគ្រប់គ្រងពន្ធនាគារមូលដ្ឋាន និងការផ្តល់កន្លែងស្នាក់នៅ ការព្យាបាល និងសេវាកម្មសម្រាប់ ព្រមទាំងការត្រួតពិនិត្យលើជនល្មើសជាអនីតិជន និងមនុស្សពេញវ័យ។

(C) ការទប់ស្កាត់ការរំលោភបំពាន ការធ្វេសប្រហែស ឬការកេងប្រវ័ញ្ចលើកុមារ ការផ្តល់សេវាកម្មដល់កុមារ និងយុវជនដែលត្រូវបានរំលោភបំពាន ទទួលរងការធ្វេសប្រហែស ឬត្រូវបានកេងប្រវ័ញ្ច ឬអ្នកដែលប្រឈមនឹងហានិភ័យនៃការរំលោភបំពាន ការធ្វេសប្រហែស ឬការកេងប្រវ័ញ្ច និងក្រុមគ្រួសាររបស់កុមារទាំងនោះ ការផ្តល់សេវាស្នំកូន និងការផ្តល់សេវាការពារមនុស្សពេញវ័យ។

(D) ការផ្តល់សេវាសុខភាពផ្លូវចិត្តដល់កុមារ និងមនុស្សពេញវ័យ ដើម្បីកាត់បន្ថយការបរាជ័យនៅសាលារៀន ការបង្កគ្រោះថ្នាក់ដល់ខ្លួនឯង ឬអ្នកដទៃ ភាពគ្មានផ្ទះសម្បែង និងការជាប់ពន្ធនាគារ ឬការដាក់ឱ្យស្នាក់នៅក្នុងស្ថាប័នដែលអាចបង្ការបាន។

(E) ការការពារ ការព្យាបាល និងការផ្តល់សេវាស្តារនីតិសម្បទាសម្រាប់ការប្រើប្រាស់សារធាតុញៀន។

(2) “ច្បាប់ស្តីពីការផ្ទេរភារកិច្ចឆ្នាំ 2011” មានន័យថា ច្បាប់ដែលត្រូវបានអនុម័តនៅ ឬមុនថ្ងៃទី 30 ខែកញ្ញា ឆ្នាំ 2012 ដើម្បីអនុវត្តគម្រោងថវិការដ្ឋដែលមានចំណងជើងថាការផ្ទេរភារកិច្ចឆ្នាំ 2011 និងផ្តល់ការទទួលខុសត្រូវលើ សេវាសុវត្ថិភាពសាធារណៈ ទៅឱ្យទីភ្នាក់ងារក្នុងមូលដ្ឋាន រួមទាំងការទទួលខុសត្រូវពាក់ព័ន្ធនឹងការរាយការណ៍ផងដែរ។ ច្បាប់នេះផ្តល់ឱ្យទីភ្នាក់ងារក្នុងមូលដ្ឋាននូវភាពបត់បែន និងការគ្រប់គ្រងជាអតិបរមាក្នុងការរៀបចំ ការគ្រប់គ្រង និងការផ្តល់សេវាសុវត្ថិភាពសាធារណៈ ដោយអនុលោមតាមច្បាប់សហព័ន្ធ និងលក្ខខណ្ឌតម្រូវផ្នែកថវិកា ដូចដែលស្ថាប័ននីតិបញ្ញត្តិបានកំណត់។ ទោះជាយ៉ាងណាច្បាប់ស្តីពីការផ្ទេរភារកិច្ចឆ្នាំ 2011 មិនត្រូវរួមបញ្ចូលកម្មវិធីថ្មីណាមួយដែលត្រូវបានផ្ទេរទៅឱ្យទីភ្នាក់ងារក្នុងមូលដ្ឋានបន្ទាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2012 ទេ លើកលែងតែ កម្មវិធីពិនិត្យសុខភាព ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលតាមកាលកំណត់ទាន់ពេល (EPSDT) និងការគ្រប់គ្រងសេវាថែទាំសុខភាពផ្លូវចិត្ត។

(b) (1) លើកលែងតែមានចែងផ្សេងនៅក្នុងផ្នែករង (d) ចាប់ពីឆ្នាំសារពើពន្ធ 2011–12 និង បន្តទៅមុខ ចំនួនទឹកប្រាក់ខាងក្រោមត្រូវដាក់តម្កល់ទៅក្នុង មូលនិធិចំណូលក្នុងមូលដ្ឋានឆ្នាំ 2011 ដែលបង្កើតឡើងតាមមាត្រាទី 30025 នៃក្រមរដ្ឋាភិបាលដូចខាងក្រោម៖

(A) ប្រាក់ចំណូលទាំងអស់ បន្ទាប់ពីដកប្រាក់សងត្រឡប់វិញ ដែលទទួលបានពីពន្ធដែលបានពណ៌នានៅក្នុងមាត្រាទី 6051.15 និង ទី 6201.15 នៃក្រមប្រាក់ចំណូល និង ពន្ធដារ ដូចដែលមាត្រាទាំងនោះមានចែងនៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2011។

(B) ប្រាក់ចំណូលទាំងអស់ បន្ទាប់ពីដកប្រាក់សងត្រឡប់វិញ ដែលប្រមូលបានពីថ្លៃអាជ្ញាបណ្ណយានយន្ត ដែលបានពណ៌នានៅក្នុងមាត្រា 11005 នៃក្រមប្រាក់ចំណូល និងពន្ធដារ ដូចដែលមាត្រាទាំងនោះមានចែងនៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2011។

(2) ចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2011 តទៅ ប្រាក់ចំណូលដែលបានដាក់តម្កល់អនុលោមតាមកថាខណ្ឌ (1) មិនត្រូវចាត់ទុកថាប្រាក់ជាចំណូលនៃមូលនិធិទូទៅ ឬ ប្រាក់ចំណូលពីពន្ធ សម្រាប់គោលបំណងនៃមាត្រាទី 8 នៃអត្ថបទ XVI នៃរដ្ឋធម្មនុញ្ញរដ្ឋ California ឡើយ។

(c) (1) មូលនិធិដែលបានដាក់តម្កល់នៅក្នុងមូលនិធិប្រាក់ចំណូលមូលដ្ឋានឆ្នាំ 2011 ត្រូវបានអនុម័តឱ្យប្រើប្រាស់ថវិកាជាបន្តបន្ទាប់សម្រាប់តែការផ្តល់មូលនិធិដល់ការផ្តល់សេវាសុវត្ថិភាពសាធារណៈដោយទីភ្នាក់ងារមូលដ្ឋានប៉ុណ្ណោះ។ ក្នុងអំឡុងពេលរង់ចាំការអនុវត្តពេញលេញនៃច្បាប់ស្តីពីការផ្ទេរភារកិច្ចឆ្នាំ 2011 មូលនិធិទាំងនេះក៏អាចត្រូវបានប្រើប្រាស់ផងដែរ ដើម្បីសងប្រាក់ត្រលប់ទៅរដ្ឋវិញសម្រាប់ការចំណាយលើកម្មវិធីដែលបានកើតឡើងក្នុងការផ្តល់សេវាសុវត្ថិភាពសាធារណៈ ក្នុងនាមទីភ្នាក់ងារមូលដ្ឋាន។ វិធីសាស្ត្រសម្រាប់ការបែងចែកមូលនិធិ ត្រូវអនុវត្តតាមការបញ្ជាក់នៅក្នុងច្បាប់ស្តីពីការផ្ទេរភារកិច្ចនៃឆ្នាំ 2011។

(2) ហិរញ្ញិកខោនធី ហិរញ្ញិកក្រុង និង ខោនធី ឬមន្ត្រីពាក់ព័ន្ធផ្សេងទៀតត្រូវបង្កើតមូលនិធិប្រាក់ចំណូលមូលដ្ឋានខោនធីឆ្នាំ 2011 នៅក្នុងរតនាគារនៃខោនធី ឬ ក្រុង និង ខោនធីនីមួយៗ។ ប្រាក់នៅក្នុងមូលនិធិប្រាក់ចំណូលមូលដ្ឋានខោនធីនីមួយៗ នៃឆ្នាំ 2011 ត្រូវប្រើប្រាស់សម្រាប់តែការផ្តល់មូលនិធិដល់ការផ្តល់សេវាសុវត្ថិភាពសាធារណៈដោយទីភ្នាក់ងារមូលដ្ឋានដូចដែលបានបញ្ជាក់ដោយច្បាប់ស្តីពីការផ្ទេរភារកិច្ចនៃឆ្នាំ 2011 ប៉ុណ្ណោះ។

(3) ដោយមិនគិតពីមាត្រាទី 6 នៃអត្ថបទ XIII B ឬបទបញ្ញត្តិរដ្ឋធម្មនុញ្ញផ្សេងទៀតណាមួយក៏ដោយ ការតម្រូវឱ្យមានកម្មវិធីថ្មីមួយ ឬកម្រិតសេវាខ្ពស់ជាងមុនទៅលើទីភ្នាក់ងារមូលដ្ឋាន ដែលត្រូវបានដាក់កំហិតដោយច្បាប់ស្តីពីការផ្ទេរភារកិច្ចនៃឆ្នាំ 2011 ឬដោយបទបញ្ញត្តិណាមួយដែលត្រូវបានទទួលយក ឬបទបញ្ជាប្រតិបត្តិ ឬសេចក្តីណែនាំរដ្ឋបាលណាមួយដែលត្រូវបានចេញដើម្បីអនុវត្តច្បាប់នោះ មិនត្រូវចាត់ទុកថាជាការតម្រូវ ដែលតម្រូវឱ្យរដ្ឋផ្តល់ប្រាក់ឧបត្ថម្ភក្នុងអត្ថន័យនៃមាត្រានោះឡើយ។ រាល់លក្ខខណ្ឌតម្រូវណាមួយដែលឱ្យទីភ្នាក់ងារមូលដ្ឋានគោរពតាមជំពូកទី 9 (ចាប់ផ្តើមពីមាត្រាទី 54950) នៃផ្នែកទី 1 នៃភាគទី 2 នៃចំណងជើងទី 5 នៃក្រមរដ្ឋាភិបាលពាក់ព័ន្ធនឹងការអនុវត្តការទទួលខុសត្រូវលើសេវាសុវត្ថិភាពសាធារណៈរបស់ខ្លួន ឬបញ្ហាផ្សេងទៀតណាមួយ មិនត្រូវចាត់ទុកជាលក្ខខណ្ឌតម្រូវដែលអាចទាមទារសំណងបានក្រោមមាត្រាទី 6 នៃអត្ថបទ XIII B ឡើយ។

(4) (A) ច្បាប់ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់បន្ទាប់ពីថ្ងៃទី 30 ខែកញ្ញា ឆ្នាំ 2012 ដែលមានផលប៉ះពាល់ជារួមក្នុងការបង្កើនការចំណាយ ដែលទីភ្នាក់ងារមូលដ្ឋានបានរ៉ាប់រងរួចហើយសម្រាប់កម្មវិធី ឬកម្រិតសេវាដែលតម្រូវដោយច្បាប់ស្តីពីការផ្ទេរភារកិច្ចនៃឆ្នាំ 2011 ត្រូវអនុវត្តចំពោះទីភ្នាក់ងារមូលដ្ឋាន តែក្នុងកម្រិតដែលរដ្ឋផ្តល់មូលនិធិប្រចាំឆ្នាំសម្រាប់ការកើនឡើងនៃការចំណាយនោះប៉ុណ្ណោះ។ ទីភ្នាក់ងារមូលដ្ឋានមិនត្រូវមានកាតព្វកិច្ចក្នុងការផ្តល់កម្មវិធី ឬកម្រិតសេវាដែលតម្រូវដោយច្បាប់ ដូចដែលបានពណ៌នានៅក្នុងកថាខណ្ឌរងនេះ លើសពីកម្រិតដែលមូលនិធិត្រូវបានផ្តល់ជូននោះឡើយ។

(B) បទបញ្ញត្តិ បទបញ្ជាប្រតិបត្តិ ឬសេចក្តីណែនាំរដ្ឋបាល ដែលត្រូវបានអនុវត្តបន្ទាប់ពីថ្ងៃទី 9 ខែតុលា ឆ្នាំ 2011 ដែលមិនមានភាពចាំបាច់សម្រាប់ការអនុវត្តច្បាប់ស្តីពីការផ្ទេរភារកិច្ចនៃឆ្នាំ 2011 ហើយដែលមានផលប៉ះពាល់ជារួមក្នុងការបង្កើនការចំណាយ ដែលទីភ្នាក់ងារមូលដ្ឋានបានរ៉ាប់រងរួចហើយសម្រាប់កម្មវិធី ឬកម្រិតសេវាដែលតម្រូវដោយច្បាប់ស្តីពីការផ្ទេរភារកិច្ចនៃឆ្នាំ 2011 ត្រូវអនុវត្តចំពោះទីភ្នាក់ងារមូលដ្ឋាន តែក្នុងកម្រិតដែលរដ្ឋផ្តល់មូលនិធិប្រចាំឆ្នាំសម្រាប់ការកើនឡើងនៃការចំណាយនោះប៉ុណ្ណោះ។ ទីភ្នាក់ងារមូលដ្ឋានមិនត្រូវមានកាតព្វកិច្ចក្នុងការផ្តល់កម្មវិធី ឬកម្រិតសេវាអនុលោមតាមបទបញ្ញត្តិថ្មី បទបញ្ជាប្រតិបត្តិថ្មី ឬសេចក្តីណែនាំរដ្ឋបាលថ្មីដូចដែលបានពណ៌នានៅក្នុងកថាខណ្ឌរងនេះ លើសពីកម្រិតដែលមូលនិធិត្រូវបានផ្តល់ជូននោះឡើយ។

(C) រាល់កម្មវិធីថ្មី ឬកម្រិតសេវាខ្ពស់ជាងមុន ដែលផ្តល់ដោយទីភ្នាក់ងារមូលដ្ឋាន ដូចដែលបានពណ៌នានៅក្នុងកថាខណ្ឌរង (A) និង (B) លើសពីកម្រិតដែលមូលនិធិត្រូវបានផ្តល់ជូន មិនត្រូវតម្រូវឱ្យមានការផ្តល់ប្រាក់ឧបត្ថម្ភពីរដ្ឋ ឬត្រូវស្ថិតក្រោមមាត្រាទី 6 នៃអត្ថបទ XIII B ឡើយ។ កថាខណ្ឌនេះមិនត្រូវអនុវត្តចំពោះច្បាប់ដែលបច្ចុប្បន្នត្រូវបានលើកលែងពីការផ្តល់ប្រាក់ឧបត្ថម្ភ ក្រោមកថាខណ្ឌ (2) នៃផ្នែករង (a) នៃផ្នែកទី 6 នៃមាត្រា XIII B ដូចដែលកថាខណ្ឌនោះមានចែងនៅថ្ងៃទី 2 ខែមករា ឆ្នាំ 2011 នោះឡើយ។

3

(D) រដ្ឋមិនត្រូវដាក់ជូនរដ្ឋាភិបាលសហព័ន្ធនូវផែនការ ឬការលើកលែងណាមួយ ឬវិសោធនកម្មលើផែនការ ឬការលើកលែងទាំងនោះ ដែលមានផលប៉ះពាល់ជារួមក្នុងការបង្កើនការចំណាយដែលទីភ្នាក់ងារមូលដ្ឋានបានរ៉ាប់រង សម្រាប់កម្មវិធី ឬកម្រិតសេវាដែលតម្រូវដោយច្បាប់ស្តីពីការផ្ទេរភារកិច្ចនៃឆ្នាំ 2011 នោះទេ លើកលែងតែក្នុងកម្រិតដែលផែនការការលើកលែង ឬវិសោធនកម្មទាំងនោះ ត្រូវបានតម្រូវដោយច្បាប់សហព័ន្ធ ឬរដ្ឋផ្តល់មូលនិធិប្រចាំឆ្នាំសម្រាប់ការកើនឡើងនៃការចំណាយនោះ។

(E) រដ្ឋមិនត្រូវបានតម្រូវឱ្យផ្តល់ប្រាក់ឧបត្ថម្ភស្របតាមកថាខណ្ឌនេះទេ សម្រាប់កាតព្វកិច្ចណាមួយដែលរដ្ឋបានដាក់ចេញតាមសំណើរបស់ទីភ្នាក់ងារមូលដ្ឋាន ឬដើម្បីអនុវត្តតាមច្បាប់សហព័ន្ធនោះទេ។ មូលនិធិរដ្ឋដែលតម្រូវដោយកថាខណ្ឌនេះ ត្រូវតែបានមកពីប្រភពផ្សេងក្រៅពីប្រភពដែលបានពណ៌នានៅក្នុងផ្នែករង (b) និង (d) ពន្ធលើអចលនទ្រព្យគិតតាមតម្លៃ ឬគណនីរងសេវាសង្គមនៃគណនីពន្ធលើការលក់នៃមូលនិធិប្រាក់ចំណូលមូលដ្ឋាន។

(5) (A) សម្រាប់កម្មវិធីដែលបានពណ៌នានៅក្នុងកថាខណ្ឌរង (C) ដល់ (E) ដោយរាប់បញ្ចូលទាំងស្រុងនៃកថាខណ្ឌ (1) នៃផ្នែករង (a) និងដែលត្រូវបានរួមបញ្ចូលនៅក្នុងច្បាប់ស្តីពីការផ្ទេរភារកិច្ចនៃឆ្នាំ 2011 ប្រសិនបើមានការផ្លាស់ប្តូរបន្តបន្ទាប់នៅក្នុងលក្ខន្តិកៈ ឬបទបញ្ញត្តិសហព័ន្ធ ដែលកែប្រែប្តូរលក្ខខណ្ឌក្នុងការទទួលបានមូលនិធិបដិភាគសហព័ន្ធដូចដែលបានពណ៌នានៅក្នុងច្បាប់ស្តីពីការផ្ទេរភារកិច្ចនៃឆ្នាំ 2011 ហើយមានផលប៉ះពាល់ជារួមក្នុងការបង្កើនការចំណាយដែលកើតឡើងដោយទីភ្នាក់ងារមូលដ្ឋាននោះ រដ្ឋត្រូវផ្តល់យ៉ាងហោចណាស់ 50 ភាគរយជារៀងរាល់ឆ្នាំ នៃចំណែកការចំណាយដែលមិនមែនជារបស់សហព័ន្ធនៃតម្លៃចំណាយទាំងនោះ ដូចដែលបានកំណត់ដោយរដ្ឋ។

(B) នៅពេលដែលរដ្ឋគឺជាភាគីនៃបណ្តឹងណាមួយ ដែលត្រូវបានប្តឹងនៅក្នុងនីតិវិធីតុលាការ ឬរដ្ឋបាលសហព័ន្ធ ដែលពាក់ព័ន្ធនឹងកម្មវិធីមួយ ឬច្រើនដែលបានពណ៌នានៅក្នុងកថាខណ្ឌរង (C) ដល់ (E) ដោយរាប់បញ្ចូលទាំងស្រុងនៃកថាខណ្ឌ (1) នៃផ្នែករង (a) និងដែលត្រូវបានរួមបញ្ចូលនៅក្នុងច្បាប់ស្តីពីការផ្ទេរភារកិច្ចនៃឆ្នាំ 2011 ហើយមានកិច្ចព្រមព្រៀងដោះស្រាយ ឬដីកាតុលាការ ឬដីការដ្ឋបាល ដែលដាក់កំហិតឱ្យមានការចំណាយក្នុងទម្រង់ជាការពិន័យជាប្រាក់ ឬមានផលប៉ះពាល់ជារួមក្នុងការបង្កើនការចំណាយ ដែលទីភ្នាក់ងារមូលដ្ឋានបានរ៉ាប់រងរួចហើយសម្រាប់កម្មវិធី ឬកម្រិតសេវាដែលតម្រូវដោយច្បាប់ស្តីពីការផ្ទេរភារកិច្ចនៃឆ្នាំ 2011 នោះ រដ្ឋត្រូវផ្តល់យ៉ាងហោចណាស់ 50 ភាគរយជារៀងរាល់ឆ្នាំ នៃចំណែកការចំណាយដែលមិនមែនជារបស់សហព័ន្ធនៃតម្លៃចំណាយទាំងនោះ ដូចដែលបានកំណត់ដោយរដ្ឋ។ ការទូទាត់ប្រាក់ពីរដ្ឋមិនត្រូវបានតម្រូវឡើយ ប្រសិនបើរដ្ឋកំណត់ថា កិច្ចព្រមព្រៀងដោះស្រាយ ឬដីកានោះ ទាក់ទងនឹងទីភ្នាក់ងារមូលដ្ឋានមួយ ឬច្រើន ដែលខកខានក្នុងការបំពេញភារកិច្ចរដ្ឋបាល ខកខានក្នុងការបំពេញកាតព្វកិច្ចផ្លូវច្បាប់ដោយសុចរិត ឬប្រព្រឹត្តក្នុងលក្ខណៈធ្វេសប្រហែស ឬខ្វះការប្តេជ្ញាចិត្ត។

(C) មូលនិធិរដ្ឋដែលត្រូវបានផ្តល់ជូននៅក្នុងកថាខណ្ឌនេះ ត្រូវតែបានមកពីប្រភពមូលនិធិផ្សេងក្រៅពីប្រភពដែលបានពណ៌នានៅក្នុងផ្នែករង (b) និង (d) ពន្ធលើអចលនទ្រព្យគិតតាមតម្លៃ ឬគណនីរងសេវាសង្គមនៃគណនីពន្ធលើការលក់នៃមូលនិធិប្រាក់ចំណូលមូលដ្ឋាន។

(6) ប្រសិនបើរដ្ឋ ឬទីភ្នាក់ងារមូលដ្ឋានខកខានក្នុងការបំពេញភារកិច្ច ឬកាតព្វកិច្ចក្រោមផ្នែកនេះ ឬក្រោមច្បាប់ស្តីពីការផ្ទេរភារកិច្ចនៃឆ្នាំ 2011 ភាគីដែលពាក់ព័ន្ធ អាចស្វែងរកដំណោះស្រាយតាមផ្លូវតុលាការបាន។ នីតិវិធីក្តីទាំងនេះត្រូវមានអាទិភាពលើរឿងក្តីរដ្ឋប្បវេណីផ្សេងទៀតទាំងអស់។

(7) មូលនិធិដែលបានដាក់តម្កល់នៅក្នុងមូលនិធិប្រាក់ចំណូលខោនធីមូលដ្ឋានឆ្នាំ 2011 ត្រូវចំណាយក្នុងលក្ខណៈមួយដែលត្រូវបានរៀបចំឡើងដើម្បីរក្សានូវសិទ្ធិទទួលបានរបស់រដ្ឋសម្រាប់មូលនិធិបដិភាគសហព័ន្ធ និងដើម្បីធានាការអនុលោមតាមដោយរដ្ឋទៅនឹងស្តង់ដាសហព័ន្ធជាធរមានដែលគ្រប់គ្រងលើការផ្តល់សេវាសុវត្ថិភាពសាធារណៈរបស់រដ្ឋ។

(8) មូលនិធិដែលបានដាក់តម្កល់នៅក្នុងមូលនិធិប្រាក់ចំណូលខោនធីមូលដ្ឋានឆ្នាំ 2011 មិនត្រូវប្រើប្រាស់ដោយទីភ្នាក់ងារមូលដ្ឋាន ដើម្បីជំនួសមូលនិធិផ្សេងទៀតសម្រាប់សេវាសុវត្ថិភាពសាធារណៈឡើយ។

(d) ប្រសិនបើពន្ធដែលបានពណ៌នានៅក្នុងផ្នែករង (b) ត្រូវបានកាត់បន្ថយ ឬឈប់មានសុពលភាពអនុវត្ត រដ្ឋត្រូវផ្តល់ប្រាក់ជារៀងរាល់ឆ្នាំទៅកាន់មូលនិធិប្រាក់ចំណូលមូលដ្ឋាននៃឆ្នាំ 2011 ក្នុងចំនួនមួយដែលស្មើនឹង ឬធំជាងចំនួនសរុប ដែលគួរតែត្រូវបានផ្តល់ដោយពន្ធនានាដែលបានពណ៌នានៅក្នុង ផ្នែករង (b)។ វិធីសាស្ត្រសម្រាប់ការកំណត់ចំនួននោះ ត្រូវពណ៌នានៅក្នុងច្បាប់ស្តីពីការផ្ទេរភារកិច្ចនៃឆ្នាំ 2011 ហើយរដ្ឋត្រូវមានកាតព្វកិច្ចក្នុងការផ្តល់ចំនួននោះ ដរាបណាទីភ្នាក់ងារមូលដ្ឋានត្រូវបានតម្រូវឱ្យបំពេញការទទួលខុសត្រូវលើសេវាសុវត្ថិភាពសាធារណៈដែលត្រូវបានចាត់តាំងដោយច្បាប់ស្តីពីការផ្ទេរភារកិច្ចនៃឆ្នាំ 2011។ ប្រសិនបើរដ្ឋខកខានក្នុងការអនុម័តឱ្យប្រើប្រាស់ថវិកានោះជារៀងរាល់ឆ្នាំ មន្ត្រីត្រួតពិនិត្យត្រូវផ្ទេរថវិកានោះពីមូលនិធិទូទៅ ជាចំណែកប្រចាំខែដែលត្រូវបែងចែកតាមសមាមាត្រទៅកាន់មូលនិធិប្រាក់ចំណូលមូលដ្ឋាននៃឆ្នាំ 2011។ បន្ទាប់ពីនោះមក អគ្គនាយកគ្រប់គ្រងហិរញ្ញវត្ថុត្រូវផ្តល់ទឹកប្រាក់ទាំងនេះទៅកាន់ទីភ្នាក់ងារមូលដ្ឋាន តាមរបៀបដែលបានណែនាំដោយច្បាប់ស្តីពីការផ្ទេរភារកិច្ចនៃឆ្នាំ 2011។ កាតព្វកិច្ចរបស់រដ្ឋក្រោមផ្នែករងនេះ មានអាទិភាពទាបជាងក្នុងការទទួលបាន ប្រាក់ពីមូលនិធិទូទៅ បើប្រៀបធៀបនឹងអាទិភាពទីមួយ សម្រាប់ប្រាក់ដែលត្រូវបែងចែកទុកតាមមាត្រាទី 8 នៃអត្ថបទ XVI និងអាទិភាពទីពីរ សម្រាប់ការទូទាត់បំណុល និងកាតព្វកិច្ចដែលត្រូវបានអនុម័តដោយអ្នកបោះឆ្នោត ដូចដែលបានពណ៌នានៅក្នុងមាត្រាទី 1 នៃអត្ថបទ XVI។

(e) (1) ដើម្បីធានាថាការអប់រំសាធារណៈមិនទទួលរងផលប៉ះពាល់ នៅក្នុងដំណើរការនៃការផ្តល់ការការពារដ៏សំខាន់ដល់សេវាសុវត្ថិភាពសាធារណៈរបស់មូលដ្ឋាន គណនីការពារការអប់រំ ត្រូវបានបង្កើតឡើងនៅក្នុងមូលនិធិទូទៅ ដើម្បីទទួល និងផ្តល់ប្រាក់ចំណូលដែលបានមកពីកំណើនពន្ធបន្ថែមដែលត្រូវបានដាក់កំហិតដោយ មាត្រានេះ ដូចដែលបានបញ្ជាក់នៅក្នុងផ្នែករង (f)។

(2) (A) មុនថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2013 និង មុនថ្ងៃទី 30 ខែមិថុនា នៃរៀងរាល់ឆ្នាំ *បន្ទាប់ពីនោះ* ~~ចាប់ពីឆ្នាំ 2014 ដល់ 2030 រួមបញ្ចូលទាំងអស់~~ នាយកហិរញ្ញវត្ថុ ត្រូវប៉ាន់ប្រមាណទឹកប្រាក់សរុបនៃចំណូលបន្ថែម ដោយដកចេញនូវប្រាក់បង្វិលសង ដែលនឹងទទួលបានពីកំណើនអត្រាពន្ធបន្ថែមដែលបានធ្វើឡើងនៅក្នុងផ្នែករង (f) ហើយនឹងមានសម្រាប់ការផ្ទេរចូលទៅក្នុងគណនីការពារការអប់រំ ក្នុងអំឡុងឆ្នាំសារពើពន្ធបន្ទាប់។ នាយកហិរញ្ញវត្ថុក៏ត្រូវធ្វើការប៉ាន់ស្មានដូចគ្នានេះត្រឹមថ្ងៃទី 10 ខែមករា ឆ្នាំ 2013 សម្រាប់ប្រាក់ចំណូលបន្ថែម បន្ទាប់ពីដកប្រាក់សងត្រឡប់វិញ ដែលរំពឹងថានឹងទទួលបាននៅចុងឆ្នាំសារពើពន្ធ 2012–13។

(B) ក្នុងរយៈពេល 10 ថ្ងៃចុងក្រោយនៃត្រីមាសនីមួយៗ ក្នុងចំណោមបីត្រីមាសដំបូងនៃរាល់ឆ្នាំសារពើពន្ធ ~~ចាប់ពីឆ្នាំ *2013–14* ឆ្នាំ 2013–14 ដល់ឆ្នាំ 2030–31 រួមបញ្ចូលទាំងអស់~~ អគ្គនាយកគ្រប់គ្រងហិរញ្ញវត្ថុត្រូវផ្ទេរមួយភាគបួននៃចំនួនសរុបដែលបានប៉ាន់ស្មាន អនុលោមតាមកថាខណ្ឌរង (A) ចូលទៅក្នុងគណនីការពារការអប់រំសម្រាប់ឆ្នាំសារពើភ័ណ្ឌនោះ លើកលែងតែទឹកប្រាក់នេះត្រូវបានកែសម្រួលតាមកថាខណ្ឌរង (D)។

(C) ក្នុងរាល់ឆ្នាំសារពើពន្ធ~~ចាប់ពីឆ្នាំ *2012–13*, ឆ្នាំ 2012–13 ដល់ឆ្នាំ 2032–33 រួមបញ្ចូលទាំងអស់~~ នាយកហិរញ្ញវត្ថុត្រូវគណនាការកែសម្រួលចំពោះគណនីការពារការអប់រំ ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌរង (D) ដោយបូកចំនួនខាងក្រោម ប្រសិនបើអាចអនុវត្តបាន៖

(i) ក្នុងត្រីមាសចុងក្រោយនៃរាល់ឆ្នាំសារពើពន្ធ~~ចាប់ពីឆ្នាំ *2012–13*, ឆ្នាំ 2012–13 ដល់ឆ្នាំ 2030–31 រួមបញ្ចូលទាំងអស់~~ នាយកហិរញ្ញវត្ថុត្រូវគណនាឡើងវិញនូវការប៉ាន់ស្មានដែលបានធ្វើសម្រាប់ឆ្នាំសារពើពន្ធនោះ អនុលោមតាមកថាខណ្ឌរង (A) ហើយត្រូវដកចំនួនដែលបានផ្ទេរចូលទៅក្នុងគណនីការពារការអប់រំរួចហើយសម្រាប់ឆ្នាំសារពើពន្ធនោះចេញពីការប៉ាន់ស្មានថ្មីនេះ។

(ii) នៅខែមិថុនា ឆ្នាំ 2015 និងរៀងរាល់ខែមិថុនា~~ចាប់ពីឆ្នាំ 2016 ដល់ឆ្នាំ 2033 រួមបញ្ចូលទាំងអស់~~ នាយកហិរញ្ញវត្ថុត្រូវកំណត់ជាចុងក្រោយនូវចំនួនទឹកប្រាក់ចំណូលបន្ថែម បន្ទាប់ពីដកប្រាក់សងត្រឡប់វិញ ដែលបានមកពីការដំឡើងអត្រាពន្ធបន្ថែមតាមកថាខណ្ឌរង (f) សម្រាប់ឆ្នាំសារពើពន្ធដែលបានបញ្ចប់ពីរឆ្នាំមុន។ ទឹកប្រាក់នៃការប៉ាន់ប្រមាណដែលបានធ្វើបច្ចុប្បន្នភាពដែលបានគណនានៅក្នុងប្រការ (i) សម្រាប់ឆ្នាំសារពើពន្ធដែលបានបញ្ចប់ពីរឆ្នាំមុន ត្រូវបានដកចេញពីទឹកប្រាក់នៃការកំណត់ចុងក្រោយនេះ។

(D) ប្រសិនបើផលបូកដែលបានកំណត់អនុលោមតាមកថាខណ្ឌរង (C) គឺជាចំនួនវិជ្ជមាន អគ្គនាយកគ្រប់គ្រងហិរញ្ញវត្ថុត្រូវផ្ទេរទឹកប្រាក់ស្មើនឹងផលបូកនោះ ចូលទៅក្នុងគណនីការពារការអប់រំ ក្នុងរយៈពេល 10 ថ្ងៃ មុនពេលបញ្ចប់ឆ្នាំសារពើពន្ធ។ ប្រសិនបើចំនួននោះគឺជាចំនួនអវិជ្ជមាន អគ្គនាយកគ្រប់គ្រងហិរញ្ញវត្ថុត្រូវផ្អាក ឬកាត់បន្ថយការផ្ទេរប្រចាំត្រីមាសបន្ទាប់ ប្រសិនបើមាន ទៅកាន់គណនីការពារការអប់រំ រហូតដល់ការកាត់បន្ថយសរុបស្មើនឹងចំនួនអវិជ្ជមានដែលបានពណ៌នានៅទីនេះ។ សម្រាប់គោលបំណងនៃការគណនាណាមួយដែលបានធ្វើឡើងស្របតាមប្រការ (i) នៃកថាខណ្ឌរង (C) ទឹកប្រាក់នៃការផ្ទេរប្រចាំត្រីមាសមិនត្រូវត្រូវបានកែប្រែឡើយ ដើម្បីឆ្លុះបញ្ចាំងពីការផ្អាក ឬការកាត់បន្ថយណាមួយដែលបានធ្វើឡើងអនុលោមតាមកថាខណ្ឌរងនេះ។

(E) មុនថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2018 និង មុនថ្ងៃទី 30 ខែមិថុនា នៃឆ្នាំនីមួយៗ ចាប់ពីឆ្នាំ 2019 ដល់ឆ្នាំ 2030 ដោយរាប់បញ្ចូលទាំងអស់ នាយកហិរញ្ញវត្ថុត្រូវប៉ាន់ស្មាន ចំនួនប្រាក់ចំណូលពន្ធបន្ថែម បន្ទាប់ពីដកប្រាក់សងត្រឡប់វិញ ដែលរំពឹងថានឹងទទួលបានក្នុងឆ្នាំសារពើពន្ធបន្ទាប់ ពីការដំឡើងអត្រាពន្ធតាមកថាខណ្ឌរង (f) នៅពេលបូកបញ្ចូលប្រាក់ចំណូលនេះជាមួយប្រាក់ចំណូលផ្សេងទៀតទាំងអស់ដែលមានសម្រាប់ប្រើប្រាស់ពីមូលនិធិទូទៅ នោះនឹងត្រូវការដើម្បីបំពេញ៖

(i) ការធានាការផ្តល់មូលនិធិអប្បបរមានៃមាត្រាទី 8 នៃអត្ថបទ XVI សម្រាប់ឆ្នាំសារពើពន្ធបន្ទាប់នោះ និង

(ii) ថវិកាតាមបន្ទុកការងារសម្រាប់ឆ្នាំសារពើពន្ធបន្ទាប់ ដោយមិនរាប់បញ្ចូលការចំណាយលើកម្មវិធីដែលបានរាប់បញ្ចូលរួចហើយតាមប្រការ (i)។ សម្រាប់គោលបំណងនៃមាត្រានេះ “ថវិកាតាមបន្ទុកការងារ” មានន័យដូចដែលបានកំណត់នៅក្នុងមាត្រាទី 13308.05 នៃក្រមរដ្ឋាភិបាល ដោយផ្អែកលើខ្លឹមសារ និងការបកស្រាយនៃមាត្រានោះដោយក្រសួងហិរញ្ញវត្ថុ នៅថ្ងៃទី 1 ខែមករា ឆ្នាំ 2016។ ទោះជាយ៉ាងណាក៏ដោយ “សេវាដែលត្រូវបានអនុញ្ញាតនាពេលបច្ចុប្បន្ន” មានន័យថា មានតែសេវាដែលត្រូវបានចាត់ទុកថាជា “សេវាដែលត្រូវបានអនុញ្ញាតនាពេលបច្ចុប្បន្ន” តាមមាត្រាទី 13308.05 នៃក្រមរដ្ឋាភិបាល គិតត្រឹមថ្ងៃទី 1 ខែមករា ឆ្នាំ 2016 ប៉ុណ្ណោះ។

(F) ដើម្បីបង្កើនសមត្ថភាពរបស់កុមារនៅសាលារៀននៅ California និងគ្រួសាររបស់ពួកគេ ក្នុងការទទួលបាន ការថែទាំសុខភាពដែលមានគុណភាព និងជាប្រចាំ ហើយកាត់បន្ថយការអវត្តមានពីសាលារៀនដោយសារបញ្ហាសុខភាព នៅពេលណាដែលនាយកហិរញ្ញវត្ថុប៉ាន់ស្មានថា ទឹកប្រាក់ដែលអាចផ្ទេរចូលទៅក្នុង គណនីការពារការអប់រំ សម្រាប់ឆ្នាំសារពើពន្ធបន្ទាប់មានច្រើនជាងចំនួនប្រាក់ចំណូលដែលត្រូវការពីគណនីនោះតាមកថាខណ្ឌរង (E) សម្រាប់ឆ្នាំសារពើពន្ធបន្ទាប់ នាយកហិរញ្ញវត្ថុត្រូវកំណត់ទឹកប្រាក់ដែលនៅសល់នោះ។ ហាសិបភាគរយនៃប្រាក់ដែលនៅសល់នោះ រហូតដល់អតិបរមាពីរពាន់លានដុល្លារក្នុងឆ្នាំសារពើពន្ធណាមួយ ត្រូវបែងចែកដោយអគ្គនាយកគ្រប់គ្រងហិរញ្ញវត្ថុ ពីគណនីការពារការអប់រំ ទៅកាន់ក្រសួងសេវាថែទាំសុខភាពរដ្ឋ California ជាប្រចាំត្រីមាស ដើម្បីបង្កើនការផ្តល់មូលនិធិសម្រាប់កម្មវិធី និងសេវាថែទាំសុខភាពដែលមានស្រាប់ ដូចដែលបានពណ៌នានៅក្នុងជំពូកទី 7 (ចាប់ផ្តើមពីមាត្រាទី 14000) ដល់ជំពូកទី 8.9 (ចាប់ផ្តើមពីមាត្រាទី 14700) ដោយរាប់បញ្ចូលទាំងស្រុង នៃផ្នែកទី 3 នៃភាគទី 9 នៃក្រមសុខុមាលភាព និងស្ថាប័ន។ ការផ្តល់មូលនិធិនេះត្រូវប្រើប្រាស់សម្រាប់តែសេវាថែទាំសុខភាពកម្រិតធ្ងន់ សង្គ្រោះបន្ទាន់ ធ្ងន់ធ្ងរភ្លាមៗ និងការបង្ការដល់កុមារ និងក្រុមគ្រួសាររបស់ពួកគេ ដែលផ្តល់ដោយអ្នកជំនាញថែទាំសុខភាព និងមណ្ឌលថែទាំសុខភាពដែលទទួលបានអាជ្ញាប័ណ្ណអនុលោមតាមមាត្រាទី 1250 នៃក្រមសុខាភិបាល និង សុវត្ថិភាពព្រមទាំងដល់គម្រោងសុខភាព ឬភាគីផ្សេងទៀត ដែលគ្រប់គ្រងការផ្តល់ការថែទាំសុខភាពសម្រាប់អ្នកទទួលផលពីកម្មវិធី Medi-Cal ដែលកំពុងចុះកិច្ចសន្យាជាមួយក្រសួងសេវាថែទាំសុខភាពរដ្ឋ California ដើម្បីផ្តល់អត្ថប្រយោជន៍សុខភាពស្របតាមមាត្រានេះ។

(G) ការបែងចែកដែលបានផ្តល់ជូននៅក្នុងកថាខណ្ឌរង (F) អាចត្រូវបានផ្អាកដោយលក្ខន្តិកៈ ក្នុងអំឡុងឆ្នាំសារពើពន្ធដែលគ្រោះអាសន្នថវិកាត្រូវបានប្រកាស ប៉ុន្តែក្នុងលក្ខខណ្ឌដែលការបែងចែកនេះមិនត្រូវកាត់បន្ថយលើសពីការកាត់បន្ថយតាមសមាមាត្រ នៅក្នុងការចំណាយសរុបនៃមូលនិធិទូទៅសម្រាប់ឆ្នាំនោះឡើយ។ សម្រាប់គោលបំណងនៃមាត្រានេះ “គ្រោះអាសន្នថវិកា” មានអត្ថន័យដូចគ្នានឹងអ្វីដែលមានចែងនៅក្នុងកថាខណ្ឌ (2) នៃផ្នែករង (b) នៃមាត្រាទី 22 នៃអត្ថបទ XVI។

(H) ការផ្តល់មូលនិធិដែលត្រូវបានផ្តល់អនុលោមតាមកថាខណ្ឌរង (F) មិនត្រូវប្រើប្រាស់ដើម្បីជំនួសមូលនិធិទូទៅរបស់រដ្ឋដែលមានស្រាប់ សម្រាប់ចំណែកនៃការទូទាត់ដែលមិនមែនជារបស់សហព័ន្ធ សម្រាប់កម្មវិធីទាំងនោះឡើយ ហើយដោយស្របតាមច្បាប់សហព័ន្ធ ត្រូវប្រើប្រាស់ដើម្បីទទួលបានមូលនិធិបដិភាគសហព័ន្ធ Medicaid។

(3) ថវិកាទាំងអស់នៅក្នុងគណនីការពារការអប់រំ ត្រូវបានអនុម័តឱ្យប្រើប្រាស់ជាបន្តបន្ទាប់នៅទីនេះ សម្រាប់ការគាំទ្រដល់មណ្ឌលសិក្សាធិការ សាលារៀន ការិយាល័យអប់រំខោនធី សាលា ធម្មនុញ្ញ និង មណ្ឌលសិក្សាមហាវិទ្យាល័យសហគមន៍ ដូចដែលបានចែងនៅក្នុងកថាខណ្ឌនេះ និងសម្រាប់ការថែទាំសុខភាព ដូចដែលបានចែងនៅក្នុងកថាខណ្ឌរង (F) នៃកថាខណ្ឌ (2)។

(A) ដប់មួយភាគរយនៃថវិកាដែលត្រូវបានអនុម័តឱ្យប្រើប្រាស់សម្រាប់ការអប់រំស្របតាមកថាខណ្ឌនេះ ត្រូវបែងចែកជាប្រចាំត្រីមាសដោយក្រុមប្រឹក្សាភិបាលមហាវិទ្យាល័យសហគមន៍ California ទៅកាន់មណ្ឌលសិក្សាមហាវិទ្យាល័យសហគមន៍ ដើម្បីផ្តល់មូលនិធិសម្រាប់គោលបំណងទូទៅដល់មណ្ឌលសិក្សាមហាវិទ្យាល័យសហគមន៍ ក្នុងសមាមាត្រទៅនឹងចំនួនដែលត្រូវបានកំណត់ស្របតាមមាត្រាទី 84750.5 នៃក្រមអប់រំ ដូចដែលមាត្រានៃក្រមនោះមានចែងនៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2012។ ចំនួនទឹកប្រាក់ដែលបានគណនាអនុលោមតាមកថាខណ្ឌរងនេះ ត្រូវកាត់បន្ថយដោយចំនួនទឹកប្រាក់ដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌរង (a), (c) និង (d) នៃមាត្រាទី 84751 នៃក្រមអប់រំ ដោយយោងតាមខ្លឹមសារនៃមាត្រាទាំងនោះដែលមានសុពលភាពនៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2012 ដែលមានចំនួនលើសពីចំនួនដែលបានគណនាអនុលោមតាមមាត្រាទី 84750.5 នៃក្រមអប់រំ ដោយយោងតាមខ្លឹមសារនៃមាត្រាទាំងនោះដែលមានសុពលភាពនៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2012។ ប៉ុន្តែគ្មានមណ្ឌលសិក្សាមហាវិទ្យាល័យសហគមន៍ណាមួយត្រូវទទួលបានថវិកាតិចជាងមួយរយដុល្លារ ($100) សម្រាប់និស្សិតពេញម៉ោងដែលមានសមមូលមួយនាក់នោះទេ។

(B) ប៉ែតសិបប្រាំបួនភាគរយនៃថវិកាដែលត្រូវបានអនុម័តឱ្យប្រើប្រាស់សម្រាប់ការអប់រំស្របតាមកថាខណ្ឌនេះ ត្រូវបែងចែកជាប្រចាំត្រីមាសដោយនាយកអប់រំសាធារណៈ ដើម្បីផ្តល់មូលនិធិសម្រាប់គោលបំណងទូទៅដល់

3

មណ្ឌលសិក្សាធិការ ការិយាល័យអប់រំខោនធី និងការផ្តល់មូលនិធិសម្រាប់គោលបំណងទូទៅរបស់រដ្ឋដល់សាលា ធម្មនុញ្ញ ក្នុងសមាមាត្រទៅនឹងដែនកំណត់ចំណូលដែលបានគណនាអនុលោមតាមមាត្រាទី 2558 និងទី 42238 នៃក្រមអប់រំ និងចំនួនដែលបានគណនាអនុលោមតាមមាត្រាទី 47633 នៃក្រមអប់រំ សម្រាប់ការិយាល័យអប់រំខោនធី មណ្ឌលសិក្សាធិការ និងសាលា ធម្មនុញ្ញ រៀងៗខ្លួន ដោយយោងតាមខ្លឹមសារនៃមាត្រានោះដែលមានសុពលភាពនៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2012។ ចំនួនទឹកប្រាក់ដែលបានគណនាតាមវិធីនេះ ត្រូវកាត់បន្ថយដោយចំនួនទឹកប្រាក់ដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌរង (c) នៃមាត្រាទី 2558 កថាខណ្ឌ (1) ដល់ (7) នៃកថាខណ្ឌរង (h) នៃមាត្រាទី 42238 និងមាត្រាទី 47635 នៃក្រមអប់រំ សម្រាប់ការិយាល័យអប់រំខោនធី មណ្ឌលសិក្សាធិការសាលារៀន និងសាលា ធម្មនុញ្ញ រៀងៗខ្លួន ដោយយោងតាមខ្លឹមសារនៃមាត្រា ទាំងនោះដែលមានសុពលភាពនៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2012 ប្រសិនបើចំនួនទឹកប្រាក់ទាំងនោះមានចំនួនលើសពីចំនួនដែលបានគណនាតាមមាត្រាទី 2558, 42238 និង 47633 នៃក្រមអប់រំ សម្រាប់ការិយាល័យអប់រំខោនធី មណ្ឌលសិក្សាធិការសាលារៀន និងសាលា ធម្មនុញ្ញ រៀងៗខ្លួន ដោយយោងតាមខ្លឹមសារនៃមាត្រាទាំងនោះដែលមានសុពលភាពនៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2012។ ប៉ុន្តែមណ្ឌលសិក្សាធិការសាលារៀន ការិយាល័យអប់រំខោនធី ឬសាលា ធម្មនុញ្ញ ណាមួយ មិនត្រូវទទួលបានថវិកាតិចជាងពីររយដុល្លារ ($200) សម្រាប់សម្រាប់សិស្សចូលរៀនប្រចាំថ្ងៃជាមធ្យមម្នាក់នោះទេ។

(4) ផ្នែករងនេះមានសុពលភាពអនុវត្តដោយស្វ័យប្រវត្តិ និងមិនតម្រូវឱ្យមាន ចំណាត់ការនីតិបញ្ញត្តិណាមួយ ដើម្បីចូលជាធរមានឡើយ។ ការបែងចែកថវិកានៅក្នុងគណនីការពារការអប់រំ ដោយក្រុមប្រឹក្សាភិបាលមហាវិទ្យាល័យសហគមន៍រដ្ឋ California និងនាយកអប់រំសាធារណៈ មិនត្រូវពន្យារពេល ឬរងផលប៉ះពាល់ក្នុងលក្ខណៈផ្សេងណាមួយ ដោយសារការខកខានរបស់ស្ថាប័ននីតិបញ្ញត្តិ និងអភិបាលរដ្ឋ ក្នុងការអនុម័តសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ អនុលោមតាមផ្នែកទី 12 នៃអត្ថបទ IV ដោយការអនុវត្តផ្នែករង (h) នៃមាត្រាទី 8 នៃអត្ថបទ XVI ឬដោយសកម្មភាព ឬការខកខានក្នុងការចាត់វិធានការផ្សេងទៀតណាមួយ ដោយស្ថាប័ននីតិបញ្ញត្តិ ឬអភិបាលរដ្ឋឡើយ។

(5) ទោះជាមានបទបញ្ញត្តិផ្សេងទៀតនៃច្បាប់ក៏ដោយ ថវិកាដែលបានដាក់តម្កល់នៅក្នុងគណនីការពារការអប់រំសម្រាប់ការអប់រំ មិនត្រូវប្រើប្រាស់ដើម្បីទូទាត់ការចំណាយណាមួយដែលកើតឡើងដោយស្ថាប័ននីតិបញ្ញត្តិ អភិបាលរដ្ឋ ឬទីភ្នាក់ងារណាមួយនៃរដ្ឋាភិបាលរដ្ឋឡើយ។

(6) មណ្ឌលសិក្សាមហាវិទ្យាល័យសហគមន៍ ការិយាល័យអប់រំខោនធី មណ្ឌលសិក្សាធិការសាលារៀន ឬសាលា ធម្មនុញ្ញ ត្រូវមានសិទ្ធិអំណាចផ្តាច់មុខក្នុងការកំណត់ថាតើថវិកាដែលទទួលបានពីគណនីការពារការអប់រំ ត្រូវចំណាយយ៉ាងដូចម្តេចនៅក្នុងសាលារៀន ឬបណ្តាសាលារៀនដែលស្ថិតក្នុងដែនយុត្តាធិការរបស់ខ្លួន ប៉ុន្តែក្នុងលក្ខខណ្ឌដែលក្រុមប្រឹក្សា ឬអង្គភាពគ្រប់គ្រងដែលពាក់ព័ន្ធ ត្រូវធ្វើការសម្រេចលើការចំណាយទាំងនេះ នៅក្នុងសម័យប្រជុំបើកចំហនៃកិច្ចប្រជុំសាធារណៈរបស់ក្រុមប្រឹក្សា ឬអង្គភាពគ្រប់គ្រងនោះ ហើយមិនត្រូវប្រើប្រាស់មូលនិធិណាមួយពីគណនីការពារការអប់រំ សម្រាប់ប្រាក់បៀវត្សរ៍ ឬអត្ថប្រយោជន៍របស់រដ្ឋបាល ឬការចំណាយរដ្ឋបាលផ្សេងទៀតឡើយ។ មណ្ឌលសិក្សាមហាវិទ្យាល័យសហគមន៍ ការិយាល័យអប់រំខោនធី មណ្ឌលសិក្សាធិការសាលារៀន និងសាលា ធម្មនុញ្ញ នីមួយៗ ត្រូវផ្សព្វផ្សាយជារៀងរាល់ឆ្នាំនៅលើគេហទំព័រអ៊ីនធឺណិតរបស់ខ្លួន នូវរបាយការណ៍គណនេយ្យអំពីចំនួនទឹកប្រាក់ដែលទទួលបានពីគណនីការពារការអប់រំ និងថាតើប្រាក់នោះត្រូវបានចំណាយយ៉ាងដូចម្តេច។

(7) សវនកម្មហិរញ្ញវត្ថុ និងគោរពភាពឯករាជ្យប្រចាំឆ្នាំ ដែលតម្រូវចំពោះមណ្ឌលសិក្សាមហាវិទ្យាល័យសហគមន៍ ការិយាល័យអប់រំខោនធី មណ្ឌលសិក្សាធិការសាលារៀន និងសាលា ធម្មនុញ្ញ បន្ថែមលើលក្ខខណ្ឌតម្រូវផ្សេងទៀតទាំងអស់នៃច្បាប់ ត្រូវបញ្ជាក់ និងផ្ទៀងផ្ទាត់ថាតើថវិកាដែលបានផ្តល់ពីគណនីការពារការអប់រំ ត្រូវបានផ្តល់ និងចំណាយបានត្រឹមត្រូវដូចដែលបានតម្រូវដោយមាត្រានេះដែរឬទេ។ ការចំណាយដែលកើតឡើងដោយអង្គភាពទាំងនោះ ដើម្បីគោរពតាមលក្ខខណ្ឌតម្រូវសវនកម្មបន្ថែមនៃមាត្រានេះ អាចត្រូវបានទូទាត់ដោយប្រើប្រាស់ថវិកាពីគណនីការពារការអប់រំ ហើយមិនត្រូវចាត់ទុកថាជាការចំណាយរដ្ឋបាលឡើយ សម្រាប់គោលបំណងនៃ មាត្រានេះ។

(8) ចំណូលដោយមិនគិតបញ្ចូលប្រាក់សំណងដែលទទួលបានស្របតាមផ្នែករង (f) សម្រាប់ការដាក់ប្រាក់នៅក្នុងគណនីការពារវិស័យអប់រំស្របតាមផ្នែកនេះ ត្រូវបានចាក់ទុកថាជា “ចំណូលពីមូលនិធិទូទៅ”, “មូលនិធិទូទៅទទួលបានពីពន្ធ” និង “ប្រាក់ដែលត្រូវបានអនុវត្តដោយរដ្ឋសម្រាប់ការគាំទ្រដល់អាជ្ញាធរសាលារៀន និងអាជ្ញាធរមហាវិទ្យាល័យសហគមន៍” សម្រាប់គោលបំណងនៃមាត្រាទី 8 នៃអត្ថបទ XVI។

(f) (1) (A) បន្ថែមពីលើពន្ធដែលបានកំណត់ដោយផ្នែកទី 1 (ចាប់ផ្តើមជាមួយមាត្រាទី 6001) ភាគទី 2 នៃក្រមចំណូល និងពន្ធដារ ដើម្បីជាឯកសិទ្ធិនៃការលក់ទ្រព្យរូបីបុគ្គលក្នុងតម្លៃលក់រាយ ពន្ធនេះត្រូវបានកំណត់ចំពោះអ្នកលក់រាយទាំងអស់ក្នុងអត្រា 1/4 ភាគរយនៃវិក្កយបត្រសរុបរបស់អ្នកលក់រាយនៃការលក់ទ្រព្យរូបីបុគ្គលទាំងអស់ដែលលក់រាយនៅក្នុងរដ្ឋនេះ នៅ ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2013 និងមុនថ្ងៃទី 1 ខែមករា ឆ្នាំ 2017។

(B) បន្ថែមពីលើដែលបានកំណត់ដោយផ្នែកទី 1 (ចាប់ផ្តើមជាមួយមាត្រាទី 6001) នៃភាគទី 2 នៃក្រមចំណូល និងពន្ធដារ ពន្ធដែលអនុវត្តត្រូវបានកំណត់លើការរក្សាទុក ការប្រើប្រាស់ ឬការប្រើប្រាស់នូវទ្រព្យរូបីបុគ្គលដែលបានទិញពីអ្នកលក់រាយនៅក្នុងរដ្ឋនេះនៅ និងក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2013 និង មុនថ្ងៃទី 1 ខែមករា ឆ្នាំ 2017 សម្រាប់ការរក្សាទុក ការប្រើប្រាស់ ឬការប្រើប្រាស់ផ្សេងទៀតនៅក្នុងរដ្ឋនៅក្នុងអត្រា 1/4 ភាគរយនៃតម្លៃលក់ទ្រព្យនោះ។

(C) ច្បាប់ស្តីពីពន្ធលើការលក់ និងការប្រើប្រាស់ រួមទាំងវិសោធនកម្មទាំងឡាយដែលបានអនុម័តនៅ ឬក្រោយកាលបរិច្ឆេទមានប្រសិទ្ធភាពនៃផ្នែកនេះ ត្រូវអនុវត្តចំពោះពន្ធដែលបានកំណត់ស្របតាមកថាខណ្ឌនេះ។

(D) កថាខណ្ឌនេះនឹងមិនត្រូវដំណើរការនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2017។

(2) សម្រាប់ឆ្នាំជាប់ពន្ធដែលចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2012 ~~និងមុនថ្ងៃទី 1 ខែមករា ឆ្នាំ 2031~~ ទាក់ទងនឹងពន្ធដែលបានកំណត់អនុលោមតាមផ្នែកទី 17041 នៃក្រមចំណូល និង ពន្ធដារ ចន្លោះអត្រាពន្ធលើប្រាក់ចំណូល និងអត្រា 9.3 ភាគរយដែលបានកំណត់នៅក្នុងកថាខណ្ឌ (1) នៃផ្នែករង (a) មាត្រាទី 17041 នៃក្រមចំណូល និង ពន្ធដារ ត្រូវកែប្រែតាមអត្រានីមួយៗខាងក្រោម៖

(A) (i) សម្រាប់ចំណែកនៃប្រាក់ចំណូលជាប់ពន្ធដែលលើសពីម្ភៃប្រាំម៉ឺនដុល្លារ ($250,000) និងមិនលើសសាមសិបម៉ឺនដុល្លារ ($300,000) អត្រាពន្ធគឺ 10.3 ភាគរយនៃចំនួនដែលលើសពីម្ភៃប្រាំម៉ឺនដុល្លារ ($250,000)។

(ii) សម្រាប់ចំណែកនៃប្រាក់ចំណូលជាប់ពន្ធដែលលើសពី សាមសិបម៉ឺនដុល្លារ ($300,000) និងមិនលើសពី ហាសិបម៉ឺនដុល្លារ ($500,000) អត្រាពន្ធគឺ 11.3 ភាគរយនៃចំនួនដែលលើសពីសាមសិបម៉ឺនដុល្លារ ($300,000)។

(iii) សម្រាប់ចំណែកនៃប្រាក់ចំណូលជាប់ពន្ធដែលលើសពី ហាសិបម៉ឺនដុល្លារ ($500,000) អត្រាពន្ធគឺ 12.3 ភាគរយនៃចំនួនដែលលើសពី ហាសិបម៉ឺនដុល្លារ ($500,000)។

(B) ចន្លោះអត្រាពន្ធលើប្រាក់ចំណូលដែលបានកំណត់ក្នុងប្រការ (i), (ii) និង (iii) នៃកថាខណ្ឌ (A) ត្រូវគណនាឡើងវិញសម្រាប់តែឆ្នាំជាប់ពន្ធដែលចាប់ផ្តើមនៅ និងក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2013 លើកលែងតែមានចែងផ្ទុយពីនេះក្នុងផ្នែករង (h) នៃមាត្រាទី 17041 នៃក្រមចំណូល និងពន្ធដារ។

(C) (i) សម្រាប់គោលបំណងនៃផ្នែករង (g) នៃមាត្រាទី 19136 នៃក្រមចំណូល និងពន្ធដារ កថាខណ្ឌនេះនឹងត្រូវបានចាត់ទុកថាជាច្បាប់នៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2012។

(ii) សម្រាប់គោលបំណងនៃផ្នែកទី 10 (ចាប់ផ្តើមជាមួយមាត្រាទី 17001) និង ផ្នែកទី 10.2 (ចាប់ផ្តើមជាមួយមាត្រាទី 18401) នៃភាគទី 2 នៃក្រមចំណូល និងពន្ធដារ ចន្លោះអត្រាពន្ធ និងអត្រាពន្ធដែលបានកែប្រែដែលបានបង្កើតឡើង និងកំណត់ដោយកថាខណ្ឌនេះ នឹងត្រូវចាត់ទុកថា ត្រូវបានបង្កើតឡើង និងកំណត់នៅក្រោមមាត្រាទី 17041 នៃក្រមចំណូល និងពន្ធដារ។

~~(D) កថាខណ្ឌនេះនឹងមិនត្រូវដំណើរការនៅថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2031។~~

(3) សម្រាប់ឆ្នាំជាប់ពន្ធដែលចាប់ផ្តើមនៅ ឬ ក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2012 ~~និង មុនថ្ងៃទី 1 ខែមករា ឆ្នាំ 2031~~ ទាក់ទងនឹងពន្ធដែលបានកំណត់អនុលោមតាមមាត្រាទី 17041 នៃក្រមចំណូល និងពន្ធដារ ចន្លោះអត្រាពន្ធលើប្រាក់ចំណូល និងអត្រា 9.3 ភាគរយដែលបានកំណត់នៅក្នុងកថាខណ្ឌ (1) នៃផ្នែករង (c) មាត្រាទី 17041 នៃក្រមចំណូល និងពន្ធដារ ត្រូវកែប្រែតាមអត្រានីមួយៗខាងក្រោម៖

(A) (i) សម្រាប់ចំណែកនៃប្រាក់ចំណូលជាប់ពន្ធដែលលើសពីសាមសិបបួនម៉ឺនដុល្លារ ($340,000) និង មិនលើសពី សែសិបម៉ឺនប្រាំបីពាន់ដុល្លារ ($408,000) អត្រាពន្ធគឺ 10.3 ភាគរយនៃចំនួនដែលលើសពី សាមសិបបួនម៉ឺនដុល្លារ ($340,000)។

(ii) សម្រាប់ចំណែកនៃប្រាក់ចំណូលជាប់ពន្ធដែលលើសពី សែសិបម៉ឺនប្រាំបីពាន់ដុល្លារ ($408,000) និង មិនលើសពី ហុកសិបប្រាំបីម៉ឺនដុល្លារ ($680,000) អត្រាពន្ធគឺ 11.3 ភាគរយនៃចំនួនដែលលើសពី សែសិបម៉ឺនប្រាំបីពាន់ដុល្លារ ($408,000)។

(iii) សម្រាប់ចំណែកនៃប្រាក់ចំណូលជាប់ពន្ធដែលលើសពី ហុកសិបប្រាំបីម៉ឺនដុល្លារ ($680,000) អត្រាពន្ធគឺ 12.3 ភាគរយនៃចំនួនដែលលើសពី ហុកសិបប្រាំបីម៉ឺនដុល្លារ ($680,000)។

(B) ចន្លោះអត្រាពន្ធលើប្រាក់ចំណូលដែលបានកំណត់ក្នុងប្រការ (i), (ii) និង (iii) នៃកថាខណ្ឌរង (A) ត្រូវគណនាឡើងវិញសម្រាប់តែឆ្នាំជាប់ពន្ធដែលចាប់ផ្តើមនៅ និង ក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2013 លើកលែងតែមានចែងផ្ទុយពីនេះក្នុងផ្នែករង (h) នៃមាត្រាទី 17041 នៃក្រមចំណូល និងពន្ធដារ។

(C) (i) សម្រាប់គោលបំណងនៃផ្នែករង (g) នៃមាត្រាទី 19136 នៃក្រមចំណូល និង ពន្ធដារ កថាខណ្ឌនេះនឹងត្រូវបានចាត់ទុកថាជាជំពូកនៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2012។

(ii) សម្រាប់គោលបំណងនៃផ្នែកទី 10 (ចាប់ផ្តើមជាមួយមាត្រាទី 17001) និងផ្នែកទី 10.2 (ចាប់ផ្តើមជាមួយមាត្រាទី 18401) នៃភាគទី 2 នៃក្រមចំណូល និង ពន្ធដារ ចន្លោះអត្រាពន្ធ និង អត្រាពន្ធដែលបានកែប្រែដែលបានបង្កើតឡើង និងកំណត់ដោយកថាខណ្ឌនេះ នឹងត្រូវចាត់ទុកថា ត្រូវបានបង្កើតឡើង និងកំណត់នៅក្រោមមាត្រាទី 17041 នៃក្រមចំណូល និងពន្ធដារ។

~~(D) កថាខណ្ឌនេះនឹងមិនត្រូវដំណើរការនៅថ្ងៃទី 1 ខែធ្នូ ឆ្នាំ 2031។~~

(g) (1) អគ្គនាយកគ្រប់គ្រងហិរញ្ញវត្ថុអនុលោមតាមសមត្ថកិច្ចផ្លូវច្បាប់របស់ខ្លួន អាចធ្វើសវនកម្មលើការចំណាយពីមូលនិធិចំណូលក្នុងស្រុកនៃឆ្នាំ 2011 និងមូលនិធិចំណូលក្នុងស្រុករបស់ខោនធីនៃឆ្នាំ 2011 ហើយត្រូវធ្វើសវនកម្មគណនីការពារវិស័យអប់រំ ដើម្បីធានាបានថាមូលនិធិទាំងនោះត្រូវបានប្រើប្រាស់ និងតាមដានដោយមានលក្ខណៈស្របតាមផ្នែកនេះ។

(2) អគ្គមេធាវី ឬ មេធាវីក្នុងមូលដ្ឋានត្រូវធ្វើការស៊ើបអង្កេតឱ្យបានទាន់ពេលវេលា និងអាចស្វែងរកការពិន័យផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌចំពោះការប្រើប្រាស់មិនបានត្រឹមត្រូវនូវប្រាក់នៅក្នុងមូលនិធិចំណូលក្នុងស្រុករបស់ខោនធីនៃឆ្នាំ 2011 ឬគណនីការពារវិស័យអប់រំ។

មាត្រាទី 5. ភាពប្រឆាំងគ្នានៃវិធានការ។

ក្នុងករណីដែលវិធានការនេះ និង វិធានការផ្សេងទៀតដែលប៉ះពាល់ដល់អត្រាពន្ធលើប្រាក់ចំណូលបុគ្គលត្រូវបង្ហាញនៅលើសន្លឹកឆ្នោតបោះឆ្នោតទូទាំងរដ្ឋដូចគ្នា នោះបទបញ្ញត្តិនៃវិធានការផ្សេង ឬវិធានការនោះនឹងត្រូវចាត់ទុកថាមានភាពប្រឆាំងនឹងវិធានការនេះ។ ក្នុងករណីដែលវិធានការនេះទទួលបានសំឡេងគាំទ្រច្រើនជាងវិធានការដែលត្រូវបានចាត់ទុកថាមានភាពប្រឆាំងនឹងវា បទបញ្ញត្តិនៃវិធានការនេះត្រូវមានសុពលភាពលុបលើទាំងស្រុង ហើយវិធានការផ្សេងទៀត និងវិធានការនោះត្រូវចាត់ទុកជាមោឃៈ។

មាត្រាទី 6. ការបំបែកចេញពីគ្នាបាន។

ប្រសិនបើបទបញ្ញត្តិនៃច្បាប់នេះ ឬភាគណាមួយនៃបទបញ្ញត្តិនេះត្រូវបានចាត់ទុកថាមិនត្រឹមត្រូវ ឬមិនស្របតាមរដ្ឋធម្មនុញ្ញ បទបញ្ញត្តិផ្សេងទៀតនឹងមិនរងផលប៉ះពាល់ឡើយ ប៉ុន្តែនឹងនៅតែជាធរមាន និងមានប្រសិទ្ធភាពពេញលេញ ហើយមកដល់ចំណុចនេះ បទបញ្ញត្តិនៃច្បាប់នេះគឺអាចអនុវត្តបាន។

មាត្រាទី 7. សិទ្ធិឈរឈ្មោះជាអ្នកស្នើ។

ដោយមិនគិតពីបទបញ្ញត្តិនៃច្បាប់ផ្សេងទៀតឡើយ ប្រសិនបើរដ្ឋ រដ្ឋាភិបាល ទីភ្នាក់ងារ ឬមន្ត្រីរបស់ខ្លួនណាម្នាក់មិនបានការពារធម្មនុញ្ញភាពនៃច្បាប់នេះ បន្ទាប់ពីមានការយល់ព្រមពីអ្នកបោះឆ្នោត ទីភ្នាក់ងារដ្ឋាភិបាលផ្សេងទៀត អ្នកគាំទ្រ ឬដោយអវត្តមាន និងពលរដ្ឋទាំងឡាយនៃរដ្ឋនេះ នឹងមានសិទ្ធិធ្វើអន្តរាគមន៍ក្នុងចំណាត់ការរបស់តុលាការដោយសួរដេញដោលទាក់ទងនឹងធម្មនុញ្ញភាពនៃច្បាប់នេះក្នុងគោលបំណងការពារធម្មនុញ្ញភាពរបស់ខ្លួន ថាតើចំណាត់ការនោះស្ថិតតុលាការជំនុំជំរះ សាលាឧទ្ធរណ៍ ឬការពិនិត្យដោយឆន្ទានុសិទ្ធិរបស់តុលាការកំពូលរដ្ឋ California ឬតុលាការកំពូលនៃសហរដ្ឋអាមេរិកឬយ៉ាងណា។ ថ្លៃសេវា និងការចំណាយលើការការពារចំណាត់ការនេះត្រូវគិតលើមូលនិធិដែលសមស្របចំពោះអគ្គមេធាវី ដែលនឹងត្រូវបំពេញភ្លាមៗ។

សំណើ 4

ច្បាប់ដែលស្នើឡើងដោយសេចក្តីព្រាងច្បាប់ព្រឹទ្ធសភាលេខ 42 នៃសម័យប្រជុំសាមញ្ញឆ្នាំ 2025–2026 (ជំពូក 245 លក្ខន្តិកៈឆ្នាំ 2025) នេះត្រូវបានដាក់ជូនប្រជាពលរដ្ឋស្របតាមមាត្រាទី 10 នៃអត្ថបទ II នៃរដ្ឋធម្មនុញ្ញនៃរដ្ឋ California។

ច្បាប់ដែលបានដាក់ស្នើនេះធ្វើវិសោធនកម្មមាត្រានៃក្រមរដ្ឋាភិបាល។ ដូច្នេះហើយ បទបញ្ញត្តិដែលស្នើឱ្យលុបត្រូវបានបោះពុម្ពជា ~~*ប្រភេទអក្សរឆូតចោល*~~ ហើយបទបញ្ញត្តិថ្មីដែលស្នើឱ្យបន្ថែមត្រូវបានបោះពុម្ពជា *ប្រភេទអក្សរទ្រេត* ដើម្បីបង្ហាញថាពួកវាថ្មី។

ច្បាប់ដែលបានដាក់ស្នើឡើង

4

មាត្រាទី 1. ច្បាប់នេះនឹងត្រូវបានគេស្គាល់ ហើយអាចត្រូវបានលើកឡើងថាជា ច្បាប់ស្តីពីការបោះឆ្នោតដោយយុត្តិធម៌រដ្ឋ California ឆ្នាំ 2026។

មាត្រាទី 2. យល់ឃើញរបស់អង្គនីតិបញ្ញត្តិ និង ប្រកាសនូវរាល់ចំណុចដូចខាងក្រោម៖

(a) ពលរដ្ឋទាំងអស់គួរតែអាចបញ្ចេញមតិរបស់ខ្លួននៅក្នុងដំណើរការនយោបាយ និងរក្សាគណនេយ្យភាពមន្ត្រីជាប់ឆ្នោតរបស់ខ្លួន។

(b) ការបោះឆ្នោតសម្រាប់តំណែងដែលជ្រើសរើសថ្នាក់មូលដ្ឋាន ឬរដ្ឋគួរតែមានលក្ខណៈយុត្តិធម៌ បើកចំហ និងប្រកួតប្រជែង។

(c) ការបង្កើនការចំណាយលើយុទ្ធនាការនយោបាយអាចជំរុញឱ្យបេក្ខជនពឹងផ្អែកលើការចូលរួមវិភាគទានធំៗពីអ្នកឧបត្ថម្ភដែលមានទ្រព្យសម្បត្តិ និងក្រុមផលប្រយោជន៍ពិសេស ដែលអាចផ្តល់ឱ្យអ្នកឧបត្ថម្ភដែលមានទ្រព្យសម្បត្តិ និងក្រុមផលប្រយោជន៍ពិសេសទាំងនោះនូវឥទ្ធិពលមិនសមាមាត្រលើការសម្រេចចិត្តរបស់រដ្ឋាភិបាល។

(d) ឥទ្ធិពលមិនសមាមាត្របែបនោះអាចធ្វើឱ្យខូចដល់ទំនុកចិត្តរបស់សាធារណជនដែលថា មន្ត្រីសាធារណៈកំពុងបំពេញភារកិច្ចរបស់ខ្លួនដោយអព្យាក្រឹត ហើយរដ្ឋាភិបាលកំពុងបំពេញនូវតម្រូវការ និងឆ្លើយតបទៅនឹងការចង់បានរបស់ពលរដ្ឋគ្រប់រូបដោយស្មើគ្នា ដោយមិនគិតពីទ្រព្យសម្បត្តិរបស់ពួកគេ។

(e) ក្រុមផលប្រយោជន៍ពិសេសចូលរួមវិភាគទានដល់បេក្ខជនដែលកំពុងកាន់តំណែងស្រាប់ច្រើនជាងបេក្ខជនប្រឆាំង ដោយសារពួកគេស្វែងរកលទ្ធភាពចូលទៅជិតស្និទមន្ត្រីជាប់ឆ្នោត ហើយការចូលរួមវិភាគទាននោះស្មើនឹងចំណែកដ៏ធំមួយនៃផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុរបស់បេក្ខជនដែលកាន់តំណែងស្រាប់ ដូចដែលបានបញ្ជាក់ដោយការសិក្សាដូចជា ការសិក្សាដែលបានបោះពុម្ពផ្សាយនៅក្នុងទិន្នានុប្បវត្តិនយោបាយក្នុងឆ្នាំ 2014 និងការសិក្សាស្រាវជ្រាវនយោបាយប្រចាំត្រីមាសក្នុងឆ្នាំ 2016។

(f) បច្ចុប្បន្ន កម្មវិធីបោះឆ្នោតដែលផ្តល់មូលនិធិដោយពលរដ្ឋ ដែលបេក្ខជនដែលមានលក្ខណៈគ្រប់គ្រាន់អាចទទួលបានមូលនិធិសាធារណៈសម្រាប់គោលបំណងប្រាស្រ័យទាក់ទងជាមួយអ្នកបោះឆ្នោតជាជាងការពឹងផ្អែកទាំងស្រុងលើអ្នកឧបត្ថម្ភឯកជន កំពុងដំណើរការនៅក្នុងទីក្រុងឯករាជ្យចំនួនប្រាំនៅរដ្ឋ California ក៏ដូចជានៅក្នុងដែនយុត្តាធិការរដ្ឋ និងមូលដ្ឋានជាច្រើនទៀតផងដែរ។

(g) កម្មវិធីបោះឆ្នោតដែលផ្តល់មូលនិធិដោយពលរដ្ឋនឹងលើកកម្ពស់ការប្រកួតប្រជែងតាមរយៈការកាត់បន្ថយផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុរបស់បេក្ខជនដែលកាន់តំណែងស្រាប់ និងផ្តល់លទ្ធភាពដល់ពលរដ្ឋពីគ្រប់មជ្ឈដ្ឋានមិនត្រឹមតែអ្នកដែលមានទំនាក់ទំនងនឹងអ្នកឧបត្ថម្ភដែលមានទ្រព្យសម្បត្តិ ឬក្រុមផលប្រយោជន៍ពិសេសប៉ុណ្ណោះទេ ក្នុងការឈរឈ្មោះបោះឆ្នោត ដូចដែលបានបញ្ជាក់ដោយការសិក្សា ដូចជា ការសិក្សាដែលបានបោះពុម្ពផ្សាយនៅក្នុងរបាយការណ៍ស្តីពីនយោបាយរដ្ឋ និងគោលនយោបាយប្រចាំត្រីមាសក្នុងឆ្នាំ 2008 និងដោយវិទ្យាស្ថានហិរញ្ញវត្ថុយុទ្ធនាការក្នុងឆ្នាំ 2015, វិទ្យាស្ថានជាតិស្តីពីប្រាក់នៅក្នុងនយោបាយរដ្ឋក្នុងឆ្នាំ 2016 និងរបាយការណ៍ស្តីពីនយោបាយរដ្ឋ និងគោលនយោបាយប្រចាំត្រីមាសក្នុងឆ្នាំ 2022។

(h) តាមរយៈការកាត់បន្ថយការពឹងផ្អែកលើអ្នកឧបត្ថម្ភដែលមានទ្រព្យសម្បត្តិ និងក្រុមផលប្រយោជន៍ពិសេស កម្មវិធីបោះឆ្នោតដែលផ្តល់មូលនិធិដោយពលរដ្ឋនឹងហាមឃាត់ការអនុវត្តមិនសមរម្យ ការពារប្រឆាំងនឹងអំពើពុករលួយ ឬទម្រង់នៃអំពើពុករលួយ និងការពារសុចរិតភាពនយោបាយនៃស្ថាប័នរដ្ឋាភិបាលរបស់យើង។

(i) ក្នុងសំណុំរឿង Johnson v. Bradley (1992) 4 Cal.4th 389 តុលាការកំពូលនៅរដ្ឋ California បានរំលេចការអង្កេតរបស់សាលាឧទ្ធរណ៍ថា “វាហាក់ដូចជាជាក់ច្បាស់ថា ប្រាក់សាធារណៈកាត់បន្ថយជាជាងបង្កើនសម្ពាធលើការរៃអង្គាសមូលនិធិលើអ្នកដែលស្វែងរកតំណែងសាធារណៈ ព្រមទាំងកាត់បន្ថយឥទ្ធិពលហួសហេតុរបស់ក្រុមផលប្រយោជន៍ពិសេស”។

(j) ក្នុងសំណុំរឿង Buckley v. Valeo (1976) 424 U.S. 1 តុលាការកំពូលរបស់សហរដ្ឋអាមេរិកបានទទួលស្គាល់ថា “ការផ្តល់ហិរញ្ញប្បទានសាធារណៈ គឺជាមធ្យោបាយមួយដើម្បីលុបបំបាត់ឥទ្ធិពលមិនត្រឹមត្រូវនៃការចូលរួមវិភាគទានឯកជនដ៏ច្រើន ដែលជួយជំរុញដល់ផលប្រយោជន៍សំខាន់របស់រដ្ឋាភិបាល”។

(k) ក្នុងសំណុំរឿង Arizona Free Enterprise v. Bennett (2011) 564 U.S. 721 តុលាការកំពូលរបស់សហរដ្ឋអាមេរិកបានទទួលស្គាល់ថា ការផ្តល់ហិរញ្ញប្បទានសាធារណៈដល់ការបោះឆ្នោត “អាចជួយជំរុញដល់ ‘ផលប្រយោជន៍សំខាន់របស់រដ្ឋាភិបាល’ ដូចជាផលប្រយោជន៍របស់រដ្ឋក្នុងការទប់ស្កាត់អំពើពុករលួយ” ការដកស្រង់ពី Buckley v. Valeo។

(l) ក្នុងសំណុំរឿង Buckley v. Valeo, តុលាការកំពូលរបស់សហរដ្ឋអាមេរិកបានកត់សម្គាល់បន្ថែមថា កម្មវិធីបោះឆ្នោតដែលផ្តល់មូលនិធិដោយពលរដ្ឋ “សម្របសម្រួល និងពង្រីកការពិភាក្សា និងការចូលរួមសាធារណៈនៅក្នុងដំណើរការបោះឆ្នោត ដែលជាគោលដៅសំខាន់សម្រាប់ពលរដ្ឋដែលដឹកនាំដោយខ្លួនឯង”។

(m) ការហាមឃាត់ដាច់ខាតលើការផ្តល់ហិរញ្ញប្បទានសាធារណៈសម្រាប់យុទ្ធនាការអនុញ្ញាតឱ្យក្រុមផលប្រយោជន៍ពិសេសទទួលបានឥទ្ធិពលមិនសមាមាត្រ និងផ្តល់ប្រយោជន៍មិនស្មើគ្នាដល់បេក្ខជនដែលកាន់តំណែងស្រាប់។ ការលើកលែងនេះគួរត្រូវបានបង្កើតឡើងដើម្បីអនុញ្ញាតដល់កម្មវិធីបោះឆ្នោតដែលផ្តល់មូលនិធិដោយពលរដ្ឋ ដើម្បីឱ្យការបោះឆ្នោតប្រព្រឹត្តិទៅកាន់តែមានយុត្តិធម៌។

មាត្រាទី 3. មាត្រាទី 85300 នៃក្រមរដ្ឋាភិបាលត្រូវបានធ្វើវិសោធនកម្មដោយចែងថា៖

85300. (a) ~~លើកលែងតែមានចែងក្នុងផ្នែករង (b) មន្ត្រីសាធារណៈមិនត្រូវចំណាយ ហើយបេក្ខជនមិនត្រូវទទួលប្រាក់ សាធារណៈ~~ *មូលនិធិ* សម្រាប់គោលបំណងស្វែងរកតំណែងដែលជ្រើសរើស។ *តំណែង ប្រសិនបើមូលនិធិត្រូវបានបម្រុងទុកដោយអង្គភាពរបស់រដ្ឋ ឬមូលដ្ឋានសម្រាប់វិស័យអប់រំ វិស័យដឹកជញ្ជូន និងសុវត្ថិភាពសាធារណៈ។*

~~(b) A មន្ត្រីសាធារណៈ ឬបេក្ខជនអាចចំណាយ ឬទទួលប្រាក់សាធារណៈសម្រាប់គោលបំណងស្វែងរកតំណែងដែលជ្រើសរើស ប្រសិនបើអង្គភាពរដ្ឋាភិបាលរបស់រដ្ឋ ឬមូលដ្ឋានបង្កើតមូលនិធិដាច់ដោយឡែកសម្រាប់គោលបំណងនេះតាមរយៈលក្ខន្តិក: បទបញ្ជា ដំណោះស្រាយ ឬធម្មនុញ្ញ ហើយចំណុចខាងក្រោមទាំងពីរគឺពិត៖~~

~~(1) ប្រាក់សាធារណៈដែលមាននៅក្នុងមូលនិធិត្រូវបានផ្តល់ជូនបេក្ខជនចូលរួមស្ម័គ្រចិត្តដែលមានលក្ខណៈគ្រប់គ្រាន់ទាំងអស់សម្រាប់តំណែងតែមួយ ដោយមិនគិតពីតំណែងដែលកាន់ស្រាប់ ឬការពេញចិត្តគណបក្សនយោបាយឡើយ។~~

~~(2) The អង្គភាពរដ្ឋាភិបាលរបស់រដ្ឋ ឬមូលដ្ឋានបានបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់ការកំណត់គុណសម្បត្តិរបស់បេក្ខជនតាមរយៈលក្ខន្តិក: បទបញ្ជា ដំណោះស្រាយ ឬធម្មនុញ្ញ។~~

(b) បេក្ខជនត្រូវគោរពតាមដែនកំណត់នៃការចំណាយ និងបំពេញតាមលក្ខណៈវិនិច្ឆ័យតឹងរ៉ឹង ដើម្បីមានសិទ្ធិទទួលបានមូលនិធិសាធារណៈ។

(c) មិនត្រូវប្រើមូលនិធិសាធារណៈដើម្បីបង់ការពិន័យ ឬថ្លៃសេវាការពារផ្លូវច្បាប់ឡើយ។

(d) (1) បេក្ខជនមិនត្រូវប្រើមូលនិធិសាធារណៈដើម្បីបង់សងឥណទានបុគ្គលសម្រាប់យុទ្ធនាការរបស់ខ្លួនគ្រប់ពេលវេលា។

(2) បន្ទាប់ពីយុទ្ធនាការចប់ បេក្ខជនដែលទទួលបានមូលនិធិសាធារណៈសម្រាប់យុទ្ធនាការរបស់ខ្លួនមិនត្រូវប្រើប្រាស់ប្រភពមូលនិធិដើម្បីបង់សងឥណទានបុគ្គលសម្រាប់យុទ្ធនាការរបស់ខ្លួនឡើយ។

(e) សម្រាប់គោលបំណងនៃមាត្រានេះ និយមន័យខាងក្រោមត្រូវបានអនុវត្ត៖

(1) "មូលនិធិដែលមានប្រើប្រាស់សម្រាប់បេក្ខជន" មានន័យថា ដែនកំណត់នៃការចំណាយ ឬការចូលរួមវិភាគទានទាំងអស់ និងមូលនិធិសាធារណៈសរុបដែលបេក្ខជនទទួលបានពីគណៈកម្មាធិការតំណែងដែលជ្រើសរើសដែលគ្រប់គ្រងដោយបេក្ខជន មួយណាក៏បានឱ្យតែតិចជាង។

(2) "ដែនកំណត់នៃការចំណាយ" មានន័យថា ដែនកំណត់នៃការចំណាយស្ម័គ្រចិត្តដែលបង្កើតឡើងដោយលក្ខន្តិកៈ បទបញ្ជា ឬធម្មនុញ្ញ ដែលបេក្ខជនចូលរួមស្ម័គ្រចិត្តដែលមានលក្ខណៈគ្រប់គ្រាន់ត្រូវតែគោរពតាម ដើម្បីទទួលបានមូលនិធិសាធារណៈ។

(3) "ការចំណាយដោយឯករាជ្យប្រឆាំង" មានន័យថា ការចំណាយសរុបដែលបានធ្វើឡើង ឬការចំណាយដែលបង្កឡើងដោយបុគ្គលណាម្នាក់សម្រាប់គោលបំណងបង្កើតឱ្យមានការចំណាយដោយឯករាជ្យផ្ទុយពីបេក្ខជនជាក់លាក់។

(4) "ការចំណាយដោយគាំទ្រឯករាជ្យ" មានន័យថា ការចំណាយសរុបដែលបានធ្វើឡើង ឬការចំណាយដែលបង្កឡើងដោយបុគ្គលណាម្នាក់សម្រាប់គោលបំណងបង្កើតឱ្យមានការចំណាយដោយឯករាជ្យគាំទ្របេក្ខជនជាក់លាក់។

(5) "មូលនិធិគាំទ្រសុទ្ធ" មានន័យថា ចំនួនទឹកប្រាក់សរុបនៃមូលនិធិដែលមានសម្រាប់បេក្ខជន បូករួមជាមួយការចំណាយដោយឯករាជ្យគាំទ្របេក្ខជននោះ និងដកការចំណាយដោយឯករាជ្យប្រឆាំងនឹងបេក្ខជននោះ។

(6) "មូលនិធិសាធារណៈ" មានន័យថា ប្រាក់ទាំងឡាយដែលអង្គភាពរដ្ឋាភិបាលថ្នាក់រដ្ឋ ឬមូលដ្ឋានផ្តល់ទៅឱ្យបេក្ខជនសម្រាប់គោលបំណងស្វែងរកតំណែងដែលជ្រើសរើស។

(7) (A) "លក្ខណៈវិនិច្ឆ័យតឹងរ៉ឹង" មានន័យថា លក្ខខណ្ឌតម្រូវដែលកំណត់ដោយលក្ខន្តិកៈ បទបញ្ជា ឬធម្មនុញ្ញ ដែលបេក្ខជនត្រូវតែបំពេញតាម ដើម្បីទទួលបានមូលនិធិសាធារណៈ។ លក្ខណៈវិនិច្ឆ័យទាំងនេះត្រូវតម្រូវឱ្យបេក្ខជនបង្ហាញការគាំទ្រទូលំទូលាយនៅក្នុងស្រុករបស់ខ្លួន ដូចជា តម្រូវឱ្យបេក្ខជនទទួលការចូលរួមវិភាគទាន ឬបណ្តុំជំនួយដែលមានទឹកប្រាក់តិចតួចពីពលរដ្ឋដែលគ្រប់អាយុបោះឆ្នោតក្នុងចំនួនជាក់លាក់។

(B) (i) ប្រសិនបើលក្ខន្តិកៈ បទបញ្ជា ឬធម្មនុញ្ញតម្រូវឱ្យបុគ្គលក្នុងចំនួនអប្បបរមាធ្វើការចូលរួមវិភាគទានតិចតួចអនុលោមតាមកថាខណ្ឌរង (A) នោះការចូលរួមវិភាគទានច្រើនបំផុតដែលលក្ខន្តិកៈ បទបញ្ជា ឬធម្មនុញ្ញអាចតម្រូវឱ្យអ្នកចូលរួមវិភាគទានចូលរួមគឺដប់ដុល្លារ ($10)។

(ii) សម្រាប់គោលបំណងនៃកថាខណ្ឌរងនេះ លក្ខន្តិកៈ បទបញ្ជា ឬធម្មនុញ្ញអាចអនុញ្ញាតឱ្យមានការចូលរួមវិភាគទានច្រើនជាងការចូលរួមវិភាគទានក្នុងចំនួនតិចតួចដែលតម្រូវនុលោមតាមកថាខណ្ឌរង (A) សម្រាប់ការរាប់ជាការចូលរួមវិភាគទានដែលស្មើនឹងចំនួនទឹកប្រាក់ចូលរួមវិភាគទានក្នុងចំនួនតិចតួចដែលតម្រូវស្របតាមកថាខណ្ឌរង (A)។

(C) "លក្ខណៈវិនិច្ឆ័យតឹងរ៉ឹង" មិនត្រូវរាប់បញ្ចូលលក្ខខណ្ឌតម្រូវដែលតម្រូវឱ្យបេក្ខជនទទួលបានហត្ថលេខាក្នុងចំនួនជាក់លាក់ ឬរៃអង្គាសចំនួនទឹកប្រាក់សរុបជាក់លាក់ច្រើនជាងដប់ដុល្លារ ($10) ក្នុងអ្នកចូលរួមវិភាគទានម្នាក់។

(f) (1) លក្ខន្តិកៈ បទបញ្ជា ឬធម្មនុញ្ញអាចបង្កើនដែនកំណត់នៃការចំណាយសម្រាប់បេក្ខជនចូលរួមស្ម័គ្រចិត្តដែលមានលក្ខណៈគ្រប់គ្រាន់ម្នាក់ៗ។

(2) ការបង្កើនដែនកំណត់នៃការចំណាយអនុលោមតាមផ្នែករងនេះមិនត្រូវលើសពីចំនួនទឹកប្រាក់ដែលស្មើនឹងចំនួនទឹកប្រាក់ខ្ពស់បំផុតនៃមូលនិធិគាំទ្រសុទ្ធរបស់បេក្ខជនផ្សេងទៀតសម្រាប់តំណែងដូចគ្នា បូករួមចំនួនទឹកប្រាក់នៃការចំណាយដោយឯករាជ្យប្រឆាំងនឹងបេក្ខជនចូលរួមស្ម័គ្រចិត្តដែលមានលក្ខណៈគ្រប់គ្រាន់ ហើយដកនឹងចំនួនទឹកប្រាក់នៃការចំណាយដោយឯករាជ្យគាំទ្របេក្ខជនចូលរួមស្ម័គ្រចិត្តដែលមានលក្ខណៈគ្រប់គ្រាន់។

(g) លក្ខន្តិកៈ ធម្មនុញ្ញ បទបញ្ជា និងដំណោះស្រាយស្តីពីមូលនិធិសាធារណៈមិនត្រូវរើសអើងដោយផ្អែកលើគណបក្ស ឬដោយយោងថាតើបេក្ខជនជាបេក្ខជនប្រឆាំង ឬបេក្ខជនដែលកាន់តំណែងស្រាប់។

(h) គណៈកម្មការមិនទទួលខុសត្រូវចំពោះការគ្រប់គ្រង ឬការអនុវត្តប្រព័ន្ធការផ្តល់ហិរញ្ញប្បទានសាធារណៈរបស់បេក្ខជនដែលបង្កើតឡើងដោយទីភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋានឡើយ។

(i) ផ្នែករង (e), (f) និង (h) នៃផ្នែកនេះអាចត្រូវបានធ្វើវិសោធនកម្មដោយលក្ខន្តិកៈ អនុលោមតាមផ្នែករង (a) នៃមាត្រាទី 81012។ ផ្នែករងផ្សេងទៀតនៃផ្នែកនេះអាចត្រូវបានធ្វើវិសោធនកម្មតែដោយលក្ខន្តិកៈដែលអនុលោមតាមផ្នែករង (b) នៃមាត្រាទី 81012 ប៉ុណ្ណោះ។

មាត្រាទី 4.1. មាត្រាទី 85320 នៃក្រមរដ្ឋាភិបាលត្រូវបានធ្វើវិសោធនកម្មដោយចែងថា៖

85320. (a) រដ្ឋាភិបាលបរទេស តួអង្គបរទេស ឬពលរដ្ឋបរទេសមិនត្រូវធ្វើការចូលរួមវិភាគទាន ការចំណាយ ឬការចំណាយដោយឯករាជ្យដោយផ្ទាល់តាមរយៈបុគ្គលផ្សេងទៀតឡើយ ពាក់ព័ន្ធនឹងលក្ខណសម្បត្តិ ឬការគាំទ្រ ឬការប្រឆាំងនឹងវិធានការសន្លឹកឆ្នោតរបស់រដ្ឋ ឬមូលដ្ឋាន ឬពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសបេក្ខជនសម្រាប់តំណែងក្នុងរដ្ឋ ឬមូលដ្ឋាន។

(b) បុគ្គល ឬគណៈកម្មាធិការមិនត្រូវរៃអង្គាសប្រាក់ ឬទទួលយកការចូលរួមវិភាគទានពីរដ្ឋាភិបាលបរទេស តួអង្គបរទេស ឬពលរដ្ឋបរទេសឡើយ ពាក់ព័ន្ធនឹងលក្ខណសម្បត្តិ ឬការគាំទ្រ ឬការប្រឆាំងនឹងវិធានការសន្លឹកឆ្នោតរបស់រដ្ឋ ឬមូលដ្ឋាន ឬពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសរើសបេក្ខជនសម្រាប់តំណែងក្នុងរដ្ឋ ឬមូលដ្ឋាន។

(c) សម្រាប់គោលបំណងនៃផ្នែកនេះ ពាក្យខាងក្រោមមានអត្ថន័យដូចខាងក្រោម៖

(1) (A) "ពលរដ្ឋបរទេស" មានន័យថា បុគ្គលដែលមិនមែនជាពលរដ្ឋនៃសហរដ្ឋអាមេរិក និងមិនមែនជាអ្នករស់នៅអចិន្ត្រៃយ៍ដែលអនុញ្ញាតដោយច្បាប់។

(B) "ពលរដ្ឋបរទេស" មិនរួមបញ្ចូលបុគ្គលដែលទទួលបានវិធានការពន្យារពេល និងដែលវិធានការពន្យារពេលរបស់ខ្លួនមិនទាន់ផុតកំណត់ក្រោមកម្មវិធីវិធានការពន្យារពេលសម្រាប់ការមកដល់នៃកុមារ (DACA) របស់សហព័ន្ធ ដូចបានពណ៌នានៅក្នុងគោលការណ៍ណែនាំដែលចេញដោយក្រសួងសន្តិសុខមាតុភូមិសហរដ្ឋអាមេរិក។

(2) "តួអង្គបរទេស" រួមបញ្ចូលបុគ្គលដូចខាងក្រោម៖

(A) គណបក្សនយោបាយបរទេស។

(B) បុគ្គលដែលស្ថិតនៅក្រៅសហរដ្ឋអាមេរិក លុះត្រាតែលក្ខខណ្ឌខាងក្រោមត្រូវបានបង្កើតឡើង៖

(i) បុគ្គលនោះគឺជារូបវន្តបុគ្គល ឬពលរដ្ឋនៃសហរដ្ឋអាមេរិក។

(ii) បុគ្គលនោះមិនមែនជារូបវន្តបុគ្គល ហើយត្រូវបានរៀបចំឡើងក្រោម ឬបង្កើតដោយច្បាប់នៃសហរដ្ឋអាមេរិក ឬរដ្ឋណាមួយ ឬទីកន្លែងផ្សេងទៀតដែលស្ថិតក្រោមដែនយុត្តាធិការរបស់សហរដ្ឋអាមេរិក និងមានទីតាំងអាជីវកម្មចម្បងរបស់ខ្លួននៅក្នុងសហរដ្ឋអាមេរិក។

(C) ដៃគូ សមាគម សាជីវកម្ម អង្គការ ឬការរួមបញ្ចូលគ្នានៃរូបវន្តបុគ្គលផ្សេងទៀតដែលរៀបចំឡើងក្រោមច្បាប់នៃ ឬមានទីតាំងអាជីវកម្មចម្បងរបស់ខ្លួននៅប្រទេសក្រៅ។

(D) ក្រុមហ៊ុនបុត្រសម្ព័ន្ធក្នុងស្រុកនៃសាជីវកម្មបរទេស ប្រសិនបើការសម្រេចចិត្តចូលរួមវិភាគទាន ឬចំណាយមូលនិធិត្រូវបានធ្វើឡើងដោយមន្ត្រី នាយក ឬបុគ្គលិកគ្រប់គ្រងនៃសាជីវកម្មបរទេសដែលមិនមែនជាពលរដ្ឋនៃ

សហរដ្ឋអាមេរិក ឬអ្នករស់នៅអចិន្ត្រៃយ៍ដែលអនុញ្ញាតដោយច្បាប់នៅសហរដ្ឋអាមេរិក។

(d) ផ្នែកនេះនឹងមិនហាមឃាត់ការចូលរួមវិភាគទាន ការចំណាយ ឬការចំណាយដោយឯករាជ្យដែលធ្វើឡើងដោយអ្នករស់នៅអចិន្ត្រៃយ៍ដែលអនុញ្ញាតដោយច្បាប់ឡើយ។

(e) *(1)* បុគ្គលទាំងឡាយដែលបំពានផ្នែកនេះនឹងត្រូវមានទោសពី~~ទស្មើសមជ្ឈឹម និងត្រូវទទួលរងការផាកពិន័យជាទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់ដែលបានចូលរួមវិភាគទាន ឬចំណាយ។~~ *បទល្មើសមជ្ឈឹម។*

(2) បន្ថែមពីលើទណ្ឌកម្មផ្សេងទៀត បុគ្គលដែលបំពានផ្នែកនេះនឹងត្រូវទទួលរងការផាកពិន័យជាទឹកប្រាក់យ៉ាងតិចស្មើនឹងចំនួនទឹកប្រាក់ដែលបានចូលរួមវិភាគទាន ឬចំណាយ ប៉ុន្តែមិនត្រូវលើសពីទឹកប្រាក់ដែលស្មើនឹងបីដងនៃចំនួនទឹកប្រាក់ដែលបានចូលរួមវិភាគទាន ឬចំណាយនោះទេ។

4

5

37

សំណើ 5

វិសោធនកម្មដែលស្នើដោយវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់ព្រឹទ្ធសភាទី 1 នៃសម័យប្រជុំសាមញ្ញឆ្នាំ 2023–2024 (ជំពូកដំណោះស្រាយលេខ 204 លក្ខន្តិកៈឆ្នាំ 2024) ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៃរដ្ឋ California ដោយកែប្រែផ្នែកនៅក្នុងនោះ។ ដូច្នេះហើយ បទប្បញ្ញត្តិដែលមានស្រាប់ដែលស្នើឱ្យលុបត្រូវបានបោះពុម្ពជាអ~~ក្សរឆ្លងចោល~~ ហើយបទបញ្ញត្តិថ្មីដែលស្នើឱ្យបន្ថែមត្រូវបានបោះពុម្ពជា*ប្រភេទអក្សរទ្រេត* ដើម្បីបង្ហាញថាបទបញ្ញត្តិទាំងនោះថ្មី។

ស្នើសុំវិសោធនកម្មមាត្រា II និង V

ទីមួយ—មាត្រាទី 15 នៃអត្ថបទ II នោះត្រូវបានធ្វើវិសោធនកម្មដោយចែងថា៖

មាត្រាទី 15. (a) ការបោះឆ្នោតកំណត់ថាតើត្រូវបោះឆ្នោតដកតំណែងមន្ត្រីឬអត់ ~~និង ប្រសិនបើសមស្រប ជ្រើសរើសអ្នកមកបន្តតំណែង~~ ត្រូវស្នើឡើងដោយអភិបាល និងមិនត្រូវធ្វើឡើងតិចជាង 60 ថ្ងៃ ឬច្រើនជាង 80 ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបញ្ជាក់ការចុះហត្ថលេខាគ្រប់គ្រាន់។

(b) ការបោះឆ្នោតដកតំណែងអាចត្រូវបានធ្វើឡើងក្នុងរយៈពេល 180 ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបញ្ជាក់ការចុះហត្ថលេខាគ្រប់គ្រាន់ ដើម្បីឱ្យការបោះឆ្នោតអាចត្រូវបានច្របាច់បញ្ចូលគ្នាជាមួយការបោះឆ្នោតធម្មតាបន្ទាប់ដែលធ្វើឡើងទាំងស្រុង ឬមួយផ្នែកនៅក្នុងដែនយុត្តាធិការតែមួយដែលធ្វើការបោះឆ្នោតដកតំណែងនោះ ប្រសិនបើចំនួនអ្នកបោះឆ្នោតដែលមានសិទ្ធិបោះឆ្នោតនៅការបោះឆ្នោតធម្មតាបន្ទាប់នោះមានយ៉ាងហោចណាស់ 50 ភាគរយនៃអ្នកបោះឆ្នោតទាំងអស់ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងការបោះឆ្នោតដកតំណែង។

(c) ប្រសិនបើសំឡេងឆ្នោតភាគច្រើនចង់ធ្វើការបោះឆ្នោតដកតំណែង មន្ត្រីនោះនឹងត្រូវបានដកតំណែង ~~ហើយប្រសិនបើមានបេក្ខជន នោះបេក្ខជនដែលទទួលបានសំឡេងច្រើននឹងក្លាយជាអ្នកបន្តតំណែង។ មន្ត្រីអាចមិនមែនជាបេក្ខជន និង មិនត្រូវឈរឈ្មោះសម្រាប់តំណែងដែលមំពេញអនុលោមតាមផ្នែករង (d) នៃមាត្រាទី 16 នៃអត្ថបទ VI.~~ *ហើយតំណែងនោះត្រូវទុកឱ្យនៅទំនេរ។ តំណែងទំនេរត្រូវបំពេញដោយអនុលោមតាមរដ្ឋធម្មនុញ្ញនេះ និងលក្ខន្តិកៈ ដែលចែងថា មន្ត្រីដែលជាកម្មវត្ថុនៃការបោះឆ្នោតដកតំណែងនឹងមិនត្រូវបានតែងតាំងឱ្យបំពេញតំណែងដែលទំនេរនោះទេ។*

ទីពីរ—មាត្រាទី 17 នៃអត្ថបទ II ត្រូវបានធ្វើវិសោធនកម្មដោយចែងថា៖

មាត្រាទី 17. ប្រសិនបើការបោះឆ្នោតដកតំណែងអភិបាលរដ្ឋ ឬរដ្ឋលេខាធិការត្រូវបានចាប់ផ្តើម កាតព្វកិច្ចនៃការបោះឆ្នោតដកតំណែងនោះត្រូវធ្វើឡើងដោយ~~អភិបាលរងរដ្ឋ~~ *រដ្ឋលេខាធិការ* ឬអគ្គនាយកគ្រប់គ្រងហិរញ្ញវត្ថុ។ *ប្រសិនបើការបោះឆ្នោតដកតំណែងអភិបាលរដ្ឋ និងរដ្ឋលេខាធិការត្រូវបានចាប់ផ្តើមនៅពេលតែមួយ កាតព្វកិច្ចនៃការបោះឆ្នោតដកតំណែងទាំងពីរត្រូវធ្វើឡើងដោយអគ្គនាយកគ្រប់គ្រងហិរញ្ញវត្ថុ។*

ទីបី—មាត្រាទី 10 នៃអត្ថបទ V ត្រូវបានធ្វើវិសោធនកម្មដោយចែងថា៖

មាត្រាទី 10. *(a)* អភិបាលរងរដ្ឋត្រូវក្លាយជាអភិបាលរដ្ឋ ប្រសិនបើតំណែងអភិបាលនៅទំនេរ។

(b) ថ្វីបើមានចែងក្នុងផ្នែករង (c) នៃមាត្រាទី 15 នៃអត្ថបទ II ក៏ដោយ ប្រសិនបើតំណែងអភិបាលរដ្ឋត្រូវបានដកតាមរយៈការបោះឆ្នោតដកតំណែង នោះអភិបាលរងរដ្ឋត្រូវក្លាយជាអភិបាលរដ្ឋសម្រាប់អាណត្តិដែលមិនទាន់ផុតកំណត់ដែលនៅសល់។ ប្រសិនបើតំណែងអភិបាលរដ្ឋត្រូវបានដកតាមរយៈការបោះឆ្នោតដកតំណែងនៅមុនការបិទរយៈពេលនៃការតែងតាំងសម្រាប់ការបោះឆ្នោតទូទាំងរដ្ឋបន្ទាប់ក្នុងអំឡុងពីរឆ្នាំដំបូងនៃអាណត្តិអភិបាលរដ្ឋ ការបោះឆ្នោតពិសេសមួយនឹងត្រូវបានធ្វើឡើងដើម្បីជំនួសតំណែងអភិបាលរដ្ឋ និងត្រូវបានច្របាច់បញ្ចូលគ្នាជាមួយការបោះឆ្នោតបឋមទូទាំងរដ្ឋ ហើយបើចាំបាច់ នៅក្នុងការបោះឆ្នោតទូទៅទូទាំងរដ្ឋបន្តបន្ទាប់។ ប្រសិនបើបេក្ខជនទទួលបានសំឡេងឆ្នោតភាគច្រើននៅក្នុងការបោះឆ្នោតពិសេសដែលត្រូវបានច្របាច់បញ្ចូលគ្នាជាមួយការបោះឆ្នោតបឋមទូទាំងរដ្ឋ បេក្ខជននោះត្រូវក្លាយជាអភិបាលរដ្ឋសម្រាប់អាណត្តិដែលមិនទាន់ផុតកំណត់ដែលនៅសល់។ ប្រសិនបើមិនមានបេក្ខជនទទួលបានសំឡេងឆ្នោតភាគច្រើនទេ នោះអ្នកទទួលបានសំឡេងឆ្នោតភាគច្រើនកំពូលចំនួនពីររូបនឹងត្រូវប្រកួតប្រជែងគ្នានៅក្នុងការបោះឆ្នោតពិសេសដែលត្រូវបានច្របាច់បញ្ចូលគ្នាជាមួយការបោះឆ្នោតទូទៅទូទាំងរដ្ឋបន្តបន្ទាប់ ហើយអ្នកឈ្នះនៅក្នុងការបោះឆ្នោតនោះនឹងក្លាយជាអភិបាលរដ្ឋសម្រាប់អាណត្តិដែលមិនទាន់ផុតកំណត់ដែលនៅសល់។

(c) អភិបាលរងរដ្ឋត្រូវបំពេញភារកិច្ចជាអភិបាលនៅអំឡុងនីតិវិធីចោទប្រកាន់ អវត្តមានពីរដ្ឋ ឬអសមត្ថភាពបណ្តោះអាសន្នផ្សេងទៀតរបស់អភិបាលរដ្ឋ ឬអភិបាលរដ្ឋជាប់ឆ្នោតដែលមិនបានចូលកាន់តំណែង។

(d) អង្គនីតិបញ្ញត្តិត្រូវកំណត់លំដាប់លំដោយអតីតភាព បន្ទាប់ពីអភិបាលរងរដ្ឋទទួលតំណែងបន្តពីអភិបាលរដ្ឋចំពោះការអនុវត្តជាបណ្តោះអាសន្ននូវតួនាទីរបស់អភិបាលរដ្ឋ។

(e) តុលាការកំពូលមានដែនយុត្តាធិការផ្តាច់មុខក្នុងការកំណត់ពីបញ្ហាដែលកើតមាននៅក្រោមផ្នែកនេះ។

(f) សិទ្ធិលើកឡើងពីបញ្ហាតំណែងទំនេរ ឬអសមត្ថភាពបណ្តោះអាសន្នត្រូវបានផ្តល់ជូនផ្តាច់មុខដល់ស្ថាប័នដែលចែងដោយលក្ខន្តិកៈនេះ។

សំណើ 37

វិធានការផ្តួចផ្តើមនេះត្រូវបានដាក់ជូនប្រជាពលរដ្ឋដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រាទី 8 នៃអត្ថបទ II នៃធម្មនុញ្ញរដ្ឋ California ។

វិធានការផ្តួចផ្តើមនេះបន្ថែមមាត្រាទៅក្នុងក្រមសុខភាព និងសុវត្ថិភាព។ ដូច្នេះហើយ បទបញ្ញត្តិថ្មីដែលបានស្នើឱ្យបន្ថែមត្រូវបានបោះពុម្ពជាប្រភេទ*អក្សរទ្រេត* ដើម្បីបញ្ជាក់ថាច្បាប់ទាំងនោះថ្មី។

ច្បាប់ដែលបានដាក់ស្នើឡើង

មាត្រាទី 1. ចំណងជើង។

វិធានការនេះត្រូវបានគេស្គាល់ថាជា "ច្បាប់ស្តីពីការសាងសង់លំនៅឋានសម្រាប់គ្រួសារ និងកម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលរដ្ឋ California ឆ្នាំ 2026"។

មាត្រាទី 2. ជំពូកទី 11.5 (ចាប់ផ្តើមជាមួយមាត្រាទី 51515) ត្រូវបានបន្ថែមទៅផ្នែកទី 3 ភាគទី 31 នៃក្រមសុខភាព និងសុវត្ថិភាព ដោយចែងថា៖

ជំពូកទី 11.5. ច្បាប់ស្តីពីការសាងសង់លំនៅឋានសម្រាប់គ្រួសារ និង ភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលរដ្ឋ California ឆ្នាំ 2026

51515. (a) ទីភ្នាក់ងារហិរញ្ញវត្ថុលំនៅឋានរដ្ឋ California ត្រូវគ្រប់គ្រង និងអនុវត្តច្បាប់ស្តីពីការសាងសង់លំនៅឋានសម្រាប់គ្រួសារ និងកម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលឆ្នាំ 2026 ដើម្បី៖

(1) បង្កើតឥណទានភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាល ដើម្បីផ្តល់លទ្ធភាពកាន់តែច្រើនក្នុងការទទួលបានហិរញ្ញប្បទានផ្ទះសម្បែងសម្រាប់ការទិញលំនៅឋានសម្រាប់មួយគ្រួសារដែលសាងសង់ថ្មី ដោយឥតគិតថ្លៃដល់អ្នកបង់ពន្ធ។

(2) ពន្លឿន និង លើកទឹកចិត្តដល់ការសាងសង់លំនៅឋានសម្រាប់មួយគ្រួសារថ្មីៗ ដើម្បីបង្កើតឱកាសកម្មសិទ្ធិផ្ទះសម្បែងសម្រាប់គ្រួសារវណ្ណៈកណ្តាល និងដោះស្រាយបញ្ហាកង្វះលំនៅឋានសម្រាប់មួយគ្រួសារនៅរដ្ឋ California។

(3) ការពារអ្នកប្រើប្រាស់ពីការអនុវត្តកម្ចីមិនយុត្តិធម៌។

(4) ផ្តល់ឱកាសសម្រាប់ការវិនិយោគផលប៉ះពាល់សង្គមតាមរយៈការលើកកម្ពស់ការទិញមូលបត្របំណុលមានការប្រាក់ទាប ដើម្បីគាំទ្រឥណទានផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលដោយមានអត្រាការប្រាក់ទាបជាងទីផ្សារ ដើម្បីលើកកម្ពស់គោលដៅភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងនៅរដ្ឋ California ព្រមទាំងលើកកម្ពស់ការផ្តល់កម្ចី និងការវិនិយោគក្នុងសហគមន៍ដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ក្រេឌីតនៃច្បាប់ស្តីពីការវិនិយោគឡើងវិញក្នុងសហគមន៍។

(b) សម្រាប់គោលបំណងនៃជំពូកនេះ៖

(1) "ច្បាប់" មានន័យថា ច្បាប់ស្តីពីការសាងសង់លំនៅឋានសម្រាប់គ្រួសារ និងកម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលរដ្ឋ California ឆ្នាំ 2026។

(2) "ទីភ្នាក់ងារ" មានន័យថា ទីភ្នាក់ងារហិរញ្ញវត្ថិលំនៅដ្ឋានរដ្ឋ California។

(3) "អ្នកដាក់ពាក្យស្នើសុំ" មានន័យថា បុគ្គលទាំងឡាយណាដែលដាក់ពាក្យស្នើសុំ ដើម្បីទទួលបានឥណទានភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាល។

(4) "មូលបត្របំណុល" មានន័យថា មូលបត្របំណុលប្រាក់ចំណូល បណ្ណសន្យាប្រាក់ រួមទាំងពណ្ណសន្យាប្រាក់រំពឹងទុកលើមូលបត្របំណុល និងបណ្ណសន្យាប្រាក់កម្ចីសាងសង់ លិខិតបំណុល បណ្ណបញ្ជាក់បណ្តោះអាសន្ន ឬបណ្ណបញ្ជាក់ផ្សេងទៀត ឬភស្តុតាងផ្សេងទៀតនៃបំណុលហិរញ្ញវត្ថុដែលចេញដោយទីភ្នាក់ងារស្របតាមផ្នែកទី 51515.06។

(5) "អ្នកខ្ចីប្រាក់" មានន័យថា អ្នកដាក់ពាក្យស្នើសុំដែលបំពេញតាមលក្ខខណ្ឌដែលបានបង្កើតឡើងនៅក្នុងផ្នែករង (a) នៃមាត្រាទី 51515.01 និង លក្ខខណ្ឌសិទ្ធិទទួលបានផ្សេងទៀតដែលបង្កើតឡើងដោយទីភ្នាក់ងារ ហើយដែលទទួលបានឥណទានភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាល។

(6) "អ្នកសាងសង់" មានន័យថា អ្នកអភិវឌ្ឍន៍លំនៅដ្ឋានដែលចូលរួមក្នុងជម្រើសអ្នកសាងសង់ដែលមានលក្ខណៈគ្រប់គ្រាន់ ដែលបានបង្កើតឡើងនៅក្នុងមាត្រាទី 51515.02។

(7) "អ្នកឱ្យខ្ចីប្រាក់" មានន័យថា ធនាគារ សហជីពឥណទាន ក្រុមហ៊ុនបរធនបាលកិច្ច ធនាគារដាក់ប្រាក់សន្សំ សមាគមធនាគារជាតិ សមាគមប្រាក់សន្សំនិងឥណទាន សមាគមសាងសង់និងឥណទាន ធនាគារដាក់ទ្រព្យបញ្ចាំ ឬស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត ឬទីភ្នាក់ងាររដ្ឋាភិបាល ដែលផ្តល់សេវាឬផ្តល់ជំនួយផ្នែកហិរញ្ញប្បទានទ្រព្យបញ្ចាំលំនៅឋាន ឬក្រុមហ៊ុនកាន់កាប់ដែលបានរៀបរាប់ខាងលើ ដែលបំពេញតាមលក្ខខណ្ឌតម្រូវដែលបានបង្កើតឡើងនៅក្នុងមាត្រាទី 51515.03 និងដែលទីភ្នាក់ងារបានចុះកិច្ចសន្យាដើម្បីបង្កើត ឬផ្តល់សេវាឥណទានភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលដែលអនុញ្ញាតដោយជំពូកនេះ។

(8) "ឥណទានកម្មសិទ្ធិភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាល" មានន័យថា ឥណទានដែលមានប្រភពអនុលោមតាមជំពូកនេះ។

(9) "ជម្រើស" មានន័យថា ជម្រើសអ្នកសាងសង់ដែលមានលក្ខណៈគ្រប់គ្រាន់ ដើម្បីលើកកម្ពស់ការសាងសង់លំនៅឋានសម្រាប់មួយគ្រួសារដែលបានបង្កើតឡើងនៅក្នុងមាត្រាទី 51515.02។

(10) "កម្មវិធី" មានន័យថា កម្មវិធីឥណទានភាពជាម្ចាស់កម្មសិទ្ធិកម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាល។

(11) "ផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់" មានន័យថា លំនៅឋានសម្រាប់មួយគ្រួសារដែលបំពេញតាមលក្ខខណ្ឌតម្រូវដែលបានបង្កើតឡើងនៅក្នុងផ្នែករង (b) នៃមាត្រាទី 51515.01 រួមមានជាអាទិ៍ ផ្ទះដែលសាងសង់ក្រោមជម្រើសអ្នកសាងសង់ដែលមានលក្ខណៈគ្រប់គ្រាន់ដែលបានបង្កើតឡើងនៅក្នុងមាត្រាទី 51515.02។

(12) "ទ្រព្យបញ្ចាំបន្ទាប់បន្សំ" មានន័យថា ទ្រព្យបញ្ចាំ លិខិតផ្ទេរសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិជាទំនុកចិត្ត ឬឧបករណ៍សុវត្ថិភាពផ្សេងទៀតលើផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ ដែលធានាឥណទានភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាល។

(13) "លំនៅឋានសម្រាប់មួយគ្រួសារ" មានន័យថា ផ្ទះនៅមួយតែឯង ផ្ទះជាប់គ្នាជាជួរ ឬ ផ្ទះល្វែង រួមទាំងដីដែលផ្ទះស្ថិតនៅ ឬខុនដូ ផ្ទះសាងសង់ជាស្រេច ឬអគារស្នាក់នៅផ្សេងទៀត ដែលបង្កើតឡើងសម្រាប់ការកាន់កាប់ដោយមួយគ្រួសារ។

51515.01. សិទ្ធិទទួលបានរបស់អ្នកខ្ចីប្រាក់ និងផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់

(a) សិទ្ធិទទួលបានរបស់អ្នកខ្ចីប្រាក់ និងអ្នកទិញផ្ទះសម្រាប់វណ្ណៈកណ្តាល។

(1) អ្នកដាក់ពាក្យស្នើសុំត្រូវបំពេញតាមលក្ខខណ្ឌតម្រូវសិទ្ធិទទួលបានខាងក្រោម ដើម្បីមានលក្ខណៈគ្រប់គ្រាន់សម្រាប់ឥណទានភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលក្រោមកម្មវិធីនេះ៖

(A) លក្ខខណ្ឌតម្រូវអ្នករស់នៅរដ្ឋ California។ អ្នកដាក់ពាក្យស្នើសុំត្រូវតែជាអ្នករស់នៅក្នុងរដ្ឋ California យ៉ាងហោចណាស់មួយឆ្នាំ មុនរយៈពេលដាក់ពាក្យ។

(B) លំនៅឋានចម្បងដែលកាន់កាប់ដោយម្ចាស់កម្មសិទ្ធិ។ អ្នកដាក់ពាក្យស្នើសុំត្រូវយល់ព្រមកាន់កាប់ផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ជាលំនៅឋានចម្បងរបស់អ្នកដាក់ពាក្យស្នើសុំក្នុងរយៈពេល 60 ថ្ងៃការបិទទទួលពាក្យ។

(C) លក្ខខណ្ឌតម្រូវប្រាក់ចំណូល។ អ្នកដាក់ពាក្យស្នើសុំត្រូវមានប្រាក់ចំណូលគ្រួសារមិនលើសពី 200 ភាគរយនៃប្រាក់ចំណូលមធ្យមក្នុងតំបន់សម្រាប់គ្រួសារដែលមានសមាជិកដូចគ្នានៅក្នុងប្រទេស ឬតំបន់ភូមិសាស្ត្រប្រជុំជន ដែលផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ស្ថិតនៅ ដែលត្រូវបានកែតម្រូវសម្រាប់ទំហំគ្រួសារដោយភ្នាក់ងារ។

(D) លក្ខខណ្ឌតម្រូវបង់ប្រាក់កក់។ អ្នកដាក់ពាក្យស្នើសុំត្រូវយល់ព្រមបង់ប្រាក់មិនតិចជាង 3 ភាគរយនៃតម្លៃទិញផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ ដោយប្រើប្រាស់ប្រាក់ដែលជាជំនួយឥតសំណង ឬ កម្ចី។

(2) អ្នកដាក់ពាក្យស្នើសុំត្រូវផ្តល់ជូនទីភ្នាក់ងារនូវព័ត៌មាននៅក្នុងទម្រង់បែបបទដែលកំណត់ដោយទីភ្នាក់ងារ ដែលនឹងអាចឱ្យទីភ្នាក់ងារកំណត់សិទ្ធិទទួលបានរបស់អ្នកដាក់ពាក្យស្នើសុំនៅក្រោមជំពូកនេះ។

(b) សិទ្ធិទទួលបានផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់។

(1) ផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ត្រូវមានលក្ខណៈដូចខាងក្រោម៖

(A) ផ្ទះដែលទើបសាងសង់ថ្មីៗ ផ្ទះថោនហូម ផ្ទះល្វែង ខុនដូ ឬផ្ទះសាងសង់ជាស្រេច ដែលអ្នកខ្ចីប្រាក់ជាអ្នកទិញដំបូង។

37

(B) ខុនដូ ឬអគារស្នាក់នៅផ្សេងទៀតនៅក្នុងអគារដែលមិនមែនជារចនាសម្ព័ន្ធស្នាក់នៅ និងត្រូវបានបន្ថែម ឬកែប្រែឡើងវិញសម្រាប់ការប្រើប្រាស់ស្នាក់នៅ ដែលអ្នកខ្ចីប្រាក់ជាអ្នកទិញដំបូង។

(2) តម្លៃលក់អតិបរមាសម្រាប់ផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់មិនត្រូវលើសពី 125 ភាគរយនៃដែនកំណត់ឥណទានសម្រាប់ទ្រព្យមួយឯកតានៅក្នុងប្រទេសដែលផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ស្ថិតនៅក្នុងខោនធីដូចបានកំណត់នៅក្នុងរបាយការណ៍ស្តីពីដែនកំណត់ឥណទានដែលបោះពុម្ពផ្សាយដោយទីភ្នាក់ងារហិរញ្ញវត្ថុលំនៅឋានសហព័ន្ធ ឬទីភ្នាក់ងារបន្តសិទ្ធិអនុលោមតាមមាត្រាទី 4542 នៃចំណងជើងទី 12 នៃក្រមសហរដ្ឋអាមេរិក។

(3) មាត្រានេះនឹងមិនបង្កើតជាការរឹតបន្តឹងលើការលក់ផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ដល់អ្នកទិញផ្ទះដែលមិនចូលរួមក្នុងកម្មវិធីនេះឡើយ។

(4) ផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់នឹងមិនត្រូវបានចាត់ទុកថាជា "ការងារសាធារណៈ" សម្រាប់គោលបំណងនៃជំពូកទី 1 (ចាប់ផ្តើមជាមួយមាត្រាទី 1720) នៃផ្នែកទី 7 នៃភាគទី 2 នៃក្រមការងារឡើយ។

51515.02. ជម្រើសអ្នកសាងសង់ដែលមានលក្ខណៈគ្រប់គ្រាន់

(a) អ្នកអភិវឌ្ឍន៍លំនៅដ្ឋានអាចចូលរួមក្នុងជម្រើសនេះដោយស្ម័គ្រចិត្តតាមរយៈការបញ្ជាក់ទៅកាន់ទីភ្នាក់ងារថា ការសាងសង់ផ្ទះថ្មី ឬផ្ទះនឹងបំពេញតាមលក្ខខណ្ឌដែលបានបង្កើតឡើងនៅក្នុងផ្នែករង (b) នៃមាត្រាទី 51515.01។ ទីភ្នាក់ងារត្រូវចេញលិខិតមួយដែលបញ្ជាក់ពីស្ថានភាពចូលរួមក្នុងរយៈពេល 30 ថ្ងៃ បន្ទាប់ពីទទួលបានលិខិតបញ្ជាក់ដែលដាក់ស្នើអនុលោមតាមផ្នែករងនេះ។ លិខិតនេះអាចត្រូវបានយកមកប្រើប្រាស់ជាមូលដ្ឋានទុកចិត្តដោយអ្នកសាងសង់ អ្នកទិញ ឬអ្នកផ្តល់កម្ចីសាងសង់ សម្រាប់គោលបំណងនៃការធ្វើទីផ្សារ និងការផ្តល់ហិរញ្ញប្បទានផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ ដែលស្ថិតក្រោមលក្ខខណ្ឌនៅក្នុងជំពូកនេះ។

(b) អ្នកសាងសង់ដែលចូលរួមត្រូវ៖

(1) ត្រូវអនុលោមតាមបទប្បញ្ញត្តិស្តីពីការងារ និងការអនុវត្តក្នុងកថាខណ្ឌ (2), (3) ប្រសិនបើលក្ខខណ្ឌគម្រោង និងការសាងសង់ដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌនោះត្រូវបានបំពេញ កថាខណ្ឌ (4) និង (5) នៃផ្នែករង (d) នៃមាត្រាទី 21080.66 នៃក្រមធនធានសាធារណៈ។

(2) ត្រូវទទួលខុសត្រូវចំពោះការបំពានទាំងអស់លើកថាខណ្ឌ (1) នៃផ្នែករង (c) ដែលប្រព្រឹត្តិដោយអ្នកម៉ៅការ និងអ្នកម៉ៅការបន្តរបស់អ្នកសាងសង់។ គណៈកម្មាធិការសហប្រតិបត្តិការការគ្រប់គ្រងការងាររួមគ្នាត្រូវបានបង្កើតអនុលោមតាមច្បាប់ស្តីពីសហប្រតិបត្តិការការគ្រប់គ្រងកាងារសហព័ន្ធឆ្នាំ 1978 (29 U.S.C. មាត្រាទី 175a) អាចចាត់វិធានការនៅក្នុងតុលាការដែលមានដែនយុត្តាធិការចំពោះការបំពានកថាខណ្ឌនេះ។

(c) គណៈកម្មាធិការសហប្រតិបត្តិការការគ្រប់គ្រងការងាររួមគ្នាត្រូវបានបង្កើតស្របតាមច្បាប់ស្តីពីសហប្រតិបត្តិការការគ្រប់គ្រងកាងារសហព័ន្ធឆ្នាំ 1978 (29 U.S.C. មាត្រាទី 175a) អាចចាត់វិធានការនៅក្នុងតុលាការដែលមានដែនយុត្តាធិការប្រឆាំងនឹងអ្នកម៉ៅការ ឬអ្នកម៉ៅការបន្តរបស់អ្នកសាងសង់នៅគ្រប់កម្រិតតាងនាមឱ្យបុគ្គលិកសំណង់ដែលជួលដោយអ្នកម៉ៅការ ឬអ្នកម៉ៅការបន្ត ដើម្បីអនុវត្តចំណុចខាងក្រោម៖

(1) កាតព្វកិច្ចរបស់និយោជកនៅក្រោមភាគទី 1 (ចាប់ផ្តើមជាមួយមាត្រាទី 100) និងមាត្រាទី 6 (ចាប់ផ្តើមជាមួយមាត្រាទី 13000) នៃក្រមធានារ៉ាប់រងនិកម្មភាពការងារ។

(2) ការមិនបានធានាការបង់ធានារ៉ាប់រងប្រាក់សំណងរបស់កម្មករដូចបានតម្រូវដោយជំពូកទី 4 (ចាប់ផ្តើមជាមួយមាត្រាទី 3700) នៃផ្នែកទី 1 នៃភាគទី 4 នៃក្រមការងារ។

(3) ការបរាជ័យក្នុងការរក្សាសុពលភាពអាជ្ញាបណ្ណអ្នកម៉ៅការថ្នាក់រដ្ឋដូចបានតម្រូវដោយជំពូកទី 9 (ចាប់ផ្តើមជាមួយមាត្រាទី 7000) នៃភាគទី 3 នៃក្រមអាជីវកម្ម និងវិជ្ជាជីវៈ។

(d) ដំណោះស្រាយ និងការពិន័យចំពោះការបំពានច្បាប់ស្តីពីការងារនៅក្រោមមាត្រានេះត្រូវវាយតម្លៃ និងផ្សព្វផ្សាយដោយអនុលោមតាមផ្នែករង (m) នៃមាត្រាទី 2699 នៃក្រមការងារ។

(e) មាត្រានេះនឹងមិនបង្កើតជាការរឹតបន្តឹងលើការទិញផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ដែលត្រូវបានសាងសង់ក្រោមជម្រើសរបស់អ្នកទិញផ្ទះដែលមិនចូលរួមក្នុងកម្មវិធីនេះឡើយ។

(f) ប្រសិនបើអ្នកសាងសង់លក់ផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ដែលសាងសង់អនុលោមតាមផ្នែកនេះក្នុងតម្លៃលើសពី 25 ភាគរយនៃតម្លៃលក់អតិបរមាដែលបានបង្កើតឡើងនៅក្នុងកថាខណ្ឌ (2) នៃផ្នែករង (b) នៃមាត្រាទី 51515.01 នោះកថាខណ្ឌរង (B) នៃកថាខណ្ឌ (1) និងកថាខណ្ឌ (2) នៃផ្នែករង (e) នៃមាត្រាទី 51515.04 នឹងមិនត្រូវអនុវត្តចំពោះផ្ទះឡើយ។

51515.03. លក្ខខណ្ឌតម្រូវសម្រាប់អ្នកឱ្យខ្ចីប្រាក់

(a) ទីភ្នាក់ងារអាចចុះកិច្ចសន្យាជាមួយអ្នកឱ្យខ្ចីប្រាក់ចាប់ម្នាក់រឺច្រើននាក់ឡើងទៅ ដើម្បីបង្កើត ឬផ្តល់សេវាឥណទានភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលដែលអនុញ្ញាតដោយជំពូកនេះ។

(b) ទីភ្នាក់ងារត្រូវវាយតម្លៃថាតើកម្មវិធី (ស្របតាមគោលបំណងរបស់ខ្លួន) អាចត្រូវបានអនុវត្តតាមលក្ខណៈដែលបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់សកម្មភាពដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការពិចារណាជាអ្នកឱ្យខ្ចីប្រាក់ ស្របតាមច្បាប់ស្តីពីការវិនិយោគឡើងវិញនៅក្នុងសហគមន៍របស់សហព័ន្ធ (12 U.S.C. មាត្រាទី 2901 et seq.) ហើយបើដូច្នេះមែន អនុវត្តកម្មវិធីតាមលក្ខណៈបែបនោះ។

51515.04. ការការពារអ្នកប្រើប្រាស់ គណនេយ្យភាព និងស្តង់ដាតម្លាភាព

(a) ការការពារអ្នកប្រើប្រាស់។ ទីភ្នាក់ងារត្រូវបង្កើតលក្ខខណ្ឌការពារអ្នកប្រើប្រាស់ដែលអាចអនុវត្តបានចំពោះអ្នកឱ្យខ្ចីប្រាក់ដែលទីភ្នាក់ងារធ្វើកិច្ចសន្យាជាមួយ ដើម្បីបង្កើតឥណទានភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាល រួមមានជាអាទិ៍ ចំណុចខាងក្រោម៖

(1) ដែនកំណត់លើថ្លៃសេវារបស់អ្នកឱ្យខ្ចីប្រាក់ពាក់ព័ន្ធនឹងការបង្កើតឥណទានភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាល។

(2) ការហាមឃាត់ការពិន័យលើការបង់សងមុន។

(3) លក្ខខណ្ឌដែលឥណទានភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលត្រូវតែជាឥណទានទ្រព្យបញ្ចាំដែលមានការប្រាក់ថេរ។

(b) ការផ្ទៀងផ្ទាត់ឥណទានបន្ថែម។ ប្រសិនបើដោយសារមូលហេតុណាមួយ ពិន្ទុឥណទានរបស់អ្នកដាក់ពាក្យស្នើសុំមិនបំពេញតាមលក្ខខណ្ឌតម្រូវដែលអាចឱ្យអ្នកដាក់ពាក្យស្នើសុំអាចទទួលបានឥណទាន ឬមិនទទួលបានលក្ខខណ្ឌអំណោយផលបំផុតដែលមានក្រោមកម្មវិធីនេះទេ អ្នកឱ្យខ្ចីប្រាក់ត្រូវអនុញ្ញាតឱ្យអ្នកដាក់ពាក្យស្នើសុំដាក់បញ្ជូនកំណត់ត្រាហិរញ្ញវត្ថុដោយស្ម័គ្រចិត្ត រួមទាំងរបាយការណ៍ធនាគារ ចុងសន្លឹកបើកប្រាក់ខែ ទ្រព្យផ្ទាល់ខ្លួនដែលអាចផ្ទៀងផ្ទាត់បាន និងប្រវត្តិបង់សងថ្លៃជួល ព្រមទាំងប្រើប្រាស់ និងវាយតម្លៃកំណត់ត្រាទាំងនោះដោយប្រើការវាយតម្លៃលំហូរសាច់ប្រាក់ ដើម្បីឱ្យអ្នកដាក់ពាក្យស្នើសុំទទួលបានឥណទាន ឬទទួលបានលក្ខខណ្ឌអំណោយផលបំផុតដែលមានក្រោមកម្មវិធីនេះ។ តាមរយៈការដាក់បញ្ជូនកំណត់ត្រាហិរញ្ញវត្ថុដោយស្ម័គ្រចិត្ត អ្នកដាក់ពាក្យស្នើសុំយល់ព្រមឱ្យប្រើប្រាស់កំណត់ត្រាទាំងនោះសម្រាប់ការវាយតម្លៃលំហូរសាច់ប្រាក់សម្រាប់គោលបំណងរបស់គម្រោងនេះ។

(c) ការការពារ និង តំណាងអ្នកទិញផ្ទះ។ អ្នកដាក់ពាក្យស្នើសុំត្រូវមានភ្នាក់ងារ ឬអន្តរការីអចលនទ្រព្យដែលមានអាជ្ញាបណ្ណនៅរដ្ឋ California ដូចបានកំណត់នៅក្នុងមាត្រាទី 10018.06 នៃក្រមអាជីវកម្ម និងវិជ្ជាជីវៈ ដែលជ្រើសរើសដោយអ្នកដាក់ពាក្យស្នើសុំ ដើម្បីធានាថាអ្នកទិញផ្ទះទទួលបានតំណាង និងការការពារអ្នកប្រើប្រាស់សមស្របនៅក្នុងដំណើរការទិញផ្ទះ។

(d) ការពន្យារពេលសងដោយសារស្ថានភាពលំបាក។ អ្នកខ្ចីប្រាក់អាចស្នើសុំការពន្យារពេលសងដោយសារស្ថានភាពលំបាកបណ្តោះអាសន្ននូវការបង់ការប្រាក់ប្រចាំខែលើឥណទានកម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលស្របតាមលក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌដែលបង្កើតដោយទីភ្នាក់ងារ។

(e) ស្តង់ដាគណនេយ្យភាពនៃការសាងសង់។

(1) ដើម្បីការពារអ្នកប្រើប្រាស់ និងពន្លឿនការដោះស្រាយវិវាទសម្រាប់ម្ចាស់ផ្ទះ៖

(A) ចំណងជើងទី 7 (ចាប់ផ្តើមជាមួយមាត្រាទី 895) នៃផ្នែកទី 2 នៃភាគទី 2 នៃក្រមរដ្ឋប្បវេណី ត្រូវអនុវត្តចំពោះផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់លើកលែងតែបានកែប្រែនៅក្នុងកថាខណ្ឌរង (B) សម្រាប់ផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ដែលសាងសង់ដោយអ្នកសាងសង់អនុលោមតាមមាត្រាទី 51515.02។

(B) ផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ដែលសាងសង់ដោយអ្នកសាងសង់អនុលោមតាមមាត្រាទី 51515.02 ត្រូវគោរពតាមនីតិវិធីសិទ្ធិជួសជុលខាងក្រោម៖

(i) លក្ខខណ្ឌតម្រូវនៃការជូនដំណឹង។ ប្រសិនបើអ្នកទាមទារ មិនថាជាម្ចាស់ផ្ទះ ក្រុមម្ចាស់ផ្ទះ ឬសមាគមនោះទេ ចាប់ផ្តើមនីតិវិធីមុនការកាត់ក្តីនៅក្នុងផ្នែករង (a) នៃមាត្រាទី 910 នៃក្រមរដ្ឋប្បវេណី បន្ថែមពីលើការអនុលោមតាមលក្ខខណ្ឌតម្រូវទាំងអស់នៅក្នុងផ្នែករងនោះ ការជូនដំណឹងជាលាយលក្ខណ៍អក្សរដែលចាំបាច់ត្រូវកំណត់អត្តសញ្ញាណម្ចាស់ផ្ទះនីមួយៗ ដោយប្រើអាសយដ្ឋាន ឬការពណ៌នាផ្សេងទៀតដែលមានលក្ខណៈគ្រប់គ្រាន់ដើម្បីជម្រាបជូនអ្នកសាងសង់អំពីទីតាំងនៃលំនៅឋាននីមួយៗ ត្រូវកំណត់លក្ខណៈ និងទីតាំងនៃការបំពានដែលបានចោទប្រកាន់នីមួយៗនៅក្នុងលំនៅឋាន និងត្រូវចុះហត្ថលេខាដោយម្ចាស់ផ្ទះដែលចោទប្រកាន់ការបំពាននោះ។

(ii) អនុញ្ញាតឱ្យមានការប្រាស្រ័យទាក់ទងបើកចំហ និងតម្លាភាព។ ទោះជាមានចែងក្នុងមាត្រាទី 913 នៃក្រមរដ្ឋប្បវេណីក៏ដោយ ក៏អ្នកសាងសង់អាចទាក់ទងទៅម្ចាស់ផ្ទះ ឬអ្នកទាមទារដោយផ្ទាល់នៅអំឡុងដំណាក់កាលនីតិវិធីមុនការកាត់ក្តី ដែលបានពណ៌នាក្នុងជំពូក 4 (ចាប់ផ្តើមជាមួយមាត្រាទី 910) នៃចំណងជើងទី 7 នៃផ្នែកទី 2 នៃភាគទី 2 នៃក្រមរដ្ឋប្បវេណី។ ទោះជាយ៉ាងណាក៏ដោយ បទបញ្ញត្តិនេះមិនមានបំណងកែប្រែវិធានក្រមសីលធម៌វិជ្ជាជីវៈរដ្ឋ California របស់គណៈមេធាវីរដ្ឋ California នោះទេ រួមទាំងច្បាប់ទី 4.2 ដែលហាមឃាត់មេធាវីមិនឱ្យប្រាស្រ័យទាក់ទងដោយផ្ទាល់ ឬដោយប្រយោលជាមួយបុគ្គលដែលមានមេធាវីផ្សេងតំណាងនៅក្នុងសំណុំរឿង។

(iii) អនុញ្ញាតលិខិតរំលត់កាតព្វកិច្ចរបស់ម្ចាស់ផ្ទះ។ ដោយមិនគិតពីមាត្រាទី 926 នៃក្រមរដ្ឋប្បវេណីឡើយ អ្នកសាងសង់អាចទទួលបានលិខិតរំលត់កាតព្វកិច្ច ឬលិខិតលះបង់សិទ្ធិពីម្ចាស់ផ្ទះសម្រាប់ការងារជួសជុលដែលកំណត់ដោយជំពូកទី 4 (ចាប់ផ្តើមជាមួយផ្នែកទី 910) នៃចំណងជើងទី 7 នៃផ្នែកទី 2 នៃភាគទី 2 នៃក្រមរដ្ឋប្បវេណី ដែលចែងថា អ្នកសាងសង់បានបំពេញការជួសជុលដោយភាពឧស្សាហ៍ព្យាយាមបំផុត ហើយម្ចាស់ផ្ទះពេញចិត្តនឹងការជួសជុលទាំងនោះ។ ម្ចាស់ផ្ទះអាចចុះហត្ថលេខាលើលិខិតរំលត់កាតព្វកិច្ចនៃការទាមទារដែលទាក់ទងតែទៅនឹងកង្វះខាតដែលបានជួសជុល។ លិខិតរំលត់កាតព្វកិច្ចនោះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ចុះហត្ថលេខាដោយស្ម័គ្រចិត្តនិងមានអ្នកដឹងឮ និង មិនត្រូវពង្រីកទៅលើបញ្ហា ឬការទាមទារដែលជួសជុលរួចហើយនោះឡើយ។

(iv) ការលើកទឹកចិត្តឱ្យមានដំណោះស្រាយតាមផ្លូវតុលាការឆាប់រហ័ស។ ប្រសិនបើតុលាការអនុម័តលើបណ្តឹងសុំព្យួរនីតិវិធីអនុលោមតាមផ្នែករង (b) នៃមាត្រាទី 930 នៃក្រមរដ្ឋប្បវេណី ហើយរយៈពេល 120 ថ្ងៃបន្ទាប់ពីនោះអ្នកទាមទារមិនបានចាត់វិធានការគាំទ្រដែលស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកទាមទារ ដើម្បីគោរពតាមលក្ខខណ្ឌតម្រូវនៃជំពូកទី 4 (ចាប់ផ្តើមជាមួយមាត្រាទី 910) នៃចំណងជើងទី 7 នៃផ្នែកទី 2 នៃភាគទី 2 នៃក្រមរដ្ឋប្បវេណី អ្នកសាងសង់អាចដាក់ពាក្យស្នើសុំទាត់ចោលបណ្តឹងនោះបាន។ តុលាការអាចផ្តល់រង្វាន់ជាថ្លៃសេវាមេធាវី និងថ្លៃចំណាយសម្រាប់ការដាក់ពាក្យស្នើសុំឬការជំទាស់នឹងបណ្តឹងស្នើសុំនោះដល់ភាគីដែលឈ្នះក្តីតាមឆន្ទានុសិទ្ធិរបស់ខ្លួន។

(v) ការបញ្ចេញព័ត៌មានដល់អ្នកទិញផ្ទះ។ មុនពេលការបញ្ចប់ដំណើរការអេស្ក្រូ អ្នកសាងសង់ផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ត្រូវលាតត្រដាងព័ត៌មានជាលាយលក្ខណ៍អក្សរក្នុងទម្រង់បែបបទដែលអនុម័តដោយទីភ្នាក់ងារ ដល់អ្នកទិញផ្ទះនីមួយៗថា ផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ត្រូវអនុលោមតាមកថាខណ្ឌរងនេះ។

(C) កថាខណ្ឌរង (B) មិនត្រូវអនុវត្តចំពោះផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ដែលគ្របដណ្តប់ដោយផ្នែករង (f) នៃមាត្រាទី 51515.02។

(2) ដោយមិនគិតពីច្បាប់ផ្សេងទៀតឡើយ វិធានការទាំងឡាយដែលលើកឡើងដោយម្ចាស់ផ្ទះ ឬក្រុមម្ចាស់ផ្ទះដែលអះអាងថាការអះអាងស្ថិតក្រោមនីតិវិធីដែលកំណត់នៅក្នុងជំពូកទី 4 (ចាប់ផ្តើមជាមួយមាត្រាទី 910) និង ជំពូកទី 5 (ចាប់ផ្តើមជាមួយមាត្រាទី 941) នៃចំណងជើងទី 7 នៃផ្នែកទី 2 នៃភាគទី 2 នៃក្រមរដ្ឋប្បវេណី ឬនីតិវិធីដែលកំណត់នៅក្នុងកថាខណ្ឌរង (B) នៃកថាខណ្ឌ (1) នៃផ្នែករងនេះដែលទាក់ទងនឹងផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ ថ្លៃសេវាភាគរយអតិបរមាសម្រាប់មេធាវីមិនត្រូវលើសពី 30 ភាគរយនៃចំទឹកប្រាក់ស្តារសរុបដែលទទួលបានតាមរយៈការសម្រុះសម្រួល ការចរចា មជ្ឈត្តកម្ម ការយោងតាមផ្លូវតុលាការ ឬសេចក្តីសម្រេចរបស់តុលាការ លើកលែងតែតុលាការបញ្ជាក់ថាមានថ្លៃសេវាខ្ពស់ជាងនេះដោយពិចារណាលើលទ្ធផលដែលទទួលបាន ហានិភ័យដែលមេធាវីបានទទួល កិច្ចព្រមព្រៀងរវាងមេធាវីនិងកូនក្តី ភាពស្មុគស្មាញនៃសំណុំរឿង និងជំនាញដែលបង្ហាញដោយមេធាវី។ កម្រៃដែលអាស្រ័យលើលទ្ធផលនៃសំណុំរឿងសម្រាប់មេធាវីត្រូវទូទាត់ចេញតែមួយមុខគត់ពីចំនួនទឹកប្រាក់នៃការសម្រុះសម្រួល ការចរចា មជ្ឈត្តកម្ម ការយោងតាមផ្លូវតុលាការ ឬសេចក្តីសម្រេចរបស់តុលាការ។

(f) អ្នកឱ្យខ្ចីប្រាក់ដែលបង្កើតឥណទានភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលអាចគិតថ្លៃសេវាបង្កើតឥណទានមិនឱ្យលើសពី 0.5 ភាគរយ ឬ ពីររយកៅសិបដុល្លារ ($290) មួយណាក៏បានឱ្យតែច្រើនជាង។ ទីភ្នាក់ងារអាចកែតម្រូវចំនួន ពីររយកៅសិបដុល្លារ ($290) មិនលើសពីម្តងរៀងរាល់ពីឆ្នាំម្តង។ អ្នកឱ្យខ្ចីប្រាក់មិនត្រូវគិតថ្លៃសេវាឥណទានផ្សេងទៀតទេលុះត្រាតែបានអនុញ្ញាតដោយទីភ្នាក់ងារ។

(g) មាត្រាទី 2924.13 នៃក្រមរដ្ឋប្បវេណីមិនត្រូវអនុវត្តចំពោះឥណទានភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលដែលធ្វើឡើងនៅក្រោមជំពូកនេះឡើយ។

51515.05. លក្ខខណ្ឌតម្រូវនៃកម្មវិធី

(a) ទីភ្នាក់ងារត្រូវអនុវត្តកម្មវិធីនេះមិនឱ្យលើសពីមួយឆ្នាំក្រោយកាលបរិច្ឆេទមានប្រសិទ្ធភាពនៃច្បាប់នេះ។ ទីភ្នាក់ងារត្រូវមានសិទ្ធិអំណាចទាំងអស់ដែលបានប្រគល់ជូនខ្លួនដោយផ្នែកនេះ ដើម្បីអនុវត្ត និងគ្រប់គ្រងកម្មវិធីនោះស្របតាមជំពូកនេះ។ តាមរយៈការអនុវត្តជំពូកនេះ ទីភ្នាក់ងារត្រូវប្រើប្រាស់វិធាន និងបទបញ្ញត្តិដែលបានទទួលយកដោយក្រុមប្រឹក្សាភិបាលរបស់ទីភ្នាក់ងារ និង ស្របតាមជំពូកនេះ។ គោលការណ៍ វិធាន និងបទបញ្ញត្តិដែលប្រើប្រាស់អនុលោមតាមផ្នែកនេះមិនត្រូវស្ថិតក្រោមជំពូកទី 3.5 (ចាប់ផ្តើមជាមួយមាត្រាទី 11340) នៃផ្នែកទី 1 នៃភាគទី 3 នៃចំណងជើងទី 2 នៃក្រមរដ្ឋាភិបាលឡើយ។

(b) ឥណទានភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលនីមួយៗត្រូវធានាដោយទ្រព្យបញ្ចាំបន្ទាប់បន្សំ ត្រូវប្រើប្រាស់ដើម្បីផ្តល់ហិរញ្ញប្បទានចំណែកនៃតម្លៃទិញផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់តែមួយមុខ និងត្រូវផ្តល់ហិរញ្ញប្បទានមិនឱ្យលើសពី 17 ភាគរយនៃតម្លៃទិញផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់ដែលគ្របដណ្តប់ដោយប្រាក់បង់មុនមួយផ្នែករបស់ម្ចាស់ផ្ទះ ដែលអ្នកដាក់ពាក្យស្នើសុំចូលរួមមិនតិចជាង 3 ភាគរយនៃតម្លៃ

ទិញផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់។ ឥណទានភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលនីមួយៗដែធានា ដោយទ្រព្យបញ្ចាំបន្ទាប់បន្សំ ត្រូវមានតម្លៃទាបជាងទ្រព្យបញ្ចាំចម្បងដែលផ្តល់ហិរញ្ញប្បទានដល់ការទិញផ្ទះថ្មីដែលមានលក្ខណៈគ្រប់គ្រាន់។ ទីភ្នាក់ងារត្រូវអនុម័តបទប្បញ្ញត្តិស្តីពីចំណាយក្នុងការបញ្ចប់ប្រតិបត្តិការទិញផ្ទះ រួមទាំង ប៉ុន្តែមិនកំណត់ត្រឹមតែ ការអនុញ្ញាតឱ្យអ្នកខ្ចីប្រើប្រាស់ប្រាក់កម្ចីសម្រាប់ភាពជាម្ចាស់ផ្ទះរបស់វណ្ណៈកណ្តាល ដើម្បីទូទាត់ចំណាយក្នុងការបញ្ចប់ប្រតិបត្តិការដែលពាក់ព័ន្ធនឹងការទិញផ្ទះថ្មីដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងស្រុង ដោយមានលក្ខខណ្ឌថា ទីភ្នាក់ងារកំណត់ថា បទប្បញ្ញត្តិបែបនេះធ្វើឱ្យមានតុល្យភាពរវាងផលប្រយោជន៍របស់អ្នកខ្ចី និងអ្នកវិនិយោគលើប័ណ្ណបំណុល។

(c) ទីភ្នាក់ងារត្រូវកំណត់លក្ខខណ្ឌរយៈពេលស្នាក់នៅសម្រាប់អ្នកខ្ចីប្រាក់ និងអត្រាការប្រាក់ កាលវិភាគបង់រំលស់ ការបង់សងប្រាក់ដើម បទបញ្ញត្តិបង់សងជាមុន និងលក្ខខណ្ឌបង់សងផ្សេងទៀតលើឥណទានភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលចំពោះលក្ខខណ្ឌដែលទីភ្នាក់ងារកំណត់ដល់អ្នកដាក់ពាក្យស្នើសុំ ហើយក្នុងកម្រិតអតិបរមាដែលអាចធ្វើទៅបាន ដើម្បីបង់សងប្រាក់ដើម ការប្រាក់ និងទឹកប្រាក់ផ្សេងទៀតដែលដល់កំណត់ទាក់ទងនឹងមូលបត្របំណុលអនុលោមតាមជំពូកនេះ រួមទាំងទឹកប្រាក់ដែលចាំបាច់ដើម្បីទូទាត់រាល់ការចំណាយរដ្ឋបាលដែលកើតឡើងដោយទីភ្នាក់ងារអនុលោមតាមជំពូកនេះ។

(d) ទីភ្នាក់ងារត្រូវបង្កើតលក្ខខណ្ឌអប់រំម្ចាស់ផ្ទះសម្រាប់អ្នកខ្ចីប្រាក់ដែលទីភ្នាក់ងារកំណត់ដែលនឹងទទួលបានប្រយោជន៍ពីការអប់រំម្ចាស់ផ្ទះ រួមទាំងអ្នកទិញផ្ទះលើកដំបូងជាដើម ហើយត្រូវអនុវត្តការងារប្រកបដោយប្រសិទ្ធភាពចំណាយបំផុត ដោយចែងថា លក្ខខណ្ឌតម្រូវនោះអាចបំពេញបានក្នុងរយៈពេលកំណត់សម្រាប់ការបិទបញ្ជី។

(e) ទីភ្នាក់ងារត្រូវបង្កើតលក្ខណៈវិនិច្ឆ័យវាយតម្លៃឥណទានកម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាល និងអាចកែតម្រូវលក្ខខណ្ឌ និងសិទ្ធិទទួលបានឥណទានភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាល រួមទាំងប៉ុន្តែមិនកំណត់ត្រឹមតែ ដែនកំណត់ឥណទាន ពិន្ទុឥណទានអប្បបរមា ឬការផ្ទៀងផ្ទាត់ឥណទានបន្ថែមដែលអនុញ្ញាតដោយផ្នែករង (b) នៃត្រាទី 51515.04 និងសមាមាត្របំណុលធៀបនឹងចំណូល ដើម្បីបំពេញតាមស្តង់ដា និងលក្ខខណ្ឌតម្រូវរបស់សហព័ន្ធដែលបង្កើតឡើងដោយ Fannie Mae, Freddie Mac ឬរដ្ឋបាលលំនៅឋានសហព័ន្ធ ដែលចែងថា លក្ខណៈវិនិច្ឆ័យទាំងនោះត្រូវស្របតាមលក្ខខណ្ឌ និងគោលបំណងនៃជំពូកនេះ។

(f) ទីភ្នាក់ងារត្រូវមានឆន្ទានុសិទ្ធិក្នុងការកំណត់របៀប ពេលវេលា និងការចែកចាយការលក់មូលបត្របំណុលតាមភូមិសាស្ត្រ រួមទាំងថាតើត្រូវធ្វើទីផ្សារមូលបត្របំណុលទៅតាមតំបន់ឬទូទាំងរដ្ឋ ហើយធ្វើបែបនោះក្នុងលក្ខណៈដែលកាត់បន្ថយថ្លៃការប្រាក់ និងលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងទូលំទូលាយពីអ្នកវិនិយោគ។

(g) ទីភ្នាក់ងារត្រូវធ្វើសវនកម្មប្រចាំឆ្នាំដោយឯករាជ្យលើកម្មវិធី ដើម្បីធានាបានថាមូលបត្របំណុលដែលទទួលបានត្រូវបានប្រើប្រាស់ដោយស្របតាមលក្ខខណ្ឌតម្រូវនៃជំពូកនេះ និងច្បាប់ជាធរមានផ្សេងទៀត។

51515.06. មូលបត្របំណុលប្រាក់ចំណូល

(a) ដោយអនុវត្តត្រឹមតែការកម្រិតនៃជំពូកនេះ ភ្នាក់ងារអាចបន្ថែមលើអំណាចផ្សេងទៀតដែលបានប្រគល់ដោយភាគនេះ៖

(1) ចេញផ្សាយ និងលក់មូលបត្របំណុលរបស់ខ្លួនក្នុងចំនួនប្រាក់ដើមដែលភ្នាក់ងារកំណត់ថាចាំបាច់សម្រាប់គោលបំណងផ្តល់មូលនិធិ ឬការទទួលបានកម្ចីទិញផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលនៅក្រោមកម្មវិធីនេះ និងសម្រាប់ការទូទាត់ការប្រាក់លើមូលបត្របំណុលទាំងនេះ ការបង្កើតបម្រុងដើម្បីធានាមូលបត្របំណុល និងការទូទាត់ចំណាយផ្សេងទៀតរបស់ភ្នាក់ងារដែលពាក់ព័ន្ធ និងចាំបាច់ ឬសមស្របទៅនឹងការចេញផ្សាយមូលបត្របំណុល រួមទាំងថ្លៃដើមនៃការលើកកម្ពស់ឥណទាន ឬសាច់ប្រាក់ងាយស្រួល ដោយផ្តល់ថាចំនួនប្រាក់ដើមនៃមូលបត្របំណុលណាមួយដែលបានចេញផ្សាយនិងលក់អនុលោមតាមជំពូកនេះ មិនត្រូវលើសពីម្ភៃប្រាំពាន់លានដុល្លារ ($25,000,000,000) ឡើយ ដោយមិនរាប់បញ្ចូលចំនួននៃមូលបត្របំណុលសងវិញណាមួយដែលបានចេញផ្សាយអនុលោមតាមកថាខណ្ឌ (2).

(2) ចេញផ្សាយ និងលក់មូលបត្របំណុលរបស់ខ្លួនដើម្បីលស់ សង បញ្ចប់សុពលភាព រៀបចំរចនាសម្ព័ន្ធឡើងវិញ ឬទិញយកមូលបត្របំណុលដែលបានចេញពីមុនមក អនុលោមតាមជំពូកនេះ និងអនុលោមតាមផ្នែកទី 3 (ដោយចាប់ផ្តើមពីមាត្រាទី 50900)។

(3) ចុះកិច្ចព្រមព្រៀងក្នុងលើសេចក្តីសម្រេច លិខិតកិច្ចសន្យា ឬឯកសារផ្សេងទៀតដែលគ្រប់គ្រងមូលបត្របំណុលជាមួយអ្នកទទួលខុសត្រូវណាមួយ។

(4) ចុះកិច្ចព្រមព្រៀងសម្រាប់ការលើកកម្ពស់ឥណទាន ឬការគាំទ្រសាច់ប្រាក់ងាយស្រួល។

(5) បញ្ចាំ និងប្រគល់សិទ្ធិឃាត់ទុក និងផលប្រយោជន៍ធានាលើទ្រព្យធានា រួមទាំង ប៉ុន្តែមិនកំណត់ត្រឹមតែកម្ចីទិញផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាល និងសិទ្ធិរបស់ភ្នាក់ងារនៅក្រោមនោះឡើយ ដើម្បីធានាកាតព្វកិច្ចរបស់ភ្នាក់ងារនៅក្រោមកិច្ចព្រមព្រៀងលើសេចក្តីសម្រេច លិខិតកិច្ចសន្យា ឬឯកសារផ្សេងទៀតដែលគ្រប់គ្រងមូលបត្របំណុល និងកិច្ចព្រមព្រៀងសម្រាប់ការលើកកម្ពស់ឥណទាន ឬការគាំទ្រសាច់ប្រាក់ងាយស្រួល។ ការបញ្ចាំ សិទ្ធិឃាត់ទុក និងផលប្រយោជន៍ធានានេះ ត្រូវគ្រប់គ្រងដោយជំពូកទី 5.5 (ចាប់ផ្តើមពីមាត្រាទី 5450) នៃភាគទី 6 នៃចំណងជើង 1 នៃក្រមរដ្ឋាភិបាល។

(6) បង្កើត ឬទទួលបានកម្ចីទិញផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាល។

(7) ប្រមូល ឬបង្កើតឱ្យមានការប្រមូល ការទូទាត់ប្រាក់កម្ចី និងចំនួនទឹកប្រាក់ផ្សេងទៀត នៅពេលដល់កំណត់ពីអ្នកខ្ចីនៅក្រោមកម្ចីទិញផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាល។

(8) អនុវត្ត ឬចាត់ចែងឱ្យមានការអនុវត្តនូវលក្ខខណ្ឌនៃកម្ចីទិញផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាល និងប័ណ្ណបញ្ចាំបន្ទាប់បន្សំទល់នឹងអ្នកខ្ចី។

(9) ទទួលយកជំនួយ ឬការបរិច្ចាគណាមួយសម្រាប់ផលប្រយោជន៍នៃកម្មវិធី។

(10) ធ្វើ និងអនុវត្តកិច្ចសន្យា និងលិខិតបកស្រាយផ្សេងទៀត ហើយធ្វើអ្វីៗទាំងអស់ដែលចាំបាច់ សមស្រប ឬគួរឲ្យចង់បាន ក្នុងការភ្ជាប់ជាមួយនឹងមូលបត្របំណុល កម្ចីទិញផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាល ប័ណ្ណបញ្ចាំបន្ទាប់បន្សំ ឬដើម្បីអនុវត្តបទប្បញ្ញត្តិនៃជំពូកនេះ។

(b) បន្ថែមលើសេចក្តីថ្លែងការណ៍ដែលត្រូវតម្រូវដោយមាត្រាទី 51374 មូលបត្របំណុលទាំងអស់ដែលបានចេញផ្សាយអនុលោមតាមមាត្រានេះត្រូវតែមានការថ្លែងការណ៍ដូចខាងក្រោមនៅលើផ្នែកខាងមុខ៖ "មូលបត្របំណុលនេះ មិនត្រូវចាត់ទុកថាជាបំណុល ឬកាតព្វកិច្ច ឬជាការសន្យាលើជំនឿទុកចិត្ត និងឥណទាននៃរដ្ឋ California ក្រៅតែពីភ្នាក់ងារនោះឡើយ ប៉ុន្តែត្រូវទូទាត់តែពីមូលនិធិដែលបានផ្តល់សម្រាប់មូលបត្របំណុលនោះតែប៉ុណ្ណោះ។"

មាត្រាទី 3. វិសោធនកម្ម។

ច្បាប់នេះត្រូវបកស្រាយឲ្យបានទូលំទូលាយ ដើម្បីសម្រេចបាននូវគោលបំណងរបស់ខ្លួន។ បទបញ្ញត្តិនៃច្បាប់នេះ អាចត្រូវធ្វើវិសោធនកម្មដរាបណាវិសោធនកម្មទាំងនោះ ស្របគ្នា និងជំរុញបន្ថែមទៀតនូវគោលបំណងនៃការសាងសង់ផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាលបន្ថែមទៀតនៅក្នុងរដ្ឋ California ការការពារអ្នកខ្ចីទិញផ្ទះនៅក្រោមកម្មវិធីនេះ និងការពង្រីកឱកាសភាពជាម្ចាស់ផ្ទះសម្រាប់ប្រជាជនរដ្ឋ California វណ្ណៈកណ្តាល ដោយលក្ខន្តិកៈដែលត្រូវបានអនុម័តដោយសំឡេងឆ្នោតលើសពី 60 ភាគរយ នៃសមាជិកនៃសភានីមួយៗនៃអង្គនីតិបញ្ញត្តិ និងត្រូវបានចុះហត្ថលេខាដោយអភិបាលរដ្ឋ។

37

មាត្រាទី 4. ការបំបែកចេញពីគ្នាបាន។

បទបញ្ញត្តិនៃច្បាប់នេះគឺអាចជាការបំបែកចេញពីគ្នាបាន។ ប្រសិនបើផ្នែកណាមួយ មាត្រាណាមួយ អនុផ្នែកណាមួយ កថាខណ្ឌណាមួយ ឃ្លាណាមួយ ប្រយោគណាមួយ ពាក្យណាមួយ ឬការអនុវត្តណាមួយនៃច្បាប់នេះ ត្រូវបានចាត់ទុកថាគ្មានសុពលភាពដោយសារហេតុផលណាមួយដោយសេចក្តីសម្រេចរបស់តុលាការដែលមានយុត្តាធិការត្រឹមត្រូវនោះ សេចក្តីសម្រេចនោះនឹងមិនប៉ះពាល់ដល់សុពលភាពនៃផ្នែកដែលនៅសេសសល់នៃច្បាប់នេះឡើយ។ ប្រជាជនរដ្ឋ California សូមប្រកាសថា ពួកគេគួរតែទទួលយកច្បាប់នេះ ហើយផ្នែកនីមួយៗ ផ្នែករង កថាខណ្ឌ ឃ្លា ប្រយោគ វគ្គ ពាក្យ និងការអនុវត្តមិនត្រូវបានប្រកាសថាមិនត្រឹមត្រូវ ឬមិនស្របតាមរដ្ឋធម្មនុញ្ញដោយមិនគិតពី ថាតើផ្នែកណាមួយនៃច្បាប់នេះ ឬការអនុវត្តរបស់វានឹងត្រូវបានប្រកាសថាមិនមានសុពលភាព។

មាត្រាទី 5. ការបកស្រាយច្បាប់ឱ្យបានទូលំទូលាយ។

គំនិតផ្តួចផ្តើមនេះត្រូវបកស្រាយឲ្យបានទូលំទូលាយ ដើម្បីសម្រេចបាននូវគោលបំណងរបស់ខ្លួន។

ផ្នែកទី 6. វិធានការសន្លឹកឆ្នោតដែលមានខ្លឹមសារផ្ទុយគ្នា។

(a) ក្នុងករណីដែលវិធានការនេះ និងវិធានការមួយផ្សេងទៀតដែលអនុញ្ញាតឲ្យមានមូលបត្របំណុលប្រាក់ចំណូលដើម្បីផ្តល់មូលនិធិដល់កម្ចីទិញផ្ទះសម្បែងសម្រាប់វណ្ណៈកណ្តាល បង្ហាញនៅលើសន្លឹកឆ្នោតជ្រើសរើសទូទាំងរដ្ឋតែមួយ បទបញ្ញត្តិនៃវិធានការផ្សេងទៀតនោះ ត្រូវចាត់ទុកថាមានជំទាស់ជាមួយនឹងវិធានការនេះ។ ប្រសិនបើវិធានការនេះទទួលបានសំឡេងគាំទ្រច្រើនជាងវិធានការដែលចាត់ទុកថាមានភាពប្រទាំងគ្នាជាមួយវា បញ្ញត្តិនៃវិធានការនេះត្រូវមានសុពលភាពអនុវត្តទាំងស្រុង ហើយបទបញ្ញត្តិនៃវិធានការផ្សេងទៀតត្រូវទុកជាមោឃៈ។

(b) ប្រសិនបើវិធានការនេះត្រូវបានអនុម័តដោយអ្នកបោះឆ្នោត ប៉ុន្តែត្រូវជំនួសទាំងស្រុង ឬមួយផ្នែកដោយវិធានការដែលមានទំនាស់ដែលត្រូវបានអនុម័តដោយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតតែមួយ ហើយវិធានការដែលមានទំនាស់នោះត្រូវបានប្រកាសជាបន្តបន្ទាប់ថាជាមោឃៈ វិធានការនេះត្រូវមានប្រសិទ្ធភាពដោយស្វ័យប្រវត្តិ និងត្រូវបានផ្តល់ប្រសិទ្ធភាពពេញលេញ។

សំណើ 38

វិធានការផ្តួចផ្តើមនេះត្រូវបានដាក់ជូនប្រជាពលរដ្ឋដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី 8 នៃអត្ថបទ II នៃរដ្ឋធម្មនុញ្ញរដ្ឋ California ។

វិធានការផ្តួចផ្តើមនេះបន្ថែមផ្នែកទៅក្នុងក្រមសុខភាព និងសុវត្ថិភាព។ ដូច្នេះហើយ បទបញ្ញត្តិថ្មីដែលបានស្នើឱ្យបន្ថែមត្រូវបានបោះពុម្ពជាប្រភេទ *អក្សរទ្រេត*ដើម្បីបញ្ជាក់ថាច្បាប់ទាំងនោះថ្មី។

ច្បាប់ដែលបានដាក់ស្នើឡើង

គំនិតផ្តួចផ្តើមស្រាវជ្រាវ និងការព្យាបាលផ្នែកភាពស៊ាំវិទ្យានៃរដ្ឋ California

មាត្រាទី 1. ចំណងជើង.

ច្បាប់នេះនឹងត្រូវបានគេស្គាល់ ហើយអាចត្រូវបានដកស្រង់ថាជា "គំនិតផ្តួចផ្តើមនៃការស្រាវជ្រាវ និងការព្យាបាលផ្នែកភាពស៊ាំវិទ្យានៃរដ្ឋ California"។

មាត្រាទី 2. ការរកឃើញ និងការប្រកាស។

ប្រជាជននៃរដ្ឋ California យល់ឃើញ និងប្រកាសទាំងអស់ដូចខាងក្រោម៖

(a) ការស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រកំពុងឈានដល់ដំណាក់កាលជិតសម្រេចបាននូវរបកគំហើញដ៏សំខាន់ដែលអាចផ្លាស់ប្តូរយ៉ាងខ្លាំងនូវការបង្ការ ការព្យាបាល និងការជាសះស្បើយពីជំងឺធ្ងន់ធ្ងរ និងជំងឺដែលបណ្តាលឱ្យមានពិការភាពមួយចំនួន ព្រមទាំងបញ្ហាសុខភាពផ្សេងទៀត ដែលប៉ះពាល់ដល់មនុស្សជាច្រើន និងមនុស្សជាទីស្រឡាញ់របស់ពួកគេជារៀងរាល់ថ្ងៃ។

(b) វិស័យស្រាវជ្រាវវេជ្ជសាស្ត្រដែលកំពុងលេចឡើង គឺស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំ ផ្តល់ក្តីសង្ឃឹមសម្រាប់របកគំហើញដ៏សំខាន់ៗក្នុងវិទ្យាសាស្ត្រសុខាភិបាល ដែលប្រសិនបើទទួលបានមូលនិធិគ្រប់គ្រាន់ នឹងនាំឱ្យមានការរីកចម្រើនយ៉ាងខ្លាំងក្នុងវិទ្យាសាស្ត្រ ក្នុងការព្យាបាល និងការបង្ការជំងឺ និងបញ្ហាសុខភាពជាច្រើនប្រភេទដែលកើតមានជាទូទៅ និងបណ្តាលឱ្យជនជាតិអាមេរិកស្លាប់ ឬពិការជារៀងរាល់ឆ្នាំ។

(c) ប្រព័ន្ធស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំ ប្រើប្រាស់ប្រព័ន្ធភាពស៊ាំធម្មជាតិរបស់រាងកាយ ដើម្បីសម្គាល់ និងទប់ស្កាត់ជំងឺ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ការព្យាបាលដោយប្រព័ន្ធភាពស៊ាំត្រូវបានបង្ហាញថា ជាវិធីព្យាបាលដ៏មានប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺមហារីកមួយចំនួន ដូចជា មហារីស្បែកប្រភេទសាហាវ នឹងកម្រ មហារីកសួត ជំងឺមហារីកឈាមមួយចំនួន និងជំងឺមហារីកកូនកណ្តុរ ព្រមទាំងជំងឺមហារីកផ្សេងទៀត។

(d) វេជ្ជបណ្ឌិត និងអ្នកវិទ្យាសាស្ត្រស្រាវជ្រាវជាច្រើនជឿថា ការព្យាបាលដោយប្រព័ន្ធភាពស៊ាំមានសក្តានុពលក្នុងការបង្ការ និងព្យាបាលឱ្យជាសះស្បើយពីជំងឺ និងបញ្ហាសុខភាពជាច្រើនប្រភេទក្នុងអំឡុងជីវិតរបស់យើង រួមមាន ជំងឺមហារីក ជំងឺបេះដូង ជំងឺប្រព័ន្ធប្រសាទ ដូចជា ជំងឺ Alzheimer's និងជំងឺ Parkinson's ជំងឺទឹកនោមផ្អែម ភាពធាត់លើសទម្ងន់ សម្ពាធឈាមខ្ពស់ កូឡេស្តេរ៉ុលខ្ពស់ ជំងឺ ALS (ជំងឺ Lou Gehrig) HIV/AIDS ជំងឺសាច់ដុំខ្សោយ និងជំងឺប្រព័ន្ធភាពស៊ាំវាយប្រហារខ្លួនឯង ដូចជា ជំងឺរលាកសន្លាក់រ៉ាំរ៉ៃ ជំងឺ Lupus និងជំងឺពិការសរសៃប្រសាទច្រើនកន្លែង។

(e) ដោយសាររបកគំហើញក្នុងវិស័យភាពស៊ាំវិទ្យាអាចជួយបង្ការជំងឺ និងសង្គ្រោះជីវិតមនុស្សបាន ការគាំទ្រដល់ការស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រអំពីភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំ គឺជាអាទិភាពដ៏សំខាន់មួយក្នុងវិធីសាស្ត្ររួមរបស់រដ្ឋក្នុងការកែលម្អសុខភាពសាធារណៈ និងសង្គ្រោះព្រមទាំងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជន។

(f) ដើម្បីអភិវឌ្ឍបច្ចេកវិទ្យាដែលកំពុងរីកចម្រើនទាំងនេះឱ្យបានពេញលេញ និងទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាទាំងនេះ វាមានសារៈសំខាន់យ៉ាងខ្លាំងដែលត្រូវបង្កើតប្រភពមូលនិធិដែលមានស្ថិរភាព និងអាចទុកចិត្តបាន ដើម្បីឱ្យការស្រាវជ្រាវជាបន្តបន្ទាប់អាចដំណើរការដោយមិនមានការរំខានពីការខ្វះខាតមូលនិធិ ដែលបើមិនដូច្នោះទេ អាចគំរាមកំហែងដល់ការរំខានដល់វឌ្ឍនភាព និងបញ្ឈប់សន្ទុះនៃរបកគំហើញវិទ្យាសាស្ត្រ។

(g) ការផ្តល់មូលនិធិសាធារណៈសម្រាប់ការស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រតែងតែជាផ្នែកសំខាន់មួយនៃការរីកចម្រើនក្នុងវិស័យវេជ្ជសាស្ត្រទំនើប។ ក្នុងចំណោមថ្នាំថ្មីទាំងអស់ដែលត្រូវបានអនុម័តដោយ FDA ក្នុងអំឡុងឆ្នាំ 2010 ដល់ 2019 ភាគច្រើនបំផុតនៃថ្នាំទាំងនោះ—គឺ 99.4 ភាគរយ—គឺជាលទ្ធផលនៃការស្រាវជ្រាវដែលទទួលបានមូលនិធិសាធារណៈ។

(h) រដ្ឋ California តែងតែស្ថិតនៅជួរមុខនៃការអភិវឌ្ឍ និងរបកគំហើញផ្នែកបច្ចេកវិទ្យា។ ជាពិសេស រដ្ឋ California បានឈានមុខគេក្នុងវិស័យវិទ្យាសាស្ត្រសុខាភិបាលអស់រយៈពេលជាយូរមកហើយ ដោយសាររដ្ឋនេះមានវិទ្យាស្ថានស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រដែលមានភាពច្នៃប្រឌិត និងមានកិត្យានុភាពបំផុតជាច្រើននៅក្នុងពិភពលោក ព្រមទាំងមានប្រព័ន្ធឧត្តមសិក្សាឈានមុខគេរបស់ប្រទេស គឺសាកលវិទ្យាល័យ California ដែលមានសាលាវេជ្ជសាស្ត្រ និងមជ្ឈមណ្ឌលស្រាវជ្រាវវិទ្យាសាស្ត្រសុខាភិបាលលំដាប់ពិភពលោកជាច្រើន។

(i) រដ្ឋ California មានកាតព្វកិច្ចក្នុងការឈានមុខគេក្នុងការអភិវឌ្ឍការព្យាបាលដោយប្រព័ន្ធភាពស៊ាំ ដែលនឹងផ្តល់អត្ថប្រយោជន៍យ៉ាងធំធេងក្នុងការព្យាបាល និងការបង្ការជំងឺជាច្រើនដែលមានភាពរ៉ាំរ៉ៃ និងបណ្តាលឱ្យរាងកាយចុះខ្សោយ ឬពិការ ដែលរហូតមកដល់ពេលនេះបានបង្ហាញថាមិនឆ្លើយតបនឹងវិធីព្យាបាលបែបប្រពៃណីដែលធ្លាប់ប្រើកាលពីអតីតកាល។

37

38

(j) ក្រៅពីការជួយសង្គ្រោះជីវិតមនុស្ស ការផ្តល់មូលនិធិសម្រាប់ការអភិវឌ្ឍការព្យាបាលដោយប្រព័ន្ធភាពស៊ាំ ក៏នឹងជួយសន្សំសំចៃថ្លៃចំណាយលើការថែទាំសុខភាពរាប់ពាន់លានដុល្លារសម្រាប់រដ្ឋ និងគ្រួសារនៅរដ្ឋ California ដោយការបង្ការ និងព្យាបាលឱ្យជាសះស្បើយពីជំងឺ និងជំងឺដែលបណ្តាលឱ្យរាងកាយចុះខ្សោយជាច្រើនប្រភេទ។

(k) ភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំ នឹងជួយពង្រីកឧស្សាហកម្មជីវបច្ចេកវិទ្យារបស់រដ្ឋ California បង្កើតការងារដែលមានប្រាក់ឈ្នួលល្អ បង្កើនទិន្នផលសេដ្ឋកិច្ច និងជំរុញប្រភពចំណូលថ្មីៗ តាមរយៈ ការផ្តល់មូលនិធិតាមរយៈជំនួយ ការផ្តល់អាជ្ញាប័ណ្ណកម្មសិទ្ធិបញ្ញា និងការវិនិយោគពីវិស័យឯកជន។ បច្ចេកវិទ្យាជីវសាស្ត្រនៅរដ្ឋ California មានសក្តានុពលក្នុងការក្លាយជាវិស័យដែលមានសារៈសំខាន់ខាងសេដ្ឋកិច្ចនាពេលអនាគត ដូចទៅនឹងវិស័យបច្ចេកវិទ្យាព័ត៌មានដែលមានសារៈសំខាន់នាពេលបច្ចុប្បន្ន។

(l) ជារៀងរាល់ឆ្នាំ គ្រួសារជាច្រើនគ្រួសាររងទុក្ខ នៅពេលជំងឺធ្ងន់ធ្ងរ ដូចជាជំងឺមហារីក ជំងឺបេះដូង ជំងឺ Alzheimer's ជំងឺ Parkinson's និងជំងឺទឹកនោមផ្អែម បំផ្លាញជីវិត ឬបណ្តាលឱ្យមនុស្សជាទីស្រឡាញ់របស់ពួកគេស្លាប់។ យើងមានកាតព្វកិច្ចចំពោះខ្លួនយើងផ្ទាល់ ក្នុងការវិនិយោគលើការស្រាវជ្រាវអំពីការព្យាបាលដោយប្រព័ន្ធភាពស៊ាំដែលមានសក្តានុពលដែលអាចជួយបង្ការ និងព្យាបាលឱ្យជាសះស្បើយពីជំងឺដែលប៉ះពាល់ដល់គ្រួសារទាំងអស់។

(m) នេះគឺជាពេលវេលាដ៏សំខាន់មួយក្នុងប្រវត្តិសាស្ត្រនៃវិទ្យាសាស្ត្រវេជ្ជសាស្ត្រ ហើយរដ្ឋ California ត្រូវចាប់យកឱកាសនេះ ដើម្បីក្លាយជាអ្នកដឹកនាំរបស់ប្រទេសក្នុងវិស័យនវានុវត្តន៍ម្តងទៀត ដូចដែលរដ្ឋនេះធ្លាប់បានធ្វើជាញឹកញាប់នាពេលកន្លងមក។

មាត្រាទី 3. គោលបំណង និងចេតនា។

គោលបំណងរបស់ប្រជាជននៃរដ្ឋ California ក្នុងការអនុម័តច្បាប់នេះ គឺដើម្បីសម្រេចបាននូវគោលដៅទាំងអស់ដូចខាងក្រោម៖

(a) ផ្តល់មូលនិធិសម្រាប់វិទ្យាស្ថានស្រាវជ្រាវផ្នែកភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំ ដែលមានកម្រិតលំដាប់ពិភពលោក និងមានភាពច្នៃប្រឌិត ហើយមានទំនាក់ទំនងជាមួយសាកលវិទ្យាល័យ California ដើម្បីប្រើប្រាស់សមត្ថភាពរបស់ប្រព័ន្ធភាពស៊ាំរបស់មនុស្ស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទំនើបបំផុត ព្រមទាំងបច្ចេកវិទ្យាកុំព្យូទ័រកម្រិតខ្ពស់ ដើម្បីបង្កើតរបកគំហើញផ្នែកវិទ្យាសាស្ត្រ និងវិធីព្យាបាលជំនាន់ថ្មី សម្រាប់ការបង្ការ និងព្យាបាលឱ្យជាសះស្បើយពីជំងឺរ៉ាំរ៉ៃ ដោយអនុញ្ញាតឱ្យប្រជាជនរដ្ឋ California រស់នៅបានយូរជាងមុន និងមានសុខភាពល្អជាងមុន។

(b) ផ្តល់ជំនួយមូលនិធិតែដល់សាកលវិទ្យាល័យសាធារណៈ និងសាកលវិទ្យាល័យមិនរកប្រាក់ចំណេញ ព្រមទាំងស្ថាប័នស្រាវជ្រាវវេជ្ជសាស្ត្រមិនរកប្រាក់ចំណេញ ដែលមានមូលដ្ឋាននៅរដ្ឋ California សម្រាប់ការស្រាវជ្រាវផ្នែកភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំ ហើយពង្រីកលទ្ធភាពទទួលបានវិធីព្យាបាល និងការព្យាបាលឱ្យជាសះស្បើយដែលអាចជួយសង្គ្រោះជីវិត សម្រាប់ប្រជាជនរដ្ឋ California ទាំងអស់ ដោយធានាថាមិនមានមូលនិធិណាមួយត្រូវបានផ្តល់ដល់អង្គការដែលមានគោលបំណងរកប្រាក់ចំណេញ ឬក្រុមហ៊ុនឱសថឡើយ។

(c) ផ្តល់មូលនិធិសម្រាប់ការស្រាវជ្រាវ ការអប់រំ និងការអភិវឌ្ឍវិធីព្យាបាល និងការព្យាបាលសម្រាប់ស្ថានភាពជំងឺផ្សេងៗ ដោយប្រើវិធីសាស្ត្រផ្នែកលើភាពស៊ាំវិទ្យា នៅតាមសាកលវិទ្យាល័យសាធារណៈ និងសាកលវិទ្យាល័យមិនរកប្រាក់ចំណេញ ព្រមទាំងមជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្រមិនរកប្រាក់ចំណេញផ្សេងទៀត ដែលមានប្រវត្តិស្នាដៃជាក់ស្តែងក្នុងការធ្វើការស្រាវជ្រាវ និងការសាកល្បងព្យាបាលដែលទទួលបានជោគជ័យ ដើម្បីជួយលុបបំបាត់ជំងឺ និងជំងឺផ្សេងៗ ដូចជា ជំងឺមហារីក ជំងឺបេះដូង ជំងឺ Alzheimer's ជំងឺ Parkinson's ជំងឺទឹកនោមផ្អែម ភាពធាត់លើសទម្ងន់ សម្ពាធឈាមខ្ពស់ និងកូឡេស្តេរ៉ុលខ្ពស់ ក្នុងអំឡុងជីវិតរបស់យើង។

(d) បែងចែកថវិកាជាងបួនពាន់លានដុល្លារ ($4,000,000,000) ជាពិសេសសម្រាប់ការស្រាវជ្រាវពាក់ព័ន្ធនឹងការបង្ការ ការព្យាបាល និងការព្យាបាលឱ្យជាសះស្បើយពីជំងឺមហារីក ជំងឺបេះដូង និងជំងឺ Alzheimer's។

(e) ប្រមូលផ្តុំអ្នកវិទ្យាសាស្ត្រជីវវេជ្ជសាស្ត្រ អ្នកធ្វើគំរូជំងឺ អ្នកជំនាញបច្ចេកវិទ្យាហ្សែន អ្នកវិទ្យាសាស្ត្រទិន្នន័យ អ្នកជំនាញផ្នែកគណនាវិទ្យា អ្នកបង្កើតវិធីព្យាបាល និងអ្នកច្នៃប្រឌិតផ្នែកការសាកល្បងព្យាបាលមកពីជុំវិញពិភពលោក ដើម្បីអភិវឌ្ឍវាក់សាំងបង្ការដែលអាចការពារប្រឆាំងនឹងជំងឺទាំងនេះ និងដើម្បីបង្កើតវិធីព្យាបាល និងការព្យាបាលឱ្យជាសះស្បើយសម្រាប់ស្ថានភាពជំងឺវេជ្ជសាស្ត្រដែលរ៉ាំរ៉ៃ និងធ្ងន់ធ្ងរបំផុតមួយចំនួននៅលើពិភពលោក។

(f) ជ្រើសរើសវិទ្យាស្ថានស្រាវជ្រាវមិនរកប្រាក់ចំណេញមួយ ដើម្បីទទួលបានមូលនិធិ ដែលមានភាពឯករាជ្យ សហការគ្នា និងមានភាពច្នៃប្រឌិត ខណៈដែលនៅតែមានទំនាក់ទំនងជាមួយសាកលវិទ្យាល័យ California ដើម្បីធ្វើឱ្យការត្រួតពិនិត្យរបស់រដ្ឋមានភាពសាមញ្ញ និងមានប្រសិទ្ធភាពជាងមុន កាត់បន្ថយនីតិវិធីរដ្ឋបាល និងនីតិវិធីស្មុគស្មាញ និងធានាថាការស្រាវជ្រាវផ្តោតលើលទ្ធផលដែលអាចវាស់វែងបាន។

(g) ផ្តល់មូលនិធិសម្រាប់មជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្រមិនរកប្រាក់ចំណេញមួយ ដែលនៅទីបំផុតនឹងអាចទ្រទ្រង់ខ្លួនឯងបានផ្នែកហិរញ្ញវត្ថុ ដោយយកផលចំណេញខាងសេដ្ឋកិច្ចដែលទទួលបានពីការអភិវឌ្ឍវិធីព្យាបាលដែលទទួលបានជោគជ័យ ទៅវិនិយោគឡើងវិញក្នុងទិសដៅស្រាវជ្រាវថ្មីៗ ដោយហេតុនេះបង្កើតឱ្យមានមជ្ឈមណ្ឌលស្រាវជ្រាវដែលមានឯករាជ្យភាពផ្នែកហិរញ្ញវត្ថុ ហើយនៅទីបំផុតនឹងលែងត្រូវការមូលនិធិសាធារណៈទៀត។

(h) តម្រូវឱ្យ 10 ភាគរយនៃចំណូលទាំងអស់ដែលបានមកពីការព្យាបាលដោយប្រព័ន្ធភាពស៊ាំ ដែលត្រូវបានអភិវឌ្ឍជាលទ្ធផលនៃច្បាប់នេះ ត្រូវប្រគល់ជូនរដ្ឋ ដើម្បីទូទាត់បង្គ្រប់ថ្លៃចំណាយនៃច្បាប់នេះ ដោយធ្វើឱ្យកម្មវិធីនេះមានលក្ខណៈប្រកបដោយប្រសិទ្ធភាពដូចជាកម្មវិធីផ្តល់ប្រាក់កម្ចី ហើយធានាថា អ្នកបង់ពន្ធនឹងអាចទទួលបានមកវិញពេញលេញនូវការវិនិយោគរបស់ពួកគេក្នុងការស្រាវជ្រាវដ៏សំខាន់នេះ។

(i) តម្រូវឱ្យអ្នកទទួលមូលនិធិណាមួយ ដែលផ្តល់អាជ្ញាប័ណ្ណសម្រាប់បច្ចេកវិទ្យា ឬថ្នាំដែលត្រូវបានអភិវឌ្ឍដោយប្រើប្រាស់មូលនិធិពីច្បាប់នេះ ត្រូវធ្វើឱ្យបច្ចេកវិទ្យា ឬថ្នាំនោះមានសម្រាប់អ្នកជំងឺនៅរដ្ឋ California ក្នុងតម្លៃដែលទាបជាងតម្លៃមធ្យមទូទាំងប្រទេសយ៉ាងហោចណាស់ 20 ភាគរយ ដើម្បីធានាថា ប្រជាជនរដ្ឋ California ទទួលបានអត្ថប្រយោជន៍ដោយផ្ទាល់ពីការវិនិយោគសាធារណៈរបស់ពួកគេ។

(j) ធានាថា មូលនិធិសម្រាប់ការស្រាវជ្រាវទាំងអស់ដែលត្រូវបានបញ្ចេញក្រោមច្បាប់នេះ ត្រូវស្ថិតក្រោមតម្រូវការដ៏តឹងរឹងអំពីគណនេយ្យភាព និងតម្លាភាព រួមទាំងតម្រូវឱ្យ 98 ភាគរយនៃមូលនិធិទាំងអស់ ត្រូវចំណាយលើថ្លៃចំណាយពាក់ព័ន្ធនឹងការស្រាវជ្រាវវេជ្ជសាស្ត្រ និងការអភិវឌ្ឍការព្យាបាលឱ្យជាសះស្បើយ កំណត់ការចំណាយផ្នែករដ្ឋបាលរបស់រដ្ឋាភិបាលថ្នាក់រដ្ឋមិនឱ្យលើសពី 2 ភាគរយ ច្បាប់ដ៏តឹងរឹងស្តីពីទំនាស់ផលប្រយោជន៍ ការបង្ហាញជាសាធារណៈអំពីការចំណាយទាំងអស់ និងការធ្វើសវនកម្មហិរញ្ញវត្ថុដោយឯករាជ្យ។

(k) ការពារ និងផ្តល់អត្ថប្រយោជន៍ដល់ថវិការដ្ឋ ដោយផ្តល់មូលនិធិសម្រាប់ការស្រាវជ្រាវដែលនឹងជួយកាត់បន្ថយថ្លៃចំណាយលើការថែទាំសុខភាពយ៉ាងច្រើននាពេលអនាគត និងដោយផ្តល់ឱកាសឱ្យរដ្ឋទទួលបានអត្ថប្រយោជន៍ពីចំណូលដែលកើតចេញពីប៉ាតង់ និងថ្លៃអាជ្ញាប័ណ្ណ ដែលកើតឡើងពីរបកគំហើញក្នុងវិស័យភាពស៊ាំវិទ្យា។

(l) ផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ចរដ្ឋ California តាមរយៈការបង្កើតការងារដែលមានប្រាក់ឈ្នួលខ្ពស់ គម្រោងឧស្សាហកម្មជីវវេជ្ជសាស្ត្រ និងវិធីព្យាបាលដែលមានសក្តានុពល ដែលនឹងបង្កើតចំណូលពន្ធថ្មីៗសម្រាប់រដ្ឋរបស់យើង។

(m) លើកកម្ពស់ឧស្សាហកម្មជីវបច្ចេកវិទ្យា និងវិទ្យាសាស្ត្រជីវិតនៅរដ្ឋ California ឱ្យឈានដល់ភាពជាអ្នកដឹកនាំលំដាប់ពិភពលោកក្នុងវិស័យដែលកំពុងរីកចម្រើននៃការស្រាវជ្រាវ និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំ ដោយពង្រឹងតួនាទីរបស់រដ្ឋនេះជាមជ្ឈមណ្ឌលសកលសម្រាប់នវានុវត្តន៍ផ្នែកសុខភាព និងកំណើនសេដ្ឋកិច្ច។

មាត្រាទី 4. ភាគ 110.5 (ចាប់ផ្តើមជាមួយមាត្រាទី 130350) ត្រូវបានបន្ថែមទៅក្រមសុខភាព និងសុវត្ថិភាព ដើម្បីអាន៖

ភាគទី 110.5. គំនិតផ្តួចផ្តើមស្រាវជ្រាវ និងការព្យាបាលផ្នែកភាពស៊ាំវិទ្យា នៃរដ្ឋ CALIFORNIA

ជំពូក 1. ច្បាប់ស្តីពីការស្រាវជ្រាវវេជ្ជសាស្ត្រផ្នែកភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំនៃរដ្ឋ CALIFORNIA

130350. ជំពូកនេះនឹងត្រូវបានគេដឹង ហើយអាចត្រូវបានដកស្រង់ថាជា "ច្បាប់ស្តីពីការស្រាវជ្រាវវេជ្ជសាស្ត្រផ្នែកភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំនៃរដ្ឋ California" ។

130351. សម្រាប់គោលបំណងនៃជំពូកនេះ ពាក្យខាងក្រោមសំដៅដូចខាងក្រោម៖

(a) "គណៈកម្មាធិការ" មានន័យថា គណៈកម្មាធិការត្រួតពិនិត្យគណនេយ្យភាពហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋ ដែលត្រូវបានបង្កើតឡើងអនុលោមតាមមាត្រាទី 130362 ។

(b) "ក្រុមប្រឹក្សា" មានន័យថា ក្រុមប្រឹក្សាស្រាវជ្រាវផ្នែកប្រឹក្សាយោបល់និងគណនេយ្យភាព ដែលត្រូវបានបង្កើតឡើងអនុលោមតាមមាត្រាទី 130355 ។

(c) "ក្រសួង" មានន័យថាជា ក្រសួងសុខាភិបាលសាធារណៈនៃរដ្ឋ ឬភ្នាក់ងារបន្តវេនពីក្រសួងនេះ។

(d) "មូលនិធិ" មានន័យថា មូលនិធិស្រាវជ្រាវវេជ្ជសាស្ត្រផ្នែកភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំនៃរដ្ឋ California ដែលត្រូវបានបង្កើតឡើងអនុលោមតាមមាត្រាទី 130377 ។

(e) "វិទ្យាស្ថាន" មានន័យថា វិទ្យាស្ថានស្រាវជ្រាវវេជ្ជសាស្ត្រមិនរកប្រាក់ចំណេញ ដែលត្រូវបានជ្រើសរើសដោយក្រសួង អនុលោមតាមមាត្រាទី 130353 ។

(f) "សិទ្ធិកម្មសិទ្ធិបញ្ញា" មានន័យថា សិទ្ធិស្របច្បាប់ដែលមានលក្ខណៈជាកម្មសិទ្ធិទាំងអស់ ពាក់ព័ន្ធនឹងចំណេះដឹងជំនាញ ឬការបង្កើតថ្មី រួមមានអាថ៌កំបាំងពាណិជ្ជកម្ម សិទ្ធិអ្នកនិពន្ធ ពាណិជ្ជសញ្ញា ស្នាដៃម៉ាស់ សូហ្វវែរ និងប៉ាតង់ទាំងអស់ ព្រមទាំងពាក្យស្នើសុំសម្រាប់សិទ្ធិទាំងនោះនៅទូទាំងពិភពលោក រួមទាំងវិញ្ញាបនបត្រអ្នកបង្កើត និងទម្រង់សិទ្ធិណាមួយដែលអាចឱ្យភាគីមួយរារាំងភាគីមួយទៀតយ៉ាងមានប្រសិទ្ធភាព មិនឱ្យអនុវត្តសកម្មភាពណាមួយដែលបានបញ្ជាក់នៅក្នុងនិយមន័យនេះ រួមទាំងសិទ្ធិតាមកិច្ចសន្យាផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីសិទ្ធិកម្មសិទ្ធិបញ្ញាដែលវិទ្យាស្ថាន សាកលវិទ្យាល័យសាធារណៈ ឬសាកលវិទ្យាល័យមិនរកប្រាក់ចំណេញ ឬស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញ ដែលបានទទួលមូលនិធិតាមផ្នែករង (b) នៃមាត្រា 130352 មានឋានៈជាអ្នកទទួលអាជ្ញាប័ណ្ណ ឬជាអ្នកប្រើប្រាស់ដែលបានការអនុញ្ញាតតាមមធ្យោបាយផ្សេងទៀត សិទ្ធិទាំងនោះនឹងមានលក្ខណៈស្របតាមនិយមន័យនេះលុះត្រាតែវិទ្យាស្ថាន សាកលវិទ្យាល័យសាធារណៈ ឬសាកលវិទ្យាល័យមិនរកប្រាក់ចំណេញ ឬស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញនោះ មានសិទ្ធិផ្តល់អាជ្ញាប័ណ្ណបន្ត ឬសិទ្ធិផ្សេងទៀតដែលមានលក្ខណៈសមមូល។

(g) "ការបង្កើតថ្មី" មានន័យថា ឧបករណ៍ វិធីសាស្ត្រ ដំណើរការ ម៉ាស៊ីន ផលិតផលដែលផលិតឡើង ការរចនា ឬសមាសធាតុនៃសារធាតុណាមួយដែលថ្មី និងមានប្រយោជន៍ ឬការកែលម្អថ្មី និងមានប្រយោជន៍ណាមួយ ឬពូជរុក្ខជាតិណាមួយ ដែលអាចទទួលបានប៉ាតង់ ឬអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលបានប៉ាតង់ តាមច្បាប់ និងបទបញ្ញត្តិស្តីពីប៉ាតង់របស់សហរដ្ឋអាមេរិក។

(h) "ចំណេះដឹងជំនាញ" មានន័យថា គំនិតបង្កើត ការយល់ឃើញ គំនិតថ្មីៗ នវានុវត្តន៍ របកគំហើញ ការបង្កើតថ្មី ចំណេះដឹង ដំណើរការ ម៉ាស៊ីន ផលិតផលដែលផលិតឡើង រូបមន្តគីមី គំរូផលិតផល ការធ្វើតេស្តវិភាគ សមាសធាតុនៃសារធាតុ ការកែលម្អ ការពង្រឹង ការកែប្រែ ការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា បច្ចេកវិទ្យា វិធីសាស្ត្រ ការអនុវត្ត បច្ចេកទេស ប្រព័ន្ធ ការរចនា ស្នាដៃសិល្បៈ គំនូរ ផែនការ លក្ខណៈបច្ចេកទេស ការកំណត់លំដាប់ហ្សែន ឱសថ រូបមន្តឱសថ ស្នាដៃម៉ាស់ សូហ្វវែរ ឯកសារ ទិន្នន័យ និងព័ត៌មាន ដោយមិនគិតថា វាស្ថិតក្នុងទម្រង់ដែលមនុស្ស ឬម៉ាស៊ីនអាចអានបាន ឬមិនអាចអានបាននោះទេ ស្នាដៃដែលបង្កើតដោយអ្នកនិពន្ធ ផលិតផល អាថ៌កំបាំងពាណិជ្ជកម្ម ជំនាញ បទពិសោធន៍ ការលើកទឹកចិត្តដែលផ្អែកលើបទពិសោធន៍ និងតម្រូវការ ឯកសារ ឧបករណ៍ យុទ្ធសាស្ត្រផ្នែកការសាកល្បងព្យាបាល និងបទប្បញ្ញត្តិ ទិន្នន័យពីការធ្វើតេស្ត រួមទាំងទិន្នន័យពីការធ្វើតេស្តផ្នែកឱសថវិទ្យា ពុលវិទ្យា និងការសាកល្បងព្យាបាល ទិន្នន័យវិភាគ និងទិន្នន័យត្រួតពិនិត្យគុណភាព ព្រមទាំងទិន្នន័យ ឬការពិពណ៌នាអំពីប៉ាតង់ ដោយមិនគិតថា ធាតុណាមួយក្នុងចំណោមធាតុខាងលើអាចទទួលបានប៉ាតង់ អាចទទួលបានការការពារតាមសិទ្ធិអ្នកនិពន្ធ ឬអាចទទួលបានការការពារតាមទម្រង់ច្បាប់ផ្សេងទៀតឬអត់នោះទេ ហើយដោយមានលក្ខខណ្ឌថា ធាតុខាងលើត្រូវបំពេញតាមលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

(1) ធាតុទាំងនេះត្រូវបានគិតបង្កើតឡើង ផលិតឡើង យកមកអនុវត្តជាក់ស្តែង ឬមានស្រាប់ក្នុងទម្រង់ផ្សេងទៀត មុនពេលកិច្ចព្រមព្រៀងផ្តល់ជំនួយឥតសំណងដែលបានចុះក្រោមមាត្រាទី 130353 ឬ 130357 ផុតកំណត់ ឬត្រូវបានបញ្ចប់។

(2) ធាតុទាំងនោះត្រូវបានផ្ទេរ ឬប្រគល់ទៅឱ្យវិទ្យាស្ថាន សាកលវិទ្យាល័យសាធារណៈ ឬសាកលវិទ្យាល័យមិនរកប្រាក់ចំណេញ ឬស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញ ដោយអ្នកបង្កើត ដែលអាចធ្វើឡើងដោយអ្នកបង្កើតតែម្នាក់ឯង ឬរួមជាមួយអ្នកដទៃ។

(3) ធាតុទាំងនោះមានទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោល ទៅនឹងខ្លឹមសារ ឬកម្មវត្ថុនៃកិច្ចព្រមព្រៀងផ្តល់មូលនិធិ ដែលផ្តល់ជំនួយឥតសំណងពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនោះ។

(i) "ប៉ាតង់" មានន័យថា ពាក្យស្នើសុំប៉ាតង់ណាមួយរបស់សហរដ្ឋអាមេរិក ឬបរទេស ឬឯកសារប៉ាតង់ដែលពាក់ព័ន្ធណាមួយ រួមមាន ពាក្យស្នើសុំប៉ាតង់បណ្តោះអាសន្ន ពាក្យស្នើសុំបែងចែក ពាក្យស្នើសុំបន្ត ពាក្យស្នើសុំបន្តមួយផ្នែក ពាក្យស្នើសុំជំនួស ការបន្តសុពលភាព ការចេញប៉ាតង់ឡើងវិញ ការពន្យារសុពលភាព ការបញ្ជាក់ឡើងវិញ ការពិនិត្យប៉ាតង់ឡើងវិញ ឬការចុះបញ្ជីប៉ាតង់នោះ ព្រមទាំងប៉ាតង់ណាមួយដែលត្រូវបានចេញពីពាក្យស្នើសុំ ឬឯកសារណាមួយក្នុងចំណោមឯកសារទាំងនោះ រួមមាន ការជំនួស ការបន្តសុពលភាព ការចេញប៉ាតង់ឡើងវិញ ការពន្យារសុពលភាព ការបញ្ជាក់ឡើងវិញ ការពិនិត្យប៉ាតង់ឡើងវិញ ឬការចុះបញ្ជីប៉ាតង់នោះផងដែរ។

(j) "សូហ្វវែរ" មានន័យថា កូដណាមួយដែលអាចអានបានដោយម៉ាស៊ីន ឬអាចប្រតិបត្តិបានដោយម៉ាស៊ីន ដែលត្រូវបានរក្សាទុកនៅលើមធ្យោបាយផ្ទុកទិន្នន័យដែលមានរូបវន្តជាក់ស្តែងណាមួយ។

130352. (a) ប្រាក់ចំណូលដែលទទួលបានពីមូលបត្របំណុលដែលបានចេញ និងលក់អនុលោមតាមជំពូកទី 2 (ចាប់ផ្តើមពីមាត្រាទី 130370) ដោយមិនរាប់បញ្ចូលមូលបត្របំណុលសម្រាប់សងបំណុលចាស់ដែលបានចេញាអនុលោមតាមមាត្រាទី 130383 ត្រូវដាក់បញ្ចូលទៅក្នុងមូលនិធិស្រាវជ្រាវវេជ្ជសាស្ត្រផ្នែកភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំនៃរដ្ឋ California ដែលត្រូវបានបង្កើតឡើងអនុលោមតាមមាត្រាទី 130377 ។

(b) ថវិកាដែលមាននៅក្នុងមូលនិធិ បន្ទាប់ពីការទូទាត់ចំនួនទឹកប្រាក់ផ្សេងទៀតដែលត្រូវបានអនុញ្ញាតក្រោមច្បាប់នេះ និងក្រោមច្បាប់ស្តីពីមូលបត្របំណុលទូទៅរបស់រដ្ឋ (ជំពូក 4 (ចាប់ផ្តើមពីមាត្រាទី 16720) នៃផ្នែកទី 3 នៃភាគទី 4 នៃចំណងជើង 2 នៃក្រមរដ្ឋាភិបាល) ត្រូវបែងចែកទៅឱ្យក្រសួង ដើម្បីបញ្ចេញ ឬចែកចាយថវិកាដូចខាងក្រោម៖

(1) ហាសិបភាគរយនៃថវិកាត្រូវបញ្ចេញទៅឱ្យវិទ្យាស្ថានស្រាវជ្រាវវេជ្ជសាស្ត្រមិនរកប្រាក់ចំណេញតែមួយ ដើម្បីធ្វើ ឬដឹកនាំការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រសុខភាព ក្នុងវិស័យភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំ។

(2) ហាសិបភាគរយនៃថវិកាត្រូវបញ្ចេញទៅឱ្យសាកលវិទ្យាល័យសាធារណៈ និងសាកលវិទ្យាល័យមិនរកប្រាក់ចំណេញ ព្រមទាំងស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញផ្សេងទៀត ដែលមានតំណាងនៅក្នុងក្រុមប្រឹក្សា ដើម្បីធ្វើការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រសុខភាព ក្នុងវិស័យភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំ។ ថវិកាដែលត្រូវបានបញ្ចេញក្រោមកថាខណ្ឌនេះ ត្រូវផ្តល់ជាជំនួយមូលនិធិដាច់ដោយឡែកសម្រាប់គម្រោងស្រាវជ្រាវជាក់លាក់ តាមរយៈដំណើរការដាក់ពាក្យស្នើសុំ ដោយពាក្យស្នើសុំត្រូវបានពិនិត្យអនុលោមតាមមាត្រាទី 130356 ហើយមិនត្រូវមានលក្ខណៈជាជំនួយមូលនិធិជាកញ្ចប់ដែលផ្តល់ក្នុងចំនួនស្មើៗគ្នានោះទេ។

130353. (a) ក្រសួងត្រូវបញ្ចេញមូលនិធិអនុលោមតាមកថាខណ្ឌ (1) នៃផ្នែករង (b) នៃមាត្រាទី 130352 ដោយអនុលោមតាមកិច្ចព្រមព្រៀងផ្តល់មូលនិធិដែលបានចុះរវាងក្រសួង និងវិទ្យាស្ថានស្រាវជ្រាវវេជ្ជសាស្ត្រមិនរកប្រាក់ចំណេញតែមួយ ដែលត្រូវបានជ្រើសរើសដោយក្រសួង ហើយដែលបំពេញតាមលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

(1) វិទ្យាស្ថាននេះ គឺជាវិទ្យាស្ថានស្រាវជ្រាវវេជ្ជសាស្ត្រដែលត្រូវបានលើកលែងពន្ធលើប្រាក់ចំណូលសហព័ន្ធ អនុលោមតាមមាត្រាទី 501(c)(3) នៃក្រមចំណូលផ្ទៃក្នុង ដែលមានស្ថាប័ននេះមានស្រាប់នៅត្រឹមថ្ងៃទី 1 ខែមករា ឆ្នាំ 2025 ហើយត្រូវបានបង្កើតឡើងក្នុងគោលបំណងចម្បង និងមានជំនាញជាក់លាក់ក្នុងការធ្វើការស្រាវជ្រាវក្នុងវិស័យភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំ។

(2) វិទ្យាស្ថាននេះមានកិច្ចព្រមព្រៀងសហព័ន្ធភាពមួយ ដែលបានចុះមិនឱ្យយឺតជាងថ្ងៃទី 1 ខែមករា ឆ្នាំ 2025 ហើយកិច្ចព្រមព្រៀងនេះបង្កើតទំនាក់ទំនងសហព័ន្ធភាពជាមួយបរិវេណសាខាមួយនៃសាកលវិទ្យាល័យ California ដែលបំពេញតាមលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

(A) បរិវេណសាកលវិទ្យាល័យនេះមានកម្មវិធីបណ្តុះបណ្តាលថ្នាក់ក្រោយឧត្តមសិក្សា ក្នុងវិស័យភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំ។

(B) បរិវេណសាកលវិទ្យាល័យនេះមានប្រព័ន្ធថែទាំសុខភាពសាធារណៈមួយ ដែលរួមមានមន្ទីរពេទ្យមួយ ឬច្រើន ហើយប្រព័ន្ធនេះធ្វើការសាកល្បងព្យាបាលដោយខ្លួនឯងលើថ្នាំ និងវិធីព្យាបាលថ្មីៗដែលកំពុងស្ថិតក្នុងដំណាក់កាលពិសោធន៍។

(C) ប្រព័ន្ធថែទាំសុខភាពរបស់បរិវេណសាកលវិទ្យាល័យនេះ មានចំនួនអ្នកជំងឺចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យលើសពី 35,000 នាក់ និងចំនួនអ្នកជំងឺមកទទួលសេវាសម្រាកព្យាបាលក្រៅមន្ទីរពេទ្យលើសពី 3,500,000 ដងក្នុងមួយឆ្នាំ។

(3) វិទ្យាស្ថាននេះត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលមួយ ដែលតាមបទបញ្ញត្តិផ្ទៃក្នុងរបស់វិទ្យាស្ថាន ដែលត្រូវបានអនុម័តមិនឱ្យយឺតជាងថ្ងៃទី 1 ខែមករា ឆ្នាំ 2025 និងតាមកិច្ចព្រមព្រៀងសម្ព័ន្ធភាពដែលបានពិពណ៌នានៅក្នុងចំណុច (2) ត្រូវមានសមាជិកជាច្រើនដែលជាតំណាងថ្នាក់ជាន់ខ្ពស់របស់បរិវេណសាកលវិទ្យាល័យ California ដែលជាភាគីមួយនៃកិច្ចព្រមព្រៀងសម្ព័ន្ធភាព ឬជាតំណាងថ្នាក់ជាន់ខ្ពស់របស់ប្រព័ន្ធថែទាំសុខភាពសាធារណៈរបស់បរិវេណសាកលវិទ្យាល័យនោះ។

(4) គិតត្រឹមថ្ងៃទី 1 ខែមករា ឆ្នាំ 2026 វិទ្យាស្ថាននេះត្រូវមានកម្មសិទ្ធិលើទីតាំងមួយ ឬជួលទីតាំងមួយដែលមានទំហំមិនតិចជាង 200,000 ហ្វីតការ៉េ ហើយទីតាំងនោះមានគោលបំណងសម្រាប់ប្រើប្រាស់ជាមជ្ឈមណ្ឌលស្រាវជ្រាវ ដែលជាទីតាំងសម្រាប់សកម្មភាពស្រាវជ្រាវរបស់វិទ្យាស្ថាន។

(5) វិទ្យាស្ថាននេះយល់ព្រមធ្វើការស្រាវជ្រាវវេជ្ជសាស្ត្ររួមគ្នាក្នុងវិស័យភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំ ជាមួយមជ្ឈមណ្ឌលស្រាវជ្រាវវេជ្ជសាស្ត្រមិនរកប្រាក់ចំណេញផ្សេងទៀតនៅរដ្ឋ California ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ រួមទាំងការធ្វើការសាកល្បងព្យាបាលរួមគ្នាដោយស្ថាប័នជាច្រើន។

(6) វិទ្យាស្ថាននេះបានកំណត់ប្រភពមូលនិធិដែលមានចំនួនមិនតិចជាងពីររយហាសិបលានដុល្លារ ($250,000,000) នៅក្នុងកិច្ចព្រមព្រៀងសម្ព័ន្ធភាពដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ (2) ដោយមូលនិធិនោះស្ថិតក្នុងទម្រង់ជាការបរិច្ចាគសប្បុរសធម៌ ឬការប្តេជ្ញាចិត្តក្នុងការរៃអង្គាសមូលនិធិ។

(7) វិទ្យាស្ថាននេះបានទទួលការប្តេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុដែលមានចំនួនមិនតិចជាង ហាសិបលានដុល្លារ ($50,000,000) ដើម្បីគាំទ្រកម្មវិធីអភិវឌ្ឍរ៉ាក់សាំងយ៉ាងឆាប់រហ័ស និងមិនតិចជាង ហាសិបលានដុល្លារ ($50,000,000) ដើម្បីគាំទ្រកម្មវិធីស្រាវជ្រាវអំពីមីក្លេសរីរាង្គ។

(b) (1) លើកលែងតែមានចែងផ្សេងនៅក្នុងកថាខណ្ឌ (2) ក្រសួងត្រូវជ្រើសរើសវិទ្យាស្ថាន និងចុះកិច្ចព្រមព្រៀងផ្តល់មូលនិធិជាមួយវិទ្យាស្ថាននេះអនុលោមតាមផ្នែករង (a) ក្នុងរយៈពេល 90 ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលជំពូកនេះចូលជាធរមាន។

(2) (A) ក្នុងករណីដែលក្រសួងមិនអាចកំណត់អត្តសញ្ញាណវិទ្យាស្ថានស្រាវជ្រាវវេជ្ជសាស្ត្រមិនរកប្រាក់ចំណេញមួយ ដែលទាំងបំពេញតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងផ្នែករង (a) និងមានឆន្ទៈចុះកិច្ចព្រមព្រៀងផ្តល់មូលនិធិអនុលោមតាមមាត្រានេះ ក្រសួងត្រូវកែប្រែលក្ខខណ្ឌដែលបានកំណត់នៅក្នុងផ្នែករង (a) ដើម្បីអនុញ្ញាតឱ្យកំណត់អត្តសញ្ញាណវិទ្យាស្ថានស្រាវជ្រាវវេជ្ជសាស្ត្រមិនរកប្រាក់ចំណេញមួយ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលមូលនិធិក្រោមជំពូកនេះ និងមានឆន្ទៈចុះកិច្ចព្រមព្រៀងផ្តល់មូលនិធិអនុលោមតាមមាត្រានេះ។

(B) ការកែប្រែលក្ខខណ្ឌណាមួយដោយក្រសួង អនុលោមតាមកថាខណ្ឌរង (A) ត្រូវជាការកែប្រែតិចតួចបំផុតដែលចាំបាច់ ដើម្បីកំណត់អត្តសញ្ញាណវិទ្យាស្ថានស្រាវជ្រាវវេជ្ជសាស្ត្រមិនរកប្រាក់ចំណេញដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយត្រូវជួយជំរុញឱ្យសម្រេចបាននូវគោលបំណងនៃជំពូកនេះ។

(C) ក្នុងករណីដែលក្រសួងកែប្រែលក្ខខណ្ឌដែលបានកំណត់នៅក្នុងផ្នែករង (a) អនុលោមតាមកថាខណ្ឌនេះ នាយកដ្ឋានត្រូវជ្រើសរើសវិទ្យាស្ថាន និងចុះកិច្ចព្រមព្រៀងផ្តល់មូលនិធិជាមួយវិទ្យាស្ថាននេះ ក្នុងរយៈពេល 90 ថ្ងៃគិតចាប់ពីកាលបរិច្ឆេទដែលលក្ខខណ្ឌដែលបានកែប្រែត្រូវបានអនុម័តដោយក្រសួង។

(c) (1) ក្រសួងត្រូវពិនិត្យឡើងវិញនូវកិច្ចព្រមព្រៀងដែលបានចុះអនុលោមតាមផ្នែករង (b) រៀងរាល់ប្រាំឆ្នាំម្តង ដើម្បីធានាថា វិទ្យាស្ថានគោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង និងបទបញ្ញត្តិនៃជំពូកនេះ។

(2) ការខកខានរបស់វិទ្យាស្ថានក្នុងការអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ឬបទប្បញ្ញត្តិនៃជំពូកនេះជាសារវន្ត អាចជាមូលហេតុសម្រាប់បញ្ចប់កិច្ចព្រមព្រៀង ប្រសិនបើក្នុងអំឡុងពេលពិនិត្យឡើងវិញរយៈពេលប្រាំឆ្នាំដែលធ្វើឡើងតាមចំណុច (1) ក្រសួងកំណត់ថា ការខកខាននោះបានរារាំង ឬធ្វើឱ្យប៉ះពាល់យ៉ាងសំខាន់ និងជាសារវន្តដល់ការសម្រេចបាននូវគោលបំណងនៃជំពូកនេះ ដោយមានលក្ខខណ្ឌថា វិទ្យាស្ថានត្រូវទទួលបានការជូនដំណឹងអំពីការកំណត់ណាមួយដែលធ្វើឡើងដោយក្រសួងអនុលោមតាមកថាខណ្ឌនេះ និងត្រូវបានផ្តល់ឱកាសសមស្របមួយដើម្បីកែតម្រូវការមិនអនុលោមតាមដែលបានកំណត់ឃើញ។

(d) កិច្ចព្រមព្រៀងផ្តល់មូលនិធិដែលបានចុះអនុលោមតាមមាត្រានេះ ត្រូវតម្រូវឱ្យការស្រាវជ្រាវ និងការអភិវឌ្ឍទាំងអស់ដែលទទួលមូលនិធិក្រោមកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តដោយអនុលោមតាមស្តង់ដាដែលបានបង្កើតឡើង ស្តីពីការផ្លាស់ប្តូរព័ត៌មានវិទ្យាសាស្ត្រដោយបើកចំហ ការពិនិត្យដោយអ្នកជំនាញសហការី និងការត្រួតពិនិត្យជាសាធារណៈ។

(e) (1) បន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃជំពូកនេះ ថវិកាចំនួនមួយរយលានដុល្លារ ($100,000,000) ត្រូវបានបែងចែកជូនពីមូលនិធិទូទៅ ជាប្រភពសម្រាប់ប្រាក់កម្ចីចាប់ផ្តើមមួយ ឬច្រើនកម្ចីដល់វិទ្យាស្ថានដើម្បីចំណាយលើការអនុវត្ត និងការគាំទ្រដំបូងចំពោះកម្មវិធីស្រាវជ្រាវរបស់វិទ្យាស្ថាន ដូចដែលបានពិពណ៌នានៅក្នុងជំពូកនេះ។ ក្រសួងត្រូវកំណត់ពេលវេលា និងចំនួនទឹកប្រាក់នៃប្រាក់កម្ចីទាំងនោះដែលផ្តល់ដល់វិទ្យាស្ថាន ដោយចំនួនសរុបរួមគ្នាមិនត្រូវលើសពីចំនួនថវិកាដែលបានបែងចែកខាងលើឡើយ។

(2) ប្រាក់កម្ចីណាមួយដែលផ្តល់ដល់វិទ្យាស្ថានអនុលោមតាមចំណុច (1) ត្រូវសងត្រឡប់ទៅមូលនិធិទូទៅវិញក្នុងរយៈពេល 12 ខែ ឬ ប្រសិនបើមិនអាចសងបានក្នុងរយៈពេល 12 ខែទេ ត្រូវសងឱ្យបានឆាប់បំផុតតាមដែលអាចអនុវត្តបានបន្ទាប់ពីរយៈពេលនោះ ដូចដែលបានកំណត់ដោយហិរញ្ញិកបន្ទាប់ពីការដកប្រាក់កម្ចីដែលពាក់ព័ន្ធពីប្រាក់ចំណូលដែលបានមកពីមូលបត្របំណុលដែលបានលក់អនុលោមតាមជំពូក 2 (ចាប់ផ្តើមពីមាត្រាទី 130370)។

130354. (a) ថវិកាដែលត្រូវបានបញ្ចេញអនុលោមតាមមាត្រាទី 130352 ត្រូវចំណាយតាមរបៀបដូចខាងក្រោម៖

(1) (A) វិទ្យាស្ថានត្រូវចំណាយមូលនិធិដែលបានបញ្ចេញឱ្យវិទ្យាស្ថាននេះអនុលោមតាមកថាខណ្ឌ (1) នៃផ្នែករង (b) នៃមាត្រាទី 130352 ដើម្បីធ្វើការស្រាវជ្រាវផ្នែកភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំ ដែល

អាចជាការស្រាវជ្រាវដែល ធ្វើឡើង នៅក្នុងវិទ្យាស្ថានដោយអ្នកស្រាវជ្រាវ និងបុគ្គលិកដែលត្រូវបានជួល ឬរក្សាទុកដោយផ្ទាល់ដោយវិទ្យាស្ថាន ឬជាការស្រាវជ្រាវដែល ត្រូវបានដឹកនាំ ដោយ វិទ្យាស្ថាន តាមមធ្យោបាយផ្សេងទៀត។

(B) មូលនិធិដែលបានបញ្ចេញតាមកថាខណ្ឌ (1) នៃផ្នែករង (b) នៃមាត្រា 130352 ចំនួនមិនតិចជាងពីរពាន់មួយរយលានដុល្លារ ($2,100,000,000) ត្រូវចំណាយដើម្បីធ្វើការស្រាវជ្រាវផ្នែកភាពសុាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពសុាំ ដែលពាក់ព័ន្ធនឹងការបង្ការ ការព្យាបាល និងការព្យាបាលឱ្យជាសះស្បើយពីជំងឺមហារីក ជំងឺបេះដូង និងជំងឺ Alzheimer's។

(2) (A) មូលនិធិដែលបានបញ្ចេញអនុលោមតាមកថាខណ្ឌ (2) នៃផ្នែករង (b) នៃមាត្រាទី 130352 ត្រូវចំណាយដើម្បីធ្វើការស្រាវជ្រាវផ្នែកភាពសុាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពសុាំ ដោយសាកលវិទ្យាល័យសាធារណៈ និងសាកលវិទ្យាល័យមិនរកប្រាក់ចំណេញ ព្រមទាំងស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញផ្សេងទៀត ដែលមានតំណាងនៅក្នុងក្រុមប្រឹក្សា។ គម្រោងស្រាវជ្រាវដែលទទួលមូលនិធិក្រោមកថាខណ្ឌនេះ នឹងត្រូវបានជ្រើសរើសតាមដែលបានចែងក្នុងមាត្រាទី 130356។

(B) មូលនិធិដែលបានបញ្ចេញតាមកថាខណ្ឌ (2) នៃផ្នែករង (b) នៃមាត្រា 130352 ចំនួនមិនតិចជាង ពីរពាន់មួយរយលានដុល្លារ ($2,100,000,000) ត្រូវចំណាយដើម្បីធ្វើការស្រាវជ្រាវផ្នែកភាពសុាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពសុាំ ដែលពាក់ព័ន្ធនឹងការបង្ការ ការព្យាបាល និងការព្យាបាលឱ្យជាសះស្បើយពីជំងឺមហារីក ជំងឺបេះដូង និងជំងឺ Alzheimer's។

(3) ចំនួនទឹកប្រាក់ដែលស្មើនឹងថ្លៃចំណាយជាក់ស្តែង ដោយមិនរាប់បញ្ចូលថ្លៃចំណាយណាមួយដែលត្រូវបានអនុញ្ញាតក្រោមច្បាប់ស្តីពីមូលប័ត្របំណុលទូទៅរបស់រដ្ឋ (ជំពូក 4 (ចាប់ផ្តើមពីមាត្រាទី 16720) នៃផ្នែកទី 3 នៃភាគទី 4 នៃចំណងជើង 2 នៃក្រមរដ្ឋាភិបាល) និងមិនត្រូវលើសពី 2 ភាគរយនៃថវិកាទាំងអស់ដែលបានបញ្ចេញអនុលោមតាមមាត្រាទី 130352 អាចត្រូវបានចំណាយសម្រាប់ថ្លៃចំណាយផ្នែករដ្ឋបាលរបស់ក្រសួង ក្រុមប្រឹក្សាគណៈកម្មាធិការ និងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋ ក្នុងការអនុវត្តការទទួលខុសត្រូវរៀងៗខ្លួនរបស់ពួកគេក្រោមជំពូកនេះ។

(b) សកម្មភាពស្រាវជ្រាវដែលអាចទទួលមូលនិធិក្រោមជំពូកនេះ ត្រូវរួមមាន ប៉ុន្តែមិនកំណត់ត្រឹមតែសកម្មភាពទាំងអស់ដូចខាងក្រោម៖

(1) ធ្វើការស្រាវជ្រាវមូលដ្ឋាន ដើម្បីសិក្សាស៊ើបអង្កេតអំពីយន្តការ នៃការវិវត្តកើតឡើងនៃជំងឺ និងមធ្យោបាយដែលអាចធ្វើអន្តរាគមន៍ទៅលើការវិវត្តនៃជំងឺ រួមមានជាអាទិ៍ ការស្រាវជ្រាវដើម្បីបង្ការជំងឺមហារីក ជំងឺ Alzheimer's ជំងឺ Parkinson's ជំងឺសរសៃឈាមបេះដូង និងជំងឺទឹកនោមផ្អែម។

(2) អភិវឌ្ឍ និងកែលម្អឧបករណ៍ធ្វើរោគវិនិច្ឆ័យ រួមទាំងជីវសញ្ញាក្នុងឈាម និងការថតរូបភាពវេជ្ជសាស្ត្រ ដើម្បីអាចរកឃើញជំងឺបានកាន់តែឆាប់។

(3) ប្រមូល សិក្សា និងបង្កើតធនាគារសំណាកជាលិកា និងគំរូជុំសាច់ពីក្រុមប្រជាជនអ្នកជំងឺដែលតំណាងឱ្យប្រជាជនអ្នកជំងឺផ្សេងៗ ដើម្បីយល់ដឹងកាន់តែច្បាស់អំពីការកកើតជំងឺ និងធ្វើតេស្តវិធីធ្វើអន្តរាគមន៍នៅដំណាក់កាលផ្សេងៗនៃការវិវត្តនៃជំងឺ។

(4) សិក្សាស៊ើបអង្កេតអំពីកត្តាហ្សែន ការប៉ះពាល់នឹងបរិស្ថាន និងកត្តារបៀបរស់នៅ ដើម្បីយល់ដឹងកាន់តែច្បាស់អំពីការរួមចំណែករបស់កត្តាទាំងនេះក្នុងការវិវត្តកើតឡើងនៃជំងឺ។

(5) ចាត់ថ្នាក់ជំងឺមហារីក និងជំងឺផ្សេងទៀតជាប្រភេទរង និងបង្កើតមូលដ្ឋានទិន្នន័យប្រមូលផ្តុំប្រភេទរងនៃជំងឺ ដើម្បីអភិវឌ្ឍ វិធីព្យាបាលដែលមានប្រសិទ្ធភាពបំផុតសម្រាប់អ្នកជំងឺម្នាក់ៗ។

(6) ធ្វើតេស្តថ្នាំ និងវិធីព្យាបាលប្រឆាំងនឹងកោសិកា ដុំសាច់ និងអ័រហ្គាណូអ៊ីដ ព្រមទាំងវាយតម្លៃវិធីព្យាបាលជាច្រើនប្រភេទ ប្រឆាំងនឹងបណ្តុំកោសិកាដែលបានបង្កើតសម្រាប់ការស្រាវជ្រាវ ដើម្បីកំណត់អត្តសញ្ញាណវិធីព្យាបាលដែលមានសក្តានុពលល្អបំផុតសម្រាប់ស្ថានភាពជំងឺនីមួយៗដែលកំពុងសិក្សា។

(7) ប្រើប្រាស់មជ្ឈមណ្ឌលដែលអនុវត្តតាមស្តង់ដាការអនុវត្តផលិតកម្មល្អ (GMP) ដើម្បីជួយសម្រួលដល់ការបង្កើត និងការរាយតម្លៃវិធីព្យាបាលថ្មីៗដោយប្រើកោសិកា និងហ្សែន។

(8) សម្របសម្រួល អនុវត្ត និងត្រួតពិនិត្យការសាកល្បងព្យាបាល ដើម្បីវាយតម្លៃសុវត្ថិភាព និងប្រសិទ្ធភាពនៃវិធីព្យាបាលថ្មីៗ ក្នុងចំណោមក្រុមអ្នកជំងឺដែលមានភាពចម្រុះ។

(9) អភិវឌ្ឍវិធីព្យាបាលដែលមានសម្រាប់អ្នកជំងឺនៅរដ្ឋ California និងមានតម្លៃសមរម្យសម្រាប់ពួកគេ។

130355. (a) ក្រសួងត្រូវសម្របសម្រួល និងគាំទ្រការបង្កើតក្រុមប្រឹក្សាស្រាវជ្រាវផ្នែកប្រឹក្សាយោបល់ និងគណនេយ្យភាព។

(b) (1) ក្រុមប្រឹក្សាត្រូវមានគណៈកម្មាធិការប្រតិបត្តិមួយដែលមានសមាជិកចំនួនប្រាំពីររូប ហើយសមាជិកនៃគណៈកម្មាធិការនេះក៏ត្រូវបម្រើការជាសមាជិកទូទៅនៃក្រុមប្រឹក្សាផងដែរ។ អធិការនៃបរិវេណសាកលវិទ្យាល័យ California នៅ Berkeley, Davis, Irvine, Los Angeles, Riverside, San Diego និង San Francisco ត្រូវតែងតាំងតំណាងម្នាក់ពីបរិវេណសាកលវិទ្យាល័យរៀងៗខ្លួន ដើម្បីបម្រើការនៅក្នុងគណៈកម្មាធិការប្រតិបត្តិ។

(2) គណៈកម្មាធិការប្រតិបត្តិ តាមរយៈការបោះឆ្នោត ដោយសំឡេងភាគច្រើន ត្រូវតែងតាំងសមាជិកបន្ថែមមិនតិចជាង 10 រូប និងមិនលើសពី 15 រូប ឱ្យចូលជាសមាជិកក្រុមប្រឹក្សា ដែលត្រូវជ្រើសរើសចេញពីក្រុមប្រភេទដែលបានពិពណ៌នានៅក្នុងកថាខណ្ឌរង (A) និង (B)។

(A) តំណាងរបស់សាកលវិទ្យាល័យមិនរកប្រាក់ចំណេញនៅរដ្ឋ California ដោយមិនរាប់បញ្ចូលសាកលវិទ្យាល័យ California ដែលបានបង្ហាញឱ្យឃើញពីភាពជោគជ័យ និងភាពជាអ្នកដឹកនាំក្នុងការស្រាវជ្រាវផ្នែកភាពសុាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពសុាំ។

(B) តំណាងរបស់ស្ថាប័នសិក្សា និងស្រាវជ្រាវមិនរកប្រាក់ចំណេញនៅរដ្ឋ California ដែលមិនមែនជាផ្នែកមួយនៃសាកលវិទ្យាល័យ California ហើយដែលបានបង្ហាញឱ្យឃើញពីភាពជោគជ័យ និងភាពជាអ្នកដឹកនាំក្នុងការស្រាវជ្រាវផ្នែកភាពសុាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពសុាំ។

(3) សមាជិកនីមួយៗនៃក្រុមប្រឹក្សាត្រូវជាគ្រូពេទ្យ អ្នកវិទ្យាសាស្ត្រ ឬអ្នកស្រាវជ្រាវដែលមានបទពិសោធន៍ជាក់ស្តែងក្នុងវិស័យភាពសុាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពសុាំ ហើយត្រូវបំពេញតាមលក្ខខណ្ឌបន្ថែមដែលអាចត្រូវបានកំណត់ដោយគណៈកម្មាធិការប្រតិបត្តិ។

(c) (1) សមាជិកនៃក្រុមប្រឹក្សាត្រូវបម្រើការក្នុងអាណត្តិរយៈពេលបួនឆ្នាំ។

(2) (A) ប្រសិនបើមានតំណែងទំនេរកើតឡើងក្នុងអំឡុងអាណត្តិរបស់សមាជិកគណៈកម្មាធិការប្រតិបត្តិ អាជ្ញាធរដែលបានតែងតាំងសមាជិកនោះត្រូវតែងតាំងសមាជិកជំនួសក្នុងរយៈពេល 45 ថ្ងៃ ដើម្បីបំពេញរយៈពេលដែលនៅសល់នៃអាណត្តិនោះ។

(B) ប្រសិនបើមានតំណែងទំនេរកើតឡើងក្នុងអំឡុងអាណត្តិ របស់ សមាជិកដែលមិនមែនជាសមាជិកគណៈកម្មាធិការប្រតិបត្តិ គណៈកម្មាធិការប្រតិបត្តិតាមរយៈការបោះឆ្នោតដោយសំឡេងភាគច្រើន ត្រូវតែងតាំងសមាជិកជំនួសដែលតំណាងឱ្យអង្គការ ឬស្ថាប័នដដែលដែលសមាជិកដែលលែងកាន់តំណែងនោះបានតំណាង ក្នុងរយៈពេល 45 ថ្ងៃ ដើម្បីបំពេញរយៈពេលដែលនៅសល់នៃអាណត្តិនោះ។

(3) (A) នៅពេលអាណត្តិរបស់សមាជិកគណៈកម្មាធិការប្រតិបត្តិផុតកំណត់ អាជ្ញាធរដែលបានតែងតាំងសមាជិកនោះ ត្រូវតែងតាំងសមាជិកនោះឡើងវិញ ឬតែងតាំងសមាជិកថ្មីសម្រាប់អាណត្តិថ្មី ក្នុងរយៈពេល 30 ថ្ងៃ។

(B) នៅពេលអាណត្តិរបស់សមាជិកដែលមិនមែនជាសមាជិកគណៈកម្មាធិការប្រតិបត្តិផុតកំណត់ គណៈកម្មាធិការប្រតិបត្តិ តាមរយៈការបោះឆ្នោតដោយសំឡេងភាគច្រើន ត្រូវតែងតាំងសមាជិកនោះឡើងវិញ ឬតែងតាំងសមាជិកថ្មីសម្រាប់អាណត្តិថ្មី ក្នុងរយៈពេល 30 ថ្ងៃ។ សមាជិកដែល

38

អាណត្តិរបស់ខ្លួនបានផុតកំណត់ ត្រូវបន្តបំពេញតួនាទីរហូតដល់មានការតែងតាំងសមាជិកជំនួស។

(d) (1) ប្រធាន និងអនុប្រធានក្រុមប្រឹក្សា ត្រូវជាសមាជិកនៃគណៈកម្មាធិការប្រតិបត្តិរៀងៗខ្លួន ត្រូវមានអាណត្តិរយៈពេលពីរឆ្នាំរៀងៗខ្លួន ហើយលើកលែងតែមានចែងផ្សេងនៅក្នុងចំណុច (2) ត្រូវបានជ្រើសរើសដោយការបោះឆ្នោតដោយសំឡេងភាគច្រើនរបស់សមាជិកក្រុមប្រឹក្សាទាំងមូល។

(2) តំណាងដែលត្រូវបានតែងតាំងមកពីសាកលវិទ្យាល័យ California ទីក្រុង Los Angeles ត្រូវបម្រើការជាប្រធានដំបូងនៃក្រុមប្រឹក្សា។

(e) ចំនួនសមាជិកអប្បបរមាដែលត្រូវមានវត្តមាន ដើម្បីឱ្យក្រុមប្រឹក្សាអាចប្រជុំ និងចាត់ការកិច្ចការបានដោយស្របច្បាប់ ត្រូវជាសមាជិកភាគច្រើននៃសមាជិកដែលកំពុងបំពេញតួនាទីនៅពេលនោះ។

(f) សមាជិកក្រុមប្រឹក្សាត្រូវបំពេញតួនាទីដោយមិនទទួលបានប្រាក់បំណាច់ឬសំណងឡើយ ប៉ុន្តែអាចទទួលបានការសងត្រឡប់ចំពោះថ្លៃធ្វើដំណើរ និងថ្លៃចំណាយចាំបាច់ដែលបានកើតឡើងជាក់ស្តែងក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

130356. (a) ក្រុមប្រឹក្សាត្រូវកំណត់ តាមនីតិវិធីដែលបានចែងក្នុងផ្នែករង (e) ថាតើគម្រោងស្រាវជ្រាវណាខ្លះដែលបានស្នើឡើងដោយសាកលវិទ្យាល័យសាធារណៈ និងសាកលវិទ្យាល័យមិនរកប្រាក់ចំណេញ ព្រមទាំងស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញផ្សេងទៀត ដែលមានតំណាងនៅក្នុងក្រុមប្រឹក្សា ត្រូវទទួលបានមូលនិធិអនុលោមតាមចំណុច (2) នៃផ្នែករង (b) នៃមាត្រាទី 130352 ដោយផ្អែកលើលក្ខខណ្ឌជ្រើសរើស និងអាទិភាពស្រាវជ្រាវដែលបានបង្កើតឡើងក្រោមជំពូកនេះ និងផ្អែកលើគុណតម្លៃផ្នែកបច្ចេកទេសនៃសំណើដែលត្រូវបានវាយតម្លៃអនុលោមតាមមាត្រានេះ។

(b) (1) ក្រុមប្រឹក្សាត្រូវបង្កើតលក្ខខណ្ឌជ្រើសរើស និងអាទិភាពស្រាវជ្រាវសម្រាប់ការផ្តល់ជំនួយមូលនិធិក្រោមមាត្រានេះ ដោយផ្អែកលើកត្តាទាំងអស់ដូចខាងក្រោម៖

(A) គុណតម្លៃផ្នែកវិទ្យាសាស្ត្រនៃសំណើ។

(B) បទពិសោធន៍របស់អ្នកដាក់ពាក្យក្នុងការធ្វើការស្រាវជ្រាវវេជ្ជសាស្ត្រដោយប្រើវិធីសាស្ត្រស្រាវជ្រាវដែលមានលក្ខណៈត្រឹមត្រូវតាមគោលការណ៍វិទ្យាសាស្ត្រ។

(C) អត្ថប្រយោជន៍ដែលអាចកើតមានចំពោះសុខភាព និងសុខមាលភាពរបស់ប្រជាជន។

(D) លក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយក្រុមប្រឹក្សា។

(2) ក្នុងការកំណត់អាទិភាពស្រាវជ្រាវអនុលោមតាមចំណុច (1) ក្រុមប្រឹក្សាត្រូវ ផ្តល់ អាទិភាពខ្ពស់បំផុតដល់គម្រោងស្រាវជ្រាវដែលមានសក្តានុពលខ្ពស់បំផុត ក្នុងការបង្កើតវិធីព្យាបាលដែលអាចរកបានឆាប់បំផុត អាចទទួលបាន និងមានតម្លៃសមរម្យបំផុត ហើយដែលមានគោលបំណងបង្កើនលទ្ធភាពទទួលបានវិធីព្យាបាលដោយប្រព័ន្ធភាពសុាំសម្រាប់អ្នកជំងឺ។

(c) (1) ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មការពិនិត្យដោយ អ្នកជំនាញវិទ្យាសាស្ត្រមួយ ឬច្រើន ដែលមានអ្នកជំនាញផ្នែកភាពសុាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពសុាំ ដើម្បីពិនិត្យ និងកំណត់អាទិភាពសំណើដោយផ្អែកលើលក្ខខណ្ឌជ្រើសរើស និងអាទិភាពស្រាវជ្រាវដែលបង្កើតឡើងដោយក្រុមប្រឹក្សាអនុលោមតាមផ្នែករង (b)។

(2) អ្នកជំនាញនៅក្នុងគណៈកម្មការពិនិត្យដោយអ្នកជំនាញវិទ្យាសាស្ត្រត្រូវបានដកសិទ្ធិពីការចូលរួមក្នុងការពិនិត្យសំណើសុំមូលនិធិ ប្រសិនបើអ្នកជំនាញនោះមានទំនាក់ទំនងសហការគ្នា ឬទំនាក់ទំនងពាណិជ្ជកម្មជាមួយអ្នកដាក់ពាក្យ។

(d) ជំនួយមូលនិធិទាំងអស់ដែលផ្តល់តាមមាត្រានេះ ត្រូវផ្តល់ដល់អ្នកស្រាវជ្រាវ ឬគម្រោងស្រាវជ្រាវដែលមានទីតាំងជាចម្បងនៅក្នុងរដ្ឋនេះ លើកលែងតែការផ្តល់មូលនិធិសម្រាប់កិច្ចសហការស្រាវជ្រាវរវាងអ្នកស្រាវជ្រាវដែលមានមូលដ្ឋាននៅរដ្ឋ California និងអ្នកស្រាវជ្រាវដែលមានមូលដ្ឋាននៅក្រៅរដ្ឋ California ត្រូវបានអនុញ្ញាត។

(e) (1) ក្រុមប្រឹក្សា តាមរយៈការបោះឆ្នោតដោយសំឡេងភាគច្រើន ត្រូវទទួលយក ឬបដិសេធពាក្យស្នើសុំមូលនិធិ ដែលបានទទួល ពី សាកលវិទ្យាល័យសាធារណៈ និងសាកលវិទ្យាល័យមិនរកប្រាក់ចំណេញ ព្រមទាំងស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញផ្សេងទៀត ដែលមានតំណាងនៅក្នុងក្រុមប្រឹក្សា។

(2) ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយវិទ្យាស្ថានដែលត្រូវបានជ្រើសរើស ដោយក្រសួងអនុលោមតាមមាត្រា ទី130353 ក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយពាក់ព័ន្ធនឹងការផ្តល់មូលនិធិសម្រាប់សំណើសុំជំនួយមូលនិធិ អនុលោមតាមផ្នែករងនេះ។

(f) ក្រុមប្រឹក្សាត្រូវបង្កើតស្តង់ដាស្តីពីទំនាស់ផលប្រយោជន៍ សម្រាប់ការពិចារណាសំណើសុំមូលនិធិ ដោយផ្អែកលើខត្តមានុវត្តដែល បានបង្កើតឡើង ដោយបណ្ឌិតសភាវិទ្យាសាស្ត្រជាតិ ដើម្បីបង្ការ ទំនាស់ផលប្រយោជន៍ក្នុងការផ្តល់មូលនិធិសម្រាប់ការស្រាវជ្រាវ ហើយត្រូវធ្វើបច្ចុប្បន្នភាពស្តង់ដារទាំងនោះយ៉ាងហោចណាស់រៀងរាល់បួនឆ្នាំម្តង ដើម្បីឱ្យមានភាពស្របគ្នាជាទូទៅជាមួយស្តង់ដាដែលបានអនុម័តដោយបណ្ឌិតសភាវិទ្យាសាស្ត្រជាតិ។

130357. (a) ក្រសួងត្រូវចុះកិច្ចព្រមព្រៀងផ្តល់ជំនួយមូលនិធិជាមួយអ្នកទទួលមូលនិធិដែលត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សាតាមមាត្រា 130356 សម្រាប់ការផ្តល់មូលនិធិដល់ការស្រាវជ្រាវវិទ្យាសាស្ត្រ ការអភិវឌ្ឍ និងការសាកល្បងព្យាបាល ជាពិសេសនៅក្នុងវិស័យភាពសុាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពសុាំ។

(b) កិច្ចព្រមព្រៀងផ្តល់ជំនួយមូលនិធិនីមួយៗ ត្រូវតម្រូវឱ្យការស្រាវជ្រាវ និងការអភិវឌ្ឍទាំងអស់ដែលទទួលបានមូលនិធិក្រោមកិច្ចព្រមព្រៀងនោះ ត្រូវអនុវត្តស្របតាមស្តង់ដាដែលបានបង្កើតឡើងស្តីពីការផ្លាស់ប្តូរព័ត៌មានវិទ្យាសាស្ត្រដោយបើកចំហ ការពិនិត្យដោយអ្នកជំនាញសហការី និងការត្រួតពិនិត្យជាសាធារណៈ។

(c) កិច្ចព្រមព្រៀងជំនួយឥតសំណងនីមួយៗ ត្រូវតម្រូវឱ្យអ្នកទទួលមូលនិធិទិញទំនិញ និងសេវាកម្មពីអ្នកផ្គត់ផ្គង់នៅរដ្ឋ California តាមលទ្ធភាពដែលអាចធ្វើទៅបានដោយសមហេតុផល ដោយខិតខំប្រឹងប្រែងដោយសុចរិតដើម្បីសម្រេចបានគោលដៅដែលការទិញទំនិញ និងសេវាកម្មទាំងនោះច្រើនជាង 50 ភាគរយ ត្រូវបានទិញពីអ្នកផ្គត់ផ្គង់នៅរដ្ឋ California។

(d) កិច្ចព្រមព្រៀងផ្តល់ជំនួយមូលនិធិនីមួយៗ ត្រូវតម្រូវឱ្យអ្នកទទួលមូលនិធិផ្តល់ឱកាសដល់វិទ្យាស្ថានដែលត្រូវបានជ្រើសរើសដោយក្រសួងអនុលោមតាមមាត្រាទី 130353 ឱ្យចូលរួមយ៉ាងសំខាន់ និងសហការក្នុងការស្រាវជ្រាវដែលទទួលបានមូលនិធិ។

(e) កិច្ចព្រមព្រៀងផ្តល់ជំនួយមូលនិធិនីមួយៗ ត្រូវតម្រូវឱ្យអ្នកទទួលមូលនិធិផ្តល់ឱកាសដល់សាកលវិទ្យាល័យ California ទីក្រុង Los Angeles ឱ្យចូលរួមយ៉ាងសំខាន់ និងសហការក្នុងការសាកល្បងព្យាបាលណាមួយដែលធ្វើឡើងជាផ្នែកមួយនៃការស្រាវជ្រាវដែលទទួលបានមូលនិធិ។

(f) កិច្ចព្រមព្រៀងផ្តល់ជំនួយមូលនិធិនីមួយៗ ត្រូវតម្រូវឱ្យអ្នកទទួលមូលនិធិចូលរួមក្នុងការធ្វើសវនកម្ម និងសហការជាមួយការធ្វើសវនកម្មដែលធ្វើឡើងអនុលោមតាមផ្នែករង (b) នៃមាត្រាទិ 130361។

(g) កិច្ចព្រមព្រៀងផ្តល់ជំនួយឥតសំណងទាំងអស់ដែលបានចុះក្រោមមាត្រានេះ ត្រូវកំណត់ថ្លៃចំណាយប្រយោលមិនឱ្យលើសពី 20 ភាគរយនៃជំនួយឥតសំណងសម្រាប់ការស្រាវជ្រាវ លើកលែងតែការកំណត់ថ្លៃចំណាយប្រយោលនេះ អាចត្រូវបានបង្កើនតាមចំនួនដែលអ្នកទទួលមូលនិធិផ្តល់មូលនិធិផ្គូផ្គងលើសពី 20 ភាគរយនៃចំនួនជំនួយឥតសំណង។

130358. (a) (1) (A) អ្នកទទួលមូលនិធិស្រាវជ្រាវណាមួយក្រោមជំពូកនេះ ត្រូវបង់ជូនរដ្ឋ California នូវចំនួនទឹកប្រាក់ស្មើនឹង 10 ភាគរយនៃចំណូលទាំងអស់ដែលអ្នកទទួលមូលនិធិស្រាវជ្រាវនោះទទួលបានពីការលក់ ការផ្តល់អាជ្ញាប័ណ្ណ ឬការធ្វើពាណិជ្ជកម្ម ឬការរកប្រាក់តាមមធ្យោបាយ

38

ផ្សេងទៀតលើសិទ្ធិកម្មសិទ្ធិបញ្ញាណាមួយ ដែលកើតចេញពីការស្រាវជ្រាវដែលទទួលបានមូលនិធិក្រោមជំពូកនេះ។

(B) ការទូទាត់ដែលធ្វើឡើងតាមកថាខណ្ឌរង (A) ត្រូវគណនាដោយមិនគិតថា ការស្រាវជ្រាវដែលបង្កើតឱ្យមានសិទ្ធិកម្មសិទ្ធិបញ្ញានោះ ត្រូវបានផ្តល់មូលនិធិទាំងស្រុង ឬត្រឹមតែផ្នែកមួយប៉ុណ្ណោះ ដោយមូលនិធិស្រាវជ្រាវដែលបានផ្តល់តាមជំពូកនេះ។

(C) ការទូទាត់ទាំងអស់ដែលធ្វើឡើងតាមកថាខណ្ឌនេះ ត្រូវបង់ជូនរដ្ឋដោយអ្នកទទួលមូលនិធិស្រាវជ្រាវ ក្នុងរយៈពេល 30 ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានចំណូលណាមួយដែលបានមកពីប្រភពនោះ។

(2) ការទូទាត់ដែលធ្វើឡើងតាមកថាខណ្ឌ (1) ត្រូវដាក់ចូលទៅក្នុងមូលនិធិទូទៅ រហូតដល់ចំនួនសរុបបង្គរនៃការទូទាត់ទាំងនោះ ស្មើនឹងថ្លៃដើមសរុបដែលរដ្ឋត្រូវចំណាយសម្រាប់មូលបត្របំណុលដែលបានចេញតាមជំពូក 2 (ចាប់ផ្តើមពីមាត្រាទី 130370) រួមទាំងការប្រាក់ដែលបានបង់លើមូលបត្របំណុលទាំងនោះ ដូចដែលបានកំណត់ដោយគណៈកម្មាធិការហិរញ្ញវត្ថុផ្នែកភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំនៃរដ្ឋ California ដែលត្រូវបានបង្កើតឡើងអនុលោមតាមកថាខណ្ឌ (1) នៃផ្នែករង (a) នៃមាត្រាទី 130375។

(3) បន្ទាប់ពីចំនួនសរុបបង្គរដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ (2) ត្រូវបានបង់ចូលទៅក្នុងមូលនិធិទូទៅរួចហើយ ចំណូលបន្ថែមណាមួយដែលទទួលបានអនុលោមតាមកថាខណ្ឌ (1) ត្រូវដាក់ចូលទៅក្នុងមូលនិធិស្រាវជ្រាវវេជ្ជសាស្ត្រផ្នែកភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំនៃរដ្ឋ California ហើយត្រូវចំណាយស្របតាមគោលបំណងនៃជំពូកនេះ។

(b) ជាលក្ខខណ្ឌនៃការទទួលបានមូលនិធិស្រាវជ្រាវក្រោមជំពូកនេះ អ្នកទទួលមូលនិធិណាមួយដែលផ្តល់អាជ្ញាប័ណ្ណ ឬលក់បច្ចេកវិទ្យា ឬថ្នាំដែលត្រូវបានអភិវឌ្ឍតាមរយៈការស្រាវជ្រាវដែលទទួលបានមូលនិធិតាមជំពូកនេះ ត្រូវយល់ព្រមថា ការផ្តល់អាជ្ញាប័ណ្ណ ឬការលក់ក្នុងគោលបំណងធ្វើឱ្យបច្ចេកវិទ្យា ឬថ្នាំនោះមានសម្រាប់អ្នកជំងឺ មន្ទីរពេទ្យ ឬក្រុមហ៊ុនធានារ៉ាប់រងនៅរដ្ឋ California រួមទាំងតាមរយៈកម្មវិធីថែទាំសុខភាពដែលទទួលបានមូលនិធិពីរដ្ឋាភិបាល ត្រូវតម្រូវឱ្យបច្ចេកវិទ្យា ឬថ្នាំនោះមានសម្រាប់អ្នកជំងឺ មន្ទីរពេទ្យ និងក្រុមហ៊ុនធានារ៉ាប់រងនៅរដ្ឋ California ក្នុងតម្លៃដែលទាបជាងតម្លៃមធ្យមទូទាំងប្រទេសយ៉ាងហោចណាស់ 20 ភាគរយ ដោយគណនាដោយមិនរាប់បញ្ចូលរដ្ឋ California សម្រាប់បច្ចេកវិទ្យា ឬថ្នាំដូចគ្នានោះដែលត្រូវកំណត់ដូចខាងក្រោម៖

(1) ក្នុងអំឡុងពេល 12 ខែដំបូងនៃការលក់បច្ចេកវិទ្យា ឬថ្នាំជាលក្ខណៈពាណិជ្ជកម្ម អ្នកជំងឺ មន្ទីរពេទ្យ និងក្រុមហ៊ុនធានារ៉ាប់រងនៅរដ្ឋ California ដែលទិញបច្ចេកវិទ្យា ឬថ្នាំនោះ មិនត្រូវបានគិតថ្លៃលើសពីតម្លៃដែលបច្ចេកវិទ្យា ឬថ្នាំនោះត្រូវបានលក់ទៅឱ្យអ្នកជំងឺ មន្ទីរពេទ្យ និងក្រុមហ៊ុនធានារ៉ាប់រងនៅគ្រប់ទីកន្លែងផ្សេងទៀតក្នុងសហរដ្ឋអាមេរិក ក្រៅពីរដ្ឋ California ឡើយ។

(2) នៅត្រឹមកាលបរិច្ឆេទដែលគ្រប់មួយឆ្នាំបន្ទាប់ពីការលក់បច្ចេកវិទ្យា ឬថ្នាំជាលក្ខណៈពាណិជ្ជកម្មជាលើកដំបូង ទិន្នន័យពីការលក់ក្នុងរយៈពេលប្រាំបួនខែដំបូង ត្រូវយកមកប្រើប្រាស់ដើម្បីគណនាតម្លៃមធ្យមទូទាំងប្រទេស។ បន្ទាប់ពីនោះ បច្ចេកវិទ្យា ឬថ្នាំនោះ ត្រូវធ្វើឱ្យមានសម្រាប់អ្នកជំងឺ មន្ទីរពេទ្យ និងក្រុមហ៊ុនធានារ៉ាប់រងនៅរដ្ឋ California ក្នុងតម្លៃដែលទាបជាងតម្លៃមធ្យមដែលបានគណនាទូទាំងប្រទេសយ៉ាងហោចណាស់ 20 ភាគរយ ដោយមិនរាប់បញ្ចូលរដ្ឋ California។

(3) តម្លៃមធ្យមទូទាំងប្រទេស ដោយមិនរាប់បញ្ចូលរដ្ឋ California ត្រូវគណនាឡើងវិញជារៀងរាល់ឆ្នាំ ហើយតម្លៃសម្រាប់បច្ចេកវិទ្យា ឬថ្នាំនោះនៅរដ្ឋ California ត្រូវកែសម្រួលតាមការចាំបាច់ ដើម្បីធានាថា អ្នកទិញនៅរដ្ឋ California ទទួលបានការសន្សំថ្លៃចំណាយយ៉ាងហោចណាស់ 20 ភាគរយ បើប្រៀបធៀបនឹងតម្លៃមធ្យមទូទាំងប្រទេសដែលបានគណនា។

(c) អ្នកទទួលមូលនិធិស្រាវជ្រាវណាមួយក្រោមជំពូកនេះ ត្រូវតម្រូវឱ្យកម្មសិទ្ធិនៃសិទ្ធិកម្មសិទ្ធិបញ្ញាណាមួយដែលកើតចេញពីការស្រាវជ្រាវដែលទទួលបានមូលនិធិ ត្រូវប្រគល់ជូនវិទ្យាស្ថាន សាកលវិទ្យាល័យសាធារណៈ ឬសាកលវិទ្យាល័យមិនរកប្រាក់ចំណេញ ឬស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញ ដែលបានទទួលមូលនិធិអនុលោមតាមផ្នែករង (b) នៃមាត្រាទី 130352។ វិធានការដើម្បីតម្រូវឱ្យកម្មសិទ្ធិលើសិទ្ធិកម្មសិទ្ធិបញ្ញាណាមួយត្រូវបានធ្វើឡើងតាមរយៈកាតព្វកិច្ចក្នុងការផ្ទេរសិទ្ធិ និងការផ្ទេរសិទ្ធិជាក់ស្តែងលើប៉ាតង់ និងសិទ្ធិកម្មសិទ្ធិបញ្ញាផ្សេងទៀត ដោយបុគ្គលិក អ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវ អ្នកម៉ៅការឯករាជ្យ ឬបុគ្គលផ្សេងទៀតទាំងអស់ ដែលទទួលបានថវិកាតាមរយៈជំនួយឥតសំណង កិច្ចសន្យា ឬតាមមធ្យោបាយផ្សេងទៀត ពីមូលនិធិដែលមានប្រភពក្រោមជំពូកនេះ ទៅឱ្យវិទ្យាស្ថាន សាកលវិទ្យាល័យសាធារណៈ ឬសាកលវិទ្យាល័យមិនរកប្រាក់ចំណេញ ឬស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញ។

(d) ចំពោះសិទ្ធិកម្មសិទ្ធិបញ្ញាណាមួយដែលត្រូវបានបង្កើតគំនិតឡើង ឬយកមកអនុវត្តជាក់ស្តែង មិនថាអាចទទួលបានប៉ាតង់ ឬមិនអាចទទួលបានប៉ាតង់ក៏ដោយ ដែលផ្នែកលើ ឬកើតចេញពីមូលនិធិដែលបានបញ្ចេញតាមផ្នែករង (b) នៃមាត្រាទី 130352 ប្រសិនបើ និងក្នុងកម្រិតដែលអ្នកទទួលមូលនិធិមានសិទ្ធិលើបច្ចេកវិទ្យាដើម រួមមានប៉ាតង់ និងសិទ្ធិកម្មសិទ្ធិបញ្ញាផ្សេងទៀត ដែលជាកម្មសិទ្ធិរបស់ខ្លួន ឬដែលខ្លួនទទួលបានអាជ្ញាប័ណ្ណ ហើយសិទ្ធិទាំងនោះអាចរារាំងដល់ការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញាថ្មី ឬអាចរារាំងតាមមធ្យោបាយផ្សេងទៀតដល់ការធ្វើអាជីវកម្មពាណិជ្ជកម្មលើសិទ្ធិកម្មសិទ្ធិបញ្ញាថ្មី អ្នកទទួលមូលនិធិនោះត្រូវផ្តល់អាជ្ញាប័ណ្ណដោយមិនគិតថ្លៃ ឬយសារអាករ ដែលមានសុពលភាពទូទាំងពិភពលោក សម្រាប់បច្ចេកវិទ្យាដើមនោះ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណ ឬអ្នកប្រើប្រាស់ដែលទទួលបានការអនុញ្ញាតនោះ មានសិទ្ធិផ្តល់អាជ្ញាប័ណ្ណបន្ត ឬប្រសិនបើសិទ្ធិដែលមានលក្ខណៈសមមូលត្រូវបានអនុញ្ញាត ដោយអាជ្ញាប័ណ្ណនេះត្រូវកំណត់ជាក់លាក់សម្រាប់ការអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញាថ្មី ក្នុងការភ្ជាប់ជាមួយការលក់ ការផ្តល់អាជ្ញាប័ណ្ណ ឬការធ្វើពាណិជ្ជកម្ម ឬការរកប្រាក់តាមមធ្យោបាយផ្សេងទៀតលើសិទ្ធិកម្មសិទ្ធិបញ្ញាថ្មី ដែលកើតចេញពីការស្រាវជ្រាវដែលទទួលបានមូលនិធិក្រោមជំពូកនេះ។

(e) (1) វិទ្យាស្ថាន ដោយពិគ្រោះយោបល់ជាមួយនាយកដ្ឋាន ត្រូវបង្កើតកម្មវិធីផ្តល់អាជ្ញាប័ណ្ណមួយ ដែលសម្រេចបាននូវគោលដៅទាំងអស់ដូចខាងក្រោម៖

(A) បង្កើនឱ្យដល់កម្រិតអតិបរមានូវចំណូល ដែលទទួលបានពីការលក់ ការផ្តល់អាជ្ញាប័ណ្ណ ឬការធ្វើពាណិជ្ជកម្ម ឬការរកប្រាក់តាមមធ្យោបាយផ្សេងទៀតលើសិទ្ធិកម្មសិទ្ធិបញ្ញាណាមួយ ដែលកើតចេញពីការស្រាវជ្រាវដែលទទួលបានមូលនិធិក្រោមជំពូកនេះ។

(B) បង្កើតលក្ខខណ្ឌផ្តល់អាជ្ញាប័ណ្ណដែលមានស្តង់ដាដូចគ្នា និងលក្ខខណ្ឌដែលអាចអនុញ្ញាតឱ្យមានការចរចា ដើម្បីបង្កើនភាពស្របគ្នានៅក្នុងកិច្ចខិតខំប្រឹងប្រែងទាំងអស់ក្នុងការធ្វើពាណិជ្ជកម្ម ឬការរកប្រាក់ពីសិទ្ធិកម្មសិទ្ធិបញ្ញាដែលកើតចេញពីការស្រាវជ្រាវដែលទទួលបានមូលនិធិក្រោមជំពូកនេះ។

(C) សម្របសម្រួលការសងប្រាក់ជូនរដ្ឋ California ស្របតាមកថាខណ្ឌ (1) នៃផ្នែករង (a) ហើយធ្វើការព្យាករអំពីការទូទាត់នាពេលអនាគតជូនរដ្ឋ California ដោយផ្អែកលើអាជ្ញាប័ណ្ណទាំងអស់ដែលកើតចេញពីការស្រាវជ្រាវដែលទទួលបានមូលនិធិក្រោមជំពូកនេះ។

(2) (A) វិទ្យាស្ថាន ដោយពិគ្រោះយោបល់ជាមួយក្រសួង ត្រូវបម្រើជាមជ្ឈមណ្ឌលទទួល ប្រមូលផ្តុំ និងពិនិត្យកិច្ចព្រមព្រៀង ព្រមទាំងជាមជ្ឈមណ្ឌលអនុម័ត សម្រាប់កិច្ចព្រមព្រៀងទាំងអស់ស្តីពីការលក់ ការផ្តល់អាជ្ញាប័ណ្ណ ឬការធ្វើពាណិជ្ជកម្ម ឬការរកប្រាក់តាមមធ្យោបាយផ្សេងទៀតលើសិទ្ធិកម្មសិទ្ធិបញ្ញាដែលកើតចេញពីការស្រាវជ្រាវដែលទទួលបានមូលនិធិក្រោមជំពូកនេះ ដើម្បីធានាឱ្យមានភាពស្របគ្នានៃលក្ខខណ្ឌសំខាន់ៗ និងបង្កើនចំណូលឱ្យបានច្រើនបំផុតដែលទទួលបានពីកិច្ចខិតខំប្រឹងប្រែងធ្វើពាណិជ្ជកម្ម ឬរកប្រាក់ទាំងនោះ។

38

(B) មុនពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងទាំងអស់ស្តីពីការលក់ ការផ្តល់អាជ្ញាប័ណ្ណ ឬការធ្វើពាណិជ្ជកម្ម ឬការរកប្រាក់តាមមធ្យោបាយផ្សេងទៀតលើសិទ្ធិកម្មសិទ្ធិបញ្ញាដែលកើតចេញពីការស្រាវជ្រាវដែលទទួលបានមូលនិធិក្រោមជំពូកនេះ កិច្ចព្រមព្រៀងទាំងនោះត្រូវផ្តល់ជូនវិទ្យាស្ថានដើម្បីពិនិត្យ ហើយវិទ្យាស្ថានត្រូវទទួលបានឱកាសដើម្បីផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងការកែសម្រួលក្នុងណែនៃកិច្ចព្រមព្រៀងដែលបានស្នើឡើង។

(C) ក្នុងគ្រប់ករណីទាំងអស់ដែលវិទ្យាស្ថានប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការចូលរួម និងសហការក្នុងការស្រាវជ្រាវ តាមផ្នែករង (d) នៃមាត្រាទី 130357 វិទ្យាស្ថានត្រូវមានការទទួលខុសត្រូវជាចម្បងក្នុងការចរចាកិច្ចព្រមព្រៀងណាមួយស្តីពីការលក់ ការផ្តល់អាជ្ញាប័ណ្ណ ឬការធ្វើពាណិជ្ជកម្ម ឬការរកប្រាក់តាមមធ្យោបាយផ្សេងទៀតលើសិទ្ធិកម្មសិទ្ធិបញ្ញាដែលកើតចេញពីការស្រាវជ្រាវនោះ។

(f) (1) (A) កិច្ចព្រមព្រៀងផ្តល់អាជ្ញាប័ណ្ណណាមួយដែលបានចុះដោយអ្នកទទួលមូលនិធិស្រាវជ្រាវក្រោមជំពូកនេះ សម្រាប់ការផ្តល់អាជ្ញាប័ណ្ណលើសិទ្ធិកម្មសិទ្ធិបញ្ញាដែលកើតចេញពីការស្រាវជ្រាវដែលទទួលបានមូលនិធិក្រោមជំពូកនេះ ត្រូវតម្រូវឱ្យអ្នកទទួលមូលនិធិស្រាវជ្រាវទទួលបានថ្លៃសួយសារអាករយ៉ាងហោចណាស់ 10 ភាគរយនៃចំណូលសរុបដែលបានមកពីការលក់ ឬការធ្វើពាណិជ្ជកម្ម ឬការរកប្រាក់តាមមធ្យោបាយផ្សេងទៀតលើសិទ្ធិកម្មសិទ្ធិបញ្ញាដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀង។

(B) ទោះបីមានចែងក្នុងកថាខណ្ឌរង (A) ក៏ដោយ កិច្ចព្រមព្រៀងផ្តល់អាជ្ញាប័ណ្ណដែលបានចុះដោយអ្នកទទួលមូលនិធិស្រាវជ្រាវក្រោមជំពូកនេះ សម្រាប់ការផ្តល់អាជ្ញាប័ណ្ណលើសិទ្ធិកម្មសិទ្ធិបញ្ញាដែលកើតចេញពីការស្រាវជ្រាវដែលទទួលបានមូលនិធិក្រោមជំពូកនេះ អាចកំណត់ថ្លៃសួយសារអាករតិចជាង 10 ភាគរយនៃចំណូលសរុបបាន ប្រសិនបើនាយកដ្ឋានកំណត់ ដោយពិគ្រោះយោបល់ជាមួយវិទ្យាស្ថានថា ការកំណត់អត្រាថ្លៃសួយសារអាករតិចជាង 10 ភាគរយ សម្រាប់កិច្ចព្រមព្រៀងផ្តល់អាជ្ញាប័ណ្ណជាក់លាក់មួយ នឹងជួយលើកកម្ពស់ការសម្រេចបាននូវគោលបំណងនៃជំពូកនេះ។ ការកំណត់សេចក្តីសម្រេចតាមកថាខណ្ឌរងនេះត្រូវធ្វើឡើងដោយពិនិត្យជាករណីៗដាច់ដោយឡែកពីគ្នា ហើយក្នុងករណីណាក៏ដោយ ក្រសួងមិនត្រូវអនុម័តអត្រាថ្លៃសួយសារអាករដែលទាបជាង 5 ភាគរយឡើយ។

(2) កិច្ចព្រមព្រៀងណាមួយដែលបានចុះដោយអ្នកទទួលមូលនិធិស្រាវជ្រាវក្រោមជំពូកនេះ ក្នុងគោលបំណងបង្កើតក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា ឬការរៀបចំអាជីវកម្មផ្សេងទៀត សម្រាប់ការធ្វើពាណិជ្ជកម្ម ឬការរកប្រាក់ពីសិទ្ធិកម្មសិទ្ធិបញ្ញាដែលកើតចេញពីការស្រាវជ្រាវដែលទទួលបានមូលនិធិក្រោមជំពូកនេះ ត្រូវតម្រូវឱ្យអ្នកទទួលមូលនិធិស្រាវជ្រាវទទួលបានប្រាក់ចំណេញសរុបមិនតិចជាង 25 ភាគរយ ពីក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា ឬការរៀបចំអាជីវកម្មផ្សេងទៀតនោះ និងពីការលក់បន្តជាបន្តបន្ទាប់នូវក្រុមហ៊ុនបណ្តាក់ទុនរួមគ្នា ឬការរៀបចំអាជីវកម្មផ្សេងទៀតនោះ។

(g) វិទ្យាស្ថាន សាកលវិទ្យាល័យសាធារណៈ ឬសាកលវិទ្យាល័យមិនរកប្រាក់ចំណេញ ឬស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញណាមួយ ដែលទទួលបានមូលនិធិអនុលោមតាមផ្នែករង (b) នៃមាត្រាទី 130352 ត្រូវតម្រូវឱ្យបុគ្គលិក អ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវ អ្នកម៉ៅការឯករាជ្យ ឬបុគ្គលផ្សេងទៀតទាំងអស់ដែលទទួលបានមូលនិធិតាមរយៈជំនួយមូលនិធិ កិច្ចសន្យា ឬមធ្យោបាយផ្សេងទៀតពីមូលនិធិដែលមានប្រភពមកពីជំពូកនេះ ហើយមានបំណងបោះពុម្ពផ្សាយលទ្ធផលនៃការស្រាវជ្រាវដែលទទួលបានមូលនិធិនោះ ត្រូវផ្តល់ច្បាប់ចម្លងនៃស្នាដៃជាលាយលក្ខណ៍អក្សរដែលបានស្នើឡើង ឬគ្រោងសង្ខេបនៃការបង្ហាញដោយផ្ទាល់មាត់ ទៅឱ្យវិទ្យាស្ថាន សាកលវិទ្យាល័យសាធារណៈ ឬសាកលវិទ្យាល័យមិនរកប្រាក់ចំណេញ ឬស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញ ដើម្បីពិនិត្យយ៉ាងហោចណាស់ 30 ថ្ងៃ មុនពេលមានការបោះពុម្ពផ្សាយ ឬការធ្វើបទបង្ហាញណាមួយ។ វិទ្យាស្ថាន សាកលវិទ្យាល័យសាធារណៈ ឬសាកលវិទ្យាល័យមិនរកប្រាក់ចំណេញ ឬស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញដែលធ្វើការពិនិត្យ ត្រូវមានសិទ្ធិអនុវត្តសកម្មភាពទាំងពីរដូចខាងក្រោម៖

(1) ស្នើឱ្យមានការកែប្រែចំពោះការបោះពុម្ពផ្សាយ ឬការធ្វើបទបង្ហាញដោយសារហេតុផលពាក់ព័ន្ធនឹងប៉ាតង់ ឬដោយសារហេតុផលផ្សេងទៀតដែលត្រូវបញ្ជាក់ឱ្យបានលម្អិតក្នុងកម្រិតសមហេតុផលនៅពេលនោះ។

(2) ស្នើសុំឱ្យពន្យារពេលការបោះពុម្ពផ្សាយ ឬការធ្វើបទបង្ហាញក្នុងរយៈពេលសមហេតុផល ដើម្បីការពារព័ត៌មានដែលអាចទទួលបានប៉ាតង់ និងអនុញ្ញាតឱ្យដាក់ពាក្យស្នើសុំប៉ាតង់សម្រាប់ការការពារសិទ្ធិកម្មសិទ្ធិបញ្ញាតាមការកំណត់របស់វិទ្យាស្ថាន សាកលវិទ្យាល័យសាធារណៈ ឬសាកលវិទ្យាល័យមិនរកប្រាក់ចំណេញ ឬស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញដែលធ្វើការពិនិត្យ។

130359. (a) វិទ្យាស្ថានត្រូវចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំជាសាធារណៈ ដែលបង្ហាញអំពីសកម្មភាពរបស់វិទ្យាស្ថាន សមិទ្ធផលនៃការស្រាវជ្រាវ និងទិសដៅនាពេលអនាគតនៃកម្មវិធីទាំងមូលរបស់វិទ្យាស្ថាន។

(b) របាយការណ៍ប្រចាំឆ្នាំនីមួយៗ ត្រូវរួមមាន ប៉ុន្តែមិនកំណត់ត្រឹមតែចំណុចទាំងអស់ដូចខាងក្រោម៖

(1) សេចក្តីសង្ខេបអំពីលទ្ធផលនៃការស្រាវជ្រាវ រួមទាំងវិស័យស្រាវជ្រាវថ្មីៗដែលមានសក្តានុពល។

(2) ការពណ៌នាអំពីវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបាននូវគោលដៅរបស់គម្រោង និងលទ្ធផលសំខាន់ៗ ឬចំណុចសំខាន់ៗនៃសមិទ្ធផលផ្នែកវិទ្យាសាស្ត្រ។

(3) ចំនួន និងប្រភេទនៃស្នាដៃស្រាវជ្រាវដែលបានបោះពុម្ពផ្សាយ និងបានឆ្លងកាត់ការពិនិត្យដោយអ្នកជំនាញសហការី ពាក្យស្នើសុំប៉ាតង់ដែលបានដាក់ និងការសាកល្បងព្យាបាលដែលបានចាប់ផ្តើម។

(4) សេចក្តីសង្ខេបអំពីការចំណាយផ្នែករដ្ឋបាលរបស់វិទ្យាស្ថាន។

(5) របាយការណ៍អំពីផែនការស្រាវជ្រាវជាយុទ្ធសាស្ត្រ និងផែនការហិរញ្ញវត្ថុរបស់វិទ្យាស្ថាន។

(c) របាយការណ៍ប្រចាំឆ្នាំត្រូវផ្សព្វផ្សាយនៅលើគេហទំព័រអ៊ីនធឺណិតរបស់វិទ្យាស្ថាន។

130360. (a) ក្រុមប្រឹក្សាត្រូវចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំជាសាធារណៈ ដែលបង្ហាញអំពីជំនួយមូលនិធិដែលបានផ្តល់ ជំនួយមូលនិធិដែលកំពុងដំណើរការ សមិទ្ធផលនៃការស្រាវជ្រាវ និងទិសដៅនាពេលអនាគតនៃកម្មវិធីផ្តល់មូលនិធិតាមរយៈជំនួយឥតសំណង មូលនិធិទាំងមូលរបស់ក្រុមប្រឹក្សា។

(b) របាយការណ៍ប្រចាំឆ្នាំនីមួយៗ ត្រូវរួមមានជាអាទិ៍ ចំណុចទាំងអស់ដូចខាងក្រោម៖

(1) សេចក្តីសង្ខេបអំពីលទ្ធផលនៃការស្រាវជ្រាវរបស់អ្នកទទួលជំនួយមូលនិធិកាលពីមុន រួមទាំងវិស័យស្រាវជ្រាវថ្មីៗដែលមានសក្តានុពល។

(2) ចំនួន និងចំនួនទឹកប្រាក់ជាដុល្លារនៃជំនួយឥតសំណងមូលនិធិសម្រាប់ការស្រាវជ្រាវដែលបានបែងចែកក្នុងឆ្នាំនោះ។

(3) អ្នកទទួលជំនួយមូលនិធិសម្រាប់ឆ្នាំមុន និងរបាយការណ៍អំពីវឌ្ឍនភាព និងសមិទ្ធផលនៃការស្រាវជ្រាវរបស់ពួកគេរហូតមកដល់បច្ចុប្បន្ន។

(4) ការវាយតម្លៃអំពីទំនាក់ទំនងរវាងជំនួយឥតសំណងមូលនិធិរបស់ក្រុមប្រឹក្សា និងយុទ្ធសាស្ត្ររួមនៃកម្មវិធីស្រាវជ្រាវរបស់ក្រុមប្រឹក្សា។

(5) របាយការណ៍អំពីផែនការស្រាវជ្រាវជាយុទ្ធសាស្ត្រ និងផែនការហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា។

(6) សេចក្តីសង្ខេបអំពីការចំណាយផ្នែករដ្ឋបាលរបស់ក្រុមប្រឹក្សា។

(c) របាយការណ៍ប្រចាំឆ្នាំត្រូវផ្សព្វផ្សាយនៅលើគេហទំព័រអ៊ីនធឺណិតរបស់ក្រុមប្រឹក្សា។

130361. (a) វិទ្យាស្ថានត្រូវជួលក្រុមហ៊ុនគណនេយ្យសាធារណៈដែលមានការបញ្ជាក់វិញ្ញាបនបត្រ ជារៀងរាល់ឆ្នាំ ដើម្បីធ្វើសវនកម្មហិរញ្ញវត្ថុដោយ

38

ឯករាជ្យលើសកម្មភាពរបស់ខ្លួន ហើយរបាយការណ៍សវនកម្មនោះត្រូវផ្តល់ជូនអ្នកត្រួតពិនិត្យហិរញ្ញវត្ថុរបស់រដ្ឋ។ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុរបស់រដ្ឋ ត្រូវពិនិត្យសវនកម្មនោះ ហើយត្រូវចេញផ្សាយរបាយការណ៍ជាសាធារណៈអំពីការពិនិត្យនោះជារៀងរាល់ឆ្នាំ។ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុរបស់រដ្ឋ ត្រូវរៀបចំកិច្ចប្រជុំសាធារណៈ ដោយមានការជូនដំណឹងសមស្របនិងរយៈពេលផ្លូវការសម្រាប់សាធារណជនផ្តល់មតិយោបល់។ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុរបស់រដ្ឋ ត្រូវវាយតម្លៃមតិយោបល់ជាសាធារណៈ ហើយត្រូវបញ្ចូលសេចក្តីសង្ខេបសមស្របនៃមតិយោបល់ទាំងនោះទៅក្នុងរបាយការណ៍ប្រចាំឆ្នាំ។

(b) ក្រុមប្រឹក្សាត្រូវជួលក្រុមហ៊ុនគណនេយ្យសាធារណៈដែលមានការបញ្ជាក់វិញ្ញាបនបត្រមួយ ឬច្រើន ជារៀងរាល់ឆ្នាំ ដើម្បីធ្វើសវនកម្មហិរញ្ញវត្ថុដោយឯករាជ្យលើសកម្មភាពរបស់ខ្លួន និងសកម្មភាពរបស់អ្នកទទួលជំនួយមូលនិធិចំនួន 10 ភាគរយ ដែលត្រូវបានជ្រើសរើសដោយចៃដន្យ ហើយបានចំណាយមូលនិធិជំនួយតាមជំពូកនេះក្នុងអំឡុងពេលដែលស្ថិតក្រោមការធ្វើសវនកម្ម។ សវនកម្មហិរញ្ញវត្ថុដោយឯករាជ្យទាំងនោះ ត្រូវផ្តល់ជូនអ្នកត្រួតពិនិត្យហិរញ្ញវត្ថុរបស់រដ្ឋ ដែលត្រូវពិនិត្យសវនកម្មទាំងនោះ ហើយត្រូវចេញផ្សាយរបាយការណ៍ជាសាធារណៈអំពីការពិនិត្យនោះជារៀងរាល់ឆ្នាំ។ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុរបស់រដ្ឋ ត្រូវពិនិត្យសវនកម្មនោះ ហើយត្រូវចេញផ្សាយរបាយការណ៍ជាសាធារណៈអំពីការពិនិត្យនោះជារៀងរាល់ឆ្នាំ។ អ្នកត្រួតពិនិត្យហិរញ្ញវត្ថុរបស់រដ្ឋ ត្រូវវាយតម្លៃមតិយោបល់ជាសាធារណៈ ហើយត្រូវបញ្ចូលសេចក្តីសង្ខេបសមស្របនៃមតិយោបល់ទាំងនោះទៅក្នុងរបាយការណ៍ប្រចាំឆ្នាំ។

130362. (a) (1) ត្រូវមានគណៈកម្មាធិការត្រួតពិនិត្យគណនេយ្យភាពហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋ ដែលមានសមាជិកចំនួនប្រាំមួយរូប។

(2) អគ្គសវនករដ្ឋ California ហិរញ្ញិក ប្រធានព្រឹទ្ធសភាបណ្តោះអាសន្ន ប្រធានសភាតំណាងរាស្ត្រ និងប្រធានក្រុមប្រឹក្សា ត្រូវតែងតាំងសមាជិកសាធារណៈម្នាក់ៗឱ្យចូលបម្រើការនៅក្នុងគណៈកម្មាធិការ។

(3) អ្នកត្រួតពិនិត្យហិរញ្ញវត្ថុរបស់រដ្ឋ ឬបុគ្គលដែលត្រូវបានអ្នកត្រួតពិនិត្យហិរញ្ញវត្ថុរបស់រដ្ឋចាត់តាំង ត្រូវបម្រើការជាប្រធានគណៈកម្មាធិការ។

(b) គណៈកម្មាធិការត្រូវអនុវត្តកិច្ចការទាំងអស់ដូចខាងក្រោម៖

(1) ពិនិត្យសវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានរៀបចំអនុលោមតាមមាត្រាទី 130361 របាយការណ៍របស់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុរបស់រដ្ឋអំពីសវនកម្មទាំងនោះ និងការអនុវត្តផ្នែកហិរញ្ញវត្ថុរបស់វិទ្យាស្ថាន និងក្រុមប្រឹក្សា។

(2) ចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំដែលរួមមានអនុសាសន៍ស្តីពីការអនុវត្តផ្នែកហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការផ្នែកហិរញ្ញវត្ថុរបស់វិទ្យាស្ថាន និងក្រុមប្រឹក្សា។

(3) ពិនិត្យ និងវាយតម្លៃមតិយោបល់ពីសាធារណជន ហើយបញ្ចូលសេចក្តីសង្ខេបដែលសមស្របនៃមតិយោបល់ទាំងនោះនៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។

(c) គណៈកម្មាធិការត្រូវរៀបចំកិច្ចប្រជុំជាសាធារណៈ ដោយផ្តល់ការជូនដំណឹងជាមុនតាមការសមស្រប និងត្រូវមានរយៈពេលផ្លូវការសម្រាប់សាធារណជនផ្តល់មតិយោបល់។

(d) មន្ត្រីត្រួតពិនិត្យត្រូវផ្តល់ការគាំទ្រពីបុគ្គលិកដល់គណៈកម្មាធិការ ដើម្បីជួយឱ្យគណៈកម្មាធិការអនុវត្តការងាររបស់ខ្លួន។

130363. (a) ទោះបីមានបទប្បញ្ញត្តិច្បាប់ផ្សេងទៀតចែងផ្ទុយពីនេះក៏ដោយ ក៏វិទ្យាស្ថានមិនត្រូវបានចាត់ទុកថាជាស្ថាប័នសាធារណៈសម្រាប់គោលបំណងណាមួយក្រោមច្បាប់រដ្ឋឡើយ រួមមានជាអាទិ៍ បញ្ញត្តិនៃផ្នែក 10 (ចាប់ផ្តើមពីមាត្រាទី 7920.000) នៃចំណងជើង 1 អត្ថបទ 9 (ចាប់ផ្តើមពីមាត្រាទី 11120) នៃជំពូក 1 នៃផ្នែក 1 នៃភាគ 3 នៃចំណងជើង 2 និងចំណងជើង 9 (ចាប់ផ្តើមពីមាត្រាទី 81000) នៃក្រមរដ្ឋាភិបាល។

(b) ច្បាប់កំណែទម្រង់នយោបាយ ឆ្នាំ 1974 (ចំណងជើង 9 (ចាប់ផ្តើមពីមាត្រាទី 81000) នៃក្រមរដ្ឋាភិបាល) ត្រូវអនុវត្តចំពោះក្រុមប្រឹក្សាលើកលែងតែមានចែងផ្សេងក្នុងមាត្រានេះ។

(1) សមាជិកក្រុមប្រឹក្សាមិនត្រូវធ្វើ ឬចូលរួមក្នុងការធ្វើសេចក្តីសម្រេច ឬប្រើតួនាទីផ្លូវការរបស់ខ្លួនក្នុងមធ្យោបាយណាមួយ ដើម្បីព្យាយាមមានឥទ្ធិពលលើសេចក្តីសម្រេចអនុម័ត ឬផ្តល់ជំនួយឥតសំណង ឬកិច្ចសន្យាដល់និយោជករបស់ខ្លួនឡើយ។ ប៉ុន្តែ សមាជិកអាចចូលរួមក្នុងសេចក្តីសម្រេចអនុម័ត ឬផ្តល់ជំនួយឥតសំណង ឬកិច្ចសន្យាដល់អង្គភាពមួយដែលប្រតិបត្តិការក្នុងវិស័យដូចគ្នានឹងនិយោជករបស់ខ្លួន។

(2) សមាជិកក្រុមប្រឹក្សាអាចចូលរួមក្នុងសេចក្តីសម្រេចអនុម័ត ឬផ្តល់ជំនួយឥតសំណង ឬកិច្ចសន្យាដល់អង្គភាពមួយ សម្រាប់គោលបំណងស្រាវជ្រាវពាក់ព័ន្ធនឹងជំងឺដែលសមាជិកនោះ ឬសមាជិកក្នុងគ្រួសាររបស់ខ្លួនកំពុងរងគ្រោះដោយសារជំងឺនោះ។

(3) ការអនុម័តស្តង់ដាទូទៅពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសនិងអាទិភាពនៃការស្រាវជ្រាវ មិនត្រូវចាត់ទុកថាជាសេចក្តីសម្រេចដែលស្ថិតក្រោមការហាមឃាត់ពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ឡើយ។

(c) (1) ការបំពេញតួនាទីជាសមាជិកក្រុមប្រឹក្សា ដោយសមាជិកមហាវិទ្យាល័យ ឬបុគ្គលិករដ្ឋបាលនៃប្រព័ន្ធណាមួយរបស់សាកលវិទ្យាល័យ California មិនត្រូវចាត់ទុកដោយខ្លួនវាផ្ទាល់ថា មិនស្រប មិនអាចរួមបញ្ចូលបាន មានទំនាស់ជាមួយ ឬផ្ទុយនឹងភារកិច្ចរបស់សមាជិកក្រុមប្រឹក្សានោះក្នុងនាមជាសមាជិកមហាវិទ្យាល័យ ឬបុគ្គលិករដ្ឋបាលនៃប្រព័ន្ធណាមួយរបស់សាកលវិទ្យាល័យ California ឡើយ ហើយក៏មិនត្រូវបណ្តាលឱ្យតំណែងណាមួយក្នុងចំណោមតំណែងទាំងពីរនោះត្រូវបានចាត់ទុកថាទំនេរដោយស្វ័យប្រវត្តិឡើយ។

(2) ការបំពេញតួនាទីជាសមាជិកក្រុមប្រឹក្សាដោយតំណាង ឬនិយោជិតនៃស្ថាប័នសិក្សា ឬស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញ មិនត្រូវចាត់ទុកថាមិនស្រប មិនអាចរួមបញ្ចូលបាន មានទំនាស់ជាមួយ ឬផ្ទុយនឹងភារកិច្ចរបស់សមាជិកក្រុមប្រឹក្សានោះ ក្នុងនាមជាតំណាង ឬនិយោជិតនៃអង្គការ ឬស្ថាប័ននោះឡើយ។

(d) មាត្រាទី 1090 នៃក្រមរដ្ឋាភិបាល មិនត្រូវអនុវត្តចំពោះជំនួយឥតសំណង ឬកិច្ចសន្យាណាមួយដែលធ្វើឡើងដោយក្រុមប្រឹក្សាឡើយ លើកលែងតែមានលក្ខខណ្ឌទាំងពីរខាងក្រោមត្រូវបានបំពេញ៖

(1) ជំនួយឥតសំណង ឬកិច្ចសន្យានោះ ត្រូវពាក់ព័ន្ធដោយផ្ទាល់នឹងសេវាកម្មដែលត្រូវផ្តល់ដោយសមាជិកក្រុមប្រឹក្សាណាម្នាក់ ឬដោយអង្គភាពដែលសមាជិកនោះតំណាងឱ្យ ឬផ្តល់ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុដល់សមាជិកនោះ ឬអង្គភាពដែលសមាជិកនោះតំណាងឱ្យ។

(2) សមាជិកក្រុមប្រឹក្សាមិនដកខ្លួនចេញពីការធ្វើសេចក្តីសម្រេច ការចូលរួមក្នុងការធ្វើសេចក្តីសម្រេច ឬការព្យាយាមប្រើតួនាទីផ្លូវការរបស់ខ្លួនក្នុងមធ្យោបាយណាមួយ ដើម្បីមានឥទ្ធិពលលើសេចក្តីសម្រេចពាក់ព័ន្ធនឹងជំនួយឥតសំណង ឬកិច្ចសន្យានោះឡើយ។

130364. ក្រសួងអាចទទួលយក កែប្រែ និងលុបចោលច្បាប់ និងបទបញ្ញត្តិ ដើម្បីអនុវត្តគោលបំណង និងបទបញ្ញត្តិនៃជំពូកនេះ។

ជំពូកទី 2. ច្បាប់ស្តីពីមូលបត្របំណុលរដ្ឋ California ស្តីពីប្រព័ន្ធភាពស៊ាំ និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំ ឆ្នាំ 2026

130370. ជំពូកនេះត្រូវបានស្គាល់ថា និងអាចយោងដោយប្រើឈ្មោះថា "ច្បាប់ស្តីពីមូលបត្របំណុលរដ្ឋ California ស្តីពីប្រព័ន្ធភាពស៊ាំ និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំ ឆ្នាំ 2026"។

130371. សម្រាប់គោលបំណងនៃជំពូកនេះ ពាក្យខាងក្រោមសំដៅដូចខាងក្រោម៖

(a) "ក្រុមប្រឹក្សា" មានន័យថា ក្រសួងសុខភាពសាធារណៈរបស់រដ្ឋ ដែលត្រូវបានកំណត់តាមផ្នែករង (b) នៃមាត្រាទី 130375។

(b) "គណៈកម្មាធិការ" មានន័យថា គណៈកម្មាធិការហិរញ្ញវត្ថុស្តីពីប្រព័ន្ធភាពស៊ាំ និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំនៃរដ្ឋ California ដែលត្រូវបានបង្កើតឡើងស្របអនុលោមតាមផ្នែករង (a) នៃមាត្រាទី 130375។

(c) "មូលនិធិ" មានន័យថា មូលនិធិស្រាវជ្រាវវេជ្ជសាស្ត្រផ្នែកភាពស៊ាំវិទ្យា និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំនៃរដ្ឋ California ដែលត្រូវបានបង្កើតឡើងតាមមាត្រាទី 130377។

(d) "ច្បាប់ស្តីពីមូលបត្របំណុលជាប់កាតព្វកិច្ចទូទៅរបស់រដ្ឋ" មានន័យថា ច្បាប់ស្តីពីមូលបត្របំណុលជាប់កាតព្វកិច្ចទូទៅរបស់រដ្ឋ ដែលមានចែងក្នុងជំពូក 4 (ចាប់ផ្តើមពីមាត្រាទី 16720) នៃផ្នែកទី 3 នៃភាគ 4 នៃចំណងជើង

2 នៃក្រមរដ្ឋាភិបាល ដោយរួមបញ្ចូលទាំងការធ្វើវិសោធនកម្មច្បាប់នោះជាបន្តបន្ទាប់តាមពេលវេលា។

130372. (a) មូលបត្របំណុលដែលមានទឹកប្រាក់សរុបចំនួន ប្រាំបីពាន់បួនរយលានដុល្លារ ($8,400,000,000) ដោយមិនរាប់បញ្ចូលទឹកប្រាក់នៃមូលបត្របំណុលសម្រាប់ការសងជំនួសណាមួយដែលបានចេញស្របតាមមាត្រាទី 130383 ឬចំនួនណាមួយនៃទឹកប្រាក់នោះដែលចាំបាច់ អាចត្រូវបានចេញ និងលក់ ដើម្បីផ្តល់មូលនិធិសម្រាប់អនុវត្តគោលបំណងដែលបានចែងក្នុងផ្នែកនេះ និងដើម្បីសងប្រាក់ជូន មូលនិធិវិលជុំសម្រាប់ចំណាយលើមូលបត្របំណុលកាតព្វកិច្ចទូទៅ ស្របអនុលោមតាមមាត្រាទី 16724.5 នៃក្រមរដ្ឋាភិបាល។

(b) នៅពេលមូលបត្របំណុលត្រូវបានលក់ ចេញ និងប្រគល់រួចហើយ មូលបត្របំណុលទាំងនោះត្រូវចាត់ទុកថាជា កាតព្វកិច្ចស្របច្បាប់ និងមានអានុភាពចងភ្ជាប់របស់រដ្ឋ California ហើយ កេរ្តិ៍ឈ្មោះ និងឥណទានពេញលេញរបស់រដ្ឋ ត្រូវបានដាក់ជាការធានា ដើម្បីធានាការទូទាត់ទាំងប្រាក់ដើម និងការប្រាក់ លើមូលបត្របំណុលទាំងនេះឱ្យបានទាន់ពេលវេលា នៅពេលប្រាក់ដើម និងការប្រាក់នោះដល់កំណត់ និងត្រូវបង់។

(c) ហិរញ្ញិកត្រូវចេញ និង លក់មូលបត្របំណុលដែល ត្រូវបានអនុញ្ញាតនៅក្នុងកថាផ្នែករង (a) ក្នុងចំនួនទឹកប្រាក់ដែល គណៈកម្មាធិការកំណត់ថា ចាំបាច់ ឬគួរឱ្យចង់បាន អនុលោមតាមមាត្រាទី 130376។ មូលបត្របំណុលត្រូវចេញ និងលក់តាមលក្ខខណ្ឌ និងបញ្ជត្តិ ដែលបានកំណត់នៅក្នុងសេចក្តីសម្រេចដែលត្រូវអនុម័តដោយគណៈកម្មាធិការ ស្របតាមមាត្រាទី 130376។

130373. ដោយមិនគិតពីមាត្រាទី 13340 នៃ ក្រមរដ្ឋាភិបាល ឬបទប្បញ្ញត្តិច្បាប់ផ្សេងទៀត ឬដោយមិនគិតពីបទប្បញ្ញត្តិណាមួយនៃច្បាប់ក៏ដោយ ថវិកាដែលមាននៅក្នុងមូលនិធិត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយមិនកំណត់តាមឆ្នាំសារពើពន្ធ សម្រាប់គោលបំណងដូចខាងក្រោម៖

(a) ការធ្វើការស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រ ក្នុងវិស័យប្រព័ន្ធភាពស៊ាំ និង ការព្យាបាលដោយប្រព័ន្ធភាពស៊ាំ ដូចដែលបានពិពណ៌នានៅក្នុងជំពូក 1 (ចាប់ផ្តើមពីមាត្រាទី 130350) រួមទាំង ចំណាយទាំងឡាយដែលកើតឡើងសម្រាប់ការគាំទ្រ និងការគ្រប់គ្រងការស្រាវជ្រាវនោះ។

(b) ការទូទាត់ចំណាយដែលពាក់ព័ន្ធនឹងការចេញមូលបត្របំណុល។

(c) ការទូទាត់ចំណាយ ឬថ្លៃចំណាយផ្សេងទៀត ដែលបានពិពណ៌នា ឬអនុញ្ញាតឱ្យមាននៅក្នុងផ្នែកនេះ និងនៅក្នុង ច្បាប់ស្តីពីមូលបត្របំណុលជាប់កាតព្វកិច្ចទូទៅរបស់រដ្ឋ។

130374. មូលបត្របំណុលដែលត្រូវបានអនុញ្ញាតដោយជំពូកនេះ នឹងត្រូវបានរៀបចំ ចុះហត្ថលេខា/អនុវត្ត ចេញ លក់ ទូទាត់ និងសងរំលស់តាមដែលបានកំណត់នៅក្នុង ច្បាប់ស្តីពីមូលបត្របំណុលជាប់កាតព្វកិច្ចទូទៅរបស់រដ្ឋ ហើយបទប្បញ្ញត្តិទាំងអស់នៃច្បាប់នោះត្រូវអនុវត្តចំពោះមូលបត្របំណុលទាំងនេះ និងចំពោះជំពូកនេះ ហើយត្រូវបាន បញ្ចូលជាផ្នែកមួយនៃជំពូកនេះ ដូចជាបានចែងពេញលេញនៅក្នុងជំពូកនេះ លើកលែងតែ ផ្នែករង (a) និង (b) នៃមាត្រាទី 16727 នៃក្រមរដ្ឋាភិបាល មិនត្រូវអនុវត្តឡើយ។

130375. (a) (1) គណៈកម្មាធិការហិរញ្ញវត្ថុសម្រាប់ប្រព័ន្ធភាពស៊ាំ និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំរដ្ឋ California ត្រូវបានបង្កើតឡើងតាមច្បាប់នេះ ក្នុងគោលបំណងតែមួយគត់ គឺដើម្បីអនុញ្ញាតឱ្យមានការចេញ និងលក់មូលបត្របំណុលដែលត្រូវបានអនុញ្ញាតដោយជំពូកនេះស្របតាម ច្បាប់ស្តីពីមូលបត្របំណុលជាប់កាតព្វកិច្ចទូទៅរបស់រដ្ឋ។ សម្រាប់គោលបំណងនៃជំពូកនេះ គណៈកម្មាធិការហិរញ្ញវត្ថុសម្រាប់ប្រព័ន្ធភាពស៊ាំ និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំរដ្ឋ California គឺជា "គណៈកម្មាធិការ" ដូចដែលពាក្យនេះត្រូវបានប្រើនៅក្នុង ច្បាប់ស្តីពីមូលបត្របំណុលជាប់កាតព្វកិច្ចទូទៅរបស់រដ្ឋ។

(2) គណកម្មាធិការនេះមានហិរញ្ញិក មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងនាយកហិរញ្ញវត្ថុ។

(3) ហិរញ្ញិកត្រូវមានតួនាទីជាប្រធានគណៈកម្មាធិការ។

(4) គណៈកម្មាធិការមួយភាគធំអាចធ្វើសកម្មភាពសម្រាប់គណៈកម្មាធិការ។

(5) ដោយមិនរាប់បញ្ចូលច្បាប់ផ្សេងទៀតឡើយសមាជិកគណៈកម្មាធិការម្នាក់អាចចាត់តាំងតំណាងឱ្យដើរតួជាសមាជិកនោះនៅកន្លែងរបស់សមាជិកដូចជាសមាជិកមានវត្តមានផ្ទាល់ សម្រាប់គោលបំណងរួម។

(b) ក្រសួងសុខាភិបាលសាធារណៈរបស់រដ្ឋ ត្រូវបានកំណត់ជា "ក្រុមប្រឹក្សា" សម្រាប់គោលបំណងនៃ ច្បាប់ស្តីពីមូលបត្របំណុលជាប់កាតព្វកិច្ចទូទៅរបស់រដ្ឋ។

130376. (a) នៅពេលទទួលបាន សំណើជាលាយលក្ខណ៍អក្សរ ពីវិទ្យាស្ថានស្រាវជ្រាវដែលត្រូវបានជ្រើសរើសដោយ ក្រសួងសុខាភិបាលសាធារណៈរបស់រដ្ឋ អនុលោមតាមមាត្រាទី 130353 ដោយបញ្ជាក់ថាត្រូវការមូលនិធិដើម្បីអនុវត្តគោលបំណងនៃជំពូកទី 1 (ចាប់ផ្តើមពីមាត្រាទី 130350) ក្រុមប្រឹក្សា ត្រូវស្នើសុំឱ្យ គណៈកម្មាធិការ ចេញមូលបត្របំណុលស្របតាមជំពូកនេះ។ នៅពេលទទួលបានសំណើនោះពីក្រុមប្រឹក្សា គណៈកម្មាធិការ ត្រូវកំណត់តាមរយៈ សេចក្តីសម្រេច ថាតើចាំបាច់ ឬគួរឱ្យចង់បាន ឬមិនចាំបាច់ ឬមិនគួរឱ្យចង់បាន ក្នុងការចេញ និងលក់មូលបត្របំណុលដែលត្រូវបានអនុញ្ញាតអនុលោមតាមជំពូកនេះ ដើម្បីអនុវត្តសកម្មភាពដែលបានកំណត់ក្នុងជំពូកនេះ ហើយប្រសិនបើចាំបាច់ ឬគួរឱ្យចង់បាន ត្រូវកំណត់ ចំនួនទឹកប្រាក់នៃមូលបត្របំណុលដែលត្រូវចេញ និងលក់។

(b) អាចអនុញ្ញាតឱ្យមានការចេញ និងលក់ មូលបត្របំណុលជាបន្តបន្ទាប់ដើម្បីអនុវត្តគោលបំណងនៃជំពូកទី 1 (ចាប់ផ្តើមពីមាត្រាទី 130350) ជាបន្តបន្ទាប់តាមដំណាក់កាល ហើយមិនចាំបាច់ឱ្យមូលបត្របំណុលទាំងអស់ត្រូវបានចេញ ឬលក់ក្នុងពេលតែមួយនោះទេ។

(c) មូលបត្របំណុលអាចមានការប្រាក់ដែល ត្រូវរាប់បញ្ចូលក្នុងប្រាក់ចំណូលសរុបសម្រាប់គោលបំណងពន្ធលើប្រាក់ចំណូលសហព័ន្ធ ប្រសិនបើគណៈកម្មាធិការកំណត់ថា ការអនុវត្តបែបនេះមានភាពចាំបាច់ ឬគួរឱ្យចង់បាន ដើម្បីផ្តល់មូលនិធិសម្រាប់គោលបំណងនៃជំពូកទី 1 (ចាប់ផ្តើមពីមាត្រាទី 130350)។

130377. ប្រាក់ចំណូលដែលបានមកពីការចេញ និងលក់មូលបត្របំណុលអនុលោមតាមជំពូកនេះ ត្រូវដាក់បញ្ចូលក្នុង រតនាគាររដ្ឋ ដើម្បីកត់ត្រាចូលក្នុង មូលនិធិស្រាវជ្រាវវេជ្ជសាស្ត្រផ្នែកប្រព័ន្ធភាពស៊ាំ និងការព្យាបាលដោយប្រព័ន្ធភាពស៊ាំរដ្ឋ California ដែលត្រូវបានបង្កើតឡើងនៅក្នុងរតនាគាររដ្ឋតាមច្បាប់នេះ។

130378. ជារៀងរាល់ឆ្នាំ ត្រូវប្រមូលចំនួនទឹកប្រាក់មួយតាមរបៀបដូចគ្នា និងនៅពេលដូចគ្នានឹងការប្រមូលចំណូលរដ្ឋផ្សេងទៀត ដោយបន្ថែមពីលើចំណូលធម្មតារបស់រដ្ឋ ក្នុងចំនួនដែលតម្រូវឱ្យគ្រប់គ្រាន់សម្រាប់ទូទាត់ប្រាក់ដើម និងការប្រាក់លើមូលបត្របំណុល ដែលដល់កំណត់ត្រូវបង់ក្នុងឆ្នាំនីមួយៗ។ វាជាកាតព្វកិច្ចរបស់មន្ត្រីទាំងអស់ ដែលច្បាប់បានប្រគល់ភារកិច្ចឱ្យទាក់ទងនឹងការប្រមូលចំណូល ត្រូវចាត់ចែង និងអនុវត្ត គ្រប់សកម្មភាពទាំងអស់ដែលចាំបាច់ ដើម្បីប្រមូលចំនួនទឹកប្រាក់បន្ថែមនោះ។

130379. ដោយមិនគិតពីមាត្រាទី 13340 នៃក្រមរដ្ឋាភិបាល មានការអនុញ្ញាតឱ្យប្រើប្រាស់ជាបន្តបន្ទាប់ពីមូលនិធិទូទៅនៅក្នុង រតនាគាររដ្ឋ សម្រាប់គោលបំណងនៃជំពូកនេះ និងដោយមិនកំណត់តាមឆ្នាំសារពើពន្ធនូវចំនួនទឹកប្រាក់មួយដែលស្មើនឹង ផលបូកសរុបនៃចំនួនទឹកប្រាក់ដូចខាងក្រោម៖

(a) ចំនួនទឹកប្រាក់ដែលចាំបាច់ជារៀងរាល់ឆ្នាំ ដើម្បីទូទាត់ប្រាក់ដើម និងការប្រាក់លើប័ណ្ណបំណុលដែលបានចេញ និងលក់អនុលោមតាមជំពូកនេះនៅពេលដែលប្រាក់ដើម និងការប្រាក់ទាំងនោះដល់កំណត់ និងត្រូវទូទាត់។

(b) ផលបូកចាំបាច់ដើម្បីអនុវត្តមាត្រាទី 130380 ។

130380. សម្រាប់គោលបំណងអនុវត្តជំពូកនេះ នាយកហិរញ្ញវត្ថុ អាចអនុញ្ញាតឱ្យដកប្រាក់ចេញពីមូលនិធិទូទៅក្នុងចំនួនមិនលើសពីចំនួនទឹកប្រាក់នៃ មូលបត្របំណុលដែលមិនទាន់បានលក់ ដែលគណៈកម្មាធិការបានអនុញ្ញាតឱ្យលក់សម្រាប់គោលបំណងអនុវត្តជំពូកនេះ ដោយ មិនរាប់បញ្ចូលមូលបត្របំណុលសម្រាប់ការសងជំនួស ដែលបានអនុញ្ញាតអនុលោមតាមមាត្រាទី 130383 បន្ទាប់ពីដកចេញនូវចំនួនទឹកប្រាក់ណាមួយដែលបានផ្តល់ជាប្រាក់កម្ចីអនុលោមតាមមាត្រាទី 130381 និង

មិនទាន់បានសងត្រឡប់វិញ ព្រមទាំងចំនួនទឹកប្រាក់ណាមួយដែលបានដកចេញពីមូលនិធិទូទៅស្របតាមមាត្រានេះ និង មិនទាន់បានប្រគល់ត្រឡប់ចូលមូលនិធិទូទៅវិញ។ ចំនួនទឹកប្រាក់ណាមួយដែលបានដកចេញនឹងត្រូវដាក់តម្កល់ទៅក្នុងមូលនិធិ។ ប្រាក់ណាមួយដែលត្រូវបានផ្តល់ឱ្យប្រើប្រាស់ស្របតាមមាត្រានេះ ត្រូវប្រគល់ត្រឡប់ទៅមូលនិធិទូទៅវិញ រួមទាំងចំនួនទឹកប្រាក់មួយដែលស្មើនឹង ការប្រាក់ដែលប្រាក់នោះនឹងទទួលបាន ប្រសិនបើប្រាក់នោះបានរក្សាទុកនៅក្នុងគណនីវិនិយោគប្រាក់រួម ដោយយកពីប្រាក់ដែលទទួលបានពីការលក់មូលបត្របំណុលសម្រាប់គោលបំណងអនុវត្តជំពូកនេះ។

130381. ក្រុមប្រឹក្សា អាចស្នើសុំ ក្រុមប្រឹក្សាវិនិយោគប្រាក់រួមឱ្យផ្តល់ប្រាក់កម្ចីពី គណនីវិនិយោគប្រាក់រួម អនុលោមតាមមាត្រាទី 16312 នៃក្រមរដ្ឋាភិបាល សម្រាប់គោលបំណងអនុវត្តជំពូកនេះ។ ចំនួនទឹកប្រាក់នៃសំណើ មិនត្រូវលើសពីចំនួនទឹកប្រាក់នៃ មូលបត្របំណុលដែលមិនទាន់បានលក់ ដែលគណៈកម្មាធិការបានអនុញ្ញាតតាមរយៈសេចក្តីសម្រេចឱ្យលក់សម្រាប់គោលបំណងអនុវត្តជំពូកនេះឡើយ ដោយមិនរាប់បញ្ចូល មូលបត្របំណុលសម្រាប់ការសងជំនួស ដែលបានអនុញ្ញាតអនុលោមតាមមាត្រាទី 130383 ហើយត្រូវដកចេញនូវ ចំនួនទឹកប្រាក់ណាមួយដែលបានផ្តល់ជាប្រាក់កម្ចីស្របតាមមាត្រានេះ និងមិនទាន់បានសងត្រឡប់វិញ និង ចំនួនទឹកប្រាក់ណាមួយដែលបានដកចេញពីមូលនិធិទូទៅអនុលោមតាមមាត្រាទី 130380 និងមិនទាន់បានប្រគល់ត្រឡប់ទៅមូលនិធិទូទៅវិញ។ ក្រុមប្រឹក្សាត្រូវចុះហត្ថលេខា និងបំពេញ ឯកសារទាំងអស់ដែលតម្រូវដោយក្រុមប្រឹក្សាវិនិយោគប្រាក់ដែលប្រមូលផ្តុំរួមគ្នា ដើម្បីទទួលបាន និងសងត្រឡប់ប្រាក់កម្ចី។ ចំនួនទឹកប្រាក់ណាមួយដែលត្រូវបានផ្តល់ជាប្រាក់កម្ចី ត្រូវដាក់បញ្ចូលទៅក្នុងមូលនិធិ ដើម្បីឱ្យក្រុមប្រឹក្សាបែងចែកស្របតាមជំពូកនេះ។

130382. ប្រាក់ទាំងអស់ដែលបានដាក់បញ្ចូលទៅក្នុង មូលនិធិ ហើយដែលបានមកពី ប្រាក់បុព្វលាភ និងការប្រាក់បង្គរ លើមូលបត្របំណុលដែលបានលក់អនុលោមតាមជំពូកនេះ ត្រូវ រក្សាទុកនៅក្នុងមូលនិធិ ហើយត្រូវមានសម្រាប់ផ្ទេរទៅមូលនិធិទូទៅ ដើម្បីកត់ជាតណាទានចំពោះ ចំណាយលើការប្រាក់នៃមូលបត្របំណុល លើកលែងតែចំនួនទឹកប្រាក់ដែលបានមកពីប្រាក់បុព្វលាភ អាចត្រូវបានរក្សាទុក និងប្រើប្រាស់ដើម្បីទូទាត់ ចំណាយលើការចេញមូលបត្របំណុល មុនពេលផ្ទេរទៅមូលនិធិទូទៅ។

130383. (a) មូលបត្របំណុលដែលបានចេញ និងលក់អនុលោមតាមជំពូកនេះ អាចត្រូវបានសងជំនួស ឬធ្វើហិរញ្ញប្បទានជំនួស ស្របតាមចំណងជើង 6 (ចាប់ផ្តើមពីមាត្រាទី 16780) នៃជំពូក 4 ផ្នែក 3 ភាគ 4 ចំណងជើង 2 នៃក្រមរដ្ឋាភិបាល។

(b) ការអនុម័តរបស់ អ្នកបោះឆ្នោតរបស់រដ្ឋ ចំពោះការចេញមូលបត្របំណុលដែលបានពិពណ៌នានៅក្នុងជំពូកនេះ រួមបញ្ចូលទាំងការអនុម័តលើការចេញ មូលបត្របំណុលសម្រាប់ការសងជំនួស ដែលត្រូវបានចេញ ដើម្បីសងជំនួសមូលបត្របំណុលណាមួយដែលបានចេញដំបូងស្របតាមជំពូកនេះ ឬមូលបត្របំណុលសម្រាប់ការសងជំនួសណាមួយដែលបានចេញពីមុន។

(c) មូលបត្របំណុលណាមួយដែលត្រូវបានសងជំនួសដោយប្រើប្រាក់ដែលបានមកពី មូលបត្របំណុលសម្រាប់ការសងជំនួស ដូចដែលបានអនុញ្ញាតដោយមាត្រានេះ អាចត្រូវបាន លុបចោលកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងកម្រិតដែលច្បាប់អនុញ្ញាត តាមរបៀប និងក្នុងកម្រិតដែលបានកំណត់នៅក្នុងសេចក្តីសម្រេច ដែលអនុញ្ញាតឱ្យចេញមូលបត្របំណុលដែលត្រូវបានសងជំនួសនោះ ហើយសេចក្តីសម្រេចនោះអាចត្រូវបានធ្វើវិសោធនកម្មពីពេលមួយទៅពេលមួយ។

130384. ដោយមិនគិតពីបទបញ្ញត្តិណាមួយនៃជំពូកនេះ ឬច្បាប់ស្តីពីមូលបត្របំណុលជាប់កាតព្វកិច្ចទូទៅរបស់រដ្ឋ ប្រសិនបើហិរញ្ញិកលក់មូលបត្របំណុលអនុលោមតាមជំពូកនេះ ដែលរួមមានមតិយោបល់របស់មេធាវីផ្នែកមូលបត្របំណុល ដែលមានខ្លឹមសារថា ការប្រាក់លើមូលបត្របំណុលទាំងនោះ ត្រូវបានលើកលែងមិនឱ្យរាប់បញ្ចូលក្នុងប្រាក់ចំណូលសរុបសម្រាប់គោលបំណងពន្ធសហព័ន្ធ ក្រោមលក្ខខ័ណ្ឌដែលបានកំណត់ ឬមានសិទ្ធិទទួលបានអត្ថប្រយោជន៍ពន្ធសហព័ន្ធផ្សេងទៀត ហិរញ្ញិកអាចរក្សាគណនីដាច់ដោយឡែកពីគ្នា សម្រាប់ការវិនិយោគប្រាក់ដែលបានមកពីមូលបត្របំណុល និងសម្រាប់ការវិនិយោគប្រាក់ចំណូលដែលទទួលបានពីការវិនិយោគប្រាក់ទាំងនោះ។ ហិរញ្ញិកអាចប្រើប្រាស់ ឬណែនាំការប្រើប្រាស់ប្រាក់ចំណេញ ឬប្រាក់ចំណូលទាំងនោះ ដើម្បីបង់រំលោះ ការផាកពិន័យ ឬការទូទាត់ផ្សេងទៀតដែលត្រូវការនៅក្រោមច្បាប់សហព័ន្ធ ឬធ្វើសកម្មភាពផ្សេងទៀតទាក់ទងនឹងការវិនិយោគ និងការប្រើប្រាស់មូលបត្របំណុលទាំងនោះដែលត្រូវការ ឬចង់បានក្រោមច្បាប់សហព័ន្ធ ដើម្បីរក្សាស្ថានភាពលើកលែងពន្ធនៃមូលបត្របំណុលទាំងនោះ និងដើម្បីទទួលបានអត្ថប្រយោជន៍ផ្សេងទៀតនៅក្រោមច្បាប់សហព័ន្ធក្នុងនាមមូលនិធិនៃរដ្ឋនេះ។

130385. ប្រាក់ចំណូលបានមកពីការលក់មូលបត្របំណុល ត្រូវបានអនុញ្ញាតដោយជំពូកនេះមិនមែនជា «ប្រាក់ចំណូលពន្ធ» ដូចដែលពាក្យនោះត្រូវបានប្រើនៅក្នុងអត្ថបទ XIII B នៃរដ្ឋធម្មនុញ្ញនៃរដ្ឋ California នោះទេ ហើយការបើកប្រាក់ចំណូលទាំងនេះ មិនស្ថិតក្រោមដែនកំណត់ដែលកំណត់ដោយអត្ថបទនោះទេ។

មាត្រាទី 5. ការបំបែកចេញពីគ្នាបាន។

វាជាគោលបំណងរបស់ប្រជាពលរដ្ឋ ដែលបទប្បញ្ញត្តិនៃច្បាប់នេះអាចបំបែកចេញពីគ្នាបាន ហើយប្រសិនបើបទប្បញ្ញត្តិណាមួយនៃច្បាប់នេះ ឬផ្នែកណាមួយនៃបទបញ្ញត្តិនោះ ត្រូវបានកំណត់ថាមិនមានសុពលភាព នោះការមិនមានសុពលភាពនោះមិនត្រូវប៉ះពាល់ដល់បទប្បញ្ញត្តិផ្សេងទៀតណាមួយនៃច្បាប់នេះ ដែលអាចអនុវត្តឱ្យមានប្រសិទ្ធភាពបានដោយមិនចាំបាច់មានបទបញ្ញត្តិដែលមិនមានសុពលភាពនោះឡើយ។

មាត្រាទី 6. ការបកស្រាយច្បាប់ឱ្យបានទូលំទូលាយ។

ច្បាប់នេះត្រូវបកស្រាយ និងអនុវត្តដោយទូលំទូលាយ ដើម្បីលើកកម្ពស់ និងសម្រេចឱ្យបានពេញលេញនូវគោលបំណងជាមូលដ្ឋានរបស់ច្បាប់នេះ។

មាត្រាទី 7. វិសោធនកម្ម។

បទប្បញ្ញត្តិនៃច្បាប់នេះអាចត្រូវបានធ្វើវិសោធនកម្មដោយច្បាប់មួយដែលត្រូវបានអនុម័តដោយសំឡេងគាំទ្រពីរភាគបីនៃសមាជិកនៃសភានីមួយៗរបស់សភានីតិប្បញ្ញត្តិ និងចុះហត្ថលេខាដោយអភិបាលរដ្ឋ ដោយមានលក្ខខណ្ឌថា វិសោធនកម្មទាំងនោះត្រូវជំរុញគោលបំណងរបស់ច្បាប់នេះបន្ថែមទៀត លើកលែងតែច្បាប់បែបនេះមិនអាចធ្វើវិសោធនកម្មបទបញ្ញត្តិនៃច្បាប់នេះពាក់ព័ន្ធនឹងការបែងចែក និងការបញ្ចេញប្រាក់ដែលបានមកពីមូលបត្របំណុល ឬគោលបំណងដែលប្រាក់ដែលបានមកពីមូលបត្របំណុលអាចត្រូវបានចំណាយសម្រាប់ឡើយ។

សំណើ 39

វិធានការផ្តួចផ្តើមនេះត្រូវបានដាក់ជូនប្រជាពលរដ្ឋដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី 8 នៃអត្ថបទ II នៃរដ្ឋធម្មនុញ្ញរដ្ឋ California។

វិធានការផ្តួចផ្តើមនេះបន្ថែមមាត្រាមួយទៅក្នុងរដ្ឋធម្មនុញ្ញរដ្ឋ California។ ដូច្នេះ បទបញ្ញត្តិថ្មីដែលស្នើឱ្យបន្ថែមត្រូវបានបោះពុម្ពក្នុងទម្រង់ជាប្រភេទ *អក្សរទ្រេត* ដើម្បីបញ្ជាក់ថាច្បាប់ទាំងនោះថ្មី។

ច្បាប់ដែលបានដាក់ស្នើឡើង

ផ្នែកទី 1. ការរកឃើញ និង គោលបំណង។

ដើម្បីអនុវត្តលក្ខណៈសម្បត្តិដែលមានស្រាប់សម្រាប់អ្នកបោះឆ្នោត រួមទាំងលក្ខខណ្ឌសញ្ជាតិអាមេរិក ដែលត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញរដ្ឋ California ប្រជាពលរដ្ឋសូមធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញរដ្ឋ California តាមរយៈនេះ៖ (A) ដើម្បីលើកកម្ពស់ទំនុកចិត្ត និងជំនឿរបស់សាធារណជនលើដំណើរការបោះឆ្នោត ដែលជំរុញឱ្យមានការចូលរួមក្នុងកិច្ចការសាធារណៈ និងគាំទ្រលទ្ធិប្រជាធិបតេយ្យដែលមានសុខភាពល្អ (B) ដើម្បីទប់ស្កាត់ និងរកឃើញការក្លែងបន្លំសន្លឹកឆ្នោត ដោយរក្សាទុកកំណត់ត្រាចុះឈ្មោះអ្នកបោះឆ្នោតឱ្យបានត្រឹមត្រូវ និងបញ្ជាក់ពីលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការបោះឆ្នោត និង (C) ដើម្បីកាត់បន្ថយហានិភ័យនៃការក្លែងធ្វើជាអ្នកបោះឆ្នោតផ្សេងទៀត ដោយតម្រូវឱ្យមានភស្តុតាងបញ្ជាក់អត្តសញ្ញាណ ដើម្បីបោះឆ្នោត។

មាត្រាទី 2. កំណែទម្រង់ការកំណត់អត្តសញ្ញាណអ្នកបោះឆ្នោតរបស់រដ្ឋ California

មាត្រាទី 2.1. មាត្រាទី 3.1 ត្រូវបានបន្ថែមទៅក្នុងអត្ថបទ II នៃរដ្ឋធម្មនុញ្ញរដ្ឋ California ដោយមានខ្លឹមសារដូចតទៅ៖

មាត្រាទី 3.1. (a) រដ្ឋលេខាធិការ និង មន្ត្រីរៀបចំការបោះឆ្នោតតាមខោនធី ត្រូវមានភារកិច្ចរៀងៗខ្លួនក្នុងការរក្សាបញ្ជីចុះឈ្មោះអ្នកបោះឆ្នោតឱ្យបានត្រឹមត្រូវ ត្រូវប្រើប្រាស់កិច្ចខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីផ្ទៀងផ្ទាត់ការបញ្ជាក់អំពីសញ្ជាតិ ដោយប្រើទិន្នន័យរបស់រដ្ឋាភិបាល ហើយត្រូវរាយការណ៍ជារៀងរាល់ឆ្នាំអំពីភាគរយនៃបញ្ជីអ្នកបោះឆ្នោតរបស់ខោនធីនីមួយៗ ដែលត្រូវបានផ្ទៀងផ្ទាត់សញ្ជាតិ។

(b) រាល់ពេលដែលអ្នកបោះឆ្នោតបោះសន្លឹកឆ្នោតដោយផ្ទាល់ក្នុងការបោះឆ្នោតណាមួយនៅក្នុងរដ្ឋ អ្នកបោះឆ្នោតត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណដែលចេញដោយរដ្ឋាភិបាល ឬប្រសិនបើបោះឆ្នោតតាមប្រៃសណីយ៍ អ្នកបោះឆ្នោតត្រូវផ្តល់លេខបួនខ្ទង់ចុងក្រោយនៃលេខសម្គាល់អត្តសញ្ញាណតែមួយគត់ដែលមាននៅលើអត្តសញ្ញាណប័ណ្ណដែលចេញដោយរដ្ឋាភិបាល ហើយលេខនោះត្រូវតែត្រូវគ្នានឹងលេខដែលអ្នកបោះឆ្នោតបានកំណត់សម្រាប់ការចុះឈ្មោះបោះឆ្នោតរបស់ខ្លួន។ ប្រភេទអត្តសញ្ញាណប័ណ្ណដែលអ្នកបោះឆ្នោតនីមួយៗបានកំណត់ ត្រូវបង្ហាញនៅក្នុងកំណត់ត្រាចុះឈ្មោះបោះឆ្នោតរបស់អ្នកបោះឆ្នោតនោះ ត្រូវកត់សម្គាល់នៅលើស្រោមសំបុត្រសន្លឹកឆ្នោតតាមប្រៃសណីយ៍ដែលបានផ្តល់ជូនអ្នកបោះឆ្នោតនោះ និងត្រូវមានផ្តល់ជូនអ្នកបោះឆ្នោតនោះតាមការស្នើសុំតាមទូរសព្ទ ឬតាមប្រព័ន្ធអេឡិចត្រូនិក។ មន្ត្រីរៀបចំការបោះឆ្នោតអាចរាប់សន្លឹកឆ្នោតធម្មតា ឬសន្លឹកឆ្នោតបណ្តោះអាសន្នបាន លុះត្រាតែបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់បុគ្គលដែលបានបោះឆ្នោត ស្របតាមលក្ខខណ្ឌតម្រូវនៃមាត្រានេះ និងបានផ្ទៀងផ្ទាត់ថា បុគ្គលនោះបានបោះសន្លឹកឆ្នោតតែមួយសន្លឹកប៉ុណ្ណោះក្នុងការបោះឆ្នោតនោះ។ អត្តសញ្ញាណប័ណ្ណដែលចេញដោយរដ្ឋាភិបាលមានន័យថា ឯកសារដែលអាចផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នកបោះឆ្នោតបានយ៉ាងច្បាស់លាស់ និងជាក់លាក់។ តាមការស្នើសុំរបស់អ្នកបោះឆ្នោតដែលមានសិទ្ធិបោះឆ្នោត រដ្ឋត្រូវផ្តល់ប័ណ្ណសម្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត ដោយមិនគិតថ្លៃ សម្រាប់ប្រើប្រាស់ក្នុងការបោះសន្លឹកឆ្នោត។

(c) មាត្រានេះត្រូវអនុវត្តដោយខ្លួនឯង។ សភានីតិបញ្ញត្តិត្រូវអនុម័តច្បាប់ជាបន្ទាន់ផងដែរ ដើម្បីអនុវត្តិមាត្រានេះ កំណត់អំពីការបោះឆ្នោតដោយអ្នកបោះឆ្នោតដែលបម្រើការងារក្នុងយោធា និងអ្នកបោះឆ្នោតនៅក្រៅប្រទេសឱ្យស្របតាមច្បាប់សហព័ន្ធ និងធានាថា មន្ត្រីរដ្ឋ និងមន្ត្រីមូលដ្ឋានទាំងអស់គោរពតាម និងគាំទ្រការអនុវត្តឱ្យបានស្របតាមមាត្រានេះ។ ប្រជាពលរដ្ឋអាចស្នើសុំឱ្យតុលាការពិនិត្យតាមផ្លូវតុលាការ និងផ្តល់វិធានការដោះស្រាយតាមផ្លូវច្បាប់ ចំពោះការអនុវត្តឱ្យបានស្របតាមមាត្រានេះរបស់រដ្ឋ ឬខោនធីណាមួយ។ ក្នុងអំឡុងរៀងរាល់ឆ្នាំសេសនីមួយៗ សវនកររដ្ឋ California ត្រូវធ្វើសវនកម្មលើការអនុវត្តឱ្យបានស្របតាមមាត្រានេះរបស់រដ្ឋ និងខោនធីនីមួយៗ ហើយត្រូវរាយការណ៍ជូនសាធារណជនអំពីលទ្ធផលនៃការរកឃើញ និងអនុសាសន៍របស់ខ្លួនសម្រាប់ការកែលម្អសុចរិតភាពនៃការបោះឆ្នោត។

មាត្រាទី 3. ការបំបែកចេញពីគ្នាបាន។

បទប្បញ្ញត្តិនៃច្បាប់នេះគឺអាចជាខដែលបំបែកចេញពីគ្នាបាន។ ប្រសិនបើផ្នែកណាមួយ មាត្រាណាមួយ ផ្នែករងណាមួយ កថាខណ្ឌណាមួយ ឃ្លាណាមួយ ប្រយោគណាមួយ ពាក្យណាមួយ ឬការអនុវត្តណាមួយនៃច្បាប់នេះ ត្រូវបានចាត់ទុកថាគ្មានសុពលភាពដោយសារហេតុផលណាមួយដោយសេចក្តីសម្រេចរបស់តុលាការដែលមានយុត្តាធិការត្រឹមត្រូវនោះ សេចក្តីសម្រេចនោះនឹងមិនប៉ះពាល់ដល់សុពលភាពនៃផ្នែកដែលនៅសេសសល់នៃច្បាប់នោះ ត្រូវបន្តមានប្រសិទ្ធភាពដោយមិនរាប់បញ្ចូលផ្នែក ឬការអនុវត្តដែលមិនមានសុពលភាពនោះ។

សំណើ 40

វិធានការផ្តួចផ្តើមនេះត្រូវបានដាក់ជូនប្រជាពលរដ្ឋដោយអនុលោមតាមបទបញ្ញត្តិនៃមាត្រាទី 8 នៃអត្ថបទ II នៃរដ្ឋធម្មនុញ្ញរដ្ឋ California។

វិធានការផ្តួចផ្តើមនេះបន្ថែមមាត្រាមួយទៅក្នុងរដ្ឋធម្មនុញ្ញរដ្ឋ California និងធ្វើវិសោធនកម្ម និងបន្ថែមមាត្រាទៅក្នុងក្រមរដ្ឋាភិបាល និងក្រមចំណូល និងពន្ធដារ ត្រូវបានបោះពុម្ពជាប្រភេទ*អក្សរទ្រេត* ដើម្បីបង្ហាញថា បទប្បញ្ញត្តិទាំងនោះជាបទប្បញ្ញត្តិថ្មី។

ច្បាប់ដែលបានដាក់ស្នើឡើង

ច្បាប់ស្តីពីពន្ធលើមហាសេដ្ឋី ឆ្នាំ 2026

ប្រជាពលរដ្ឋនៃរដ្ឋ California សូមអនុម័តច្បាប់ដូចតទៅ៖

មាត្រាទី 1. ចំណងជើង.

ច្បាប់នេះត្រូវបានស្គាល់ និងអាចយោងហៅថា ច្បាប់ស្តីពីពន្ធលើមហាសេដ្ឋី ឆ្នាំ 2026។

មាត្រាទី 2. ការរកឃើញ។

(a) ប្រជាពលរដ្ឋទទួលស្គាល់ថា ការទទួលបានសេវាថែទាំសុខភាពគ្រប់គ្រាន់ ការអប់រំសាធារណៈប្រកបដោយគុណភាព និងអាហារដែលមានជីវជាតិ គឺជាកត្តាចាំបាច់សម្រាប់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងសម្រាប់វិបុលភាព និងភាពធន់របស់រដ្ឋទាំងមូល។ ផលប៉ះពាល់ជាបន្តបន្ទាប់ពីការកាត់បន្ថយថវិកាពីរដ្ឋាភិបាលសហព័ន្ធដែលកំពុងខិតជិតមកដល់សម្រាប់កម្មវិធីថែទាំសុខភាព ការអប់រំ និងស្បៀងអាហារ ឥឡូវនេះកំពុងគំរាមកំហែងដល់មូលដ្ឋានគ្រឹះទាំងនេះ និងធ្វើឱ្យសុខុមាលភាពរបស់ប្រជាពលរដ្ឋ California ទាំងអស់ប្រឈមនឹងហានិភ័យ។

(b) បណ្តាញសុវត្ថិភាពថែទាំសុខភាពរបស់រដ្ឋ California កំពុងប្រឈមនឹងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ដោយសារកម្មវិធី Medi-Cal ដែលជាមូលដ្ឋានសំខាន់នៃការធានារ៉ាប់រងសុខភាពសម្រាប់ប្រជាពលរដ្ឋ California ដែលមានចំណូលទាបជិត 15 លាននាក់ រួមមានកុមារជាងពាក់កណ្តាលនៃរដ្ឋ មនុស្សចាស់ និងជនពិការចំនួន 2.2 លាននាក់ និងមនុស្សពេញវ័យដែលកំពុងធ្វើការចំនួនម្ភាក់ក្នុងចំណោមប្រាំនាក់នៃប្រជាជនទាំងអស់ កំពុងប្រឈមនឹងការកាត់បន្ថយថវិកាពីរដ្ឋាភិបាលសហព័ន្ធរាប់ពាន់លានដុល្លារ ដែលនឹងធ្វើឱ្យបញ្ហាប្រឈមដែលមានស្រាប់កាន់តែធ្ងន់ធ្ងរឡើង។

(c) គេព្យាករថា កម្មវិធី Medi-Cal នឹងបាត់បង់ថវិកាពីរដ្ឋាភិបាលសហព័ន្ធរហូតដល់ $19 ពាន់លានក្នុងមួយឆ្នាំ ដោយសារការអនុវត្តច្បាប់ថវិកាសហព័ន្ធថ្មីបំផុត និងវិធានការរដ្ឋបាល ដែលធ្វើឱ្យចំណាយត្រូវផ្ទេរទៅឱ្យមូលនិធិទូទៅរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន ឬបង្ខំឱ្យមានការកាត់បន្ថយសេវាដែលចាំបាច់។ ក្នុងរយៈពេលដប់ឆ្នាំខាងមុខ ការកាត់បន្ថយថវិកាពីរដ្ឋាភិបាលសហព័ន្ធសម្រាប់កម្មវិធី Medi-Cal តែមួយ គេព្យាករថានឹងមានទឹកប្រាក់សរុបប្រមាណ $190 ពាន់លាន។

(d) ការបាត់បង់ថវិកាពីរដ្ឋាភិបាលសហព័ន្ធចំនួនរាប់ពាន់លានដុល្លារ កំពុងធ្វើឱ្យបណ្តាញសុវត្ថិភាពថែទាំសុខភាពរបស់រដ្ឋ California ដែលមានថវិកាមិនគ្រប់គ្រាន់ស្រាប់ហើយ កាន់តែរងសម្ពាធបន្ថែមទៀត។ ថវិការដ្ឋសម្រាប់ឆ្នាំ 2025–26 បានរួមបញ្ចូលការរឹតបន្តឹងថ្មីៗជាច្រើន រួមមានការកាត់បន្ថយការផ្តល់ថវិកាដល់អ្នកផ្តល់សេវាថែទាំសុខភាព និងការកាត់បន្ថយយ៉ាងសំខាន់នូវអត្ថប្រយោជន៍ និងសេវាកម្មសម្រាប់អ្នកចុះឈ្មោះក្នុងកម្មវិធី Medi-Cal។ ការកាត់បន្ថយថវិការបស់រដ្ឋសម្រាប់កម្មវិធី Medi-Cal ត្រូវបានគេប៉ាន់ប្រមាណថានឹងឈានដល់ $7 ពាន់លាន ក្នុងឆ្នាំ 2027–28 ហើយនឹងកើនឡើងដល់ $8.6 ពាន់លានក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ 2028–29 តទៅ។

(e) សូម្បីតែមុនពេលមានការកាត់បន្ថយថវិកាពីរដ្ឋាភិបាលសហព័ន្ធ និងរដ្ឋទាំងនេះ ក៏ថវិកាសម្រាប់កម្មវិធី Medi-Cal នៅមានកម្រិតទាបពេកសម្រាប់អ្នកផ្តល់សេវាថែទាំសុខភាពជាច្រើន ដើម្បីរក្សាកម្រិតសេវាកម្មបច្ចុប្បន្នបានដែរ ពីព្រោះជាទូទៅ Medi-Cal ផ្តល់សំណងដល់មន្ទីរពេទ្យ និងគ្លីនិកក្នុងអត្រាដែលទាបជាងថ្លៃដើមជាក់ស្តែងនៃការផ្តល់សេវាថែទាំសុខភាពយ៉ាងច្រើន។

(f) មន្ទីរពេទ្យ និងគ្លីនិកថែទាំសុខភាពបឋម ជាពិសេសនៅតំបន់ជនបទ បានប្រឈមនឹងសម្ពាធផ្នែកហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរ ការខាតបង់ក្នុងប្រតិបត្តិការ និងការកាត់បន្ថយបុគ្គលិក ដោយសារការទូទាត់សំណងដែលមានចំនួនទាបជាងថ្លៃដើមជាបន្តបន្ទាប់ទាំងនេះ។ Medi-Cal គឺជាប្រភពនៃការធានារ៉ាប់រងសុខភាពសម្រាប់ការសម្រាលកូនពាក់កណ្តាលនៃការសម្រាលកូនទាំងអស់នៅទូទាំងរដ្ឋ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ មានការបិទផ្នែកសម្ភព និងផ្នែកសង្គ្រោះបន្ទាន់ដែលមានសារៈសំខាន់ ដោយការបិទទាំងនេះត្រូវបានចាត់ទុកថា បណ្តាលមកមួយផ្នែកធំដោយសារអត្រាទូទាត់សំណងរបស់ Medi-Cal មានកម្រិតទាប។

(g) ការវិនិយោគលើកម្មវិធី Medi-Cal គឺជាការវិនិយោគលើសន្តិសុខផ្នែកសុខភាពរបស់គ្រួសារគ្រប់រូប។ វាជួយរក្សាឱ្យគ្លីនិកថែទាំសុខភាពបឋម និងមណ្ឌលសុខភាពសហគមន៍នៅតាមទីប្រជុំជន និងទីក្រុងនានាបន្តបើកដំណើរការ ដោយអនុញ្ញាតឱ្យប្រជាពលរដ្ឋគ្រប់គ្រងជំងឺរ៉ាំរ៉ៃ ការពារផលវិបាកដែលអាចចំណាយថ្លៃខ្ពស់ និងរស់នៅបានយូរជាងមុន និងមានសុខភាពល្អជាងមុន។ រាល់ថវិកាដែលត្រូវបានកាត់បន្ថយពីកម្មវិធីទាំងនេះ សុទ្ធតែបង្កផលប៉ះពាល់ជាបន្តបន្ទាប់៖ គ្លីនិកត្រូវបានបិទ គ្រួសារបាត់បង់គ្រូពេទ្យដែលពួកគេធ្លាប់ទទួលសេវា ហើយអ្នកជំងឺរងការឈឺចាប់ដោយមិនចាំបាច់ពីជំងឺ ឬស្ថានភាពសុខភាពដែលអាចត្រូវបានការពារ ឬគ្រប់គ្រងបាន។

(h) ការទទួលបានសេវាថែទាំសុខភាពដែលមានគុណភាពខ្ពស់ និងមានតម្លៃសមរម្យ អាចជួយសង្គ្រោះជីវិត ការពារគ្រួសារពីបំណុលថ្លៃព្យាបាលដែលមានបន្ទុកធ្ងន់ធ្ងរ និងពង្រឹងសហគមន៍។ នៅពេលការធានារ៉ាប់រងសុខភាពត្រូវបានបាត់បង់ ឬកាត់បន្ថយ មន្ទីរពេទ្យ និងគ្លីនិកត្រូវបង្ខំចិត្តធ្វើការសម្រេចចិត្តដ៏លំបាកខ្លាំង ដូចជា កាត់បន្ថយបុគ្គលិក រឹតត្បិតសេវាកម្ម ឬបិទផ្នែកទាំងមូល ដែលធ្វើឱ្យប្រជាជនទាំងមូលមួយចំនួនគ្មានបណ្តាញសុវត្ថិភាពសម្រាប់ការថែទាំសុខភាព និងធ្វើឱ្យសុខភាពរបស់ប្រជាពលរដ្ឋ California ទាំងអស់ចុះខ្សោយ។

(i) ខណៈដែលថវិកាសម្រាប់កម្មវិធី Medi-Cal កំពុងប្រឈមនឹងការកាត់បន្ថយថវិកាពីរដ្ឋាភិបាលសហព័ន្ធ និងថវិកាដែលរដ្ឋបានអនុម័តសម្រាប់កម្មវិធីនេះ ប្រជាពលរដ្ឋ California កំពុងប្រឈមនឹងការកើនឡើងយ៉ាងខ្លាំងនៃថ្លៃធានារ៉ាប់រងសុខភាពឯកជនផងដែរ។ សម្ពាធពីរយ៉ាងនេះនឹងធ្វើឱ្យចំនួនប្រជាពលរដ្ឋដែលគ្មានការធានារ៉ាប់រងសុខភាព និងអ្នកដែលមានការធានារ៉ាប់រងសុខភាពមិនគ្រប់គ្រាន់កាន់តែកើនឡើង ដោយសារនិយោជកកាត់បន្ថយអត្ថប្រយោជន៍ និងរំខានដល់ការធានារ៉ាប់រងសម្រាប់អ្នកក្នុងបន្ទុក ហើយបុគ្គលម្នាក់ៗបោះបង់ការធានារ៉ាប់រងសុខភាពដែលពួកគេមិនអាចមានលទ្ធភាពបង់បាន។

(j) កុមារគ្រប់រូបនៅរដ្ឋ California សមនឹងទទួលបានឱកាសទទួលការអប់រំដែលមានគុណភាពខ្ពស់។ បច្ចុប្បន្ន សាលារៀនសាធារណៈនៅរដ្ឋ California កំពុងប្រឈមនឹងភាពមិនប្រាកដប្រជាដែលមិនធ្លាប់មានពីមុនមក ដែលមួយផ្នែកបណ្តាលមកពីការកាត់បន្ថយកម្មវិធី Medi-Cal និងកម្មវិធីជំនួយអាហារូបត្ថម្ភបន្ថែម (SNAP)។

(k) លើសពីនេះ សំណើថវិកាសហព័ន្ធបច្ចុប្បន្នសម្រាប់ឆ្នាំ 2026 នឹងកាត់បន្ថយយ៉ាងខ្លាំងនូវថវិកាសរុបសម្រាប់សាលារៀនសាធារណៈជាពិសេសសម្រាប់សិស្សដែលមានតម្រូវការខ្ពស់ សាលារៀននៅតំបន់ជនបទ និងសហគមន៍ដែលជួបប្រទះភាពខ្វះខាត។

(l) ការរំខានពីរដ្ឋាភិបាលសហព័ន្ធទាំងនេះកើតឡើងនៅពេលដែលសាលារៀននៅរដ្ឋ California នៅតែកំពុងតស៊ូដោះស្រាយផលប៉ះពាល់ពីការខ្វះខាតថវិការដ្ឋនាពេលថ្មីៗនេះ និងការពន្យារពេលទូទាត់ដែលកំពុងខិតជិតមកដល់។ លើសពីបញ្ហាទាំងនេះ ការថយចុះនៃចំនួនសិស្សចុះឈ្មោះ និងថវិកាដែលពាក់ព័ន្ធនឹងចំនួនសិស្សចុះឈ្មោះ ការកើនឡើងនៃចំណាយ និងតម្រូវការរបស់សិស្សដែលកាន់តែកើនឡើង កំពុងដាក់សម្ពាធផ្នែកថវិការកាន់តែខ្លាំងលើមណ្ឌលសិក្សានានា។

(m) ប្រជាពលរដ្ឋ California ច្រើនជាង 5 លាននាក់—ក្នុងចំណោមនោះមានកុមារ គ្រួសារ មនុស្សចាស់ និងជនពិការ—ពឹងផ្អែកលើ CalFresh ដែលជាកម្មវិធីជំនួយអាហារូបត្ថម្ភបន្ថែម (SNAP) របស់រដ្ឋ California ជាជំនួយដ៏សំខាន់សម្រាប់ការផ្គត់ផ្គង់អាហារដល់គ្រួសារ នៅក្នុងរដ្ឋដែលមនុស្សម្នាក់ក្នុងចំណោមប្រាំនាក់ជួបប្រទះភាពអត់ឃ្លានដោយសារកង្វះសន្តិសុខស្បៀងអាហារ។

(n) ការកាត់បន្ថយថវិកាសហព័ន្ធជាប្រវត្តិសាស្ត្រចំពោះកម្មវិធី SNAP ដែលមានចែងក្នុងច្បាប់ថវិកាសហព័ន្ធនាពេលថ្មីៗនេះ នឹងដកហូតជំនួយស្បៀងអាហារដ៏សំខាន់ដែលមានតម្លៃរាប់ពាន់លានដុល្លារ ពីប្រជាពលរដ្ឋក្នុងសហគមន៍របស់យើងដែលងាយរងគ្រោះបំផុត ដែលនឹងបណ្តាលឱ្យបាត់បង់អាហាររាប់លានពេល និងធ្វើឱ្យភាពអត់ឃ្លានកាន់តែធ្ងន់ធ្ងរឡើងនៅទូទាំងសហគមន៍ដែលកំពុងតស៊ូរួចស្រាប់ដើម្បីរកប្រាក់ឱ្យបានគ្រប់គ្រាន់សម្រាប់ចំណាយលើជីវភាពរស់នៅ។

(o) ភស្តុតាងដ៏រឹងមាំបង្ហាញថា SNAP និង CalFresh មិនត្រឹមតែជួយកាត់បន្ថយភាពអត់ឃ្លានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយកែលម្អយ៉ាងខ្លាំងនូវលទ្ធផលផ្នែកសុខភាព និងការអប់រំសម្រាប់កុមារនៅរដ្ឋ California ជួយបំបែកវដ្តនៃភាពក្រីក្រ និងកសាងអនាគតដែលរឹងមាំជាងមុនសម្រាប់គ្រួសារទាំងមូល។

(p) ការកាត់បន្ថយថវិកាទាំងនេះនឹងដាក់សម្ពាធបន្ថែមលើកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋដែលកំពុងប្រឈមនឹងសម្ពាធស្រាប់ និងធនធានដែលមានកម្រិតរបស់ធនាគារស្បៀងអាហារ និងស្ថាប័នមូលដ្ឋាន ដូចជា CalFood និងកម្មវិធីជំនួយស្បៀងអាហាររដ្ឋ California។

(q) ជារួម ការកាត់បន្ថយថវិកាពីរដ្ឋាភិបាលសហព័ន្ធ និងថវិកាដែលរដ្ឋបានអនុម័តទាំងនេះ បង្កើតហានិភ័យជាបន្តបន្ទាប់ដែលកាន់តែធ្ងន់ធ្ងរឡើងសម្រាប់ប្រជាពលរដ្ឋកាលីហ្វ័រញ៉ាដែលមានចំណូលទាប និងមធ្យម ដែលកំពុងស្វែងរកការទទួលបានសេវាថែទាំសុខភាព ការអប់រំ និងអាហារូបត្ថម្ភដែលចាំបាច់។ ការកាត់បន្ថយថវិកាទាំងនេះក៏គំរាមកំហែងដល់សមត្ថភាពរបស់រដ្ឋ California ក្នុងការរៀបចំផែនការសម្រាប់អនាគតរបស់ខ្លួនផងដែរ ដែលការរៀបចំផែនការនេះតម្រូវឱ្យមានការវិនិយោគជាបន្តបន្ទាប់លើកម្មវិធីសំខាន់ៗរបស់រដ្ឋ។

(r) រដ្ឋ California មានមហាសេដ្ឋីប្រហែល 200 នាក់ ដែលនៅពេលបូកបញ្ចូលគ្នា មានទ្រព្យសម្បត្តិសរុបដ៏មហាសាលប្រមាណ $2 ទ្រីលាន។ យោងតាមការប៉ាន់ប្រមាណផ្នែកសេដ្ឋកិច្ចពីប្រភពឈានមុខ មហាសេដ្ឋីទាំងនេះបង់ពន្ធប្រចាំឆ្នាំស្មើនឹងតិចជាង 1.5% នៃទ្រព្យសម្បត្តិសរុបរបស់ពួកគេ ដោយរាប់បញ្ចូលទាំងពន្ធសហព័ន្ធ ពន្ធរដ្ឋ និងពន្ធមូលដ្ឋាន ដែលជាសមាមាត្រតូចមួយប៉ុណ្ណោះ បើប្រៀបធៀបនឹងអ្វីដែលប្រជាពលរដ្ឋ California ទូទៅបង់។

(s) នៅក្នុងរដ្ឋ California មានអ្នកជាប់ពន្ធច្រើនជាង 19 លាននាក់ ដែលមិនមែនជាមហាសេដ្ឋី។ ពួកគេរួមមានបុគ្គលដែលជាអ្នកធ្វើការ ដូចជា គិលានុបដ្ឋាក គ្រូបង្រៀន និង អ្នកពន្លត់អគ្គិភ័យ ព្រមទាំងអ្នកជាប់ពន្ធដែលមានទ្រព្យសម្បត្តិច្រើនជាង ដូចជា អ្នកជំនាញដែលទទួលបានប្រាក់ឈ្នួលខ្ពស់ សហគ្រិន និងអ្នកធ្វើការក្នុងឧស្សាហកម្មបច្ចេកវិទ្យា។ ប្រជាពលរដ្ឋ California ទាំងអស់នេះ បង់ពន្ធលើចំណែកដ៏ធំជាងឆ្ងាយនៃចំណូលសេដ្ឋកិច្ចពិតប្រាកដរបស់ពួកគេ បើប្រៀបធៀបនឹងមហាសេដ្ឋីរបស់រដ្ឋ។ យោងតាមការវិភាគផ្នែកសេដ្ឋកិច្ច និងដោយរាប់បញ្ចូលពន្ធទាំងអស់នៅគ្រប់កម្រិតរដ្ឋាភិបាល មហាសេដ្ឋីបង់ពន្ធស្មើនឹង 24% នៃចំណូលរបស់ពួកគេ ខណៈដែលអ្នកជាប់ពន្ធជាមធ្យមបង់ពន្ធស្មើនឹង 30% នៃចំណូលរបស់ពួកគេ។ នេះមានន័យថា អ្នកជាប់ពន្ធជាមធ្យមបង់ពន្ធលើចំណែកនៃចំណូលសេដ្ឋកិច្ចរបស់ខ្លួន ដែលមានទំហំធំជាង 25% បើប្រៀបធៀបនឹងមហាសេដ្ឋីជាមធ្យម ដោយរាប់បញ្ចូលពន្ធរដ្ឋ និងពន្ធសហព័ន្ធទាំងអស់។ សូមមើល Akcan Balkir, Emmanuel Saez, Danny Yagan និង Gabriel Zucman តើមហាសេដ្ឋីអាមេរិកបង់ពន្ធប៉ុន្មាន? ភស្តុតាងពីទិន្នន័យរដ្ឋបាលវិទ្យាស្ថានជាតិស្រាវជ្រាវសេដ្ឋកិច្ច ឯកសារស្រាវជ្រាវសម្រាប់ការពិភាក្សា លេខ 34170 (ឆ្នាំ 2025)។

(t) ពន្ធលើទ្រព្យសម្បត្តិមិនមែនជាគំនិតថ្មីក្រោមច្បាប់រដ្ឋ California ទេ។ ពន្ធលើទ្រព្យសម្បត្តិដែលមានវិសាលភាពតូចជាង និងមានលក្ខណៈប្លែកក្រៅវិតិចជាងនេះ ត្រូវបានបង់រួចមកហើយដោយប្រជាពលរដ្ឋកាលីហ្វ័រញ៉ាដែលមានទ្រព្យសម្បត្តិច្រើន និងអ្នកដែលមានចំណូលទាបដូចគ្នា។ ពន្ធទាំងនេះរួមមាន ថ្លៃអាជ្ញាបណ្ណយានយន្តប្រចាំឆ្នាំ ដែលជាពន្ធផ្នែកលើ 0.65% នៃតម្លៃយានយន្ត និងពន្ធអចលនទ្រព្យលើលំនៅដ្ឋានប្រចាំឆ្នាំ ដែលមានអត្រាប្រមាណ 1% នៃតម្លៃផ្ទះដែលត្រូវបានកំណត់សម្រាប់គោលបំណងពន្ធ។

(u) ទ្រព្យសម្បត្តិដ៏មហាសាល និងកំពុងកើនឡើងរបស់មហាសេដ្ឋី ផ្តល់ឱ្យពួកគេនូវអត្ថប្រយោជន៍ពិសេសដែលមនុស្សភាគច្រើនមិនអាចទទួលបាន។ ខណៈដែលគិលានុបដ្ឋាក គ្រូបង្រៀន អ្នកពន្លត់អគ្គិភ័យ និងអ្នកធ្វើការក្នុងវិស័យបច្ចេកវិទ្យា សុទ្ធតែបង់ពន្ធលើប្រាក់ចំណូលដែលពួកគេទទួលបានពីការងាររបស់ខ្លួនស្មើរតែទាំងអស់ មហាសេដ្ឋីអាចការពារចំនួនទឹកប្រាក់ដ៏មហាសាលមិនឱ្យជាប់ពន្ធបាន។ ទ្រព្យសម្បត្តិសំខាន់ៗរបស់ពួកគេ—ភាគហ៊ុន អាជីវកម្ម និងអចលនទ្រព្យ—មានតម្លៃកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែដោយសារការកើនឡើងនៃតម្លៃនេះត្រូវបានយកមកគិតពន្ធនៅពេលលក់តែប៉ុណ្ណោះ ហើយមហាសេដ្ឋីជាញឹកញាប់មិនចាំបាច់លក់ទ្រព្យសម្បត្តិរបស់ពួកគេ នោះពួកគេមិនបង់ពន្ធលើទ្រព្យសម្បត្តិដែលកំពុងកើនឡើងរបស់ពួកគេឡើយ។ លើសពីនេះ នៅពេលទ្រព្យសម្បត្តិប្រភេទទាំងនេះត្រូវបានផ្ទេរទៅឱ្យអ្នកទទួលមរតក ច្បាប់បច្ចុប្បន្នអនុញ្ញាតឱ្យទ្រព្យសម្បត្តិដែលមិនទាន់ត្រូវបានជាប់ពន្ធមានតម្លៃរាប់ពាន់លានដុល្លារ ត្រូវបានទទួលមរតកដោយមិនធ្លាប់បង្កើតកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូលឡើយ។ មនុស្សជាច្រើនក៏ប្រើយុទ្ធសាស្ត្រហិរញ្ញវត្ថុដ៏ស្មុគស្មាញ ដើម្បីផ្លាស់ទីទ្រព្យសម្បត្តិ “តាមឯកសារ” ខណៈដែលតាមការពិត ពួកគេនៅតែបន្តទទួលបានអត្ថប្រយោជន៍ពីសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ California។

(v) អ្នកសិក្សាស្រាវជ្រាវបានបង្ហាញថា ការបិទចន្លោះប្រហោងក្នុងច្បាប់ពន្ធដែលផ្តល់អត្ថប្រយោជន៍ដល់មហាសេដ្ឋី គឺអាចធ្វើទៅបាន អាចអនុវត្តបានជាក់ស្តែង និងមានភាពយុត្តិធម៌។ ពួកគេបង្ហាញថា គោលនយោបាយដែលត្រូវបានរៀបចំឡើងយ៉ាងប្រុងប្រយ័ត្ន អាចរក្សាឱ្យសហគ្រិនបន្តទទួលបានជោគជ័យ ខណៈពេលដែលការពារសេដ្ឋកិច្ចរបស់រដ្ឋ និងជៀសវាងការដាក់បន្ទុកហួសហេតុលើមន្ត្រីដែលទទួលបន្ទុកអនុវត្តគោលនយោបាយ ឬលើមូលដ្ឋានអ្នកជាប់ពន្ធទាំងមូល។ សូមមើល Brian Galle, David Gamage និង Darien Shanske ក្នុងអត្ថបទ ចំណាត់ការហិរញ្ញវត្ថុ៖ ការ

40

យកពន្ធលើអ្នកមានទ្រព្យសម្បត្តិនៅកម្រិតរដ្ឋ លេខ 113 នៃទស្សនាវដ្តី California ព្រឹត្តិបត្រសិក្សាស្រាវជ្រាវផ្នែកច្បាប់ ទំព័រ 635 (ឆ្នាំ 2025)។

(w) ចាប់តាំងពីទសវត្សរ៍ឆ្នាំ 1980 មក ទ្រព្យសម្បត្តិរបស់មហាសេដ្ឋីបានកើនឡើងជាមធ្យម 7% ក្នុងមួយឆ្នាំ ដែលមានល្បឿនលឿនជាងយ៉ាងខ្លាំង បើប្រៀបធៀបនឹងការកើនឡើងនៃប្រាក់ឈ្នួល និងប្រាក់សន្សំរបស់ប្រជាពលរដ្ឋ California ទូទៅ។ ទ្រព្យសម្បត្តិសរុបរបស់មហាសេដ្ឋីនៅរដ្ឋ California បានកើនឡើងយ៉ាងខ្លាំង ពី $300 ពាន់លានក្នុងឆ្នាំ 2011 ដល់ $700 ពាន់លានក្នុងឆ្នាំ 2019 និងដល់ជាង $2 ទ្រីលានក្នុងឆ្នាំ 2025។ ពន្ធលើទ្រព្យសម្បត្តិដែលត្រូវបានដាក់ដោយច្បាប់នេះ នឹងធ្វើឱ្យការកើនឡើងយ៉ាងខ្លាំងនៃទ្រព្យសម្បត្តិនេះថយចុះត្រឹមកម្រិតតិចតួចប៉ុណ្ណោះ ដោយចំណូលពន្ធដែលប្រមូលបាននឹងមានចំនួនតិចជាងទ្រព្យសម្បត្តិដែលមហាសេដ្ឋីជាទូទៅអាចបង្កើនបានក្នុងរយៈពេលតែមួយឆ្នាំ។ មហាសេដ្ឋីនៅរដ្ឋ California សូម្បីតែបន្ទាប់ពីបានបង់ពន្ធនេះរួចហើយ ក៏នឹងបន្តប្រមូលផ្តុំទ្រព្យសម្បត្តិដែលកំពុងកើនឡើងជាបន្តបន្ទាប់របស់ពួកគេ។

(x) យោងតាមអ្នកសេដ្ឋកិច្ចឈានមុខ ទ្រព្យសម្បត្តិរបស់មហាសេដ្ឋីមានការប្រមូលផ្តុំខ្លាំងជាងនៅរដ្ឋ California បើប្រៀបធៀបនឹងសហរដ្ឋអាមេរិកទាំងមូល។ ជាលទ្ធផល រដ្ឋនេះស្ថិតក្នុងទីតាំងពិសេសមួយក្នុងការដោះស្រាយទាំងវិបត្តិនៃវិសមភាពទ្រព្យសម្បត្តិនៅក្នុងសហរដ្ឋអាមេរិក ដែលមានភស្តុតាងច្បាស់លាស់ជាច្រើនបញ្ជាក់ និងវិបត្តិដែលកំពុងលេចឡើង និងមានទំនាក់ទំនងគ្នា ដែលរដ្ឋកំពុងប្រឈមពាក់ព័ន្ធនឹងកម្មវិធីថែទាំសុខភាព ការអប់រំ និងការផ្តល់ជំនួយដល់អ្នកដែលជួបប្រទះភាពអត់ឃ្លាន។

(y) មហាសេដ្ឋីបានកសាងទ្រព្យសម្បត្តិដ៏មហាសាលរបស់ពួកគេ ដោយមានជំនួយពីធនធានរបស់រដ្ឋ California ហើយជាអ្នកទទួលបានអត្ថប្រយោជន៍ធំបំផុតពីច្បាប់របស់រដ្ឋាភិបាលសហព័ន្ធ ដែលបានរួមចំណែកដល់វិបត្តិថវិការបស់រដ្ឋនាពេលបច្ចុប្បន្ន។ ដូច្នេះ វាជារឿងចាំបាច់ និងមានភាពយុត្តិធម៌ ក្នុងការស្នើឱ្យអ្នកដែលបានទទួលអត្ថប្រយោជន៍ច្រើនបំផុតពីធនធានរបស់រដ្ឋ California ចូលរួមចំណែកតាមសមាមាត្រ ដើម្បីគាំទ្រការថែទាំសុខភាព ការអប់រំ និងអាហារូបត្ថម្ភនៅរដ្ឋ California តាមរយៈការដាក់ពន្ធម្តងតែម្តងក្នុងអត្រា 5% លើទ្រព្យសម្បត្តិរបស់មហាសេដ្ឋី។

(z) ដោយពិចារណាអំពីស្ថានភាពថវិកាបន្ទាន់ ដើម្បីធានាថា ចំណូលដែលប្រមូលបានអាចត្រូវបានចំណាយដោយមិនមានការពន្យារពេលដែលមិនចាំបាច់ និងដើម្បីលុបបំបាត់ភាពមិនប្រាកដប្រជាដែលបណ្តាលមកពីបណ្តឹងតវ៉ាតាមផ្លូវច្បាប់ណាមួយ ប្រជាពលរដ្ឋបានចែងឱ្យមានការពិនិត្យតាមផ្លូវតុលាការលើច្បាប់នេះដោយមាននីតិវិធីពន្លឿន។

ផ្នែកទី 3. គោលបំណង និងចេតនា។

(a) គោលបំណងនៃច្បាប់ស្តីពីពន្ធលើមហាសេដ្ឋី ឆ្នាំ 2026 ដែលនៅក្នុងនេះហៅថា "ច្បាប់" គឺដើម្បីការពារការទទួលបានសេវាថែទាំសុខភាពដែលមានគុណភាពខ្ពស់ និងមានសមធម៌ និងដើម្បីគាំទ្រការផ្តល់មូលនិធិសម្រាប់ការអប់រំសាធារណៈចាប់ពីថ្នាក់មត្តេយ្យរហូតដល់ថ្នាក់ទីដប់បួន និងកម្មវិធីជំនួយស្បៀងអាហារ តាមរយៈការប្រមូលចំណូលពីការដាក់ពន្ធម្តងតែម្តងលើទ្រព្យសម្បត្តិរបស់មហាសេដ្ឋី។

(b) ចំណូលដែលបានមកពីច្បាប់នេះ មានគោលបំណងដើម្បីឆ្លើយតបទៅនឹងតម្រូវការបន្ទាន់ដែលមានស្រាប់ក្នុងវិស័យថែទាំសុខភាព ការអប់រំ និងអាហារូបត្ថម្ភ ដែលកំពុងកាន់តែធ្ងន់ធ្ងរឡើងដោយសារការកាត់បន្ថយថវិកាពីរដ្ឋាភិបាលសហព័ន្ធ និងរដ្ឋ និងដោយសារភាពមិនប្រាកដប្រជាផ្នែកហិរញ្ញវត្ថុទូលំទូលាយដែលរដ្ឋកំពុងប្រឈម។

(c) ដោយកំណត់ទ្រព្យសម្បត្តិរបស់មហាសេដ្ឋីជាប្រភពនៃចំណូលដ៏សំខាន់នេះ ច្បាប់នេះដោះស្រាយអំពើអយុត្តិធម៌ជាមូលដ្ឋានដែលកើតឡើងដោយសារភាគរយដ៏ធំនៃទ្រព្យសម្បត្តិរបស់មហាសេដ្ឋីមិនដែលត្រូវបានយកពន្ធដោយរដ្ឋឡើយ ដោយសារសមត្ថភាពពិសេសរបស់មហាសេដ្ឋីក្នុងការគ្រប់គ្រងពេលវេលា ទីកន្លែង និងចំនួនទឹកប្រាក់នៃពន្ធលើប្រាក់ចំណូលដែលពួកគេត្រូវបង់។

(d) ច្បាប់នេះបង្កើនមូលនិធិសម្រាប់ការថែទាំសុខភាព ការអប់រំ និងជំនួយស្បៀងអាហារ តាមរយៈការដាក់ពន្ធម្តងតែម្តងដែលអនុវត្តចំពោះក្រុមដែលមានវិសាលភាពកំណត់យ៉ាងជាក់លាក់ ហើយអាចអនុវត្តបានជាក់ស្តែងតាមផ្នែករដ្ឋបាល និងអាចអនុវត្តឱ្យមានប្រសិទ្ធភាពចំពោះមហាសេដ្ឋីទាំងអស់នៅក្នុងរដ្ឋ។

(e) ច្បាប់នេះមានគោលបំណងអនុវត្តការប្រព្រឹត្តដូចគ្នាចំពោះអ្នកជាប់ពន្ធ និងទ្រព្យសម្បត្តិដែលស្ថិតក្នុងស្ថានភាពស្រដៀងគ្នា លើកលែងតែក្នុងកម្រិតដែលគោលនយោបាយពន្ធដារដែលមានមូលដ្ឋានត្រឹមត្រូវតម្រូវឱ្យមានការអនុវត្តខុសគ្នា។

មាត្រាទី 4. មាត្រាទី 37 ត្រូវបានបន្ថែមទៅក្នុងអត្ថបទ XIII នៃរដ្ឋធម្មនុញ្ញរដ្ឋ California ដោយមានខ្លឹមសារដូចតទៅ៖

មាត្រាទី 37. (a) មាត្រានេះផ្តល់សិទ្ធិអំណាច និងអនុញ្ញាតឱ្យដាក់ពន្ធម្តងតែម្តងលើទ្រព្យសម្បត្តិដែលបានប្រមូលផ្តុំរបស់មហាសេដ្ឋីនៅរដ្ឋ California ដោយ ពន្ធនេះត្រូវដាក់លើបុគ្គលទាំងឡាយដែលជាអ្នករស់នៅក្នុងរដ្ឋ California តាមន័យដែលមានចែងក្នុងមាត្រាទី 17014 និង 17015.5 នៃក្រមស្តីពីចំណូល និងពន្ធដារ គិតត្រឹមកាលបរិច្ឆេទបង្កើតកាតព្វកិច្ចពន្ធ ដែលបានកំណត់និយមន័យក្នុងច្បាប់ស្តីពីពន្ធលើមហាសេដ្ឋី ឆ្នាំ 2026។

(b) និយមន័យដូចតទៅនេះត្រូវអនុវត្តចំពោះមាត្រានេះ៖

(1) "ច្បាប់" សំដៅលើ ច្បាប់ស្តីពីពន្ធលើមហាសេដ្ឋី ឆ្នាំ 2026។

(2) "មូលនិធិបម្រុង" សំដៅលើ មូលនិធិបម្រុងពន្ធលើមហាសេដ្ឋី ឆ្នាំ 2026 ដែលត្រូវបានបង្កើតឡើងដោយច្បាប់នេះ។

(c) ទោះបីជាមានបទប្បញ្ញត្តិផ្សេងទៀតណាមួយនៃរដ្ឋធម្មនុញ្ញក៏ដោយ ច្បាប់នេះចែងអំពីការដាក់ពន្ធលើគ្រប់ទម្រង់នៃទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងទ្រព្យសម្បត្តិ ទាំងទ្រព្យសម្បត្តិដែលមានរូបរាង និងទ្រព្យសម្បត្តិអរូបី ហើយអនុញ្ញាតឱ្យមានការចាត់ថ្នាក់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងទ្រព្យសម្បត្តិ សម្រាប់ការដាក់ពន្ធក្នុងអត្រាខុសៗគ្នា ឬសម្រាប់ការលើកលែងពន្ធ ក្នុងគោលបំណងដាក់ពន្ធម្តងតែម្តងលើទ្រព្យសម្បត្តិរបស់មហាសេដ្ឋីនៅរដ្ឋ California។ ទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងទ្រព្យសម្បត្តិដែលត្រូវបានដាក់ពន្ធតាមនេះ រួមមានជាអាទិ៍ ភាគហ៊ុនមូលធន មូលបត្របំណុល ឬភស្តុតាងផ្សេងទៀតនៃបំណុល និងសិទ្ធិណាមួយតាមផ្លូវច្បាប់ ឬសិទ្ធិទទួលផលប្រយោជន៍ក្នុងទ្រព្យសម្បត្តិទាំងនោះឡើយ។

(d) មូលនិធិបម្រុងពន្ធលើមហាសេដ្ឋី ឆ្នាំ 2026 ត្រូវបានបង្កើតឡើងតាមរយៈនេះ នៅក្នុងរតនាគាររដ្ឋ។ ចំណូលទាំងអស់ដែលបានមកពីច្បាប់នេះ រួមទាំងពន្ធ ការប្រាក់ និងប្រាក់ពិន័យ ហើយបន្ទាប់ពីកាត់ចេញនូវប្រាក់សងត្រឡប់ ត្រូវដាក់បញ្ចូលទៅក្នុងរតនាគាររដ្ឋដោយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដោយកត់ជាឥណទានចូលក្នុងមូលនិធិបម្រុង។ បន្ទាប់ពីបានគណនាចំណាយរដ្ឋបាលតាមដែលច្បាប់បានចែងរួច មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបែងចែក និងផ្ទេរចំនួនទឹកប្រាក់ដែលនៅសល់ក្នុងមូលនិធិបម្រុង ទៅកាន់គណនីរងដូចតទៅនេះ ដែលត្រូវបានបង្កើតឡើងតាមរយៈនេះ៖ 90% ទៅកាន់គណនីសុខាភិបាលពន្ធលើមហាសេដ្ឋី និង 10% ទៅកាន់គណនីអប់រំ និងជំនួយស្បៀងអាហារនៃពន្ធលើមហាសេដ្ឋី។ ចំនួនទឹកប្រាក់នៅក្នុងគណនីសុខាភិបាលនៃពន្ធលើមហាសេដ្ឋី និងគណនីអប់រំ និងជំនួយស្បៀងអាហារនៃពន្ធលើមហាសេដ្ឋី ត្រូវបែងចែកតាមដែលច្បាប់បានចែង។

(e) ទោះបីជាមានច្បាប់ផ្សេងទៀតណាមួយក៏ដោយ មូលនិធិបម្រុងគឺជាមូលនិធិពិសេស ដែលត្រូវរក្សាឱ្យដាច់ដោយឡែក និងដោយឡែកពីមូលនិធិទូទៅ ឬមូលនិធិ ឬគណនីរដ្ឋផ្សេងទៀតជាអចិន្ត្រៃយ៍។ ពន្ធ និងចំនួនទឹកប្រាក់ដែលបានមកពីច្បាប់នេះ មិនត្រូវចាត់ទុកថាជាផ្នែកមួយនៃមូលនិធិទូទៅ ដូចដែលពាក្យនេះត្រូវបានប្រើប្រាស់ក្នុងជំពូក 1 (ចាប់ផ្តើមពីមាត្រាទី 16300) នៃផ្នែក 2 នៃភាគ 4 នៃចំណងជើង 2 នៃក្រមរដ្ឋាភិបាលឡើយ ហើយមិនត្រូវចាត់ទុកជា "ចំណូលមូលនិធិទូទៅ" "ចំណូលរដ្ឋ" "ចំនួនទឹកប្រាក់" ឬ "ប្រាក់ចំណូលដែលបានមកពីពន្ធ" តាមផ្នែក 8 នៃជំពូក XIII B សម្រាប់គោលបំណងនៃមាត្រាណាមួយនៃជំពូក XIII B ឬផ្នែក 8 ឬ 8.5 នៃមាត្រា XVI នៃរដ្ឋធម្មនុញ្ញឡើយ។ ចំណូលណាមួយដែលប្រមូលបានតាមរយៈច្បាប់នេះ ក៏មិនត្រូវចាត់ទុកជា "ពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួនដែលបានបង់លើចំណេញមូលធនសុទ្ធ" សម្រាប់គោលបំណងនៃផ្នែក 20 នៃជំពូក XVI នៃរដ្ឋធម្មនុញ្ញឡើយ។ ពន្ធដែលដាក់ដោយច្បាប់នេះ មិនត្រូវចាត់ទុកជា "ពន្ធតាមតម្លៃលើអចលនទ្រព្យ" សម្រាប់គោលបំណងនៃ ផ្នែក 1 នៃជំពូក XIII A នៃរដ្ឋធម្មនុញ្ញឡើយ។ ក្នុងកម្រិតដែលបទប្បញ្ញត្តិណាមួយនៃជំពូក XIII A អាចត្រូវបានបកស្រាយថា កំណត់ រឹតត្បិត ឬអនុវត្តចំពោះអត្រាពន្ធ មូលដ្ឋានពន្ធ ការកំណត់តម្លៃ ឬការដាក់ពន្ធដែលត្រូវបានអនុញ្ញាតដោយមាត្រានេះ បទបញ្ញត្តិនោះមិនត្រូវអនុវត្តចំពោះមាត្រានេះឡើយ ហើយមាត្រានេះត្រូវមានអាទិភាពជំនួសបទបញ្ញត្តិនោះ។ ទោះបីជាមានមាត្រាទី 16305.7 នៃក្រមរដ្ឋាភិបាលក៏ដោយ ការប្រាក់ ឬភាគលាភណាមួយដែលទទួលបានពីចំនួនទឹកប្រាក់នៅក្នុងមូលនិធិបម្រុង ត្រូវរក្សាទុកនៅក្នុងមូលនិធិបម្រុង ហើយត្រូវប្រើប្រាស់សម្រាប់តែគោលបំណងដាក់លាក់ដែលបានចែងក្នុងផ្នែករងនេះ និងតាមដែលច្បាប់បានចែងប៉ុណ្ណោះ។

(f) "ការបែងចែកថវិកាដែលស្ថិតក្រោមដែនកំណត់" នៃអង្គភាពនីមួយៗរបស់រដ្ឋាភិបាល និងរដ្ឋនៅក្រោមមាត្រា XIII B មិនត្រូវរាប់បញ្ចូលការបែងចែកប្រាក់ចំណូលពីមូលនិធិបម្រុងនោះទេ។ ការកែសម្រួលដែនកំណត់នៃការបែងចែកថវិកានៃអង្គភាពណាមួយរបស់រដ្ឋាភិបាលនឹងមិនត្រូវបានតម្រូវឡើយស្របតាមផ្នែកទី 3 នៃមាត្រា XIII B ជាលទ្ធផលនៃប្រាក់ចំណូលដែលដាក់ចូល ឬដែលបានបែងចែកចេញពីមូលនិធិបម្រុង។

(g) លើកលែងតែមានចែងក្នុងផ្នែក 16310 និង 16381 នៃក្រមរដ្ឋាភិបាល ដូចដែលផ្នែកទាំងនោះបានចែងនៅថ្ងៃទី 1 ខែមករា ឆ្នាំ 2025 និងលើកលែងតែមានចែងផ្ទុយពីនេះនៅក្នុងច្បាប់នេះ ប្រាក់នៅក្នុងមូលនិធិបម្រុងនឹងមិនត្រូវផ្តល់ឱ្យគេខ្ចី ផ្តល់ជាឥណទាន ឬផ្ទេរទៅមូលនិធិទូទៅ ឬមូលនិធិ ឬគណនីរបស់រដ្ឋ ឬមូលដ្ឋានផ្សេងទៀតឡើយ។ ប្រាក់ដែលដាក់ចូលក្នុងមូលនិធិបម្រុងត្រូវប្រើប្រាស់សម្រាប់តែគោលបំណងជាក់លាក់ដែលច្បាប់ចែងប៉ុណ្ណោះ។ គ្មានសកម្មភាពណាត្រូវធ្វើឡើងដែលផ្លាស់ប្តូរស្ថានភាពមូលនិធិបម្រុងជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្ន ឬខ្ចី បង្វែរ ឬបែងចែកយកប្រាក់នៅក្នុងមូលនិធិបម្រុងក្នុងលក្ខណៈផ្ទុយពីផ្នែករងនេះឡើយ។

(h) ទោះបីជាមានចែងនៅក្នុងផ្នែកទី 32 ឬបទប្បញ្ញត្តិផ្សេងទៀតនៃច្បាប់ក៏ដោយ បណ្តឹងប្រឆាំងនឹងសុពលភាពតាមផ្នែកអត្ថបទ ទៅនឹងច្បាប់ស្តីពីពន្ធលើមហាសេដ្ឋីឆ្នាំ 2026 ត្រូវបានអនុញ្ញាតឱ្យកាត់សេចក្តីតាមរយៈសំណុំរឿងបញ្ជាក់សុពលភាព ក្រោមផ្នែកទី 50314 នៃក្រមប្រាក់ចំណូល និងពន្ធដារ ដោយមិនតម្រូវឱ្យបង់ពន្ធដែលត្រូវបានអះអាងថាគ្មានសុពលភាពទាំងស្រុងនោះឡើយ។ ផ្នែករងនេះត្រូវបានអនុម័តដោយគ្មានអត្ថន័យបង្កប់ពាក់ព័ន្ធនឹងសមត្ថកិច្ចបច្ចុប្បន្ន ឬការវិវត្តនៃច្បាប់ក្រៅពីច្បាប់នេះឡើយ។ គ្មានចំណុចណាមួយនៅក្នុងផ្នែករងនេះដាក់កំហិតលើសិទ្ធិរបស់អ្នកបង់ពន្ធណាម្នាក់ក្នុងការបង់ពន្ធដែលបានកំណត់ក្រោមច្បាប់នេះ និងស្នើសុំការសងប្រាក់វិញ ឬការត្រួតពិនិត្យតាមផ្លូវតុលាការ ឬដាក់ពាក្យបណ្តឹងផ្សេងទៀតដែលត្រូវបានអនុញ្ញាតដោយច្បាប់ និងមិនផ្ទុយនឹងផ្នែករងនេះ។

ផ្នែកទី 5. ប្រការ 1.1 (ចាប់ផ្តើមជាមួយផ្នែកទី 16355) ត្រូវបានបន្ថែមទៅជំពូកទី 2 នៃភាគទី 2 នៃផ្នែកទី 4 នៃចំណងជើងទី 2 នៃក្រមរដ្ឋាភិបាលដោយចែងថា៖

ប្រការ 1.1. មូលនិធិបម្រុងពន្ធលើមហាសេដ្ឋីឆ្នាំ 2026

16355. (a) ផ្នែកទី 37 នៃមាត្រា XIII នៃរដ្ឋធម្មនុញ្ញរដ្ឋ California ចែងអំពីការបង្កើតមូលនិធិបម្រុងពន្ធលើមហាសេដ្ឋីឆ្នាំ 2026 ដែលក្នុងនោះប្រាក់ចំណូលទាំងអស់ពីច្បាប់ស្តីពីពន្ធលើមហាសេដ្ឋីឆ្នាំ 2026 ត្រូវដាក់ចូល។

(b) បន្ទាប់ពីទូទាត់ចំណាយរដ្ឋបាលដូចមានចែងក្នុងផ្នែករង (e) អគ្គមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ ត្រូវបែងចែក និងផ្ទេរប្រាក់ដែលនៅសល់នៅក្នុងមូលនិធិបម្រុងដូចខាងក្រោម៖

(1) កៅសិបភាគរយត្រូវបែងចែកទៅឱ្យគណនីសុខភាពពន្ធលើមហាសេដ្ឋីសម្រាប់ការផ្តល់មូលនិធិថែទាំសុខភាព រួមមានជាអាទិ៍ ការចំណាយដើម្បីស្តារ ឬដោះស្រាយរាល់ការកាត់បន្ថយមូលនិធិរបស់សហព័ន្ធ ឬថវិកាអនុម័តរបស់រដ្ឋ; ការវិនិយោគដើម្បីការពារ ឬលើកកម្ពស់កម្មវិធី Medi-Cal និងកម្មវិធីធានារ៉ាប់រងសុខភាពផ្សេងទៀតសម្រាប់បុគ្គលដែលមានប្រាក់ចំណូលទាប និងមធ្យម; ការគាំទ្រដល់អ្នកផ្តល់សេវាថែទាំសុខភាពនៃបណ្តាញការពារសុខភាពសង្គមដែលបម្រើប្រជាជនងាយរងគ្រោះ; ការទប់ស្កាត់ ឬកាត់បន្ថយផលប៉ះពាល់នៃការបិទគ្រឹះស្ថាន ឬការកាត់បន្ថយកម្រិតសេវា; និងការវិនិយោគផ្សេងទៀតដើម្បីគាំទ្រដល់សិទ្ធិទទួលបានការថែទាំសុខភាព ការធានារ៉ាប់រង អត្ថប្រយោជន៍ មូលនិធិ សេវាកម្ម និងការទូទាត់ប្រាក់ដល់អ្នកផ្តល់សេវា។

(2) ដប់ភាគរយត្រូវបែងចែកទៅឱ្យគណនីអប់រំពន្ធលើមហាសេដ្ឋី និងជំនួយស្បៀងអាហារសម្រាប់ការចំណាយពាក់ព័ន្ធនឹងការអប់រំ និងជំនួយស្បៀងអាហារ រួមទាំងចំណុចទាំងពីរខាងក្រោម៖

(A) ការចំណាយពាក់ព័ន្ធនឹងការអប់រំដើម្បីស្តារ ឬដោះស្រាយរាល់ការកាត់បន្ថយមូលនិធិរបស់សហព័ន្ធ ឬថវិកាអនុម័តរបស់រដ្ឋ ឬធ្វើការវិនិយោគដើម្បីការពារ ឬលើកកម្ពស់ប្រព័ន្ធអប់រំសាធារណៈពីថ្នាក់ពីថ្នាក់មត្តេយ្យ រហូតដល់ថ្នាក់ទី 14។

(B) ការចំណាយលើជំនួយស្បៀងអាហារដើម្បីស្តារ ឬដោះស្រាយរាល់ការកាត់បន្ថយមូលនិធិរបស់សហព័ន្ធ ឬថវិកាអនុម័តរបស់រដ្ឋ ឬការវិនិយោគបន្ថែមនៅក្នុងកម្មវិធីនានា រួមទាំង CalFresh, CFAP, CalFood ឬកម្មវិធីអាហារសកលរបស់រដ្ឋ California សម្រាប់អាហារសាលារៀន។

(c) អង្គនីតិបញ្ញត្តិមានសិទ្ធិអនុម័តថវិការហូតដល់ពីរម៉ឺនពីរពាន់ប្រាំរយលានដុល្លារ ($22,500,000,000) ក្នុងឆ្នាំសារពើពន្ធនីមួយៗពីគណនីសុខភាពពន្ធលើមហាសេដ្ឋី និងរហូតដល់ពីរពាន់ប្រាំរយលានដុល្លារ ($2,500,000,000) ក្នុងមួយឆ្នាំៗពីគណនីអប់រំពន្ធលើមហាសេដ្ឋី និងជំនួយស្បៀងអាហារ។ អង្គនីតិបញ្ញត្តិអាចអនុម័តថវិកាចំនួនទឹកប្រាក់ទាបជាងនេះ ប្រសិនបើស្ថាប័ននេះកំណត់ថា ការរក្សាទុកមូលនិធិជាទុនបម្រុងគឺចាំបាច់ដើម្បីជំរុញគោលបំណងនៃវិធានការនេះ។

(d) ការបម្រុងទុកប្រាក់ពីមូលនិធិបម្រុងមិនត្រូវយកមកប្រើប្រាស់ជាហេតុផលដើម្បីកាត់បន្ថយ បំបាត់ចោល ឬខកខានក្នុងការបង្កើនទុនបម្រុងផ្សេងទៀតរបស់រដ្ឋសម្រាប់កម្មវិធីថែទាំសុខភាព ការអប់រំ ឬជំនួយស្បៀងអាហារឡើយ។ ការអនុម័តថវិកាមូលនិធិពីវិធានការនេះមិនត្រូវយកមកប្រើប្រាស់ដើម្បីជំនួសមូលនិធិរដ្ឋដែលមានស្រាប់សម្រាប់កម្មវិធីថែទាំសុខភាព ការអប់រំ ឬជំនួយស្បៀងអាហារឡើយ។

(e) នាយកនាយកដ្ឋានហិរញ្ញវត្ថុត្រូវផ្ទេរទៅឱ្យក្រុមប្រឹក្សាពន្ធលើសិទ្ធិអាជីវកម្ម ក្នុងទម្រង់ជាកម្ចីចាប់ផ្តើមដំណើរការពីមូលនិធិបម្រុង ឬមូលនិធិទូទៅរហូតដល់ចំនួនហាសិបលានដុល្លារ ($50,000,000) សម្រាប់ឆ្នាំដំបូងបន្ទាប់ពីការអនុម័តច្បាប់នេះសម្រាប់ចំណាយជាក់ស្តែង និងចាំបាច់ក្នុងការបំពេញភារកិច្ចរបស់ខ្លួនក្រោមច្បាប់នេះ និងសម្រាប់ការរាយតម្លៃប្រសិទ្ធភាពការងារ។ កម្ចីទាំងឡាយដែលបានផ្តល់ស្របតាមផ្នែករងនេះត្រូវបង់សងវិញដោយប្រើពន្ធដែលប្រមូលបានស្របតាមច្បាប់ស្តីពីពន្ធលើមហាសេដ្ឋីឆ្នាំ 2026 និងនៅមុនការធ្វើការចំណាយ ឬការអនុម័តថវិកាពីមូលនិធិបម្រុង។ នៅឆ្នាំបន្តបន្ទាប់ទៀត ក្រុមប្រឹក្សាពន្ធលើសិទ្ធិអាជីវកម្មត្រូវទទួលបានការទូទាត់សងប្រាក់វិញជារៀងរាល់ឆ្នាំពីមូលនិធិបម្រុង សម្រាប់ចំណាយជាក់ស្តែង និងចាំបាច់ក្នុងការបំពេញភារកិច្ចរបស់ខ្លួនក្រោមច្បាប់នេះ និងសម្រាប់ការរាយតម្លៃពីប្រសិទ្ធភាពរបស់វា។ កិច្ចព្រមព្រៀងអន្តរទីភ្នាក់ងារទាំងឡាយដែលបានចុះដោយក្រុមប្រឹក្សាពន្ធលើសិទ្ធិអាជីវកម្មសម្រាប់ការគ្រប់គ្រងច្បាប់នេះ ត្រូវបានគ្រប់ដណ្តប់ដោយចំនួនទឹកប្រាក់ដែលបានចែងនៅក្នុងផ្នែករងនេះ។

(f) ក្រោយការអនុម័តច្បាប់ស្តីពីពន្ធលើមហាសេដ្ឋីឆ្នាំ 2026 និងក្នុងឆ្នាំសារពើពន្ធនីមួយៗបន្ទាប់ពីនោះដែលមូលនិធិបម្រុងនៅតែបន្តមាននាយកដ្ឋានហិរញ្ញវត្ថុដោយមានការពិគ្រោះយោបល់ជាមួយទីភ្នាក់ងាររដ្ឋពាក់ព័ន្ធ ត្រូវផ្តល់ជូនអង្គនីតិបញ្ញត្តិនូវព័ត៌មានទាំងអស់ខាងក្រោម៖

(1) សមតុល្យបច្ចុប្បន្ននៅក្នុងមូលនិធិបម្រុងគិតត្រឹមកាលបរិច្ឆេទរាយការណ៍។

(2) ប្រាក់ចំណូលប៉ាន់ស្មានដែលនឹងត្រូវបង្កើតឡើងសម្រាប់មូលនិធិបម្រុងសម្រាប់ឆ្នាំសារពើពន្ធបច្ចុប្បន្ន និងសម្រាប់រយៈពេលដែលច្បាប់ស្តីពីពន្ធលើមហាសេដ្ឋីឆ្នាំ 2026 ត្រូវបានរំពឹងថានឹងបង្កើតប្រាក់ចំណូលសម្រាប់មូលនិធិបម្រុង។

40

(3) ចំនួនទឹកប្រាក់ប៉ាន់ស្មាន និងក្នុងករណីដែលអាចកំណត់បានដោយសមហេតុផល ចំនួនទឹកប្រាក់ជាក់ស្តែង ដែលត្រូវការដើម្បីស្តារការកាត់បន្ថយមូលនិធិរបស់សហព័ន្ធ និងថវិកាអនុម័តរបស់រដ្ឋ ដូចមានចែងក្នុងផ្នែករង (h)។

(4) ការចំណាយពីមូលនិធិបម្រុងដែលបានស្នើឡើងសម្រាប់ឆ្នាំសារពើពន្ធខាងមុខ ដែលមានបំណងស្តារការកាត់បន្ថយមូលនិធិរបស់សហព័ន្ធ និងថវិកាអនុម័តរបស់រដ្ឋ ដូចមានចែងក្នុងផ្នែករង (h)។

(5) ការចំណាយពីមុន (បើមាន) ពីមូលនិធិបម្រុង និងការបែងចែករបស់វា។

(6) ចំនួនទឹកប្រាក់ (បើមាន) ដែលត្រូវបានណែនាំឱ្យបម្រុងទុកសម្រាប់ឆ្នាំសារពើពន្ធបន្តបន្ទាប់ ដោយផ្អែកលើការកាត់បន្ថយមូលនិធិរបស់សហព័ន្ធ និងថវិកាអនុម័តរបស់រដ្ឋដែលរំពឹងទុកនាពេលអនាគត។

(7) ការបញ្ជាក់ថាប្រាក់ពីមូលនិធិបម្រុងមិនត្រូវបានយកមកប្រើប្រាស់ដើម្បីដាក់ជំនួស ឬជំនួសមូលនិធិរបស់រដ្ឋដែលនឹងត្រូវបានអនុម័តថវិកាតាមរបៀបផ្សេង។

(g) បន្ទាប់ពីនាយកនាយកដ្ឋានហិរញ្ញវត្ថុកំណត់ថា ប្រាក់ចំណូលទាំងអស់ដែលបានមកពីច្បាប់ស្តីពីពន្ធលើមហាសេដ្ឋីឆ្នាំ 2026 ត្រូវបានប្រមូល និងចំណាយរួចហើយ អង្គនីតិបញ្ញត្តិមានសិទ្ធិលុបចោលមូលនិធិបម្រុងនោះបាន។

(h) សម្រាប់គោលបំណងនៃផ្នែកនេះ៖

(1) "ការកាត់បន្ថយមូលនិធិរបស់សហព័ន្ធ" និងការយោងផ្សេងទៀតដល់ការកាត់បន្ថយ ឬការកាត់មូលនិធិរបស់សហព័ន្ធ មានន័យថា ការថយចុះណាមួយនៃការចូលរួមហិរញ្ញវត្ថុសហព័ន្ធ ជំនួយឥតសំណង ការទូទាត់ការទូទាត់សង ឬមូលនិធិរបស់សហព័ន្ធផ្សេងទៀតដែលបានផ្តល់ឱ្យរដ្ឋ California សម្រាប់កម្មវិធីថែទាំសុខភាព ការអប់រំ ឬជំនួយស្បៀងអាហារដោយផ្ទៀបនឹងកម្រិតនៃឆ្នាំសារពើពន្ធរដ្ឋ 2024–25 ដែលត្រូវបានកែសម្រួលសម្រាប់អតិផរណា និងកំណើនប្រជាជន រួមមានជាអាទិ៍៖ (A) ការកាត់បន្ថយភាគរយជំនួយវេជ្ជសាស្ត្រសហព័ន្ធរបស់ Medicaid; (B) ការផ្លាស់ប្តូរវិធានសិទ្ធិទទួលបានសហព័ន្ធដែលកាត់បន្ថយចំនួនប្រជាជនដែលគ្របដណ្តប់; (C) ការកាត់បន្ថយថវិកាអនុម័តតាមឆន្ទានុសិទ្ធិរបស់សហព័ន្ធ; (D) ការកំណត់ ឬការដាក់កំហិតលើពន្ធលើអ្នកផ្តល់សេវារបស់សហព័ន្ធ ឬការទូទាត់តាមការណែនាំ; (E) លក្ខខណ្ឌការងារ ឬលក្ខខណ្ឌរដ្ឋបាលផ្សេងទៀតដែលកាត់បន្ថយការចុះឈ្មោះ; (F) ការកាត់បន្ថយរយៈពេលគ្របដណ្តប់ថយក្រោយ; (G) ការអនុវត្ត ច្បាប់សាធារណៈ 119-21; ឬ (H) ការកាត់បន្ថយផ្សេងទៀតលើមូលនិធិរបស់សហព័ន្ធដែលគំរាមកំហែង ឬបង្កឱ្យមានការកាត់បន្ថយ Medi-Cal ឬការគ្របដណ្តប់ការថែទាំសុខភាព សិទ្ធិទទួលបាន អត្ថប្រយោជន៍ មូលនិធិ កម្មវិធី សេវាកម្ម និងប្រាក់ទូទាត់ជូនអ្នកផ្តល់សេវាផ្សេងទៀត ដែលប៉ះពាល់ដល់បុគ្គលដែលមានប្រាក់ចំណូលទាបនិងមធ្យម មូលនិធិអប់រំ ឬជំនួយស្បៀងអាហារទូទាំងរដ្ឋ ឬបណ្តាញការពារសុខភាពសង្គមជាទូទៅ។

(2) "ការកាត់បន្ថយថវិកាអនុម័តរបស់រដ្ឋ" ឬការយោងផ្សេងទៀតដល់ការកាត់បន្ថយ ឬការកាត់ថវិកាអនុម័តរបស់រដ្ឋ មានន័យថា ការថយចុះនូវថវិកាអនុម័តសម្រាប់កម្មវិធីថែទាំសុខភាព ការអប់រំ ឬជំនួយស្បៀងអាហារទូទាំងរដ្ឋណាមួយ ឬទាំងអស់ក្រោមកម្រិតឆ្នាំសារពើពន្ធរដ្ឋ 2024–25 ដែលបង្កឱ្យមានការកាត់បន្ថយ Medi-Cal ឬការគ្របដណ្តប់ការថែទាំសុខភាព សិទ្ធិទទួលបាន អត្ថប្រយោជន៍ មូលនិធិ កម្មវិធី សេវាកម្ម និងប្រាក់ទូទាត់ជូនអ្នកផ្តល់សេវាផ្សេងទៀត ដែលប៉ះពាល់ដល់បុគ្គលដែលមានប្រាក់ចំណូលទាបនិងមធ្យម លុះត្រាតែការកាត់បន្ថយទាំងនេះត្រូវបានបង្កឡើងដោយការថយចុះនូវចំនួនករណីអ្នកទទួលសេវាដែលបានកត់ត្រា ការចុះឈ្មោះ ឬប្រជាជនដែលមានលក្ខណៈឯករាជ្យពីការកាត់បន្ថយមូលនិធិរបស់សហព័ន្ធ; ឬការកាត់បន្ថយថវិកាអនុម័តរបស់រដ្ឋសម្រាប់កម្មវិធីអប់រំសាធារណៈពីថ្នាក់ kindergarten រហូតដល់ថ្នាក់ទី 14 ឬកម្មវិធីជំនួយស្បៀងអាហារ។

(3) "មូលនិធិបម្រុង" សំដៅលើមូលនិធិបម្រុងពន្ធលើមហាសេដ្ឋីឆ្នាំ 2026។

ផ្នែកទី 6. ផ្នែក 17220 នៃក្រមប្រាក់ចំណូល និងពន្ធដារត្រូវបានធ្វើវិសោធនកម្ម ដោយចែងថា៖

17220. (a) ផ្នែក 164(a)(3) នៃ ក្រមពន្ធដារផ្នែកក្នុង ដែលពាក់ព័ន្ធនឹងលទ្ធភាពកាត់កងពន្ធលើប្រាក់ចំណូលរបស់រដ្ឋ មូលដ្ឋាន និងបរទេស ពន្ធលើប្រាក់ចំណេញសង្គ្រាម និងពន្ធលើប្រាក់ចំណេញលើស មិនត្រូវបានអនុវត្តឡើយ។

(b) ផ្នែក 164(b)(5) នៃ ក្រមពន្ធដារផ្នែកក្នុង ដែលពាក់ព័ន្ធនឹងពន្ធលើការលក់ទូទៅ មិនត្រូវបានអនុវត្តឡើយ។

(c) ផ្នែក 164(b)(6) នៃ ក្រមពន្ធដារផ្នែកក្នុង ដែលពាក់ព័ន្ធនឹងការដាក់កំហិតលើការកាត់ពន្ធបុគ្គលសម្រាប់ឆ្នាំជាប់ពន្ធ 2018 ដល់ 2025 មិនត្រូវបានអនុវត្តឡើយ។

(d) បន្ថែមពីលើបទប្បញ្ញត្តិនៃមាត្រា 164(c) នៃក្រមពន្ធដារផ្នែកក្នុង ដែលពាក់ព័ន្ធនឹងការកាត់កងពន្ធដែលត្រូវបានបដិសេធក្នុងករណីពន្ធជាក់លាក់ ការកាត់កងពន្ធមិនត្រូវបានអនុញ្ញាតឡើយចំពោះពន្ធដែលបានកំណត់ក្រោមជំពូកទី 10.5 (ចាប់ផ្តើមជាមួយផ្នែកទី 17935) ជំពូកទី 10.6 (ចាប់ផ្តើមជាមួយផ្នែកទី 17941) ឬជំពូកទី 10.7 (ចាប់ផ្តើមជាមួយផ្នែកទី 17948) នៃភាគនេះ ឬក្រោមភាគទី 11 (ចាប់ផ្តើមជាមួយផ្នែកទី 23001)។

(e) ការកាត់កងពន្ធមិនត្រូវបានអនុញ្ញាតឡើយចំពោះពន្ធដែលបានកំណត់ដោយរដ្ឋលើតម្លៃសុទ្ធនៃទ្រព្យសម្បត្តិ រួមទាំងច្បាប់ស្តីពីពន្ធលើមហាសេដ្ឋីឆ្នាំ 2026 (ភាគទី 27 (ចាប់ផ្តើមជាមួយផ្នែកទី 50300)) ទោះជាមានចែងក្នុងបទប្បញ្ញត្តិផ្សេងទៀតនៃច្បាប់ក៏ដោយ រួមទាំងមាត្រា 164(a)(2) នៃក្រមពន្ធដារផ្នែកក្នុង ដែលពាក់ព័ន្ធនឹងលទ្ធភាពកាត់កងពន្ធលើទ្រព្យសម្បត្តិបុគ្គល។

ផ្នែកទី 7. ភាគទី 27 (ចាប់ផ្តើមជាមួយផ្នែកទី 50300) ត្រូវបានបន្ថែមទៅផ្នែកទី 2 នៃក្រមប្រាក់ចំណូល និងពន្ធដារ ដោយចែងថា៖

ភាគទី 27. ច្បាប់ស្តីពីពន្ធលើមហាសេដ្ឋីឆ្នាំ 2026

ជំពូកទី 1. ការដាក់ពន្ធលើទ្រព្យសម្បត្តិបុគ្គល ដែលមានតម្លៃសុទ្ធនៃទ្រព្យសម្បត្តិលើស $1 ពាន់លាន

50300. ភាគនេះនឹងត្រូវបានគេស្គាល់ ហើយអាចត្រូវបានលើកឡើងថាជា ច្បាប់ស្តីពីពន្ធលើមហាសេដ្ឋីឆ្នាំ 2026។

50301. (a) ពន្ធអាករត្រូវបានកំណត់សម្រាប់ឆ្នាំពន្ធ 2026 លើសកម្មភាពនៃការរក្សាទុកនូវការប្រមូលផ្តុំទ្រព្យសម្បត្តិហួសហេតុដោយបុគ្គលដែលអនុវត្តដែលមានតម្លៃសុទ្ធនៃទ្រព្យសម្បត្តិចាប់ពីមួយពាន់លានដុល្លារ ($1,000,000,000) ឡើងទៅ និងលើទ្រព្យបាលដែលអនុវត្ត។ សម្រាប់គោលបំណងនៃភាគនេះ ការកំណត់ថាតើបុគ្គល ឬទ្រព្យបាលណាជាបុគ្គលដែលអនុវត្ត ឬទ្រព្យបាលដែលអនុវត្ត ត្រូវបានកំណត់គិតត្រឹមថ្ងៃជាប់កាតព្វកិច្ចពន្ធ ហើយចំនួនតម្លៃសុទ្ធនៃទ្រព្យសម្បត្តិដែលជាប់ពន្ធត្រូវវាស់វែងគិតត្រឹមកាលបរិច្ឆេទវាយតម្លៃ។ សម្រាប់គោលបំណងនៃផ្នែកនេះដែលពាក់ព័ន្ធនឹងការដាក់លិខិតប្រកាសពន្ធ ប្តីប្រពន្ធត្រូវចាត់ទុកថាជាបុគ្គលតែម្នាក់។

(b) ចំពោះបុគ្គល និងទ្រព្យបាលដែលពន្ធត្រូវបានកំណត់ក្រោមផ្នែករង (a) ពន្ធដែលបានកំណត់គឺ 5 ភាគរយនៃតម្លៃសុទ្ធនៃទ្រព្យសម្បត្តិរបស់បុគ្គល ឬទ្រព្យបាលនោះ។ ក្នុងករណីបុគ្គល (ក្រៅពីទ្រព្យបាល) ដែលមានតម្លៃសុទ្ធនៃទ្រព្យសម្បត្តិតិចជាងមួយពាន់មួយរយលានដុល្លារ ($1,100,000,000), ពន្ធដែលកំណត់ដោយផ្នែកនេះត្រូវកាត់បន្ថយចំនួន 0.1 ពិន្ទុភាគរយ ប៉ុន្តែមិនត្រូវឱ្យទាបជាងសូន្យឡើយ សម្រាប់រាល់ពីរលានដុល្លារ ($2,000,000) ដែលតម្លៃសុទ្ធនៃទ្រព្យសម្បត្តិរបស់បុគ្គលនោះធ្លាក់ក្រោមមួយពាន់មួយរយលានដុល្លារ ($1,100,000,000)។ ក្នុងករណីបុគ្គល (ក្រៅពីទ្រព្យ

បាល) ដែលជ្រើសរើសបង្កើតគណនីការពន្យារពេលសងជាជម្រើស (ODA) ស្របតាមផ្នែកទី 50304 ទ្រព្យសកម្មដែលភ្ជាប់នឹង ODA មិនត្រូវស្ថិតក្រោមពន្ធក្រោមផ្នែកនេះឡើយ លុះត្រាតែបញ្ជាក់ដោយផ្នែក 50304។

(c) លើកលែងតែមានចែងក្នុងផ្នែករង (b) ពន្ធបន្ថែមណាមួយដែលត្រូវបង់ដែលជាលទ្ធផលនៃផ្នែកនេះ ឬផ្នែកទី 50304 សម្រាប់ឆ្នាំពន្ធណាមួយត្រូវតែរាយការណ៍រួមគ្នា និងដល់កំណត់បង់ក្នុងពេលជាមួយគ្នាជាមួយនឹងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំរបស់អ្នកបង់ពន្ធក្រោមភាគទី 10 (ចាប់ផ្តើមជាមួយផ្នែកទី 17001)។ អ្នកបង់ពន្ធដែលមានកាតព្វកិច្ចបង់ពន្ធបន្ថែមណាមួយដែលបានកំណត់ក្រោមផ្នែកនេះ ត្រូវមានជម្រើស៖ (1) បង់ពន្ធណាមួយដែលដល់កំណត់ក្រោមភាគនេះ រួមជាមួយពន្ធលើប្រាក់ចំណូលណាមួយដែលជំពាក់សម្រាប់ឆ្នាំពន្ធ 2026 ឬ (2) បង់ជា 5 ដំណាក់ប្រចាំឆ្នាំស្មើៗគ្នាដោយចាប់ផ្តើមពីឆ្នាំដែលពន្ធនោះដល់កំណត់បង់ ដែលការបង់ប្រាក់ដំណាក់ប្រចាំឆ្នាំជាបន្តបន្ទាប់នីមួយៗក៏ត្រូវស្ថិតក្រោមការគិតថ្លៃសេវាពន្យារពេលសងប្រចាំឆ្នាំដែលមិនអាចទូទាត់កាត់កងពន្ធបានក្នុងអត្រា 7.5 ភាគរយនៃសមតុល្យដែលនៅសល់មិនទាន់បានបង់ផងដែរ។

(d) នៅពេលលិខិតប្រកាសពន្ធត្រូវបានដាក់ស្នើស្របតាមផ្នែកទី 18501 ដែលពាក់ព័ន្ធនឹងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលសម្រាប់ឆ្នាំពន្ធ 2026 អ្នករស់នៅរដ្ឋ California គ្រប់រូបដែលត្រូវបានតម្រូវឱ្យដាក់លិខិតប្រកាសពន្ធ ត្រូវធ្វើមួយក្នុងចំណោមចំណុចខាងក្រោម៖

(1) ប្រកាសថា ទ្រព្យសកម្មសុទ្ធរបស់បុគ្គលមានតម្លៃតិចជាង ឬស្មើនឹងមួយពាន់លានដុល្លារ ($1,000,000,000) គិតត្រឹមកាលបរិច្ឆេទវាយតម្លៃ។

(2) ដាក់ស្នើលិខិតប្រកាសចំនួនទឹកប្រាក់ពន្ធបន្ថែមដែលជំពាក់នៅក្រោមភាគនេះ រួមជាមួយទម្រង់បែបបទដែលបង្កើតដោយក្រុមប្រឹក្សាសម្រាប់គណនាពន្ធបន្ថែមដែលត្រូវជំពាក់ក្រោមភាគនេះ រួមជាមួយការវាយតម្លៃដែលទាមទារ ឬភស្តុតាងផ្សេងទៀតនៃតម្លៃទីផ្សារយុត្តិធម៌។ ក្នុងករណីបុគ្គលដែលអនុវត្តដែលមិនត្រូវបានតម្រូវឱ្យដាក់លិខិតប្រកាសពន្ធក្រោមផ្នែកទី 18501 បុគ្គលនោះត្រូវដាក់ស្នើនូវលិខិតប្រកាស ទម្រង់បែបបទ ការវាយតម្លៃ ឬភស្តុតាងដែលបានពណ៌នានៅក្នុងកថាខណ្ឌនេះ ស្របតាមពេលវេលា និងរបៀបរបបនៃការដាក់ស្នើដែលត្រូវការសម្រាប់ការធ្វើលិខិតប្រកាសពន្ធលើប្រាក់ចំណូល។

(e) ទំនួលខុសត្រូវសវនកម្មរបស់ក្រុមប្រឹក្សា។

(1) ក្រុមប្រឹក្សាត្រូវធ្វើការពិនិត្យមើលលិខិតប្រកាសពន្ធទាំងអស់ដែលបានដាក់ស្នើស្របតាមភាគនេះ និងត្រូវកំណត់ពីចំនួនទឹកប្រាក់ពន្ធត្រឹមត្រូវក្រោមភាគនេះ។ ក្រុមប្រឹក្សាក៏ត្រូវពិនិត្យមើលវិញ្ញាបនបត្របញ្ជាក់ ឬលិខិតប្រកាសពន្ធទាំងអស់របស់អ្នកបង់ពន្ធផងដែរ នៅពេលក្រុមប្រឹក្សាជឿជាក់ដោយសមហេតុផលថា អ្នកបង់ពន្ធគួរបង់ពន្ធដែលកំណត់ដោយភាគនេះ។ ដោយមិនដាក់កំហិតលើអំណាចផ្សេងទៀតរបស់ក្រុមប្រឹក្សា ក្នុងការពិនិត្យមើលលិខិតប្រកាសពន្ធដែលបានដាក់ដោយអ្នកបង់ពន្ធ និងពិនិត្យមើលថាតើលិខិតប្រកាសពន្ធគួរតែត្រូវបានដាក់ដោយអ្នកបង់ពន្ធ ប៉ុន្តែមិនបានដាក់នោះទេ ក្រុមប្រឹក្សាមានអំណាចទាំងអស់ដែលចែងនៅក្នុងផ្នែកទី 19504។

(2) ទោះជាមានចែងក្នុងកថាខណ្ឌមុនក៏ដោយ ក្រុមប្រឹក្សានៅតែមានអំណាចក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិសមស្របរបស់ខ្លួនចំពោះរយៈពេល និងលក្ខណៈនៃការពិនិត្យមើលដែលសមស្របក្រោមកាលៈទេសៈ។

ជំពូកទី 2. ការគណនាតម្លៃសុទ្ធនៃទ្រព្យសម្បត្តិ

50302. បំណុលពិត និងការទទួលខុសត្រូវផ្សេងទៀតដែលជំពាក់ដោយអ្នកបង់ពន្ធនឹងត្រូវបានយកមកពិចារណាសម្រាប់គោលបំណងនៃការកំណត់តម្លៃសុទ្ធនៃទ្រព្យសម្បត្តិរបស់អ្នកបង់ពន្ធ។ បន្ថែមពីលើនេះ បំណុល និងការទទួលខុសត្រូវត្រូវយកមកពិចារណាដោយស្ថិតក្រោមដែនកំណត់ខាងក្រោម៖

(a) ចំពោះបំណុលដែលមានការធានាផ្ទាល់ខ្លួនដែលអ្នកបង់ពន្ធត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនយ៉ាងពេញលេញ ដោយគ្មានការកំណត់កម្រិតណាមួយក្រៅពីការកំណត់ដែលកើតចេញពីច្បាប់ស្តីពីក្ស័យធនត្រូវយកមកពិចារណាយ៉ាងពេញលេញ។

(b) ក្នុងករណីបំណុលក្រៅពីបំណុលដែលមានការធានាផ្ទាល់ខ្លួនដែលបានពណ៌នានៅក្នុងផ្នែករង (a) ចំពោះបំណុល ឬការទទួលខុសត្រូវនីមួយៗ ចំនួនទឹកប្រាក់ដែលអាចត្រូវយកមកពិចារណាមិនត្រូវមានចំនួនលើសពីទឹកប្រាក់ដែលបានរួមបញ្ចូលក្នុងតម្លៃសុទ្ធនៃទ្រព្យសម្បត្តិរបស់អ្នកបង់ពន្ធដែលកើតចេញពីទ្រព្យសម្បត្តិដែលធ្វើជាទ្រព្យបញ្ចាំសម្រាប់បំណុល ឬការទទួលខុសត្រូវនោះទេ។

(c) បំណុល និងការទទួលខុសត្រូវផ្សេងទៀតនៃឯកកម្មសិទ្ធិរបស់អ្នកបង់ពន្ធត្រូវកាត់បន្ថយតម្លៃសុទ្ធនៃទ្រព្យសម្បត្តិ ដូចជាថាវាជាបំណុល ឬការទទួលខុសត្រូវផ្សេងទៀតរបស់អ្នកបង់ពន្ធ។ តម្លៃសុទ្ធនៃទ្រព្យសម្បត្តិរបស់អ្នកបង់ពន្ធមិនត្រូវបានកាត់បន្ថយដោយចំនួនទឹកប្រាក់បំណុល ឬការទទួលខុសត្រូវផ្សេងទៀតនៃភាពជាដៃគូ ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ឬអង្គភាពអាជីវកម្មផ្សេងទៀត ក្រៅពីឯកកម្មសិទ្ធិ ដែលត្រូវបានបែងចែកមកឱ្យអ្នកបង់ពន្ធសម្រាប់គោលបំណងគណនាពន្ធនោះឡើយ លើកលែងតែក្នុងកម្រិតដែលអ្នកបង់ពន្ធត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះបំណុលនេះ ឬការទទួលខុសត្រូវផ្សេងទៀត។

(d) តម្លៃសុទ្ធនៃទ្រព្យសម្បត្តិរបស់អ្នកបង់ពន្ធមិនត្រូវបានកាត់បន្ថយដោយការធានារបស់អ្នកបង់ពន្ធចំពោះបំណុល ឬការទទួលខុសត្រូវផ្សេងទៀតរបស់បុគ្គលផ្សេងឡើយ។

(e) គ្មានបំណុល ឬការទទួលខុសត្រូវណាមួយ រួមទាំងបំណុលដែលមានការធានាផ្ទាល់ខ្លួនដែលពណ៌នានៅក្នុងផ្នែករង (a) នឹងកាត់បន្ថយតម្លៃសុទ្ធនៃទ្រព្យសម្បត្តិឡើយ ប្រសិនបើបំណុល ឬការទទួលខុសត្រូវនោះជំពាក់បុគ្គល ឬបុគ្គលដែលពាក់ព័ន្ធ; ប្រសិនបើអត្ថិភាព ឬចំនួនទឹកប្រាក់នៃការទទួលខុសត្រូវនោះអាស្រ័យលើព្រឹត្តិការណ៍នាពេលអនាគតដែលមានភាពមិនប្រាកដប្រជាថាតើនឹងកើតឡើងឬយ៉ាងណា ឬដែលមានភាពមិនប្រាកដប្រជាថាតើនឹងកើតឡើងក្នុងអំឡុងពេលប្រាំឆ្នាំបន្ទាប់ឬយ៉ាងណា ឬប្រសិនបើបំណុល ឬការទទួលខុសត្រូវនោះមិនត្រូវបានចរចាក្នុងលក្ខខណ្ឌឯករាជ្យនោះទេ។ បន្ថែមពីនេះ គ្មានចំនួនទឹកប្រាក់ណាមួយត្រូវបានយកមកពិចារណាសម្រាប់បំណុល ឬការទទួលខុសត្រូវណាមួយឡើយ លុះត្រាតែអត្រាការប្រាក់ទីផ្សារត្រូវបានគិតលើអ្នកបង់ពន្ធ។

(f) ការសន្យាថានឹងធ្វើការចូលរួមវិភាគទានជាបន្តបន្ទាប់ដល់អង្គការសប្បុរសធម៌ ឬអង្គការមនុស្សធម៌ នឹងមិនកាត់បន្ថយតម្លៃសុទ្ធនៃទ្រព្យសម្បត្តិឡើយ លើកលែងតែការសន្យានោះអាចអនុវត្តបានតាមផ្លូវច្បាប់ដោយអង្គការដែលទទួលបានការសន្យាចូលរួមវិភាគទាននោះ ហើយក្នុងគ្រប់ករណី ការសន្យាណាមួយមិនអាចកាត់បន្ថយតម្លៃសុទ្ធនៃទ្រព្យសម្បត្តិបានឡើយ ប្រសិនបើការសន្យានោះត្រូវបានធ្វើឡើងក្រោយថ្ងៃទី 15 ខែតុលា ឆ្នាំ 2025។

(g) រាល់បំណុល ឬការទទួលខុសត្រូវរបស់អ្នកបង់ពន្ធដែលជាថ្នូរនឹងអ្នកបង់ពន្ធមានសិទ្ធិទទួលបានអត្ថប្រយោជន៍នាពេលអនាគត ឬសិទ្ធិកម្មសិទ្ធិនៅពេលអនាគត រួមទាំងកាតព្វកិច្ចតាមកិច្ចសន្យាក្នុងការចូលរួមវិភាគទានដល់អង្គភាពណាមួយនៅថ្ងៃអនាគត ត្រូវកាត់បន្ថយតែតម្លៃសុទ្ធនៃទ្រព្យសម្បត្តិក្នុងកម្រិតដែល៖

(1) តម្លៃនៃអត្ថប្រយោជន៍ ឬសិទ្ធិកម្មសិទ្ធិនាពេលអនាគតនោះត្រូវបានរួមបញ្ចូលនៅក្នុងទ្រព្យសកម្មសុទ្ធរបស់អ្នកបង់ពន្ធ។

(2) អ្នកបង់ពន្ធអាចបង្ហាញតាមរយៈភស្តុតាងច្បាស់លាស់ និងគួរឱ្យទុកចិត្តថា ចំនួនទឹកប្រាក់ដែលជំពាក់ក្រោមបំណុល ឬការទទួលខុសត្រូវនោះ គឺលើសពីអត្ថប្រយោជន៍ ឬសិទ្ធិកម្មសិទ្ធិនាពេលអនាគតដែលមិនត្រូវបានរួមបញ្ចូលក្នុងទ្រព្យសកម្មសុទ្ធរបស់អ្នកបង់ពន្ធឡើយ។

(3) ក្នុងករណីនៃការសន្យាចូលរួមវិភាគទានជាបន្តបន្ទាប់ដល់អង្គការសប្បុរសធម៌ ឬអង្គការមនុស្សធម៌ដែលមានតម្លៃគតិយុត្តិ តម្លៃនៃអត្ថប្រយោជន៍នាពេលអនាគតដែលទទួលបានជាថ្នូរត្រូវមានតម្លៃស្មើនឹងសូន្យ លើកលែងតែក្នុងកម្រិតដែលអត្ថប្រយោជន៍ទាំងនោះបង្កើតបានជាអត្ថប្រយោជន៍សំខាន់សម្រាប់គោលបំណងនៃការកំណត់ការកាត់ពន្ធលើការចូលរួមវិភាគទានសប្បុរសធម៌របស់អ្នកចូលរួមវិភាគទាន។

40

50303. (a) លើកលែងតែមានការកំណត់ផ្សេងពីនេះដោយក្រុមប្រឹក្សា និងលើកលែងតែមានការចែងផ្សេងពីនេះនៅក្នុងផ្នែកនេះ តម្លៃទីផ្សារយុត្តិធម៌នៃទ្រព្យសកម្មនីមួយៗដែលជាកម្មសិទ្ធិរបស់អ្នកបង់ពន្ធ គឺជាតម្លៃដែលទ្រព្យសកម្មនោះអាចដោះដូរគ្នាបានរវាងអ្នកទិញដែលមានឆន្ទៈ និងអ្នកលក់ដែលមានឆន្ទៈ ដោយគ្មានភាគីណាមួយស្ថិតក្រោមការគាបសង្កត់ណាមួយក្នុងការទិញ ឬលក់ឡើយ ហើយភាគីទាំងសងខាងសុទ្ធតែមានចំណេះដឹងសមហេតុផលអំពីការពិតដែលពាក់ព័ន្ធ។ ទីតាំងទ្រព្យសកម្មនឹងត្រូវយកមកពិចារណានៅគ្រប់ករណីដែលសមស្រប។ ចំពោះទ្រព្យសកម្មដែលជាទូទៅត្រូវបានទិញដោយសាធារណជននៅលើទីផ្សារលក់រាយ តម្លៃទីផ្សារយុត្តិធម៌របស់ទ្រព្យសកម្មនោះ គឺជាតម្លៃដែលទំនិញនោះ ឬទំនិញប្រហាក់ប្រហែលគ្នាត្រូវដាក់លក់នៅលើទីផ្សារលក់រាយ។ តម្លៃទីផ្សារយុត្តិធម៌របស់ទ្រព្យសកម្មមិនត្រូវជាចំណុចណាមួយខាងក្រោមទេ៖

(1) តម្លៃដែលជាលទ្ធផលនៃការលក់ទ្រព្យសម្បត្តិដោយបង្ខំ។

(2) តម្លៃលក់នៅលើទីផ្សារផ្សេងក្រៅពីទីផ្សារដែលទ្រព្យសម្បត្តិនោះត្រូវបានលក់ជូនសាធារណជនជាទូទៅបំផុត ប្រសិនបើតម្លៃនៅលើទីផ្សារនោះនឹងបណ្តាលឱ្យមានតម្លៃទីផ្សារយុត្តិធម៌ទាបជាង លើកលែងតែក្នុងករណីទ្រព្យសម្បត្តិដែលស្ថិតក្រោមផ្នែកទី 423 ដែលពាក់ព័ន្ធនឹងការវាយតម្លៃដីបើកចំហដែលមានការដាក់កំហិត។

(b) លក្ខណៈពិសេសទាំងឡាយរបស់ទ្រព្យសកម្ម រួមទាំងផែនការសិទ្ធិភាគហ៊ុន មិនត្រូវយកមកពិចារណាក្នុងការកំណត់តម្លៃរបស់ទ្រព្យសកម្មនោះឡើយ ប្រសិនបើគោលបំណង និងផលប៉ះពាល់សំខាន់នៃការបន្ថែមលក្ខណៈពិសេសនោះ គឺដើម្បីកាត់បន្ថយតម្លៃវាយតម្លៃរបស់ទ្រព្យសកម្មនោះ។ គ្មានការបញ្ចុះតម្លៃក្នុងការវាយតម្លៃ ឬការបញ្ចុះតម្លៃផ្សេងទៀតត្រូវបានយកមកពិចារណាឡើយ ប្រសិនបើការបញ្ចុះតម្លៃនោះនឹងបណ្តាលឱ្យតម្លៃនៃផលប្រយោជន៍ផ្នែកខ្លះក្នុងទ្រព្យសកម្មនោះធ្លាក់ចុះទាបជាងចំណែកសមាមាត្ររបស់អ្នកបង់ពន្ធនៃតម្លៃទ្រព្យសកម្មទាំងមូល។

(c) វិធីសាស្ត្រវាយតម្លៃ ការដកចេញ និងលក្ខខណ្ឌរាយការណ៍ខាងក្រោមត្រូវអនុវត្តចំពោះប្រភេទទ្រព្យសកម្មជាក់លាក់៖

(1) សម្រាប់ទ្រព្យសកម្មដែលជួញដូរជាសាធារណៈទាំងអស់ តម្លៃទីផ្សារយុត្តិធម៌របស់ទ្រព្យសកម្មត្រូវបានសន្មតថាជាតម្លៃជួញដូរលើទីផ្សាររបស់ទ្រព្យសកម្មនោះនៅកាលបរិច្ឆេទវាយតម្លៃ ដូចបានកំណត់ក្នុងផ្នែករង (o) នៃផ្នែកទី 50308។

(2) សម្រាប់ឯកកម្មសិទ្ធិទាំងអស់ ទ្រព្យសកម្មទាំងអស់ដែលជាកម្មសិទ្ធិ ឬកាន់កាប់តាមរយៈឯកកម្មសិទ្ធិត្រូវរាយការណ៍ និងកំណត់តម្លៃដូចជាថាវាជាកម្មសិទ្ធិដោយផ្ទាល់ និងកាន់កាប់ដោយអ្នកបង់ពន្ធ និងមិនមែនតាមរយៈឯកកម្មសិទ្ធិនោះទេ។

(3) លើកលែងតែទ្រព្យសកម្ម និងអង្គភាពដែលគ្រប់គ្រងដោយកថាខណ្ឌ (1) និង (2) ចំពោះរាល់សិទ្ធិ ឬផលប្រយោជន៍ទាំងអស់ក្នុងអង្គភាពអាជីវកម្មណាមួយ រួមទាំងសិទ្ធិភាគហ៊ុន និងកម្មសិទ្ធិទាំងអស់ សិទ្ធិបំណុលទាំងអស់ ព្រមទាំងសិទ្ធិផ្នែកលើកិច្ចសន្យា ឬមិនមែនផ្នែកលើកិច្ចសន្យាផ្សេងទៀត ការវាយតម្លៃត្រូវធ្វើឡើងដូចខាងក្រោម៖

(A) អ្នកបង់ពន្ធត្រូវរាយការណ៍ចំណុចខាងក្រោមនៅពេលវេលាដែលដាក់ស្នើទម្រង់បែបបទស្របតាមជំពូកនេះ៖

(i) ភាគរយនៃអង្គភាពអាជីវកម្មដែលជាកម្មសិទ្ធិរបស់អ្នកបង់ពន្ធ។

(ii) តម្លៃតាមបញ្ជីនៃអង្គភាពអាជីវកម្មគិតត្រឹមថ្ងៃបញ្ចប់នៃឆ្នាំពន្ធ ដែលបានកំណត់ស្របតាមគោលការណ៍គណនេយ្យដែលទទួលស្គាល់ជាទូទៅ។

(iii) ប្រាក់ចំណេញតាមបញ្ជីនៃអង្គភាពអាជីវកម្មក្នុងឆ្នាំពន្ធស្របតាមគោលការណ៍គណនេយ្យដែលទទួលស្គាល់ជាទូទៅ។ សម្រាប់គោលបំណងនៃកថាខណ្ឌនេះ "ឆ្នាំពន្ធ" របស់អង្គភាពអាជីវកម្ម មានន័យថា ឆ្នាំពន្ធចុងក្រោយរបស់អង្គភាពអាជីវកម្មដែលបញ្ចប់នៅក្នុង ឬត្រឹមឆ្នាំពន្ធរបស់អ្នកបង់ពន្ធ។

(B) ប្រសិនបើមិនអាចធ្វើការរាយការណ៍ដែលតម្រូវក្រោមកថាខណ្ឌរង (A) បានទេ ដោយសារអ្នកបង់ពន្ធគ្មានព័ត៌មានអំពីតម្លៃតាមបញ្ជី ឬប្រាក់ចំណេញតាមបញ្ជីរបស់អង្គភាពអាជីវកម្ម ហើយក៏គ្មានសិទ្ធិទទួលបានព័ត៌មាននោះផងដែរ អ្នកបង់ពន្ធត្រូវតែដាក់ស្នើរបាយការណ៍វាយតម្លៃដែលបានបញ្ជាក់ជាផ្លូវការនូវផលប្រយោជន៍ទាំងអស់របស់អ្នកបង់ពន្ធនៅក្នុងអង្គភាពអាជីវកម្មនោះ។

(C) ចំពោះផលប្រយោជន៍ទាំងឡាយណាដែលផ្តល់នូវសិទ្ធិបោះឆ្នោត ឬសិទ្ធិគ្រប់គ្រងដោយផ្ទាល់ផ្សេងទៀត ភាគរយនៃអង្គភាពអាជីវកម្មដែលកាន់កាប់ដោយអ្នកបង់ពន្ធនោះ ត្រូវសន្មតថាមានចំនួនមិនតិចជាងភាគរយរបស់អ្នកបង់ពន្ធនៃសិទ្ធិបោះឆ្នោតសរុប ឬសិទ្ធិគ្រប់គ្រងដោយផ្ទាល់ផ្សេងទៀតនោះឡើយ។

(D) ចំពោះផលប្រយោជន៍ប្រាក់ចំណេញទាំងឡាយនៅក្នុងអង្គភាពអាជីវកម្ម ភាគរយនៃអង្គភាពដែលកាន់កាប់ដោយអ្នកបង់ពន្ធ ត្រូវសន្មតថាមានចំនួនមិនតិចជាងភាគរយផលប្រយោជន៍អតិបរមានៃប្រាក់ចំណេញរបស់អង្គភាពនោះដែលអ្នកបង់ពន្ធអាចទទួលបាន ដោយមិនគិតថាតើផលប្រយោជន៍ប្រាក់ចំណេញនោះស្ថិតក្រោមលក្ខខណ្ឌទុកមុនដែលមិនទាន់ត្រូវបានបំពេញនៅឡើយនោះទេ។

(E) លើកលែងតែទ្រព្យសកម្ម និងអង្គភាពដែលគ្រប់គ្រងដោយកថាខណ្ឌ (1) និង (2) ចំពោះផលប្រយោជន៍ផ្សេងទៀតទាំងអស់នៅក្នុងអង្គភាពអាជីវកម្ម រួមទាំងសិទ្ធិភាគហ៊ុន និងសិទ្ធិកម្មសិទ្ធិផ្សេងទៀត សិទ្ធិបំណុលទាំងអស់ និងសិទ្ធិផ្នែកលើកិច្ចសន្យា ឬមិនមែនផ្នែកលើកិច្ចសន្យាផ្សេងទៀត តម្លៃទីផ្សារយុត្តិធម៌នៃផលប្រយោជន៍ទាំងនោះនៅចុងបញ្ចប់នៃឆ្នាំពន្ធ ត្រូវសន្មតថាជាផលបូកនៃតម្លៃតាមបញ្ជីរបស់អង្គភាពអាជីវកម្មនោះស្របតាមគោលការណ៍គណនេយ្យដែលទទួលស្គាល់ជាទូទៅគិតត្រឹមថ្ងៃបញ្ចប់ឆ្នាំពន្ធ បូកនឹងមេគុណតម្លៃបច្ចុប្បន្ន 7.5 ដងនៃប្រាក់ចំណេញតាមបញ្ជីប្រចាំឆ្នាំរបស់អង្គភាពអាជីវកម្ម គិតជាមធ្យមភាគលើឆ្នាំពន្ធបច្ចុប្បន្ន និងឆ្នាំពន្ធពីរមុននោះ ប្រសិនបើមាន ស្របតាមគោលការណ៍គណនេយ្យដែលទទួលស្គាល់ជាទូទៅ ដោយផលបូកសរុបទាំងមូលនេះត្រូវគុណនឹងភាគរយនៃអង្គភាពអាជីវកម្មដែលកាន់កាប់ដោយអ្នកបង់ពន្ធគិតត្រឹមថ្ងៃចុងបញ្ចប់នៃឆ្នាំពន្ធ។ ក្នុងករណីអង្គភាពមូលធនឯកជន តម្លៃនេះមិនត្រូវតិចជាងផលបូកនៃតម្លៃ ដូចបានកំណត់ក្រោមផ្នែករងនេះ នៃអង្គភាពនីមួយៗដែលជាកម្មសិទ្ធិរបស់អង្គភាពមូលធនឯកជន លើសពីបំណុល ក្រៅពីផលប្រយោជន៍ប្រាក់ចំណេញ របស់អង្គភាពមូលធនឯកជននោះឡើយ។ សម្រាប់គោលបំណងនៃកថាខណ្ឌរងនេះ ប្រសិនបើប្រាក់ចំណេញតាមបញ្ជីជាមធ្យមក្នុងរយៈពេលពាក់ព័ន្ធមានតិចជាងសូន្យ វានឹងត្រូវបានរាប់ថាស្មើសូន្យ។ ក្រុមប្រឹក្សាអាចអនុញ្ញាតឱ្យអ្នកបង់ពន្ធគណនាតម្លៃតាមបញ្ជី និងប្រាក់ចំណេញតាមបញ្ជី ដោយប្រើវិធីសាស្ត្រគណនេយ្យក្រៅពីគោលការណ៍គណនេយ្យដែលទទួលស្គាល់ជាទូទៅ ប្រសិនបើអាជីវកម្មដែលត្រូវវាយតម្លៃនោះរក្សាបញ្ជី និងកំណត់ត្រាជាប្រចាំ ហើយរាយការណ៍ប្រាក់ចំណូល និងចំណាយដោយប្រើវិធីសាស្ត្រផ្សេងទៀតនោះ។

(F) ប្រសិនបើអ្នកបង់ពន្ធ ឬក្រុមប្រឹក្សាអាចបង្ហាញដោយភស្តុតាងច្បាស់លាស់ និងគួរឱ្យទុកចិត្តបានថា តម្លៃដែលត្រូវសន្មតក្រោមកថាខណ្ឌរង (C), (D) ឬ (E) នឹងធ្វើឱ្យតម្លៃជាក់ស្តែងរបស់អង្គភាពអាជីវកម្មដែលកាន់កាប់ដោយអ្នកបង់ពន្ធ ឬភាគរយដែលកាន់កាប់ដោយអ្នកបង់ពន្ធ លើសឬក្រោមយ៉ាងសំខាន់ អ្នកបង់ពន្ធ ឬក្រុមប្រឹក្សាអាចដាក់ស្នើរបាយការណ៍វាយតម្លៃដែលមានការបញ្ជាក់ជាផ្លូវការនូវភាគរយនៃអង្គភាពអាជីវកម្មដែលកាន់កាប់ដោយអ្នកបង់ពន្ធ ហើយបន្ទាប់មកប្រើប្រាស់តម្លៃនៃការវាយតម្លៃដែលមានការបញ្ជាក់ជាផ្លូវការនោះជំនួសឱ្យវិធីសាស្ត្រភាគរយសន្មតវិញ។

(4) ផលប្រយោជន៍ទាំងអស់នៅក្នុងអចលនទ្រព្យដែលកាន់កាប់ដោយផ្ទាល់ដោយអ្នកបង់ពន្ធ ឬកាន់កាប់តាមរយៈទ្រព្យបាលដែលអាចលុបចោលបានមិនត្រូវរួមបញ្ចូលនៅក្នុងតម្លៃសុទ្ធនៃទ្រព្យសម្បត្តិនោះទេ។ ក្នុងករណីដែលតម្រូវឱ្យមានការវាយតម្លៃអចលនទ្រព្យ តម្លៃដែលប្រើសម្រាប់គណនាកត្តា

40

ទ្រព្យសម្បត្តិនៃពន្ធលើប្រាក់ចំណូលសាជីវកម្ម ក្រោមផ្នែកទី 25129 នឹងត្រូវយកមកប្រើ។

(5) ទ្រព្យរូបីបុគ្គលដែលស្ថិតនៅក្រៅរដ្ឋ California ត្រូវបានដកចេញ ប្រសិនបើស្ថិតនៅក្រៅរដ្ឋ California យ៉ាងហោចណាស់ 270 ថ្ងៃក្នុងឆ្នាំ 2026 លើកលែងតែទ្រព្យសកម្មមិនត្រូវបានដកចេញដូច្នោះ ប្រសិនបើត្រូវបានផ្លាស់ទីជាបណ្តោះអាសន្នដោយមានគោលបំណងសំខាន់ក្នុងការគេចពន្ធ។

(6) ចំពោះផលប្រយោជន៍ទាំងអស់នៅក្នុងទ្រព្យបាល តម្លៃសុទ្ធនៃទ្រព្យសម្បត្តិនឹងត្រូវកំណត់ដូចខាងក្រោម៖

(A) តម្លៃសុទ្ធនៃទ្រព្យសម្បត្តិរបស់បុគ្គលរួមបញ្ចូលតម្លៃសុទ្ធនៃទ្រព្យសម្បត្តិនៃទ្រព្យបាលរបស់អ្នកបង្កើតណាមួយនៃបុគ្គលនោះ។

(B) សម្រាប់គោលបំណងនៃការកំណត់ថាតើតម្លៃសុទ្ធនៃទ្រព្យសម្បត្តិរបស់បុគ្គលលើសមួយពាន់លានដុល្លារ ($1,000,000,000) ឬមួយពាន់មួយរយលានដុល្លារ ($1,100,000,000) ក្រោមផ្នែករង (a) នៃផ្នែកទី 50301 តម្លៃសុទ្ធនៃទ្រព្យសម្បត្តិត្រូវរាប់បញ្ចូលតម្លៃទ្រព្យសម្បត្តិដែលកាន់កាប់ដោយទ្រព្យបាល ក្រៅពីទ្រព្យបាលរបស់អ្នកបង្កើត ឬទ្រព្យបាលដែលរួចផុតពន្ធ ដែលបុគ្គលនោះផ្ទេរ ឬបានផ្ទេរទ្រព្យសម្បត្តិ។ ក្នុងដែនកំណត់ដែលស្របតាមរដ្ឋធម្មនុញ្ញនៃសហរដ្ឋអាមេរិក និងរដ្ឋ California តម្លៃសុទ្ធនៃទ្រព្យសម្បត្តិសម្រាប់គោលបំណងទាំងអស់ត្រូវរួមបញ្ចូលតម្លៃនៃទ្រព្យសម្បត្តិដែលកាន់កាប់ដោយទ្រព្យបាល ក្រៅពីទ្រព្យបាលរបស់អ្នកបង្កើត ឬទ្រព្យបាលដែលរួចផុតពន្ធ ដែលបុគ្គលនោះផ្ទេរទ្រព្យសម្បត្តិក្នុងឆ្នាំ 2026 និង 75 ភាគរយនៃតម្លៃរបស់ទ្រព្យសម្បត្តិដែលបានផ្ទេរនោះក្នុងឆ្នាំ 2025។ ប្រសិនបើមានបុគ្គលច្រើនជាងម្នាក់បានផ្ទេរទ្រព្យសម្បត្តិទៅឱ្យទ្រព្យបាលបែបនេះ តម្លៃសុទ្ធនៃទ្រព្យសម្បត្តិរបស់បុគ្គលដែលចូលរួមវិភាគទាននោះ (សម្រាប់គោលបំណងណាក៏ដោយ) ត្រូវបង្កើនដោយសមាមាត្រនៃតម្លៃទ្រព្យសម្បត្តិនៃទ្រព្យបាល ដែលសមាមាត្រនោះស្មើនឹងចំណែកនៃតម្លៃទ្រព្យសម្បត្តិទាំងអស់ដែលបានផ្ទេរទៅឱ្យទ្រព្យបាលដែលបានផ្ទេរដោយបុគ្គលនោះ។

(C) ក្នុងករណីអ្នកទទួលផលនៃទ្រព្យបាល មិនថាទ្រព្យបាលនោះជាអ្នករស់នៅរដ្ឋ California ឬអត់នោះទេ អ្នកទទួលផលនឹងត្រូវចាត់ទុកថាជាម្ចាស់កម្មសិទ្ធិលើទ្រព្យសកម្មរបស់ទ្រព្យបាលក្នុងកម្រិតដែលទ្រព្យសកម្មទាំងនោះអាចចែកជូនដល់អ្នកទទួលផល មិនថាទ្រព្យសកម្មនោះត្រូវបានចែកជូន ឬអត់នោះទេ។ ទោះជាយ៉ាងណាក៏ដោយ អ្នកទទួលផលនៃទ្រព្យបាលនឹងមិនត្រូវបានចាត់ទុកជាម្ចាស់កម្មសិទ្ធិនៃទ្រព្យសកម្មទ្រព្យបាលទេ ប្រសិនបើទ្រព្យបាលនេះជាទ្រព្យបាលដែលអនុវត្ត។

(7) ទ្រព្យសកម្មប្រភេទខាងក្រោមត្រូវរួចផុតពីការយកពន្ធទាំងអស់ក្រោមភាគនេះ និងលក្ខខណ្ឌរាយការណ៍នៃផ្នែកនេះផងដែរ៖

(A) លើកលែងតែមានចែងក្នុងកថាខណ្ឌរង (B) ប្រាក់សោធននិវត្តន៍ដែលមានលក្ខណៈគ្រប់គ្រាន់ និងការរៀបចំផែនការសោធននិវត្តន៍បុគ្គលរួមទាំងផែនការដែលមានចែងក្នុងផ្នែក 219(g)(5) នៃ ក្រមពន្ធដារផ្នែកក្នុង ឬការរៀបចំផែនការសោធននិវត្តន៍ពីបរទេសដែលមានលក្ខណៈស្រដៀងគ្នានឹងផែនការដែលមានចែងក្នុងផ្នែកនោះ និងដែលត្រូវបានលើកលែងពីការយកពន្ធរបស់សហរដ្ឋអាមេរិកដោយសារកាតព្វកិច្ចសន្ធិសញ្ញារបស់សហរដ្ឋអាមេរិក។

(B) ចំនួនទឹកប្រាក់មាននៅក្នុងគណនីសោធននិវត្តន៍ Roth IRA ឬការរៀបចំផែនការសោធននិវត្តន៍ប្រភេទ Roth ផ្សេងទៀត ឬគណនីលក្ខណៈស្រដៀងគ្នា លើកលែងតែក្នុងកម្រិតដែលតម្លៃសរុបនៅក្នុងគណនីទាំងអស់នោះដែលអ្នកបង់ពន្ធមានផលប្រយោជន៍ជាអ្នកទទួលផលមិនថាដោយផ្ទាល់ ឬដោយប្រយោល លើសពីដប់លានដុល្លារ ($10,000,000) ក្នុងតម្លៃបច្ចុប្បន្ន។

(C) ប្រាក់បំណាច់ពន្យារពេលដែលគ្មានលក្ខណៈគ្រប់គ្រាន់ ក្រៅពីផលប្រយោជន៍ប្រាក់ចំណេញតាមលក្ខខណ្ឌ និងការសន្យាបង់សងផ្សេងទៀតនាពេលអនាគតដែលបានបញ្ជាក់ដោយក្រុមប្រឹក្សា លើកលែងតែប្រាក់សោធននិវត្តន៍ ទឹកប្រាក់បំណាច់ពន្យារពេល ឬការទូទាត់ផ្សេងទៀតសម្រាប់ទំនិញ ឬសេវាកម្ម ដែលមិនបានពណ៌នាក្នុងកថាខណ្ឌរង (A) និង (B) ត្រូវចាត់ទុកជាទ្រព្យសកម្មជាប់ពន្ធរបស់អ្នកបង់ពន្ធ ប្រសិនបើ៖

(i) ក្រោមលក្ខខណ្ឌនៃការរៀបចំប្រាក់បំណាច់ ផែនការ កិច្ចសន្យា ឬការរៀបចំផ្សេងទៀតដែលចែងអំពីការទូទាត់ អ្នកបង់ពន្ធមានសិទ្ធិចងកាតព្វកិច្ចតាមផ្លូវច្បាប់គិតត្រឹមថ្ងៃចុងបញ្ចប់នៃឆ្នាំពន្ធចំពោះការទូទាត់នោះ។

(ii) ប្រាក់បំណាច់នោះមិនទាន់ត្រូវបានទទួលជាក់ស្តែង ឬទទួលតាមគតិយុត្តិនៅ ឬមុនចុងបញ្ចប់នៃឆ្នាំពន្ធ។

(iii) ស្របតាមការរៀបចំប្រាក់បំណាច់ ការទូទាត់ត្រូវបង់ទៅឱ្យ ឬតាងនាមឱ្យអ្នកបង់ពន្ធនៅ ឬក្រោយថ្ងៃចុងបញ្ចប់នៃឆ្នាំពន្ធ។

(D) លើកលែងតែទ្រព្យសកម្មដែលត្រូវបានលើកលែង ឬដកចេញ អ្នកបង់ពន្ធត្រូវចាត់ទុកទ្រព្យសកម្មដែលបានពណ៌នានៅក្នុងកថាខណ្ឌនេះដូចជាថាវាត្រូវបានកាន់កាប់ដោយផ្ទាល់ និងមិនស្ថិតក្នុងគណនីដែលទទួលបានការអនុគ្រោះពន្ធ។

(E) ក្នុងករណីផែនការប្រាក់សោធននិវត្តន៍ដែលបានកំណត់ដែលមិនត្រូវបានលើកលែងផ្សេងពីនេះក្រោមផ្នែកនេះ ចំនួនទឹកប្រាក់ដែលស្មើនឹងតម្លៃបច្ចុប្បន្ននៃអត្ថប្រយោជន៍ដែលបានបង្ករបស់អ្នកបង់ពន្ធនៅថ្ងៃចុងក្រោយនៃឆ្នាំពន្ធ ត្រូវចាត់ទុកថាបានរួមបញ្ចូលដោយអ្នកបង់ពន្ធនៅក្នុងតម្លៃសុទ្ធនៃទ្រព្យសម្បត្តិរបស់អ្នកបង់ពន្ធ។

(8) ក្រុមប្រឹក្សាត្រូវអនុម័តបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងការយកពន្ធលើទឹកប្រាក់ត្រូវទទួល និងទ្រព្យសកម្មស្រដៀងគ្នាក្រោមភាគនេះ។ អាស្រ័យលើលក្ខខណ្ឌនៃផ្នែករងនេះ ក្រុមប្រឹក្សាអាចលើកលែងទឹកប្រាក់ត្រូវទទួលនិងទ្រព្យសកម្មស្រដៀងគ្នាពីការយកពន្ធទាំងអស់ក្រោមភាគនេះ និងពីលក្ខខណ្ឌរាយការណ៍នៃផ្នែកនេះ។ ក្នុងការអនុម័តបទប្បញ្ញត្តិទាំងនោះ ក្រុមប្រឹក្សាត្រូវពិចារណាថាតើអ្នកបង់ពន្ធទំនងជាទទួលបានប្រាក់ទូទាត់ដោយសមហេតុផលពីទឹកប្រាក់ត្រូវទទួលប្រភេទជាក់លាក់ឬអត់។ ទឹកប្រាក់ត្រូវទទួលទាំងអស់ត្រូវរួមបញ្ចូលនៅក្នុងតម្លៃសុទ្ធនៃទ្រព្យសម្បត្តិនៅក្រោមភាគនេះ រហូតដល់ក្រុមប្រឹក្សាបានអនុម័តបទប្បញ្ញត្តិ។

(9) ចំពោះទ្រព្យសកម្មទាំងអស់ផ្សេងទៀត រួមទាំងស្នាដៃសិល្បៈ និងវត្ថុប្រមូល ឧបករណ៍ហិរញ្ញវត្ថុក្រៅពីឧបករណ៍ដែលត្រូវបានជួញដូរជាសាធារណៈ សិទ្ធិកម្មសិទ្ធិបញ្ញា បំណុល និងកាតព្វកិច្ចផ្សេងទៀតដែលជំពាក់អ្នកបង់ពន្ធ ក្រៅពីបំណុលដែលត្រូវបានជួញដូរជាសាធារណៈ ព្រមទាំងយានជំនិះ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនផ្សេងទៀត អ្នកបង់ពន្ធអាចដកនូវតម្លៃទ្រព្យសកម្មសរុបនៃទ្រព្យសកម្មរួមបញ្ចូលគ្នាទាំងនោះបានរហូតដល់ប្រាំលានដុល្លារ ($5,000,000) ដោយមិនគិតពីប្រភេទ ចេញពីតម្លៃសុទ្ធនៃទ្រព្យសម្បត្តិ និងពីតម្រូវការរាយការណ៍នៃផ្នែកនេះ។ លើកលែងតែទ្រព្យសកម្មដែលត្រូវបានដកចេញបែបនេះ អ្នកបង់ពន្ធត្រូវរាយការណ៍ពីតម្លៃទីផ្សារយុត្តិធម៌នៃទ្រព្យសកម្មទាំងនោះ ហើយសម្រាប់ទ្រព្យសកម្មនីមួយៗ ឬក្រុមទ្រព្យសកម្មដែលមានលក្ខណៈអាចផ្លាស់ប្តូរជំនួសគ្នាបាន រួមទាំងកិច្ចសន្យាឧបករណ៍និស្សន្ទដែលពាក់ព័ន្ធនឹងមូលបត្រគោលដូចគ្នា ដែលមានតម្លៃលើសពីមួយលានដុល្លារ ($1,000,000) អ្នកបង់ពន្ធត្រូវដាក់ស្នើរបាយការណ៍វាយតម្លៃដែលមានការបញ្ជាក់។

(10) មិនថាក្នុងករណីណាក៏ដោយ តម្លៃនៃទ្រព្យសកម្មមិនត្រូវកំណត់ឱ្យទាបជាងចំនួនទឹកប្រាក់ដែលទ្រព្យសកម្មនោះត្រូវបានធានារ៉ាប់រងឡើយ។ ក្នុងករណីអង្គភាពអាជីវកម្ម មិនថាក្នុងករណីណាក៏ដោយ តម្លៃនៃអង្គភាពនោះមិនត្រូវកំណត់ឱ្យទាបជាងការវាយតម្លៃដែលបានបង្ហាញនៅក្នុងជុំនៃការផ្តល់មូលនិធិ ឬការលក់ភាគហ៊ុនផ្សេងទៀតដែលកើតមានឡើងក្នុងរយៈពេលពីរឆ្នាំគិតចាប់ពីកាលបរិច្ឆេទកំណត់តម្លៃនោះឡើយ លើកលែងតែអ្នកបង់ពន្ធអាចបង្ហាញដោយភស្តុតាងច្បាស់លាស់ និងគួរឱ្យទុកចិត្តថា ការវាយតម្លៃនោះនឹងបំផ្លើសតម្លៃនៃអង្គភាពនោះយ៉ាងសំខាន់។

40

(11) តម្លៃសុទ្ធនៃទ្រព្យសម្បត្តិត្រូវរួមបញ្ចូលតម្លៃនៃទ្រព្យសម្បត្តិណាមួយដែលបុគ្គលបានផ្ទេរ ក្រៅពីទ្រព្យសម្បត្តិដែលបានផ្ទេរទៅឱ្យទ្រព្យបាលដូចបានពណ៌នានៅខាងលើ ក្នុងតម្លៃទាបជាងតម្លៃទីផ្សារយុត្តិធម៌ ក្រោយថ្ងៃទី 15 ខែតុលា ឆ្នាំ 2025 ប្រសិនបើទ្រព្យសម្បត្តិនោះ ដែលយកមកពិចារណាតែឯង ឬរួមគ្នាជាមួយវត្ថុផ្ទេរផ្សេងទៀតដែលមានលក្ខណៈអាចផ្លាស់ប្តូរជំនួសគ្នា មានតម្លៃទីផ្សារយុត្តិធម៌លើសពីមួយលានដុល្លារ ($1,000,000)។ ទ្រព្យសកម្មដែលបានរួមបញ្ចូលនៅក្នុងតម្លៃសុទ្ធនៃទ្រព្យសម្បត្តិរបស់អ្នកផ្ទេរជាលទ្ធផលនៃកថាខណ្ឌនេះ មិនត្រូវរួមបញ្ចូលនៅក្នុងតម្លៃសុទ្ធនៃទ្រព្យសម្បត្តិរបស់អ្នកទទួលនោះឡើយ។

(12) ទ្រព្យសកម្មរបស់បុគ្គលម្នាក់ដែលអាចត្រូវបានអះអាងថាជាអ្នកក្នុងបន្ទុក ដែលមានចំនួនសរុបលើសពីប្រាំម៉ឺនដុល្លារ ($50,000) ត្រូវចាត់ទុកថាជាទ្រព្យសកម្មរបស់អ្នកបង់ពន្ធដែលអាចអះអាងបុគ្គលនោះថាជាអ្នកក្នុងបន្ទុក។

ជំពូកទី 3. គណនីពន្យារពេលសងជាជម្រើសសម្រាប់អ្នកបង់ពន្ធដែលមានលក្ខណៈគ្រប់គ្រាន់ដែលមានការឆ្លើយតបនឹងសាច់ប្រាក់ងាយស្រួល

50304. (a) ក្រុមប្រឹក្សាត្រូវបង្កើតកិច្ចសន្យាគណនីពន្យារពេលសងជាជម្រើស និងទម្រង់បែបបទដែលពាក់ព័ន្ធសម្រាប់គណនីពន្យារពេលសងជាជម្រើស ដែលហៅម្យ៉ាងទៀតនៅទីនេះថា "ODA" ដើម្បីបង្កើតកិច្ចព្រមព្រៀងកិច្ចសន្យាដែលចងកាតព្វកិច្ចរវាងអ្នកបង់ពន្ធ និងរដ្ឋ។ អ្នកបង់ពន្ធដែលមានលក្ខណៈគ្រប់គ្រាន់អាចជ្រើសរើសចុះហត្ថលេខាលើកិច្ចសន្យា ដើម្បីចាប់ផ្តើម ODA ក្រោមភាគនេះបាន។ ដើម្បីក្លាយជាអ្នកបង់ពន្ធមានលក្ខណៈគ្រប់គ្រាន់ បុគ្គលម្នាក់ត្រូវដាក់លិខិតប្រកាសថា ចំនួនទឹកប្រាក់ពន្ធបន្ថែមដែលត្រូវបង់ជាលទ្ធផលនៃភាគនេះ ដោយគ្មានការប្រើប្រាស់ ODA នឹងលើសពីផលបូកនៃតម្លៃរួមបញ្ចូលគ្នានៃទ្រព្យសកម្មទាំងអស់របស់អ្នកបង់ពន្ធដែលស្ថិតក្រោមវិធានកំណត់តម្លៃនៃកថាខណ្ឌ (1) នៃផ្នែករង (c) នៃផ្នែកទី 50303 មានន័យថា មានតែបុគ្គលដែលនឹងត្រូវបង់ពន្ធបន្ថែមជាលទ្ធផលនៃភាគនេះដែលលើសពីតម្លៃសរុបរួមបញ្ចូលគ្នានៃទ្រព្យសកម្មដែលមានការជួញដូរជាសាធារណៈទាំងអស់របស់បុគ្គលនោះប៉ុណ្ណោះ ទើបត្រូវចាត់ទុកថាជាអ្នកបង់ពន្ធដែលមានលក្ខណៈគ្រប់គ្រាន់។ ជាផ្នែកមួយនៃកិច្ចសន្យានេះ អ្នកបង់ពន្ធដែលមានលក្ខណៈគ្រប់គ្រាន់ដែលជ្រើសរើសចាប់ផ្តើម ODA ត្រូវយល់ព្រមតាមចំណុចទាំងអស់ខាងក្រោម៖

(1) ដាក់លិខិតប្រកាសព័ត៌មានប្រចាំឆ្នាំ និងទម្រង់បែបបទទាំងអស់ ដូចបានពណ៌នា និងបញ្ជាក់នៅក្នុងផ្នែកនេះ។

(2) ផ្ទេរផ្សា និងបង់សងរាល់បំណុលពន្ធដែលអាចកើតឡើងជាលទ្ធផលនៃ ODA។

(3) ត្រូវស្ថិតក្រោមយុត្តាធិការផ្ទាល់ខ្លួននៅក្នុងរដ្ឋនេះសម្រាប់គោលបំណងនៃការប្រមូលពន្ធណាមួយដែលបានកំណត់ដោយភាគនេះ និងការបំពេញតម្រូវការរាយការណ៍ណាមួយដែលបានកំណត់ដោយភាគនេះ រួមជាមួយការប្រាក់ពាក់ព័ន្ធ ឬការពិន័យណាមួយដែលរដ្ឋនេះបានកំណត់លើអ្នកបង់ពន្ធ ពាក់ព័ន្ធនឹង ODA។

(b) កិច្ចសន្យានេះត្រូវមានសុពលភាពចងកាតព្វកិច្ចផ្លូវច្បាប់លើអ្នកបង់ពន្ធ ព្រមទាំងលើទ្រព្យមរតក និងអ្នកទទួលសិទ្ធិបន្តរបស់អ្នកបង់ពន្ធ រហូតទាល់តែអ្នកបង់ពន្ធ ឬទ្រព្យមរតក ឬអ្នកទទួលសិទ្ធិបន្តរបស់អ្នកបង់ពន្ធផ្ទេរផ្សា និងបិទ ODA ឱ្យបានត្រឹមត្រូវ តាមរយៈការបំប្លែងបណ្តឹងទាមទារពន្ធដែលបានប្រមូលផ្តុំជាសាច់ប្រាក់ឱ្យបានពេញលេញ ហើយបន្ទាប់មកបង់សងប្រាក់ពន្ធទាំងអស់ដែលដល់កំណត់បង់លើបណ្តឹងទាមទារពន្ធដែលបានបំប្លែងជាសាច់ប្រាក់នោះ។

(c) អ្នកបង់ពន្ធអាចរក្សាទុក ODA បានតែមួយប៉ុណ្ណោះ។ អ្នកបង់ពន្ធអាចភ្ជាប់ទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្មទៅនឹង ODA បានតែក្នុងកម្រិតដែលចំនួនទឹកប្រាក់ពន្ធបន្ថែមដែលត្រូវបង់ជាលទ្ធផលនៃផ្នែកទី 50301 ដោយគ្មានការប្រើប្រាស់ ODA នឹងលើសពីផលបូកនៃតម្លៃរួមបញ្ចូលគ្នានៃទ្រព្យសកម្មទាំងអស់របស់អ្នកបង់ពន្ធដែលស្ថិតក្រោមវិធានកំណត់តម្លៃនៃកថាខណ្ឌ (1) នៃផ្នែករង (c) នៃផ្នែកទី 50303។ ដើម្បីភ្ជាប់ទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្មទៅនឹង ODA អ្នកបង់ពន្ធត្រូវរាយការណ៍អំពីចំណុចទាំងពីរខាងក្រោម៖

(1) ឆ្នាំដែល ODA ត្រូវបានចាប់ផ្តើម។

(2) បញ្ជីទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្មទាំងអស់ដែលត្រូវភ្ជាប់ទៅនឹង ODA សម្រាប់ឆ្នាំបច្ចុប្បន្ន។

(d) ប្រសិនបើអ្នកបង់ពន្ធបានចាប់ផ្តើម ODA រហូតទាល់តែ ODA នោះត្រូវបានផ្ទេរផ្សា និងបិទ អ្នកបង់ពន្ធត្រូវរាយការណ៍ជារៀងរាល់ឆ្នាំអំពីប្រតិបត្តិការចែកចាយដ៏មានសារៈសំខាន់ទាំងឡាយដែលបានធ្វើឡើងពាក់ព័ន្ធនឹង ODA ហើយត្រូវបំពេញ និងដាក់ស្នើទម្រង់បែបបទដែលបានផ្តល់ដោយក្រុមប្រឹក្សាសម្រាប់គោលបំណងនោះ។ អ្នកបង់ពន្ធត្រូវបន្តធ្វើរបាយការណ៍ទាំងនោះជារៀងរាល់ឆ្នាំ រហូតទាល់តែអ្នកបង់ពន្ធបានផ្ទេរផ្សា ODA តាមរយៈការបំប្លែងបណ្តឹងទាមទារពន្ធដែលបានប្រមូលផ្តុំជាសាច់ប្រាក់ឱ្យបានពេញលេញ ហើយបន្ទាប់មកបង់សងប្រាក់ពន្ធទាំងអស់ដែលជំពាក់លើបណ្តឹងទាមទារពន្ធដែលបានបំប្លែងជាសាច់ប្រាក់នោះ។ ជាសមាសធាតុមួយនៃកិច្ចសន្យាផ្លូវច្បាប់ដែលចុះហត្ថលេខាដោយអ្នកបង់ពន្ធនៅពេលចាប់ផ្តើម ODA តម្រូវការរាយការណ៍ទាំងនោះត្រូវបន្តអនុវត្ត ទោះបីជា និងសូម្បីតែបន្ទាប់ពីអ្នកបង់ពន្ធលែងជាអ្នកស្នាក់នៅក្នុងរដ្ឋ California ក្នុងន័យនៃផ្នែកទី 17014 និង 17015.5 ក៏ដោយ ហើយពេលនោះត្រូវអនុវត្តជាកិច្ចសន្យាចងកាតព្វកិច្ចផ្លូវច្បាប់ជាមួយរដ្ឋ។ ការខកខានមិនបានធ្វើរបាយការណ៍ប្រចាំឆ្នាំ និងការខកខានមិនបានដាក់ស្នើទម្រង់បែបបទណាមួយដែលតម្រូវ ត្រូវចាត់ទុកថាជាការរំលោភបំពានកិច្ចសន្យា ហើយក៏ត្រូវស្ថិតក្រោមការពិន័យដូចគ្នាទៅនឹងការខកខានមិនបានដាក់ទម្រង់បែបបទពន្ធលើប្រាក់ចំណូលសម្រាប់អ្នករស់នៅក្នុងរដ្ឋ California ដែលតម្រូវឱ្យដាក់ទម្រង់បែបបទពន្ធលើប្រាក់ចំណូលផងដែរ។ នៅពេលមរណភាពរបស់អ្នកបង់ពន្ធណាម្នាក់ដែលបានចាប់ផ្តើម ODA ដែលមិនទាន់ត្រូវបានផ្ទេរផ្សា និងបិទទាំងស្រុង ទ្រព្យមរតក និងអ្នកទទួលសិទ្ធិបន្តរបស់អ្នកបង់ពន្ធនោះនឹងត្រូវបានតម្រូវឱ្យផ្ទេរផ្សា ODA នោះ ដើម្បីបំប្លែងបណ្តឹងទាមទារពន្ធដែលបានប្រមូលផ្តុំជាសាច់ប្រាក់ឱ្យបានពេញលេញ និងបន្ទាប់មកបង់សងប្រាក់ពន្ធទាំងអស់ដែលជំពាក់លើបណ្តឹងទាមទារពន្ធដែលបានបំប្លែងជាសាច់ប្រាក់ទាំងនោះ ដោយចាត់ទុកបណ្តឹងទាមទារទាំងនេះថាជាបំណុលពន្ធមិនទាន់បង់របស់អ្នកបង់ពន្ធដែលជំពាក់រដ្ឋ។

(e) ភាគរយកាត់ទុកពន្ធដែលមិនទាន់បំប្លែងជាសាច់ប្រាក់ដែលបានប្រមូលផ្តុំរបស់អ្នកបង់ពន្ធត្រូវស្មើនឹង 5 ភាគរយ។

(f) ការដក និងប្រតិបត្តិការខាងក្រោម ត្រូវចាត់ទុកថាជាប្រតិបត្តិការចែកចាយដ៏មានសារៈសំខាន់ ដែលអ្នកបង់ពន្ធត្រូវរាយការណ៍ជារៀងរាល់ឆ្នាំ៖

(1) ការដកប្រាក់ ទ្រព្យសម្បត្តិ ឬតម្លៃផ្សេងទៀតចេញពីទ្រព្យសកម្មណាមួយដែល ODA ត្រូវបានភ្ជាប់ទៅ។

(2) ប្រតិបត្តិការជាមួយអ្នកបង់ពន្ធ ឬបុគ្គលពាក់ព័ន្ធនឹងអ្នកបង់ពន្ធ ដែលមានឥទ្ធិពលផ្ទេរទ្រព្យសកម្មណាមួយ ឬតម្លៃនៃទ្រព្យសកម្មដែល ODA ត្រូវបានភ្ជាប់ដោយមិនបានផ្ទេរនូវកាតព្វកិច្ច ODA នោះក្នុងពេលជាមួយគ្នាផងដែរ។

(g) ទោះបីជាមានផ្នែករង (f) ក៏ដោយ ប្រតិបត្តិការចែកចាយដ៏មានសារៈសំខាន់មិនត្រូវរួមបញ្ចូលប្រតិបត្តិការធម្មតា និងចាំបាច់សម្រាប់ការរក្សា ឬបង្កើនតម្លៃនៃទ្រព្យសកម្មដែល ODA ត្រូវបានភ្ជាប់ទៅនោះឡើយ ហើយដែលមិនមានឥទ្ធិពលនៃការចែកចាយប្រាក់ចំណេញ ភាគលាភ ឬការទូទាត់ផ្សេងទៀតដល់ម្ចាស់សម្រាប់ការប្រើប្រាស់ទុន ឬការផ្ទេរស្រដៀងគ្នាឡើយ។

(h) ក្រុមប្រឹក្សាត្រូវផ្តល់ការណែនាំសម្រាប់បញ្ជាក់ថាប្រភេទប្រតិបត្តិការណាខ្លះត្រូវចាត់ទុកថាជាប្រតិបត្តិការចែកចាយដ៏មានសារៈសំខាន់ និងសម្រាប់បញ្ជាក់ថា ការផ្ទេរដែលបានធ្វើឡើងក្នុងដំណើរធម្មតានៃពាណិជ្ជកម្ម ឬអាជីវកម្ម និងការដោះដូរទ្រព្យសកម្មដែលមិនអាចជួញដូរបានដោយងាយមិនត្រូវចាត់ទុកថាជាប្រតិបត្តិការចែកចាយដ៏មានសារៈសំខាន់នោះឡើយ។ ចំពោះប្រតិបត្តិការចែកចាយដ៏មានសារៈសំខាន់ណាមួយ អ្នកបង់ពន្ធត្រូវ

40

រាយការណ៍អំពីតម្លៃទីផ្សារយុត្តិធម៌ដែលបានដកចេញពីទ្រព្យសកម្មដែល ODA ត្រូវបានភ្ជាប់ទៅ ឬដែលត្រូវបានផ្ទេរ ឬប្រើប្រាស់ផ្សេងទៀតសម្រាប់ផលប្រយោជន៍របស់អ្នកបង់ពន្ធ ឬរបស់បុគ្គលពាក់ព័ន្ធ។

(i) អ្នកបង់ពន្ធត្រូវគុណភាគរយកាត់ទុកពន្ធដែលមិនទាន់បំប្លែងជាសាច់ប្រាក់ដែលបានប្រមូលផ្តុំរបស់អ្នកបង់ពន្ធ ជាមួយនឹងតម្លៃទីផ្សារយុត្តិធម៌ ដូចដែលបានកំណត់ក្រោមផ្នែកទី 50303 នៃប្រតិបត្តិការចែកចាយដ៏មានសារៈសំខាន់ទាំងអស់សម្រាប់ឆ្នាំពន្ធ។ ត្រូវមានពន្ធដែលកំណត់លើអ្នកបង់ពន្ធក្នុងចំនួនទឹកប្រាក់នៃផលគុណដែលបាន។ ប្រាក់ពន្ធបន្ថែមណាមួយដែលត្រូវបង់ជាលទ្ធផលនៃផ្នែកនេះសម្រាប់ឆ្នាំពន្ធណាមួយ ត្រូវបង់រួមគ្នាជាមួយប្រាក់ពន្ធលើប្រាក់ចំណូលណាមួយដែលត្រូវជំពាក់សម្រាប់ឆ្នាំពន្ធនោះ។

(j) អ្នកបង់ពន្ធណាមួយដែលរក្សាទុក ODA ហើយបានមានប្រតិបត្តិការចែកចាយដ៏មានសារៈសំខាន់ មិនថានៅក្នុងឆ្នាំបច្ចុប្បន្ន ឬក្នុងឆ្នាំមុនណាមួយ ត្រូវរាយការណ៍ជារៀងរាល់ឆ្នាំនូវរាល់ចំណុចដូចខាងក្រោម៖

(1) ឆ្នាំដែល ODA ត្រូវបានចាប់ផ្តើម។

(2) បញ្ជីនៃទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្មទាំងអស់ដែល ODA កំពុងភ្ជាប់នៅបច្ចុប្បន្ន ឬដែល ODA ធ្លាប់បានភ្ជាប់។

(3) សមតុល្យបន្តរបស់អ្នកបង់ពន្ធនៃតម្លៃទីផ្សារយុត្តិធម៌សរុបនៃប្រតិបត្តិការចែកចាយដ៏មានសារៈសំខាន់ទាំងអស់ដែលបានធ្វើឡើងពាក់ព័ន្ធនឹង ODA។

(k) ប្រសិនបើក្នុងឆ្នាំណាមួយ អ្នកបង់ពន្ធដែលធ្លាប់បានចាប់ផ្តើម ODA លក់ ចាត់ចែងចោល ឬបញ្ចប់តាមរបៀបផ្សេងទៀតនូវរាល់ផលប្រយោជន៍របស់អ្នកបង់ពន្ធនៅក្នុង ODA និងនៅក្នុងទ្រព្យសកម្មទាំងអស់ដែល ODA ត្រូវបានភ្ជាប់ទៅ នោះបន្ទាប់ពីបានបង់ពន្ធណាមួយដែលត្រូវជំពាក់ជាលទ្ធផលនៃប្រតិបត្តិការទាំងនោះ ដែលជាប្រតិបត្តិការចែកចាយដ៏មានសារៈសំខាន់ ដូចដែលបានបញ្ជាក់នៅក្នុងផ្នែករង (f) ODA នោះត្រូវបានបំប្លែងជាសាច់ប្រាក់ទាំងស្រុង។ នៅចុងឆ្នាំពន្ធណាមួយ អ្នកបង់ពន្ធដែលធ្លាប់បានចាប់ផ្តើម ODA អាចជ្រើសរើសបិទ ODA នោះដោយដាក់ស្នើទម្រង់បែបបទដែលផ្តល់ដោយក្រុមប្រឹក្សា។ បន្ទាប់មក អ្នកបង់ពន្ធត្រូវផ្ទេរផ្សា ODA ស្របតាមផ្នែករង (l)។

(l) មុនពេលបិទ ODA អ្នកបង់ពន្ធត្រូវដកទ្រព្យសកម្មណាមួយដែល ODA ត្រូវបានភ្ជាប់ទៅ ហើយត្រូវចាត់ទុកការដកទ្រព្យសកម្មទាំងនោះថាជាប្រតិបត្តិការចែកចាយដ៏មានសារៈសំខាន់ស្របតាមផ្នែកនេះ។ ផ្នែកទី 50303 ត្រូវគ្រប់គ្រងលើការកំណត់តម្លៃទីផ្សារយុត្តិធម៌នៃទ្រព្យសកម្មណាមួយដែលបានដកចេញពី ODA។ ដូចដែលបានប្រើប្រាស់ក្នុងផ្នែកនេះ ពាក្យថា "អ្នកបង់ពន្ធ" ក៏ត្រូវរួមបញ្ចូលផងដែរនូវទ្រព្យមរតក ឬអ្នកទទួលសិទ្ធិបន្តណាមួយរបស់អ្នកបង់ពន្ធ ដែលត្រូវតម្រូវឱ្យទទួលខុសត្រូវក្រោមបទប្បញ្ញត្តិនេះសម្រាប់ការបំពេញ ODA របស់អ្នកបង់ពន្ធ។

ជំពូកទី 4. របាយការណ៍វាយតម្លៃដែលមានការបញ្ជាក់

50305. (a) អ្នកវាយតម្លៃណាមួយដែលធ្វើរបាយការណ៍វាយតម្លៃដែលមានការបញ្ជាក់សម្រាប់គោលបំណងនៃភាគនេះ ត្រូវបញ្ជូនច្បាប់ចម្លងនៃរបាយការណ៍វាយតម្លៃដែលមានការបញ្ជាក់នោះទៅកាន់ក្រុមប្រឹក្សា ព្រមទាំងព័ត៌មានដែលគ្រប់គ្រាន់សម្រាប់កំណត់អត្តសញ្ញាណអ្នកបង់ពន្ធដែលរបាយការណ៍វាយតម្លៃដែលមានការបញ្ជាក់នោះត្រូវបានរៀបចំឡើងសម្រាប់រូបគេ ហើយត្រូវអនុវត្តតាមវិធានណាមួយដែលអនុវត្តបាន ឬការណែនាំពាក់ព័ន្ធផ្សេងទៀតដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សា។

(b) ក្រុមប្រឹក្សាត្រូវអនុម័តបទប្បញ្ញត្តិ ឬផ្សព្វផ្សាយសេចក្តីណែនាំ ដោយរៀបរាប់លម្អិតបន្ថែមអំពីតម្រូវការសម្រាប់របាយការណ៍វាយតម្លៃដែលមានការបញ្ជាក់ និងសម្រាប់អ្នកវាយតម្លៃដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើរបាយការណ៍វាយតម្លៃដែលមានការបញ្ជាក់សម្រាប់គោលបំណងនៃជំពូកនេះ។ វិធាន និងការណែនាំត្រូវផ្អែកលើវិធានស្តីពីរបាយការណ៍វាយតម្លៃដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងអ្នកវាយតម្លៃដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នៃផ្នែក 1.170A-17 នៃចំណងជើងទី 26 នៃក្រមបទប្បញ្ញត្តិសហព័ន្ធ។

(c) ក្នុងករណីមានការបង់ពន្ធខ្វះណាមួយដែលបណ្តាលមកពីការប្រកាសតម្លៃលើស ឬខ្វះជាសារធាតុ ឬដុល នៅក្នុងរបាយការណ៍វាយតម្លៃដែលមានការបញ្ជាក់ ក្រុមប្រឹក្សាតាមការពិចារណារបស់ខ្លួន អាចដាក់ពិន័យលើអ្នកវាយតម្លៃ ដូចជាថាអ្នកវាយតម្លៃនោះជា "អ្នកបង់ពន្ធ" សម្រាប់គោលបំណងនៃផ្នែកទី 50312 ប៉ុន្តែការពិន័យបែបនេះមិនត្រូវលើសពី 2 ភាគរយនៃការប្រកាសពន្ធខ្វះ ក្នុងករណីមានការប្រកាសតម្លៃលើស ឬខ្វះជាសារធាតុ ឬ 4 ភាគរយនៃការប្រកាសពន្ធខ្វះ ក្នុងករណីមានការប្រកាសតម្លៃលើស ឬខ្វះដុលឡើយ។

ជំពូកទី 5. ការបែងចែកសមាមាត្រ និងឥណទានពន្ធ

50306. (a) ការបែងចែកសមាមាត្រស្តង់ដា។ ចំពោះការបែងចែកសមាមាត្រនៃប្រាក់ពន្ធដែលបានកំណត់ដោយភាគនេះរវាងដែនសមត្ថកិច្ចច្រើនផ្សេងគ្នា វិធាននៃផ្នែកនេះត្រូវអនុវត្ត។ វិធាននៅក្នុងជំពូកនេះត្រូវជំនួសឱ្យវិធានដទៃទៀត រួមទាំងវិធានពាក់ព័ន្ធនឹងការបែងចែកប្រាក់ចំណូលសម្រាប់គោលបំណងនៃភាពជាអ្នករស់នៅរយៈពេលផ្នែកមួយនៃឆ្នាំ។ មួយរយភាគរយនៃប្រាក់ពន្ធណាមួយដែលបានកំណត់ក្រោមផ្នែកទី 50301 និង 50304 ត្រូវបានបែងចែកទៅរដ្ឋ California សម្រាប់បុគ្គលដែលអនុវត្តនិងទ្រព្យបាលដែលអនុវត្តទាំងអស់ ដោយគ្មានការកាត់បន្ថយ ឬគុណដោយផ្នែកលើប្រវត្តិនៃការរស់នៅនោះឡើយ រួមទាំងថាតើបុគ្គលណាមួយធ្លាប់ជាអ្នករស់នៅរដ្ឋ California មុនកាលបរិច្ឆេទកាតព្វកិច្ចពន្ធដែលបានពិពណ៌នានៅក្នុងផ្នែករង (n) នៃផ្នែកទី 50308។ សម្រាប់គោលបំណងនៃផ្នែកនេះ ភាពជាអ្នករស់នៅត្រូវកំណត់ក្រោមផ្នែកទី 17014 និង 17015.5 គិតត្រឹមកាលបរិច្ឆេទកាតព្វកិច្ចពន្ធ។

(b) ការបែងចែកសមាមាត្រជំនួស។

(1) វិធីសាស្ត្រស្តង់ដា។ វិធីសាស្ត្របែងចែកសមាមាត្រស្តង់ដារក្រោមផ្នែកនេះ គឺជាវិធីសាស្ត្រដែលបានបញ្ជាក់នៅក្នុងផ្នែករង (a)។

(2) ពេលដែលការបែងចែកសមាមាត្រជំនួសអាចត្រូវបានប្រើ។ ប្រសិនបើវិធីសាស្ត្របែងចែកសមាមាត្រស្តង់ដាមិនបង្ហាញដោយយុត្តិធម៌នូវវិសាលភាពដែលទ្រព្យសម្បត្តិហួសហេតុរបស់អ្នកបង់ពន្ធត្រូវបានប្រមូលផ្តុំនៅក្នុង ឬត្រូវបានទ្រទ្រង់យ៉ាងសំខាន់ដោយរដ្ឋ California អ្នកបង់ពន្ធអាចដាក់ញត្តិសុំ ឬក្រុមប្រឹក្សាអាចតម្រូវក្នុងសេចក្តីជូនដំណឹងអំពីការប៉ាន់ប្រមាណដែលបានស្នើឡើង ឱ្យប្រើវិធីសាស្ត្របែងចែកសមាមាត្រជំនួសសម្រាប់ទ្រព្យសម្បត្តិទាំងអស់ ឬផ្នែកណាមួយរបស់អ្នកបង់ពន្ធ។ វិធីសាស្ត្រជំនួសណាមួយដែលត្រូវបានអនុម័តក្រោមផ្នែករងនេះ ត្រូវយកមកអនុវត្តមុនពេលគណនាឥណទានណាមួយក្រោមផ្នែកទី 50307។

(3) ញត្តិ ការបង្ហាញភស្តុតាងដែលត្រូវការ។ ញត្តិត្រូវបានអនុម័ត លុះត្រាតែភាគីដែលដាក់ញត្តិបញ្ជាក់ដោយភស្តុតាងច្បាស់លាស់ និងគួរឱ្យទុកចិត្តថាលក្ខខណ្ឌទាំងពីរខាងក្រោមនេះគឺជាការពិត៖

(A) ទ្រព្យសម្បត្តិហួសហេតុមិនបានប្រមូលផ្តុំយ៉ាងសំខាន់នៅក្នុងរដ្ឋ California។

(B) ទ្រព្យសម្បត្តិហួសហេតុមិនត្រូវបានទ្រទ្រង់យ៉ាងសំខាន់នៅក្នុងរដ្ឋ California រយៈពេលយ៉ាងតិច 365 ថ្ងៃសរុប ក្នុងអំឡុងពេល 48 ខែ ដែលបញ្ចប់នៅកាលបរិច្ឆេទកំណត់តម្លៃ ដូចដែលបានកំណត់នៅក្នុងផ្នែករង (o) នៃផ្នែកទី 50308។

(4) ជម្រើសស្របតាមរដ្ឋធម្មនុញ្ញ។ ម្យ៉ាងវិញទៀត ភាគីដែលដាក់ញត្តិអាចឈ្នះដោយបញ្ជាក់ថា រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក រដ្ឋធម្មនុញ្ញនៃរដ្ឋ California ឬច្បាប់សហព័ន្ធ ហាមឃាត់ការអនុវត្តវិធីសាស្ត្រស្តង់ដារចំពោះទ្រព្យសម្បត្តិទាំងអស់ ឬផ្នែកណាមួយរបស់អ្នកបង់ពន្ធ។

*(5) បន្ទុកភស្តុតាង និងវិធីសាស្ត្រដែលបានស្នើឡើង។ ភាគីដែលដាក់ញត្តិទទួលបន្ទុកភស្តុតាងក្នុងការបង្ហាញថាវិធីសាស្ត្រស្តង់ដារគឺអយុត្តិធម៌ ឬគ្មានសុពលភាព និងក្នុងការស្នើវិធីសាស្ត្រដែលមានភាពយុត្តិធម៌ និងសមហេតុផលជាងមុន ដែលអាចអនុវត្តបានក្នុងការគ្រប់គ្រង។ នៅពេលក្រុមប្រឹក្សាតម្រូវវិធីសាស្ត្រជំនួសនៅក្នុងសេចក្តីជូនដំណឹងអំពីការប៉ាន់ប្រមាណដែលបានស្នើឡើង ក្រុមប្រឹក្សាគឺជាភាគីដាក់សំណើនៅមុខ

40

ការិយាល័យបណ្តឹងឧទ្ធរណ៍ពន្ធដារ និងទទួលបន្ទុកភស្តុតាងនេះពាក់ព័ន្ធនឹងវិធីសាស្ត្រជំនួស ហើយសេចក្តីជូនដំណឹងនោះត្រូវចែងឱ្យបានជាក់លាក់អំពីហេតុផលដែលវិធីសាស្ត្រស្តង់ដារមានភាពអយុត្តិធម៌ និងពណ៌នាអំពីវិធីសាស្ត្រជំនួសដែលបានស្នើឡើង។

(6) ភាគរយអប្បបរមា; យន្តការការពាររដ្ឋធម្មនុញ្ញ។ ការធ្លាស្រាលក្រោមផ្នែករងនេះមិនត្រូវកាត់បន្ថយភាគរយបែងចែកសមាមាត្រឱ្យទាបជាង 25 ភាគរយនោះឡើយ លុះត្រាតែការិយាល័យបណ្តឹងឧទ្ធរណ៍ពន្ធដារ ឬតុលាការនៅពេលពិនិត្យឡើងវិញ រកឃើញនៅលើកំណត់ហេតុថាភាគរយទាបជាងនេះត្រូវបានតម្រូវ ដើម្បីជៀសវាងការយកពន្ធដែលមិនសមាមាត្រខ្លាំងហួសហេតុ ដែលរំលោភបំពានលើរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ឬរដ្ឋធម្មនុញ្ញនៃរដ្ឋ California ឬច្បាប់សហព័ន្ធដែលគ្រប់គ្រង។ ក្នុងការកំណត់ថាតើពន្ធមួយមានភាពមិនសមាមាត្រខ្លាំងហួសហេតុដែរឬទេ ការិយាល័យបណ្តឹងឧទ្ធរណ៍ពន្ធដារ និងតុលាការត្រូវពិចារណាថាតើតម្លៃសុទ្ធនៃទ្រព្យសម្បត្តិរបស់អ្នកបង់ពន្ធមានទំនាក់ទំនងមានសារៈសំខាន់ទៅនឹងរដ្ឋ California ឬអត់ ហើយត្រូវកាត់បន្ថយភាគរយបែងចែកសមាមាត្រ រួមទាំងការកាត់បន្ថយឱ្យទាបជាង 25 ភាគរយ និងកន្លែងណាដែលសមស្របកាត់បន្ថយមកត្រឹមសូន្យ ក្នុងកម្រិតចាំបាច់ដើម្បីជៀសវាងការយកពន្ធដែលមានលក្ខណៈតាមអំពើចិត្ត ឬគ្មានសមាមាត្រសមស្របទាំងស្រុងទៅនឹងទំនាក់ទំនងរបស់អ្នកបង់ពន្ធជាមួយរដ្ឋនេះ។

(7) បទប្បញ្ញត្តិ។ ក្រុមប្រឹក្សាអាចអនុម័តបទប្បញ្ញត្តិដែលផ្តល់នូវឧទាហរណ៍មិនផ្តាច់មុខនៃវិធីសាស្ត្រជំនួសដែលអាចទទួលយកបាន និងការបង្ហាញភស្តុតាង ដែលស្របតាមកថាខណ្ឌ (2)។

(8) ក្នុងកម្រិតដែលបទប្បញ្ញត្តិ ឬការអនុវត្តណាមួយនៃផ្នែកនេះ ដែលកំណត់ការបែងចែកសមាមាត្រដោយយោងទៅលើភាពជាអ្នករស់នៅ ត្រូវបានចាត់ទុកថាគ្មានសុពលភាព ផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬមិនអាចអនុវត្តបានតាមមធ្យោបាយផ្សេងទៀត នោះភាពជាអ្នករស់នៅត្រូវយកមកកំណត់ចំពោះបទប្បញ្ញត្តិ ឬការអនុវត្តបែបនេះ ដោយអនុលោមតាមវិធានដែលគ្រប់គ្រងពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួននៅក្នុងភាគទី 10 (ចាប់ផ្តើមជាមួយផ្នែកទី 17001) រួមទាំងផ្នែកទី 17014 និង 17015.5។

50307. (a) ត្រូវអនុញ្ញាតជាឥណទានប្រឆាំងនឹងពន្ធដែលបានកំណត់ដោយភាគនេះ នូវទឹកប្រាក់ស្មើនឹងចំណែកសមាមាត្ររបស់អ្នកបង់ពន្ធនៃពន្ធណាមួយដែលបានបង់លើពន្ធលើតម្លៃសុទ្ធនៃទ្រព្យសម្បត្តិ ដែលត្រូវបានយកពន្ធផងដែរក្រោមភាគនេះ ដែលក្នុងនោះចំណែកសមាមាត្រត្រូវជាសមាមាត្រដែលភាគយកគឺជាចំនួនថ្ងៃសរុបដែលអ្នកបង់ពន្ធបានរស់នៅក្នុងរដ្ឋ ឬដែនសមត្ថកិច្ចជាប់ពន្ធផ្សេងទៀតក្នុងអំឡុងពេលឆ្នាំពន្ធ 2026 និងភាគបែងត្រូវជា 365។ ដើម្បីបំបាត់រាល់ការសង្ស័យ ដោយសារតែអចលនទ្រព្យដែលកាន់កាប់ផ្ទាល់មិនត្រូវបានយកពន្ធក្រោមភាគនេះ គ្មានឥណទានណាមួយត្រូវបានអនុញ្ញាតក្រោមផ្នែករងនេះសម្រាប់ពន្ធលើអចលនទ្រព្យដែលកាន់កាប់ផ្ទាល់នោះឡើយ។

(b) ឥណទានបន្ថែមត្រូវបានអនុញ្ញាតចំពោះពន្ធដែលបានបង់នៅក្នុងដែនសមត្ថកិច្ចផ្សេងទៀត ក្នុងកម្រិតដែលរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកតម្រូវ។

ជំពូកទី 6. បទប្បញ្ញត្តិទូទៅ និងនិយមន័យ

50308. សម្រាប់គោលបំណងនៃភាគនេះ និយមន័យខាងក្រោមត្រូវអនុវត្ត៖

(a) "បុគ្គលដែលអនុវត្ត" មានន័យថា សម្រាប់ឆ្នាំពន្ធ 2026 បុគ្គលណាមួយដែលជាអ្នករស់នៅក្នុងរដ្ឋនេះ ក្នុងន័យនៃផ្នែកទី 17014 និង 17015.5 គិតត្រឹមកាលបរិច្ឆេទកាតព្វកិច្ចពន្ធដែលមានចែងក្នុងផ្នែករង (n)។

(b) "ទ្រព្យបាលដែលអនុវត្ត" មានន័យថា ទ្រព្យបាលណាមួយ ក្រៅពីទ្រព្យបាលប្រភេទអ្នកបង្កើត ឬទ្រព្យបាលដែលទទួលបានការអនុគ្រោះពន្ធ មិនថាតើទ្រព្យបាលនោះជាអ្នករស់នៅក្នុងរដ្ឋ California ឬអត់ ប្រសិនបើបុគ្គលដែលអនុវត្តដែលនៅមានជីវិត និងមានតម្លៃសុទ្ធនៃទ្រព្យសម្បត្តិចំនួនមួយពាន់លានដុល្លារ ($1,000,000,000) ឡើងទៅ ឬអង្គភាពណាមួយដែលនឹងបង្កើតបានជាបុគ្គលពាក់ព័ន្ធចំពោះបុគ្គលនោះ បានផ្ទេរទ្រព្យសម្បត្តិទៅឱ្យទ្រព្យបាលនោះ។ ប្រសិនបើបុគ្គលច្រើនជាងម្នាក់បានផ្ទេរទ្រព្យសម្បត្តិទៅឱ្យទ្រព្យបាលនោះ ចំណែកមួយនៃទ្រព្យបាលត្រូវចាត់ទុកថាជាទ្រព្យបាលដែលអនុវត្ត ដែលក្នុងនោះចំណែកដែលត្រូវបានចាត់ទុកដូច្នោះ ត្រូវស្មើនឹងសមាមាត្រនៃតម្លៃទ្រព្យសកម្មដែលបានផ្ទេរទៅឱ្យទ្រព្យបាលដោយបុគ្គលដែលអនុវត្ត ឬអង្គភាពណាមួយដែលនឹងបង្កើតបានជាបុគ្គលពាក់ព័ន្ធចំពោះបុគ្គលនោះ ធៀបនឹងតម្លៃសរុបនៃទ្រព្យសកម្មដែលបានផ្ទេរទៅឱ្យទ្រព្យបាល។ បន្ថែមពីនេះ ទ្រព្យបាលណាមួយអាចជ្រើសរើសក្លាយជាទ្រព្យបាលដែលអនុវត្ត តាមរយៈការជូនដំណឹងដល់ក្រុមប្រឹក្សាអំពីការជ្រើសរើសនោះ តាមមធ្យោបាយណាមួយដែលក្រុមប្រឹក្សាអាចកំណត់។ បុគ្គលដែលមានតម្លៃសុទ្ធនៃទ្រព្យសម្បត្តិមួយពាន់លានដុល្លារ ($1,000,000,000) ឡើងទៅ ដែលបានផ្ទេរទ្រព្យសម្បត្តិទៅឱ្យទ្រព្យបាលដែលអនុវត្ត អាចជ្រើសរើសចាត់ទុកទ្រព្យបាលនោះថាជាផ្នែកមួយនៃតម្លៃសុទ្ធនៃទ្រព្យសម្បត្តិរបស់បុគ្គលនោះ ដោយការជូនដំណឹងដល់ក្រុមប្រឹក្សាអំពីការជ្រើសរើសនោះតាមមធ្យោបាយណាមួយដែលក្រុមប្រឹក្សាអាចកំណត់។ ក្នុងករណីមានការជ្រើសរើសនោះ ទ្រព្យបាលនឹងមិនត្រូវស្ថិតក្រោមពន្ធដាច់ដោយឡែកក្រោមផ្នែកទី 50301 ឡើយ។

(c) "ក្រុមប្រឹក្សា" មានន័យថា ក្រុមប្រឹក្សាពន្ធលើសិទ្ធិអាជីវកម្ម។

(d) "អ្នកក្នុងបន្ទុក" ត្រូវមានន័យដូចគ្នានឹងនិយមន័យនៃពាក្យនោះដែលមានចែងក្នុងផ្នែកទី 152 នៃ ក្រមពន្ធដារផ្នែកក្នុង។

(e) "ទ្រព្យបាលប្រភេទអ្នកបង្កើត" មានន័យថា ទ្រព្យបាលណាមួយដែលនឹងត្រូវជាទ្រព្យបាលប្រភេទអ្នកបង្កើតសម្រាប់គោលបំណងពន្ធលើប្រាក់ចំណូល ហើយរួមទាំងទ្រព្យបាលណាមួយដែលទ្រព្យសកម្មរបស់វាត្រូវដាក់បញ្ចូលក្នុងទ្រព្យមរតករបស់អ្នកបង្កើតសម្រាប់គោលបំណងពន្ធលើការផ្ទេរទ្រព្យសម្បត្តិសហព័ន្ធ។

(f) "តម្លៃសុទ្ធនៃទ្រព្យសម្បត្តិ" មានន័យថា តម្លៃសរុបនៃទ្រព្យសកម្មទាំងអស់ និងផលប្រយោជន៍លើទ្រព្យសម្បត្តិដែលត្រូវយកមកគិតចំពោះអ្នកបង់ពន្ធ និងសហព័ទ្ធរបស់ពួកគេទូទាំងពិភពលោកក្រោមផ្នែកទី 50303 និងបទប្បញ្ញត្តិផ្សេងទៀតដែលអនុវត្តបាននៃភាគនេះ គិតត្រឹមកាលបរិច្ឆេទកំណត់តម្លៃដែលមានចែងក្នុងផ្នែករង (o) ដោយមិនប្រកាន់ថាសហព័ទ្ធនោះរស់នៅទីណាក៏ដោយ ដោយត្រូវកាត់បន្ថយដោយតម្លៃសរុបនៃបំណុលនិងកាតព្វកិច្ចផ្សេងទៀត ក្នុងកម្រិតដែលការកាត់បន្ថយទាំងនោះត្រូវបានអនុញ្ញាតក្រោមផ្នែកទី 50302។ ដើម្បីជៀសវាងរាល់ការសង្ស័យ ទ្រព្យសកម្មដែលត្រូវបានយកមកគិតក្រោមផ្នែកទី 50303 គិតត្រឹមកាលបរិច្ឆេទកំណត់តម្លៃ ត្រូវបានដាក់បញ្ចូលទៅក្នុងតម្លៃសុទ្ធនៃទ្រព្យសម្បត្តិ ទោះបីជាបានទទួលបន្ទាប់ពីកាលបរិច្ឆេទកាតព្វកិច្ចពន្ធក៏ដោយ ហើយផលប្រយោជន៍ដែលបានចាត់ចែងចោលមុនកាលបរិច្ឆេទកំណត់តម្លៃត្រូវបានដកចេញពីតម្លៃសុទ្ធលើកលែងតែក្នុងកម្រិតដែលភាគនេះ រួមមានជាអាទិ៍ ផ្នែកទី 50303 និងផ្នែកទី 50312 តម្រូវឱ្យទ្រព្យសកម្មដែលបានផ្ទេរ ទ្រព្យសកម្មដែលបានកំណត់លក្ខណៈឡើងវិញ ឬទ្រព្យសកម្មដែលកាន់កាប់ដោយទ្រព្យបាល ឬផលប្រយោជន៍លើទ្រព្យសម្បត្តិផ្សេងទៀត ត្រូវដាក់បញ្ចូលក្នុងតម្លៃសុទ្ធនៃទ្រព្យសម្បត្តិរបស់អ្នកបង់ពន្ធ។

(g) "គណនីពន្យារពេលសងជាជម្រើស" ឬ "ODA" មានន័យថា គណនីបម្រុងពន្ធដែលមិនទាន់បំប្លែងជាសាច់ប្រាក់ ដែលគ្រប់គ្រងដោយផ្នែកទី 50304។

(h) "បុគ្គល" ត្រូវមានន័យដូចគ្នានឹងពាក្យដែលត្រូវបានកំណត់នៅក្នុងផ្នែកទី 17007។

(i) "អង្គភាពមូលធនឯកជន" មានន័យថា អង្គភាពអាជីវកម្ម ក្រៅពីអង្គភាពជួញដូរជាសាធារណៈ មូលនិធិរួម ឬមូលនិធិជួញដូរតាមផ្សារហ៊ុន ដែលប្រកបជាចម្បងនូវអាជីវកម្មនៃការវិនិយោគលើអាជីវកម្មផ្សេងទៀត។

40

(j) "ទ្រព្យសកម្មដែលជួញដូរជាសាធារណៈ" មានន័យថា ទ្រព្យសកម្មដែលត្រូវបានជួញដូរនៅលើផ្សារហ៊ុន; ជួញដូរនៅលើទីផ្សារបន្ទាប់បន្សំដែលតម្លៃលក់សម្រាប់ទ្រព្យសកម្មនោះត្រូវបានធ្វើបច្ចុប្បន្នភាពជាញឹកញាប់; មាននៅលើវេទិកាអនឡាញ ឬអេឡិចត្រូនិកដែលផ្គូផ្គងអ្នកទិញ និងអ្នកលក់ជាទៀងទាត់; ឬទ្រព្យសកម្មផ្សេងទៀតណាមួយដែលក្រុមប្រឹក្សាកំណត់ថាមានតម្លៃដែលអាចកំណត់បានយ៉ាងងាយស្រួលតាមមធ្យោបាយស្រដៀងគ្នា។

(k) "បុគ្គលពាក់ព័ន្ធ" មានន័យថា បុគ្គលណាមួយដែលពាក់ព័ន្ធនឹងអ្នកបង់ពន្ធក្រោមផ្នែកទី 267 ឬ 318 នៃ ក្រមពន្ធដារផ្ទៃក្នុង គិតត្រឹមថ្ងៃទី 1 ខែមករា ឆ្នាំ 2026 ព្រមទាំងបុគ្គលផ្សេងទៀតណាមួយដែលត្រូវបានបញ្ជាក់ដូច្នោះដោយបទប្បញ្ញត្តិដែលអនុម័តដោយក្រុមប្រឹក្សា។

(l) "អត្ថប្រយោជន៍ជាសារធាតុ" មានអត្ថន័យដូចពាក្យដែលកំណត់ដោយតុលាការកំពូលសហរដ្ឋអាមេរិកនៅក្នុងសំណុំរឿង សហរដ្ឋអាមេរិក ទល់នឹង មូលនិធិបរិច្ចាគរបស់សមាគមមេធាវីអាមេរិក (1986) 477 U.S. 105។

(m) "ទ្រព្យបាលដែលទទួលបានការអនុគ្រោះពន្ធ" មានន័យថា ទ្រព្យបាលដែលត្រូវបានលើកលែងពីពន្ធលើប្រាក់ចំណូលសហព័ន្ធក្រោមផ្នែកទី 501 នៃ ក្រមពន្ធដារផ្ទៃក្នុង។

(n) "កាលបរិច្ឆេទកាតព្វកិច្ចពន្ធ" មានន័យថា ថ្ងៃទី 1 ខែមករា ឆ្នាំ 2026។

(o) "កាលបរិច្ឆេទកំណត់តម្លៃ" មានន័យថា ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2026។

50309. (a) ការប្រមូល និងការគ្រប់គ្រងពន្ធដែលមានចែងក្នុងភាគនេះត្រូវគ្រប់គ្រងដោយភាគទី 10.2 (ចាប់ផ្តើមជាមួយផ្នែកទី 18401) លុះត្រាតែត្រូវបានជំនួសដោយច្បាស់លាស់ដោយភាគនេះ។

(b) ក្រុមប្រឹក្សាអាចអនុម័តបទប្បញ្ញត្តិដើម្បីអនុវត្ត បកស្រាយ ធ្វើឱ្យមានភាពជាក់លាក់ ឬអនុវត្តបទប្បញ្ញត្តិណាមួយនៃភាគនេះតាមរបៀបផ្សេងទៀត។

(1) បទប្បញ្ញត្តិអាចរួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមតែ៖

(A) ការកំណត់អត្តសញ្ញាណប្រតិបត្តិការរំលោភប្រើ ដែលមានគោលបំណងផ្លាស់ប្តូរលក្ខណៈនៃទ្រព្យសកម្មពីសាធារណៈទៅជាមិនមែនសាធារណៈ ឬផ្ទុយទៅវិញ។

(B) ការកំណត់អត្តសញ្ញាណប្រតិបត្តិការរំលោភប្រើ ដែលមានគោលបំណងកាត់បន្ថយដោយសិប្បនិម្មិតនូវតម្លៃវាយតម្លៃនៃទ្រព្យសកម្មរបស់អ្នកបង់ពន្ធ។

(2) រហូតដល់ថ្ងៃទី 1 ខែមករា ឆ្នាំ 2028 បទប្បញ្ញត្តិស្តីពីនីតិវិធីធ្វើច្បាប់នៃច្បាប់ស្តីពីនីតិវិធីរដ្ឋបាល (ជំពូកទី 3.5 (ចាប់ផ្តើមជាមួយផ្នែកទី 11340) នៃភាគទី 1 នៃផ្នែកទី 3 នៃចំណងជើងទី 2 នៃក្រមរដ្ឋាភិបាល) មិនត្រូវអនុវត្តចំពោះបទប្បញ្ញត្តិ ស្តង់ដា លក្ខណៈវិនិច្ឆ័យ នីតិវិធី ការសម្រេចចិត្ត វិធានសេចក្តីជូនដំណឹង គោលការណ៍ណែនាំ ឬការណែនាំផ្សេងទៀតណាមួយដែលបានបង្កើត ឬចេញដោយក្រុមប្រឹក្សាស្របតាមភាគនេះឡើយ។

(3) ទោះបីជាមានផ្នែកទី 19057 ឬច្បាប់ផ្សេងទៀតក៏ដោយ រាល់សេចក្តីជូនដំណឹងអំពីការវាយតម្លៃខ្វះខាតដែលបានស្នើឡើងក្រោមភាគនេះពាក់ព័ន្ធនឹងឆ្នាំពន្ធដែលចាប់ផ្តើមនៅ ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2026 និងមុនថ្ងៃទី 1 ខែមករា ឆ្នាំ 2027 ត្រូវផ្ញើជូនអ្នកបង់ពន្ធតាមប្រៃសណីយ៍ក្នុងរយៈពេល 10 ឆ្នាំ បន្ទាប់ពីលិខិតប្រកាសពន្ធត្រូវបានដាក់។

(c) ក្នុងរយៈពេលប្រាំមួយខែបន្ទាប់ពីការអនុម័ត ក្រុមប្រឹក្សាត្រូវចេញផ្សាយនូវទម្រង់បែបបទដែលតម្រូវសម្រាប់អ្នកបង់ពន្ធដើម្បីបង់ពន្ធដែលបានកំណត់ដោយភាគនេះ។ ទម្រង់បែបបទទាំងនោះអាចចែងឱ្យមានឯកសារភ្ជាប់របស់អ្នកបង់ពន្ធដែលបង្ហាញពីការអនុលោមភាព។ ក្រុមប្រឹក្សាត្រូវកែប្រែទម្រង់បែបបទពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួន និងកែប្រែ ឬបង្កើតទម្រង់បែបបទផ្សេងទៀតតាមការចាំបាច់ សម្រាប់ការរាយការណ៍អំពីទ្រព្យសកម្ម ឬព័ត៌មានផ្សេងទៀតដែលមានប្រយោជន៍សម្រាប់ការអនុវត្តភាគនេះ។

(d) ក្នុងកម្រិតដែលមិនផ្ទុយនឹងជំពូកនេះ បទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងការវាយតម្លៃ ការប្រមូល ការអនុវត្តច្បាប់ និងបណ្តឹងឧទ្ធរណ៍នៃពន្ធលើប្រាក់ចំណូល ត្រូវយកមកអនុវត្តចំពោះការយកពន្ធលើតម្លៃសុទ្ធនៃទ្រព្យសម្បត្តិដែលកំណត់ដោយភាគនេះ។

50310. អំណាចរបស់អង្គនីតិបញ្ញត្តិ

អង្គនីតិបញ្ញត្តិអាចធ្វើវិសោធនកម្មច្បាប់ស្តីពីពន្ធលើមហាសេដ្ឋីឆ្នាំ 2026 តាមរយៈលក្ខន្តិកៈដែលត្រូវបានអនុម័តនៅក្នុងសភានីតិបញ្ញត្តិនីមួយៗ តាមរយៈការបោះឆ្នោតហៅឈ្មោះដែលបានកត់ត្រាទុកក្នុងកំណត់ហេតុ ដោយមានសមាជិកពីរភាគបីយល់ព្រម ប្រសិនបើលក្ខន្តិកៈនោះស្របតាម និងលើកកម្ពស់គោលបំណងរបស់ច្បាប់ស្តីពីពន្ធលើមហាសេដ្ឋីឆ្នាំ 2026។

50311. ភាពអាចបំបែកបាន

(a) បទប្បញ្ញត្តិនៃច្បាប់ស្តីពីពន្ធលើមហាសេដ្ឋីឆ្នាំ 2026 ដែលហៅម្យ៉ាងទៀតថា "ច្បាប់" គឺអាចបំបែកបាន។ ទោះបីជាច្បាប់នេះត្រូវបានរៀបចំឡើងយ៉ាងយកចិត្តទុកដាក់ដើម្បីអនុលោមតាមច្បាប់ដែលមានស្រាប់ក៏ដោយ ប្រសិនបើបទប្បញ្ញត្តិណាមួយនៃច្បាប់នេះ ឬការអនុវត្តរបស់វាត្រូវបានចាត់ទុកថាគ្មានសុពលភាព ផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬមិនអាចអនុវត្តបានតាមរបៀបណាមួយ ការរកឃើញនោះមិនត្រូវប៉ះពាល់ដល់ភាពអាចអនុវត្តបាននៃបទប្បញ្ញត្តិ ឬការអនុវត្តផ្សេងទៀតឡើយ។

(b) ក្នុងការអនុវត្តច្បាប់នេះ តុលាការត្រូវ ក្នុងកម្រិតអតិបរមាដែលស្របតាមរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក និងរដ្ឋធម្មនុញ្ញនៃរដ្ឋ California រក្សាទុកនូវការយកពន្ធដែលបានអនុញ្ញាត រួមទាំងតាមរយៈការកែសម្រួលកាលបរិច្ឆេទ ឬរយៈពេលដែលបានបញ្ជាក់ ដោយប្រើប្រាស់ការកែសម្រួលដែលមានកម្រិតតិចតួចបំផុតដែលអាចធ្វើទៅបាន ដើម្បីកែតម្រូវពិការភាពរដ្ឋធម្មនុញ្ញ ឬពិការភាពផ្លូវច្បាប់ផ្សេងទៀត ខណៈពេលដែលអនុញ្ញាតឱ្យបទប្បញ្ញត្តិដែលនៅសល់ដំណើរការ។ ប្រសិនបើតុលាការកំណត់ថាការដាក់ទំនួលខុសត្រូវក្រោមច្បាប់នេះ ដោយយោងទៅតាមកាលបរិច្ឆេទកាតព្វកិច្ចពន្ធដែលមានចែងក្នុងផ្នែករង (n) នៃផ្នែកទី 50308 ឬកាលបរិច្ឆេទកំណត់តម្លៃដែលមានចែងក្នុងផ្នែករង (o) នៃផ្នែកទី 50308 ទាំងស្រុង ឬដោយផ្នែក មានលក្ខណៈផ្ទុយនឹងរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក រដ្ឋធម្មនុញ្ញនៃរដ្ឋ California ឬច្បាប់សហព័ន្ធផ្សេងទៀតដែលគ្រប់គ្រង នោះក្នុងកម្រិតនៃការកំណត់នោះ រាល់ឯកសារយោងទាំងអស់នៅក្នុងច្បាប់នេះ និងនៅក្នុងផ្នែកទី 37 នៃមាត្រា XIII នៃរដ្ឋធម្មនុញ្ញនៃរដ្ឋ California ចំពោះ "កាលបរិច្ឆេទកាតព្វកិច្ចពន្ធ" និង "កាលបរិច្ឆេទកំណត់តម្លៃ" ត្រូវបកស្រាយជំនួសវិញថា សំដៅលើកាលបរិច្ឆេទ ឬកាលបរិច្ឆេទដំបូងបំផុតបន្ទាប់ពីកាលបរិច្ឆេទកាតព្វកិច្ចពន្ធ ឬកាលបរិច្ឆេទកំណត់តម្លៃ ដែលអាចអនុវត្តបាន ដែលការទទួលខុសត្រូវអាចត្រូវបានដាក់ឱ្យស្របតាមច្បាប់នោះ។ ក្នុងការកែសម្រួលកាលបរិច្ឆេទ ឬរយៈពេលណាមួយដែលមានចែងក្នុងច្បាប់នេះ តុលាការត្រូវរក្សាទុកក្នុងកម្រិតអតិបរមាដែលច្បាប់អនុញ្ញាត នូវការយកពន្ធសម្រាប់ឆ្នាំពន្ធ 2026 ឬប្រសិនបើមិនអាចអនុញ្ញាតបានទេ គឺសម្រាប់ឆ្នាំ 2027 ឬឆ្នាំបន្តបន្ទាប់ដំបូងបំផុតដែលអាចអនុញ្ញាតបាន ខណៈពេលដែលនៅតែរក្សាទុកនូវរចនាសម្ព័ន្ធទាំងស្រុង និងគោលបំណងរួមនៃច្បាប់នេះ។

50312. ការអនុវត្តច្បាប់ និងទណ្ឌកម្ម

(a) អ្នកបង់ពន្ធដែលស្ថិតក្រោមពន្ធដែលបានកំណត់ក្រោមភាគនេះ ដែលមានការប្រកាសពន្ធខ្វះជាសារធាតុ ឬការប្រកាសពន្ធខ្វះដុលសម្រាប់ឆ្នាំពន្ធណាមួយ ត្រូវទទួលរងការពិន័យដែលបានកំណត់ក្រោមផ្នែកនេះ។ ការប្រកាសពន្ធខ្វះមានលក្ខណៈជាសារធាតុ ប្រសិនបើការប្រកាសពន្ធខ្វះនោះលើសពីចំនួនធំជាងគេនៃចំណុចខាងក្រោម៖

(1) មួយលានដុល្លារ ($1,000,000)។

(2) ម្ភៃភាគរយនៃពន្ធដែលមានបង្ហាញនៅលើលិខិតប្រកាសពន្ធដើម ឬដែលមានបង្ហាញនៅលើលិខិតប្រកាសពន្ធកែសម្រួលដែលបានដាក់ស្នើនៅឬមុនថ្ងៃកំណត់ដើម ឬថ្ងៃកំណត់ដែលបានពន្យារពេលនៃលិខិតប្រកាសពន្ធសម្រាប់ឆ្នាំពន្ធនោះ។

(b) ការប្រកាសពន្ធខ្ទះគឺជាការប្រកាសពន្ធខ្ទះដុល ប្រសិនបើការប្រកាសពន្ធខ្ទះនោះលើសពីចំនួនធំជាងគេនៃចំណុចខាងក្រោម៖

(1) ដប់លានដុល្លារ ($10,000,000)។

(2) សែសិបភាគរយនៃពន្ធដែលមានបង្ហាញនៅលើលិខិតប្រកាសពន្ធដើម ឬដែលមានបង្ហាញនៅលើលិខិតប្រកាសពន្ធកែសម្រួលដែលបានដាក់ស្នើនៅ ឬមុនថ្ងៃកំណត់ដើម ឬថ្ងៃកំណត់ដែលបានពន្យារពេលនៃលិខិតប្រកាសពន្ធសម្រាប់ឆ្នាំពន្ធនោះ។

(c) ទណ្ឌកម្មមានដូចខាងក្រោម៖

(1) ការពិន័យសម្រាប់ការប្រកាសពន្ធខ្ទះជាសារធាតុក្រោមផ្នែកនេះ ត្រូវមានចំនួនស្មើនឹង 20 ភាគរយនៃការប្រកាសពន្ធខ្ទះណាមួយ។ សម្រាប់គោលបំណងនៃផ្នែកនេះ "ការប្រកាសពន្ធខ្ទះ" មានន័យថា ចំនួនទឹកប្រាក់ដែលពន្ធដែលបានកំណត់ដោយភាគនេះលើសពីចំនួនពន្ធដែលមានបង្ហាញនៅលើលិខិតប្រកាសពន្ធដើម ឬដែលមានបង្ហាញនៅលើលិខិតប្រកាសពន្ធកែសម្រួលដែលបានដាក់ស្នើនៅ ឬមុនថ្ងៃកំណត់ដើម ឬថ្ងៃកំណត់ដែលបានពន្យារពេលនៃលិខិតប្រកាសពន្ធសម្រាប់ឆ្នាំពន្ធនោះ។

(2) ការពិន័យក្រោមផ្នែកនេះសម្រាប់ការប្រកាសពន្ធខ្ទះដុលត្រូវមានចំនួនស្មើនឹង 40 ភាគរយនៃការប្រកាសពន្ធខ្ទះណាមួយ។

(d) ការពិន័យដែលបានកំណត់ដោយផ្នែកនេះ ត្រូវជាការបន្ថែមលើការពិន័យផ្សេងទៀតណាមួយដែលបានកំណត់ក្រោមភាគ 10.2 (ចាប់ផ្តើមជាមួយផ្នែកទី 18401) ឬច្បាប់ផ្សេងទៀត។

(e) ការសងប្រាក់ពន្ធវិញ ឬក្រេឌីតសម្រាប់ចំនួនទឹកប្រាក់ណាមួយដែលបានបង់ដើម្បីទូទាត់ការពិន័យដែលបានកំណត់ក្រោមផ្នែកនេះ អាចត្រូវបានអនុញ្ញាតបានតែលើមូលដ្ឋានថាចំនួនទឹកប្រាក់នៃការពិន័យនោះត្រូវបានគណនាដោយមិនត្រឹមត្រូវដោយក្រុមប្រឹក្សា។

(f) មិនត្រូវដាក់ការពិន័យណាមួយក្រោមផ្នែកនេះចំពោះការប្រកាសពន្ធខ្វះណាមួយឡើយ ក្នុងកម្រិតដែលការប្រកាសពន្ធខ្ទះនោះបណ្តាលមកពីកត្តាណាមួយដូចខាងក្រោម៖

(1) ការប្រែប្រួលច្បាប់ដែលត្រូវបានបញ្ញត្តិ អនុម័ត ចេញ ឬក្លាយជាស្ថាពរបន្ទាប់ពីកាលបរិច្ឆេទមុនជាងគេក្នុងចំណោមកាលបរិច្ឆេទទាំងពីរខាងក្រោម៖

(A) កាលបរិច្ឆេទដែលអ្នកបង់ពន្ធដាក់លិខិតប្រកាសពន្ធសម្រាប់ឆ្នាំពន្ធដែលការប្រែប្រួលនោះចាប់ផ្តើមអនុវត្ត។

(B) កាលបរិច្ឆេទកំណត់ដែលបានពន្យារសម្រាប់លិខិតប្រកាសពន្ធរបស់អ្នកបង់ពន្ធ សម្រាប់ឆ្នាំពន្ធដែលការប្រែប្រួលនោះចាប់ផ្តើមអនុវត្ត។

(2) សម្រាប់គោលបំណងនៃផ្នែករងនេះ "ការប្រែប្រួលច្បាប់" មានន័យថាការប្រែប្រួលតាមលក្ខន្តិក: ឬការបកស្រាយច្បាប់ ឬវិធានច្បាប់ តាមបទប្បញ្ញត្តិ ឬសេចក្តីសម្រេចផ្នែកច្បាប់របស់ទីប្រឹក្សាច្បាប់ ក្នុងន័យនៃផ្នែករង (b) នៃផ្នែកទី 11340.9 នៃក្រមរដ្ឋាភិបាល ឬសេចក្តីសម្រេចតុលាការសហព័ន្ធ ឬតុលាការ California ដែលបានបោះពុម្ពផ្សាយ។

(3) ក្រុមប្រឹក្សាត្រូវអនុវត្តផ្នែករងនេះតាមរបៀបដ៏សមហេតុផលមួយ។

(g) មិនត្រូវដាក់ការពិន័យណាមួយក្រោមផ្នែកនេះក្នុងកម្រិតដែលការប្រកាសពន្ធខ្ទះរបស់អ្នកបង់ពន្ធបណ្តាលមកពីការពឹងផ្អែកដោយសមហេតុផលរបស់អ្នកបង់ពន្ធទៅលើយោបល់ជាលាយលក្ខណ៍អក្សររបស់ក្រុមប្រឹក្សា ប៉ុន្តែមានតែក្នុងករណីដែលយោបល់ជាលាយលក្ខណ៍អក្សរនោះជាសេចក្តីសម្រេចផ្នែកច្បាប់ដោយប្រធានទីប្រឹក្សាច្បាប់ ក្នុងន័យនៃកថាខណ្ឌ (1) នៃផ្នែករង (a) នៃផ្នែកទី 21012។

(h) ចំនួនទឹកប្រាក់នៃការប្រកាសពន្ធខ្ទះក្រោមផ្នែករង (a) ត្រូវកាត់បន្ថយដោយផ្នែកនោះនៃការប្រកាសពន្ធខ្ទះ ដែលបណ្តាលមកពីកត្តាណាមួយក្នុងចំណោមកត្តាខាងក្រោម៖

(1) ការព្យាបាលផ្នែកពន្ធនៃធាតុណាមួយដោយអ្នកបង់ពន្ធ ប្រសិនបើមានឬធ្លាប់មានមូលដ្ឋានគតិយុត្តជាសារធាតុសម្រាប់ការព្យាបាលនោះ។

(2) ធាតុណាមួយ ប្រសិនបើចំណុចខាងក្រោមអនុវត្ត៖

(A) ហេតុការណ៍ពាក់ព័ន្ធដែលប៉ះពាល់ដល់ការព្យាបាលផ្នែកពន្ធនៃធាតុនោះ ត្រូវបានបង្ហាញឱ្យដឹងគ្រប់គ្រាន់នៅក្នុងលិខិតប្រកាសពន្ធ ឬនៅក្នុងសេចក្តីថ្លែងការណ៍មួយដែលបានភ្ជាប់ជាមួយលិខិតប្រកាសពន្ធនោះ។

(B) មានមូលដ្ឋានសមហេតុផលសម្រាប់ការព្យាបាលផ្នែកពន្ធនៃធាតុនោះដោយអ្នកបង់ពន្ធ។

(i) ទោះជាមានចែងក្នុងផ្នែករង (a) នៃផ្នែកទី 18567 ក៏ដោយ ក៏ក្រុមប្រឹក្សាត្រូវផ្តល់ការពន្យារពេលដាក់លិខិតប្រកាសពន្ធរយៈពេលប្រាំមួយខែសម្រាប់តែឆ្នាំពន្ធ 2026 ប៉ុណ្ណោះ។ ទោះជាមានចែងក្នុងផ្នែករង (b) នៃផ្នែកទី 18567 ក៏ដោយ ការពិន័យដែលបានកំណត់ដោយផ្នែកនេះ មិនត្រូវអនុវត្តចំពោះការបង់ពន្ធប៉ាន់ស្មានដែលតម្រូវឱ្យធ្វើឡើងត្រឹមខែមេសា ឆ្នាំ 2027 ឡើយ។ ការពិន័យដែលបានកំណត់ក្រោមផ្នែកនេះ គឺត្រូវអនុវត្តចំពោះការបង់ប្រាក់ចុងក្រោយសម្រាប់ឆ្នាំពន្ធ 2026 ដែលបានធ្វើឡើងនៅក្នុងខែតុលា ឆ្នាំ 2027។ ផ្នែកទី 18567 ត្រូវអនុវត្តចំពោះពន្ធដែលបានកំណត់ដោយច្បាប់នេះសម្រាប់រាល់ឆ្នាំបន្ទាប់ពីឆ្នាំ 2027។

(j) ទោះបីមានបទប្បញ្ញត្តិផ្សេងទៀតនៃច្បាប់ក៏ដោយ ក្រុមប្រឹក្សាអាចជួលនិងបង់ថ្លៃសេវាសមហេតុផលដល់អ្នកជំនាញខាងក្រៅ ឬទីប្រឹក្សាច្បាប់ខាងក្រៅតាមភាពសមស្រប ដើម្បីជួយគ្រប់គ្រង និងប្រមូលពន្ធដែលបានអនុញ្ញាតដោយភាគនេះឱ្យបានពេញលេញ។ ទោះបីថ្លៃសេវាទាំងនោះអាចត្រូវបានគ្របដណ្តប់ដោយចំនួនទឹកប្រាក់ដែលមានចែងនៅក្នុងផ្នែករង (e) នៃផ្នែកទី 16355 នៃក្រមរដ្ឋាភិបាលក៏ដោយ ក្រុមប្រឹក្សាអាចស្វែងរកមូលនិធិបន្ថែមសម្រាប់ការទូទាត់សងវិញ បើចាំបាច់។

(k) វិធានទូទៅប្រឆាំងនឹងការគេចវេះពន្ធ។

(1) ប្រសិនបើក្រុមប្រឹក្សាកំណត់ថា ប្រតិបត្តិការណាមួយ ឬស៊េរីនៃប្រតិបត្តិការខ្វះខ្លឹមសារសេដ្ឋកិច្ច ឬថាគោលបំណងសំខាន់សម្រាប់ប្រតិបត្តិការណាមួយ ឬស៊េរីនៃប្រតិបត្តិការ គឺដើម្បីទទួលបានផលប្រយោជន៍ពន្ធទាក់ទងនឹងភាគនេះ ដែលមិនមែនជាចេតនារបស់អ្នកបោះឆ្នោត ឬអង្គនីតិបញ្ញត្តិ ក្រុមប្រឹក្សាអាចកំណត់លទ្ធផលផ្នែកពន្ធដល់បុគ្គលណាមួយតាមរបៀបដែលសមហេតុផលស្របតាមហេតុការណ៍ និងកាលៈទេសៈទាំងអស់ ដើម្បីបដិសេធផលប្រយោជន៍នោះ។

(2) សម្រាប់គោលបំណងនៃផ្នែករងនេះ ប្រតិបត្តិការណាមួយ ឬស៊េរីនៃប្រតិបត្តិការត្រូវចាត់ទុកថាខ្វះខ្លឹមសារសេដ្ឋកិច្ច ប្រសិនបើបុគ្គលនោះមិនមានគោលបំណងអាជីវកម្មដែលមានសុពលភាព និងជាសារធាតុ ដែលមិនមែនជាគោលបំណងពន្ធ សម្រាប់ការចូលធ្វើប្រតិបត្តិការ ឬស៊េរីនៃប្រតិបត្តិការនោះ ដោយគិតគូរពីផលប៉ះពាល់សេដ្ឋកិច្ចជារួមនៃប្រតិបត្តិការ ឬស៊េរីនៃប្រតិបត្តិការនោះ ក្រៅពីផលប៉ះពាល់ពន្ធរដ្ឋ និងសហព័ន្ធ។

(l) ការបែងចែកក្នុងក្រុមដែលស្ថិតក្រោមការគ្រប់គ្រង; ខ្លឹមសារលើសទម្រង់។

(1) ក្នុងករណីណាមួយនៃអង្គការ ពាណិជ្ជកម្ម អាជីវកម្ម អង្គភាព ឬការរៀបចំពីរ ឬច្រើន ដែលជាកម្មសិទ្ធិ ឬគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោល ដោយផលប្រយោជន៍ដូចគ្នា ក្រុមប្រឹក្សាអាចចែកចាយ បែងចែកសមាមាត្រ ឬបែងចែកទ្រព្យសកម្ម បំណុល ឬធាតុផ្សេងទៀតដែលពាក់ព័ន្ធនឹងការកំណត់តម្លៃសុទ្ធនៃទ្រព្យសម្បត្តិក្រោមភាគនេះ រវាង ឬក្នុងចំណោមបុគ្គលទាំងនោះ ប្រសិនបើក្រុមប្រឹក្សាកំណត់ថាការចែកចាយ ការបែងចែកសមាមាត្រ ឬការបែងចែកបែបនេះគឺចាំបាច់ ដើម្បីទប់ស្កាត់ការគេចវេះពន្ធដែលបានកំណត់ដោយភាគនេះ ឬដើម្បីឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីកម្មសិទ្ធិសេដ្ឋកិច្ច និងការទទួលបានផលប្រយោជន៍ពីធាតុពន្ធទាំងនោះ។

(2) ក្នុងការអនុវត្តអំណាចរបស់ខ្លួនក្រោមកថាខណ្ឌ (1) ក្រុមប្រឹក្សាអាចមិនទទួលស្គាល់អង្គភាព ការរៀបចំ ឬប្រតិបត្តិការណាមួយដែលខ្វះខ្លឹមសារសេដ្ឋកិច្ច ចាត់ទុកប្រតិបត្តិការពាក់ព័ន្ធថាជាប្រតិបត្តិការតែមួយក្រោមគោលលទ្ធិប្រតិបត្តិការតាមជំហាន ឬអនុវត្តតាមខ្លឹមសារជាជាងទម្រង់នៃប្រតិបត្តិការនោះ។

(m) ការប្រើប្រាស់គោលលទ្ធិពន្ធលើប្រាក់ចំណូល; គ្មានការលើកលែងដោយប្រយោលទេ។

(1) ក្នុងការអនុវត្តភាគនេះ ក្រុមប្រឹក្សាអាចពឹងផ្អែកលើ ហើយតុលាការអាចយកមកប្រើ នូវគោលការណ៍ច្បាប់ដែលបានអភិវឌ្ឍពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តពន្ធលើប្រាក់ចំណូលរបស់រដ្ឋ និងសហព័ន្ធ រួមទាំង ដោយមិនកំណត់ត្រឹមតែ គោលលទ្ធិដែលទាក់ទងនឹងខ្លឹមសារសេដ្ឋកិច្ច គោលបំណងអាជីវកម្ម ប្រតិបត្តិការក្លែងក្លាយ ប្រតិបត្តិការតាមជំហាន និងខ្លឹមសារលើសទម្រង់។

(2) មិនត្រូវមានការលើកលែង ការមិនរាប់បញ្ចូល ឬការកាត់កងពីពន្ធដែលបានកំណត់ដោយភាគនេះឡើយ វៀរលែងតែអ្វីដែលត្រូវបានអនុញ្ញាតយ៉ាងច្បាស់លាស់នៅក្នុងភាគនេះ ឬនៅក្នុងផ្នែកទី 37 នៃមាត្រា XIII នៃរដ្ឋធម្មនុញ្ញនៃរដ្ឋ California។

(n) អំណាចរបស់ក្រុមប្រឹក្សា។ ដោយមិនមានការសន្និដ្ឋានណាមួយអំពីអំណាចរបស់ក្រុមប្រឹក្សាទាក់ទងនឹងពន្ធផ្សេងទៀត ប្រសិនបើក្រុមប្រឹក្សាមិនយល់ស្របនឹងការសម្រេចរបស់ការិយាល័យបណ្តឹងឧទ្ធរណ៍ពន្ធដារ ក្រុមប្រឹក្សាអាចលើកសំណុំរឿងនៅតុលាការជាន់ខ្ពស់សម្រាប់ការកាត់ក្តីឡើងវិញពីដើម។

50313. ការបកស្រាយ

បទប្បញ្ញត្តិនៃភាគនេះត្រូវបកស្រាយដោយទូលំទូលាយដើម្បីសម្រេចគោលបំណងរបស់ខ្លួន។

50314. ការពិនិត្យឡើងវិញដោយពន្លឿន

(a) គោលបំណងនៃផ្នែកនេះ គឺដើម្បីចែងអំពីការដោះស្រាយយ៉ាងឆាប់រហ័ស និងដាច់ខាតនូវសុពលភាពតាមផ្នែអត្ថបទនៃច្បាប់នេះ តាមរយៈសំណុំរឿងបញ្ជាក់សុពលភាព។

(b) សំណុំរឿង ឬនីតិវិធី ដើម្បីកំណត់ថាតើពន្ធដែលបានកំណត់ដោយច្បាប់នេះ ឬរាល់នីតិវិធីទាក់ទងនឹងរឿងនេះ មានលក្ខណៈស្របរដ្ឋធម្មនុញ្ញ ឬគ្មានសុពលភាពតាមផ្នែអត្ថបទ ហើយដែលបានដាក់តែដើម្បីកំណត់សុពលភាពនៃច្បាប់នេះ ឬផ្នែកណាមួយនៃច្បាប់នេះ ត្រូវផ្តើមឡើងស្របតាមជំពូកទី 9 (ចាប់ផ្តើមជាមួយផ្នែកទី 860) ចំណងជើងទី 10 ភាគទី 2 នៃក្រមនីតិវិធីរដ្ឋប្បវេណី។

(c) សំណុំរឿងបញ្ជាក់សុពលភាពមិនត្រូវដាក់លើសពី 60 ថ្ងៃបន្ទាប់ពីការអនុម័តច្បាប់ដោយអ្នកបោះឆ្នោតឡើយ។ ប្រសិនបើគ្មានសំណុំរឿងត្រូវបានដាក់ក្នុងអំឡុងពេលនោះទេ ពន្ធ និងរាល់នីតិវិធីទាក់ទងនឹងរឿងនេះ រួមទាំងការអនុម័ត និងការយល់ព្រមលើច្បាប់នេះ ត្រូវចាត់ទុកថាមានសុពលភាពតាមផ្នែអត្ថបទ និងស្របច្បាប់ក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ហើយមិនអាចជំទាស់បានឡើយ។

(d) ជំពូកទី 9 (ចាប់ផ្តើមជាមួយផ្នែកទី 860) ចំណងជើងទី 10 ភាគទី 2 នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវគ្រប់គ្រងរាល់សំណុំរឿងបញ្ជាក់សុពលភាពក្រមផ្នែកនេះ ទោះយ៉ាងណា ទោះបីមានច្បាប់ផ្សេងទៀតក៏ដោយ៖

(1) ទីតាំងសាលាក្តីតែមួយគត់សម្រាប់សំណុំរឿងបញ្ជាក់សុពលភាពណាមួយ ត្រូវជាតុលាការជាន់ខ្ពស់ ខោនធី Sacramento ដែលរាល់សំណុំរឿងទាំងអស់ត្រូវបញ្ជូលរួមគ្នាយ៉ាងហោចណាស់សម្រាប់ការកាត់ក្តី ឬក្នុងកម្រិតដែលតុលាការកំណត់។

(2) បណ្តឹងឧទ្ធរណ៍ពីការសម្រេចដែលមិនអំណោយផលនៅតុលាការជាន់ខ្ពស់ ខោនធី Sacramento ត្រូវធ្វើឡើងដោយផ្ទាល់ទៅកាន់តុលាការកំពូលរដ្ឋ California ដោយគ្មានការពិនិត្យឧទ្ធរណ៍ថ្នាក់កណ្តាលឡើយ។

(3) ប្រសិនបើតុលាការកំពូលអនុញ្ញាតញត្តិសុំពិនិត្យឡើងវិញ តុលាការកំពូលត្រូវស្តាប់បណ្តឹងឧទ្ធរណ៍ ឬដីកាណាមួយដែលពាក់ព័ន្ធនឹងសុពលភាពនៃច្បាប់នេះតាមនីតិវិធីពន្លឿន។

(4) ដោយស្ថិតក្រោមការកែសម្រួលតាមការចាំបាច់ដោយតុលាការដែលមានសមត្ថកិច្ច ដើម្បីសម្របសម្រួលការសម្រេចចិត្តតុលាការប្រកបដោយភាពរហ័សរហួន និងត្រឹមត្រូវ តុលាការជាន់ខ្ពស់ Sacramento ត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាពដើម្បីដោះស្រាយសំណុំរឿងបញ្ជាក់សុពលភាពណាមួយត្រឹមថ្ងៃទី 1 ខែមេសា ឆ្នាំ 2027 ហើយតុលាការកំពូលរដ្ឋ California ត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាពដើម្បីដោះស្រាយនីតិវិធីពិនិត្យឡើងវិញណាមួយត្រឹមថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 2027 ឬឱ្យបានឆាប់តាមដែលអាចធ្វើទៅបានបន្ទាប់ពីនោះ។ កាលវិភាគដាក់អត្ថាធិប្បាយ និងសវនាការ ត្រូវកំណត់តាមការចាំបាច់ដើម្បីឱ្យទាន់កាលបរិច្ឆេទទាំងនេះ។

(5) ផ្នែកទី 868 នៃក្រមនីតិវិធីរដ្ឋប្បវេណីមិនត្រូវអនុវត្តចំពោះសំណុំរឿងដែលបានលើកឡើងក្រោមផ្នែកនេះឡើយ។

(e) រដ្ឋ ទីភ្នាក់ងាររដ្ឋាភិបាល មន្ត្រីណាមួយរបស់ខ្លួន និយោជករដ្ឋាភិបាលផ្សេងទៀត អ្នកស្នើ ឬក្នុងករណីគ្មានអ្នកស្នើ ពលរដ្ឋណាមួយនៃរដ្ឋនេះ គឺជា "បុគ្គលដែលមានផលប្រយោជន៍" ក្រោមផ្នែកទី 863 នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ផ្នែកទី 8. ទំនាស់។

ច្បាប់នេះចែងអំពីពន្ធលើតម្លៃសុទ្ធនៃទ្រព្យសម្បត្តិ មិនមែនលើប្រាក់ចំណូលនៃមហាសេដ្ឋី។ ក្នុងករណីដែលវិធានការនេះ និងវិធានការផ្សេងទៀតដែលកំណត់យកពន្ធ ឬប៉ះពាល់ដល់អត្រាពន្ធលើតម្លៃសុទ្ធនៃទ្រព្យសម្បត្តិ មិនមែនលើប្រាក់ចំណូល នៃមហាសេដ្ឋី ឬដែលចែងអំពីការប្រើប្រាស់មូលនិធិពីពន្ធលើតម្លៃសុទ្ធនៃទ្រព្យសម្បត្តិរបស់មហាសេដ្ឋី ត្រូវបង្ហាញនៅលើសន្លឹកឆ្នោតទូទាំងរដ្ឋដូចគ្នា នោះបទប្បញ្ញត្តិនៃវិធានការផ្សេងទៀត ឬវិធានការផ្សេងទៀតទាំងឡាយ ត្រូវចាត់ទុកថាមានទំនាស់នឹងវិធានការនេះ។ ក្នុងករណីដែលវិធានការនេះទទួលបានសំឡេងគាំទ្រច្រើនជាងវិធានការដែលត្រូវបានចាត់ទុកថាមានទំនាស់នឹងវា បទប្បញ្ញត្តិនៃវិធានការនេះត្រូវមានអាទិភាពទាំងស្រុង ហើយបទប្បញ្ញត្តិណាដែលមានទំនាស់នៃវិធានការផ្សេងទៀត ឬវិធានការផ្សេងទៀតទាំងឡាយ ត្រូវជាមោឃៈ និងគ្មានសុពលភាព។

ផ្នែកទី 9. សិទ្ធិឈរជាភាគីរបស់អ្នកស្នើ។

គោលបំណងនៃផ្នែកនេះគឺដើម្បីធានានូវការការពារយ៉ាងពេញលេញ និងគ្រប់ជ្រុងនៃច្បាប់នេះ ដើម្បីការពារសិទ្ធិផ្តួចផ្តើមរបស់ប្រជាជន និងសិទ្ធិរបស់ប្រជាជនក្នុងការជ្រើសរើសអ្នកដែលនឹងការពារច្បាប់នេះនៅក្នុងតុលាការ។ ទោះបីមានបទប្បញ្ញត្តិផ្សេងទៀតនៃច្បាប់ក៏ដោយ រដ្ឋ ទីភ្នាក់ងាររដ្ឋាភិបាល មន្ត្រីណាមួយរបស់ខ្លួន និយោជករដ្ឋាភិបាលផ្សេងទៀត អ្នកស្នើ ឬក្នុងករណីគ្មានអ្នកស្នើ ពលរដ្ឋណាមួយនៃរដ្ឋនេះ អាចការពារភាពស្របច្បាប់នៃច្បាប់នេះ ដូចមានចែងក្នុងនោះ តាមរយៈសំណុំរឿងបញ្ជាក់សុពលភាព ឬតាមមធ្យោបាយផ្សេងទៀតដែលអាចមាន ហើយត្រូវបានអនុញ្ញាតឱ្យប្តឹងដោយផ្ទាល់ ឬធ្វើអន្តរាគមន៍សម្រាប់គោលបំណងការពារច្បាប់នេះ នៅតុលាការជំនុំជម្រះ ក្នុងដំណាក់កាលឧទ្ធរណ៍ ក្នុងការពិនិត្យឡើងវិញដោយតុលាការកំពូលនៃរដ្ឋ California ឬក្នុងការអនុវត្តយុត្តាធិការដើមរបស់តុលាការនោះ ឬនៅចំពោះមុខតុលាការកំពូលនៃសហរដ្ឋអាមេរិក។ ថ្លៃសេវា និងចំណាយសមហេតុផលនៃការការពារច្បាប់នេះ និងការតស៊ូមតិសម្រាប់សុពលភាពរបស់វា ប្រសិនបើអគ្គរដ្ឋអាជ្ញាមិនការពារច្បាប់នេះទេ ត្រូវជាបន្ទុកលើមូលនិធិដែលបានអនុម័តថវិកាជូនអគ្គរដ្ឋអាជ្ញា ដែលត្រូវទូទាត់ភ្លាមៗ។

សំណើ 41

វិធានការផ្តួចផ្តើមនេះត្រូវបានដាក់ជូនប្រជាជនដោយអនុលោមតាមបទប្បញ្ញត្តិនៃផ្នែកទី 8 មាត្រា II នៃរដ្ឋធម្មនុញ្ញនៃរដ្ឋ California។

វិធានការផ្តួចផ្តើមនេះបន្ថែមផ្នែកមួយចំនួនទៅក្នុងរដ្ឋធម្មនុញ្ញនៃរដ្ឋ California។ ដូច្នេះ បទប្បញ្ញត្តិថ្មីដែលស្នើឱ្យបន្ថែមត្រូវបានបោះពុម្ពជា *អក្សរទ្រេត* ដើម្បីបញ្ជាក់ថាបទប្បញ្ញត្តិទាំងនោះជាបទប្បញ្ញត្តិថ្មី។

ច្បាប់ដែលបានស្នើ

ផ្នែកទី 1. ចំណងជើង។

ច្បាប់នេះត្រូវស្គាល់ និងអាចដកស្រង់ថាជា ច្បាប់កែលម្អតម្លាភាព ប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងរដ្ឋាភិបាលរដ្ឋ California ឆ្នាំ 2026។

ផ្នែកទី 2. សេចក្តីរកឃើញ និងសេចក្តីប្រកាស។

ប្រជាជននៃរដ្ឋ California តាមនេះរកឃើញ និងប្រកាសដូចខាងក្រោម៖

(a) ជារៀងរាល់ថ្ងៃ ប្រជាជនរដ្ឋ California កំពុងប្រឈមមុខនឹងវិបត្តិលទ្ធភាពចំណាយ។ ចំណាយលើលំនៅឋាន អាហារ អគ្គិសនី ការថែទាំសុខភាព ការធានារ៉ាប់រងផ្ទះ និងរថយន្ត ព្រមទាំងតម្រូវការចាំបាច់ជាច្រើនទៀតក្នុងជីវិត នៅតែបន្តកើនឡើង។

(b) ប្រជាជនរដ្ឋ California ស្ថិតក្នុងចំណោមប្រជាជនដែលជាប់ពន្ធខ្ពស់បំផុតនៅសហរដ្ឋអាមេរិករួចទៅហើយ។ ការវិភាគថ្មីមួយដោយវិទ្យាស្ថានស្រាវជ្រាវដែលមិនចូលខាងគណបក្សណាមួយ បានសន្និដ្ឋានថា California ជាប់ចំណាត់ថ្នាក់លេខ 48 នៅទូទាំងប្រទេស ក្នុងការដាក់បន្ទុកពន្ធលើប្រជាជនរបស់ខ្លួន ដោយពិចារណាលើពន្ធលើប្រាក់ចំណូលបុគ្គល ពន្ធលើការលក់ ពន្ធលើអចលនទ្រព្យ និងទម្រង់ពន្ធផ្សេងៗទៀត។ រដ្ឋ California មានពន្ធលើការលក់របស់រដ្ឋខ្ពស់ជាងគេនៅទូទាំងប្រទេស អត្រាពន្ធលើប្រាក់ចំណូលកម្រិតខ្ពស់បំផុតខ្ពស់ជាងគេ និងពន្ធលើប្រេងសាំងខ្ពស់ជាងគេក្នុងចំណោមសូចនាករផ្សេងៗទៀត។

(c) កម្មវិធីសាធារណៈផ្តល់នូវសេវាកម្មដែលត្រូវការជាចាំបាច់ រួមទាំងដល់កុមារ គ្រួសារ និងជនងាយរងគ្រោះបំផុតនៅក្នុងរដ្ឋរបស់យើង។ ប៉ុន្តែប្រាក់ពន្ធរាប់ពាន់លានដុល្លាររបស់យើងបានហូរចូលទៅក្នុងកម្មវិធីដូចជាកិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហាភាពគ្មានផ្ទះសម្បែង ដោយទទួលបានលទ្ធផលតិចតួចបំផុត។

(d) មុនពេលសុំឱ្យអ្នកបង់ពន្ធបង់ប្រាក់ដែលរកបានមកដោយញើសឈាមរបស់ពួកគេកាន់តែច្រើនឡើងដើម្បីគាំទ្រកម្មវិធីដែលគ្មានប្រសិទ្ធភាព យើងត្រូវតែបង្កើតឱ្យមានតម្លាភាពកាន់តែខ្លាំង និងវឌ្ឍនភាពនៃការកែលម្អកម្មវិធីដែលអាចតាមដានបាន ដើម្បីធានាថាយើងឈប់ផ្តល់មូលនិធិដល់ភាពបរាជ័យ ហើយចាប់ផ្តើមផ្តល់មូលនិធិដល់លទ្ធផលជោគជ័យ។ រដ្ឋាភិបាលត្រូវប្រើប្រាស់ប្រាក់ពន្ធរបស់យើងឱ្យបានឆ្លាតវៃជាងមុន។

(e) កិច្ចខិតខំប្រឹងប្រែងខ្លះក្នុងចំណោមការខិតខំប្រឹងប្រែងទាំងនេះកំពុងដំណើរការរួចហើយ។ ឧទាហរណ៍ រដ្ឋបាល Newsom បានខិតខំប្រឹងប្រែងដើម្បីបង្កើនប្រសិទ្ធផលក្នុងរដ្ឋាភិបាលតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា និងស្វ័យប្រវត្តិកម្មកាន់តែច្រើន ការបង្កើត ការិយាល័យនវានុវត្តន៍ទិន្នន័យ និងការធ្វើទំនើបកម្ម នាយកដ្ឋានយានយន្ត។ នេះគឺស្របទៅនឹងកិច្ចខិតខំប្រឹងប្រែងមុនៗដែលប្រធានាធិបតី Obama បានអនុវត្តនៅកម្រិតសហព័ន្ធក្នុងគោលបំណងកាត់បន្ថយការខ្ជះខ្ជាយនៅក្នុងរដ្ឋាភិបាល និងកាត់បន្ថយកម្មវិធីដែលមិនសូវមានដំណើរការល្អ។

(f) ប៉ុន្តែ ខណៈពេលដែលកិច្ចខិតខំប្រឹងប្រែងដែលមានស្រាប់ទាំងនេះគឺជាការចាប់ផ្តើមដ៏ល្អមួយ គួរតែមានការចាត់វិធានការបន្ថែមទៀតដើម្បីកាត់បន្ថយភាពគ្មានប្រសិទ្ធភាព និងកាត់បន្ថយការខ្ជះខ្ជាយរបស់រដ្ឋាភិបាល។ ឧទាហរណ៍ ការសិក្សានាពេលថ្មីៗនេះបានរកឃើញថា នៅក្នុងកម្មវិធីមួយចំនួន រហូតដល់ 25 សេននៃរាល់មួយដុល្លារ ត្រូវបានបាត់បង់ដោយសារភាពគ្មានប្រសិទ្ធភាព ឬការខ្ជះខ្ជាយ។

(g) យ៉ាងណាក៏ដោយ អង្គនីតិបញ្ញត្តិ និងក្រុមផលប្រយោជន៍ពិសេស បន្តស្នើពន្ធថ្មី និងខ្ពស់ជាងមុន សម្រាប់គម្រោងចិត្តចូលចិត្ត ដោយមិនបានខិតខំប្រឹងក្នុងការធានាថាកម្មវិធីរបស់រដ្ឋាភិបាលកំពុងប្រើប្រាស់ចំណូលដែលមានស្រាប់របស់ខ្លួនឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលតាមដែលអាចធ្វើទៅបាននោះទេ។ ប្រជាជនរដ្ឋ California មានសិទ្ធិទាមទារឱ្យរដ្ឋាភិបាលរដ្ឋ ធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃកម្មវិធីនានា និងកាត់បន្ថយការខ្ជះខ្ជាយមុននឹងស្នើសុំឱ្យយើងបង់ពន្ធកាន់តែខ្ពស់ជាងមុន—ដែលវាគ្រាន់តែធ្វើឱ្យវិបត្តិការចំណាយលើការរស់នៅរបស់យើងកាន់តែធ្ងន់ធ្ងរតែប៉ុណ្ណោះ។

(h) នៅក្នុងឆ្នាំ 1979 អ្នកបោះឆ្នោតនៃរដ្ឋ California បានអនុម័តលើដែនកំណត់ការចំណាយរបស់រដ្ឋ ដើម្បីជួយទប់ស្កាត់ការចំណាយខ្ជះខ្ជាយ និងជំរុញឱ្យរដ្ឋាភិបាលមានប្រសិទ្ធភាពជាងមុន—និងដើម្បីប្រគល់ចំណូលដែលលើសពីដែនកំណត់ ត្រឡប់ទៅកាន់អ្នកបង់ពន្ធវិញ។ ប៉ុន្តែក្នុងរយៈពេលប៉ុន្មានឆ្នាំចាប់តាំងពីពេលនោះមក ក្រុមផលប្រយោជន៍ពិសេស បានអនុម័តពន្ធថ្មីៗម្តងហើយម្តងទៀត ដែលលើកលែងខ្លួនពួកគេពីដែនកំណត់ការចំណាយរបស់រដ្ឋ។ ការណ៍នេះជំរុញឱ្យពន្ធកាន់តែខ្ពស់ឡើង និងធ្វើឱ្យមានលទ្ធភាពតិចជាងមុនដែលចំណូលលើសរបស់រដ្ឋនឹងត្រូវបានសងពន្ធវិញជូនអ្នកបង់ពន្ធ។

(i) ដើម្បីធានាថាការចំណាយរបស់រដ្ឋមិនកើនឡើងហួសពីការគ្រប់គ្រងកាន់តែខ្លាំង មុនពេលលក្ខខណ្ឌតម្រូវថ្មីៗផ្នែកប្រសិទ្ធផល និងតម្លាភាពនៃច្បាប់នេះអាចមានឥទ្ធិពលតាមការគ្រោងទុក យើងត្រូវតែទប់ស្កាត់មិនឱ្យពន្ធថ្មីណាមួយត្រូវបានលើកលែងពីដែនកំណត់ការចំណាយរបស់រដ្ឋឡើយ។ ការការពារដែនកំណត់ការចំណាយរបស់រដ្ឋដែលត្រូវបានអនុម័តដោយអ្នកបោះឆ្នោតនេះ គឺមានសារៈសំខាន់ណាស់ក្នុងការជំរុញឱ្យរដ្ឋាភិបាលរដ្ឋក្លាយជាអ្នកចាត់ចែងប្រាក់ពន្ធរបស់ប្រជាជនរដ្ឋ California ឱ្យបានកាន់តែប្រសើរ ស្របតាមគោលបំណងនៃច្បាប់នេះ។ រដ្ឋាភិបាល ទំនងជានឹងប្រើប្រាស់ប្រាក់របស់អ្នកបង់ពន្ធប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលកាន់តែខ្ពស់ នៅពេលដែលរដ្ឋាភិបាលត្រូវប្រតិបត្តិការក្នុងកម្រិតធនធានហិរញ្ញវត្ថុដែលខ្លួនមាន ក្រោមដែនកំណត់ការចំណាយរបស់រដ្ឋ។

ផ្នែកទី 3. សេចក្តីថ្លែងការណ៍អំពីគោលបំណង។

ក្នុងការអនុម័តច្បាប់នេះ គោលបំណង និងចេតនារបស់ប្រជាជននៃរដ្ឋ California គឺតម្រូវឱ្យសវនករដ្ឋ California ធ្វើសវនកម្មជាមុន និងជាបន្តបន្ទាប់លើកម្មវិធីរបស់រដ្ឋទាំងអស់ ដែលមានគោលដៅទទួលបានចំណូលពីពន្ធពិសេសថ្មី ឬពន្ធពិសេសដែលត្រូវបានដំឡើង។ សវនកម្មត្រូវកំណត់អត្តសញ្ញាណផ្នែកដែលអាចមានការសន្សំថវិកា និងការកែលម្អ ហើយលទ្ធផលនៃសវនកម្មត្រូវផ្សព្វផ្សាយជាសាធារណៈ ដើម្បីធានាថា ថវិកាបន្ថែម គឺពិតជាចាំបាច់ កម្មវិធីសាធារណៈកំពុងផ្តល់លទ្ធផល និងប្រាក់របស់អ្នកបង់ពន្ធមិនត្រូវបានបាត់បង់ដោយសារភាពគ្មានប្រសិទ្ធភាព ការខ្ជះខ្ជាយ ឬការប្រើប្រាស់ខុសគោលដៅ ព្រមទាំងហាមឃាត់ការលើកលែងពីដែនកំណត់ការចំណាយរបស់រដ្ឋ ដែលជាកត្តាបង្ខំឱ្យរដ្ឋាភិបាលរដ្ឋអនុវត្តការងារប្រកបដោយប្រសិទ្ធផល និងមានវិន័យ។

ផ្នែកទី 4. មាត្រា XXIV ត្រូវបានបន្ថែមទៅក្នុងរដ្ឋធម្មនុញ្ញនៃរដ្ឋ California ដោយចែងថា៖

មាត្រា XXIV

ការការពារប្រាក់របស់អ្នកបង់ពន្ធ

ផ្នែកទី 1. សវនកម្មមុនការបោះឆ្នោតសម្រាប់គំនិតផ្តួចផ្តើមពន្ធពិសេស

(a) នៅពេលដែលវិញ្ញាបនបត្រសម្រាប់គំនិតផ្តួចផ្តើមពន្ធពិសេសដែលបានស្នើឡើង ត្រូវបានដាក់ជូនរដ្ឋលេខាធិការ ស្របតាមផ្នែករង (a) នៃផ្នែកទី 9034 នៃក្រមការបោះឆ្នោត សវនកររដ្ឋ California ត្រូវចាប់ផ្តើមរៀបចំសវនកម្មហិរញ្ញវត្ថុ និងសវនកម្មលទ្ធផលការងារ មុនការបោះឆ្នោត សម្រាប់កម្មវិធីនីមួយៗដែលនឹងទទួលបានប្រាក់ពីពន្ធពិសេស។

(b) សវនកម្មហិរញ្ញវត្ថុ និងសវនកម្មលទ្ធផលការងារ មុនការបោះឆ្នោតត្រូវពិនិត្យយ៉ាងហោចណាស់នូវបញ្ហាទាំងអស់ដូចខាងក្រោម៖

(1) ថាតើបច្ចុប្បន្ន កម្មវិធីនេះកំពុងទទួលបានធនធាន រួមទាំងបុគ្គលិក ឧបករណ៍ បច្ចេកវិទ្យា និងសូហ្វវែរកុំព្យូទ័រ ព្រមទាំងកន្លែងបរិក្ខារ ក្នុងតម្លៃទាបបំផុតសម្រាប់គុណភាពដែលត្រូវការ ឬយ៉ាងណា។

(2) ថាតើកម្មវិធីនេះកំពុងបង្កើនលទ្ធផលដែលទទួលបានជាអតិបរមាសម្រាប់រាល់ប្រាក់មួយដុល្លារដែលបានចំណាយឬអត់។

(3) កម្រិតដែលកម្មវិធីនេះកំពុងសម្រេចបានជាក់ស្តែងនូវគោលដៅ និងលទ្ធផលដែលបានកំណត់ទុករបស់ខ្លួន។

(4) ទំហំនៃការក្លែងបន្លំ ការខ្ជះខ្ជាយ និងការរំលោភបំពាន ទាំងជាក់ស្តែង និងដែលអាចកើតមាន នៅក្នុងកម្មវិធី និងភាពគ្រប់គ្រាន់នៃប្រព័ន្ធដែលមានស្រាប់ ដែលមានគោលបំណងទប់ស្កាត់ការក្លែងបន្លំ ការខ្ជះខ្ជាយ និងការរំលោភបំពាន។

(5) ការវាយតម្លៃថាតើកម្មវិធីនេះកំពុងអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ផ្នែកក្នុងដែលពាក់ព័ន្ធដែរឬទេ។

(6) ការវាយតម្លៃថាតើកម្មវិធីនេះបានកំណត់អត្តសញ្ញាណកត្តាគំរាមកំហែងធំបំផុតរបស់ខ្លួន និងមានផែនការកាត់បន្ថយផលប៉ះពាល់ពីកត្តាគំរាមកំហែងទាំងនោះដែរឬអត់។

(7) កម្រិតដែលទិន្នន័យដែលត្រូវបានប្រើប្រាស់ ឬពឹងផ្អែកដោយកម្មវិធីដើម្បីធ្វើការសម្រេចចិត្ត មានភាពត្រឹមត្រូវ និងអាចជឿទុកចិត្តបាន។

(8) ថាតើកម្មវិធីនេះមានខ្សែសង្វាក់គណនេយ្យភាព និងការត្រួតពិនិត្យគ្រប់គ្រាន់ឬអត់។

(9) ថាតើការចំណាយរបស់កម្មវិធីនេះប្រៀបធៀបទៅនឹងកម្មវិធីស្រដៀងគ្នាណាមួយនៅក្នុងវិស័យក្រៅរដ្ឋាភិបាល មានលក្ខណៈយ៉ាងដូចម្តេច។

(10) អនុសាសន៍អំពីរបៀបដែលកម្មវិធីនេះអាចសម្រេចបាននូវការសន្សំសំចៃចរិកា ដែលយ៉ាងហោចណាស់ 10 ភាគរយជារៀងរាល់ឆ្នាំ។

(c) ក្នុងការរៀបចំសវនកម្មហិរញ្ញវត្ថុ និងសវនកម្មលទ្ធផលការងារ មុនការបោះឆ្នោតដែលតម្រូវដោយផ្នែកនេះ សវនកររដ្ឋ California ត្រូវអញ្ជើញឱ្យមានការផ្តល់ធាតុចូលពីការិយាល័យវិភាគនីតិបញ្ញត្តិ (LAO) ហើយអាចពឹងផ្អែកលើព័ត៌មានដែលមាននៅក្នុងរបាយការណ៍ ការវិភាគ និងអនុសាសន៍របស់ការិយាល័យនេះ។

(d) សវនកររដ្ឋ California ត្រូវបញ្ចូលសេចក្តីសង្ខេបប្រតិបត្តិនៅក្នុងសវនកម្មហិរញ្ញវត្ថុ និងសវនកម្មលទ្ធផលការងារ មុនការបោះឆ្នោត ដែលសង្ខេបរាល់សេចក្តីរកឃើញ និងអនុសាសន៍ទាំងអស់ពាក់ព័ន្ធនឹងបញ្ហាដែលបានពណ៌នានៅក្នុងផ្នែករង (b)។

(e) (1) ច្បាប់ចម្លងនៃសវនកម្មហិរញ្ញវត្ថុ និងសវនកម្មលទ្ធផលការងារ មុនការបោះឆ្នោត ត្រូវប្រគល់ជូនអភិបាលរដ្ឋ អង្គនីតិបញ្ញត្តិ និងរដ្ឋលេខាធិការ ហើយត្រូវបង្ហោះនៅលើគេហទំព័ររបស់សវនកររដ្ឋ California និងដាក់ឱ្យសាធារណជនអាចចូលមើលបាន។

(2) ប្រសិនបើគំនិតផ្តួចផ្តើមពន្ធពិសេស មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីដាក់បញ្ចូលក្នុងការបោះឆ្នោត ដូចដែលបានចែងក្នុងមាត្រា II សេចក្តីសង្ខេបប្រតិបត្តិពីសវនកម្មហិរញ្ញវត្ថុ និងសវនកម្មលទ្ធផលការងារ មុនការបោះឆ្នោតត្រូវបោះពុម្ពនៅក្នុងមគ្គុទ្ទេសក៍ព័ត៌មានសម្រាប់អ្នកបោះឆ្នោតរបស់រដ្ឋភ្លាមៗបន្ទាប់ពីការវិភាគដោយមិនលំអៀងដែលរៀបចំដោយអ្នកវិភាគនីតិបញ្ញត្តិ។ សវនកររដ្ឋ California ត្រូវបញ្ចប់សវនកម្មហិរញ្ញវត្ថុ និងសវនកម្មលទ្ធផលការងារ មុនការបោះឆ្នោត រួមទាំងសេចក្តីសង្ខេបប្រតិបត្តិឱ្យបានទាន់ពេលវេលាគ្រប់គ្រាន់ ដើម្បីបំពេញតាមកាលកំណត់សម្រាប់ការបង្ហាញជាសាធារណៈនៃមគ្គុទ្ទេសក៍ព័ត៌មានសម្រាប់អ្នកបោះឆ្នោតរបស់រដ្ឋ។

(f) ប្រសិនបើគំនិតផ្តួចផ្តើមពន្ធពិសេស ត្រូវបានអនុម័តដោយអ្នកបោះឆ្នោត សវនកររដ្ឋ California ត្រូវទទួលបានការទូទាត់សងវិញពីចំណូលដែលបង្កើតបានពីគំនិតផ្តួចផ្តើមពន្ធពិសេស សម្រាប់ចំណាយសមហេតុផលដែលបានកើតឡើងក្នុងការរៀបចំសវនកម្មហិរញ្ញវត្ថុ និងសវនកម្មលទ្ធផលការងារ មុនការបោះឆ្នោត ដោយចំនួនទឹកប្រាក់ចំណាយត្រូវកំណត់ដោយអ្នកគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋ។

ផ្នែកទី 2. សវនកម្មជាបន្តបន្ទាប់សម្រាប់ពន្ធពិសេសថ្មី ឬពន្ធពិសេសដែលត្រូវបានដំឡើងទាំងអស់

(a) (1) សម្រាប់ពន្ធពិសេសទាំងអស់ដែលត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិ ឬតាមរយៈវិធានការផ្តួចផ្តើមទូទាំងរដ្ឋ នៅ ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2026 សវនកររដ្ឋ California ត្រូវធ្វើសវនកម្មហិរញ្ញវត្ថុ និងសវនកម្មលទ្ធផលការងារជាបន្តបន្ទាប់ លើកម្មវិធីនីមួយៗដែលទទួលបានប្រាក់ពីពន្ធពិសេស។

(2) ចាប់ពីកាលបរិច្ឆេទដែលពន្ធពិសេសចូលជាធរមាន ត្រូវបញ្ចប់សវនកម្មហិរញ្ញវត្ថុ និងសវនកម្មលើលទ្ធផលការងារជាបន្តបន្ទាប់រៀងរាល់បួនឆ្នាំម្តង។

(b) សវនកម្មហិរញ្ញវត្ថុ និងសវនកម្មលទ្ធផលការងារជាបន្តបន្ទាប់ ដែលតម្រូវដោយផ្នែកនេះ ត្រូវពិនិត្យលើបញ្ហាដូចខាងក្រោម៖

(1) បញ្ហាទាំងអស់ដែលបានពណ៌នានៅក្នុងផ្នែករង (b) នៃផ្នែកទី 1 នៃមាត្រានេះ។

(2) អនុសាសន៍អំពីរបៀបដែលកម្មវិធីអាចធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព និងកាត់បន្ថយចំណាយ ឬកាត់បន្ថយបន្ទុកដែលកម្មវិធីដាក់លើអ្នកបង់ពន្ធ និងប្រាក់ចំណូលរបស់រដ្ឋ។

(c) (1) ក្នុងការរៀបចំសវនកម្មហិរញ្ញវត្ថុ និងសវនកម្មលទ្ធផលការងារជាបន្តបន្ទាប់ដែលតម្រូវដោយផ្នែកនេះ សវនកររដ្ឋ California ត្រូវអញ្ជើញឱ្យមានការផ្តល់ធាតុចូលពីការិយាល័យវិភាគនីតិបញ្ញត្តិ (LAO) ហើយអាចពឹងផ្អែកលើព័ត៌មានដែលមាននៅក្នុងរបាយការណ៍ ការវិភាគ និងអនុសាសន៍របស់ការិយាល័យនេះ។

(2) សវនកររដ្ឋ California ក៏ត្រូវអញ្ជើញសាធារណជនឱ្យផ្តល់ធាតុចូលផងដែរ ដើម្បីជាមូលដ្ឋានសម្រាប់ស្តង់ដារដែលខ្លួនប្រើប្រាស់ក្នុងការវាស់វែងប្រសិទ្ធភាពនៃកម្មវិធីនានា និងសម្រាប់ការសម្រេចចិត្តលើវិធីប្រើប្រាស់ប្រាក់ពន្ធឱ្យកាន់តែមានប្រសិទ្ធភាព។

(d) សវនកររដ្ឋ California ត្រូវទទួលបានការទូទាត់សងវិញពីចំណូលដែលបង្កើតបានពីពន្ធពិសេស សម្រាប់ចំណាយសមហេតុផលដែលបានកើតឡើងក្នុងការរៀបចំសវនកម្មហិរញ្ញវត្ថុ និងសវនកម្មលទ្ធផលការងារជាបន្តបន្ទាប់ ដោយចំនួនទឹកប្រាក់ចំណាយត្រូវកំណត់ដោយអ្នកគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋ។

ផ្នែកទី 3. ការហាមឃាត់ការលើកលែងពីដែនកំណត់ការចំណាយរបស់រដ្ឋ

(a) គ្មានពន្ធរបស់រដ្ឋណាមួយដែលត្រូវបានអនុម័ត ឬចូលជាធរមាននៅ ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2026 ត្រូវបានលើកលែង ឬដកចេញពីដែនកំណត់ការចំណាយរបស់រដ្ឋាភិបាលឡើយ។

(b) រដ្ឋ California មិនត្រូវដាក់ពន្ធ ប្រមូលពន្ធ ឬអនុវត្តការប្រមូលពន្ធរបស់រដ្ឋណាមួយដែលត្រូវបានអនុម័ត ឬចូលជាធរមាននៅឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2026 ទេ ប្រសិនបើពន្ធរបស់រដ្ឋនោះត្រូវបានលើកលែង ឬដកចេញពីដែនកំណត់ការចំណាយរបស់រដ្ឋាភិបាល។

ផ្នែកទី 4. សម្រាប់គោលបំណងនៃមាត្រានេះ៖

(a) "សវនកររដ្ឋ California" មានន័យថាសវនកររដ្ឋ California ដូចដែលបានពណ៌នានៅក្នុងជំពូក 6.5 (ចាប់ផ្តើមជាមួយផ្នែកទី 8543) នៃផ្នែកទី 1 នៃចំណងជើងទី 2 នៃក្រមរដ្ឋាភិបាល។

(b) "លើកលែង ឬដកចេញពីដែនកំណត់ការចំណាយរបស់រដ្ឋាភិបាល" មានន័យថា មួយក្នុងចំណោមខាងក្រោម៖

(1) ចំណូលពីពន្ធរបស់រដ្ឋ ត្រូវបានដាក់បញ្ចូលទាំងស្រុង ឬមួយផ្នែក ទៅក្នុងមូលនិធិ ឬគណនីជាក់លាក់មួយ ដែលនៅក្រៅមូលនិធិទូទៅ ហើយថវិកាអនុម័តពីមូលនិធិ ឬគណនីជាក់លាក់នោះ មិនត្រូវបានរាប់បញ្ចូលក្នុងថវិកាអនុម័តដែលស្ថិតក្រោមដែនកំណត់ នៃអង្គភាពនីមួយៗនៃរដ្ឋាភិបាល និងរដ្ឋ California ក្រោមមាត្រា XIII B ឡើយ។

(2) ដែនកំណត់ថវិកាអនុម័តសម្រាប់រដ្ឋ California ត្រូវបានបង្កើនដោយលក្ខន្តិកៈស្របតាមផ្នែកទី 4 នៃមាត្រា XIII B។

(c) "ដែនកំណត់ការចំណាយរបស់រដ្ឋាភិបាល" មានន័យថា មាត្រា XIII B។

41

(d) "ពន្ធពិសេស" មានន័យថាពន្ធដែលអាចប្រើបានតែដើម្បីផ្តល់មូលនិធិដល់គោលបំណងជាក់លាក់ មិនមែនគោលបំណងគ្មានដែនកំណត់នោះទេ។

(e) "គំនិតផ្តួចផ្តើមពន្ធពិសេស" មានន័យថាវិធានការផ្តួចផ្តើម ដែលបានស្នើឡើងស្របតាមផ្នែកទី 8 នៃមាត្រា II ឬផ្នែកទី 3 នៃមាត្រា XVIII ហើយមានចែងអំពីពន្ធពិសេស។

ផ្នែកទី 5. មាត្រានេះអនុវត្តចំពោះសំណើប្រជាមតិទូទាំងរដ្ឋទាំងអស់ដែលត្រូវបានដាក់ជូនអ្នកបោះឆ្នោត នៅ ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2026 រួមទាំងវិធានការដែលមាននៅលើសន្លឹកឆ្នោតក្នុងការបោះឆ្នោតតែមួយ ដែលវិធានការបន្ថែមមាត្រានេះត្រូវបានអ្នកបោះឆ្នោតអនុម័ត។

ផ្នែកទី 5. វិធានការដែលមានទំនាស់។

(a) (1) ក្នុងករណីដែលសំណើប្រជាមតិនេះមាននៅលើសន្លឹកឆ្នោតនៃការបោះឆ្នោតទូទាំងរដ្ឋតែមួយជាមួយសំណើប្រជាមតិមួយផ្សេងទៀតដែល (A) ដាក់វិធានសវនកម្មខុសគ្នាលើពន្ធពិសេស ឬ (B) មានពន្ធរបស់រដ្ឋដែលត្រូវបានលើកលែង ឬដកចេញពីដែនកំណត់ថវិកាអនុម័ត នោះសំណើប្រជាមតិផ្សេងទៀតនោះត្រូវចាត់ទុកថាមានទំនាស់នឹងវិធានការនេះ។ ក្នុងករណីដែលសំណើប្រជាមតិនេះទទួលបានសំឡេងគាំទ្រច្រើនជាង បទប្បញ្ញត្តិនៃវិធានការនេះត្រូវមានអាទិភាពទាំងស្រុង ហើយបទប្បញ្ញត្តិទាំងអស់នៃវិធានការផ្សេងទៀតត្រូវទុកជាមោឃៈ និងគ្មានសុពលភាព។

(2) សម្រាប់គោលបំណងនៃផ្នែកនេះ "ពន្ធពិសេស" ត្រូវមានអត្ថន័យដូចគ្នាដូចដែលបានកំណត់នៅក្នុងផ្នែកទី 4 នៃច្បាប់នេះ។

(b) ប្រសិនបើសំណើប្រជាមតិនេះត្រូវបានអ្នកបោះឆ្នោតអនុម័ត ប៉ុន្តែត្រូវបានជំនួសទាំងស្រុង ឬមួយផ្នែកដោយសំណើប្រជាមតិដែលមានទំនាស់ផ្សេងទៀតណាមួយដែលអ្នកបោះឆ្នោតអនុម័តក្នុងការបោះឆ្នោតតែមួយ ហើយវិធានការដែលមានទំនាស់នោះត្រូវបានសម្រេចថាគ្មានសុពលភាពនៅពេលក្រោយ នោះវិធានការនេះត្រូវមានប្រសិទ្ធភាពដោយស្វ័យប្រវត្តិ និងត្រូវបានផ្តល់ប្រសិទ្ធភាពពេញលេញ។

ផ្នែកទី 6. លក្ខណៈអាចបំបែកបាន។

បទប្បញ្ញត្តិនៃច្បាប់នេះអាចបំបែកបាន។ ប្រសិនបើផ្នែកណាមួយ ផ្នែកទីណាមួយ ផ្នែករងណាមួយ កថាខណ្ឌណាមួយ ឃ្លាណាមួយ ឃ្លារងណាមួយ ប្រយោគណាមួយ វគ្គណាមួយ ពាក្យណាមួយ ឬការអនុវត្តណាមួយនៃច្បាប់នេះ ត្រូវបានសម្រេចថាគ្មានសុពលភាពដោយសារហេតុផលណាមួយ ដោយសេចក្តីសម្រេចរបស់តុលាការណាមួយដែលមានយុត្តាធិការ នោះសេចក្តីសម្រេចនោះមិនត្រូវប៉ះពាល់ដល់សុពលភាពនៃផ្នែកដែលនៅសល់នៃច្បាប់នេះឡើយ។ ប្រជាជននៃរដ្ឋ California សូមប្រកាសថា ពួកគេនឹងបានអនុម័តច្បាប់នេះ និងផ្នែកនីមួយៗ ផ្នែកទីនីមួយៗ ផ្នែករងនីមួយៗ កថាខណ្ឌនីមួយៗ ឃ្លានីមួយៗ ឃ្លារងនីមួយៗ ប្រយោគនីមួយៗ វគ្គនីមួយៗ ពាក្យនីមួយៗ និងការអនុវត្តនីមួយៗ ដែលមិនត្រូវបានប្រកាសថាគ្មានសុពលភាព ឬមិនស្របតាមរដ្ឋធម្មនុញ្ញ ដោយមិនគិតថាតើផ្នែកណាមួយនៃច្បាប់នេះ ឬការអនុវត្តរបស់វានឹងត្រូវបានប្រកាសថាគ្មានសុពលភាពនៅពេលក្រោយឬយ៉ាងណា។

ផ្នែកទី 7. កាលបរិច្ឆេទចូលជាធរមាន។

ច្បាប់នេះត្រូវចូលជាធរមាននៅកាលបរិច្ឆេទដែលអាចធ្វើទៅបានឆាប់បំផុតស្របតាមផ្នែកទី 10 នៃមាត្រា II នៃរដ្ឋធម្មនុញ្ញនៃរដ្ឋ California។ ច្បាប់នេះត្រូវចាប់ផ្តើមអនុវត្តនៅថ្ងៃតែមួយដែលវាចូលជាធរមាន។

ផ្នែកទី 8. ការបកស្រាយក្នុងន័យទូលំទូលាយ។

ច្បាប់នេះត្រូវបកស្រាយក្នុងន័យទូលំទូលាយ ដើម្បីឱ្យសម្រេចបាននូវចេតនា និងគោលបំណងរបស់វា។

ផ្នែកទី 9. ការការពារផ្នែកច្បាប់។

គោលបំណងនៃផ្នែកនេះគឺដើម្បីធានាថាសិទ្ធិដ៏មានតម្លៃរបស់ប្រជាជនក្នុងការផ្តួចផ្តើមសំណើប្រជាមតិ មិនអាចត្រូវបានលុបចោលដោយមិនត្រឹមត្រូវដោយអ្នកនយោបាយរដ្ឋដែលបដិសេធមិនការពារឆន្ទៈរបស់អ្នកបោះឆ្នោតឡើយ។ ដូច្នេះ ប្រសិនបើច្បាប់នេះត្រូវបានអ្នកបោះឆ្នោតនៃរដ្ឋ California អនុម័ត ហើយក្រោយមកត្រូវបានដាក់ពាក្យបណ្តឹងផ្លូវច្បាប់ដែលព្យាយាមកំណត់វិសាលភាព ឬការអនុវត្តច្បាប់នេះតាមវិធីណាមួយ ឬចោទថាច្បាប់នេះបំពានច្បាប់រដ្ឋ ឬសហព័ន្ធណាមួយទាំងស្រុង ឬមួយផ្នែក ហើយទាំងអភិបាលរដ្ឋ និងអគ្គរដ្ឋអាជ្ញាបដិសេធមិនការពារច្បាប់នេះឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន ក្នុងនាមរដ្ឋ California នោះត្រូវចាត់វិធានការដូចខាងក្រោម៖

(a) ទោះបីមានបទប្បញ្ញត្តិណាមួយផ្ទុយពីនេះដែលមានចែងក្នុងជំពូកទី 6 (ចាប់ផ្តើមជាមួយផ្នែកទី 12500) នៃភាគទី 2 នៃផ្នែកទី 3 នៃចំណងជើងទី 2 នៃក្រមរដ្ឋាភិបាល ឬច្បាប់ផ្សេងទៀតក៏ដោយ អគ្គរដ្ឋអាជ្ញាត្រូវតែងតាំងទីប្រឹក្សាច្បាប់ឯករាជ្យ ដើម្បីការពារច្បាប់នេះដោយស្មោះត្រង់ និងយ៉ាងម៉ឺងម៉ាត់ ឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន ក្នុងនាមរដ្ឋ California។

(b) មុននឹងតែងតាំង ឬក្រោយមកជំនួសទីប្រឹក្សាច្បាប់ឯករាជ្យ អគ្គរដ្ឋអាជ្ញាត្រូវអនុវត្តការប្រុងប្រយ័ត្នត្រឹមត្រូវក្នុងការកំណត់គុណវុឌ្ឍិរបស់ទីប្រឹក្សាច្បាប់ឯករាជ្យ ហើយត្រូវទទួលការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីទីប្រឹក្សាច្បាប់ឯករាជ្យថា ទីប្រឹក្សាច្បាប់ឯករាជ្យនឹងការពារច្បាប់នេះដោយស្មោះត្រង់ និងយ៉ាងម៉ឺងម៉ាត់ ឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន។ ការបញ្ជាក់ជាលាយលក្ខណ៍អក្សរត្រូវដាក់ឱ្យសាធារណជនអាចទទួលបានភ្លាមៗតាមការស្នើសុំ។

(c) ដើម្បីគាំទ្រដល់ការការពារច្បាប់នេះ ក្នុងករណីដែលអភិបាលរដ្ឋ និងអគ្គរដ្ឋអាជ្ញាខកខានមិនការពារ បើទោះបីជាមានឆន្ទៈរបស់អ្នកបោះឆ្នោតក៏ដោយ ការអនុម័តថវិកាបន្តត្រូវបានធ្វើឡើងតាមនេះពីមូលនិធិទូទៅទៅឱ្យអ្នកគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋ ដោយមិនគិតពីឆ្នាំសារពើពន្ធ ក្នុងចំនួនទឹកប្រាក់ចាំបាច់ដើម្បីរ៉ាប់រងថ្លៃចំណាយនៃការជួលទីប្រឹក្សាច្បាប់ឯករាជ្យ ដើម្បីការពារច្បាប់នេះដោយស្មោះត្រង់ និងយ៉ាងម៉ឺងម៉ាត់ ក្នុងនាមរដ្ឋ California ឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន។

សំណើ 42

វិធានការផ្តួចផ្តើមនេះត្រូវបានដាក់ជូនប្រជាជនដោយអនុលោមតាមបទប្បញ្ញត្តិនៃផ្នែកទី 8 មាត្រា II នៃរដ្ឋធម្មនុញ្ញនៃរដ្ឋ California។

វិធានការផ្តួចផ្តើមនេះបន្ថែមផ្នែកមួយចំនួនទៅក្នុងរដ្ឋធម្មនុញ្ញនៃរដ្ឋ California។ ដូច្នេះ បទប្បញ្ញត្តិថ្មីដែលស្នើឱ្យបន្ថែមត្រូវបានបោះពុម្ពជា *អក្សរទ្រេត* ដើម្បីបញ្ជាក់ថាបទប្បញ្ញត្តិទាំងនោះជាបទប្បញ្ញត្តិថ្មី។

ច្បាប់ដែលបានស្នើ

ផ្នែកទី 1. ចំណងជើង.

ច្បាប់នេះត្រូវមានឈ្មោះ និងអាចហៅថា ច្បាប់ស្តីពីការការពារសោធននិវត្តន៍ និងប្រាក់សន្សំផ្ទាល់ខ្លួន ឆ្នាំ 2026។

ផ្នែកទី 2. សេចក្តីរកឃើញ និងសេចក្តីប្រកាស។

(a) គ្រួសារនានានៅរដ្ឋ California កំពុងចំណាយកាន់តែច្រើនលើអ្វីៗគ្រប់យ៉ាង ហើយយើងក៏បានបង់ពន្ធក្នុងចំណោមពន្ធខ្ពស់ជាងគេនៅទូទាំងប្រទេសរួចហើយ។ ការវិភាគថ្មីមួយដោយវិទ្យាស្ថានស្រាវជ្រាវដែលមិនចូលខាងគណបក្សណាមួយ បានសន្និដ្ឋានថា California ជាប់ចំណាត់ថ្នាក់ទី 3 អាក្រក់បំផុតនៅទូទាំងប្រទេស ក្នុងការដាក់បន្ទុកពន្ធលើប្រជាជនរបស់ខ្លួននៅពេលពិចារណាលើពន្ធលើប្រាក់ចំណូលបុគ្គល ពន្ធលើការលក់ ពន្ធលើអចលនទ្រព្យ និងទម្រង់ពន្ធផ្សេងៗទៀត។ ក្នុងរឿងនេះ California ស្ថិតនៅពីក្រោយតែ New Jersey និង ស្រុក Columbia ប៉ុណ្ណោះ។ រដ្ឋ California ក៏មានពន្ធលើការលក់របស់រដ្ឋខ្ពស់ជាងគេនៅទូទាំងប្រទេស អត្រាពន្ធលើប្រាក់ចំណូលកម្រិតខ្ពស់បំផុតខ្ពស់ជាងគេ និងពន្ធលើប្រេងសាំងខ្ពស់ជាងគេក្នុងចំណោមសូចនាករផ្សេងៗទៀត។

41

42

(b) ជារៀងរាល់ថ្ងៃ ប្រជាជន California ក៏កំពុងប្រឈមមុខនឹងវិបត្តិលទ្ធភាពចំណាយផងដែរ។ ចំណាយលើលំនៅឋាន អាហារ អគ្គិសនី ការថែទាំសុខភាព ការធានារ៉ាប់រងផ្ទះ និងរថយន្ត ព្រមទាំងតម្រូវការចាំបាច់ជាច្រើនទៀតក្នុងជីវិត នៅតែបន្តកើនឡើង។ ប្រជាជនរដ្ឋ California កំពុងជួបការលំបាកផ្នែកសេដ្ឋកិច្ចក្នុងការចិញ្ចឹមជីវិតប្រចាំថ្ងៃឱ្យបានគ្រប់គ្រាន់។ ការសន្សំប្រាក់សម្រាប់ចូលនិវត្តន៍ ឬទុកសម្រាប់ពេលមានបញ្ហាបន្ទាន់ កាន់តែពិបាកថែមទៀត។ ដោយសារតម្លៃជីវភាពក្នុងរដ្ឋនេះខ្ពស់ខ្លាំង ការវិភាគថ្មីមួយបានបង្ហាញថា ប្រជាជន California ត្រូវការសន្សំប្រាក់រហូតដល់ $2.3 លាន ប្រសិនបើពួកគេចង់ចូលនិវត្តន៍ដោយមានជីវភាពសុខស្រួលរយៈពេល 20 ឆ្នាំ។ ចំនួនទឹកប្រាក់នេះគឺមិនអាចទៅរួចសម្រាប់ប្រជាជន California ជាច្រើន។

(c) ដើម្បីធ្វើឱ្យស្ថានការណ៍កាន់តែធ្ងន់ធ្ងរទៅទៀត អ្នកនយោបាយ និងក្រុមផលប្រយោជន៍ពិសេសចង់ចាប់ផ្តើមយកពន្ធលើទ្រព្យសម្បត្តិសោធននិវត្តន៍ ទ្រព្យសម្បត្តិដែលបុគ្គលម្នាក់ៗជាម្ចាស់ និងទម្រង់ផ្សេងទៀតនៃប្រាក់សន្សំផ្ទាល់ខ្លួន—ទោះបីជា “California សុបិន” កំពុងកាន់តែឆ្ងាយពីលទ្ធភាពសម្រេចបានសម្រាប់មនុស្សជាច្រើនក្នុងចំណោមពួកយើង ហើយប្រជាជន California ជាច្រើនកំពុងជួបការលំបាកក្នុងការសន្សំប្រាក់ឱ្យបានគ្រប់គ្រាន់សម្រាប់ចូលនិវត្តន៍ក៏ដោយ។ នេះគ្រាន់តែជាផ្នែកមួយចំនួននៃអ្វីដែលអាចប្រឈមនឹងហានិភ័យ៖

(1) គ្រូបង្រៀន មន្ត្រីប៉ូលិស អ្នកពន្លត់អគ្គិភ័យ និងកម្មករដែលខិតខំបម្រើការងារផ្សេងទៀត ទទួលបានអត្ថប្រយោជន៍សោធននិវត្តន៍ប្រភេទកំណត់អត្ថប្រយោជន៍ជាមុន។ ពួកគេអាចត្រូវបានយកពន្ធលើតម្លៃនាពេលអនាគតនៃអត្ថប្រយោជន៍សោធននិវត្តន៍របស់ពួកគេ ហើយត្រូវបង្ខំឱ្យបង់ប្រាក់ទៅរដ្ឋាភិបាល មុនពេលពួកគេទទួលបានប្រាក់សោធននិវត្តន៍សូម្បីតែមួយសេនក៏ដោយ។

(2) ប្រជាជនរដ្ឋ California ដែលចូលរួមវិភាគទានក្នុងផែនការចូលនិវត្តន៍ 401(k) និងគណនីចូលនិវត្តន៍បុគ្គល (IRA) ហើយវិនិយោគក្នុងភាគហ៊ុន មូលបត្របំណុល មូលនិធិរួម និងការវិនិយោគផ្សេងទៀត អាចត្រូវបានយកពន្ធលើតម្លៃនៃប្រាក់សន្សំសម្រាប់ចូលនិវត្តន៍របស់ពួកគេ។ ការណ៍នេះអាចធ្វើឱ្យកម្មករបាត់បង់ប្រាក់សន្សំមួយផ្នែកដែលពួកគេខិតខំរកបាន ដែលនាំឱ្យពួកគេពន្យារពេលចូលនិវត្តន៍ និងធ្វើឱ្យពួកគេងាយរងផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចកាន់តែខ្លាំងនៅពេលវ័យចំណាស់។

(d) រដ្ឋ California បានដាក់ពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណេញមូលធន ពន្ធលើអចលនទ្រព្យ ពន្ធលើទ្រព្យសម្បត្តិផ្ទាល់ខ្លួន ពន្ធសាជីវកម្ម ពន្ធលើការលក់ និងការប្រើប្រាស់ ពន្ធលើប្រតិបត្តិការអចលនទ្រព្យ និងពន្ធជាច្រើនប្រភេទផ្សេងទៀតលើអ្នករស់នៅរបស់ខ្លួនរួចហើយ។ លើសពីនេះ នៅពេលប្រជាជន California ចាប់ផ្តើមប្រើប្រាស់ទ្រព្យសម្បត្តិសោធននិវត្តន៍របស់ពួកគេ លក់ទ្រព្យសម្បត្តិដែលបុគ្គលម្នាក់ៗជាម្ចាស់ ឬសម្រេចបាននូវការកើនឡើងនៃប្រាក់សន្សំផ្ទាល់ខ្លួនផ្សេងទៀត ពួកគេស្ថិតក្រោមពន្ធរបស់រដ្ឋលើប្រាក់ចំណូល ប្រាក់ចំណេញមូលធន និងទ្រព្យសម្បត្តិរួចទៅហើយ។ ប៉ុន្តែអ្នកនយោបាយ និងក្រុមផលប្រយោជន៍ពិសេស គួរត្រូវបានហាមឃាត់មិនឱ្យយកពន្ធលើការកាន់កាប់ ឬការគ្រប់គ្រងទ្រព្យសម្បត្តិផ្ទាល់ខ្លួនតែប៉ុណ្ណោះ ដូចជាទ្រព្យសម្បត្តិសោធននិវត្តន៍ ទ្រព្យសម្បត្តិដែលបុគ្គលម្នាក់ៗជាម្ចាស់ និងទម្រង់ផ្សេងៗទៀតនៃប្រាក់សន្សំផ្ទាល់ខ្លួន ដែលប្រជាជនរដ្ឋ California ខិតខំសន្សំទុក។

(e) ពន្ធប្រតិសកម្មក៏អាចបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដូចគ្នា ដល់ការរៀបចំផែនការចូលនិវត្តន៍ និងប្រាក់សន្សំផ្ទាល់ខ្លួនរបស់ប្រជាជនរដ្ឋ California។ គោលការណ៍ជាមូលដ្ឋាននៃភាពយុត្តិធម៌នៅក្នុងសង្គមប្រជាធិបតេយ្យ តម្រូវឱ្យបុគ្គល គ្រួសារ និងអាជីវកម្មអាចយល់ដឹង និងពឹងផ្អែកលើច្បាប់ពន្ធដែលគ្រប់គ្រងការរៀបចំផែនការហិរញ្ញវត្ថុរបស់ពួកគេ ដើម្បីឱ្យពួកគេអាចធ្វើការសម្រេចចិត្តដោយបានជូនដំណឹងជាមុនអំពីវិធានដែលត្រូវអនុវត្ត។

(f) សមត្ថភាពរបស់ប្រជាជនរដ្ឋ California ក្នុងការរៀបចំ និងសម្រេចបាននូវគោលដៅហិរញ្ញវត្ថុ និងការចូលនិវត្តន៍របស់ពួកគេ អាស្រ័យលើការទទួលបានជូនដំណឹងជាមុនអំពីកាតព្វកិច្ចពន្ធដែលអនុវត្តចំពោះពួកគេ។ ការផ្លាស់ប្តូរជាប្រតិសកម្មលើច្បាប់ពន្ធ គឺអយុត្តិធម៌ជាមូលដ្ឋាន និងធ្វើឱ្យអន្តរាយដល់ទំនុកចិត្តលើរដ្ឋាភិបាល រំខានដល់ការរៀបចំផែនការចូលនិវត្តន៍ និងហិរញ្ញវត្ថុ ព្រមទាំងរារាំងអ្នករស់នៅ និងអាជីវកម្មនានាមិនឱ្យត្រៀមខ្លួនសម្រាប់អនាគត។

(g) អ្នកនយោបាយនៅ Sacramento និងក្រុមផលប្រយោជន៍ពិសេសបានខ្ជះខ្ជាយប្រាក់ពន្ធរបស់យើងរាប់ពាន់លានដុល្លារទៅលើកម្មវិធីដែលគ្មានប្រសិទ្ធភាព និងមិនបានផល។ ប៉ុន្តែពួកគេនៅតែបន្តត្រឡប់មកស្នើសុំប្រាក់របស់យើងបន្ថែមទៀត ជាមួយនឹងសំណើពន្ធថ្មីៗ។ ពួកគេមិនចាំបាច់យកពន្ធលើទ្រព្យសម្បត្តិសោធននិវត្តន៍របស់យើង ឬយកពន្ធលើយើងជាប្រតិសកម្មដោយផ្អែកលើអំពើ សកម្មភាព ឬស្ថានភាពកាលពីអតីតកាលនោះទេ—ពួកគេចាំបាច់ត្រូវផ្តល់លទ្ធផលឱ្យបានកាន់តែប្រសើរ ជាមួយនឹងអ្វីដែលអ្នកបង់ពន្ធបានផ្តល់ឱ្យពួកគេដើម្បីចំណាយរួចទៅហើយ។

ផ្នែកទី 3. សេចក្តីថ្លែងការណ៍អំពីគោលបំណង។

ក្នុងការអនុម័តច្បាប់នេះ គោលបំណង និងចេតនារបស់ប្រជាជននៃរដ្ឋ California គឺការពារសមត្ថភាពរបស់ប្រជាជន California ក្នុងការសន្សំប្រាក់សម្រាប់អនាគតរបស់ពួកគេ ដោយហាមឃាត់ការដាក់ពន្ធថ្មីលើទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់យើង រួមទាំងការកាន់កាប់ ឬការគ្រប់គ្រងទ្រព្យសម្បត្តិសោធននិវត្តន៍ ទ្រព្យសម្បត្តិដែលបុគ្គលម្នាក់ៗជាម្ចាស់ និងទម្រង់ផ្សេងៗទៀតនៃប្រាក់សន្សំផ្ទាល់ខ្លួន ព្រមទាំងតម្រូវឱ្យពន្ធថ្មីទាំងអស់អនុវត្តតែទៅមុខប៉ុណ្ណោះ។

ផ្នែកទី 4. មាត្រា VIII ត្រូវបានបន្ថែមទៅក្នុងរដ្ឋធម្មនុញ្ញនៃរដ្ឋ California ដោយចែងថា៖

មាត្រា VIII

ផ្នែកទី 1. ការហាមឃាត់ការយកពន្ធលើទ្រព្យសម្បត្តិសោធននិវត្តន៍ ទ្រព្យសម្បត្តិដែលបុគ្គលម្នាក់ៗជាម្ចាស់ និងទម្រង់ផ្សេងៗទៀតនៃប្រាក់សន្សំផ្ទាល់ខ្លួន

(a) គ្មានច្បាប់របស់រដ្ឋណាមួយ និងគ្មានបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញនេះ ដែលត្រូវបានអនុម័តនៅ ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2026 អាចអនុម័ត បង្កើត ដាក់ ឬអនុញ្ញាតឱ្យប្រមូលពន្ធលើការកាន់កាប់ ឬការគ្រប់គ្រងទ្រព្យសម្បត្តិសោធននិវត្តន៍ ទ្រព្យសម្បត្តិដែលបុគ្គលម្នាក់ៗជាម្ចាស់ និងទម្រង់ផ្សេងៗទៀតនៃប្រាក់សន្សំផ្ទាល់ខ្លួន ទោះបីកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលក៏ដោយ។

(b) គ្មានអ្វីនៅក្នុងផ្នែកនេះត្រូវបកប្រែ ឬកំណត់ការដាក់ ឬការប្រមូលពន្ធណាមួយដែលបានចូលជាធរមាន ត្រូវបានដាក់ និងបានប្រមូលជាលើកដំបូងនៅ ឬមុនថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 ឡើយ។

(c) គ្មានអ្វីនៅក្នុងផ្នែកនេះត្រូវបកប្រែ ឬប៉ះពាល់ដល់ការយកពន្ធលើអចលនទ្រព្យ ដូចដែលមានចែងនៅក្នុងបទប្បញ្ញត្តិផ្សេងទៀតនៃរដ្ឋធម្មនុញ្ញនេះឡើយ។

ផ្នែកទី 2. ការហាមឃាត់ពន្ធប្រតិសកម្ម

(a) (1) គ្មានច្បាប់របស់រដ្ឋណាមួយ និងគ្មានបទប្បញ្ញត្តិណាមួយនៃរដ្ឋធម្មនុញ្ញនេះ ដែលត្រូវបានអនុម័តនៅ ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2026 អាចអនុម័ត បង្កើត ដាក់ ឬអនុញ្ញាតឱ្យប្រមូលពន្ធដែលអនុវត្តជាប្រតិសកម្មដើម្បីបង្កើតកាតព្វកិច្ចពន្ធដោយផ្អែកលើអំពើ សកម្មភាព ឬស្ថានភាពណាមួយ ដែលបានកើតឡើង ឬមានស្រាប់មុនកាលបរិច្ឆេទចូលជាធរមាននៃច្បាប់របស់រដ្ឋ ឬបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញនោះ។

(2) ផ្នែករងនេះក៏អនុវត្តចំពោះពន្ធដែលត្រូវបានដាក់លើអ្នកបង់ពន្ធ ដោយផ្អែកលើស្ថានភាពជាអ្នករស់នៅរបស់ពួកគេនៅកាលបរិច្ឆេទមួយមុនកាលបរិច្ឆេទចូលជាធរមាននៃពន្ធនោះផងដែរ។

(b) គ្មានអ្វីនៅក្នុងផ្នែករង (a) ត្រូវបកប្រែ ឬកំណត់ការដាក់ ឬការប្រមូលពន្ធណាមួយដែលបានចូលជាធរមាន ត្រូវបានដាក់ និងបានប្រមូលជាលើកដំបូងនៅ ឬមុនថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 ឡើយ។

42

(c) ផ្នែករង (a) មិនអនុវត្តចំពោះពន្ធដែលត្រូវបានដាក់ដោយលក្ខន្តិកៈដែលអង្គនីតិបញ្ញត្តិអនុម័តនៅ ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2026 ទេ ប្រសិនបើលក្ខខណ្ឌទាំងពីរខាងក្រោមអនុវត្ត៖

(1) ពន្ធនេះមិនអនុវត្តជាប្រតិសកម្មលើសពី 365 ថ្ងៃមុនកាលបរិច្ឆេទដែលលក្ខន្តិកៈនោះចូលជាធរមានឡើយ។

(2) យ៉ាងហោចណាស់មានលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌខាងក្រោម៖

(A) អភិបាលរដ្ឋប្រកាសអាសន្ន ដោយសារអគ្គិភ័យ ទឹកជំនន់ ព្យុះ ភាពចលាចលស៊ីវិល រញ្ជួយដី ការផ្ទុះភ្នំភ្លើង ឬការវាយប្រហារពីសត្រូវបរទេសដែលបានកើតឡើង ឬជិតនឹងកើតឡើង ហើយការប្រើប្រាស់ចំណូលពីពន្ធនោះត្រូវបានកំណត់យ៉ាងច្បាស់ដោយលក្ខន្តិកៈឱ្យប្រើសម្រាប់ឆ្លើយតបនឹងគ្រោះអាសន្ននោះ។

(B) អភិបាលរដ្ឋប្រកាសគ្រោះអាសន្នផ្នែកហិរញ្ញវត្ថុ ស្របតាមផ្នែករង (f) នៃផ្នែកទី 10 នៃមាត្រា IV ហើយការប្រើប្រាស់ប្រាក់ចំណូលពីពន្ធនោះត្រូវបានកំណត់យ៉ាងច្បាស់ដោយលក្ខន្តិកៈឱ្យប្រើសម្រាប់ឆ្លើយតបនឹងគ្រោះអាសន្នផ្នែកហិរញ្ញវត្ថុនោះ។

ផ្នែកទី 3. និយមន័យ

សម្រាប់គោលបំណងនៃមាត្រានេះ និយមន័យខាងក្រោមត្រូវអនុវត្ត៖

(a) "ទ្រព្យសម្បត្តិសោធននិវត្តន៍ ទ្រព្យសម្បត្តិដែលបុគ្គលម្នាក់ៗជាម្ចាស់និងទម្រង់ផ្សេងៗទៀតនៃប្រាក់សន្សំផ្ទាល់ខ្លួន" មានន័យថា សោធននិវត្តន៍គណនីចូលនិវត្តន៍ រួមមាន ប៉ុន្តែមិនកំណត់ត្រឹមតែ គណនី 401(k) គណនី 403(b) និងគណនីចូលនិវត្តន៍បុគ្គលផ្សេងទៀតទាំងអស់ មូលនិធិរួម និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងអស់ ទោះជារូបី ឬអរូបីក៏ដោយ រួមមាន ប៉ុន្តែមិនកំណត់ត្រឹមតែ ទ្រព្យសម្បត្តិហិរញ្ញវត្ថុ គណនីវិនិយោគ ផលប្រយោជន៍ក្នុងអាជីវកម្ម ទ្រព្យសម្បត្តិឌីជីថល កម្មសិទ្ធិបញ្ញា ទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងទ្រព្យសម្បត្តិផ្សេងទៀតដែលប្រើប្រាស់ដើម្បីបង្កើត ឬប្រមូលចំណូល ឬប្រាក់សន្សំសម្រាប់ការចូលនិវត្តន៍ ឬការរៀបចំផែនការហិរញ្ញវត្ថុ។

(b) "ពន្ធ" មានន័យថាពន្ធដូចដែលបានកំណត់នៅក្នុងផ្នែករង (b) នៃផ្នែកទី 3 នៃមាត្រា XIII A។

ផ្នែកទី 4. ការអនុវត្តមាត្រា

មាត្រានេះអនុវត្តចំពោះសំណើប្រជាមតិទូទាំងរដ្ឋទាំងអស់ដែលត្រូវបានដាក់ជូនអ្នកបោះឆ្នោត នៅ ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2026 រួមទាំងវិធានការដែលមាននៅលើសន្លឹកឆ្នោតក្នុងការបោះឆ្នោតតែមួយ ដែលវិធានការបន្ថែមមាត្រានេះត្រូវបានអ្នកបោះឆ្នោតអនុម័ត។

ផ្នែកទី 5. វិធានការដែលមានទំនាស់។

(a) (1) ក្នុងករណីដែលសំណើប្រជាមតិនេះមាននៅលើសន្លឹកឆ្នោតនៃការបោះឆ្នោតទូទាំងរដ្ឋតែមួយជាមួយសំណើប្រជាមតិមួយផ្សេងទៀត ដែលនឹងបង្កើតឡើង អនុម័ត បង្កើត ដាក់ ឬអនុញ្ញាតឱ្យប្រមូលពន្ធលើការកាន់កាប់ឬការគ្រប់គ្រងទ្រព្យសម្បត្តិសោធននិវត្តន៍ ទ្រព្យសម្បត្តិដែលបុគ្គលម្នាក់ៗជាម្ចាស់ និងទម្រង់ផ្សេងៗទៀតនៃប្រាក់សន្សំផ្ទាល់ខ្លួន ឬអនុម័តពន្ធដែលនឹងបង្កើតកាតព្វកិច្ចពន្ធដោយផ្អែកលើអំពើ សកម្មភាព ឬស្ថានភាពដែលបានកើតឡើង ឬមានស្រាប់មុនកាលបរិច្ឆេទចូលជាធរមាននៃសំណើប្រជាមតិនោះសំណើប្រជាមតិផ្សេងទៀតត្រូវចាត់ទុកថាមានទំនាស់នឹងវិធានការនេះ។ ក្នុងករណីដែលសំណើប្រជាមតិនេះទទួលបានសំឡេងគាំទ្រច្រើនជាង បទប្បញ្ញត្តិនៃវិធានការនេះត្រូវមានអាទិភាពទាំងស្រុង ហើយបទប្បញ្ញត្តិទាំងអស់នៃវិធានការផ្សេងទៀតត្រូវទុកជាមោឃៈ និងគ្មានសុពលភាព។

(2) សម្រាប់គោលបំណងនៃផ្នែកនេះ ពាក្យ "ទ្រព្យសម្បត្តិសោធននិវត្តន៍ ទ្រព្យសម្បត្តិដែលបុគ្គលម្នាក់ៗជាម្ចាស់ និងទម្រង់ផ្សេងៗទៀតនៃប្រាក់សន្សំផ្ទាល់ខ្លួន" ត្រូវមានអត្ថន័យដូចគ្នានឹងអត្ថន័យដែលបានស្នើឡើងនៅក្នុងផ្នែកទី 3 នៃមាត្រា VIII នៃរដ្ឋធម្មនុញ្ញនៃរដ្ឋ California ដូចដែលបានកំណត់នៅក្នុងផ្នែកទី 4 នៃច្បាប់នេះ។

(b) ប្រសិនបើសំណើប្រជាមតិនេះត្រូវបានអ្នកបោះឆ្នោតអនុម័ត ប៉ុន្តែត្រូវបានជំនួសទាំងស្រុង ឬមួយផ្នែកដោយសំណើប្រជាមតិដែលមានទំនាស់ផ្សេងទៀតណាមួយដែលអ្នកបោះឆ្នោតអនុម័តក្នុងការបោះឆ្នោតតែមួយ ហើយវិធានការដែលមានទំនាស់នោះត្រូវបានសម្រេចថាគ្មានសុពលភាពនៅពេលក្រោយ នោះវិធានការនេះត្រូវមានប្រសិទ្ធភាពដោយស្វ័យប្រវត្តិ និងត្រូវបានផ្តល់ប្រសិទ្ធភាពពេញលេញ។

ផ្នែកទី 6. លក្ខណៈអាចបំបែកបាន។

បទប្បញ្ញត្តិនៃច្បាប់នេះអាចបំបែកបាន។ ប្រសិនបើផ្នែកណាមួយ ផ្នែកទីណាមួយ ផ្នែករងណាមួយ កថាខណ្ឌណាមួយ ឃ្លាណាមួយ ឃ្លារងណាមួយ ប្រយោគណាមួយ វគ្គណាមួយ ពាក្យណាមួយ ឬការអនុវត្តណាមួយនៃច្បាប់នេះ ត្រូវបានសម្រេចថាគ្មានសុពលភាពដោយសារហេតុផលណាមួយ ដោយសេចក្តីសម្រេចរបស់តុលាការណាមួយដែលមានយុត្តាធិការ នោះសេចក្តីសម្រេចនោះមិនត្រូវប៉ះពាល់ដល់សុពលភាពនៃផ្នែកដែលនៅសល់នៃច្បាប់នេះឡើយ។ ប្រជាជននៃរដ្ឋ California សូមប្រកាសថា ពួកគេនឹងបានអនុម័តច្បាប់នេះ និងផ្នែកនីមួយៗ ផ្នែកទីនីមួយៗ ផ្នែករងនីមួយៗ កថាខណ្ឌនីមួយៗ ឃ្លានីមួយៗ ឃ្លារងនីមួយៗ ប្រយោគនីមួយៗ វគ្គនីមួយៗ ពាក្យនីមួយៗ និងការអនុវត្តនីមួយៗ ដែលមិនត្រូវបានប្រកាសថាគ្មានសុពលភាព ឬមិនស្របតាមរដ្ឋធម្មនុញ្ញ ដោយមិនគិតថាតើផ្នែកណាមួយនៃច្បាប់នេះ ឬការអនុវត្តរបស់វានឹងត្រូវបានប្រកាសថាគ្មានសុពលភាពនៅពេលក្រោយឬយ៉ាងណា។

ផ្នែកទី 7. កាលបរិច្ឆេទចូលជាធរមាន។

ច្បាប់នេះត្រូវចូលជាធរមាននៅកាលបរិច្ឆេទដែលអាចធ្វើទៅបានឆាប់បំផុតស្របតាមផ្នែកទី 10 នៃមាត្រា II នៃរដ្ឋធម្មនុញ្ញនៃរដ្ឋ California។ ច្បាប់នេះត្រូវចាប់ផ្តើមអនុវត្តនៅថ្ងៃតែមួយដែលវាចូលជាធរមាន។

ផ្នែកទី 8. ការបកស្រាយក្នុងន័យទូលំទូលាយ។

ច្បាប់នេះត្រូវបកស្រាយក្នុងន័យទូលំទូលាយ ដើម្បីឱ្យសម្រេចបាននូវចេតនា និងគោលបំណងរបស់វា។

ផ្នែកទី 9. ការការពារផ្នែកច្បាប់។

គោលបំណងនៃផ្នែកនេះគឺដើម្បីធានាថាសិទ្ធិដ៏មានតម្លៃរបស់ប្រជាជនក្នុងការផ្តួចផ្តើមសំណើប្រជាមតិ មិនអាចត្រូវបានលុបចោលដោយមិនត្រឹមត្រូវដោយអ្នកនយោបាយរដ្ឋដែលបដិសេធមិនការពារឆន្ទៈរបស់អ្នកបោះឆ្នោតឡើយ។ ដូច្នេះ ប្រសិនបើច្បាប់នេះត្រូវបានអ្នកបោះឆ្នោតនៃរដ្ឋ California អនុម័ត ហើយក្រោយមកត្រូវបានដាក់ពាក្យបណ្តឹងផ្លូវច្បាប់ដែលព្យាយាមកំណត់វិសាលភាព ឬការអនុវត្តច្បាប់នេះតាមវិធីណាមួយ ឬចោទថាច្បាប់នេះបំពានច្បាប់រដ្ឋ ឬសហព័ន្ធណាមួយទាំងស្រុង ឬមួយផ្នែក ហើយទាំងអភិបាលរដ្ឋ និងអគ្គរដ្ឋអាជ្ញាបដិសេធមិនការពារច្បាប់នេះឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន ក្នុងនាមរដ្ឋ California នោះត្រូវចាត់វិធានការដូចខាងក្រោម៖

(a) ទោះបីមានបទប្បញ្ញត្តិណាមួយផ្ទុយពីនេះដែលមានចែងក្នុងជំពូកទី 6 (ចាប់ផ្តើមជាមួយផ្នែកទី 12500) នៃភាគទី 2 នៃផ្នែកទី 3 នៃចំណងជើងទី 2 នៃក្រមរដ្ឋាភិបាល ឬច្បាប់ផ្សេងទៀតក៏ដោយ អគ្គរដ្ឋអាជ្ញាត្រូវតែងតាំងទីប្រឹក្សាច្បាប់ឯករាជ្យ ដើម្បីការពារច្បាប់នេះដោយស្មោះត្រង់ និងយ៉ាងម៉ឺងម៉ាត់ ឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន ក្នុងនាមរដ្ឋ California។

(b) មុននឹងតែងតាំង ឬក្រោយមកជំនួសទីប្រឹក្សាច្បាប់ឯករាជ្យ អគ្គរដ្ឋអាជ្ញាត្រូវអនុវត្តការប្រុងប្រយ័ត្នត្រឹមត្រូវក្នុងការកំណត់គុណវុឌ្ឍិរបស់ទីប្រឹក្សាច្បាប់ឯករាជ្យ ហើយត្រូវទទួលការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីទីប្រឹក្សាច្បាប់ឯករាជ្យថា ទីប្រឹក្សាច្បាប់ឯករាជ្យនឹងការពារច្បាប់នេះដោយស្មោះត្រង់ និងយ៉ាងម៉ឺងម៉ាត់ ឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន។ ការបញ្ជាក់ជាលាយលក្ខណ៍អក្សរត្រូវដាក់ឱ្យសាធារណជនអាចទទួលបានភ្លាមៗតាមការស្នើសុំ។

(c) ដើម្បីគាំទ្រដល់ការការពារច្បាប់នេះ ក្នុងករណីដែលអភិបាលរដ្ឋ និងអគ្គរដ្ឋអាជ្ញាខកខានមិនការពារ បើទោះបីជាមានឆន្ទៈរបស់អ្នកបោះឆ្នោតក៏ដោយ ការអនុម័តថវិកាបន្តត្រូវបានធ្វើឡើងតាមនេះពីមូលនិធិទូទៅទៅឱ្យអ្នកគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋ ដោយមិនគិតពីឆ្នាំសារពើពន្ធ ក្នុងចំនួនទឹកប្រាក់ចាំបាច់ដើម្បីរ៉ាប់រងថ្លៃចំណាយនៃការជួលទីប្រឹក្សាច្បាប់ឯករាជ្យ ដើម្បីការពារច្បាប់នេះដោយស្មោះត្រង់ និងយ៉ាងម៉ឺងម៉ាត់ ក្នុងនាមរដ្ឋ California ឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន។

សំណើ 43

វិសោធនកម្មនេះដែលបានស្នើឡើងដោយវិសោធនកម្មរដ្ឋធម្មនុញ្ញសភាលេខ 22 នៃសម័យប្រជុំធម្មតាឆ្នាំ 2025–2026 (ជំពូកសេចក្តីសម្រេចលេខ 132 លក្ខន្តិកៈឆ្នាំ 2026) ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៃរដ្ឋ California យ៉ាងច្បាស់លាស់ ដោយបន្ថែមផ្នែកមួយទៅក្នុងនោះ។ ដូច្នេះ បទប្បញ្ញត្តិថ្មីដែលស្នើឱ្យបន្ថែមត្រូវបានបោះពុម្ពជាប្រភេទ*អក្សរទ្រេត*ដើម្បីបង្ហាញថាវាជាផ្នែកថ្មី។

វិសោធនកម្មដែលបានស្នើចំពោះមាត្រា XIII A

ថា ផ្នែកទី 4.5 ត្រូវបានបន្ថែមទៅក្នុងមាត្រា XIII A នៃរដ្ឋធម្មនុញ្ញនេះ ដោយចែងថា៖

ផ្នែកទី 4.5. (a) ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2027 តទៅ និងដោយមិនគិតពីមាត្រា II និងមាត្រា XI ទេ រដ្ឋាភិបាលមូលដ្ឋានណាមួយ រួមទាំងអ្នកបោះឆ្នោតរបស់រដ្ឋាភិបាលមូលដ្ឋានដែលកំពុងអនុវត្តអំណាចសំណើប្រជាមតិ មិនអាចដាក់ បន្តរយៈពេល ឬបង្កើនពន្ធពិសេសណាមួយបានទេ លើកលែងតែមានចែងក្នុងផ្នែកទី 4 នៃមាត្រានេះ ផ្នែករង (d) នៃផ្នែកទី 2 នៃមាត្រា XIII C និងកថាខណ្ឌ (2) នៃផ្នែករង (a) នៃផ្នែកទី 3 នៃមាត្រា XIII D លុះត្រាតែ និងរហូតដល់ពន្ធនោះត្រូវបានដាក់ជូនអ្នកបោះឆ្នោត ហើយត្រូវបានអនុម័តដោយសំឡេងពីរភាគបី។

(b) ដោយមិនគិតពីមាត្រា II និងមាត្រា XI ទេ រដ្ឋាភិបាលមូលដ្ឋានណាមួយ រួមទាំងអ្នកបោះឆ្នោតរបស់រដ្ឋាភិបាលមូលដ្ឋានដែលកំពុងអនុវត្តអំណាចសំណើប្រជាមតិ មិនអាចដាក់ពន្ធគិតតាមតម្លៃលើអចលនទ្រព្យបានទេ លើកលែងតែមានចែងក្នុងកថាខណ្ឌ (1) នៃផ្នែករង (a) នៃផ្នែកទី 3 នៃមាត្រា XIII D។

(c) "រដ្ឋាភិបាលមូលដ្ឋាន" និង "ពន្ធពិសេស" ត្រូវមានអត្ថន័យដូចដែលបានចែងក្នុងផ្នែកទី 1 នៃមាត្រា XIII C។

សំណើ 44

វិធានការផ្តួចផ្តើមនេះត្រូវបានដាក់ជូនប្រជាជនដោយអនុលោមតាមបទប្បញ្ញត្តិនៃផ្នែកទី 8 មាត្រា II នៃរដ្ឋធម្មនុញ្ញនៃរដ្ឋ California។

សំណើប្រជាមតិនេះបន្ថែមផ្នែកនានាទៅក្នុងក្រមសាជីវកម្ម ក្រមរដ្ឋាភិបាល និងក្រមសុខភាព និងសុវត្ថិភាព។ ដូច្នេះ បទប្បញ្ញត្តិថ្មីដែលស្នើឱ្យបន្ថែមត្រូវបានបោះពុម្ពជាប្រភេទ*អក្សរទ្រេត*ដើម្បីបង្ហាញថាវាជាផ្នែកថ្មី។

ច្បាប់ដែលបានស្នើ

ផ្នែកទី 1. ចំណងជើង.

វិធានការនេះត្រូវមានឈ្មោះ និងអាចហៅថា "ច្បាប់ស្តីពីគណនេយ្យភាព និងតម្លាភាពនៃហិរញ្ញប្បទានគ្លីនិក។"

ផ្នែកទី 2. សេចក្តីរកឃើញ និងសេចក្តីប្រកាស។

ប្រជាជននៃរដ្ឋ California រកឃើញ និងប្រកាសទាំងអស់ដូចខាងក្រោម៖

(a) មណ្ឌលសុខភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមសហព័ន្ធ (FQHCs) គឺជាប្រភេទមួយនៃគ្លីនិកសហគមន៍ ដែលជាមូលដ្ឋាននៃបណ្តាញការពារសុខភាពសង្គមរបស់រដ្ឋ California ព្រោះបេសកកម្មរបស់ពួកគេគឺផ្តល់សេវាថែទាំសុខភាពបឋម និងការថែទាំបង្ការដល់ប្រជាជនដែលមានចំណូលទាប និងប្រជាជនដែលមិនសូវទទួលបានសេវា។

(b) FQHCs ភាគច្រើននៅក្នុងរដ្ឋ ត្រូវបានដំណើរការដោយអង្គការមិនរកប្រាក់ចំណេញ ដែលត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានការទទួលខុសត្រូវធានាថាគ្លីនិកបំពេញបេសកកម្មរបស់ខ្លួនក្នុងនាមជាអ្នកផ្តល់សេវាថែទាំសុខភាពនៃបណ្តាញការពារសុខភាពសង្គម និងជាសាជីវកម្មមិនរកប្រាក់ចំណេញសម្រាប់ផលប្រយោជន៍សាធារណៈ ដែលស្ថិតក្រោមការលើកលែងពន្ធរបស់រដ្ឋ និងសហព័ន្ធ។

(c) ក្រុមប្រឹក្សាភិបាលគ្លីនិកមានការទទួលខុសត្រូវយ៉ាងសំខាន់ និងមានសិទ្ធិអំណាចយ៉ាងទូលំទូលាយក្នុងការសម្រេចចិត្តទាក់ទងនឹងការរៀបចំរចនាសម្ព័ន្ធរបស់អង្គការ និងការកំណត់ប្រាក់បំណាច់ រួមទាំងប្រាក់បំណាច់របស់នាយកប្រតិបត្តិ និងថ្នាក់ដឹកនាំផ្សេងទៀត។

(d) ទោះបីជាច្បាប់របស់រដ្ឋដែលមានស្រាប់តម្រូវឱ្យក្រុមប្រឹក្សាភិបាលនៃអង្គការមិនរកប្រាក់ចំណេញពិនិត្យ និងអនុម័តប្រាក់បំណាច់របស់នាយកប្រតិបត្តិ និងនាយកហិរញ្ញវត្ថុ ដើម្បីធានាថាប្រាក់បំណាច់នោះយុត្តិធម៌ និងសមរម្យក៏ដោយ ក៏គ្លីនិកជាច្រើនបានចំណាយចំណែកដ៏ច្រើនហួសប្រមាណនៃប្រាក់ចំណូលរបស់ខ្លួនទៅលើប្រាក់បំណាច់ថ្នាក់ដឹកនាំ ដែលនាំឱ្យមានការវិនិយោគមិនគ្រប់គ្រាន់លើសេវាសួលសម្រាប់អ្នកជំងឺ។

(e) ចាប់តាំងពីឆ្នាំ 2018 មក អង្គការមិនរកប្រាក់ចំណេញទាំងអស់ រួមទាំងគ្លីនិកផង ត្រូវបានតម្រូវឱ្យរាយការណ៍ជារៀងរាល់ឆ្នាំទៅ IRS អំពីចំនួនទឹកប្រាក់នៃការចំណាយដែលពាក់ព័ន្ធនឹងបេសកកម្មរបស់ខ្លួន ពោលគឺការចំណាយលើ "កម្មវិធី" ព្រមទាំងការចំណាយលើ "ការគ្រប់គ្រង និងរដ្ឋបាល។" គ្លីនិកជាច្រើននៅក្នុងរដ្ឋ California មានការចំណាយលើការគ្រប់គ្រង និងរដ្ឋបាលខ្ពស់ជាងមធ្យមភាគយ៉ាងខ្លាំង—ពេលខ្លះស្មើនឹង 30 ទៅ 40 ភាគរយនៃប្រាក់ចំណូលសរុប—ខណៈដែលគ្លីនិកមួយចំនួនទៀតចំណាយតិចជាង 10 ភាគរយ។

(f) គ្លីនិកជាច្រើនមានប្រាក់ចំណេញខ្ពស់ ដោយពេលខ្លះរាយការណ៍ថាមានប្រាក់លើសចំណាយប្រចាំឆ្នាំរហូតដល់ 20 ភាគរយនៃប្រាក់ចំណូលសរុប ជំនួសឱ្យការចំណាយមូលនិធិទាំងនោះតាមរបៀបដែលស្របតាមបេសកកម្មសប្បុរសធម៌របស់ខ្លួន។

(g) ការបណ្តុះបណ្តាល ការជ្រើសរើស និងការរក្សាបុគ្គលិកឱ្យបន្តធ្វើការងារគឺជាបញ្ហាសម្រាប់គ្លីនិកនៅក្នុងរដ្ឋ California។ បុគ្គលិកគ្លីនិករាយការណ៍ថា មានការខ្វះបុគ្គលិកជាប្រចាំ បន្ទុកការងារខ្ពស់ និងការផ្លាស់ប្តូរបុគ្គលិកជាញឹកញាប់ ព្រមទាំងរយៈពេលរង់ចាំយូរសម្រាប់អ្នកជំងឺ។

(h) គោលបំណងនៃសំណើប្រជាមតិនេះ គឺបង្កើតស្តង់ដារអប្បបរមាសមរម្យមួយសម្រាប់ការចំណាយដែលផ្តោតលើបេសកកម្ម ជាសមាមាត្រនៃប្រាក់ចំណូលសរុប ដើម្បីធានាថាការផ្តល់សេវាដល់អ្នកជំងឺរបស់គ្លីនិក និងស្ថិរភាពនៃកម្លាំងពលកម្ម ត្រូវបានផ្តល់អាទិភាពជាងការចំណាយលើការគ្រប់គ្រង និងចំណាយទូទៅ។

ផ្នែកទី 3. តម្រូវការរាយការណ៍។

ផ្នែកទី 3.1. ផ្នែកទី 12586.3 ត្រូវបានបន្ថែមទៅក្នុងក្រមរដ្ឋាភិបាលដោយចែងថា៖

12586.3. (a) សម្រាប់គោលបំណងនៃផ្នែកនេះ និយមន័យខាងក្រោមត្រូវអនុវត្ត៖

(1) "គ្លីនិក" មានន័យថាសាជីវកម្មគ្លីនិកណាមួយ ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌ (3) នៃផ្នែករង (b) នៃផ្នែកទី 1200 នៃក្រមសុខភាព និងសុវត្ថិភាព ដែលជាមណ្ឌលសុខភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមសហព័ន្ធ (FQHC) ដូចដែលពាក្យនេះត្រូវបានកំណត់នៅក្នុងផ្នែកទី 1396d នៃចំណងជើងទី 42 នៃ ក្រមសហរដ្ឋអាមេរិក។ សម្រាប់គោលបំណងនៃកថាខណ្ឌនេះ FQHCs រួមបញ្ចូលអង្គការដែលមិនទទួលបានជំនួយ FQHC ប៉ុន្តែត្រូវបានកំណត់ដោយ រដ្ឋបាលធនធានសុខភាព និងសេវាកម្ម សហព័ន្ធថាបំពេញតាមលក្ខខណ្ឌតម្រូវរបស់កម្មវិធី FQHC ដូចដែលបានកំណត់

នៅក្នុងផ្នែកទី 1395x(aa)(4)(B) និង 1396d(l)(2)(B) នៃចំណងជើងទី 42 នៃ ក្រមសហរដ្ឋអាមេរិក ហៅម្យ៉ាងទៀតថា "អង្គការដែលមានលក្ខណៈស្រដៀងនឹងមណ្ឌលសុខភាព FQHC។" "គ្លីនិក" មិនរួមបញ្ចូលកុលសម្ព័ន្ធឥណ្ឌាដែលទទួលស្គាល់ដោយសហព័ន្ធ អង្គការកុលសម្ព័ន្ធ ឬអង្គការឥណ្ឌានៅទីប្រជុំជន ដូចដែលបានកំណត់នៅក្នុងផ្នែកទី 1603 នៃចំណងជើងទី 25 នៃ ក្រមសហរដ្ឋអាមេរិក ឬកន្លែងផ្តល់សេវាអ្នកជំងឺក្រៅណាមួយដែលត្រូវបានបើកដំណើរការ ថែទាំ ឬដំណើរការដោយអង្គភាពបែបនោះឡើយ។

(2) "សមមាត្រចំណាយលើបេសកកម្ម" គឺជាចំនួនទឹកប្រាក់សរុបដែលបានចំណាយលើសកម្មភាពទាំងឡាយណាដែលសម្រេចបាននូវគោលបំណងដែលត្រូវបានលើកលែងពន្ធរបស់គ្លីនិកនីមួយៗ ចែកនឹងចំណូលសរុបរបស់គ្លីនិកនោះ ដូចដែលតួលេខទាំងនោះត្រូវបានបញ្ជាក់នៅក្នុងកថាខណ្ឌ (1) នៃផ្នែករង (b)។ នៅពេលគណនាសមមាត្រចំណាយលើបេសកកម្ម អគ្គរដ្ឋអាជ្ញាត្រូវដកចេញពីទាំងចំនួនទឹកប្រាក់សរុបដែលបានចំណាយលើសកម្មភាព និងចំណូលសរុប នូវចំនួនទឹកប្រាក់ស្មើនឹងប្រាក់ពិន័យណាមួយដែលបានបង់ ការចំណាយនានាដែលធ្វើឡើងដោយផ្អែកលើផែនការដែលបានឯកភាពជាមួយនាយកដ្ឋានសុខភាពសាធារណៈរដ្ឋ ឬសំណងដែលទទួលបានស្របតាមផ្នែកទី 1234.5 នៃក្រមសុខភាព និងសុវត្ថិភាព។

(3) "ភាគីពាក់ព័ន្ធ" មានន័យថាអង្គការពាក់ព័ន្ធ ឬអង្គការដែលស្ថិតក្រោមកម្មសិទ្ធិ ឬការគ្រប់គ្រងរួម ដូចដែលបានកំណត់នៅក្នុងផ្នែកទី 413.17(b) នៃចំណងជើងទី 42 នៃ ក្រមបទប្បញ្ញត្តិសហព័ន្ធ។ ភាគីពាក់ព័ន្ធអាចមានដូចជា អង្គភាពគ្រប់គ្រង ម្ចាស់អចលនទ្រព្យ អង្គភាពដែលផ្តល់បុគ្គលិក ក្រុមហ៊ុនមេ ក្រុមហ៊ុនកាន់កាប់ភាគហ៊ុន ក្រុមហ៊ុនបុត្រសម្ព័ន្ធ ស្ថាប័នជាបងប្អូន និងផ្សេងៗទៀត។

(b) (1) ជារៀងរាល់ឆ្នាំ គ្លីនិកនីមួយៗត្រូវដាក់ឯកសារនៅការិយាល័យចុះបញ្ជីអង្គការសប្បុរសធម៌ និងអ្នករៃអង្គាសប្រាក់ នូវទិន្នន័យឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យអគ្គរដ្ឋអាជ្ញាអាចគណនា "សមមាត្រចំណាយលើបេសកកម្ម" ដូចដែលបានកំណត់នៅទីនេះ។ ទិន្នន័យនេះត្រូវរួមមានសមាសធាតុចំនួនពីរ៖

(A) ចំនួនទឹកប្រាក់សរុបដែលបានចំណាយសម្រាប់គោលបំណងដែលទទួលបានការលើកលែងពន្ធរបស់គ្លីនិក។ ចំនួននេះនឹងផ្អែកលើទិន្នន័យដែលបានរាយការណ៍នៅក្នុងតួលេខ "ការចំណាយសរុបលើសេវាកម្មនៃកម្មវិធី" នៅបន្ទាត់ 4e នៃភាគទី III នៃ ទម្រង់របស់អង្គភាពសេវាពន្ធដារផ្ទៃក្នុង 990 របស់គ្លីនិកនីមួយៗ សម្រាប់ឆ្នាំប្រតិទិន 2024 ឬឆ្នាំពន្ធដែលចាប់ផ្តើមនៅឆ្នាំ 2024 ឬផ្នែកបន្តនៃការរាយការណ៍ពន្ធរបស់គ្លីនិក ប៉ុន្តែត្រូវកែសម្រួលដោយផ្អែកលើសេចក្តីណែនាំដែលចេញដោយអគ្គរដ្ឋអាជ្ញាតាមកថាខណ្ឌ (2)។

(B) ប្រាក់ចំណូលសរុបរបស់អង្គការ។ ចំនួននេះនឹងផ្អែកលើទិន្នន័យដែលបានរាយការណ៍នៅក្នុងតួលេខប្រាក់ចំណូលសរុប ពីបន្ទាត់ 12 នៃភាគទី I នៃ ទម្រង់របស់អង្គភាពសេវាពន្ធដារផ្ទៃក្នុង 990 របស់គ្លីនិកនីមួយៗ សម្រាប់ឆ្នាំប្រតិទិន 2024 ឬឆ្នាំពន្ធដែលចាប់ផ្តើមនៅឆ្នាំ 2024 ឬផ្នែកបន្តនៃការរាយការណ៍ពន្ធរបស់គ្លីនិក ប៉ុន្តែត្រូវកែសម្រួលដោយផ្អែកលើសេចក្តីណែនាំដែលចេញដោយអគ្គរដ្ឋអាជ្ញាតាមកថាខណ្ឌ (2)។

(2) អគ្គរដ្ឋអាជ្ញាមានសិទ្ធិអំណាចចេញសេចក្តីណែនាំដែលមានអានុភាពចងភ្ជាប់ អំពីរបៀបរាយការណ៍តួលេខទាំងពីរនេះ។

(A) ក្នុងចំណោមប្រធានបទផ្សេងទៀត សេចក្តីណែនាំនេះអាចចែងអំពី៖

(i) ស្តង់ដាររាយការណ៍បន្ថែមសម្រាប់ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ដែលដោះស្រាយទៅលើកម្រិតដែលរបៀបដែលទិន្នន័យនោះត្រូវបានរាយការណ៍ទៅ អង្គភាពសេវាពន្ធដារផ្ទៃក្នុង មានលទ្ធភាពបង្កើនដោយសិប្បនិម្មិតនូវចំនួនទឹកប្រាក់សរុបដែលបានចំណាយលើគោលបំណងដែលបានលើកលែងពន្ធរបស់គ្លីនិក រួមទាំងតាមរយៈការអនុញ្ញាតឱ្យប្រតិបត្តិការទៅភាគីពាក់ព័ន្ធត្រូវបានគិតបញ្ចូលជាចំនួនដែលបានចំណាយលើគោលបំណងដែលបានលើកលែងពន្ធរបស់គ្លីនិក ទោះបីជាការចំណាយជាលទ្ធផលរបស់ភាគីពាក់ព័ន្ធនោះនឹងមិនត្រូវបានចាត់ទុកថាជាការចំណាយដែលសន្មតថាលើគោលបំណងដែលបានលើកលែងពន្ធនោះក៏ដោយ ឬកាត់បន្ថយចំណូលសរុបដោយសិប្បនិម្មិត រួមទាំងតាមរយៈការអនុញ្ញាតឱ្យចំណូលត្រូវបានគិតបញ្ចូលទៅភាគីពាក់ព័ន្ធ។

(ii) របៀបដែលប្រាក់ពិន័យដែលបានបង់ក្រោមផ្នែកទី 1234.5 នៃក្រមសុខភាព និងសុវត្ថិភាព ព្រមទាំងសំណង និងការចំណាយនានាដែលធ្វើឡើងអនុលោមតាមផែនការដែលបានឯកភាពជាមួយនាយកដ្ឋានសុខភាពសាធារណៈរដ្ឋក្រោមផ្នែកទី 1234.5 នៃក្រមសុខភាព និងសុវត្ថិភាព ត្រូវរាយការណ៍ ដើម្បីដកពួកវាចេញពីការគណនាសមមាត្រចំណាយលើបេសកកម្ម។

(iii) ស្របតាមកថាខណ្ឌរង (B) លក្ខខណ្ឌតម្រូវបន្ថែមក្នុងការរាយការណ៍សម្រាប់ការចំណាយដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាការចំណាយលើសេវាកម្មនៃកម្មវិធីនៅលើ ទម្រង់របស់អង្គភាពសេវាពន្ធដារផ្ទៃក្នុង 990 ប៉ុន្តែដែលអគ្គរដ្ឋអាជ្ញាកំណត់ថាទោះជាយ៉ាងណានៅតែបានចំណាយលើគោលបំណងដែលបានលើកលែងពន្ធរបស់គ្លីនិក ឬការចំណាយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាការចំណាយលើសេវាកម្មនៃកម្មវិធីនៅលើទម្រង់របស់អង្គភាពសេវាពន្ធដារផ្ទៃក្នុង 990 ប៉ុន្តែដែលអគ្គរដ្ឋអាជ្ញាកំណត់ថាទោះជាយ៉ាងណាមិនបានចំណាយលើគោលបំណងដែលបានលើកលែងពន្ធរបស់គ្លីនិក។

(B) រាល់សេចក្តីណែនាំទាំងអស់ត្រូវរៀបចំឡើងដើម្បីជំរុញគោលដៅនៃច្បាប់ស្តីពីគណនេយ្យភាព និងតម្លាភាពនៃហិរញ្ញប្បទានគ្លីនិក តាមរយៈការបង្កើតស្តង់ដារអប្បបរមាសមហេតុផលមួយសម្រាប់ការចំណាយផ្តោតទៅរកបេសកកម្ម ជាសមមាត្រនៃប្រាក់ចំណូលសរុប ដើម្បីធានាថាការផ្តល់សេវាថែទាំអ្នកជំងឺរបស់គ្លីនិក និងស្ថិរភាពនៃកម្លាំងពលកម្ម ត្រូវបានផ្តល់អាទិភាពខ្ពស់ជាងការចំណាយលើការគ្រប់គ្រង និងចំណាយប្រតិបត្តិការទូទៅ។

(C) អគ្គរដ្ឋអាជ្ញាត្រូវចេញការរកឃើញដែលបញ្ជាក់ពីហេតុផលសម្រាប់ការកំណត់របស់ខ្លួន នៅពេលចេញសេចក្តីណែនាំ។

(D) ដោយមិនគិតពីជំពូកទី 3.5 (ចាប់ផ្តើមជាមួយផ្នែកទី 11340) នៃភាគទី 1 នៃផ្នែកទី 3 នៃចំណងជើងទី 2 នៃក្រមរដ្ឋាភិបាល អគ្គរដ្ឋអាជ្ញាអាចអនុវត្តកថាខណ្ឌនេះតាមរយៈព្រឹត្តិបត្រ សេចក្តីជូនដំណឹង ឬសេចក្តីណែនាំផ្សេងទៀតដែលស្រដៀងគ្នា ដោយមិនចាំបាច់ចាត់វិធានការបទប្បញ្ញត្តិបន្ថែមទៀតឡើយ។ ផ្នែកទី 1229.1 នៃក្រមសុខភាព និងសុវត្ថិភាព មិនត្រូវអនុវត្តចំពោះការបំពាននានាដែលផ្អែកលើស្តង់ដារដែលបានអនុម័តក្រោមកថាខណ្ឌនេះទេ។

(3) គ្មានចំណុចណាមួយនៅក្នុងផ្នែកនេះត្រូវបកស្រាយថាជាការគ្រប់គ្រងទៅលើរបៀបដែលគ្លីនិករាយការណ៍ទិន្នន័យទៅ អង្គភាពសេវាពន្ធដារផ្ទៃក្នុងឡើយ។

(4) អគ្គរដ្ឋអាជ្ញាត្រូវផ្សព្វផ្សាយទិន្នន័យនេះជាសាធារណៈនៅលើគេហទំព័ររបស់ខ្លួន ក្នុងរយៈពេល 90 ថ្ងៃបន្ទាប់ពីទទួលបាន។

(5) គ្លីនិកនីមួយៗត្រូវដាក់ឯកសារទិន្នន័យនេះ យ៉ាងយូរបំផុតនៅពេលដែលពួកគេដាក់របាយការណ៍នៅការិយាល័យចុះបញ្ជីអង្គការសប្បុរសធម៌ និងអ្នករៃអង្គាសប្រាក់ ក្រោមផ្នែកទី 12586។

(c) គ្លីនិកនីមួយៗត្រូវបង់ថ្លៃសេវាចុះបញ្ជីប្រចាំឆ្នាំបន្ថែម ដែលថ្លៃសេវានេះត្រូវប្រើប្រាស់ដើម្បីផ្តល់មូលនិធិដល់សកម្មភាពនានាដែលបានចែងនៅក្នុងផ្នែកនេះ និងផ្នែកទី 1234.5 នៃក្រមសុខភាព និងសុវត្ថិភាព ដោយមិនគិតពីច្បាប់ផ្សេងណាមួយឡើយ។ អគ្គរដ្ឋអាជ្ញាត្រូវអនុម័តតារាងថ្លៃសេវាឱ្យបានគ្រប់គ្រាន់ដើម្បីរ៉ាប់រងការចំណាយសមហេតុផលក្នុងការគ្រប់គ្រងការអនុវត្តបទប្បញ្ញត្តិទាំងនេះ ដោយមានការពិគ្រោះយោបល់ជាមួយនាយកដ្ឋានសុខភាពសាធារណៈរដ្ឋ។ ថ្លៃសេវាត្រូវកែសម្រួលជារៀងរាល់ឆ្នាំ ដើម្បីឱ្យស្របតាមចំណាយជាក់ស្តែងដែលបានកើតឡើង ហើយមិនត្រូវលើសពីចំនួនដែលចាំបាច់ដើម្បីបំពេញចំណាយបទប្បញ្ញត្តិសមហេតុផលនៃការគ្រប់គ្រងបទប្បញ្ញត្តិទាំងនេះឡើយ។

44

(d) អគ្គរដ្ឋអាជ្ញាត្រូវដាក់ទណ្ឌកម្មចំពោះការខកខានមិនបានអនុលោមតាមបទប្បញ្ញត្តិនៃការរាយការណ៍នៃផ្នែកនេះ ក្នុងទម្រង់ជាការពិន័យរដ្ឋបាលចំនួនប្រាំពាន់ដុល្លារ ($5,000) សម្រាប់ការបំពានលើកទីមួយ និងមួយម៉ឺនដុល្លារ ($10,000) សម្រាប់ខែបន្ទាប់នីមួយៗ ដែលគ្លីនិកខកខានមិនបានដាក់របាយការណ៍ប្រចាំឆ្នាំដែលតម្រូវដោយផ្នែកនេះ។ អគ្គរដ្ឋអាជ្ញាអាចធ្វើបច្ចុប្បន្នភាពប្រាក់ពិន័យនេះតាមកាលកំណត់ ដើម្បីគិតគូរអតិផរណា។

(e) យ៉ាងយូរបំផុត 90 ថ្ងៃបន្ទាប់ពីទទួលបានឯកសារដែលគ្លីនិកនីមួយៗបានដាក់ជូន អគ្គរដ្ឋអាជ្ញាត្រូវគណនាសមមាត្រចំណាយលើបេសកកម្មសម្រាប់គ្លីនិកនីមួយៗ បញ្ជូនការគណនានេះទៅកាន់គ្លីនិក និងនាយកដ្ឋានសុខភាពសាធារណៈរដ្ឋ ព្រមទាំងផ្សព្វផ្សាយការគណនារបស់ខ្លួនជាសាធារណៈនៅលើគេហទំព័ររបស់ខ្លួន។

(f) អគ្គរដ្ឋអាជ្ញាអាចធ្វើសវនកម្មលើគ្លីនិកដែលស្ថិតក្រោមផ្នែកនេះតាមរបៀប និងទម្រង់ដែលកំណត់ដោយអគ្គរដ្ឋអាជ្ញា ដើម្បីធានាភាពត្រឹមត្រូវនៃព័ត៌មានដែលបានរាយការណ៍ និងការអនុលោមតាមលក្ខខណ្ឌតម្រូវនៃផ្នែកនេះ។ សវនកម្មទាំងនេះក៏អាចរួមបញ្ចូលផងដែរនូវសវនកម្មណាមួយទៅលើអ្នកម៉ៅការ ឬភាគីពាក់ព័ន្ធនានា។

(g) ផ្នែកទី 9230 នៃក្រមសាជីវកម្ម និងផ្នែកទី 12583 នៃក្រមរដ្ឋាភិបាលមិនត្រូវយកមកអនុវត្តចំពោះផ្នែកនេះឡើយ។

ផ្នែកទី 4. ការពិន័យ។

ផ្នែកទី 4.1. ផ្នែកទី 1234.5 ត្រូវបានបន្ថែមទៅក្រមសុខភាព និងសុវត្ថិភាព ដោយចែងថា៖

1234.5. (a) (1) គណនីពិន័យសមមាត្រចំណាយលើបេសកកម្ម ត្រូវបានបង្កើតឡើងនៅទីនេះ នៅក្នុងមូលនិធិប្រាក់តម្កល់ពិសេស ដែលបានបង្កើតឡើងអនុលោមតាមផ្នែកទី 16370 នៃក្រមរដ្ឋាភិបាល។ គណនីនេះត្រូវផ្ទុកនូវទឹកប្រាក់ទាំងអស់ដែលបានដាក់តម្កល់អនុលោមតាមផ្នែករង (b)។

(2) ប្រាក់ដែលត្រូវបានរក្សាទុកនៅក្នុងមូលនិធិប្រាក់តម្កល់ពិសេស ត្រូវរក្សាទុកជាប្រាក់តម្កល់បណ្តោះអាសន្នដោយភាគីទីបី សម្រាប់រយៈពេល 5 ឆ្នាំ បន្ទាប់ពីនោះប្រាក់ទាំងនេះត្រូវជាកម្មវត្ថុនៃការអនុម័តថវិកាដោយអង្គនីតិបញ្ញត្តិ ទៅលើគំនិតផ្តួចផ្តើមនានាដែលផ្តល់មូលនិធិសម្រាប់ការបណ្តុះបណ្តាល ការជ្រើសរើស និងការរក្សាបុគ្គលិកគ្លីនិកឱ្យនៅបន្តការងារ។

(3) ក្នុងពេលដែលរក្សាទុកជាប្រាក់តម្កល់បណ្តោះអាសន្នដោយភាគីទីបី ប្រាក់ទាំងនេះត្រូវសងត្រលប់វិញទៅកាន់គ្លីនិកនានា ដូចដែលបានកំណត់ក្នុងកថាខណ្ឌ (1) នៃផ្នែករង (a) នៃផ្នែកទី 12586.3 នៃក្រមរដ្ឋាភិបាល ដែលបានបង់ប្រាក់ទាំងនោះ ក្នុងលក្ខខណ្ឌដែល៖

(A) គ្លីនិកនោះឈានដល់ការអនុលោមតាមលក្ខខណ្ឌតម្រូវសមមាត្រចំណាយលើបេសកកម្ម 90 ភាគរយ ដែលត្រូវអនុវត្ត។

(B) គ្លីនិកនោះឈានដល់កិច្ចព្រមព្រៀងជាមួយនាយកដ្ឋានសុខភាពសាធារណៈរដ្ឋ លើផែនការចំណាយប្រាក់ទាំងអស់ដែលត្រូវបានសងត្រលប់មកវិញនោះ ទៅលើការចំណាយដែលផ្តោតលើបេសកកម្ម។

(4) ដោយមិនគិតពីកថាខណ្ឌមុន នាយកដ្ឋានសុខភាពសាធារណៈរដ្ឋអាចប្រើប្រាស់ប្រាក់នៅក្នុងមូលនិធិប្រាក់តម្កល់ពិសេស ដើម្បីផ្តល់មូលនិធិដល់សកម្មភាពនានាដែលបានចែងនៅក្នុងផ្នែកនេះ រួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ត្រឹម ការថែរក្សាមូលនិធិប្រាក់តម្កល់ពិសេស និងការធ្វើការពិនិត្យដែលត្រូវការដើម្បីឱ្យគ្លីនិកមានសិទ្ធិទទួលសំណងអនុលោមតាមកថាខណ្ឌ (3)។ ប្រាក់ដែលបានចំណាយ អាចត្រូវបានដកចេញពីទឹកប្រាក់ណាមួយដែលត្រូវសងត្រលប់ទៅឱ្យគ្លីនិកវិញ អនុលោមតាមកថាខណ្ឌ (3)។

(5) នាយកដ្ឋានសុខភាពសាធារណៈរដ្ឋត្រូវមានសិទ្ធិអំណាចក្នុងការធ្វើសវនកម្មលើគ្លីនិកនានា សម្រាប់ការអនុលោមតាមផែនការណាមួយដែលបានឯកភាពគ្នាអនុលោមតាមកថាខណ្ឌរង (B) នៃកថាខណ្ឌ (3) និងអាចទារយកមកវិញនូវសំណងណាមួយក្នុងកម្រិតដែលគ្លីនិកនោះមិនបានអនុលោមតាម។ ការទារប្រាក់មកវិញនេះត្រូវស្ថិតក្រោមនីតិវិធីដូចគ្នាដែលចែងនៅក្នុងកថាខណ្ឌ (2) និង (3) នៃផ្នែករង (b)។

(b) (1) ជារៀងរាល់ឆ្នាំ នាយកដ្ឋានសុខភាពសាធារណៈរដ្ឋត្រូវដាក់ការពិន័យរដ្ឋបាលលើគ្លីនិកនីមួយៗ ដែលស្ថិតក្រោមការចែងនៃផ្នែកទី 12586.3 នៃក្រមរដ្ឋាភិបាល ដែលមានសមមាត្រចំណាយលើបេសកកម្មក្រោម 90 ភាគរយ ដោយប្រាក់ពិន័យរដ្ឋបាលនោះត្រូវស្មើនឹងគម្លាតរវាងទឹកប្រាក់ដែលគ្លីនិកបានចំណាយលើការចំណាយដែលផ្តោតលើបេសកកម្ម និង 90 ភាគរយនៃប្រាក់ចំណូលសរុបរបស់គ្លីនិក។ នាយកដ្ឋានសុខភាពសាធារណៈរដ្ឋត្រូវចេញសេចក្តីជូនដំណឹងអំពីការពិន័យទៅកាន់គ្លីនិកណាដែលត្រូវបានរកឃើញថាមានការបំពាន ក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីទទួលបានការគណនាសមមាត្រចំណាយលើបេសកកម្មរបស់អគ្គរដ្ឋអាជ្ញា។

(2) ប្រសិនបើគ្លីនិកមិនមានការតវ៉ាចំពោះការគណនាសមមាត្រចំណាយលើបេសកកម្ម ឬការកំណត់ប្រាក់ពិន័យទេ ប្រាក់ពិន័យទាំងនោះត្រូវបង់ឱ្យបានពេញលេញទៅនាយកដ្ឋានសុខភាពសាធារណៈរដ្ឋ ក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងអំពីការពិន័យ ហើយត្រូវដាក់បញ្ចូលទៅក្នុងគណនីពិន័យសមមាត្រចំណាយលើបេសកកម្ម។

(3) ប្រសិនបើគ្លីនិកមានការតវ៉ាចំពោះការគណនាសមមាត្រចំណាយលើបេសកកម្មដែលធ្វើឡើងអនុលោមតាមផ្នែករង (e) នៃផ្នែកទី 12586.3 នៃក្រមរដ្ឋាភិបាល ឬការកំណត់ប្រាក់ពិន័យដែលធ្វើឡើងអនុលោមតាមផ្នែករងនេះ គ្លីនិកត្រូវ ក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីគ្លីនិកទទួលបានសេចក្តីជូនដំណឹងអំពីការពិន័យ ដាក់ពាក្យស្នើសុំប្តឹងតវ៉ាទៅកាន់ទាំងអគ្គរដ្ឋអាជ្ញា និងនាយកដ្ឋានសុខភាពសាធារណៈរដ្ឋក្នុងពេលដំណាលគ្នា។ ពាក្យស្នើសុំប្តឹងតវ៉ាអាចត្រូវបានធ្វើឡើងដោយមណ្ឌលមួយ ដោយផ្អែកលើការសម្រេចណាមួយដែលមិនបណ្តាលឱ្យមានការកំណត់ប្រាក់ពិន័យ។ សំណើនេះត្រូវរួមបញ្ចូលនូវសេចក្តីថ្លែងការណ៍លម្អិតដែលរៀបរាប់ពីហេតុផលនៃការប្តឹងតវ៉ា និងរួមបញ្ចូលនូវរាល់ឯកសារគាំទ្រទាំងអស់ដែលគ្លីនិកនឹងយកមកបង្ហាញនៅពេលបើកសវនាការ។ នៅពេលគ្លីនិកបានបញ្ជូនសំណើបានទាន់ពេលវេលា សវនាការមួយត្រូវបានកំណត់ពេល ហើយដំណើរការនីតិវិធីត្រូវអនុវត្តស្របតាមប្រការ 1 (ចាប់ផ្តើមជាមួយផ្នែកទី 131050) នៃជំពូក 2 នៃភាគ 1 នៃផ្នែក 112។

(c) (1) គ្លីនិកអាចដាក់ពាក្យស្នើសុំការលើកលែងទៅកាន់នាយកដ្ឋានសុខភាពសាធារណៈរដ្ឋ ដើម្បីផ្តល់ការផ្អាកបណ្តោះអាសន្ននូវលក្ខខណ្ឌតម្រូវ 90 ភាគរយ ឬសម្រាប់លក្ខខណ្ឌតម្រូវសមមាត្រចំណាយលើបេសកកម្មជាជម្រើស ដោយផ្អែកលើស្ថានភាពដែលនឹកស្មានមិនដល់ ឬស្ថានភាពពិសេស ឬស្ថានភាពសេដ្ឋកិច្ចរបស់គ្លីនិក។ ការចេញ និងលក្ខខណ្ឌនៃការលើកលែងអនុលោមតាមផ្នែករងនេះ ត្រូវស្ថិតក្រោមសិទ្ធិអំណាចផ្តាច់មុខ និងតែមួយគត់របស់នាយកដ្ឋានសុខភាពសាធារណៈរដ្ឋ។ ការលើកលែងដែលបានចេញអនុលោមតាមផ្នែករងនេះ ត្រូវមានរយៈពេលមួយឆ្នាំគិតចាប់ពីកាលបរិច្ឆេទនៃការចេញ។

(2) ដើម្បីទទួលបានការលើកលែងដោយផ្អែកលើស្ថានភាពដែលនឹកស្មានមិនដល់ ឬស្ថានភាពពិសេស គ្លីនិកត្រូវរៀបរាប់លម្អិតពីស្ថានភាពខាងក្រោមដែលគ្លីនិកបានជួបប្រទះ៖

(A) ពេលវេលាដែលគ្លីនិកបានដឹងជាលើកដំបូង អំពីស្ថានភាពដែលនឹកស្មានមិនដល់ ឬស្ថានភាពពិសេសនោះ។

(B) មូលហេតុដែលគ្លីនិកមិនអាចរំពឹងទុកជាមុនបានថា ស្ថានភាពទាំងនោះនឹងកើតឡើង។

(C) ចំណាត់ការនានាដែលគ្លីនិកបានធ្វើ ដើម្បីដោះស្រាយស្ថានភាពទាំងនោះ។

(D) ការចំណាយដែលបានកើតឡើងជាលទ្ធផលនៃការដោះស្រាយស្ថានភាពទាំងនោះ។

(E) ពេលវេលាដែលគ្លីនិកវាំងថាស្ថានភាពទាំងនោះនឹងត្រូវបានដោះស្រាយរួចរាល់។

(F) វិធានការបង្ការដែលគ្លីនិកកំពុងអនុវត្ត ដើម្បីធានាថាស្ថានភាពទាំងនោះនឹងមិនកើតឡើងដោយនឹកស្មានមិនដល់ទៀតទេនាពេលអនាគត។

(3) ដើម្បីទទួលបានការលើកលែងដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច គ្លីនិកត្រូវបង្ហាញថា ការអនុលោមតាមលក្ខខណ្ឌតម្រូវនៃសមាមាត្រចំណាយលើបេសកកម្មចំនួន 90 ភាគរយ នឹងបង្កឱ្យមានការសង្ស័យអំពីសមត្ថភាពរបស់គ្លីនិក ក្នុងការបន្តប្រតិបត្តិការជាសហគ្រាសកំពុងដំណើរការ ក្រោមគោលការណ៍គណនេយ្យដែលទទួលស្គាល់ជាទូទៅ។ ភស្តុតាងត្រូវរួមបញ្ចូលនូវឯកសារបញ្ជាក់អំពីស្ថានភាពហិរញ្ញវត្ថុរបស់គ្លីនិក ស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពមេ ឬអង្គភាពពាក់ព័ន្ធណាមួយ និងភស្តុតាងនៃផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុដោយផ្ទាល់ ជាក់ស្តែង ឬដែលអាចកើតឡើង ពីការអនុលោមតាមសមាមាត្រចំណាយលើបេសកកម្ម 90 ភាគរយ។

(4) ការពិចារណាលើសមត្ថភាពរបស់គ្លីនិកក្នុងការបន្តប្រតិបត្តិការជាសហគ្រាសកំពុងដំណើរការ ត្រូវរួមបញ្ចូលនូវកត្តាខាងក្រោម ពាក់ព័ន្ធនឹងគ្លីនិក ឬអង្គភាពពាក់ព័ន្ធណាមួយ៖

(A) ការបិទជាក់ស្តែង ឬដែលទំនងជានឹងកើតឡើង នូវកន្លែងផ្តល់សេវាណាមួយ ដែលដំណើរការដោយគ្លីនិក ឬអង្គភាពពាក់ព័ន្ធណាមួយ។

(B) ការបិទជាក់ស្តែង ឬដែលទំនងជានឹងកើតឡើង នូវសេវាកម្មអ្នកជំងឺ ឬកម្មវិធីនានា។

(C) ការបាត់បង់ការងារជាក់ស្តែង ឬដែលទំនងជានឹងកើតឡើង។

(D) ថាតើកន្លែងផ្តល់សេវាដែលដំណើរការដោយគ្លីនិក មានលក្ខណៈតូចតាច ស្ថិតនៅតំបន់ជនបទ ឬតំបន់ដាច់ស្រយាល ឬបម្រើសេវាដល់តំបន់គ្របដណ្តប់នៅជនបទដែរឬទេ។

(E) ថាតើការបិទកន្លែងផ្តល់សេវាណាមួយដែលដំណើរការដោយគ្លីនិក នឹងប៉ះពាល់យ៉ាងសំខាន់ដល់ការទទួលបានសេវានៅក្នុងតំបន់ ឬតំបន់សេវាកម្មដែរឬទេ។

(F) ថាតើគ្លីនិកកំពុងស្ថិតក្នុងវិបត្តិហិរញ្ញវត្ថុ ដែលបណ្តាលឱ្យ ឬទំនងជានឹងបណ្តាលឱ្យមានការបិទកន្លែងផ្តល់សេវាណាមួយដែលខ្លួនប្រតិបត្តិការ ឬអង្គភាពពាក់ព័ន្ធណាមួយ ការបិទសេវាកម្មអ្នកជំងឺ ឬកម្មវិធីនានា ឬការបាត់បង់ការងារ ដែរឬទេ។ កត្តាដែលត្រូវពិចារណាក្នុងការកំណត់ពីវិបត្តិហិរញ្ញវត្ថុរួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ត្រឹម ស្ថានភាពប្រតិបត្តិការកន្លងមក និងដែលបានព្យាករណ៍របស់គ្លីនិក ដោយផ្អែកលើសូចនាករហិរញ្ញវត្ថុ រួមទាំងចំនួនសាច់ប្រាក់ក្នុងដៃ និងថាតើគ្លីនិកមាន ឬត្រូវបានព្យាករណ៍ថានឹងជួបប្រទះនូវរឹមប្រតិបត្តិការអវិជ្ជមានដែរឬទេ។

(5) សំណើសុំការលើកលែងអនុលោមតាមផ្នែករងនេះ ត្រូវដាក់ស្នើជាលាយលក្ខណ៍អក្សរទៅកាន់ក្រសួងសុខាភិបាលរដ្ឋ។

(6) ក្រសួងសុខាភិបាលរដ្ឋត្រូវជូនដំណឹងដល់គ្លីនិកអំពីសេចក្តីសម្រេចលើសំណើសុំការលើកលែងនេះ ជាលាយលក្ខណ៍អក្សរ។

(7) គ្លីនិកអាចដាក់ពាក្យស្នើសុំបន្តសុពលភាពនៃការលើកលែង ដែលបានចេញអនុលោមតាមផ្នែករងនេះ នៅពេលណាក៏បាន ប៉ុន្តែមិនយឺតជាង 180 ថ្ងៃមុនពេលផុតកំណត់នៃការលើកលែងដែលមានស្រាប់។

ផ្នែកទី 5. បណ្តឹងទាមទារពីការរំលោភទ្រព្យបាលសប្បុរសធម៌។

ផ្នែកទី 5.1. ផ្នែកទី *5142.1* ត្រូវបានបន្ថែមទៅក្នុងក្រមសាជីវកម្ម ដោយចែងថា៖

5142.1. (a) ដោយមិនគិតពីផ្នែកទី 5142 ក្នុងករណីដែលគ្លីនិកដែលស្ថិតក្រោមការចែងនៃផ្នែកទី 12586.3 នៃក្រមរដ្ឋាភិបាល បានខកខានមិនបានរាយការណ៍ទិន្នន័យតាមការតម្រូវអនុលោមតាមផ្នែករង (b) នៃផ្នែកទី 12586.3 នៃក្រមរដ្ឋាភិបាល ឬមានទាំងសមាមាត្រចំណាយលើបេសកកម្ម (ដូចដែលបានកំណត់ក្នុងកថាខណ្ឌ (2) នៃផ្នែករង (a) នៃផ្នែកទី 12586.3 នៃក្រមរដ្ឋាភិបាល) ក្រោម 90 ភាគរយផង និងមិនស្ថិតក្រោមការលើកលែង អនុលោមតាមផ្នែករង (c) នៃផ្នែកទី 1234.5 នៃក្រមសុខភាព និងសុវត្ថិភាពផងនោះ អ្នកជំងឺណាម្នាក់របស់ FQHC នោះ អាចដាក់បណ្តឹងដើម្បីស្នើសុំដីកាបង្គាប់បញ្ជាប់ កែតម្រូវ ឬដោះស្រាយការរំលោភតាមវិធីផ្សេងទៀត ចំពោះការរំលោភទ្រព្យបាលសប្បុរសធម៌ អនុលោមតាមនីតិវិធីដូចគ្នាដែលត្រូវអនុវត្តចំពោះបណ្តឹងទាមទារ ដែលបានប្តឹងអនុលោមតាមផ្នែកទី 5142។

(b) ដោយមិនគិតពីផ្នែកទី 5231 សុចរិតភាពមិនត្រូវយកមកធ្វើជាអំណះអំណាងការពារខ្លួន ចំពោះបណ្តឹងណាមួយដែលបានប្តឹងអនុលោមតាមផ្នែកនេះឡើយ ហើយរាល់ទម្រង់នៃវិធានវិនិច្ឆ័យអាជីវកម្ម ក៏មិនត្រូវយកមកអនុវត្តក្នុងទិដ្ឋភាពណាមួយចំពោះការរំលោភបំពានដែលត្រូវបានប្តឹងតវ៉ានោះដែរ លើកលែងតែមានចែងក្នុងផ្នែកទី 5239។

(c) ផ្នែកនេះក៏ត្រូវជាកម្មវត្ថុនៃការអនុវត្តច្បាប់ដោយអនុលោមតាមផ្នែកទី 17204 នៃក្រមអាជីវកម្ម និងវិជ្ជាជីវៈផងដែរ។

ផ្នែកទី 6. ទណ្ឌកម្មព្រហ្មទណ្ឌ។

ផ្នែកទី 6.1. ផ្នែកទី 6814.1 ត្រូវបានបន្ថែមទៅក្នុងក្រមសាជីវកម្ម ដោយចែងថា៖

6814.1. រាល់នាយក មន្ត្រី ឬភ្នាក់ងារនៃគ្លីនិកណាមួយដែលស្ថិតក្រោមការចែងនៃផ្នែកទី 12586.3 នៃក្រមរដ្ឋាភិបាល ដែលបានរាយការណ៍ខុសដោយដឹងខ្លួន នូវការចំណាយ ឬប្រាក់ចំណូល ក្រោមផ្នែកទី 12586.3 នៃក្រមរដ្ឋាភិបាល ឬបានចូលរួមដោយដឹងខ្លួនក្នុងគម្រោង ដើម្បីបង្វែរការចំណាយ ឬប្រាក់ចំណូល តាមរយៈភាគីពាក់ព័ន្ធ ដូចដែលបានកំណត់ក្នុងផ្នែកទី 12586.3 នៃក្រមរដ្ឋាភិបាល រួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ត្រឹម មូលនិធិពាក់ព័ន្ធនានា ដោយមានចេតនាបង្កើនដោយសិប្បនិម្មិតនូវសមាមាត្រចំណាយលើបេសកកម្មរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារដោយអនុលោមតាមផ្នែករង (h) នៃផ្នែកទី 1170 នៃក្រមព្រហ្មទណ្ឌ ឬផ្តន្ទាទោសដាក់ពន្ធនាគារខោនធី ដោយមានរយៈពេលមិនលើសពីមួយឆ្នាំ។

ផ្នែកទី 7. ភាពអាចញែកចេញបាន។

បទប្បញ្ញត្តិនៃច្បាប់នេះអាចបំបែកបាន។ ប្រសិនបើបទប្បញ្ញត្តិណាមួយនៃច្បាប់នេះ ឬការអនុវត្តរបស់វា ត្រូវបានចាត់ទុកថាគ្មានសុពលភាព ភាពគ្មានសុពលភាពនោះមិនត្រូវប៉ះពាល់ដល់បទប្បញ្ញត្តិ ឬការអនុវត្តផ្សេងទៀតដែលអាចមានប្រសិទ្ធភាពដោយមិនចាំបាច់មានបទប្បញ្ញត្តិ ឬការអនុវត្តដែលគ្មានសុពលភាពនោះឡើយ។

ផ្នែកទី 8. កាលបរិច្ឆេទចូលជាធរមាន។

ស្របតាមគោលបំណងនៃច្បាប់នេះ លក្ខខណ្ឌតម្រូវស្តីពីសមាមាត្រចំណាយលើបេសកកម្ម ដែលមានចែងក្នុងច្បាប់នេះ ត្រូវយកមកអនុវត្តចំពោះឆ្នាំសារពើពន្ធពេញលេញដំបូងរបស់គ្លីនិកនីមួយៗ ដែលចាប់ផ្តើមយ៉ាងហោចណាស់ 6 ខែ បន្ទាប់ពីការអនុម័តច្បាប់នេះ។

ផ្នែកទី 9. វិសោធនកម្ម។

អនុលោមតាមផ្នែករង (c) នៃផ្នែកទី 10 នៃមាត្រា II នៃរដ្ឋធម្មនុញ្ញនៃរដ្ឋ California ច្បាប់នេះអាចត្រូវបានធ្វើវិសោធនកម្ម តាមរយៈវិធានការជាបន្តបន្ទាប់ដែលត្រូវបានដាក់ជូនឱ្យប្រជាជនបោះឆ្នោតនៅក្នុងការបោះឆ្នោតទូទាំងរដ្ឋ ឬតាមរយៈលក្ខន្តិកៈដែលត្រូវបានអនុម័តយ៉ាងត្រឹមត្រូវដោយអង្គនីតិបញ្ញត្តិ និងចុះហត្ថលេខាដោយអភិបាលរដ្ឋ ប៉ុន្តែទាល់តែដើម្បីជំរុញគោលបំណងនៃច្បាប់នេះប៉ុណ្ណោះ។

ផ្នែកទី 10. វិធានការប្រកួតប្រជែង។

ក្នុងករណីដែលវិធានការនេះ និងវិធានការមួយផ្សេងទៀត ដែលគ្រប់គ្រងលើសមាមាត្រចំណាយលើបេសកកម្មនៅគ្លីនិកដែលស្ថិតក្រោមការគ្របដណ្តប់មួយចំនួន ឬទាំងអស់ មានបង្ហាញនៅលើសន្លឹកឆ្នោតទូទាំងរដ្ឋតែមួយ បទប្បញ្ញត្តិនៃវិធានការ ឬវិធានការផ្សេងទៀតនោះ ត្រូវចាត់ទុកថាមានភាពផ្ទុយគ្នាជាមួយនឹងវិធានការនេះ។ វិធានការមួយផ្សេងទៀត មិនត្រូវ

ចាត់ទុកថាមានភាពផ្ទុយគ្នាជាមួយនឹងវិធានការនេះទេ គ្រាន់តែដោយសារតែវាបន្ថែម ឬធ្វើវិសោធនកម្មលើផ្នែកមួយ ឬច្រើននៃក្រមរដ្ឋាភិបាល ក្រមសុខភាព និងសុវត្ថិភាព ឬក្រមសាជីវកម្ម ដែលត្រូវបានបន្ថែម ឬធ្វើវិសោធនកម្មដោយវិធានការនេះនោះឡើយ។ ក្នុងករណីដែលវិធានការនេះទទួលបានសំឡេងគាំទ្រច្រើនជាងវិធានការដែលត្រូវបានចាត់ទុកថាមានភាពផ្ទុយគ្នានឹងវា បទប្បញ្ញត្តិនៃវិធានការនេះត្រូវមានអាទិភាពទាំងស្រុង ហើយវិធានការ ឬវិធានការផ្សេងទៀតត្រូវទុកជាមោឃៈ។

សំណើ 45

វិធានការផ្តួចផ្តើមនេះត្រូវបានដាក់ជូនប្រជាជនដោយអនុលោមតាមបទប្បញ្ញត្តិនៃផ្នែកទី 8 មាត្រា II នៃរដ្ឋធម្មនុញ្ញនៃរដ្ឋ California។

វិធានការផ្តួចផ្តើមនេះបន្ថែមផ្នែកទៅក្រមធនធានសាធារណៈ។ ដូច្នេះបទប្បញ្ញត្តិថ្មីដែលត្រូវបានស្នើឱ្យបន្ថែមត្រូវបានបោះពុម្ពជា*អក្សរទ្រេត* ដើម្បីបញ្ជាក់ថាបទប្បញ្ញត្តិទាំងនោះជាថ្មី។

ច្បាប់ដែលបានស្នើ

ផ្នែកទី 1. ជំពូក 1.5 (ចាប់ផ្តើមជាមួយផ្នែកទី 21010) ត្រូវបានបន្ថែមទៅក្នុងផ្នែក 13 នៃក្រមធនធានសាធារណៈ ដោយចែងថា៖

ជំពូក 1.5. ច្បាប់ស្តីពីការកសាងរដ្ឋ California ឱ្យមានតម្លៃសមរម្យ

ប្រការ 1. ចំណងជើង ការរកឃើញ និងការប្រកាស និងគោលបំណង

21010. ចំណងជើង

ជំពូកនេះត្រូវមានឈ្មោះ និងអាចហៅថា ច្បាប់ស្តីពីការកសាងរដ្ឋ California ឱ្យមានតម្លៃសមរម្យ។

21011. ការរកឃើញ និងការប្រកាស

ប្រជាជននៃរដ្ឋ California សូមឃើញ និងប្រកាសនូវចំណុចទាំងអស់ដូចខាងក្រោម៖

(a) ប្រព័ន្ធហួសសម័យរបស់រដ្ឋ California ក្នុងការអនុម័តគម្រោងចាំបាច់នានា គឺមានភាពយឺតយ៉ាវពេក មានលក្ខណៈការិយាធិបតេយ្យពេក និងមានតម្លៃថ្លៃពេក។ គម្រោងចាំបាច់នានា ដូចជា ទឹកស្អាត ថាមពលស្អាត មន្ទីរពេទ្យ លំនៅឋានដែលមានតម្លៃសមរម្យ ផ្លូវថ្នល់ ការទប់ស្កាត់ភ្លើងឆេះព្រៃ សាលារៀន សុវត្ថិភាពសាធារណៈ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត កំពុងត្រូវបានពន្យារពេល ឬរារាំងដោយសារបែបបទរដ្ឋបាលដែលមាននីតិវិធីស្មុគស្មាញ ការយឺតយ៉ាវផ្នែកការិយាធិបតេយ្យ និងបណ្តឹងផ្លូវច្បាប់ដែលច្រើនហួសហេតុ។

(b) ភាពយឺតយ៉ាវទាំងនេះ បានបង្កើនការចំណាយលើការរស់នៅយ៉ាងច្រើនសន្ធឹកសន្ធាប់សម្រាប់ប្រជាពលរដ្ឋ California ទាំងអស់។ ការស្រាវជ្រាវបង្ហាញថា ត្រឹមតែភាពយឺតយ៉ាវក្នុងការផ្តល់លិខិតអនុញ្ញាតតែមួយមុខ បានបន្ថែមការចំណាយរាប់ម៉ឺនដុល្លារទៅលើតម្លៃផ្ទះថ្មីមួយ ដែលជំរុញឱ្យថ្លៃជួល និងប្រាក់កម្ចីទិញផ្ទះកើនឡើងសម្រាប់ម្ចាស់ផ្ទះ និងអ្នកជួល។ បែបបទរដ្ឋបាលដែលមាននីតិវិធីស្មុគស្មាញស្រដៀងគ្នានេះ បានបន្ថែមការចំណាយរាប់ពាន់លានដុល្លារទៅលើការចំណាយលើការសាងសង់មន្ទីរពេទ្យ ហេដ្ឋារចនាសម្ព័ន្ធទឹក ផ្លូវថ្នល់ ស្ពាន ថាមពលស្អាត សាលារៀន បណ្តាញអ៊ីនធឺណិតល្បឿនលឿន និងគម្រោងកាត់បន្ថយគ្រោះថ្នាក់ភ្លើងឆេះព្រៃ ដែលការចំណាយទាំងនេះនៅទីបំផុតត្រូវធ្លាក់ទៅលើអ្នកប្រើប្រាស់ និងអ្នកបង់ពន្ធ។

(c) ច្បាប់ស្តីពីការអនុញ្ញាតរបស់រដ្ឋ California ត្រូវបានតាក់តែងឡើងតាំងពីជាង 50 ឆ្នាំមុន ពេលគឺមុនពេលដែលច្បាប់បរិស្ថានទំនើបនាពេលបច្ចុប្បន្នត្រូវបានដាក់ឱ្យអនុវត្តទៅទៀត។ ប្រព័ន្ធដែលហួសសម័យនោះ ឥឡូវនេះកំពុងដើរផ្ទុយពីគោលដៅបរិស្ថាន និងសុខភាពសាធារណៈរបស់រដ្ឋ តាមរយៈការពន្យារពេល ឬរារាំងគម្រោងចាំបាច់នានា ដែលនឹងជួយកាត់បន្ថយការបំពុលខ្យល់ បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការពារប្រភពផ្គត់ផ្គង់ទឹក ការពារសហគមន៍ពីភ្លើងឆេះព្រៃ ព្រមទាំងអភិរក្សសត្វព្រៃ និងបរិស្ថាន។

(d) ច្បាប់នេះនឹងធ្វើទំនើបកម្ម និងសម្រួលច្បាប់របស់រដ្ឋឱ្យមានភាពរលូនដើម្បីកាត់បន្ថយបែបបទរដ្ឋបាលស្មុគស្មាញ និងការពន្យារពេលដែលមិនចាំបាច់ ដាក់កម្រិតលើបណ្តឹងដែលគ្មានមូលដ្ឋានត្រឹមត្រូវ ដែលរារាំងគម្រោងចាំបាច់នានា ស្របពេលដែលអនុញ្ញាតឱ្យទីភ្នាក់ងារសាធារណៈ និងអ្នកស្នើសុំគម្រោងចាំបាច់ បន្តចែករំលែកបន្ទុកក្នុងការការពារក្តីទល់នឹងបណ្តឹងទាំងនោះ និងពន្លឿនការផ្តល់គម្រោងនានា ដែលប្រជាពលរដ្ឋ California ពឹងផ្អែកជារៀងរាល់ថ្ងៃ។

(e) រាល់ការពន្យារពេលមួយឆ្នាំ មានន័យថាប្រជាពលរដ្ឋ California ត្រូវរង់ចាំកាន់តែយូរ និងចំណាយប្រាក់កាន់តែច្រើន សម្រាប់អ្វីដែលពួកគេត្រូវការបំផុត។ ច្បាប់នេះអនុវត្តចំពោះគម្រោងដែលចាំបាច់បំផុតរបស់រដ្ឋដូចជា៖

(1) ទឹកស្អាតសម្រាប់ពិសារ និងការផ្គត់ផ្គង់ទឹកដែលមានសុវត្ថិភាព សម្រាប់សហគមន៍ទូទាំងរដ្ឋ។

(2) មន្ទីរពេទ្យ និងគ្លីនិកដែលមានសុវត្ថិភាព និងទំនើប ដើម្បីធានាការទទួលបានសេវាថែទាំសុខភាពក្នុងតម្លៃសមរម្យ។

(3) ថាមពលស្អាត និងអគ្គិសនីដែលអាចទុកចិត្តបាន ដើម្បីកាត់បន្ថយការចំណាយលើថ្លៃថាមពល និងប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ។

(4) លំនៅឋានគ្រប់ប្រភេទ ដើម្បីធ្វើឱ្យលំនៅឋានកាន់តែមានតម្លៃសមរម្យ សម្រាប់គ្រួសារដែលកំពុងតស៊ូដោះស្រាយជាមួយថ្លៃជួល និងប្រាក់កម្ចីទិញផ្ទះដែលកើនឡើងយ៉ាងគំហុក ក៏ដូចជាសម្រាប់ប្រជាជនវ័យចំណាស់ដែលងាយរងគ្រោះផងដែរ។

(5) ផ្លូវថ្នល់ ស្ពាន និងមធ្យោបាយដឹកជញ្ជូនសាធារណៈ ដើម្បីកាត់បន្ថយការកកស្ទះចរាចរណ៍ និងពង្រឹងសុវត្ថិភាពសាធារណៈ។

(6) គម្រោងទប់ស្កាត់ភ្លើងឆេះព្រៃ និងភាពធន់ ដើម្បីការពារអាយុជីវិត លំនៅឋាន និងធនធានធម្មជាតិ។

(7) សាលារៀនរដ្ឋ និងកន្លែងផ្តល់ការអប់រំ ដែលមានសុវត្ថិភាព និងត្រូវបានធ្វើទំនើបកម្ម សម្រាប់សិស្ស និងអ្នកអប់រំ។

(8) ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិតល្បឿនលឿន និងទូរគមនាគមន៍ដើម្បីតភ្ជាប់សហគមន៍ដែលខ្វះខាតសេវា និងពង្រីកឱកាស។

(f) តាមរយៈការពន្លឿនគម្រោងចាំបាច់ទាំងនេះ ច្បាប់នេះនឹងធ្វើឱ្យរដ្ឋ California មានតម្លៃសមរម្យជាងមុន និងជួយកាត់បន្ថយការចំណាយលើលំនៅឋាន ថាមពល អគ្គិសនី ការថែទាំសុខភាព និងតម្រូវការចាំបាច់ផ្សេងទៀត ស្របពេលជាមួយគ្នានេះផងដែរ ក៏ជួយកាត់បន្ថយការចំណាយរបស់អ្នកបង់ពន្ធ សម្រាប់គម្រោងសាធារណការផងដែរ។

(g) ច្បាប់នេះក៏នឹងជួយជំរុញឱ្យដំណើរការឆាប់រហ័សនូវគម្រោងនានាដែលបង្កើតការងារមានប្រាក់ឈ្នួលខ្ពស់ និងផ្តល់ការងារដល់ប្រជាពលរដ្ឋ California រាប់ម៉ឺននាក់ ជាពិសេសក្នុងវិស័យសំណង់ ថាមពលស្អាត និងហេដ្ឋារចនាសម្ព័ន្ធ ដោយជួយជំរុញកំណើនសេដ្ឋកិច្ចរបស់រដ្ឋ California នៅពេលដែលត្រូវការបំផុត។

(h) អ្វីដែលសំខាន់នោះគឺ ច្បាប់នេះរក្សាទុកនូវច្បាប់ខ្យល់ស្អាត ទឹកស្អាត និងការពារបរិស្ថានរបស់រដ្ឋ និងសហព័ន្ធ រួមមាន ច្បាប់ប្រភេទសត្វជិតផុតពូជ, ច្បាប់ទឹកផឹកមានសុវត្ថិភាព, ច្បាប់ត្រួតពិនិត្យសារធាតុពុលសហព័ន្ធ, ច្បាប់ទឹកស្អាតសហព័ន្ធ, ច្បាប់ទឹកស្អាតសហព័ន្ធ ច្បាប់កែលម្អគុណភាពបរិស្ថានសហព័ន្ធ, ច្បាប់ដំណោះស្រាយការឡើងកម្តៅផែនដី California, ច្បាប់តំបន់ឆ្នេរ California និង ច្បាប់អភិរក្ស និងស្ពានធនធានសហព័ន្ធ ។ ជំពូកនេះនឹងជួយសាងសង់គម្រោងនានាដែលចាំបាច់ ដើម្បីធ្វើឱ្យរដ្ឋ California កាន់តែមានតម្លៃសមរម្យ ដោយមិនលុបចោលច្បាប់ទាំងឡាយដែលធានាសុវត្ថិភាពសម្រាប់ក្រុមគ្រួសារ និងបរិស្ថាននោះឡើយ។

(i) យើងអាចធ្វើបាន ហើយត្រូវតែកសាងរដ្ឋ California មួយដែលមានតម្លៃសមរម្យ។

21012. សេចក្តីថ្លែងការណ៍អំពីគោលបំណង

គោលបំណងនៃជំពូកនេះ គឺដើម្បីធ្វើឱ្យរដ្ឋ California កាន់តែមានតម្លៃសមរម្យ តាមរយៈការសម្រួល និងការពន្លឿនការអនុម័តលើគម្រោងចាំបាច់នានា ការកាត់បន្ថយការចំណាយសម្រាប់ក្រុមគ្រួសារ និងអ្នកបង់ពន្ធ ការកែលម្អគុណភាពជីវិត ការបង្កើតការងារល្អៗ និងការរក្សាការការពារបរិស្ថានដែលរឹងមាំបំផុតក្នុងពិភពលោករបស់រដ្ឋ California។

ប្រការ 2. ការអនុវត្តជំពូកនេះ និងទំនាក់ទំនង ជាមួយច្បាប់ផ្សេងទៀត

21013. គម្រោងនានាដែលស្ថិតក្រោមការអនុវត្តនៃជំពូកនេះ

ជំពូកនេះអនុវត្តចំពោះតែគម្រោងលំនៅឋានចាំបាច់ គម្រោងថាមពលស្អាតចាំបាច់ គម្រោងទឹកចាំបាច់ គម្រោងសុខភាពសាធារណៈចាំបាច់ គម្រោងសុវត្ថិភាពសាធារណៈចាំបាច់ គម្រោងចូលប្រើបណ្តាញអ៊ីនធឺណិតល្បឿនលឿនចាំបាច់ គម្រោងកន្លែងអប់រំចាំបាច់ និងគម្រោងដឹកជញ្ជូនចាំបាច់ ដែលប្រជាជននៃរដ្ឋ California នៅទីនេះប្រកាសថា មានសារៈសំខាន់បំផុតចំពោះគុណភាពជីវិត និងលទ្ធភាពរស់នៅសមរម្យរបស់ពួកគេនៅក្នុងរដ្ឋនេះ។

21014. ការអនុវត្តជំពូកនេះ

(a) ជំពូកនេះមិនកាត់បន្ថយសិទ្ធិអំណាចរបស់ទីភ្នាក់ងារសាធារណៈណាមួយ ក្នុងការអនុម័ត ឬបដិសេធលើគម្រោងចាំបាច់ណាមួយនោះឡើយ។ គ្មានលទ្ធផលណាមួយលើគម្រោងចាំបាច់ដែលបានស្នើឡើង ត្រូវបានកំណត់ទុកជាមុនដោយជំពូកនេះទេ។

(b) ជំពូកនេះមិនលើកលែងដល់គម្រោងចាំបាច់ណាមួយ ពីការត្រួតពិនិត្យផ្នែកបរិស្ថាន ក្រោមការចែងនៃផ្នែកនេះ ឬច្បាប់ផ្សេងទៀតឡើយ។ ជំពូកនេះបង្កើតឡើងនូវកាលវិភាគច្បាស់លាស់ និងនីតិវិធីផ្សេងទៀត សម្រាប់ការត្រួតពិនិត្យក្រោមការចែងនៃផ្នែកនេះ និងការត្រួតពិនិត្យលិខិតអនុញ្ញាតរដ្ឋបាល សម្រាប់គម្រោងចាំបាច់នានា។

(c) លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងជំពូកនេះ ជំពូកនេះត្រូវអនុវត្តចំពោះការត្រួតពិនិត្យ និងដំណើរការរាល់ពាក្យស្នើសុំ ឬការអនុម័តសម្រាប់គម្រោងចាំបាច់ និងសិទ្ធិប្រើប្រាស់ដីធ្លីដែលភ្ជាប់មកជាមួយ រួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ត្រឹម សិទ្ធិប្រើប្រាស់ដីធ្លីតាមឆន្ទានុសិទ្ធិ ទាំងផ្នែកកាត់ក្តី និងផ្នែកនីតិបញ្ញត្តិ ដែលបង្កឱ្យមានការត្រួតពិនិត្យផ្នែកបរិស្ថានកម្រិតកម្មវិធីកម្រិតផែនការ ឬកម្រិតគម្រោង ក្រោមការចែងនៃផ្នែកនេះ។

(d) ជំពូកនេះត្រូវអនុវត្តចំពោះទីភ្នាក់ងារសាធារណៈទាំងអស់។

(e) (1) ក្នុងកម្រិតដែលមានភាពផ្ទុយគ្នារវាងជំពូកនេះ និងច្បាប់ផ្សេងទៀត ជំពូកនេះត្រូវមានអាទិភាព។ ដោយមិនគិតពីចំណុចណាមួយដែលផ្ទុយពីនេះ ជំពូកនេះមិនត្រូវលុបចោល ឬដាក់កម្រិតលើការលើកលែងតាមច្បាប់ ឬតាមប្រភេទណាមួយដែលត្រូវអនុវត្តបានពីផ្នែកនេះឡើយ។

(2) ដោយមិនគិតពីផ្នែកទី 21100 ឬច្បាប់ផ្សេងទៀត បទប្បញ្ញត្តិនៃជំពូកនេះត្រូវមានអាទិភាព និងជំនួស រាល់លក្ខខណ្ឌតម្រូវដែលផ្ទុយគ្នាសម្រាប់ការត្រួតពិនិត្យផ្នែកបរិស្ថាននៃគម្រោងចាំបាច់ និងការត្រួតពិនិត្យលិខិតអនុញ្ញាតដែលភ្ជាប់មកជាមួយណាមួយ។ គ្មានបទប្បញ្ញត្តិណាមួយនៃផ្នែកទី 21100 ឬច្បាប់ផ្សេងទៀត ត្រូវធ្វើឱ្យជាមោឃៈ ឬដាក់កម្រិតលើការអនុវត្តជំពូកនេះចំពោះគម្រោងចាំបាច់ណាមួយឡើយ។

(f) (1) ពាក្យស្នើសុំសម្រាប់គម្រោងចាំបាច់ ដែលត្រូវបានដាក់ជូនទីភ្នាក់ងារសាធារណៈ មុនកាលបរិច្ឆេទចូលជាធរមាននៃជំពូកនេះ ហើយដែលមិនទាន់ទទួលបានការអនុម័តជាស្ថាពរមុនកាលបរិច្ឆេទនោះ អាចត្រូវបានដកវិញ និងដាក់ស្នើសុំឡើងវិញ បន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃជំពូកនេះ។

(2) ពាក្យស្នើសុំសម្រាប់គម្រោងចាំបាច់ ដែលត្រូវបានដកវិញ និងដាក់ស្នើសុំឡើងវិញ ដូចដែលបានចែងក្នុងកថាខណ្ឌ (1) អាចត្រូវបានត្រួតពិនិត្យ និងអនុម័តអនុលោមតាមបទប្បញ្ញត្តិនៃជំពូកនេះ។

(3) គម្រោងលំនៅឋានចាំបាច់ដែលមានពាក្យស្នើសុំត្រូវបានដកវិញ និងដាក់ស្នើសុំឡើងវិញ ដូចដែលបានចែងក្នុងកថាខណ្ឌ (1) មិនត្រូវបាត់បង់សិទ្ធិជាស្ថាពរណាមួយ ឬអត្ថប្រយោជន៍ផ្សេងទៀត ដែលអ្នកស្នើសុំទទួលបានតាមរយៈបទប្បញ្ញត្តិច្បាប់ណាមួយឡើយ រួមមានជាអាទិ៍ ប៉ុន្តែមិនកំណត់ត្រឹម ច្បាប់ផែនទីបំណែងចែកដី (ផ្នែក 2 (ចាប់ផ្តើមជាមួយផ្នែកទី 66410) នៃចំណងជើង 7 នៃក្រមរដ្ឋាភិបាល) ច្បាប់គណនេយ្យភាពលំនៅឋាន (ផ្នែកទី 65589.5 នៃក្រមរដ្ឋាភិបាល) វិធានការដោះស្រាយសម្រាប់អ្នកសាងសង់ (ជំពូក 268 នៃលក្ខន្តិកៈឆ្នាំ 2024) និង ច្បាប់វិបត្តិលំនៅឋានឆ្នាំ 2019 (ជំពូក 12 (ចាប់ផ្តើមជាមួយផ្នែកទី 66300) នៃផ្នែក 1 នៃចំណងជើង 7 នៃក្រមរដ្ឋាភិបាល)។ សិទ្ធិជាស្ថាពរ ត្រូវគិតត្រលប់ទៅកាលបរិច្ឆេទដែលពាក្យស្នើសុំបឋមណាមួយ ត្រូវបានដាក់ជូនអនុលោមតាមផ្នែកទី 65941.1 នៃក្រមរដ្ឋាភិបាល ឬកាលបរិច្ឆេទដែលការទទួលបានសិទ្ធិជាស្ថាពរ បានកើតឡើងអនុលោមតាមច្បាប់ដែលអាចអនុវត្តបានផ្សេងទៀត។

(4) (A) ប្រសិនបើពាក្យស្នើសុំសម្រាប់គម្រោងចាំបាច់ ត្រូវបានចាត់ទុក ឬកំណត់ថាបានពេញលេញ មុនកាលបរិច្ឆេទចូលជាធរមាននៃជំពូកនេះ ពាក្យស្នើសុំនោះត្រូវចាត់ទុកថាបានពេញលេញសម្រាប់គោលបំណងនៃជំពូកនេះ ហើយទីភ្នាក់ងារសាធារណៈមិនត្រូវទាមទារឱ្យមានការត្រួតពិនិត្យភាពពេញលេញបន្ថែមទៀតឡើយ។

(B) ក្នុងកាលៈទេសៈដែលពាក្យស្នើសុំត្រូវបានដកវិញ និងដាក់ស្នើសុំឡើងវិញ ដូចដែលបានចែងក្នុងកថាខណ្ឌ (1) រាល់កាលកំណត់ នៅក្នុងជំពូកនេះ ដែលត្រូវបានចាប់ផ្តើមអនុវត្ត ដោយផ្អែកលើកាលបរិច្ឆេទដែលពាក្យស្នើសុំត្រូវបានកំណត់ ឬចាត់ទុកថាបានពេញលេញ ត្រូវគណនាចាប់ពីពេលដែលពាក្យស្នើសុំគម្រោងចាំបាច់ ត្រូវបានដាក់ស្នើសុំឡើងវិញដោយអ្នកស្នើសុំ។

(g) កាលវិភាគ និងកាលកំណត់ ដែលមានចែងនៅក្នុងជំពូកនេះ ត្រូវអនុវត្តចំពោះរាល់ពាក្យស្នើសុំគម្រោងចាំបាច់ ដែលត្រូវបានកំណត់ ឬចាត់ទុកថាបានពេញលេញ អនុលោមតាមផ្នែកទី 21017 ឬច្បាប់ផ្សេងទៀត បន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃជំពូកនេះ ដោយមិនគិតពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំឡើយ។

(h) ដោយមិនគិតពីច្បាប់ផ្សេងណាមួយឡើយ៖

(1) ប្រសិនបើគម្រោងចាំបាច់ គឺជាផ្នែកមួយ ឬសមាសភាគមួយនៃគម្រោងដែលធំជាងនេះ ផ្នែក ឬសមាសភាគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាគម្រោងចាំបាច់ អាចត្រូវបានដំណើរការ ត្រួតពិនិត្យ និងអនុម័តដោយអនុលោមតាមជំពូកនេះ។

(2) ប្រសិនបើគម្រោងទាំងមូល គឺជាគម្រោងចាំបាច់ គម្រោងចាំបាច់នោះអាចត្រូវបានអនុវត្តជាច្រើនដំណាក់កាល ហើយពាក្យស្នើសុំតាមដំណាក់កាលមិនតម្រូវឱ្យបំពេញតាមលក្ខណៈវិនិច្ឆ័យដោយឡែកពីគ្នាក្នុងនាមជាគម្រោងចាំបាច់ ដើម្បីត្រូវបានដំណើរការ ត្រួតពិនិត្យ និងអនុម័តដោយអនុលោមតាមជំពូកនេះឡើយ។

(i) លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងជំពូកនេះ គ្មានចំណុចណាមួយនៅក្នុងជំពូកនេះ ត្រូវបកស្រាយថាជាការលុបបំបាត់ ឬដាក់កម្រិតលើឆន្ទានុសិទ្ធិរបស់ទីភ្នាក់ងារដឹកនាំ ក្នុងការកំណត់នូវកម្រិតគោលនៃសារៈសំខាន់ដែលសមស្រប ឬវិធានការកាត់បន្ថយផលប៉ះពាល់ ក្នុងការរៀបចំឯកសារត្រួតពិនិត្យផ្នែកបរិស្ថានឡើយ។

(j) គ្មានចំណុចណាមួយនៅក្នុងជំពូកនេះ ហាមឃាត់ទីភ្នាក់ងារសាធារណៈពីការតម្រូវឱ្យអ្នកស្នើសុំបង់ថ្លៃសេវា ស្របតាមមាត្រា XIIIA និង XIIIC នៃរដ្ឋធម្មនុញ្ញនៃរដ្ឋ California ក្នុងគោលបំណងរ៉ាប់រងការចំណាយរបស់រដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងការដំណើរការ និងការត្រួតពិនិត្យពាក្យស្នើសុំគម្រោងចាំបាច់នោះឡើយ។

(k) អ្នកស្នើសុំអាចយល់ព្រមផ្តល់ពេលវេលាបន្ថែមដល់ទីភ្នាក់ងារសាធារណៈ ដើម្បីបញ្ចប់ការត្រួតពិនិត្យផ្នែកបរិស្ថានអនុលោមតាមផ្នែកទី 21018 ឬ 21019 ឬដើម្បីធ្វើការសម្រេចចិត្តលើចំណាត់ការផ្សេងទៀតរបស់ទីភ្នាក់ងារសាធារណៈដែលអ្នកស្នើសុំបានទាមទារអនុលោមតាមផ្នែកទី 21023 តាមរយៈការយល់ព្រមផ្អាកការដាក់នូវសំណើជាលាយលក្ខណ៍អក្សរ ដែល

អ្នកស្នើសុំមានសិទ្ធិដាក់ជូននៅឡើយ អនុលោមតាមផ្នែករង (a) នៃផ្នែកទី 21020 ឬផ្នែករង (b) នៃផ្នែកទី 21023។

21015. ទំនាក់ទំនងជាមួយច្បាប់ផ្សេងទៀត

(a) ដើម្បីបង្កើនលទ្ធភាពជាអតិបរមាក្នុងការសម្រួល និងពន្លឿនការអនុម័តគម្រោងចាំបាច់នានា អ្នកស្នើសុំអាចជ្រើសរើសមិនប្រើប្រាស់ទាល់តែសោះ ប្រើប្រាស់ខ្លះ ឬប្រើប្រាស់ទាំងអស់ នូវបទប្បញ្ញត្តិនៃជំពូកនេះ ហើយអាចធ្វើដូច្នេះដោយរួមបញ្ចូលគ្នាជាមួយ ឬជាជម្រើសជំនួសឱ្យ ច្បាប់ យន្តការ ឬនីតិវិធីផ្សេងទៀត ស្តីពីការប្រើប្រាស់ដីធ្លី និងការត្រួតពិនិត្យផ្នែកបរិស្ថាន។ គ្មានចំណុចណាមួយនៅក្នុងជំពូកនេះ ដែល (1) ហាមឃាត់អ្នកស្នើសុំពីការទាញយកប្រយោជន៍ពីច្បាប់ស្តីពីការប្រើប្រាស់ដីធ្លី និងការត្រួតពិនិត្យផ្នែកបរិស្ថានផ្សេងទៀត ដែលនឹងផ្តល់នូវការត្រួតពិនិត្យ និងការអនុម័តគម្រោងចាំបាច់នានា ដែលកាន់តែរហ័ស ឬមានអត្ថប្រយោជន៍ជាង បើប្រៀបធៀបនឹងជំពូកនេះ ឬ (2) តម្រូវឱ្យអ្នកស្នើសុំដែលស្វែងរកការអនុម័តលើគម្រោងដែលបំពេញតាមនិយមន័យនៃគម្រោងចាំបាច់ ត្រូវប្រើប្រាស់ជំពូកនេះនោះឡើយ។

(b) ក្នុងកម្រិតដែលភាពមិនច្បាស់លាស់ណាមួយកើតឡើង ពាក់ព័ន្ធនឹងរបៀបដែលជំពូកនេះអាចប្រតិបត្តិការរួមគ្នាជាមួយនឹងបទប្បញ្ញត្តិច្បាប់ផ្សេងទៀត គោលនយោបាយ និងចេតនាដែលមានចែងក្នុងផ្នែកទី 21029 ត្រូវមានអាទិភាព។

(c) បទប្បញ្ញត្តិខាងក្រោម ត្រូវអនុវត្តចំពោះគម្រោងលំនៅឋានចាំបាច់៖

(1) បទប្បញ្ញត្តិស្តីពីប្រាក់ឈ្នួលអត្រាគ្រប់គ្រង នៃកថាខណ្ឌ (8) នៃផ្នែករង (a) នៃផ្នែកទី 65913.4 នៃក្រមរដ្ឋាភិបាល ត្រូវអនុវត្តតែចំពោះអគារដែលមានកម្ពស់លើសពី 85 ហ្វីត ពីនីវ៉ូដីនៅក្នុងគម្រោងលំនៅឋានចាំបាច់ណាមួយប៉ុណ្ណោះ។

(2) បទប្បញ្ញត្តិនៃកថាខណ្ឌ (3) និង (5) នៃផ្នែករង (d) នៃផ្នែកទី 21080.66 ដូចដែលបានបន្ថែមដោយផ្នែកទី 59 នៃជំពូក 22 នៃលក្ខន្តិកៈឆ្នាំ 2025 (សេចក្តីព្រាងច្បាប់រដ្ឋសភា 130) ត្រូវអនុវត្តចំពោះគម្រោងលំនៅឋានចាំបាច់ ដែលប្រើប្រាស់ជំពូកនេះ។

(3) (A) បន្ថែមពីលើអ្នកម៉ៅការផ្ទាល់ ឬអ្នកម៉ៅការបន្ត បទប្បញ្ញត្តិនៃផ្នែកទី 218.9 នៃក្រមការងារត្រូវមានវិសាលភាពគ្របដណ្តប់ទៅដល់ម្ចាស់គម្រោងលំនៅឋានចាំបាច់ ក្នុងអំឡុងពេលសាងសង់គម្រោងលំនៅឋានចាំបាច់ ដែលប្រើប្រាស់ជំពូកនេះ។

(B) សម្រាប់គោលបំណងនៃកថាខណ្ឌនេះ ពាក្យ "ម្ចាស់" មានន័យថាជាម្ចាស់ ដូចដែលបានកំណត់នៅក្នុងផ្នែករង (e) នៃផ្នែកទី 8182 នៃក្រមរដ្ឋប្បវេណី។

(d) ដោយមិនគិតពីផ្នែករង (a)៖

(1) រាល់គម្រោងចាំបាច់ទាំងអស់ដែលប្រើប្រាស់ជំពូកនេះ ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងផ្នែកទី 21016 ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យបឋម និងការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធ។

(2) ដោយលើកលែងចំពោះគម្រោងលំនៅឋានចាំបាច់ រាល់គម្រោងចាំបាច់ទាំងអស់ដែលប្រើប្រាស់ជំពូកនេះ ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងផ្នែកទី 21028 ដែលពាក់ព័ន្ធនឹងការអនុវត្តលក្ខខណ្ឌតម្រូវផ្នែកការងារ ដែលបានរៀបរាប់ក្នុងផ្នែកទី 21183.5 ចំពោះគម្រោងចាំបាច់។

(3) (A) លើកលែងតែមានចែងក្នុងកថាខណ្ឌរង (B) រាល់គម្រោងលំនៅឋានចាំបាច់ទាំងអស់ដែលប្រើប្រាស់ជំពូកនេះ ត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងផ្នែករង (c) ដែលពាក់ព័ន្ធនឹងប្រាក់ឈ្នួល និងស្តង់ដាការងារលើគម្រោងលំនៅឋានចាំបាច់។

(B) ប្រសិនបើអ្នកស្នើសុំគម្រោងលំនៅឋានចាំបាច់ ជ្រើសរើសបន្តនីតិវិធីមួយផ្នែកអនុលោមតាមជំពូកនេះ និងមួយផ្នែកទៀតអនុលោមតាមច្បាប់ស្តីពីដំណើរការត្រួតពិនិត្យផ្នែកបរិស្ថានឱ្យមានភាពរលូនដោយស្ម័គ្រចិត្តផ្សេងទៀត ដែលត្រូវបានចងក្រងជាក្រមនៅក្រៅជំពូកនេះ ហើយក៏តម្រូវឱ្យប្រើប្រាស់ផងដែរនូវប្រាក់ឈ្នួលអត្រាកំពុងអនុវត្ត ឬកិច្ចព្រមព្រៀងការងារគម្រោង នោះអ្នកស្នើសុំត្រូវមានកាតព្វកិច្ចអនុលោមតាមលក្ខខណ្ឌតម្រូវស្តីពីប្រាក់ឈ្នួលអត្រាកំពុងអនុវត្ត ឬកិច្ចព្រមព្រៀងការងារគម្រោងណាមួយ ដែលត្រូវបានតម្រូវដោយច្បាប់សម្រួលឱ្យមានភាពរលូនផ្សេងទៀតនោះ សម្រាប់សមាសភាគគម្រោងចាំបាច់ ដែលត្រូវបានដំណើរការ និងអនុម័តអនុលោមតាមច្បាប់សម្រួលឱ្យមានភាពរលូនផ្សេងទៀតនោះ។

ប្រការ 3. ការត្រួតពិនិត្យបឋម ការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធ និងភាពពេញលេញនៃពាក្យស្នើសុំគម្រោងចាំបាច់

21016. ធនធានវប្បធម៌កុលសម្ព័ន្ធ៖ ការត្រួតពិនិត្យបឋម និងការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធលើគម្រោងចាំបាច់

(a) គោលបំណង។ ប្រជាជននៃរដ្ឋ California នៅទីនេះប្រកាសថា ផ្នែកនេះមានភាពចាំបាច់ ដើម្បីផ្តល់ឱ្យមានការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធតាំងពីដំណាក់កាលដំបូង និងប្រកបដោយអត្ថន័យ ក្នុងនាមជាធាតុផ្សំដ៏សំខាន់មួយនៃការធ្វើផែនការគម្រោងចាំបាច់ ស្របពេលដែលរក្សាបាននូវការការពារសម្រាប់ធនធានវប្បធម៌កុលសម្ព័ន្ធ។ កុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ មានចំណេះដឹង និងជំនាញ ពាក់ព័ន្ធនឹងធនធានវប្បធម៌កុលសម្ព័ន្ធដែលមានទីតាំងស្ថិតនៅក្នុងតំបន់គម្រោងចាំបាច់។

(b) ការសាងតាមន័យ និងការបកស្រាយ។

(1) ដោយមិនគិតពីផ្នែកទី 21015 ឬបទប្បញ្ញត្តិច្បាប់ផ្សេងទៀត ដំណើរការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធសម្រាប់គម្រោងចាំបាច់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងផ្នែកនេះ។

(2) គ្មានចំណុចណាមួយនៅក្នុងជំពូកនេះ មានបំណងកែប្រែ ឬផ្ទុយពីកាតព្វកិច្ចពិគ្រោះយោបល់រវាងរដ្ឋាភិបាលនិងរដ្ឋាភិបាលនៅថ្នាក់សហព័ន្ធដែលពាក់ព័ន្ធនឹងកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ឡើយ។

(3) កាលវិភាគដែលបានបង្កើតឡើងនៅក្នុងប្រការ 4 (ចាប់ផ្តើមជាមួយផ្នែកទី 21018) មិនត្រូវផ្លាស់ប្តូររយៈពេលនៃការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់លើគម្រោងចាំបាច់ ដោយអនុលោមតាមផ្នែកទី 21080.3.1 និង 21080.3.2 ឡើយ។

(4) ប្រសិនបើមានការសិក្សាបច្ចេកទេសណាមួយត្រូវបានធ្វើឡើងសម្រាប់គម្រោងចាំបាច់ ដែលផ្តល់ជាព័ត៌មានដល់ការវិភាគ វិធានការ ឬការចាត់ចែងលើធនធានវប្បធម៌កុលសម្ព័ន្ធ នោះកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ ត្រូវទទួលបានឱកាសក្នុងការត្រួតពិនិត្យ និងផ្តល់ធាតុចូលលើការសិក្សាទាំងនោះ។

(5) នៅពេលដែលត្រូវបានផ្តល់ដោយកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ ចំណេះដឹងប្រពៃណីកុលសម្ព័ន្ធ ត្រូវដាក់បញ្ចូលទៅក្នុងការកំណត់អត្ថសញ្ញាណ ការចាត់ចែង និងវិធានការការពារនានា ដែលពាក់ព័ន្ធនឹងធនធានវប្បធម៌កុលសម្ព័ន្ធ។ ដោយសារតែធនធានវប្បធម៌កុលសម្ព័ន្ធ គឺជាប្រភេទមួយដាច់ដោយឡែកពីធនធានវប្បធម៌ និងធនធានបុរាណវិទ្យាវិធីសាស្ត្រ និងស្តង់ដាបុរាណវិទ្យាមួយចំនួន អាចនឹងមិនសមស្របសម្រាប់ធនធានវប្បធម៌កុលសម្ព័ន្ធឡើយ។ ប្រសិនបើទីភ្នាក់ងារដឹកនាំសម្រេចចិត្តមិនប្រើប្រាស់វិធីសាស្ត្រ និងស្តង់ដាកុលសម្ព័ន្ធ ឬចំណេះដឹងប្រពៃណីកុលសម្ព័ន្ធទេ ខ្លួនត្រូវពន្យល់ពីសេចក្តីសម្រេចរបស់ខ្លួននៅក្នុងឯកសារបរិស្ថានសម្រាប់គម្រោងចាំបាច់ ដោយមានការគាំទ្រពីភស្តុតាងសំខាន់។

(6) រាល់ព័ត៌មានពាក់ព័ន្ធនឹងធនធានវប្បធម៌កុលសម្ព័ន្ធ និងចំណេះដឹងប្រពៃណីកុលសម្ព័ន្ធ ដែលត្រូវបានលាតត្រដាងដោយកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ ត្រូវរក្សាទុកជាការសម្ងាត់ ស្របតាមផ្នែករង (c) នៃផ្នែកទី 21082.3 ហើយព័ត៌មាននោះ មិនត្រូវលាតត្រដាងនៅក្នុងកំណត់ត្រា

រដ្ឋបាលនៃដំណើរការនីតិវិធី ដោយគ្មានការអនុញ្ញាតពីកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់នោះឡើយ។ ទីភ្នាក់ងារដឹកនាំ តាមរយៈការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ដែលរងផលប៉ះពាល់ ត្រូវកំណត់នូវវិធានការសមស្របនានា ដើម្បីរក្សាការសម្ងាត់នៃព័ត៌មានពាក់ព័ន្ធនឹងធនធានវប្បធម៌កុលសម្ព័ន្ធ និងចំណេះដឹងប្រពៃណីកុលសម្ព័ន្ធ រួមមានជាអាទិ៍ ការលុបបិទបាំងទីតាំងច្បាស់លាស់ ការដាក់កម្រិតលើការគូសផែនទី ការផ្ទុកទិន្នន័យប្រកបដោយសុវត្ថិភាព ឬការចាត់ចែងក្នុងគោលបំណងការពារផ្សេងទៀត នូវព័ត៌មានស្តីពីធនធានវប្បធម៌កុលសម្ព័ន្ធ។ ការពន្យល់ជាលាយលក្ខណ៍អក្សរណាមួយ ក្រោមកថាខណ្ឌ (5) នៃផ្នែករង (c) មិនត្រូវជាកម្មវត្ថុនៃការប្តឹងតវ៉ាឡើយ ក្នុងកម្រិតដែលទីភ្នាក់ងារដឹកនាំមិនមានការអនុញ្ញាតពីកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ ក្នុងការលាតត្រដាងព័ត៌មានគាំទ្រ ដោយសារតែលក្ខខណ្ឌតម្រូវស្តីពីការរក្សាការសម្ងាត់នៃកថាខណ្ឌនេះ។

(7) ការបញ្ចប់ដំណើរការត្រួតពិនិត្យបឋម អនុលោមតាមផ្នែករង (c) ដំណើរការដោយឡែកពីគ្នា និងមិនកែប្រែ ផ្អាក ឬប៉ះពាល់ដល់លក្ខខណ្ឌតម្រូវ ឬកាលវិភាគណាមួយ ដែលមានចែងក្នុងផ្នែកទី 21017 ឬបទប្បញ្ញត្តិផ្សេងទៀតនៃផ្នែកនេះឡើយ។

(c) ការត្រួតពិនិត្យបឋម។ នៅពេលដែលអ្នកស្នើសុំបានដាក់ពាក្យស្នើសុំបឋមអនុលោមតាមច្បាប់ផ្សេងទៀត សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សររបស់អ្នកស្នើសុំអនុលោមតាមផ្នែករង (b) នៃផ្នែកទី 21024 ឬពាក្យស្នើសុំសម្រាប់គម្រោងចាំបាច់ណាមួយ ការត្រួតពិនិត្យដំណាក់កាលដំបូង ដើម្បីកំណត់អត្តសញ្ញាណ និងវាយតម្លៃធនធានវប្បធម៌កុលសម្ព័ន្ធ ត្រូវតែធ្វើឡើង។ ការត្រួតពិនិត្យបឋម មានន័យថាជាសកម្មភាពនៃការចូលរួមក្នុងការពិភាក្សាដំបូងមុនពេលដែលពាក្យស្នើសុំមួយត្រូវបានកំណត់ថាពេញលេញ ដោយទីភ្នាក់ងារដឹកនាំ តាមរយៈដំណើរការជួបប្រជុំនិងពិគ្រោះយោបល់រវាងកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ ទីភ្នាក់ងារដឹកនាំ និងអ្នកស្នើសុំ ពាក់ព័ន្ធនឹងផលប៉ះពាល់ដែលអាចកើតមាន ដែលគម្រោងចាំបាច់ស្នើឡើងមួយ អាចមានទៅលើធនធានវប្បធម៌កុលសម្ព័ន្ធ។ ក្នុងនាមជាផ្នែកមួយនៃដំណើរការត្រួតពិនិត្យបឋម ចំណុចទាំងអស់ខាងក្រោមត្រូវតែកើតឡើង៖

(1) (A) អ្នកស្នើសុំត្រូវផ្តល់ឱ្យទីភ្នាក់ងារដឹកនាំ នូវព័ត៌មានដែលមានស្រាប់ដូចខាងក្រោម៖

(i) ការពណ៌នាអំពីគម្រោងចាំបាច់ដែលបានស្នើឡើង។

(ii) ផែនទីទីតាំងជាទម្រង់គំនិត ដែលបង្ហាញពីផ្ទៃក្រឡាគ្របដណ្តប់ ខ្សែគំនូសតម្រង់ ឬព្រំប្រទល់ទូទៅ ដែលបានស្នើឡើងនៃតំបន់គម្រោង។

(iii) ផែនទីបង្ហាញតំបន់ជុំវិញ ដែលបញ្ជាក់ពីទីតាំងសម្គាល់សំខាន់ៗ ផ្លូវថ្នល់ និងលក្ខណៈធម្មជាតិនានា។

(iv) រាល់ការសិក្សាបច្ចេកទេសភូមិវិស្វកម្ម ការសិក្សាផ្នែកបរិស្ថាន និងការសិក្សាបច្ចេកទេសជាក់លាក់តាមទីតាំងណាមួយ ដែលត្រូវបានរៀបចំឡើងពីមុន ដើម្បីគាំទ្រដល់ការជួបប្រជុំ និងពិគ្រោះយោបល់អនុលោមតាមកថាខណ្ឌ (4) ទៅលើការរចនាបឋម ការកំណត់ខ្សែកន្លង ឬការវិភាគលទ្ធភាពអនុវត្ត ដែលពាក់ព័ន្ធនឹង ឬប៉ះពាល់ដល់ធនធានវប្បធម៌កុលសម្ព័ន្ធ។

(v) សម្រាប់គម្រោងលីនេអ៊ែរ ដូចជាខ្សែបញ្ជូនអគ្គិសនី បំពង់បង្ហូរ ខ្សែផ្លូវដែក ប្រឡាយទឹក ខ្សែទូរគមនាគមន៍ និងផ្លូវថ្នល់ អ្នកស្នើសុំត្រូវបញ្ចូលនូវច្រករបៀងទូទៅ និងទីតាំងនៃបរិក្ខារ ឬអនុស្ថានីយ ចាប់ផ្តើម និងបញ្ចប់ណាមួយ។

(B) អ្នកស្នើសុំមិនត្រូវបានតម្រូវឱ្យបង្កើតការសិក្សា ឬការវិភាគថ្មី សម្រាប់គោលបំណងនៃផ្នែករងនេះឡើយ។ រាល់ធាតុចូលណាមួយអនុលោមតាមផ្នែកនេះ ក្រៅពីអ្វីដែលពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណធនធានវប្បធម៌កុលសម្ព័ន្ធ ត្រូវផ្តល់ក្នុងអំឡុងពេលដំណើរការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធ អនុលោមតាមផ្នែករង (d)។

(2) ក្នុងរយៈពេល 20 ថ្ងៃ បន្ទាប់ពីទទួលបានព័ត៌មានដែលបានរៀបរាប់ក្នុងកថាខណ្ឌ (1) ទីភ្នាក់ងារដឹកនាំត្រូវបញ្ចប់ការស្វែងរកកំណត់ត្រាសម្រាប់ធនធានបុរាណវិទ្យា ធនធានវប្បធម៌ និងធនធានវប្បធម៌កុលសម្ព័ន្ធ ដែលត្រូវបានកត់ត្រា និងចងក្រងជាឯកសារ នៅក្នុងតំបន់គម្រោងដែលបានស្នើឡើង និងតំបន់ដែលអាចរងផលប៉ះពាល់ (APE) ដូចដែលពាក្យនេះត្រូវបានកំណត់ន័យក្រោមផ្នែកទី 800.16 នៃចំណងជើង 36 នៃក្រមបទប្បញ្ញត្តិសហព័ន្ធ ដូចដែលបានកំណត់ដោយទីភ្នាក់ងារដឹកនាំ តាមរយៈប្រភពទាំងអស់ដូចខាងក្រោម៖

(A) ឯកសារតំបន់ដីសក្តារៈ ដែលគ្រប់គ្រងដោយគណៈកម្មការបេតិកភណ្ឌជនជាតិដើមអាមេរិក។

(B) ព័ន្ធព័ត៌មានធនធានប្រវត្តិសាស្ត្ររដ្ឋ California (CHRIS) ដែលគ្រប់គ្រងដោយការិយាល័យអភិរក្សប្រវត្តិសាស្ត្ររដ្ឋ។

(C) កំណត់ត្រារបស់ទីភ្នាក់ងារដឹកនាំ។

(3) នៅពេលបញ្ចប់ការស្វែងរកដែលតម្រូវដោយកថាខណ្ឌ (2) ទីភ្នាក់ងារដឹកនាំត្រូវផ្តល់ឱ្យកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ នូវរាល់ព័ត៌មានទាំងអស់ដែលទទួលបានអនុលោមតាមកថាខណ្ឌ (1) និង (2) ក៏ដូចជាការអញ្ជើញដើម្បីជួបប្រជុំ និងពិគ្រោះយោបល់ ដោយអនុលោមតាមកថាខណ្ឌ (4)។

(4) បន្ទាប់ពីទទួលបានព័ត៌មានដែលផ្តល់ដោយទីភ្នាក់ងារដឹកនាំអនុលោមតាមកថាខណ្ឌ (3) និងតាមការស្នើសុំរបស់កុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ នោះកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ ទីភ្នាក់ងារដឹកនាំ និងអ្នកស្នើសុំ ត្រូវជួបប្រជុំ និងពិគ្រោះយោបល់ពាក់ព័ន្ធនឹងគម្រោងចាំបាច់ដែលបានស្នើឡើង និងធនធានវប្បធម៌កុលសម្ព័ន្ធដែលបានស្គាល់ ឬបានកត់ត្រាណាមួយ ហើយកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់អាចចែករំលែកព័ត៌មានណាមួយ រួមទាំងព័ត៌មាននៅក្នុងបញ្ជីកំណត់ត្រារបស់រដ្ឋាភិបាលកុលសម្ព័ន្ធ ផងដែរ។ ក្នុងអំឡុងពេលនៃការជួបប្រជុំ និងពិគ្រោះយោបល់ ភាគីទាំងបីត្រូវកំណត់អត្តសញ្ញាណ និងវាយតម្លៃលើវិធីសាស្ត្រ វិធានការ និងលក្ខខណ្ឌនៃការចាត់ចែង និងការពារ ដើម្បីដោះស្រាយផលប៉ះពាល់ទៅលើធនធានវប្បធម៌កុលសម្ព័ន្ធ រួមទាំងការបញ្ចៀស និងការអភិរក្សនៅនឹងកន្លែង។ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយភាគីទាំងអស់ រាល់កិច្ចព្រមព្រៀងនានារវាងភាគីទាំងអស់ដែលកើតចេញពីការជួបប្រជុំ និងពិគ្រោះយោបល់ ត្រូវធ្វើឱ្យបានរួចរាល់ជាស្ថាពរ ក្នុងអំឡុងពេលដំណើរការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធ ដែលមានចែងក្នុងផ្នែករង (d)។ លទ្ធផលនៃការជួបប្រជុំ និងពិគ្រោះយោបល់ ត្រូវតែចងក្រងជាឯកសារ និងរក្សាទុកដោយទីភ្នាក់ងារដឹកនាំ ក្រោមកិច្ចព្រមព្រៀងជាមួយកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់។

(5) (A) ប្រសិនបើកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ មិនបានឆ្លើយតបទៅនឹងការអញ្ជើញសម្រាប់ការត្រួតពិនិត្យបឋម ដែលផ្តល់ដោយទីភ្នាក់ងារដឹកនាំអនុលោមតាមកថាខណ្ឌ (3) ក្នុងរយៈពេល 30 ថ្ងៃទេ ដំណើរការត្រួតពិនិត្យបឋមអនុលោមតាមផ្នែករងនេះ ត្រូវចាត់ទុកថាបានបញ្ចប់ ហើយភាគីនានាត្រូវឈានចូលទៅក្នុងដំណើរការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធ ដែលមានចែងក្នុងផ្នែករង (d)។ ការសម្រេចចិត្តរបស់កុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ ក្នុងការមិនចូលរួមជួបប្រជុំ និងពិគ្រោះយោបល់ ក្រោមដំណើរការត្រួតពិនិត្យបឋមនៅក្នុងផ្នែករងនេះ មិនត្រូវប៉ះពាល់ជាដាច់ខាតដល់លទ្ធភាព ឬសិទ្ធិរបស់កុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ ក្នុងការចូលរួមក្នុងដំណើរការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធ ដែលមានចែងក្នុងផ្នែករង (d) ឡើយ។

(B) ដំណើរការត្រួតពិនិត្យបឋមដែលបានផ្តល់នៅក្នុងផ្នែករងនេះ ត្រូវបញ្ចប់នៅពេលដែលដំណើរការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធ ដែលមានចែងក្នុងផ្នែករង (d) ចាប់ផ្តើម។

(C) ក្នុងករណីដែលដំណើរការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធដែលមានចែងក្នុងផ្នែករង (d) មិនត្រូវបានយកមកអនុវត្តទេ ដំណើរការត្រួតពិនិត្យបឋមក្រោមផ្នែករងនេះ ត្រូវបញ្ចប់នៅកាលបរិច្ឆេទនៃកិច្ចព្រមព្រៀងរបស់ភាគីនានា ដែលទទួលបានពីការជួបប្រជុំ និងពិគ្រោះយោបល់អនុលោមតាមកថាខណ្ឌ (4) ឬ 30 ថ្ងៃគិតចាប់ពីកាលបរិច្ឆេទដែលពាក្យស្នើសុំសម្រាប់គម្រោងចាំបាច់ ត្រូវបានកំណត់ថាបានពេញលេញដោយទីភ្នាក់ងារដឹកនាំ ឬត្រូវបានចាត់ទុកថាបានពេញលេញដោយអានុភាពនៃច្បាប់ អាស្រ័យលើថាតើកាលបរិច្ឆេទណាមួយកើតឡើងមុន។

45

(d) ការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធ។ ការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធសម្រាប់គម្រោងចាំបាច់ ត្រូវធ្វើឡើងអនុលោមតាមផ្នែកទី 21074, 21080.3.1, 21080.3.2, 21082.3, 21084.2 និង 21084.3 លើកលែងតែត្រូវបានកែប្រែដូចខាងក្រោម៖

(1) គោលបំណងនៃការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធ គឺដើម្បីកំណត់អត្តសញ្ញាណធនធានវប្បធម៌កុលសម្ព័ន្ធ និងវាយតម្លៃលើវិធានការនៃការចាត់ចែង និងការពារ សម្រាប់ធនធានវប្បធម៌កុលសម្ព័ន្ធទាំងនោះ រួមទាំងការអនុវត្តនូវវិធានការនៃការចាត់ចែង និងការពារទាំងនោះផងដែរ។

(2) ការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធនឹងមិនមានអត្ថន័យទេ ប្រសិនបើកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ មិនត្រូវបានផ្តល់ជូននូវព័ត៌មានបច្ចេកទេសដែលបានស្នើសុំដោយសមហេតុផល រួមមានជាអាទិ៍ ព័ត៌មានដែនកំណត់របស់គម្រោង ទិន្នន័យ ផែនទី និងព័ត៌មានពាក់ព័ន្ធនឹងសកម្មភាពគម្រោង ក្នុងកម្រិតដែលពួកវាទាក់ទងនឹងការចាត់ចែង និងការការពារធនធានវប្បធម៌កុលសម្ព័ន្ធ។ ក្នុងអំឡុងពេលនៃការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធអនុលោមតាមផ្នែករងនេះ ទីភ្នាក់ងារដឹកនាំត្រូវចូលរួមក្នុងការពិភាក្សាជាបន្តបន្ទាប់ ជាមួយកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ ពាក់ព័ន្ធនឹងការរៀបចំវិធានការកាត់បន្ថយផលប៉ះពាល់ ដែលទាក់ទងនឹងធនធានវប្បធម៌កុលសម្ព័ន្ធ រួមទាំងគោលគំនិត ឬវិធីសាស្ត្របឋម មុនពេលបោះពុម្ពផ្សាយឯកសារព្រាងផ្នែកបរិស្ថានណាមួយ។ នេះរួមបញ្ចូលទាំងការជូនដំណឹងដល់កុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ អំពីការសិក្សាបច្ចេកទេស ឬរបាយការណ៍ដែលមានស្រាប់ណាមួយ ដែលស្ថិតក្រោមការកាន់កាប់របស់ទីភ្នាក់ងារដឹកនាំ ដែលពាក់ព័ន្ធនឹងធនធានវប្បធម៌កុលសម្ព័ន្ធ ដែលស្ថិតនៅលើ ឬនៅតំបន់ជុំវិញទីតាំងគម្រោងចាំបាច់ ក្នុងកម្រិតដែលត្រូវបានអនុញ្ញាតដោយច្បាប់ស្តីពីការរក្សាការសម្ងាត់ដែលអាចអនុវត្តបាន ព្រមទាំងផ្តល់ឱ្យកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់នូវសិទ្ធិចូលមើលការសិក្សា ឬរបាយការណ៍ទាំងនោះ។ ក្នុងកម្រិតដែលឯកសារព្រាងស្តីពីការត្រួតពិនិត្យផ្នែកបរិស្ថានណាមួយ ត្រូវបានផ្តល់ទៅឱ្យអ្នកស្នើសុំ ដើម្បីពិនិត្យជាមុនមុនពេលចាប់ផ្តើមរយៈពេលទទួលមតិយោបល់ពីសាធារណជន សម្រាប់ឯកសារត្រួតពិនិត្យផ្នែកបរិស្ថាននោះ ឯកសារព្រាងនោះក៏ត្រូវផ្តល់ជូនដល់កុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ផងដែរ នៅពេលដែលវាត្រូវបានផ្តល់ទៅឱ្យអ្នកស្នើសុំ។ គ្មានចំណុចណាមួយនៅក្នុងផ្នែកនេះត្រូវបកស្រាយថាជាការតម្រូវឱ្យទីភ្នាក់ងារដឹកនាំរៀបចំ ឬចែកចាយ ឯកសារព្រាងស្តីពីការត្រួតពិនិត្យផ្នែកបរិស្ថាន សម្រាប់គោលបំណងនៃការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធឡើយ។

(3) ក្នុងករណីដែលទីភ្នាក់ងារដឹកនាំ កុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ និងអ្នកស្នើសុំ បានព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរ លើវិធានការនានាដើម្បីបញ្ចៀស ឬកាត់បន្ថយផលប៉ះពាល់ដ៏មានសារៈសំខាន់ទៅលើធនធានវប្បធម៌កុលសម្ព័ន្ធ វិធានការទាំងនោះ និងកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរណាមួយ ត្រូវក្លាយជាលក្ខខណ្ឌដែលអាចអនុវត្តតាមផ្លូវច្បាប់បាននៃការអនុម័តគម្រោង ដោយស្ថិតក្រោមលក្ខខណ្ឌតម្រូវស្តីពីការរក្សាការសម្ងាត់ ក្រោមកថាខណ្ឌ (6) នៃផ្នែករង (b)។

(e) ការចាត់ចែង និងការការពារធនធានវប្បធម៌កុលសម្ព័ន្ធ។ នៅពេលដែលអាចធ្វើទៅបាន ផលប៉ះពាល់ដែលបង្កការខូចខាតដល់ធនធានវប្បធម៌កុលសម្ព័ន្ធណាមួយ ត្រូវបញ្ចៀស។ ស្របតាមផ្នែករង (b) នៃផ្នែកទី 21014 គ្មានចំណុចណាមួយនៅក្នុងផ្នែករងនេះ ផ្លាស់ប្តូរកាតព្វកិច្ចរបស់ទីភ្នាក់ងារដឹកនាំ ក្រោមច្បាប់ CEQA ក្នុងការបញ្ចៀស ឬកាត់បន្ថយផលប៉ះពាល់ដ៏មានសារៈសំខាន់ទៅលើធនធានវប្បធម៌កុលសម្ព័ន្ធ នៅពេលដែលអាចធ្វើទៅបាននោះឡើយ។ វិធានការកាត់បន្ថយផលប៉ះពាល់ និងការចាត់ចែង ដែលត្រូវបានអនុម័តដោយមានការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ អនុលោមតាមផ្នែករងនេះ ដើម្បីបញ្ចៀស ឬកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ដ៏មានសារៈសំខាន់ទៅលើធនធានវប្បធម៌កុលសម្ព័ន្ធ ត្រូវតែស្របទៅនឹងចំណុចខាងក្រោម៖

(1) ការបញ្ចៀស និងការអភិរក្សនៅនឹងកន្លែងត្រូវយកមកពិចារណានៅពេលមានការស្នើសុំពីកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់។ ធនធានវប្បធម៌កុលសម្ព័ន្ធអាចត្រូវបានបញ្ចៀស ឬអភិរក្សនៅនឹងកន្លែង តាមរយៈការរចនាគម្រោង ការបង្កើតតំបន់ទ្រនាប់ ឬវិធានការការពារផ្សេងទៀត ដើម្បីបញ្ចៀសធនធានវប្បធម៌កុលសម្ព័ន្ធ និងការពារបរិបទវប្បធម៌និងធម្មជាតិ ឬការធ្វើផែនការតំបន់បៃតង ឧទ្យាន ឬលំហចំហផ្សេងទៀត ដើម្បីដាក់បញ្ចូលធនធានវប្បធម៌កុលសម្ព័ន្ធទាំងនោះ ដោយមានលក្ខណៈវិនិច្ឆ័យនៃការការពារ និងការគ្រប់គ្រងស្របតាមវប្បធម៌ ដែលបានយោងនៅក្នុងឯកសារបរិស្ថានរបស់គម្រោង។

(2) ប្រសិនបើគម្រោងចាំបាច់មានសក្តានុពលបង្កឱ្យមានការផ្លាស់ប្តូរអវិជ្ជមានយ៉ាងខ្លាំងដល់សារៈសំខាន់នៃធនធានវប្បធម៌កុលសម្ព័ន្ធ ហើយការបញ្ចៀស និងការអភិរក្សនៅនឹងកន្លែងមិនអាចធ្វើទៅបានទេ ទីភ្នាក់ងារដឹកនាំត្រូវបង្ហាញ និងចងក្រងជាឯកសារនូវមូលដ្ឋានសម្រាប់ការកំណត់នោះ ដោយមានភស្តុតាងសំខាន់ ហើយកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់អាចកំណត់អត្តសញ្ញាណវិធានការកាត់បន្ថយផលប៉ះពាល់ស្របតាមវប្បធម៌ ដែលទីភ្នាក់ងារដឹកនាំត្រូវពិចារណា និងដាក់បញ្ចូល ក្នុងកម្រិតដែលអាចធ្វើទៅបាន ក្នុងការរៀបចំវិធានការកាត់បន្ថយផលប៉ះពាល់ និងការចាត់ចែង ក្នុងលក្ខណៈស្របតាមកថាខណ្ឌ (2) នៃផ្នែករង (b) នៃផ្នែកទី 21084.3។

(3) នៅពេលដែលគម្រោងចាំបាច់ស្នើឡើងនូវសកម្មភាពកាយដីពាក់ព័ន្ធនឹងការសាងសង់ និងនៅពេលមានការស្នើសុំពីកុលសម្ព័ន្ធដែលត្រូវបានពិគ្រោះយោបល់ ទីភ្នាក់ងារដឹកនាំត្រូវបញ្ចូលនូវវិធានការដោះស្រាយការរកឃើញដោយចៃដន្យដើម្បីកាត់បន្ថយផលប៉ះពាល់ដ៏មានសារៈសំខាន់ទៅលើធនធានវប្បធម៌កុលសម្ព័ន្ធ។ វិធានការទាំងនោះអាចរួមបញ្ចូលនូវនីតិវិធីសម្រាប់ការផ្អាកជាបណ្តោះអាសន្ននូវការឈូសឆាយពង្រាបដី ពិធីសារកំណត់អត្តសញ្ញាណ និងការវាយតម្លៃ បទប្បញ្ញត្តិស្តីពីពេលវេលា និងវិធីសាស្ត្រនៃការចាត់ចែង ឬវិធានការការពារបន្ថែម។

(f) ការអនុម័តគម្រោងចាំបាច់។ ទីភ្នាក់ងារដឹកនាំអាចអនុម័តគម្រោងចាំបាច់ណាមួយអនុលោមតាមផ្នែកនេះបាន លុះត្រាតែចំណុចទាំងអស់ខាងក្រោមត្រូវបានបំពេញ៖

(1) ការពិគ្រោះយោបល់ជាមួយកុលសម្ព័ន្ធត្រូវបានបញ្ចប់ដោយសុឆន្ទៈ។

(2) ក្នុងករណីដែលមានការព្រមព្រៀងគ្នារវាងភាគីទាំងអស់ អនុលោមតាមកថាខណ្ឌ (4) នៃផ្នែករង (c) ឬផ្នែករង (d) រាល់វិធានការកាត់បន្ថយផលប៉ះពាល់ និងការបញ្ចៀសដែលបានព្រមព្រៀងគ្នា ត្រូវបានបញ្ចូលជាលក្ខខណ្ឌគម្រោងដែលអាចអនុវត្តតាមផ្លូវច្បាប់បាន។

(3) ប្រសិនបើការបញ្ចៀស និងការអភិរក្សនៅនឹងកន្លែង មិនអាចធ្វើទៅបានទេ ទីភ្នាក់ងារដឹកនាំបានបង្ហាញ និងចងក្រងជាឯកសារនូវមូលដ្ឋានសម្រាប់ការកំណត់នោះដោយមានភស្តុតាងសំខាន់ ហើយបានបញ្ចូលវិធានការផ្សេងទៀតដើម្បីកាត់បន្ថយផលប៉ះពាល់ជាអប្បបរមា ស្របតាមច្បាប់ CEQA។

21017. ការកំណត់ភាពពេញលេញនៃពាក្យស្នើសុំគម្រោងចាំបាច់

(a) (1) នៅពេលដែលទីភ្នាក់ងារសាធារណៈទទួលបានពាក្យស្នើសុំដំបូងសម្រាប់គម្រោងចាំបាច់ ទីភ្នាក់ងារសាធារណៈត្រូវត្រួតពិនិត្យពាក្យស្នើសុំនោះធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ថាតើពាក្យស្នើសុំនោះពេញលេញដែរឬទេ និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកស្នើសុំអំពីការកំណត់នេះ។

(2) ការកំណត់ជាលាយលក្ខណ៍អក្សរអំពីភាពពេញលេញសម្រាប់ពាក្យស្នើសុំដំបូង ត្រូវធ្វើឡើងក្នុងរយៈពេល 30 ថ្ងៃ បន្ទាប់ពីទីភ្នាក់ងារសាធារណៈទទួលបានពាក្យស្នើសុំដំបូងនោះ។ ប្រសិនបើទីភ្នាក់ងារសាធារណៈខកខានមិនបានផ្តល់ការកំណត់អំពីភាពពេញលេញ ក្នុងរយៈពេល 30 ថ្ងៃទេ នោះពាក្យស្នើសុំដំបូង ត្រូវចាត់ទុកថាបានពេញលេញ សម្រាប់គោលបំណងនៃផ្នែកនេះ។

(3) ពាក្យស្នើសុំមិនត្រូវបានកំណត់ថាមិនពេញលេញឡើយ ដោយផ្អែកលើ (A) ការសិក្សា ឬឯកសារផ្តល់ព័ត៌មាន ឬឯកសារវិភាគ ដែលមិនត្រូវបានតម្រូវដោយទីភ្នាក់ងារសាធារណៈ នៅក្នុងបញ្ជីឈ្មោះផ្នាត់លក្ខខណ្ឌតម្រូវនៃការដាក់ស្នើសុំជាលាយលក្ខណ៍អក្សរដែលផ្សព្វផ្សាយជាសាធារណៈ ឬឯកសារស្រដៀងគ្នា ដែលមានស្រាប់នៅពេលដែលពាក្យស្នើសុំដំបូងត្រូវបាន

ដាក់ស្នើសុំ ឬ (B) លក្ខន្តិក: បទប្បញ្ញត្តិ វិធាន ស្តង់ដា ឬបទបញ្ញត្តិមូលដ្ឋាន ដែលមិនមែនជាច្បាប់ដែលមានស្រាប់នោះឡើយ។

(b) ប្រសិនបើការកំណត់អំពីភាពពេញលេញរបស់ទីភ្នាក់ងារសាធារណៈ រកឃើញថាពាក្យស្នើសុំដំបូងសម្រាប់គម្រោងចាំបាច់មិនពេញលេញ នៅពេលដែលការរកឃើញនោះត្រូវបានធ្វើឡើង ទីភ្នាក់ងារសាធារណៈក៏ត្រូវផ្តល់ជូនអ្នកស្នើសុំនូវបញ្ជីកែតម្រូវជាលាយលក្ខណ៍អក្សរយ៉ាងហ្មត់ចត់ ដែលមានការពន្យល់យ៉ាងល្អិតល្អន់អំពីចំណុច និងព័ត៌មានជាក់លាក់ ឬការខ្វះខាតព័ត៌មានទាំងនោះ ដែលនាំឱ្យមានការរកឃើញពីភាពមិនពេញលេញនេះ។

(c) (1) (A) អ្នកស្នើសុំត្រូវដាក់ជូននូវព័ត៌មានបន្ថែម ឬពាក្យស្នើសុំដែលបានកែសម្រួលដែលដោះស្រាយបញ្ហាដែលបានបញ្ជាក់នៅក្នុងបញ្ជីកែតម្រូវជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល 90 ថ្ងៃបន្ទាប់ពីទទួលបានការជូនដំណឹងថាពាក្យស្នើសុំដំបូងរបស់ខ្លួនមិនពេញលេញ។

(B) ប្រសិនបើអ្នកស្នើសុំមិនអាចអនុលោមតាមកាលកំណត់ 90 ថ្ងៃ នៅក្នុងកថាខណ្ឌរង (A) ដើម្បីដាក់ជូនព័ត៌មានបន្ថែម ឬពាក្យស្នើសុំដែលបានកែសម្រួលទេ អ្នកស្នើសុំត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ទីភ្នាក់ងារសាធារណៈ អំពីមូលហេតុដែលខ្លួនមិនអាចធ្វើដូច្នេះបាន ហើយត្រូវបញ្ជូលនូវការប៉ាន់ស្មានអំពីពេលវេលាដែលខ្លួននឹង អាចធ្វើបាន។

(2) នៅពេលមានការដាក់ជូនឯកសារព័ត៌មានបន្ថែម ឬពាក្យស្នើសុំដែលបានកែសម្រួល ទីភ្នាក់ងារសាធារណៈត្រូវកំណត់ថាតើឯកសារដាក់ជូនបន្ថែមនោះមានភាពពេញលេញដែរឬទេ ដោយផ្អែកតែទៅលើបញ្ជីកែតម្រូវជាលាយលក្ខណ៍អក្សរ ដែលផ្តល់ដោយទីភ្នាក់ងារនោះ អនុលោមតាមផ្នែករង (b) ប៉ុណ្ណោះ។ ទីភ្នាក់ងារសាធារណៈត្រូវផ្តល់ការកំណត់អំពីភាពពេញលេញដោយផ្អែកលើឯកសារដាក់ជូនបន្ថែមនោះ ក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីទទួលបានឯកសារទាំងនោះ។ ប្រសិនបើទីភ្នាក់ងារសាធារណៈរកឃើញថាឯកសារដាក់ជូនបន្ថែមនៅតែមិនពេញលេញ នៅពេលដែលការរកឃើញនោះត្រូវបានធ្វើឡើង ទីភ្នាក់ងារសាធារណៈត្រូវផ្តល់ជូនអ្នកស្នើសុំនូវបញ្ជីកែតម្រូវជាលាយលក្ខណ៍អក្សរយ៉ាងហ្មត់ចត់ដែលបានធ្វើបច្ចុប្បន្នភាពថ្មី។ បញ្ជីកែតម្រូវជាលាយលក្ខណ៍អក្សរដែលបានធ្វើបច្ចុប្បន្នភាព អាចមានតែចំណុចនានាដែលត្រូវបានរួមបញ្ចូលនៅក្នុងបញ្ជីកែតម្រូវជាលាយលក្ខណ៍អក្សរ ដែលបានផ្តល់ជូនជាការឆ្លើយតបទៅនឹងពាក្យសុំដំបូងរបស់អ្នកស្នើសុំប៉ុណ្ណោះ។

(3) ប្រសិនបើការដាក់ស្នើព័ត៌មានបំពេញបន្ថែមត្រូវបានចាត់ទុកថាមិនពេញលេញម្តងទៀត អ្នកស្នើសុំអាចដាក់ស្នើព័ត៌មានបំពេញបន្ថែមជាបន្តបន្ទាប់ ឬពាក្យសុំដែលបានកែសម្រួលបន្ថែមទៀត ដោយអនុលោមតាមនីតិវិធី និងកាលវិភាគដែលមានចែងនៅក្នុងផ្នែករងនេះ។

(4) ប្រសិនបើទីភ្នាក់ងារសាធារណៈខកខានក្នុងការកំណត់ភាពពេញលេញក្នុងរយៈពេល 30 ថ្ងៃ បន្ទាប់ពីទទួលបានព័ត៌មានបំពេញបន្ថែម ឬពាក្យសុំដែលបានកែសម្រួលដោយអនុលោមតាមកថាខណ្ឌ (2) ឬ (3) នោះពាក្យសុំនោះត្រូវចាត់ទុកថាពេញលេញ សម្រាប់គោលបំណងនៃផ្នែកនេះ។

(5) ទីភ្នាក់ងារសាធារណៈមិនត្រូវស្នើសុំ ឬតម្រូវឱ្យអ្នកស្នើសុំផ្តល់ព័ត៌មានថ្មីណាមួយឡើយ លើកលែងតែព័ត៌មាននោះត្រូវបានរួមបញ្ចូលនៅក្នុងបញ្ជីកែតម្រូវជាលាយលក្ខណ៍អក្សរយ៉ាងហ្មត់ចត់ សម្រាប់កំណែមុនភ្លាមៗនៃពាក្យសុំ។

(d) (1) ការកំណត់ភាពពេញលេញដែលរកឃើញថា ពាក្យសុំដំបូង ពាក្យសុំដែលបានបំពេញបន្ថែម ឬពាក្យសុំដែលបានកែសម្រួលមិនពេញលេញ ត្រូវអាចប្តឹងឧទ្ធរណ៍ដោយអ្នកស្នើសុំទៅកាន់គណៈកម្មការរៀបចំផែនការ នាយករៀបចំផែនការ ឬមន្ត្រីផ្សេងទៀតរបស់ទីភ្នាក់ងារសាធារណៈដែលមានសិទ្ធិអំណាចចុងក្រោយលើភាពពេញលេញនៃពាក្យសុំ។ ប្រសិនបើទីភ្នាក់ងារសាធារណៈមិនមានគណៈកម្មការរៀបចំផែនការ នាយករៀបចំផែនការ ឬមន្ត្រីផ្សេងទៀតដែលមានសិទ្ធិអំណាចចុងក្រោយលើភាពពេញលេញនៃពាក្យសុំទេ នោះបណ្តឹងឧទ្ធរណ៍ត្រូវស្តាប់ដោយស្ថាប័នសម្រេចចិត្ត ឬមន្ត្រីដែលមានឋានៈខ្ពស់បំផុត ដែលត្រូវបានបោះឆ្នោតជ្រើសរើស ឬតែងតាំងរបស់ទីភ្នាក់ងារ។ ត្រូវតែមានការកំណត់ជាលាយលក្ខណ៍អក្សរចុងក្រោយលើបណ្តឹងឧទ្ធរណ៍យ៉ាងយូរ 60 ថ្ងៃ បន្ទាប់ពីទទួលបានបណ្តឹងឧទ្ធរណ៍ជាលាយលក្ខណ៍អក្សររបស់អ្នកស្នើសុំ។

(2) ប្រសិនបើការកំណត់ជាលាយលក្ខណ៍អក្សរចុងក្រោយលើបណ្តឹងឧទ្ធរណ៍មិនត្រូវបានធ្វើឡើងក្នុងរយៈពេល 60 ថ្ងៃ ដូចដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ (1) ទេ នោះពាក្យសុំនោះត្រូវចាត់ទុកថាពេញលេញ សម្រាប់គោលបំណងនៃផ្នែកនេះ។

(e) អ្នកស្នើសុំអាចលើកបណ្តឹងរដ្ឋប្បវេណី ដើម្បីតវ៉ានឹងការកំណត់អវិជ្ជមានក្រោមផ្នែករង (d)។ បណ្តឹងណាមួយត្រូវតែចាប់ផ្តើមក្នុងរយៈពេល 90 ថ្ងៃ គិតចាប់ពីការកំណត់ជាលាយលក្ខណ៍អក្សរចុងក្រោយអវិជ្ជមាន ដែលចេញដោយអនុលោមតាមផ្នែករង (d)។

ប្រការ 4. ការពិនិត្យមើលពាក្យសុំដែលពេញលេញ សម្រាប់គម្រោងចាំបាច់

21018. កាលវិភាគរបស់ទីភ្នាក់ងារមូលដ្ឋានសម្រាប់ការបញ្ចប់ការត្រួតពិនិត្យបរិស្ថាននៃគម្រោងចាំបាច់

(a) ទីភ្នាក់ងារមូលដ្ឋានដែលដើរតួជាទីភ្នាក់ងារដឹកនាំ (ទីភ្នាក់ងារដឹកនាំមូលដ្ឋាន) សម្រាប់ពាក្យសុំ ឬការអនុម័តគម្រោងចាំបាច់ ត្រូវសម្រេចថាតើគម្រោងនោះស្ថិតនៅក្រោមផ្នែករង (b), (c) ឬ (d) ក្នុងរយៈពេល 30 ថ្ងៃ គិតចាប់ពីពេលដែលពាក្យសុំគម្រោងចាំបាច់ត្រូវបានកំណត់ ឬចាត់ទុកថាពេញលេញដោយអនុលោមតាមផ្នែកទី 21017 ឬចាត់ទុកថាពេញលេញដោយអនុលោមតាមច្បាប់ផ្សេងទៀត អាស្រ័យលើថាតើមួយណាកើតឡើងមុន។

(b) គម្រោងចាំបាច់ដែលតម្រូវឱ្យមានរបាយការណ៍អំពីផលប៉ះពាល់បរិស្ថាន។ សម្រាប់គម្រោងចាំបាច់ដែលតម្រូវឱ្យមានរបាយការណ៍អំពីផលប៉ះពាល់បរិស្ថាន ទីភ្នាក់ងារដឹកនាំមូលដ្ឋានត្រូវធ្វើការកំណត់ចុងក្រោយថាតើត្រូវបញ្ចាក់សុពលភាពរបាយការណ៍អំពីផលប៉ះពាល់បរិស្ថានយ៉ាងយូរ 365 ថ្ងៃ បន្ទាប់ពីពាក្យសុំគម្រោងចាំបាច់ត្រូវបានកំណត់ ឬចាត់ទុកថាពេញលេញដោយអនុលោមតាមផ្នែកទី 21017 ឬចាត់ទុកថាពេញលេញដោយអនុលោមតាមច្បាប់ផ្សេងទៀត អាស្រ័យលើថាតើមួយណាកើតឡើងមុន។

(c) គម្រោងចាំបាច់ដែលតម្រូវឱ្យមានសេចក្តីប្រកាសអវិជ្ជមាន ឬសេចក្តីប្រកាសអវិជ្ជមានដែលមានវិធានការកាត់បន្ថយផលប៉ះពាល់។ សម្រាប់គម្រោងចាំបាច់ដែលតម្រូវឱ្យមានសេចក្តីប្រកាសអវិជ្ជមាន ឬសេចក្តីប្រកាសអវិជ្ជមានដែលមានវិធានការកាត់បន្ថយផលប៉ះពាល់ ទីភ្នាក់ងារដឹកនាំមូលដ្ឋានត្រូវធ្វើការកំណត់ចុងក្រោយថាតើត្រូវអនុម័តសេចក្តីប្រកាសអវិជ្ជមាន ឬសេចក្តីប្រកាសអវិជ្ជមានដែលមានវិធានការកាត់បន្ថយផលប៉ះពាល់ យ៉ាងយូរ 180 ថ្ងៃ បន្ទាប់ពីពាក្យសុំគម្រោងចាំបាច់ត្រូវបានកំណត់ ឬចាត់ទុកថាពេញលេញដោយអនុលោមតាមផ្នែកទី 21017 ឬចាត់ទុកថាពេញលេញដោយអនុលោមតាមច្បាប់ផ្សេងទៀត អាស្រ័យលើថាតើមួយណាកើតឡើងមុន។

(d) សម្រាប់រាល់ឯកសារត្រួតពិនិត្យបរិស្ថានផ្សេងទៀតទាំងអស់ដែលបានរៀបចំឡើងដោយអនុលោមតាមផ្នែកនេះ សម្រាប់ពាក្យសុំ ឬការអនុម័តគម្រោងចាំបាច់ ទីភ្នាក់ងារដឹកនាំមូលដ្ឋានត្រូវធ្វើការកំណត់ចុងក្រោយក្នុងរយៈពេល 90 ថ្ងៃ បន្ទាប់ពីពាក្យសុំគម្រោងចាំបាច់ត្រូវបានកំណត់ ឬចាត់ទុកថាពេញលេញដោយអនុលោមតាមផ្នែកទី 21017 ឬចាត់ទុកថាពេញលេញដោយអនុលោមតាមច្បាប់ផ្សេងទៀត អាស្រ័យលើថាតើមួយណាកើតឡើងមុន ថាគម្រោងចាំបាច់ត្រូវបានលើកលែងពីផ្នែកនេះ ឬថាផលប៉ះពាល់របស់គម្រោងចាំបាច់ត្រូវបានវាយតម្លៃរួចហើយក្រោមឯកសារត្រួតពិនិត្យបរិស្ថានមុនៗ ដោយអនុលោមតាម ប៉ុន្តែមិនកំណត់ត្រឹម ផ្នែកទី 21083.3 ឬ 21094.5 ឬឧបសម្ព័ន្ធបន្ថែម ដោយអនុលោមតាមផ្នែកទី 15162 ឬ 15164 នៃ ចំណងជើង 14 នៃក្រមបទប្បញ្ញត្តិរដ្ឋ California។

(e) កាលកំណត់ដែលមានចែងក្នុងផ្នែករង (b), (c) និង (d) ត្រូវតែពន្យារពេលតាមការស្នើសុំជាលាយលក្ខណ៍អក្សរពីអ្នកស្នើសុំ។

21019. កាលវិភាគសម្រាប់ការបញ្ចប់ការត្រួតពិនិត្យបរិស្ថាននៃគម្រោងចាំបាច់ ដោយទីភ្នាក់ងារសាធារណៈដែលមិនមែនជាទីភ្នាក់ងារមូលដ្ឋាន

(a) ទីភ្នាក់ងារសាធារណៈក្រៅពីទីភ្នាក់ងារមូលដ្ឋាន ដែលដើរតួជាទីភ្នាក់ងារដឹកនាំ (ទីភ្នាក់ងារដឹកនាំមិនមែនមូលដ្ឋាន) សម្រាប់គម្រោងចាំបាច់ ត្រូវសម្រេចថាតើគម្រោងនោះស្ថិតនៅក្រោមផ្នែករង (b), (c) ឬ (d) ក្នុងរយៈពេល 30 ថ្ងៃ គិតចាប់ពីពេលដែលពាក្យសុំគម្រោងចាំបាច់ត្រូវបានកំណត់ ឬចាត់ទុកថាពេញលេញដោយអនុលោមតាមផ្នែកទី 21017 ឬចាត់ទុកថាពេញលេញដោយអនុលោមតាមច្បាប់ផ្សេងទៀត អាស្រ័យលើថាតើមួយណាកើតឡើងមុន។

(b) គម្រោងចាំបាច់ដែលតម្រូវឱ្យមានរបាយការណ៍អំពីផលប៉ះពាល់បរិស្ថាន។ សម្រាប់គម្រោងចាំបាច់ដែលតម្រូវឱ្យមានរបាយការណ៍អំពីផលប៉ះពាល់បរិស្ថាន ទីភ្នាក់ងារដឹកនាំមិនមែនមូលដ្ឋានត្រូវធ្វើការកំណត់ចុងក្រោយថាតើត្រូវបញ្ជាក់សុពលភាពរបាយការណ៍អំពីផលប៉ះពាល់បរិស្ថានយ៉ាងយូរ 365 ថ្ងៃ បន្ទាប់ពីពាក្យសុំគម្រោងចាំបាច់ត្រូវបានកំណត់ ឬចាត់ទុកថាពេញលេញដោយអនុលោមតាមផ្នែកទី 21017 ឬចាត់ទុកថាពេញលេញដោយអនុលោមតាមច្បាប់ផ្សេងទៀត អាស្រ័យលើថាតើមួយណាកើតឡើងមុន។

(c) គម្រោងចាំបាច់ដែលតម្រូវឱ្យមានសេចក្តីប្រកាសអវិជ្ជមាន ឬសេចក្តីប្រកាសអវិជ្ជមានដែលមានវិធានការកាត់បន្ថយផលប៉ះពាល់។ សម្រាប់គម្រោងចាំបាច់ដែលតម្រូវឱ្យមានសេចក្តីប្រកាសអវិជ្ជមាន ឬសេចក្តីប្រកាសអវិជ្ជមានដែលមានវិធានការកាត់បន្ថយផលប៉ះពាល់ ទីភ្នាក់ងារដឹកនាំមិនមែនមូលដ្ឋានត្រូវធ្វើការកំណត់ចុងក្រោយថាតើត្រូវអនុម័តសេចក្តីប្រកាសអវិជ្ជមាន ឬសេចក្តីប្រកាសអវិជ្ជមានដែលមានវិធានការកាត់បន្ថយផលប៉ះពាល់ យ៉ាងយូរ 180 ថ្ងៃ បន្ទាប់ពីពាក្យសុំគម្រោងចាំបាច់ត្រូវបានកំណត់ ឬចាត់ទុកថាពេញលេញដោយអនុលោមតាមផ្នែកទី 21017 ឬចាត់ទុកថាពេញលេញដោយអនុលោមតាមច្បាប់ផ្សេងទៀត អាស្រ័យលើថាតើមួយណាកើតឡើងមុន។

(d) សម្រាប់រាល់ឯកសារត្រួតពិនិត្យបរិស្ថានផ្សេងទៀតទាំងអស់ដែលបានរៀបចំឡើងដោយអនុលោមតាមផ្នែកនេះ សម្រាប់ពាក្យសុំ ឬការអនុម័តគម្រោងចាំបាច់ ទីភ្នាក់ងារដឹកនាំមិនមែនមូលដ្ឋានត្រូវធ្វើការកំណត់ចុងក្រោយក្នុងរយៈពេល 90 ថ្ងៃ បន្ទាប់ពីពាក្យសុំគម្រោងចាំបាច់ត្រូវបានកំណត់ ឬចាត់ទុកថាពេញលេញដោយអនុលោមតាមផ្នែកទី 21017 ឬចាត់ទុកថាពេញលេញដោយអនុលោមតាមច្បាប់ផ្សេងទៀត អាស្រ័យលើថាតើមួយណាកើតឡើងមុន ថាគម្រោងចាំបាច់ត្រូវបានលើកលែងពីផ្នែកនេះ ឬថាផលប៉ះពាល់របស់គម្រោងចាំបាច់ត្រូវបានវាយតម្លៃរួចហើយក្រោមឯកសារត្រួតពិនិត្យបរិស្ថានមុនៗ ដោយអនុលោមតាម ប៉ុន្តែមិនកំណត់ត្រឹម ផ្នែកទី 21083.3 ឬ 21094.5 ឬឧបសម្ព័ន្ធបន្ថែម ដោយអនុលោមតាមផ្នែកទី 15162 ឬ 15164 នៃ ចំណងជើង 14 នៃក្រមបទប្បញ្ញត្តិរដ្ឋ California។

(e) កាលកំណត់ដែលមានចែងក្នុងផ្នែករង (b), (c) និង (d) ត្រូវតែពន្យារពេលតាមការស្នើសុំជាលាយលក្ខណ៍អក្សរពីអ្នកស្នើសុំ។

21020. ការមិនអនុលោមតាមកាលកំណត់សម្រាប់ការបញ្ចប់ការត្រួតពិនិត្យបរិស្ថាននៃគម្រោងចាំបាច់

(a) នៅពេលទីភ្នាក់ងារដឹកនាំមូលដ្ឋាន ឬទីភ្នាក់ងារដឹកនាំមិនមែនមូលដ្ឋានខកខានក្នុងការអនុលោមតាមកាលកំណត់ដែលមានចែងក្នុងផ្នែករង (b) ដល់ (d) រួមបញ្ចូល នៃផ្នែកទី 21018 ឬផ្នែករង (b) ដល់ (d) រួមបញ្ចូល នៃផ្នែកទី 21019 អ្នកស្នើសុំអាចស្នើសុំជាលាយលក្ខណ៍អក្សរឱ្យទីភ្នាក់ងារៀបចំកិច្ចប្រជុំ ឬសវនាការអំពីគម្រោងចាំបាច់ ដូចមានចែងក្នុងផ្នែកនេះ។

(b) ក្នុងរយៈពេល 60 ថ្ងៃ បន្ទាប់ពីទទួលបានការស្នើសុំជាលាយលក្ខណ៍អក្សរ ដោយអនុលោមតាមផ្នែករង (a) ទីភ្នាក់ងារដឹកនាំមូលដ្ឋាន ឬទីភ្នាក់ងារដឹកនាំមិនមែនមូលដ្ឋានត្រូវធ្វើចំណុចទាំងអស់ដូចខាងក្រោម៖

(1) បំពេញឯកសារត្រួតពិនិត្យបរិស្ថានទាំងអស់សម្រាប់គម្រោងចាំបាច់ ឬប្រមូលផ្តុំឯកសារត្រួតពិនិត្យបរិស្ថានដែលមានស្រាប់ រួមទាំងឯកសារត្រួតពិនិត្យបរិស្ថានដែលបានរៀបចំដោយអ្នកស្នើសុំ តាមដែលត្រូវបានអនុញ្ញាតដោយអនុលោមតាមផ្នែករង (b) នៃផ្នែកទី 21082.1 ឬច្បាប់ផ្សេងទៀត។

(2) រៀបចំកិច្ចប្រជុំ ឬសវនាការលើពាក្យសុំគម្រោងចាំបាច់ ដូចខាងក្រោម៖

(A) ប្រសិនបើទីភ្នាក់ងារមានស្ថាប័នសម្រេចចិត្តដែលមានសមាជិកច្រើនដែលស្ថិតនៅក្រោមច្បាប់ស្តីពីកិច្ចប្រជុំបើកចំហ Bagley-Keene (ប្រការ 9 (ចាប់ផ្តើមជាមួយផ្នែកទី 11120) នៃជំពូកទី 1 នៃភាគទី 1 នៃផ្នែកទី 3 នៃចំណងជើងទី 2 នៃក្រមរដ្ឋាភិបាល) ច្បាប់ Ralph M. Brown (ជំពូកទី 9 (ចាប់ផ្តើមជាមួយផ្នែកទី 54950) នៃភាគទី 1 នៃផ្នែកទី 2 នៃចំណងជើងទី 5 នៃក្រមរដ្ឋាភិបាល) ឬច្បាប់កិច្ចប្រជុំបើកចំហស្រដៀងគ្នានេះ ទីភ្នាក់ងារត្រូវដាក់គម្រោងចាំបាច់នៅក្នុងរបៀបវារៈរបស់ខ្លួនសម្រាប់កិច្ចប្រជុំជាប្រចាំ ឬកិច្ចប្រជុំពិសេសរបស់ស្ថាប័នសម្រេចចិត្តជាន់ខ្ពស់បំផុតរបស់ទីភ្នាក់ងារ។

(B) ប្រសិនបើទីភ្នាក់ងារមិនមានស្ថាប័នសម្រេចចិត្តដែលមានសមាជិកច្រើន ដែលស្ថិតនៅក្រោមច្បាប់ស្តីពីកិច្ចប្រជុំបើកចំហ Bagley-Keene, ច្បាប់ Ralph M. Brown ឬច្បាប់កិច្ចប្រជុំបើកចំហស្រដៀងគ្នានេះទេ នោះមន្ត្រីជាន់ខ្ពស់បំផុតរបស់ទីភ្នាក់ងារ ឬតំណាងរបស់ខ្លួន ត្រូវរៀបចំសវនាការជាមួយអ្នកស្នើសុំអំពីគម្រោងចាំបាច់។

(3) ទោះបីជាមានបទប្បញ្ញត្តិផ្សេងទៀតនៃផ្នែកនេះ ឬច្បាប់ផ្សេងទៀតក៏ដោយ នៅឯកិច្ចប្រជុំ ឬសវនាការដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ (2) ទីភ្នាក់ងារត្រូវធ្វើចំណុចទាំងពីរដូចខាងក្រោម៖

(A) ធ្វើការកំណត់ជាលាយលក្ខណ៍អក្សរចុងក្រោយលើឯកសារត្រួតពិនិត្យបរិស្ថានដែលមានស្រាប់ ដែលត្រូវបានបំពេញរួចរាល់គិតត្រឹមកាលបរិច្ឆេទនៃកិច្ចប្រជុំ ឬសវនាការ។

(B) ធ្វើការកំណត់ជាលាយលក្ខណ៍អក្សរចុងក្រោយដើម្បីអនុម័ត ឬមិនអនុម័តគម្រោងចាំបាច់។

(c) (1) ប្រសិនបើទីភ្នាក់ងារដឹកនាំមូលដ្ឋាន ឬទីភ្នាក់ងារដឹកនាំមិនមែនមូលដ្ឋានមានគណៈកម្មការរៀបចំផែនការ ឬនាយករៀបចំផែនការ នៅពេលទទួលបានការស្នើសុំជាលាយលក្ខណ៍អក្សរ ដោយអនុលោមតាមផ្នែករង (a) គណៈកម្មការរៀបចំផែនការ ឬនាយករៀបចំផែនការត្រូវរៀបចំកិច្ចប្រជុំជាប្រចាំ ឬកិច្ចប្រជុំពិសេស ក្នុងគោលបំណងផ្តល់អនុសាសន៍អំពីគម្រោងចាំបាច់។

(2) កិច្ចប្រជុំរបស់គណៈកម្មការរៀបចំផែនការ ឬនាយករៀបចំផែនការ ដែលបានពិពណ៌នានៅក្នុងផ្នែករងនេះ ត្រូវធ្វើឡើងក្នុងរយៈពេល 30 ថ្ងៃ បន្ទាប់ពីទទួលបានការស្នើសុំជាលាយលក្ខណ៍អក្សរ ដោយអនុលោមតាមផ្នែករង (a)។

(3) ឯកសារត្រួតពិនិត្យបរិស្ថានណាមួយដែលចាំបាច់សម្រាប់កិច្ចប្រជុំដែលបានពិពណ៌នានៅក្នុងផ្នែករងនេះ ត្រូវតែបំពេញជាមុន មុនកាលបរិច្ឆេទនៃកិច្ចប្រជុំ ដូចដែលបានតម្រូវដោយច្បាប់។

(d) កាលកំណត់ដែលមានចែងក្នុងផ្នែករង (b) និង (c) ត្រូវតែពន្យារពេលតែតាមការស្នើសុំជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយអ្នកស្នើសុំប៉ុណ្ណោះ។

(e) លើកលែងតែមានចែងនៅក្នុងផ្នែករង (f) ទីភ្នាក់ងារដឹកនាំមូលដ្ឋាន និងទីភ្នាក់ងារដឹកនាំមិនមែនមូលដ្ឋានមានភារកិច្ចរដ្ឋបាលដែលមិនមានឆន្ទានុសិទ្ធិ ក្នុងការអនុលោមតាមកាលកំណត់ដែលមានចែងនៅក្នុងផ្នែកនេះ ឬនៅក្នុងការស្នើសុំជាលាយលក្ខណ៍អក្សរណាមួយដែលធ្វើឡើងដោយអនុលោម

តាមផ្នែករង (d) និងបំពេញសកម្មភាពនានាដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ (3) នៃផ្នែករង (b)។

(f) ប្រសិនបើ មុនពេលផុតកំណត់នៃរយៈពេល 60 ថ្ងៃដែលមានចែងក្នុងផ្នែករង (b) ទីភ្នាក់ងារបំពេញឯកសារត្រួតពិនិត្យបរិស្ថានទាំងអស់សម្រាប់គម្រោងចាំបាច់ ហើយចេញការកំណត់ជាលាយលក្ខណ៍អក្សរចុងក្រោយដើម្បីអនុម័តគម្រោងចាំបាច់ ទីភ្នាក់ងារ និងអ្នកស្នើសុំអាចយល់ព្រមគ្នាជាលាយលក្ខណ៍អក្សរដើម្បីលុបចោលកិច្ចប្រជុំ ឬសវនាការលើគម្រោងចាំបាច់ដែលតម្រូវដោយកថាខណ្ឌ (2) នៃផ្នែករង (b)។

(g) (1) អ្នកស្នើសុំអាចលើកបណ្តឹងក្រោមផ្នែកនេះ ដើម្បីតវ៉ានឹងមួយក្នុងចំណោមចំណុចទាំងពីរដូចខាងក្រោម៖

(A) ការខកខានរបស់ទីភ្នាក់ងារក្នុងការអនុលោមតាមភារកិច្ចរដ្ឋបាលដែលមិនមានឆន្ទានុសិទ្ធិរបស់ខ្លួន ដែលបានពិពណ៌នានៅក្នុងផ្នែករង (e)។

(B) ការបដិសេធរបស់ទីភ្នាក់ងារ ឬការដាក់លក្ខខណ្ឌនៃការអនុម័តដោយខុសច្បាប់លើគម្រោងចាំបាច់។

(2) បណ្តឹងត្រូវតែចាប់ផ្តើមក្នុងរយៈពេល 90 ថ្ងៃ គិតចាប់ពីការខកខាន ការបដិសេធ ឬការដាក់លក្ខខណ្ឌរបស់ទីភ្នាក់ងារ ដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ (1)។

(h) ទោះបីជាមានបទប្បញ្ញត្តិផ្សេងទៀតនៃផ្នែកនេះ ផ្នែកទី 21018 ឬផ្នែកទី 21019 ក៏ដោយ នៅពេលដែលទីភ្នាក់ងារដឹកនាំសម្រាប់គម្រោងចាំបាច់ ក៏ជាអ្នកស្នើសុំសម្រាប់គម្រោងចាំបាច់នោះដែរ ទីភ្នាក់ងារដឹកនាំអាចពន្យារកាលកំណត់ណាមួយដែលមានចែងក្នុងផ្នែកនេះ ផ្នែកទី 21018 ឬផ្នែកទី 21019 តាមរយៈសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដែលបញ្ជាក់ពីរយៈពេលនៃការពន្យារ និងមូលហេតុសម្រាប់ការពន្យារនោះ។ សេចក្តីជូនដំណឹងត្រូវបង្ហោះនៅលើគេហទំព័រអ៊ីនធឺណិតរបស់ទីភ្នាក់ងារដឹកនាំ និងដាក់បញ្ចូលក្នុងកំណត់ត្រារដ្ឋបាល។

21021. កាលវិភាគសម្រាប់មតិយោបល់សាធារណៈលើគម្រោងចាំបាច់

(a) ទីភ្នាក់ងារសាធារណៈត្រូវផ្សព្វផ្សាយឯកសារត្រួតពិនិត្យបរិស្ថានសម្រាប់គម្រោងចាំបាច់ ដើម្បីឱ្យមានរយៈពេលសម្រាប់យោបល់សាធារណៈដូចខាងក្រោម៖

(1) ម្ភៃថ្ងៃ សម្រាប់សេចក្តីប្រកាសអវិជ្ជមាន ឬសេចក្តីប្រកាសអវិជ្ជមានដែលមានវិធានការកាត់បន្ថយផលប៉ះពាល់ ឬឯកសារផ្សេងទៀតដែលតម្រូវឱ្យមានការផ្សព្វផ្សាយជាសាធារណៈក្រោមច្បាប់រដ្ឋ។

(2) សែសិបប្រាំថ្ងៃ សម្រាប់សេចក្តីព្រាងរបាយការណ៍អំពីផលប៉ះពាល់បរិស្ថាន ឬរបាយការណ៍អំពីផលប៉ះពាល់បរិស្ថានបន្តបន្ទាប់ ឬរបាយការណ៍អំពីផលប៉ះពាល់បរិស្ថានបំពេញបន្ថែម។

(b) រយៈពេលសម្រាប់យោបល់សាធារណៈដែលបានពិពណ៌នានៅក្នុងផ្នែករង (a) មិនត្រូវផ្អាក ឬពន្យារឡើយ លើកលែងតែដោយតុលាការដែលមានយុត្តាធិការត្រឹមត្រូវ។

(c) ប្រសិនបើទីភ្នាក់ងារសាធារណៈបន្តសវនាការសាធារណៈណាមួយលើគម្រោងសំខាន់ចាំបាច់ ឬការត្រួតពិនិត្យ CEQA នៃគម្រោងសំខាន់ចាំបាច់នោះ ទីភ្នាក់ងារសាធារណៈត្រូវបន្តសវនាការទៅកាលបរិច្ឆេទជាក់លាក់មួយ ហើយនៅពេលអនុម័តការបន្តសវនាការ ត្រូវបិទរយៈពេលសម្រាប់យោបល់សាធារណៈ។ ទីភ្នាក់ងារសាធារណៈមិនត្រូវបើករយៈពេលសម្រាប់យោបល់សាធារណៈឡើងវិញនៅសវនាការបន្តបន្ទាប់ណាមួយលើគម្រោងសំខាន់ចាំបាច់នោះឡើយ។

(d) (1) ទោះបីជាមានច្បាប់ផ្សេងទៀតក៏ដោយ មានតែមតិយោបល់ដូចខាងក្រោមប៉ុណ្ណោះដែលត្រូវដាក់បញ្ចូលក្នុងកំណត់ត្រារដ្ឋបាលសម្រាប់គម្រោងសំខាន់ចាំបាច់៖

(A) មតិយោបល់តាមប្រព័ន្ធអេឡិចត្រូនិក និងជាលាយលក្ខណ៍អក្សរដែលទទួលបានក្នុងអំឡុងរយៈពេលសម្រាប់យោបល់សាធារណៈដែលមានចែងក្នុងផ្នែករង (a)។

(B) សម្រាប់ការកំណត់របស់ CEQA ដែលមិនមានរយៈពេលផ្តល់មតិយោបល់ដូចមានចែងក្នុងផ្នែករង (a) មតិយោបល់តាមប្រព័ន្ធអេឡិចត្រូនិក និងជាលាយលក្ខណ៍អក្សរដែលទទួលបានយ៉ាងហោចណាស់ 48 ម៉ោងមុនសវនាការសាធារណៈ ឬការសម្រេចចិត្តដែលបានជូនដំណឹងអំពីឯកសារត្រួតពិនិត្យបរិស្ថានសម្រាប់គម្រោងសំខាន់ចាំបាច់។

(C) (i) សម្រាប់សវនាការ ឬបណ្តឹងឧទ្ធរណ៍លើការកំណត់របស់ CEQA មតិយោបល់តាមប្រព័ន្ធអេឡិចត្រូនិក និងជាលាយលក្ខណ៍អក្សរដែលទទួលបានយ៉ាងហោចណាស់ 48 ម៉ោងមុនសវនាការសាធារណៈ លើបញ្ហាដែលមិនអាចលើកឡើងក្នុងអំឡុងរយៈពេលសម្រាប់យោបល់សាធារណៈដែលមានចែងក្នុងផ្នែករង (a) ដោយសារការផ្លាស់ប្តូរយ៉ាងសំខាន់ចំពោះគម្រោងសំខាន់ចាំបាច់ ដែលរារាំងមិនឱ្យលើកឡើងបញ្ហានោះក្នុងអំឡុងរយៈពេលសម្រាប់យោបល់សាធារណៈ ឬព័ត៌មានថ្មីដែលមិនត្រូវបានដឹង និងមិនអាចត្រូវបានដឹងក្នុងអំឡុងរយៈពេលសម្រាប់យោបល់សាធារណៈ។

(ii) "ការផ្លាស់ប្តូរយ៉ាងសំខាន់ចំពោះគម្រោងសំខាន់ចាំបាច់" មិនរួមបញ្ចូលការផ្លាស់ប្តូរណាមួយចំពោះគម្រោងសំខាន់ចាំបាច់ដែលធ្វើឡើងជាការឆ្លើយតបទៅនឹងមតិយោបល់សាធារណៈ តាមរយៈដំណើរការត្រួតពិនិត្យជម្រើសរបស់ CEQA ឬតាមរយៈកង្វល់របស់ទីភ្នាក់ងារទទួលបន្ទុកដែលបានកំណត់ក្នុងអំឡុងពេលដំណើរការ CEQA នោះឡើយ។

(D) សក្តីកម្មផ្ទាល់មាត់នៅសវនាការសាធារណៈដែលបានជូនដំណឹង និងបានកត់ត្រាទុក។

(2) មតិយោបល់សាធារណៈផ្សេងទៀតទាំងអស់ត្រូវមិនយកមកពិចារណា និងផាត់ចេញពីកំណត់ត្រារដ្ឋបាល។

(e) ទោះបីជាមានច្បាប់ផ្សេងទៀតក៏ដោយ ការឆ្លើយតបរបស់ទីភ្នាក់ងារទទួលបន្ទុក ឬអ្នកដាក់ពាក្យសុំចំពោះមតិយោបល់ដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ (1) នៃផ្នែករង (d) ឬមតិយោបល់ពីអ្នកដាក់ពាក្យសុំជាការឆ្លើយតបទៅនឹងសំណួររបស់ទីភ្នាក់ងារសាធារណៈ ឬដើម្បីបង្ហាញពីការអនុលោមតាមផ្នែកនេះរបស់គម្រោងសំខាន់ចាំបាច់ ត្រូវដាក់បញ្ចូលក្នុងកំណត់ត្រារដ្ឋបាលសម្រាប់គម្រោងសំខាន់ចាំបាច់ដោយគ្មានលក្ខខណ្ឌ។

21022. ការកំណត់អំពីផលប៉ះពាល់

ទោះបីជាមានច្បាប់ផ្សេងទៀតក៏ដោយ៖

(a) (1) ទីភ្នាក់ងារសាធារណៈដែលកំពុងពិចារណាថាតើត្រូវអនុម័តគម្រោងសំខាន់ចាំបាច់ឬទេ ត្រូវកំណត់អត្តសញ្ញាណ វាយតម្លៃ កំណត់សារសំខាន់ និងកាត់បន្ថយផលប៉ះពាល់នៃគម្រោងសំខាន់ចាំបាច់ ដោយផ្អែកលើការអនុលោមតាមច្បាប់ដែលមានស្រាប់។

(2) ក្នុងកម្រិតដែលទីភ្នាក់ងារសាធារណៈបានបោះពុម្ពផ្សាយ អនុម័ត ឬប្រើប្រាស់ជាប្រចាំនូវកម្រិតសារសំខាន់សម្រាប់ផលប៉ះពាល់បរិស្ថាននៃគម្រោងសំខាន់ចាំបាច់ នៅកាលបរិច្ឆេទដែលពាក្យសុំបឋម ឬពាក្យសុំសម្រាប់គម្រោងសំខាន់ចាំបាច់ត្រូវបានដាក់ អាស្រ័យលើថាតើមួយណាកើតឡើងមុន អ្នកដាក់ពាក្យសុំអាចជ្រើសរើសឱ្យកម្រិតសារសំខាន់ទាំងនោះចូលជាប់សុពលភាពចំពោះគម្រោងរបស់ខ្លួន ក្នុងករណីនេះ ទីភ្នាក់ងារសាធារណៈត្រូវប្រើកម្រិតទាំងនោះក្នុងការកំណត់សារសំខាន់នៃផលប៉ះពាល់បរិស្ថានរបស់គម្រោងសំខាន់ចាំបាច់។

(b) ការអនុលោមរបស់គម្រោងសំខាន់ចាំបាច់តាមផ្នែកនេះ និងគោលការណ៍ណែនាំ CEQA របស់រដ្ឋ ត្រូវផ្អែកទាំងស្រុងលើការអនុលោមរបស់គម្រោងតាមផ្នែករង (b) នៃផ្នែកទី 21029។

(c) អ្នកដាក់ពាក្យសុំអាចលះបង់ការអនុវត្តផ្នែករង (a) ឬ (b) មួយ ឬទាំងពីរចំពោះគម្រោងសំខាន់ចាំបាច់ ដោយដាក់សំណើជាលាយលក្ខណ៍អក្សរសម្រាប់ការលះបង់ទៅទីភ្នាក់ងារសាធារណៈ។

21023. សកម្មភាពផ្សេងទៀតរបស់ទីភ្នាក់ងារសាធារណៈសម្រាប់គម្រោងសំខាន់ចាំបាច់

(a) ប្រសិនបើគម្រោងសំខាន់ចាំបាច់តម្រូវឱ្យមានសកម្មភាពផ្សេងទៀតរបស់ទីភ្នាក់ងារសាធារណៈ ដែលមិនត្រូវបានចែងយ៉ាងច្បាស់លាស់ដោយបទប្បញ្ញត្តិផ្សេងទៀតនៃជំពូកនេះ ទីភ្នាក់ងារសាធារណៈត្រូវធ្វើសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរចុងក្រោយ ដោយផ្អែកលើការអនុលោមតាមច្បាប់ដែលមានស្រាប់។ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរចុងក្រោយលើសកម្មភាពផ្សេងទៀតរបស់ទីភ្នាក់ងារសាធារណៈ ត្រូវបញ្ចប់ដូចខាងក្រោម៖

(1) ក្នុងករណីដែលទីភ្នាក់ងារសាធារណៈជាទីភ្នាក់ងារទទួលបន្ទុកសម្រាប់គម្រោងសំខាន់ចាំបាច់ ទីភ្នាក់ងារសាធារណៈត្រូវធ្វើសេចក្តីសម្រេចចុងក្រោយស្របពេលជាមួយនឹងការបញ្ចាក់របស់ខ្លួនលើរបាយការណ៍អំពីផលប៉ះពាល់បរិស្ថាន ការអនុម័តសេចក្តីប្រកាសអវិជ្ជមាន ឬសេចក្តីប្រកាសអវិជ្ជមានដែលមានវិធានការកាត់បន្ថយផលប៉ះពាល់ ឬការកំណត់អំពីការវាយតម្លៃពីមុន ឬការលើកលែងពីផ្នែកនេះ តាមដែលអាចអនុវត្តបាន។

(2) ទីភ្នាក់ងារទទួលបន្ទុករបស់រដ្ឋអាចពន្យារសេចក្តីសម្រេចចុងក្រោយដែលតម្រូវដោយកថាខណ្ឌ (1) រហូតដល់ 90 ថ្ងៃ ប្រសិនបើចំណុចទាំងអស់ដូចខាងក្រោមអនុវត្ត៖

(A) មុនថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 ទីភ្នាក់ងាររដ្ឋមានដំណើរការដែលបានបង្កើតឡើង ដែលមានចែងក្នុងលក្ខន្តិកៈ ឬបទប្បញ្ញត្តិ សម្រាប់ធ្វើសវនាការស្តាប់ភស្តុតាងលើប្រភេទសកម្មភាពរបស់ទីភ្នាក់ងារសាធារណៈដែលកំពុងស្នើសុំសម្រាប់គម្រោងសំខាន់ចាំបាច់។

(B) មុនកាលកំណត់ដែលមានចែងក្នុងកថាខណ្ឌ (1) ទីភ្នាក់ងាររដ្ឋផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកដាក់ពាក្យសុំថា ខ្លួននឹងបន្តធ្វើសវនាការស្តាប់ភស្តុតាង។

(3) ក្នុងករណីដែលអ្នកដាក់ពាក្យសុំស្វែងរកការអនុម័តសម្រាប់គម្រោងសំខាន់ចាំបាច់ពីទីភ្នាក់ងារសាធារណៈដែលមិនមែនជាទីភ្នាក់ងារទទួលបន្ទុកសម្រាប់គម្រោងសំខាន់ចាំបាច់នោះ ក្នុងលើកដំបូងដែលគម្រោងសំខាន់ចាំបាច់បានឆ្លងកាត់ការត្រួតពិនិត្យបរិស្ថានដោយអនុលោមតាមផ្នែកនេះ ទីភ្នាក់ងារសាធារណៈនោះត្រូវធ្វើសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរចុងក្រោយ មុនកាលបរិច្ឆេទណាមួយដែលយឺតជាង រវាង (A) 90 ថ្ងៃគិតចាប់ពីកាលបរិច្ឆេទដែលពាក្យសុំសម្រាប់សកម្មភាពរបស់ទីភ្នាក់ងារសាធារណៈត្រូវបានកំណត់ ឬចាត់ទុកថាពេញលេញដោយអនុលោមតាមផ្នែកទី 21017 ឬចាត់ទុកថាពេញលេញដោយអនុលោមតាមច្បាប់ផ្សេងទៀតអាស្រ័យលើថាតើមួយណាកើតឡើងមុន ឬ (B) មួយថ្ងៃបានកន្លងផុតទៅ គិតចាប់ពីកាលបរិច្ឆេទដែលទីភ្នាក់ងារទទួលបន្ទុកបានអនុម័តគម្រោង។

(b) នៅពេលទីភ្នាក់ងារសាធារណៈខកខានក្នុងការអនុលោមតាមកាលកំណត់ដែលមានចែងក្នុងផ្នែករង (a) អ្នកដាក់ពាក្យសុំអាចធ្វើសំណើជាលាយលក្ខណ៍អក្សរឱ្យទីភ្នាក់ងារសាធារណៈរៀបចំកិច្ចប្រជុំ ឬសវនាការលើសកម្មភាពផ្សេងទៀតរបស់ទីភ្នាក់ងារសាធារណៈដែលបានស្នើសុំពីទីភ្នាក់ងារសាធារណៈនោះ។

(c) ក្នុងរយៈពេល 45 ថ្ងៃ បន្ទាប់ពីទទួលបានសំណើជាលាយលក្ខណ៍អក្សរដោយអនុលោមតាមផ្នែករង (b) ទីភ្នាក់ងារសាធារណៈត្រូវធ្វើចំណុចទាំងអស់ដូចខាងក្រោម៖

(1) រៀបចំកិច្ចប្រជុំ ឬសវនាការលើពាក្យសុំគម្រោងសំខាន់ចាំបាច់ ដូចខាងក្រោម៖

(A) ប្រសិនបើទីភ្នាក់ងារសាធារណៈមានស្ថាប័នសម្រេចចិត្តដែលមានសមាជិកច្រើន ដែលស្ថិតនៅក្រោមច្បាប់ស្តីពីកិច្ចប្រជុំបើកចំហ Bagley-Keene (ប្រការ 9 (ចាប់ផ្តើមជាមួយផ្នែកទី 11120) នៃជំពូក 1 នៃភាគ 1 នៃផ្នែក 3 នៃចំណងជើង 2 នៃក្រមរដ្ឋាភិបាល) ច្បាប់ Ralph M. Brown (ជំពូក 9 (ចាប់ផ្តើមជាមួយផ្នែកទី 54950) នៃភាគ 1 នៃផ្នែក 2 នៃចំណងជើង 5 នៃក្រមរដ្ឋាភិបាល) ឬច្បាប់កិច្ចប្រជុំបើកចំហស្រដៀងគ្នានេះ ទីភ្នាក់ងារសាធារណៈត្រូវដាក់សកម្មភាពផ្សេងទៀតរបស់ទីភ្នាក់ងារដែលបានស្នើសុំពីទីភ្នាក់ងារសាធារណៈនោះនៅក្នុងរបៀបវារៈរបស់ខ្លួន សម្រាប់កិច្ចប្រជុំជាប្រចាំ ឬកិច្ចប្រជុំពិសេសរបស់ស្ថាប័នសម្រេចចិត្តជាន់ខ្ពស់បំផុតរបស់ទីភ្នាក់ងារ។

(B) ប្រសិនបើទីភ្នាក់ងារសាធារណៈមិនមានស្ថាប័នសម្រេចចិត្តដែលមានសមាជិកច្រើន ដែលស្ថិតនៅក្រោមច្បាប់ស្តីពីកិច្ចប្រជុំបើកចំហ Bagley-Keene ច្បាប់ Ralph M. Brown ឬច្បាប់កិច្ចប្រជុំបើកចំហស្រដៀងគ្នានេះទេ មន្ត្រីជាន់ខ្ពស់បំផុតរបស់ទីភ្នាក់ងារសាធារណៈ ឬតំណាងដែលបានតែងតាំងរបស់ខ្លួន ត្រូវរៀបចំសវនាការជាមួយអ្នកដាក់ពាក្យសុំអំពីសកម្មភាពផ្សេងទៀតរបស់ទីភ្នាក់ងារសាធារណៈដែលបានស្នើសុំដោយអ្នកដាក់ពាក្យសុំ។

(2) ទោះបីជាមានបទប្បញ្ញត្តិផ្សេងទៀតនៃផ្នែកនេះ ឬច្បាប់ផ្សេងទៀតក៏ដោយ នៅឯកិច្ចប្រជុំ ឬសវនាការដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ (1) ទីភ្នាក់ងារសាធារណៈត្រូវធ្វើសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរចុងក្រោយដើម្បីផ្តល់ ឬបដិសេធសកម្មភាពផ្សេងទៀតរបស់ទីភ្នាក់ងារសាធារណៈដែលបានស្នើសុំដោយអ្នកដាក់ពាក្យសុំ។

(d) កាលកំណត់ដែលមានចែងក្នុងផ្នែករង (a) និង (c) ត្រូវពន្យារបានតែតាមសំណើជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយអ្នកដាក់ពាក្យសុំប៉ុណ្ណោះ។

(e) លើកលែងតែមានចែងក្នុងផ្នែករង (f) ទីភ្នាក់ងារសាធារណៈមានភារកិច្ចរដ្ឋបាលដែលមិនមានឆន្ទានុសិទ្ធិក្នុងការអនុលោមតាមកាលកំណត់ដែលមានចែងក្នុងផ្នែកនេះ ឬក្នុងសំណើជាលាយលក្ខណ៍អក្សរណាមួយដោយអនុលោមតាមផ្នែករង (d) និងធ្វើសេចក្តីសម្រេចដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ (2) នៃផ្នែករង (c)។

(f) ប្រសិនបើ មុនពេលផុតកំណត់នៃរយៈពេល 45 ថ្ងៃដែលមានចែងក្នុងផ្នែករង (c) ទីភ្នាក់ងារសាធារណៈធ្វើការកំណត់ជាលាយលក្ខណ៍អក្សរចុងក្រោយដើម្បីផ្តល់សកម្មភាពផ្សេងទៀតរបស់ទីភ្នាក់ងារសាធារណៈដែលបានស្នើសុំសម្រាប់គម្រោងសំខាន់ចាំបាច់ ទីភ្នាក់ងារសាធារណៈ និងអ្នកដាក់ពាក្យសុំអាចយល់ព្រមគ្នាជាលាយលក្ខណ៍អក្សរដើម្បីលុបចោលកិច្ចប្រជុំ ឬសវនាការដែលតម្រូវដោយកថាខណ្ឌ (1) នៃផ្នែករង (c)។

(g) (1) អ្នកដាក់ពាក្យសុំអាចលើកបណ្តឹងក្រោមផ្នែកនេះ ដើម្បីតវ៉ានឹងចំណុចទាំងពីរដូចខាងក្រោម៖

(A) ការខកខានរបស់ទីភ្នាក់ងារក្នុងការអនុលោមតាមភារកិច្ចរដ្ឋបាលដែលមិនមានឆន្ទានុសិទ្ធិរបស់ខ្លួន ដែលបានពិពណ៌នានៅក្នុងផ្នែករង (e)។

(B) ការបដិសេធរបស់ទីភ្នាក់ងារ ឬការដាក់លក្ខខណ្ឌអនុម័តដែលខុសច្បាប់លើសកម្មភាពផ្សេងទៀតរបស់ទីភ្នាក់ងារសាធារណៈដែលបានស្នើសុំពីទីភ្នាក់ងារសាធារណៈនោះ។

(2) បណ្តឹងត្រូវតែចាប់ផ្តើមក្នុងរយៈពេល 90 ថ្ងៃ គិតចាប់ពីការខកខាន ការបដិសេធ ឬការដាក់លក្ខខណ្ឌរបស់ទីភ្នាក់ងារ ដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ (1)។

ប្រការ 5. ដំណើរការកំណត់ទំហំការងារបឋម និងការវិភាគជម្រើសដែលបានសម្រួល សម្រាប់គម្រោងសំខាន់ចាំបាច់

21024. ដំណើរការកំណត់ទំហំការងារបឋម សម្រាប់គម្រោងសំខាន់ចាំបាច់

(a) អ្នកដាក់ពាក្យសុំអាចប្រើប្រាស់ ប៉ុន្តែមិនត្រូវបានតម្រូវឱ្យប្រើប្រាស់ដំណើរការកំណត់ទំហំការងារបឋម និងការវិភាគជម្រើសដែលបានសម្រួលដូចដែលមានចែងនៅក្នុងប្រការនេះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកដាក់ពាក្យសុំជ្រើសរើសដោយស្ម័គ្រចិត្តប្រើប្រាស់ដំណើរការកំណត់ទំហំការងារបឋម និងការវិភាគជម្រើសដែលបានសម្រួលនេះ អ្នកដាក់ពាក្យសុំត្រូវអនុលោមតាមប្រការនេះ។

(b) (1) មុនពេលដាក់ពាក្យសុំសម្រាប់គម្រោងសំខាន់ចាំបាច់ អ្នកដាក់ពាក្យសុំដែលជ្រើសរើសបន្តដោយអនុលោមតាមប្រការនេះ ត្រូវផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅទីភ្នាក់ងារទទួលបន្ទុក អំពីបំណងរបស់ខ្លួនក្នុងការបំពេញដំណើរការកំណត់ទំហំការងារ និងការវិភាគជម្រើសដែលបានសម្រួលដែលមានចែងក្នុងប្រការនេះ។

(2) សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរត្រូវបង្ហាញពីទិដ្ឋភាពទូទៅនិងការពិពណ៌នាបឋមអំពីគម្រោងសំខាន់ចាំបាច់ដែលបានស្នើឡើង ឱ្យបានគ្រប់គ្រាន់ដើម្បីជម្រាបជូនទីភ្នាក់ងារទទួលបន្ទុក និងសាធារណជនអំពីលក្ខណៈពិសេសដែលបានរំពឹងទុករបស់គម្រោង។ សេចក្តីជូនដំណឹង

ជាលាយលក្ខណ៍អក្សរមិនត្រូវបានតម្រូវឱ្យរួមបញ្ចូលប្លង់វិស្វកម្មលម្អិត ការសិក្សាបច្ចេកទេស ឬគំនូសប្លង់កម្រិតរចនានោះឡើយ។ ការពិពណ៌នាត្រូវរួមបញ្ចូល ក្នុងកម្រិតដែលបានដឹង នូវចំណុចដូចខាងក្រោម៖

(A) ទីតាំង ទំហំ និងព្រំប្រទល់របស់គម្រោង។

(B) សមាសភាគសំខាន់ៗ និងគោលបំណងមូលដ្ឋានរបស់គម្រោង។

(C) ប្រភេទទូទៅនៃការប្រើប្រាស់ដី កន្លែងប្រើប្រាស់ ឬហេដ្ឋារចនាសម្ព័ន្ធដែលបានស្នើឡើង។

(D) តំបន់ធនធានណាមួយដែលគេដឹង ឬអាចព្យាករណ៍ទុកជាមុនដោយសមហេតុផល ដែលអាចនឹងរងផលប៉ះពាល់។

(E) លិខិតអនុញ្ញាត ឬការអនុម័តណាមួយដែលរំពឹងទុកថាត្រូវការពីទីភ្នាក់ងារសាធារណៈ។

(3) សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរនេះ ក៏ត្រូវបញ្ជាក់ឱ្យឃើញច្បាស់លាស់ផងដែរនូវអាសយដ្ឋានអ៊ីមែលសម្រាប់អ្នកដាក់ពាក្យសុំដែលទីភ្នាក់ងារទទួលបន្ទុក និងសាធារណជនអាចប្រើដើម្បីដាក់មតិយោបល់លើគម្រោងសំខាន់ចាំបាច់ដែលបានស្នើឡើង។

(c) (1) បន្ទាប់ពីទីភ្នាក់ងារទទួលបន្ទុកទទួលបានសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដែលបានពិពណ៌នានៅក្នុងផ្នែករង (b) អ្នកដាក់ពាក្យសុំ និងទីភ្នាក់ងារទទួលបន្ទុកត្រូវចូលរួមក្នុងកិច្ចប្រជុំយ៉ាងតិចពីរ ក្នុងគោលបំណងពិភាក្សាអំពីគម្រោងសំខាន់ចាំបាច់ដែលបានស្នើឡើង ជម្រើសដែលមានសក្តានុពល និងកំណត់តំបន់ធនធានដែលអាចនឹងរងផលប៉ះពាល់។

(2) ទីភ្នាក់ងារដឹកនាំត្រូវរក្សាកំណត់ត្រានៃសេចក្តីសង្ខេបកិច្ចប្រជុំទាំងអស់។

(d) (1) ទីភ្នាក់ងារដឹកនាំត្រូវបង្ហោះសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដែលទទួលបានដោយអនុលោមតាមផ្នែករង (b) នៅលើគេហទំព័រអ៊ីនធឺណិតរបស់ខ្លួន។ ការបង្ហោះនេះត្រូវបញ្ជាក់ឱ្យឃើញច្បាស់លាស់នូវអាសយដ្ឋានអ៊ីមែលដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ (3) នៃផ្នែករង (b) ដើម្បីសម្រួលដល់លទ្ធភាពរបស់សាធារណជនក្នុងការដាក់មតិយោបល់ជូនអ្នកដាក់ពាក្យសុំតាមរយៈអ៊ីមែល។

(2) អ្នកដាក់ពាក្យសុំត្រូវរក្សាកំណត់ត្រាដែលសង្ខេបអំពីមតិយោបល់របស់សាធារណជនដែលទទួលបានតាមរយៈអ៊ីមែលក្នុងអំឡុងដំណាក់កាលកំណត់ទំហំការងារបឋម។

(3) អ្នកដាក់ពាក្យសុំមិនត្រូវបានតម្រូវឱ្យឆ្លើយតបចំពោះមតិយោបល់ណាមួយដែលទទួលបានដោយអនុលោមតាមផ្នែកនេះឡើយ។

(e) អ្នកដាក់ពាក្យសុំអាច ប៉ុន្តែមិនត្រូវបានតម្រូវឱ្យ រៀបចំកិច្ចប្រជុំសាធារណៈឬសិក្ខាសាលាមួយ ឬច្រើន រួមទាំងតាមទម្រង់និម្មិត ឬតាមអ៊ីនធឺណិត ក្នុងគោលបំណងទទួលបានមតិយោបល់សាធារណៈបន្ថែមលើគម្រោងចាំបាច់ដែលបានស្នើឡើង។

(f) ដំណើរការកំណត់ទំហំការងារបឋមដែលបានពិពណ៌នានៅក្នុងផ្នែកនេះ ត្រូវបញ្ចប់ក្នុងរយៈពេលមិនលើសពី 60 ថ្ងៃ ចាប់ពីកាលបរិច្ឆេទដែលទីភ្នាក់ងារទទួលបន្ទុកទទួលបានសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដោយអនុលោមតាមផ្នែករង (b)។

(g) ក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនជ្រើសរើសប្រើប្រាស់ដំណើរការកំណត់ទំហំការងារដែលមានចែងក្នុងផ្នែកទីនេះ តម្រូវការកំណត់ទំហំការងារផ្សេងទៀតដែលមានចែងក្នុងផ្នែក នេះ ត្រូវបន្តអនុវត្ត។

(h) ទោះបីជាមានបទប្បញ្ញត្តិណាមួយនៃផ្នែកនេះក៏ដោយ ចំពោះគម្រោងលំនៅឋានសំខាន់ចាំបាច់ ដំណើរការកំណត់ទំហំការងារបឋមដែលបានផ្តល់ជូនដោយអនុលោមតាមផ្នែកនេះ មិនត្រូវជាតម្រូវការមុនសម្រាប់ការដាក់ពាក្យសុំបឋមដោយអនុលោមតាមច្បាប់ស្តីពីវិបត្តិលំនៅឋានឆ្នាំ 2019 ដូចដែលបានប្រកាសឱ្យប្រើដោយជំពូក 654 នៃលក្ខន្តិក:ឆ្នាំ 2019 (សេចក្តីព្រាងច្បាប់ព្រឹទ្ធសភា 330) ឡើយ។

21025. ការវិភាគជម្រើសដែលបានសម្រួលសម្រាប់គម្រោងចាំបាច់

(a) នៅពេលបញ្ចប់ដំណើរការកំណត់ទំហំការងារបឋមដែលមានចែងក្នុងផ្នែកទី 21024 អ្នកដាក់ពាក្យសុំត្រូវរៀបចំជម្រើសដែលបានស្នើឡើងមួយចំពោះគម្រោងសំខាន់ចាំបាច់។ ជម្រើសដែលបានស្នើឡើងត្រូវពិចារណាអំពីមតិយោបល់ដែលទទួលបានដោយអនុលោមតាមផ្នែកទី 21024 និងត្រូវអនុលោមតាមចំណុចទាំងអស់ដូចខាងក្រោម៖

(1) ជម្រើសដែលបានស្នើឡើងត្រូវស្របគ្នាជាមួយនឹងគោលបំណងមូលដ្ឋានរបស់គម្រោងសំខាន់ចាំបាច់ដែលបានស្នើឡើង ដូចដែលបានពិពណ៌នាដោយអនុលោមតាមផ្នែកទី 21024។

(2) ក្នុងកម្រិតដែលអាចអនុវត្តបាន ជម្រើសដែលបានស្នើឡើងត្រូវរចនាឡើងឱ្យស្របគ្នាជាមួយនឹងគោលនយោបាយកំណត់តំបន់ និងប្រើប្រាស់ដីក្នុងតំបន់ដែលអនុវត្ត។

(3) ជម្រើសដែលបានស្នើឡើងមិនចាំបាច់ត្រូវស្ថិតនៅទីតាំងផ្សេងពីគម្រោងចាំបាច់ដែលបានស្នើឡើងនោះទេ។

(b) ទោះបីជាមានផ្នែកទី 21100 ឬបទប្បញ្ញត្តិណាមួយផ្សេងទៀតនៃផ្នែកនេះក៏ដោយ និងលើកលែងតែមានចែងក្នុងផ្នែករង (f) របាយការណ៍អំពីផលប៉ះពាល់បរិស្ថានដែលបានរៀបចំឡើងសម្រាប់គម្រោងសំខាន់ចាំបាច់ដែលអនុលោមតាមប្រការនេះ ត្រូវវិភាគតែចំណុចដូចខាងក្រោម៖

(1) គម្រោងចាំបាច់ដែលបានស្នើឡើង។

(2) (A) ជម្រើសដែលបានស្នើឡើងរបស់អ្នកដាក់ពាក្យសុំដែលបានរៀបចំដោយអនុលោមតាមប្រការនេះ។

(B) សម្រាប់គោលបំណងនៃការបំពេញតាមប្រការនេះ ជម្រើសដែលបានស្នើឡើងរបស់អ្នកដាក់ពាក្យសុំអាចរួមបញ្ចូលសមាសភាគជំនួស ឬបន្ថែមនៃគម្រោងសំខាន់ចាំបាច់ដែលបានស្នើឡើង ដែលសមាសភាគបន្ថែម ឬជំនួសនោះអាចរួមបញ្ចូលការកែលម្អរូបវន្តនៅលើទីតាំង ឬក្រៅទីតាំង ឬប៉ារ៉ាម៉ែត្រប្រតិបត្តិការ ឬកម្មវិធីជំនួស ឬបន្ថែម ដែលត្រូវបានរចនាឡើងដើម្បីកាត់បន្ថយផលប៉ះពាល់។

(C) ជម្រើសដែលបានស្នើឡើងដែលបានរៀបចំដោយអនុលោមតាមប្រការនេះ ត្រូវសន្មតថាកាត់បន្ថយផលប៉ះពាល់ដែលជម្រើសនោះមានបំណងដោះស្រាយ ដល់កម្រិតដែលមិនមានសារសំខាន់ ដរាបណាអ្នកដាក់ពាក្យសុំបង្ហាញថាមានភស្តុតាងរឹងមាំដើម្បីគាំទ្រការសន្មតនេះ។ ទោះជាយ៉ាងណាក៏ដោយ ការសន្មតនេះមិនត្រូវមានឥទ្ធិពល ឬផលប៉ះពាល់លើថាតើជម្រើសនោះទីបំផុតអាចអនុវត្តបាន ឬមានភាពប្រសើរជាងគេតាមទស្សនៈបរិស្ថាននោះឡើយ។

(3) ជម្រើសមិនធ្វើគម្រោង។ ជម្រើសមិនធ្វើគម្រោងត្រូវពិចារណាអំពីលក្ខខណ្ឌបរិស្ថានដែលអាចព្យាករណ៍ទុកជាមុនដោយសមហេតុផល ដែលនឹងកើតឡើងប្រសិនបើគម្រោងចាំបាច់មិនត្រូវបានអនុម័ត រួមទាំងការប្រើប្រាស់ជំនួសនាពេលអនាគតដែលអាចព្យាករណ៍ទុកជាមុនដោយសមហេតុផលនៃទីតាំងដែលបានស្នើឡើងសម្រាប់គម្រោងចាំបាច់ ផលប៉ះពាល់បរិស្ថានណាមួយពីការប្រើប្រាស់ជំនួសទាំងនោះ និងអត្ថប្រយោជន៍ដែលកើតចេញពីគម្រោងចាំបាច់។

(c) ជម្រើសដែលបានពិពណ៌នានៅក្នុងផ្នែករង (b) សម្រាប់គម្រោងចាំបាច់ គឺគ្រប់គ្រាន់សម្រាប់គោលបំណងទាំងអស់ក្រោមផ្នែកនេះ និងច្បាប់ផ្សេងទៀតណាមួយ។ លើកលែងតែមានចែងក្នុងផ្នែករង (f) ជម្រើសបន្ថែមទាំងអស់ក្រៅពីអ្វីដែលបានពិពណ៌នានៅក្នុងផ្នែករង (b) គឺមិនចាំបាច់ទេ ហើយគ្មានទីភ្នាក់ងារសាធារណៈ ឬស្ថាប័ន ឬអង្គភាពផ្សេងទៀតណាមួយត្រូវតម្រូវឱ្យមានការវិភាគលើជម្រើសដែលមិនចាំបាច់នោះឡើយ។

(d) ក្នុងរយៈពេល 15 ថ្ងៃ បន្ទាប់ពីការបិទដំណើរការកំណត់ទំហំការងារបឋមក្នុងផ្នែកទី 21024 អ្នកដាក់ពាក្យសុំត្រូវបញ្ជូនទៅកាន់ទីភ្នាក់ងារទទួលបន្ទុកនូវឯកសារដាក់ស្នើជាលាយលក្ខណ៍អក្សរ ដែលរួមមាន៖

(1) ការពិពណ៌នាអំពីគម្រោងចាំបាច់ដែលបានស្នើឡើង។

(2) ការពិពណ៌នាអំពីជម្រើសដែលបានស្នើឡើងតែមួយ ដែលបានរៀបចំដោយអនុលោមតាមប្រការនេះ។

(3) ការពិពណ៌នាអំពីជម្រើសមិនធ្វើគម្រោងដែលបានពិពណ៌នានៅក្នុងកថាខណ្ឌ (3) នៃផ្នែករង (b)។

(e) ទីភ្នាក់ងារទទួលបន្ទុកត្រូវ ក្នុងរយៈពេល 15 ថ្ងៃ បន្ទាប់ពីទទួលបានជម្រើសដែលបានស្នើឡើង ចេញវិញ្ញាបនបត្រជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ថាតើអ្នកដាក់ពាក្យសុំបានបំពេញតាមតម្រូវការនៃប្រការនេះឬយ៉ាងណា។ ជំនួសឱ្យការធ្វើដូច្នេះ ទីភ្នាក់ងារទទួលបន្ទុកអាចបញ្ជាក់ថាអ្នកដាក់ពាក្យសុំបានបំពេញតាមតម្រូវការនៃប្រការនេះ ដោយមិនចាត់វិធានការណាមួយក្នុងរយៈពេល 15 ថ្ងៃ បន្ទាប់ពីទទួលបានជម្រើសដែលបានស្នើឡើង។ ការបញ្ជាក់របស់ទីភ្នាក់ងារទទួលបន្ទុកត្រូវជាស្ថាពរលើកលែងតែភាគីពាក់ព័ន្ធដាក់បណ្តឹងឧទ្ធរណ៍រដ្ឋបាលក្នុងរយៈពេលប្រាំថ្ងៃបន្ទាប់ពីការចេញវិញ្ញាបនបត្រ។

(f) គ្មានអ្វីនៅក្នុងប្រការនេះហាមឃាត់អ្នកដាក់ពាក្យសុំពីការស្នើជម្រើសគម្រោងបន្ថែម តាមឆន្ទានុសិទ្ធិរបស់អ្នកដាក់ពាក្យសុំនោះឡើយ។

(g) អាស្រ័យលើតម្រូវការនៃជំពូកនេះ និងដែនកំណត់ណាមួយដែលកំណត់ដោយបទប្បញ្ញត្តិផ្សេងទៀតនៃច្បាប់ ទីភ្នាក់ងារទទួលបន្ទុកនៅតែរក្សាឆន្ទានុសិទ្ធិក្នុងការអនុម័តគម្រោងសំខាន់ចាំបាច់ដែលបានស្នើឡើង អនុម័តជម្រើសដែលបានស្នើឡើងដែលបានរៀបចំដោយអនុលោមតាមប្រការនេះ ឬជ្រើសរើសជម្រើសមិនធ្វើគម្រោង។

(h) សម្រាប់គោលបំណងនៃផ្នែកនេះ "ជម្រើសដែលបានស្នើឡើង" មានន័យថា ជម្រើសតែមួយដែលមានសក្តានុពលអាចអនុវត្តបាន ចំពោះគម្រោងសំខាន់ចាំបាច់ ដែលត្រូវបានរៀបចំដោយអ្នកដាក់ពាក្យសុំ។

ប្រការ 6. ការពិនិត្យឡើងវិញដោយតុលាការចំពោះការអនុម័ត ឬការអនុញ្ញាតគម្រោងសំខាន់ចាំបាច់

21026. ការពិនិត្យឡើងវិញដោយតុលាការចំពោះការអនុម័ត ឬការអនុញ្ញាត

(a) (1) សកម្មភាព ឬនីតិវិធីណាមួយដើម្បីវាយប្រហារ ពិនិត្យឡើងវិញ លុបចោល ទុកជាមោឃៈ ឬប្រកាសជាមោឃៈនូវការអនុម័ត ឬការអនុញ្ញាតណាមួយដោយទីភ្នាក់ងារសាធារណៈទាក់ទងនឹងគម្រោងសំខាន់ចាំបាច់ ដោយហេតុផលនៃការមិនអនុលោមតាមផ្នែកនេះ ឬគោលការណ៍ណែនាំ CEQA របស់រដ្ឋ ត្រូវអនុវត្ត និងបញ្ចប់ដោយអនុលោមតាមតម្រូវការនៃប្រការនេះ។

(2) ប្រការនេះត្រូវអនុវត្តចំពោះរាល់សកម្មភាព ឬនីតិវិធីទាំងអស់ដែលកំពុងជាប់នៅកាលបរិច្ឆេទចូលជាធរមាននៃជំពូកនេះ ឬដែលបានចាប់ផ្តើមក្រោយកាលបរិច្ឆេទនោះ។

(b) (1) ក្នុងសកម្មភាព ឬនីតិវិធីណាមួយដែលបាននាំយកមកដើម្បីវាយប្រហារ ពិនិត្យឡើងវិញ លុបចោល ទុកជាមោឃៈ ឬប្រកាសជាមោឃៈនូវការអនុម័ត ឬការអនុញ្ញាតគម្រោងសំខាន់ចាំបាច់ ដោយហេតុផលនៃការមិនអនុលោមតាមផ្នែកនេះ ឬគោលការណ៍ណែនាំ CEQA របស់រដ្ឋ ដូចមានចែងក្នុងផ្នែករង (b) នៃផ្នែកទី 21029 ការទាមទាររបស់អ្នកដាក់ញត្តិត្រូវកំណត់ចំពោះការមិនអនុលោមរបស់ទីភ្នាក់ងារសាធារណៈតាមច្បាប់ដែលមានស្រាប់ និងមានលក្ខណៈគោលបំណង ហើយវិសាលភាពនៃការពិនិត្យឡើងវិញរបស់តុលាការត្រូវកំណត់ចំពោះថាតើការអនុម័ត ឬការអនុញ្ញាតនោះអនុលោមតាមច្បាប់ដែលមានស្រាប់ និងមានលក្ខណៈគោលបំណងដែរឬទេ។

(2) សម្រាប់គោលបំណងនៃផ្នែករងនេះ "គោលបំណង" មានន័យថា មិនពាក់ព័ន្ធនឹងការវិនិច្ឆ័យផ្ទាល់ខ្លួន ឬប្រធានបទ និងអាចផ្ទៀងផ្ទាត់បានជាឯកសណ្ឋាន ដោយយោងទៅតាមស្តង់ដារ ឬលក្ខណៈវិនិច្ឆ័យខាងក្រៅ និងឯកសណ្ឋាន ដែលមានស្រាប់ និងអាចដឹងបានដោយទាំងអ្នកដាក់ពាក្យសុំ និងទីភ្នាក់ងារសាធារណៈ មុនពេលដាក់ពាក្យសុំ។

(c) (1) ក្នុងសកម្មភាព ឬនីតិវិធីណាមួយដើម្បីវាយប្រហារ ពិនិត្យឡើងវិញ លុបចោល ទុកជាមោឃៈ ឬប្រកាសជាមោឃៈនូវការអនុម័ត ឬការអនុញ្ញាតគម្រោងសំខាន់ចាំបាច់ ដោយហេតុផលនៃការមិនអនុលោមតាមផ្នែកនេះ ឬគោលការណ៍ណែនាំ CEQA របស់រដ្ឋ ដូចមានចែងក្នុងផ្នែករង (b) នៃផ្នែកទី 21029 តុលាការត្រូវកំណត់ត្រឹមតែថាតើការអនុម័ត ឬការអនុញ្ញាតនោះត្រូវបានគាំទ្រដោយភស្តុតាងរឹងមាំ ដោយផ្អែកលើកំណត់ត្រាទាំងមូលដែរឬទេ។

(2) ក្នុងសកម្មភាព ឬនីតិវិធីណាមួយដើម្បីវាយប្រហារ ពិនិត្យឡើងវិញ លុបចោល ទុកជាមោឃៈ ឬប្រកាសជាមោឃៈនូវការអនុម័ត ឬការអនុញ្ញាតគម្រោងសំខាន់ចាំបាច់របស់ទីភ្នាក់ងារសាធារណៈ ដោយហេតុផលថាការអនុម័ត ឬការអនុញ្ញាតនោះត្រូវបានធ្វើឡើងដោយមិនបានបំពេញនីតិវិធីចូលរួមរបស់សាធារណជន តុលាការត្រូវកំណត់ត្រឹមតែថាតើការខកខានក្នុងការអនុលោមតាមនីតិវិធីចូលរួមរបស់សាធារណជនមានលក្ខណៈតាមអំពើចិត្ត និងគ្មានហេតុផលសមស្រប ហើយបណ្តាលឱ្យមានកំហុសដែលបង្កផលប៉ះពាល់ដែរឬទេ។

(3) គ្មានអ្វីនៅក្នុងផ្នែកនេះ ឬគោលការណ៍ណែនាំ CEQA របស់រដ្ឋ ត្រូវយកមកអនុវត្ត ឬបកស្រាយថាជាការដាក់ចេញនូវតម្រូវការផ្នែកនីតិវិធី ឬខ្លឹមសារលើសពីអ្វីដែលបានចែងយ៉ាងច្បាស់លាស់នៅក្នុងផ្នែកនេះ ឬគោលការណ៍ណែនាំ CEQA របស់រដ្ឋ ដូចដែលត្រូវបានកែសម្រួល ឬកំណត់ដោយបទប្បញ្ញត្តិនៃជំពូកនេះឡើយ។

(d) គ្មានអ្វីនៅក្នុងប្រការនេះត្រូវបកស្រាយថាជាការជំនួសផ្នែកទី 1756 និង 1759 នៃក្រមសេវាសាធារណៈ ឬបទប្បញ្ញត្តិផ្សេងទៀតនៃច្បាប់ដែលគ្រប់គ្រងការពិនិត្យឡើងវិញដោយតុលាការចំពោះបញ្ហា ឬសេចក្តីសម្រេចរបស់គណៈកម្មការសេវាសាធារណៈឡើយ។

21027. កាលកំណត់ និងដំណើរការដែលត្រូវអនុវត្តចំពោះការពិនិត្យឡើងវិញដោយតុលាការចំពោះការអនុម័ត ឬការអនុញ្ញាតគម្រោងចាំបាច់

(a) កាលកំណត់។

(1) (A) សកម្មភាព ឬនីតិវិធីមួយ ដើម្បីវាយប្រហារ ពិនិត្យឡើងវិញ លុបចោល ទុកជាមោឃៈ ឬប្រកាសជាមោឃៈនូវការអនុម័ត ឬការអនុញ្ញាតរបស់ទីភ្នាក់ងារសាធារណៈចំពោះគម្រោងសំខាន់ចាំបាច់ ត្រូវចាប់ផ្តើមក្នុងរយៈពេល 30 ថ្ងៃ ចាប់ពីកាលបរិច្ឆេទដែលទីភ្នាក់ងារសាធារណៈដាក់សេចក្តីជូនដំណឹងអំពីការកំណត់ ឬសេចក្តីជូនដំណឹងអំពីការលើកលែងដោយអនុលោមតាមផ្នែកទី 21108 ឬ 21152។ សកម្មភាព ឬនីតិវិធីនោះត្រូវបញ្ចប់ក្នុងរយៈពេល 270 ថ្ងៃ ដោយរាប់បញ្ចូលទាំងនីតិវិធីតុលាការថ្នាក់ដំបូង និងថ្នាក់ឧទ្ធរណ៍ ដោយអនុលោមតាមនីតិវិធីសម្រួលតុលាការដែលត្រូវអនុវត្តចំពោះគម្រោងអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំបរិស្ថានដោយអនុលោមតាមផ្នែកទី 21185។

(B) តុលាការអាច តាមឆន្ទានុសិទ្ធិរបស់ខ្លួន ពន្យារកាលកំណត់ 270 ថ្ងៃដែលមានចែងក្នុងអនុកថាខណ្ឌ (A) រហូតដល់ 90 ថ្ងៃបន្ថែមទៀត។

(2) ទោះបីជាមានបទប្បញ្ញត្តិផ្ទុយណាមួយនៅក្នុងផ្នែកទី 21185 ឬបទបញ្ជាណាមួយដែលត្រូវបានអនុម័តដោយ គណៈកម្មាធិការតុលាការក៏ដោយ និងលើកលែងតែមានចែងក្នុងអនុកថាខណ្ឌ (B) នៃកថាខណ្ឌ (1) កាលកំណត់ 270 ថ្ងៃក្នុងកថាខណ្ឌ (1) ត្រូវពន្យារបានតែតាមការយល់ព្រមជាលាយលក្ខណ៍អក្សរទៅវិញទៅមករបស់ដើមបណ្តឹង ឬអ្នកដាក់ញត្តិ ទីភ្នាក់ងារសាធារណៈ និងអ្នកដាក់ពាក្យសុំប៉ុណ្ណោះ។

(b) កំណត់ត្រារដ្ឋបាល។

កំណត់ត្រារដ្ឋបាលទាំងមូលមានតែសេចក្តីជូនដំណឹង ការសិក្សា និងឯកសារផ្សេងទៀតដែលស្របតាមចំណុចទាំងពីរដូចខាងក្រោម៖

(1) ឯកសារដែលត្រូវបានតម្រូវក្រោមផ្នែកនេះឱ្យបញ្ជូន ឬចែកចាយដល់សមាជិកសាធារណជនដោយទីភ្នាក់ងារទទួលបន្ទុក ដាក់ឱ្យសាធារណជនអាចប្រើបាននៅកន្លែងរក្សាទុកឯកសារសាធារណៈ ដូចជាបណ្ណាល័យ ឬដាក់បញ្ចូលនៅលើគេហទំព័រអ៊ីនធឺណិតរបស់ទីភ្នាក់ងារទទួលបន្ទុក។

(2) ចំពោះមតិយោបល់សាធារណៈ មតិយោបល់ដែលបានពិពណ៌នានៅក្នុងផ្នែករង (d) នៃផ្នែកទី 21021 និងការឆ្លើយតប និងមតិយោបល់ដែលបានពិពណ៌នានៅក្នុងផ្នែករង (e) នៃផ្នែកទី 21021។

(c) វិធានការដោះស្រាយ។

(1) ប្រសិនបើតុលាការរកឃើញ តាមរយៈការកាត់ក្តី សវនាការ ឬការបញ្ជូនសំណុំរឿងត្រឡប់មកវិញពីតុលាការឧទ្ធរណ៍ ថាការអនុម័ត ឬការអនុញ្ញាតរបស់ទីភ្នាក់ងារសាធារណៈចំពោះគម្រោងសំខាន់ចាំបាច់ មិនត្រូវបានគាំទ្រដោយភស្តុតាងរឹងមាំនៅក្នុងកំណត់ត្រាទេ តុលាការត្រូវចេញបញ្ជា និងដីកាបញ្ជាជាកាតព្វកិច្ច ដោយពន្យល់យ៉ាងជាក់លាក់អំពីកង្វះខាតថា តើតម្រូវការណាមួយនៃផ្នែកនេះ ឬគោលការណ៍ណែនាំ CEQA របស់រដ្ឋ ដែលការអនុម័ត ឬការអនុញ្ញាតនោះមិនអនុលោមតាម ហើយកំណត់ថា តើផ្នែកដំណាក់កាល ឬសកម្មភាពណាមួយនៃគម្រោងសំខាន់ចាំបាច់ ត្រូវបានប៉ះពាល់ដោយការមិនអនុលោមតាមនោះ។

(2) វិធានការដោះស្រាយត្រូវកំណត់ត្រឹមតែការហាមឃាត់ការចាប់ផ្តើមផ្នែកដំណាក់កាល ឬសកម្មភាពដែលមិនអនុលោមតាមនោះ រហូតទាល់តែការមិនអនុលោមតាមនោះត្រូវបានកែតម្រូវ។

(3) នៅពេលដែលសកម្មភាពកែតម្រូវដែលបានតម្រូវទាំងនោះត្រូវបានបញ្ចប់ ទីភ្នាក់ងារសាធារណៈត្រូវដាក់លិខិតឆ្លើយតបចំពោះដីកាបញ្ជាដោយបញ្ជាក់ពីការអនុលោមតាម ហើយបន្ទាប់មកតុលាការត្រូវលុបចោលសំណុំរឿង ឬនីតិវិធីនោះ។ តុលាការមិនអាចបញ្ជា ឬដឹកនាំតាមរយៈដីកា ឬទម្រង់ផ្សេងទៀតនៃបញ្ជា ដីកាហាមឃាត់ ឬសេចក្តីសម្រេច ឱ្យទីភ្នាក់ងារសាធារណៈដកហូតការអនុម័ត ឬការអនុញ្ញាតរបស់ខ្លួនចំពោះគម្រោងចាំបាច់នោះឡើយ។

(4) ផ្នែក ដំណាក់កាល ឬសកម្មភាពណាមួយនៃគម្រោងសំខាន់ចាំបាច់ដែលមិនស្ថិតក្នុងវិសាលភាពនៃចំណុចខ្វះខាតដែលបានកំណត់នៅក្នុងដីកា មិនត្រូវស្ថិតក្រោមដីកានោះទេ ហើយមិនត្រូវស្ថិតក្រោមការតវ៉ាបន្ថែមទៀតនៅក្នុងសកម្មភាព ឬនីតិវិធីក្រោមផ្នែកនេះឡើយ។

(d) ការអនុម័ត ឬការអនុញ្ញាតជាបន្តបន្ទាប់។

(1) គ្មានសកម្មភាព ឬនីតិវិធីបន្ថែមទៀតដើម្បីតវ៉ានឹងការអនុវត្តរហូតដល់ការបញ្ចប់ការសាងសង់ ឬការអនុម័ត ឬការអនុញ្ញាតជាបន្តបន្ទាប់នៃគម្រោងសំខាន់ចាំបាច់ ឬផ្នែកណាមួយនៃគម្រោងសំខាន់ចាំបាច់ អាចត្រូវបានដាក់ឡើយ ប្រសិនបើការអនុម័ត ឬការអនុញ្ញាតរបស់ទីភ្នាក់ងារសាធារណៈមិនបានស្ថិតក្រោមការតវ៉ាតាមផ្លូវតុលាការ ការអនុម័ត ឬការអនុញ្ញាតរបស់ទីភ្នាក់ងារសាធារណៈត្រូវបានតវ៉ា ហើយត្រូវបានតម្កល់ទុកឱ្យមានសុពលភាព ឬទីភ្នាក់ងារសាធារណៈបានដាក់លិខិតឆ្លើយតបចំពោះដីកាបញ្ជា ដែលត្រូវបានតុលាការទទួលយកថាបានបំពេញតាមតម្រូវការដោយអនុលោមតាមផ្នែករង (c)។

(2) ការកែសម្រួលបន្តិចបន្តួចចំពោះគម្រោងសំខាន់ចាំបាច់ ដែលមិនបណ្តាលឱ្យមានផលប៉ះពាល់សំខាន់ថ្មីណាមួយ ឬដែលមិនធ្វើឱ្យផលប៉ះពាល់សំខាន់ណាមួយដែលបានកំណត់ពីមុនមកនៃគម្រោងសំខាន់ចាំបាច់ដែលបានអនុម័តដំបូង កាន់តែធ្ងន់ធ្ងរឡើងជាខ្លាំង មិនអាចត្រូវបានតវ៉ានៅក្នុងសកម្មភាព ឬនីតិវិធីក្រោមផ្នែកនេះឡើយ។

(e) វិធានការដីកាហាមឃាត់។

(1) នៅពេលមានការបង្ហាញដោយភស្តុតាងច្បាស់លាស់ និងគួរឱ្យជឿជាក់ថា គម្រោងសំខាន់ចាំបាច់មួយនឹងមានផលប៉ះពាល់អវិជ្ជមានជាក់លាក់លើសុវត្ថិភាពសាធារណៈ ហើយមិនមានវិធីសាស្ត្រដែលអាចអនុវត្តបានដើម្បីកាត់បន្ថយ ឬជៀសវាងផលប៉ះពាល់អវិជ្ជមានជាក់លាក់លើសុវត្ថិភាពសាធារណៈនោះបានប្រកបដោយការពេញចិត្តទេ តុលាការអាចបញ្ជាឱ្យការសាងសង់ ឬការបញ្ចប់សមាសភាគជាក់លាក់នៃគម្រោងសំខាន់ចាំបាច់ដែលនឹងបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានជាក់លាក់លើសុវត្ថិភាពសាធារណៈ ត្រូវបានផ្អាក ឬហាមឃាត់ ដោយចេញត្រឹមតែដីកាហាមឃាត់បណ្តោះអាសន្នប៉ុណ្ណោះ។

(2) សម្រាប់គោលបំណងនៃកថាខណ្ឌ (1) ការកាត់បន្ថយផលប៉ះពាល់ប្រកបដោយការពេញចិត្ត ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានជាក់លាក់លើសុវត្ថិភាពសាធារណៈ ត្រូវចាត់ទុកថាមាន នៅពេលមានចំណុចណាមួយដូចខាងក្រោម៖

(A) ការសម្រេចចិត្តជាបន្តបន្ទាប់របស់ទីភ្នាក់ងារសាធារណៈដើម្បីកែប្រែគម្រោងសំខាន់ចាំបាច់ ដើម្បីជៀសវាង ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានជាក់លាក់លើសុវត្ថិភាពសាធារណៈនោះមកកម្រិតតិចជាងកម្រិតសំខាន់ ហើយការសម្រេចចិត្តនោះមិនត្រូវតម្រូវឱ្យទីភ្នាក់ងារចាត់វិធានការបន្ថែមណាមួយក្រៅផ្នែកនេះឡើយ។

(B) ការកំណត់របស់ទីភ្នាក់ងារសាធារណៈថា ផលប៉ះពាល់អវិជ្ជមានជាក់លាក់លើសុវត្ថិភាពសាធារណៈមិនអាចជៀសវាង ឬកាត់បន្ថយមកកម្រិតតិចជាងកម្រិតសំខាន់បានឡើយ បន្ទាប់ពីការរៀបចំរបាយការណ៍អំពីផលប៉ះពាល់បរិស្ថាន ឬរបាយការណ៍អំពីផលប៉ះពាល់បរិស្ថានបំពេញបន្ថែមដែលដោះស្រាយតែផលប៉ះពាល់អវិជ្ជមានជាក់លាក់លើសុវត្ថិភាពសាធារណៈនោះ ស្របតាមកាលកំណត់ និងនីតិវិធីដែលមានចែងក្នុងជំពូកនេះ។

ប្រការ 7. និយមន័យ

21028. និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ និយមន័យខាងក្រោមត្រូវបានអនុវត្ត៖

(a) "អ្នកដាក់ពាក្យសុំ" មានន័យថា បុគ្គល នីតិបុគ្គល ទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសេវាសាធារណៈ ដែលស្នើគម្រោងចាំបាច់មួយ។

(b) "ការអនុម័ត ឬការអនុញ្ញាត" មានន័យថា ការអនុម័ត ការអនុញ្ញាត ការកំណត់ ការរកឃើញ ការផ្តល់មូលនិធិ ប្រតិបត្តិការអចលនទ្រព្យ ឬកិច្ចសន្យា ឬសកម្មភាពផ្សេងទៀតរបស់ទីភ្នាក់ងារសាធារណៈ ដែលជំរុញដល់ការរីកចម្រើន ការសាងសង់ ការបញ្ចប់ ឬការធ្វើឱ្យសម្រេចបាននូវគម្រោងសំខាន់ចាំបាច់មួយ។

(c) "គ្រឹះស្ថានអប់រំ California" មានន័យថា ទាំងអស់ដូចខាងក្រោម៖ មណ្ឌលសិក្សាធិការ; អគ្គនាយកសាលារៀនខោនធី; ក្រុមប្រឹក្សាអប់រំខោនធី; មណ្ឌលមហាវិទ្យាល័យសហគមន៍; សាលាពិសេសរបស់រដ្ឋ; ក្រុមប្រឹក្សាអភិបាលនៃមហាវិទ្យាល័យសហគមន៍ California ឬ អធិការបតីនៃមហាវិទ្យាល័យសហគមន៍ California; សាកលវិទ្យាល័យរដ្ឋ California ឬ ក្រុមប្រឹក្សាអាណាព្យាបាលនៃសាកលវិទ្យាល័យរដ្ឋ California; សាកលវិទ្យាល័យ California ឬ ក្រុមប្រឹក្សាអាណាព្យាបាលនៃសាកលវិទ្យាល័យ California; មហាវិទ្យាល័យច្បាប់ San Francisco ដែលពីមុនហៅថា មហាវិទ្យាល័យច្បាប់ Hastings; ធម្មនុញ្ញ / សាលាធម្មនុញ្ញ ដែលបានបង្កើតឡើងដោយអនុលោមតាម ច្បាប់សាលាធម្មនុញ្ញឆ្នាំ 1992 (ភាគ 26.8 (ចាប់ផ្តើមជាមួយផ្នែកទី 47600) នៃផ្នែក 4 នៃចំណងជើង 2 នៃក្រមអប់រំ); និងមហាវិទ្យាល័យ ឬសាកលវិទ្យាល័យមិនរកប្រាក់ចំណេញដែលមានសមាជិកភាពនៅក្នុង សមាគមមហាវិទ្យាល័យ និងសាកលវិទ្យាល័យឯករាជ្យ California។

(d) "CEQA" មានន័យថា ច្បាប់ស្តីពីគុណភាពបរិស្ថាន California (ផ្នែក 13 (ចាប់ផ្តើមជាមួយផ្នែកទី 21000))។

(e) (1) "កុលសម្ព័ន្ធពិគ្រោះយោបល់" មានន័យថា កុលសម្ព័ន្ធមួយដែលមានឈ្មោះនៅក្នុងបញ្ជីថ្មីបំផុតដែលបានបោះពុម្ពផ្សាយដោយសហរដ្ឋអាមេរិក ដោយអនុលោមតាម ច្បាប់បញ្ជីកុលសម្ព័ន្ធឥណ្ឌាដែលសហព័ន្ធទទួលស្គាល់ឆ្នាំ 1994 (25 U.S.C. ផ្នែក 5131) ហើយមានទំនាក់ទំនងជាប្រពៃណី និងវប្បធម៌ជាមួយតំបន់ភូមិសាស្ត្រនៃគម្រោងសំខាន់ចាំបាច់ដែលបានស្នើឡើង។

(2) ទោះបីជាមានផ្នែក 21073 ឬច្បាប់ផ្សេងទៀតក៏ដោយ "កុលសម្ព័ន្ធជនជាតិដើមអាម៉េរិកនៅរដ្ឋ California" ដូចដែលបានប្រើប្រាស់ក្នុង ឬទាក់ទងនឹងផ្នែក 21074, 21080.3.1, 21080.3.2, 21082.3, 21084.2, 21084.3 និងជំពូកនេះ ត្រូវមានន័យជំនួសវិញ និងត្រូវអានថាជា "កុលសម្ព័ន្ធពិគ្រោះយោបល់" នៅពេលដែលគម្រោងនោះជាគម្រោងចាំបាច់។

(f) "ថ្ងៃ" មានន័យថា ទាំងពីរដូចខាងក្រោម៖

(1) ដូចដែលបានប្រើប្រាស់ក្នុងផ្នែក 21018 និង 21019 "ថ្ងៃ" មានន័យថា ថ្ងៃណាមួយក្រៅពីថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃណាមួយដែលត្រូវបានកំណត់ជាថ្ងៃឈប់សម្រាករបស់រដ្ឋ។

(2) ដូចដែលបានប្រើប្រាស់ក្នុងផ្នែកណាមួយនៃជំពូកនេះ លើកលែងតែផ្នែក 21018 និង 21019 "ថ្ងៃ" មានន័យថា ថ្ងៃតាមប្រតិទិន។

(g) "មូលដ្ឋានអប់រំ" មានន័យថា អចលនទ្រព្យ កន្លែង សំណង់ អគារ ឬវត្ថុភ្ជាប់អចលនទ្រព្យណាមួយ ដែលជាកម្មសិទ្ធិ ឬត្រូវបានដំណើរការ ឬនឹងជាកម្មសិទ្ធិ ឬត្រូវបានដំណើរការនៅពេលបញ្ចប់ ដោយគ្រឹះស្ថានអប់រំ California មួយ ឬច្រើន សម្រាប់គោលបំណងអប់រំ។

(h) "ឯកសារពិនិត្យមើលបរិស្ថាន" ឬ "សំណុំឯកសារពិនិត្យមើលបរិស្ថាន" មានន័យថា ការសិក្សាដំបូង; សេចក្តីប្រកាសអវិជ្ជមាន; សេចក្តីប្រកាសអវិជ្ជមានដែលមានវិធានការកាត់បន្ថយផលប៉ះពាល់; សេចក្តីព្រាង និងរបាយការណ៍អំពីផលប៉ះពាល់បរិស្ថានចុងក្រោយ; ឯកសារដែលបានរៀបចំជំនួសឱ្យរបាយការណ៍អំពីផលប៉ះពាល់បរិស្ថាន; សេចក្តីប្រកាសអវិជ្ជមាន និងសេចក្តីប្រកាសអវិជ្ជមានដែលមានវិធានការកាត់បន្ថយផលប៉ះពាល់ ដែលរៀបចំឡើងតាមកម្មវិធីដែលបានបញ្ជាក់ដោយអនុលោមតាមផ្នែក 21080.5; ឯកសារ ឬសំណុំឯកសារដែលប្រើដើម្បីបញ្ជាក់ពីភាពអាចអនុវត្តបាននៃការលើកលែងតាមលក្ខន្តិក: ឬការលើកលែងតាមប្រភេទពីផ្នែកនេះ ឬបទប្បញ្ញត្តិសម្រួល ដែលរួមមាន ប៉ុន្តែមិនកំណត់ត្រឹម បទប្បញ្ញត្តិដោយអនុលោមតាមផ្នែក 21083.3 និង 21094.5; ឯកសារបន្ថែម និងឯកសារពិនិត្យមើលជាបន្ថែម ឬជាបន្តបន្ទាប់ផ្សេងទៀត; ឯកសារដែលបានរៀបចំក្រោម ច្បាប់គោលនយោបាយបរិស្ថានជាតិឆ្នាំ 1969 (42 U.S.C. ផ្នែក 4321 et seq.) ហើយត្រូវបានប្រើប្រាស់ដោយទីភ្នាក់ងារសាធារណៈជំនួសឱ្យឯកសារ ឬសំណុំឯកសារណាមួយខាងលើ; និងឯកសារបរិស្ថានដូចដែលបានកំណត់ក្នុងផ្នែក 15361 នៃចំណងជើង 14 នៃក្រមបទប្បញ្ញត្តិរដ្ឋ California។

(i) (1) "គម្រោងចាំបាច់សម្រាប់ការចូលប្រើអ៊ីនធឺណិតតាមបណ្តាញទូលំទូលាយ" មានន័យថា គម្រោងមួយដើម្បីផ្តល់សេវាលក់រាយសម្រាប់ទីផ្សារទូទៅតាមរយៈសេវាខ្សែ សេវាឥតខ្សែ ឬវិទ្យុ ដល់អតិថិជននៅក្នុងរដ្ឋនេះ ដែលផ្តល់សមត្ថភាពក្នុងការបញ្ជូនទិន្នន័យទៅ និងទទួលទិន្នន័យពីចំណុចបញ្ចប់អ៊ីនធឺណិតទាំងអស់ ឬភាគច្រើនយ៉ាងសំខាន់ រួមមាន ប៉ុន្តែមិនកំណត់ត្រឹមសមត្ថភាពណាមួយដែលជាផ្នែកបន្ទាប់បន្សំ និងអាចឱ្យសេវាទំនាក់ទំនងដំណើរការបាន ដោយមិនរាប់បញ្ចូលសេវាចូលប្រើអ៊ីនធឺណិតតាម dial-up។

(2) "គម្រោងចាំបាច់សម្រាប់ការចូលប្រើអ៊ីនធឺណិតតាមបណ្តាញទូលំទូលាយ" ត្រូវអនុលោមតាមតម្រូវការកម្លាំងពលកម្មទាំងអស់ដែលមានចែងក្នុងផ្នែក 21183.5។

(j) (1) "គម្រោងថាមពលស្អាតចាំបាច់" មានន័យថា គម្រោងមួយដែលគាំទ្រដល់គោលដៅរបស់ California ស្តីពីអាកាសធាតុ ប្រសិទ្ធភាពថាមពល ភាពជឿជាក់ ការបំប្លែងទៅប្រើអគ្គិសនី និរន្តរភាព ឬថាមពលស្អាតតាមរយៈចំណុចមួយ ឬច្រើនដូចខាងក្រោម៖

(A) (i) ការផលិត ការបង្កើត ឬការរក្សាទុកអគ្គិសនីដែលបានមកពីធនធានកកើតឡើងវិញ ឬមាននិរន្តរភាព រួមទាំង ប៉ុន្តែមិនកំណត់ត្រឹម ថាមពលពន្លឺព្រះអាទិត្យ ថាមពលខ្យល់ ថាមពលកម្តៅក្នុងដី កោសិកាឥន្ធនៈដែលអនុលោមតាមស្តង់ដារការបំភាយឧស្ម័នដែលបានអនុម័តដោយក្រុមប្រឹក្សាធនធានខ្យល់រដ្ឋ ដោយអនុលោមតាមតម្រូវការកម្មវិធីបញ្ជាក់ការផលិតថាមពលចែកចាយនៃផ្នែក 94203 នៃចំណងជើង 17 នៃក្រមបទប្បញ្ញត្តិរបស់រដ្ឋ California, ការផលិតវារីអគ្គិសនីខ្នាតតូចដែលមានកម្លាំង 30 មេហ្គាវ៉ាត់ ឬតិចជាងនេះ ឧស្ម័នពីប្រព័ន្ធរំលាយ ការបំប្លែងកាកសំណល់រឹងក្រុង ឧស្ម័នពីទីលានចាក់សំរាម រលកសមុទ្រ ថាមពលកម្តៅមហាសមុទ្រ ឬចរន្តជំនោរ និងខ្សែបញ្ជូនអគ្គិសនីដែលពាក់ព័ន្ធ។

(ii) សម្រាប់គោលបំណងនៃផ្នែកនេះ "ខ្សែបញ្ជូនអគ្គិសនីដែលពាក់ព័ន្ធ" មានន័យថា ខ្សែបញ្ជូនអគ្គិសនីដែលត្រូវការសម្រាប់ការតភ្ជាប់បណ្តាញ ឬការបញ្ជូនអគ្គិសនីពីសំណង់ដែលបានពិពណ៌នានៅក្នុងចំណុចរង (i)។

(iii) ទោះបីជាមានចំណុចរង (i) ក៏ដោយ អនុកថាខណ្ឌនេះមិនរាប់បញ្ចូលការផលិត ឬការបង្កើតអគ្គិសនីពីថាមពលនុយក្លេអ៊ែរឡើយ។

(B) ការផលិត ការបង្កើត ការរក្សាទុក ការបញ្ជូន ឬការចែកចាយអ៊ីដ្រូសែនស្អាតដែលមិនបានមកពីវត្ថុធាតុដើមឥន្ធនៈផូស៊ីល។

(C) ការអភិវឌ្ឍ ការសាងសង់ ឬការដំឡើងបណ្តាញអគ្គិសនីខ្នាតតូច និងហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធ។ សម្រាប់គោលបំណងនៃអនុកថាខណ្ឌនេះ "បណ្តាញអគ្គិសនីខ្នាតតូច" មានន័យថា បណ្តាញអគ្គិសនីខ្នាតតូចដូចដែលបានកំណត់ក្នុងផ្នែករង (d) នៃផ្នែក 8370 នៃក្រមសេវាសាធារណៈ។

(D) ការចាប់យក ការដឹកជញ្ជូន ឬការរក្សាទុកការបំភាយកាបូនឌីអុកស៊ីតដើម្បីញែកចេញពីប្រភពជាអចិន្ត្រៃយ៍ រួមមានជាអាទិ៍ កន្លែងផលិតថាមពលកន្លែងផលិតកម្ម ឬកន្លែងចម្រាញ់។

(E) ការអភិវឌ្ឍ ការសាងសង់ ការធ្វើឱ្យប្រសើរឡើង ឬការពង្រីកសមាសភាគប្រព័ន្ធបញ្ជូន ឬចែកចាយ ដែលត្រូវបានកំណត់នៅក្នុងដំណើរការរៀបចំផែនការបញ្ជូនដែលត្រូវបានអនុម័តដោយ ប្រតិបត្តិករប្រព័ន្ធឯករាជ្យ ឬនៅក្នុងរបាយការណ៍គោលនយោបាយថាមពលរួមបញ្ចូលគ្នាដែលត្រូវបានអនុម័តដោយអនុលោមតាមផ្នែក 25302 រួមទាំងការផ្តល់ហិរញ្ញប្បទានដល់កន្លែង ទ្រព្យសកម្ម ឬសមាសភាគទាំងនោះតាមរយៈការលក់ ការជួល ការផ្ទេរសិទ្ធិ ការបញ្ចាំ ឬការចាត់ចែង ឬការដាក់បន្ទុកផ្សេងទៀតដែលទាមទារការអនុម័តពីទីភ្នាក់ងាររដ្ឋ។

(2) "គម្រោងថាមពលស្អាតចាំបាច់" ត្រូវអនុលោមតាមតម្រូវការកម្លាំងពលកម្មទាំងអស់ដែលមានចែងក្នុងផ្នែក 21183.5។

(k) (1) "គម្រោងមូលដ្ឋានអប់រំចាំបាច់" មានន័យថា ការវិញយក ការសាងសង់ ការពង្រីក ការកែទម្រង់ ការជួសជុល ការកែលម្អ ការរៀបចំគ្រឿងសង្ហារឹម ឬការបំពាក់ឧបករណ៍ដល់មូលដ្ឋានអប់រំ។

(2) គម្រោងមូលដ្ឋានអប់រំចាំបាច់ត្រូវអនុលោមតាមតម្រូវការកម្លាំងពលកម្មទាំងអស់ដែលមានចែងក្នុងផ្នែក 21183.5។

(l) "គម្រោងលំនៅឋានចាំបាច់" មានន័យថា ទាំងអស់ដូចខាងក្រោម៖

(1) យូនីតលំនៅឋានតែប៉ុណ្ណោះ។

(2) ការអភិវឌ្ឍប្រើប្រាស់ចម្រុះ។

(3) លំនៅឋានបណ្តោះអាសន្ន ទីជម្រកសង្គ្រោះបន្ទាន់ ឬលំនៅឋានគាំទ្រដូចដែលបានកំណត់ក្នុងផ្នែក 65582 នៃក្រមរដ្ឋាភិបាល។

(4) លំនៅឋានកម្មករកសិដ្ឋាន ដូចដែលបានកំណត់ក្នុងផ្នែករង (h) នៃផ្នែក 50199.7 នៃក្រមសុខភាព និងសុវត្ថិភាព។

(5) កន្លែងស្នាក់នៅជាក្រុម ដែលមានន័យថា អគារ ឬផ្នែកណាមួយនៃអគារដែលត្រូវបានរចនាឡើងសម្រាប់ ឬសម្របសម្រួលការប្រើប្រាស់ជាលំនៅឋានដោយបុគ្គលដែលមិនរស់នៅជាមួយគ្នាជាគ្រួសារ ជាទូទៅដោយគ្មានផ្ទះបាយដាច់ដោយឡែក ឬបរិក្ខារបន្ទប់ទឹកសម្រាប់បន្ទប់ ឬយូនីតនីមួយៗឡើយ។ ការប្រើប្រាស់នេះរួមមានជាអាទិ៍ វត្តដូនជី អារាម និងលំនៅឋានស្ថាប័នប្រភេទផ្សេងទៀត។

(6) យូនីតលំនៅឋាននិស្សិត។ សម្រាប់គោលបំណងនៃកថាខណ្ឌនេះ "យូនីតលំនៅឋាននិស្សិត" មានន័យថា យូនីតលំនៅឋាន ឬកន្លែងស្នាក់នៅជាក្រុមណាមួយដែលមានបំណងសម្រាប់ការប្រើប្រាស់ដោយនិស្សិត រួមមានជាអាទិ៍ លំនៅឋាននិស្សិតបែបអន្តេវាសិកដ្ឋាន និងលំនៅឋាននិស្សិតបែបបន្ទប់ឈុត។

(7) (A) យូនីតលំនៅឋានមនុស្សចាស់។ សម្រាប់គោលបំណងនៃកថាខណ្ឌនេះ "យូនីតលំនៅឋានមនុស្សចាស់" មានន័យថា យូនីតលំនៅឋាន ឬកន្លែងស្នាក់នៅជាក្រុមដែលមានទំហំណាមួយ ដែលមានបំណងសម្រាប់ការស្នាក់នៅរបស់បុគ្គលដែលមានអាយុ 55 ឆ្នាំ ឬចាស់ជាងនេះ រួមមានជាអាទិ៍ ដូចខាងក្រោម៖ (i) ការអភិវឌ្ឍលំនៅឋានអន្តរជំនាន់; (ii) លំនៅឋានប្រមូលផ្តុំសម្រាប់មនុស្សចាស់; (iii) ការអភិវឌ្ឍលំនៅឋានសម្រាប់ពលរដ្ឋជាមនុស្សចាស់ ដូចដែលបានកំណត់ក្នុងកថាខណ្ឌ (4) នៃផ្នែករង (b) នៃផ្នែក 51.3 នៃក្រមរដ្ឋប្បវេណី; (iv) មូលដ្ឋានចែទាំលំនៅឋានសម្រាប់មនុស្សចាស់ ដូចដែលបានកំណត់ក្នុងកថាខណ្ឌ (1) នៃផ្នែករង (o) នៃផ្នែក 1569.2 នៃក្រមសុខភាព និងសុវត្ថិភាព; និង (v) សហគមន៍ចូលនិវត្តន៍ដែលមានការថែទាំជាបន្តបន្ទាប់ ដូចដែលបានកំណត់ក្នុងកថាខណ្ឌ (10) នៃផ្នែករង (c) នៃផ្នែក 1771 នៃក្រមសុខភាព និងសុវត្ថិភាព។

(B) កថាខណ្ឌនេះមិនត្រូវបកស្រាយថាជាការកំណត់សិទ្ធិអំណាចរបស់ទីភ្នាក់ងារសាធារណៈក្នុងការចាត់ថ្នាក់ការប្រើប្រាស់ដីសម្រាប់លំនៅឋានមនុស្សចាស់ថាជាការប្រើប្រាស់មិនមែនលំនៅឋាន ក្រោមបទបញ្ជាកំណត់តំបន់របស់ខ្លួន ឬច្បាប់ផ្សេងទៀតឡើយ លើកលែងតែយូនីតលំនៅឋានមនុស្សចាស់ត្រូវមានលក្ខណសម្បត្តិគ្រប់គ្រាន់ជា "គម្រោងអភិវឌ្ឍន៍លំនៅឋាន" ដោយអនុលោមតាមកថាខណ្ឌ (2) នៃផ្នែករង (h) នៃផ្នែក 65589.5 នៃក្រមរដ្ឋាភិបាល។

(8) ការបែងចែកដី ឬការអភិវឌ្ឍកម្មសិទ្ធិរួម ដូចដែលបានកំណត់ក្នុងផ្នែក 4100 នៃក្រមរដ្ឋប្បវេណី ដែលមានយូនីតលំនៅឋាន ឬឡូត៍លំនៅឋានដែលមិនទាន់បានកែលម្អ។

(9) ការបំប្លែងអគារពាណិជ្ជកម្មដែលមានស្រាប់ទៅជាការប្រើប្រាស់ជាលំនៅឋាន។

(m) "គម្រោងចាំបាច់" មានន័យថា គម្រោងមួយដែលបំពេញតាមតម្រូវការទាំងអស់ដូចខាងក្រោម៖

(1) (A) គម្រោងនេះគឺជាគម្រោងលំនៅឋានចាំបាច់ គម្រោងទឹកចាំបាច់ គម្រោងថាមពលស្អាតចាំបាច់ គម្រោងសុខភាពសាធារណៈចាំបាច់ គម្រោងសុវត្ថិភាពសាធារណៈចាំបាច់ គម្រោងចាំបាច់សម្រាប់ការចូលប្រើអ៊ីនធឺណិតតាមបណ្តាញទូលំទូលាយ គម្រោងមូលដ្ឋានអប់រំចាំបាច់ ឬគម្រោងដឹកជញ្ជូនចាំបាច់។

(B) គម្រោងចាំបាច់រួមបញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឯកជន និងហេដ្ឋារចនាសម្ព័ន្ធឧបករណ៍ប្រើប្រាស់ និងមូលដ្ឋានសេវាសាធារណៈដែលពាក់ព័ន្ធ និងជាជំនួយទាំងអស់ ដែលតម្រូវដោយក្រុមហ៊ុនផ្គត់ផ្គង់ឧបករណ៍ប្រើប្រាស់ ឬទីភ្នាក់ងារសាធារណៈ ឬដែលបានរួមបញ្ចូលនៅក្នុងពាក្យសុំគម្រោងចាំបាច់ជាផ្នែកមួយនៃគម្រោងទាំងមូល ដើម្បីបម្រើដល់គម្រោងដែលបានកំណត់នៅក្នុងអនុកថាខណ្ឌ (A) រួមមានជាអាទិ៍ ការកែលម្អផ្នែកអគ្គិសនី ទូរគមនាគមន៍ ឧស្ម័ន ទឹក ទឹកកខ្វក់ ទឹកព្យុះភ្លៀង ការដឹកជញ្ជូនសាធារណៈ ប៉ូលិស ពន្លត់អគ្គិភ័យ និងការដឹកជញ្ជូន ដែលផ្តល់សេវាសាធារណៈ និងសេវាឧបករណ៍ប្រើប្រាស់ និងហេដ្ឋារចនាសម្ព័ន្ធដែលត្រូវការដល់គម្រោង។ នៅពេលដែលស្តង់ដារកម្លាំងពលកម្មជាក់លាក់ណាមួយត្រូវបានអនុវត្តចំពោះគម្រោងចាំបាច់ដោយបទប្បញ្ញត្តិផ្សេងទៀតនៃជំពូកនេះ ស្តង់ដារកម្លាំងពលកម្មនោះត្រូវអនុវត្តចំពោះសមាសភាគនៃគម្រោងចាំបាច់ដែលបានពិពណ៌នានៅក្នុងអនុកថាខណ្ឌនេះ។

(2) គម្រោងនេះមិនរាប់បញ្ចូលពន្ធនាគារ ឬមូលដ្ឋានឃុំឃាំងផ្សេងទៀត ឬពាក់ព័ន្ធនឹងការអភិវឌ្ឍមូលដ្ឋានផលិតប្រេង ឬឧស្ម័នធម្មជាតិថ្មីនោះឡើយ។

(n) (1) "គម្រោងសុខភាពសាធារណៈចាំបាច់" មានន័យថា មូលដ្ឋានព្យាបាលវេជ្ជសាស្ត្រ។

(2) "គម្រោងសុខភាពសាធារណៈចាំបាច់" ត្រូវអនុលោមតាមតម្រូវការកម្លាំងពលកម្មទាំងអស់ដែលមានចែងក្នុងផ្នែក 21183.5។

(o) (1) "គម្រោងសុវត្ថិភាពសាធារណៈចាំបាច់" មានន័យថា មូលដ្ឋានសម្រាប់អ្នកឆ្លើយតបបឋម ឬគម្រោងកាត់បន្ថយហានិភ័យភ្លើងឆេះព្រៃ។

(2) (A) "គម្រោងសុវត្ថិភាពសាធារណៈចាំបាច់" ត្រូវអនុលោមតាមតម្រូវការកម្លាំងពលកម្មទាំងអស់ដែលមានចែងក្នុងផ្នែក 21183.5។

(B) គម្រោងកាត់បន្ថយហានិភ័យភ្លើងឆេះព្រៃដែលកំណត់ត្រឹមការគ្រប់គ្រងរុក្ខជាតិ ការកាត់បន្ថយឥន្ធនៈឆេះ ការបង្កើត ឬការថែរក្សាចន្លោះទប់ស្កាត់ភ្លើង ឬការកាត់បន្ថយបន្ទុកឥន្ធនៈឆេះ ដែលត្រូវបានអនុវត្តដោយផ្ទាល់ដោយទីភ្នាក់ងារសាធារណៈដោយប្រើប្រាស់និយោជិតរបស់ខ្លួន ត្រូវចាត់ទុកថាអនុលោមតាមកថាខណ្ឌនេះ ប្រសិនបើនិយោជិតរបស់ទីភ្នាក់ងារសាធារណៈដែលធ្វើការលើគម្រោងនោះ ត្រូវបានគ្របដណ្តប់ដោយកិច្ចព្រមព្រៀងចរចាជាសមូហភាព ឬច្បាប់សេវាកម្មស៊ីវិលរបស់រដ្ឋផ្សេងទៀត ដែលផ្តល់ស្តង់ដារប្រាក់ឈ្នួល ការបណ្តុះបណ្តាល និងសុវត្ថិភាពសមមូល។

(p) (1) "គម្រោងដឹកជញ្ជូនចាំបាច់" មានន័យថា ទាំងពីរដូចខាងក្រោម៖

(A) គម្រោងដែលបានពិពណ៌នានៅក្នុងផ្នែករង (a) ឬ (b) នៃផ្នែក 2 នៃមាត្រា XIX នៃរដ្ឋធម្មនុញ្ញនៃរដ្ឋ California។

(B) ហេដ្ឋារចនាសម្ព័ន្ធសម្រាប់សាកថ្ម និងចាក់បំពេញឥន្ធនៈយានយន្តអគ្គិសនី។

(2) "គម្រោងដឹកជញ្ជូនចាំបាច់" ត្រូវអនុលោមតាមតម្រូវការកម្លាំងពលកម្មទាំងអស់ដែលមានចែងក្នុងផ្នែក 21183.5។

(3) "គម្រោងដឹកជញ្ជូនចាំបាច់" មិនរាប់បញ្ចូលរថភ្លើងល្បឿនលឿន ប្រព័ន្ធរថភ្លើងល្បឿនលឿន ច្រករបៀង ឬកំណាត់ដែលអាចប្រើប្រាស់បាន ដូចដែលពាក្យទាំងនោះត្រូវបានកំណត់ក្នុងផ្នែក 2704.01 នៃក្រមផ្លូវថ្នល់ និងផ្លូវហាយវេ ឬសមាសភាគផ្សេងទៀតណាមួយនៃ ច្បាប់ស្តីពីសញ្ញាបណ្ណរថភ្លើងដឹកអ្នកដំណើរល្បឿនលឿន ប្រកបដោយសុវត្ថិភាព និងអាចទុកចិត្តបាន សម្រាប់សតវត្សទី 21 (ជំពូក 20 (ចាប់ផ្តើមជាមួយផ្នែកទី 2704) នៃផ្នែក 3 នៃក្រមផ្លូវថ្នល់ និងផ្លូវហាយវេ) ឡើយ។

(q) (1) "គម្រោងទឹកចាំបាច់" មានន័យថា គម្រោង ឬសកម្មភាពណាមួយដើម្បីសាងសង់ ពង្រីក ជួសជុល ជំនួស កែលម្អ ឬបង្កើនសមត្ថភាពរបស់ចំណុចណាមួយដូចខាងក្រោម៖ (A) "ប្រព័ន្ធទឹកសាធារណៈ" ដូចដែលបានកំណត់ក្នុងផ្នែករង (h) នៃផ្នែក 116275 នៃក្រមសុខភាព និងសុវត្ថិភាព; (B) ប្រព័ន្ធដែលផ្តល់ទឹកដោយផ្ទាល់ ឬដោយប្រយោលដល់ប្រព័ន្ធទឹកសាធារណៈ; ឬ (C) ប្រព័ន្ធដែលត្រូវបានពិពណ៌នាជាទូទៅ និងស្ថិតក្នុងវិសាលភាពនៃ ផែនការភាពធន់ផ្នែកទឹក របស់រដ្ឋ។

(2) "គម្រោងទឹកចាំបាច់" ត្រូវអនុលោមតាមតម្រូវការកម្លាំងពលកម្មទាំងអស់ដែលមានចែងក្នុងផ្នែក 21183.5។

(3) "គម្រោងទឹកចាំបាច់" មិនរាប់បញ្ចូលសំណង់បញ្ជូនទឹកតំបន់ដីសណ្តដូចដែលបានកំណត់ក្នុងផ្នែករង (f) នៃផ្នែក 79702 នៃក្រមទឹកឡើយ។

(r) "ច្បាប់ដែលមានស្រាប់" មានន័យថា ដូចខាងក្រោម៖

(1) តម្រូវការផ្លូវច្បាប់ដែលត្រូវបានអនុម័តជាផ្លូវការ ដែលមានចែងក្នុងលក្ខន្តិក: បទប្បញ្ញត្តិ វិធាន ស្តង់ដា ឬបទបញ្ជា ដែលមានអត្ថិភាព និងចូលជាធរមាននៅកាលបរិច្ឆេទដែលពាក្យសុំសម្រាប់គម្រោងចាំបាច់ត្រូវបានដាក់ស្នើទៅកាន់ទីភ្នាក់ងារសាធារណៈ។

(2) (A) តម្រូវការផ្លូវច្បាប់ដែលត្រូវបានអនុម័តជាផ្លូវការ ដែលមានចែងក្នុងលក្ខន្តិកៈ បទប្បញ្ញត្តិ បទបញ្ជា ស្តង់ដា ឬវិធាន ដែលមិនទាន់ចូលជាធរមាននៅកាលបរិច្ឆេទដែលពាក្យសុំសម្រាប់គម្រោងចាំបាច់ត្រូវបានដាក់ស្នើទៅកាន់ទីភ្នាក់ងារសាធារណៈ ប៉ុន្តែទីភ្នាក់ងារដឹកនាំធ្វើការកំណត់ថា ការអនុលោមតាមលក្ខន្តិកៈ បទប្បញ្ញត្តិ បទបញ្ជា ស្តង់ដា ឬវិធានជាក់លាក់នោះ គឺចាំបាច់ដើម្បីកាត់បន្ថយ ឬជៀសវាងផលប៉ះពាល់អវិជ្ជមានជាក់លាក់លើសុវត្ថិភាពអាយុជីវិត ដែលមានន័យថា ផលប៉ះពាល់លើសុវត្ថិភាពអាយុជីវិតដែលមានសារៈសំខាន់ អាចកំណត់ជាបរិមាណបាន ដោយផ្ទាល់ និងមិនអាចជៀសវាងបាន រួមទាំងផលប៉ះពាល់លើសុវត្ថិភាពអាយុជីវិតដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យា សម្ភារៈ ឬប្រព័ន្ធសមាហរណកម្មបណ្តាញអគ្គិសនីថ្មី ឬដែលទើបនឹងលេចឡើង ហើយដែលផ្អែកលើស្តង់ដា គោលនយោបាយ ឬលក្ខខណ្ឌសុវត្ថិភាពសាធារណៈដែលមានលក្ខណៈវត្ថុវិស័យ ត្រូវបានកំណត់ និងជាលាយលក្ខណ៍អក្សរ។ ទីភ្នាក់ងារដឹកនាំត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យសុំក្នុងរយៈពេល 72 ម៉ោង បន្ទាប់ពីធ្វើការកំណត់ដែលបានពិពណ៌នានៅក្នុងអនុកថាខណ្ឌនេះ។

(B) ការកំណត់ដែលបានពិពណ៌នានៅក្នុងអនុកថាខណ្ឌ (A) ត្រូវធ្វើឡើងមុនពេល (i) ការពិនិត្យមើលបរិស្ថាននៃគម្រោងចាំបាច់ដោយអនុលោមតាមជំពូកនេះត្រូវបានបញ្ចប់ ឬ (ii) ពាក្យសុំលិខិតអនុញ្ញាតសាងសង់ដំបូង ឬកញ្ចប់ឯកសារពិនិត្យមើលប្លង់ត្រូវបានដាក់ស្នើទៅកាន់អាជ្ញាធរដែលមានយុត្តាធិការលើគម្រោង អាស្រ័យលើថាតើមួយណាកើតឡើងមុន។

(3) ការធ្វើបច្ចុប្បន្នភាពណាមួយចំពោះក្រមស្តង់ដាសំណង់ California រួមមានជាអាទិ៍ ក្រមអគ្គីភ័យ California ដែលចូលជាធរមានមុនពេល (A) ការពិនិត្យមើលបរិស្ថាននៃគម្រោងចាំបាច់ដោយអនុលោមតាមជំពូកនេះត្រូវបានបញ្ចប់ ឬ (B) ពាក្យសុំលិខិតអនុញ្ញាតសាងសង់ដំបូង ឬកញ្ចប់ឯកសារពិនិត្យមើលប្លង់ត្រូវបានដាក់ស្នើទៅកាន់អាជ្ញាធរដែលមានយុត្តាធិការលើគម្រោង អាស្រ័យលើថាតើមួយណាកើតឡើងមុន។

(s) "អាចធ្វើទៅបាន" មានន័យថា អាចសម្រេចបានដោយជោគជ័យក្នុងរយៈពេលសមស្របមួយ ដោយគិតគូរពីកត្តាសេដ្ឋកិច្ច បរិស្ថាន ច្បាប់ សង្គម និងបច្ចេកវិទ្យា។

(t) (1) "មូលដ្ឋានអ្នកឆ្លើយតបបឋម" មានន័យថា ទាំងអស់ដូចខាងក្រោម៖

(A) ស្ថានីយពន្លត់អគ្គីភ័យដែលជាកម្មសិទ្ធិ ឬដំណើរការដោយរដ្ឋ California ទីក្រុង ខោនធី ទីក្រុងនិងខោនធី អាជ្ញាធរអំណាចរួម កុលសម្ព័ន្ធពិគ្រោះយោបល់ ឬមណ្ឌលពិសេស។

(B) ប៉ុស្តិ៍ប៉ូលិស ឬប៉ុស្តិ៍សេរីហ្វ ដែលជាកម្មសិទ្ធិ ឬដំណើរការដោយទីក្រុង ខោនធី ទីក្រុងនិងខោនធី អាជ្ញាធរអំណាចរួម ឬមណ្ឌលពិសេស ដោយមិនរាប់បញ្ចូលផ្នែកណាមួយដែលប្រើប្រាស់ជាពន្ធនាគារ ឬមូលដ្ឋានឃុំឃាំងផ្សេងទៀតឡើយ។

(2) "មូលដ្ឋានអ្នកឆ្លើយតបបឋម" មិនរាប់បញ្ចូលចំណុចណាមួយដូចខាងក្រោម៖

(A) មូលដ្ឋានណាមួយដែលជាកម្មសិទ្ធិ ដំណើរការ ឬជួលដោយរដ្ឋាភិបាលសហរដ្ឋអាម៉េរិក។

(B) មូលដ្ឋានណាមួយដែលប្រើប្រាស់ជាមូលដ្ឋានឃុំឃាំងអន្តោប្រវេសន៍ ឬពន្ធនាគាររដ្ឋ។

(u) "ទីភ្នាក់ងារដឹកនាំ" មានន័យថា ទីភ្នាក់ងារដឹកនាំដូចដែលបានកំណត់ក្នុងផ្នែក 21067។

(v) "ទីភ្នាក់ងារមូលដ្ឋាន" មានន័យថា អង្គភាពសាធារណៈដែលមិនមែនជា "ទីភ្នាក់ងាររដ្ឋ" ដូចដែលបានកំណត់ក្នុងមាត្រានេះ។

(w) "អគារការិយាល័យវេជ្ជសាស្ត្រ" មានន័យថា អគារមួយដែលមានមុខងារចម្បងក្នុងការផ្តល់កន្លែងការិយាល័យសម្រាប់អ្នកប្រកបវិជ្ជាជីវៈថែទាំសុខភាពដែលមានអាជ្ញាបណ្ណ វិញ្ញាបនបត្រ ចុះបញ្ជី ឬត្រូវបានអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈដោយអនុលោមតាមផ្នែក 2 (ចាប់ផ្តើមជាមួយផ្នែកទី 500) នៃក្រមអាជីវកម្ម និងវិជ្ជាជីវៈ។

(x) "មូលដ្ឋានព្យាបាលវេជ្ជសាស្ត្រ" មានន័យថា ទាំងអស់ដូចខាងក្រោម៖ (1) មូលដ្ឋានសុខាភិបាលដូចដែលបានកំណត់ក្នុងផ្នែក 1250 នៃក្រមសុខភាព និងសុវត្ថិភាព; (2) គ្លីនិកដូចដែលបានកំណត់ក្នុងផ្នែក 1200 នៃក្រមសុខភាព និងសុវត្ថិភាព; និង (3) អគារការិយាល័យវេជ្ជសាស្ត្រ។

(y) (1) "ការអភិវឌ្ឍប្រើប្រាស់ចម្រុះ" មានន័យថា ការអភិវឌ្ឍដែលមានការប្រើប្រាស់សម្រាប់លំនៅឋាន និងមិនមែនសម្រាប់លំនៅឋាន ដែលបំពេញតាមលក្ខខណ្ឌណាមួយដូចខាងក្រោម៖

(A) យ៉ាងហោចណាស់ពីរភាគបីនៃទំហំផ្ទៃក្រឡាថ្មី ឬដែលបានបំប្លែង ត្រូវបានកំណត់សម្រាប់ការប្រើប្រាស់ជាលំនៅឋាន។

(B) យ៉ាងហោចណាស់ 50 ភាគរយនៃទំហំផ្ទៃក្រឡាថ្មី ឬដែលបានបំប្លែង ត្រូវបានកំណត់សម្រាប់ការប្រើប្រាស់ជាលំនៅឋាន ហើយគម្រោងនេះបំពេញតាមចំណុចទាំងពីរដូចខាងក្រោម៖

(i) គម្រោងនេះរួមបញ្ចូលយ៉ាងហោចណាស់ 500 យូនីតលំនៅឋានថ្មីសុទ្ធ។

(ii) គ្មានផ្នែកណាមួយនៃគម្រោងត្រូវបានកំណត់សម្រាប់ការប្រើប្រាស់ជាសណ្ឋាគារ ម៉ូតែល ផ្ទះសំណាក់ ផ្ទះសំណាក់ដែលមានអាហារពេលព្រឹក ឬកន្លែងស្នាក់នៅបណ្តោះអាសន្នផ្សេងទៀតឡើយ លើកលែងតែផ្នែកមួយនៃគម្រោងអាចត្រូវបានកំណត់សម្រាប់ការប្រើប្រាស់ជាសណ្ឋាគារលំនៅឋានដូចដែលបានកំណត់ក្នុងផ្នែក 50519 នៃក្រមសុខភាព និងសុវត្ថិភាព។

(C) យ៉ាងហោចណាស់ 50 ភាគរយនៃទំហំផ្ទៃក្រឡាថ្មីសុទ្ធ ឬដែលបានបំប្លែង ត្រូវបានកំណត់សម្រាប់ការប្រើប្រាស់ជាលំនៅឋាន ហើយគម្រោងនេះបំពេញតាមចំណុចទាំងអស់ដូចខាងក្រោម៖

(i) គម្រោងនេះរួមបញ្ចូលយ៉ាងហោចណាស់ 500 យូនីតលំនៅឋានថ្មីសុទ្ធ។

(ii) គម្រោងនេះពាក់ព័ន្ធនឹងការរុះរើ ឬការបំប្លែងយ៉ាងហោចណាស់ 100,000 ហ្វីតការ៉េនៃការប្រើប្រាស់មិនមែនសម្រាប់លំនៅឋានទៅជាការប្រើប្រាស់សម្រាប់លំនៅឋាន។

(iii) គម្រោងនេះរុះរើយ៉ាងហោចណាស់ 50 ភាគរយនៃការប្រើប្រាស់មិនមែនសម្រាប់លំនៅឋានដែលមានស្រាប់នៅលើទីតាំងនោះ។

(iv) គ្មានផ្នែកណាមួយនៃគម្រោងត្រូវបានកំណត់សម្រាប់ការប្រើប្រាស់ជាសណ្ឋាគារ ម៉ូតែល ផ្ទះសំណាក់ ផ្ទះសំណាក់ដែលមានអាហារពេលព្រឹក ឬកន្លែងស្នាក់នៅបណ្តោះអាសន្នផ្សេងទៀតឡើយ លើកលែងតែផ្នែកមួយនៃគម្រោងអាចត្រូវបានកំណត់សម្រាប់ការប្រើប្រាស់ជាសណ្ឋាគារលំនៅឋានដូចដែលបានកំណត់ក្នុងផ្នែក 50519 នៃក្រមសុខភាព និងសុវត្ថិភាព។

(2) សម្រាប់គោលបំណងនៃផ្នែករងនេះ ការប្រើប្រាស់មិនមែនសម្រាប់លំនៅឋាន មិនត្រូវរាប់បញ្ចូលការប្រើប្រាស់ ឬការកំណត់ជាឧស្សាហកម្មធុនធ្ងន់ ការទាញយកធនធាន កំពង់ផែ រោងចក្រចម្រាញ់ ឬការប្រើប្រាស់ ឬការកំណត់ពាក់ព័ន្ធនឹងសារធាតុគ្រោះថ្នាក់ឡើយ។

(3) ចម្ងាយអប្បបរមាដែលតម្រូវរវាងការប្រើប្រាស់មិនមែនសម្រាប់លំនៅឋានណាមួយដែលបានរួមបញ្ចូលក្នុងការអភិវឌ្ឍប្រើប្រាស់ចម្រុះ និងការប្រើប្រាស់សម្រាប់លំនៅឋានក្រៅទីតាំងដែលមានស្រាប់ណាមួយ ត្រូវកំណត់ដោយច្បាប់រដ្ឋ។

(z) "ទីភ្នាក់ងារសាធារណៈ" មានន័យថា ទីភ្នាក់ងារសាធារណៈដូចដែលបានកំណត់ក្នុងផ្នែក 15379 នៃចំណងជើង 14 នៃក្រមបទប្បញ្ញត្តិរបស់រដ្ឋ California; ទីភ្នាក់ងារទទួលខុសត្រូវ; ទីភ្នាក់ងារមូលដ្ឋាន; ទីភ្នាក់ងាររដ្ឋ; ទីភ្នាក់ងារដឹកនាំ; គណៈកម្មការបង្កើតទីភ្នាក់ងារមូលដ្ឋាន; ទីក្រុង; ខោនធី; ទីក្រុងនិងខោនធី; មណ្ឌលពិសេស; អាជ្ញាធរអំណាចរួម; ឬអាជ្ញាធររដ្ឋាភិបាលផ្សេងទៀតណាមួយដែលត្រូវបានបង្កើតឡើងក្រោមច្បាប់រដ្ឋ ឬមូលដ្ឋាន ទោះបីជាមានលក្ខណៈទូទាំងរដ្ឋ មូលដ្ឋាន ឬតំបន់ក៏ដោយ។

(aa) "នីតិវិធីសម្រាប់ការចូលរួមរបស់សាធារណៈជន" មានន័យថា នីតិវិធីសម្រាប់ការចូលរួមរបស់សាធារណៈជនដែលមានចែងក្នុងផ្នែក 21016, 21018, 21020, 21021, 21023 និង 21024។

(ab) "ទីភ្នាក់ងារទទួលខុសត្រូវ" មានន័យថា ទីភ្នាក់ងារទទួលខុសត្រូវដូចដែលបានកំណត់ក្នុងផ្នែក 15381 នៃចំណងជើង 14 នៃក្រមបទប្បញ្ញត្តិរបស់រដ្ឋ California។

(ac) "ទីភ្នាក់ងាររដ្ឋ" មានន័យថា ទីភ្នាក់ងាររដ្ឋដូចដែលបានកំណត់ក្នុងផ្នែករង (a) នៃផ្នែក 8557 នៃក្រមរដ្ឋាភិបាល និងស្ថាប័នរដ្ឋណាមួយដូចដែលបានកំណត់ក្នុងផ្នែក 11121 នៃក្រមរដ្ឋាភិបាល។

(ad) "គោលការណ៍ណែនាំរដ្ឋ CEQA" មានន័យថា ជំពូក 3 (ចាប់ផ្តើមជាមួយផ្នែកទី 15000) នៃផ្នែក 6 នៃចំណងជើង 14 នៃក្រមបទប្បញ្ញត្តិរបស់រដ្ឋ California។

(ae) "កស្តុតាងសំខាន់" មានន័យថា ព័ត៌មានពាក់ព័ន្ធគ្រប់គ្រាន់ និងការទាញយកន័យដោយសមហេតុផលពីព័ត៌មានដែលមាន ដែលអាចធ្វើអំណះអំណាងយុត្តិធម៌ដើម្បីគាំទ្រសេចក្តីសន្និដ្ឋានមួយ ទោះបីជាអាចឈានដល់សេចក្តីសន្និដ្ឋានផ្សេងទៀតក៏ដោយ។

(af) "ធនធានវប្បធម៌កុលសម្ព័ន្ធ" រួមមានចំណុចណាមួយដូចខាងក្រោម៖

(1) ទីតាំង លក្ខណៈពិសេស ទីកន្លែង ទេសភាពវប្បធម៌ ឬទីកន្លែងសក្ការៈ រួមទាំងទីបញ្ចុះសពដែលបានធ្វើឱ្យបរិសុទ្ធ ទីបញ្ចុះសពជនជាតិដើមអាម៉េរិក ឬតំបន់បញ្ចុះសពរបស់កុលសម្ព័ន្ធពិគ្រោះយោបល់ ឬវត្ថុដែលមានតម្លៃខាងវប្បធម៌ចំពោះកុលសម្ព័ន្ធពិគ្រោះយោបល់ ដែលមានលក្ខណៈណាមួយដូចខាងក្រោម៖

(A) មានចុះបញ្ជី ឬមានលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីចុះបញ្ជីក្នុង បញ្ជីធនធានប្រវត្តិសាស្ត្រ California ឬ បញ្ជីជាតិនៃទីកន្លែងប្រវត្តិសាស្ត្រ។

(B) មានចុះបញ្ជីក្នុងបញ្ជីមូលដ្ឋាននៃធនធានប្រវត្តិសាស្ត្រ ដូចដែលបានកំណត់ក្នុងផ្នែក 5020.1។

(C) ត្រូវបានកំណត់ដោយគណៈកម្មការទទួលបន្ទុកបេតិកភណ្ឌជនជាតិដើមអាម៉េរិក ជាទីកន្លែងសក្ការៈដោយអនុលោមតាមផ្នែក 5097.94 ឬ 5097.96។

(D) មានចុះបញ្ជីក្នុងបញ្ជីរបស់រដ្ឋាភិបាលកុលសម្ព័ន្ធដែលត្រូវបានរក្សាទុកដោយ មន្ត្រីអភិរក្សប្រវត្តិសាស្ត្រកុលសម្ព័ន្ធ ដែលត្រូវបានអនុម័តដោយរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដោយអនុលោមតាមផ្នែក 101 នៃច្បាប់សហព័ន្ធ ច្បាប់អភិរក្សប្រវត្តិសាស្ត្រជាតិ (54 U.S.C. ផ្នែក 300101 et seq.)។

(2) ទេសភាពវប្បធម៌ដែលបំពេញតាមលក្ខណៈវិនិច្ឆ័យនៃកថាខណ្ឌ (1) ក្នុងកម្រិតដែលទេសភាពនោះត្រូវបានកំណត់តាមភូមិសាស្ត្រដោយផ្អែកលើទំហំ និងវិសាលភាពរបស់ទេសភាព។

(3) ធនធានប្រវត្តិសាស្ត្រដែលបានពិពណ៌នាក្នុងផ្នែក 21084.1 ធនធានបុរាណវិទ្យាដែលមានលក្ខណៈតែមួយគត់ ដូចដែលបានកំណត់ក្នុងផ្នែករង (g) នៃផ្នែក 21083.2 ឬ "ធនធានបុរាណវិទ្យាដែលមិនមានលក្ខណៈតែមួយគត់" ដូចដែលបានកំណត់ក្នុងផ្នែករង (h) នៃផ្នែក 21083.2 ដែលអនុលោមតាមលក្ខណៈវិនិច្ឆ័យនៃកថាខណ្ឌ (1)។

(ag) "គម្រោងកាត់បន្ថយហានិភ័យភ្លើងឆេះព្រៃ" មានន័យថា សកម្មភាពដែលកាត់បន្ថយហានិភ័យភ្លើងឆេះព្រៃចំពោះសំណង់លំនៅឋាន ឬសំណង់ពាណិជ្ជកម្ម ឬទាំងពីរ។ "គម្រោងកាត់បន្ថយហានិភ័យភ្លើងឆេះព្រៃ" រួមមានជាអាទិ៍ ការជំនួស ការពង្រឹងឱ្យធន់ ឬការដាក់ខ្សែឧបករណ៍ប្រើប្រាស់អគ្គិសនីនៅក្រោមដី ផ្លូវ និងហេដ្ឋារចនាសម្ព័ន្ធ; ការគ្រប់គ្រងរុក្ខជាតិ; ការកាត់បន្ថយឥន្ធនៈឆេះ; ការពង្រឹងលំនៅឋានឱ្យធន់; ការបង្កើត ឬការថែរក្សាចន្លោះទប់ស្កាត់ភ្លើង និងផ្លូវចូលប្រើប្រាស់; និងការកាត់បន្ថយបន្ទុកឥន្ធនៈឆេះ។

មាត្រា 8. ការបកស្រាយជំពូក និងបទប្បញ្ញត្តិទូទៅ

21029. ការបកស្រាយជំពូក

(a) ជាគោលនយោបាយរបស់ប្រជាជននៃរដ្ឋ California ថា ជំពូកនេះត្រូវបកស្រាយ និងអនុវត្ត ដើម្បីផ្តល់ទម្ងន់ខ្ពស់បំផុតដែលអាចធ្វើទៅបានដល់ផលប្រយោជន៍នៃគម្រោងចាំបាច់ និងដល់ការអនុម័ត និងការសម្រេចឱ្យបាននូវគម្រោងចាំបាច់។

(b) (1) ប្រជាជននៃរដ្ឋ California មានបំណងឱ្យតុលាការ ដោយអនុលោមតាមវិធានដែលទទួលស្គាល់ជាទូទៅសម្រាប់ការបកស្រាយលក្ខន្តិក: មិនបកស្រាយផ្នែកនេះ ឬគោលការណ៍ណែនាំរដ្ឋ CEQA តាមរបៀបដែលដាក់តម្រូវការផ្នែកនីតិវិធី ឬខ្លឹមសារលើគម្រោងចាំបាច់លើសពីតម្រូវការដែលបានចែងយ៉ាងច្បាស់លាស់នៅក្នុងផ្នែកនេះ ឬគោលការណ៍ណែនាំរដ្ឋ CEQA។

(2) ប្រជាជននៃរដ្ឋ California ក៏មានបំណងឱ្យតុលាការបកស្រាយ និងអនុវត្តផ្នែករងនេះតាមការណែនាំក្នុងផ្នែក 21083.1 ហើយឱ្យផ្នែករងនេះស្ថិតក្នុង in pari materia ជាមួយផ្នែក 21083.1 ដើម្បីឱ្យបានអតិបរមាតាមដែលច្បាប់អនុញ្ញាត ផ្នែករងនេះកំណត់សិទ្ធិអំណាចរបស់តុលាការក្នុងការចេញសាលក្រម ឬដាក់មធ្យោបាយដោះស្រាយដែលមិនត្រូវបានអនុញ្ញាតយ៉ាងច្បាស់លាស់ដោយជំពូកនេះ។

21030. បញ្ហាដែលមានសារៈសំខាន់ទូទាំងរដ្ឋ

ប្រជាជននៃរដ្ឋ California តាមនេះប្រកាសថា ការសម្រួលការពិនិត្យមើលនិងការអនុម័តគម្រោងចាំបាច់ ដូចដែលបានផ្តល់ជូនក្នុងជំពូកនេះ គឺជាបញ្ហាដែលមានសារៈសំខាន់ទូទាំងរដ្ឋ ពីព្រោះភាពគ្រប់គ្រាន់ ភាពអាចរកបាន និងភាពមានតម្លៃសមរម្យនៃលំនៅឋាន ថាមពលស្អាត ទឹក ការដឹកជញ្ជូនអ៊ីនធឺណិតតាមបណ្តាញទូលំទូលាយ មូលដ្ឋានអប់រំ ហេដ្ឋារចនាសម្ព័ន្ធសុខភាពសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធសុវត្ថិភាពសាធារណៈ មិនគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការរបស់ប្រជាជន និងសេដ្ឋកិច្ចរបស់ California។ ដូច្នេះ រដ្ឋ California តាមនេះកាន់កាប់ដែនអំណាចទាំងស្រុងក្នុងវិស័យនៃការពិនិត្យមើល និងការអនុម័តគម្រោងចាំបាច់ ដូចដែលបានផ្តល់ជូនក្នុងជំពូកនេះ។

21031. សេចក្តីយោងតាមលក្ខន្តិក:

(a) លើកលែងតែមានចែងក្នុងផ្នែករង (b) សេចក្តីយោងទាំងអស់ទៅកាន់លក្ខន្តិក: ឬបទប្បញ្ញត្តិរបស់រដ្ឋដែលត្រូវបានចងក្រងជាក្រមនៅក្រៅជំពូកនេះ សំដៅទៅលើលក្ខន្តិក: និងបទប្បញ្ញត្តិទាំងនោះតាមស្ថានភាពដែលមាននៅថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2025 ដោយមិនគិតពីការធ្វើវិសោធនកម្ម ការលុបចោល ការផុតសុពលភាព ឬការផុតកំណត់ជាបន្តបន្ទាប់ណាមួយដែលកើតឡើងបន្ទាប់ពីកាលបរិច្ឆេទនោះឡើយ។

(b) សេចក្តីយោងទៅកាន់ផ្នែក 218.9 នៃក្រមការងារ សំដៅទៅលើផ្នែកនោះតាមស្ថានភាពដែលមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2026។

21032. ភាពអាចបំបែកបាន

បទប្បញ្ញត្តិនៃជំពូកនេះអាចបំបែកបាន។ ប្រសិនបើចំណែកណាមួយ ផ្នែក ផ្នែករង កថាខណ្ឌ អនុកថាខណ្ឌ ប្រការ ប្រការរង ប្រយោគ ឃ្លា ពាក្យ ឬការអនុវត្តណាមួយនៃជំពូកនេះត្រូវបានកំណត់ថាមិនមានសុពលភាពដោយហេតុផលណាមួយ តាមសេចក្តីសម្រេចរបស់តុលាការណាមួយដែលមានយុត្តាធិការត្រឹមត្រូវ នោះសេចក្តីសម្រេចនោះមិនត្រូវប៉ះពាល់ដល់សុពលភាពនៃផ្នែកដែលនៅសល់នៃជំពូកនេះឡើយ។ ប្រជាជននៃរដ្ឋ California តាមនេះប្រកាសថា ពួកគេនឹងបានអនុម័តជំពូកនេះ និងចំណែក ផ្នែក ផ្នែករង កថាខណ្ឌ អនុកថាខណ្ឌ ប្រការ ប្រការរង ប្រយោគ ឃ្លា ពាក្យ និងការអនុវត្តនីមួយៗទាំងអស់ ដែលមិនត្រូវបានប្រកាសថាមិនមានសុពលភាព ឬផ្ទុយនឹងរដ្ឋធម្មនុញ្ញ ដោយមិនគិតថាតើសមាសភាគណាមួយនៃជំពូកនេះ ឬការអនុវត្តជំពូកនេះ នឹងត្រូវបានប្រកាសជាបន្តបន្ទាប់ថាមិនមានសុពលភាពឬយ៉ាងណាឡើយ។

21033. កាលបរិច្ឆេទចូលជាធរមាន

ជំពូកនេះត្រូវចូលជាធរមានតាមដែលបានចែងក្នុងផ្នែករង (a) នៃផ្នែក 10 នៃមាត្រា II នៃរដ្ឋធម្មនុញ្ញ California ហើយចាប់ពីកាលបរិច្ឆេទចូលជាធរមាននោះ ត្រូវអនុវត្តចំពោះការពិនិត្យមើល និងដំណើរការរបស់ទីភ្នាក់ងារសាធារណៈ និងការត្រួតពិនិត្យតាមផ្លូវតុលាការ និងដំណើរការទាំងអស់ដែលកំពុងរង់ចាំ និងនាពេលអនាគត សម្រាប់គម្រោងចាំបាច់ទាំងអស់។

21034. វិសោធនកម្ម

អង្គនីតិបញ្ញត្តិអាចធ្វើវិសោធនកម្មជំពូកនេះដោយលក្ខន្តិកៈមួយដែលត្រូវបានអនុម័តនៅក្នុងសភានីមួយៗនៃអង្គនីតិបញ្ញត្តិតាមរយៈការបោះឆ្នោតហៅឈ្មោះដែលបានកត់ត្រាទុកក្នុងកំណត់ហេតុ ដោយមានសមាជិកពីរភាគបីយល់ព្រម ប្រសិនបើលក្ខន្តិកៈនោះស្របតាម និងលើកកម្ពស់គោលបំណងនៃជំពូកនេះ។ គ្មានសេចក្តីព្រាងច្បាប់ដែលស្នើសុំធ្វើវិសោធនកម្មជំពូកនេះអាចត្រូវបានអនុម័ត ឬក្លាយជាលក្ខន្តិកៈឡើយ លុះត្រាតែសេចក្តីព្រាងច្បាប់នោះត្រូវបានបោះពុម្ព និងចែកចាយជូនសមាជិកអង្គនីតិបញ្ញត្តិ និងផ្សព្វផ្សាយតាមអ៊ីនធឺណិតជាទម្រង់ចុងក្រោយរបស់ខ្លួន យ៉ាងហោចណាស់ 12 ថ្ងៃធ្វើការ មុនពេលអនុម័តនៅក្នុងសភាណាមួយនៃអង្គនីតិបញ្ញត្តិ។

ផ្នែកទី 2. វិធានការដែលផ្ទុយគ្នា។

ក្នុងករណីដែលវិធានការផ្តួចផ្តើមនេះ និងវិធានការមួយ ឬច្រើនផ្សេងទៀតដែលពាក់ព័ន្ធនឹងការពិនិត្យមើល ឬការអនុម័តគម្រោងចាំបាច់ ដូចដែលបានកំណត់ក្នុងច្បាប់នេះ បង្ហាញខ្លួននៅលើសន្លឹកឆ្នោតនៃការបោះឆ្នោតទូទាំងរដ្ឋដូចគ្នា វិធានការមួយ ឬច្រើនផ្សេងទៀតនោះត្រូវចាត់ទុកថាផ្ទុយគ្នាជាមួយវិធានការនេះ។ ក្នុងករណីដែលវិធានការផ្តួចផ្តើមនេះទទួលបានចំនួនសន្លឹកឆ្នោតគាំទ្រច្រើនជាង បទប្បញ្ញត្តិនៃវិធានការនេះត្រូវមានអាទិភាពទាំងស្រុង ហើយបទប្បញ្ញត្តិនៃវិធានការមួយ ឬច្រើនផ្សេងទៀតត្រូវទុកជាមោឃៈ។

ផ្នែកទី 3. ការបកស្រាយយ៉ាងទូលំទូលាយ។

ច្បាប់នេះត្រូវបកស្រាយក្នុងន័យទូលំទូលាយ ដើម្បីឱ្យសម្រេចបាននូវចេតនា និងគោលបំណងរបស់វា។

ផ្នែកទី 4. ការការពារផ្នែកច្បាប់។

គោលបំណងនៃផ្នែកនេះគឺដើម្បីធានាថាសិទ្ធិដ៏មានតម្លៃរបស់ប្រជាជនក្នុងការផ្តួចផ្តើមសំណើប្រជាមតិ មិនអាចត្រូវបានលុបចោលដោយមិនត្រឹមត្រូវដោយអ្នកនយោបាយរដ្ឋដែលបដិសេធមិនការពារឆន្ទៈរបស់អ្នកបោះឆ្នោតឡើយ។ ដូច្នេះ ប្រសិនបើច្បាប់នេះត្រូវបានអ្នកបោះឆ្នោតនៃរដ្ឋ California អនុម័ត ហើយក្រោយមកត្រូវបានដាក់ពាក្យបណ្តឹងផ្លូវច្បាប់ដែលព្យាយាមកំណត់វិសាលភាព ឬការអនុវត្តច្បាប់នេះតាមវិធីណាមួយ ឬចោទថាច្បាប់នេះបំពានច្បាប់រដ្ឋ ឬសហព័ន្ធណាមួយទាំងស្រុង ឬមួយផ្នែក ហើយទាំងអភិបាលរដ្ឋ និងអគ្គរដ្ឋអាជ្ញាបដិសេធមិនការពារច្បាប់នេះឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន ក្នុងនាមរដ្ឋ California នោះត្រូវចាត់វិធានការដូចខាងក្រោម៖

(a) ទោះបីមានបទប្បញ្ញត្តិណាមួយផ្ទុយពីនេះដែលមានចែងក្នុងជំពូកទី 6 (ចាប់ផ្តើមជាមួយផ្នែកទី 12500) នៃភាគទី 2 នៃផ្នែកទី 3 នៃចំណងជើងទី 2 នៃក្រមរដ្ឋាភិបាល ឬច្បាប់ផ្សេងទៀតក៏ដោយ អគ្គរដ្ឋអាជ្ញាត្រូវតែងតាំងទីប្រឹក្សាច្បាប់ឯករាជ្យ ដើម្បីការពារច្បាប់នេះដោយស្មោះត្រង់ និងយ៉ាងម៉ឺងម៉ាត់ ឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន ក្នុងនាមរដ្ឋ California។

(b) មុនពេលតែងតាំង ឬជំនួសទីប្រឹក្សាឯករាជ្យ អគ្គរដ្ឋអាជ្ញាត្រូវអនុវត្តការប្រុងប្រយ័ត្នត្រឹមត្រូវក្នុងការកំណត់គុណវុឌ្ឍិរបស់ទីប្រឹក្សាឯករាជ្យ និងត្រូវទទួលបានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីទីប្រឹក្សាឯករាជ្យថាទីប្រឹក្សាឯករាជ្យនឹងការពារច្បាប់នេះដោយស្មោះត្រង់ និងម៉ឺងម៉ាត់ឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន។ ការបញ្ជាក់ជាលាយលក្ខណ៍អក្សរត្រូវដាក់ឱ្យសាធារណជនអាចទទួលបានភ្លាមៗតាមការស្នើសុំ។

(c) ដើម្បីគាំទ្រដល់ការការពារច្បាប់នេះ ក្នុងករណីដែលអភិបាលរដ្ឋ និងអគ្គរដ្ឋអាជ្ញាខកខានមិនការពារ បើទោះបីជាមានឆន្ទៈរបស់អ្នកបោះឆ្នោតក៏ដោយ ការអនុម័តថវិកាបន្តត្រូវបានធ្វើឡើងតាមនេះពីមូលនិធិទូទៅទៅឱ្យអ្នកគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋ ដោយមិនគិតពីឆ្នាំសារពើពន្ធ ក្នុងចំនួនទឹកប្រាក់ចាំបាច់ដើម្បីរាប់រងថ្លៃចំណាយនៃការជួលទីប្រឹក្សាច្បាប់ឯករាជ្យ ដើម្បីការពារច្បាប់នេះដោយស្មោះត្រង់ និងយ៉ាងម៉ឺងម៉ាត់ ក្នុងនាមរដ្ឋ California ឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន។